ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កិច្ចតែងការបង្រៀន

# គណិតវិទ្យា

## ថ្នាក់ទី ១២



ស្របតាមកម្មវិធីសិក្សាថ្មី

វិទ្យាស្ថានជាតិអប់រំ

# គណិតវិទ្យា

## កិច្ចតែងការបង្រៀន

## ថ្នាក់ទី ១២


រៀបរៀងដោយ ៖

*គរុនិស្សិតក្រុម២ ឯកទេស គណិតវិទ្យា-រូបវិទ្យា ជំនាន់ទី ១៧*

ណែនាំដោយសាស្ត្រាចារ្យ ៖

**ថៃ ហេង , ម៉ែន ខាំង , ចាន់ វ៉ាដា , លឹម បូណា , ផាន់ សុភាព**



ភ្នំពេញ , មិថុនា ២០១២ , ព្រះរាជាណាចក្រកម្ពុជា

ត្រូវនឹងខែ បឋមសាឍ ឆ្នាំ រោង ព.ស. ២៥៥៦



**រក្សាសិទ្ធិ** **ហាមថតចម្លងសៀវភៅនេះ**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

## បញ្ជីបែងចែកភារកិច្ច និងការទទួលខុសត្រូវលើកិច្ចតែងការបង្រៀន
## របស់គរុនិស្សិតកម្រិតឧត្តម ( បរិញ្ញា+១ ) ជំនាន់ទី១៧
## ឯកទេស ៖ គណិតវិទ្យា-រូបវិទ្យា ( ក្រុម២ )

| ល.រ. | គោត្តនាម-នាម | | ភេទ | ក្របខណ្ឌខេត្ត | ទទួលលើ |
|---|---|---|---|---|---|
| ១ | នីម | លេងហេង | ប្រុស | តាកែវ | មាឌសូលីត និងប្រវែងធ្នូ |
| ២ | ប៉ែត | ឡោ | ប្រុស | តាកែវ | ភាពចែកដាច់ និងវិធីចែកអឺគ្លីត |
| ៣ | ប៉ែន | ផេត | ប្រុស | តាកែវ | បំណែងចែកប្រូបាប |
| ៤ | ម៉ាន់ | សួង | ប្រុស | តាកែវ | ប្រូបាបមានលក្ខខណ្ឌ |
| ៥ | លាក់ | ធក | ប្រុស | តាកែវ | លីមីតនៃអនុគមន៍ |
| ៦ | លឹម | វង្សា | ប្រុស | តាកែវ | សមីការប៉ារ៉ាម៉ែត និងកូអរដោនេប៉ូលែ |
| ៧ | រ៉ាន់ | ជី | ប្រុស | តាកែវ | អេលីប |
| ៨ | ស៊ិន | គឹមសេង | ប្រុស | តាកែវ | បំនួនបឋម |
| ៩ | ហៃ | ប៉ាហ៊ិន | ប្រុស | តាកែវ | ពហុគុណរួម និងតួចែករួម |
| ១០ | ឌុន | វណ្ណា | ស្រី | កំពត | អនុគមន៍អសនិទាន |
| ១១ | នួន | ភេទ | ប្រុស | កំពត | បំណែងចែកនរម៉ាល់ |
| ១២ | ស៊ុត | ចាន់និមល | ប្រុស | កំពត | អនុវត្តន៍ដេរីវេ ( កម្រិតខ្ពស់ ) |
| ១៣ | ស៊ូ | លីន | ស្រី | កំពត | ផលគុណនៃពីរវ៉ិចទ័រ |
| ១៤ | សួង | ចិល | ប្រុស | កំពត | សមីការឌីផេរ៉ង់ស្យែលលំដាប់១ |
| ១៥ | កៃ | ជីប | ប្រុស | កំពង់ឆ្នាំង | អនុវត្តន៍ផលគុណនៃពីរវ៉ិចទ័រ |
| ១៦ | ឈន | ភារម្យ | ប្រុស | កំពង់ឆ្នាំង | អនុគមន៍ត្រីកោណមាត្របម្រុះ |
| ១៧ | យ៉ែម | សុជាន្នី | ប្រុស | កំពង់ឆ្នាំង | អាំងតេក្រាលកំណត់ |
| ១៨ | ស៊ី | វណ្ណា | ប្រុស | កំពង់ឆ្នាំង | សមីការឌីផេរ៉ង់ស្យែលលំដាប់២ |
| ១៩ | ឱ | គុជ្ជា | ប្រុស | កំពង់ឆ្នាំង | សមីការតម្រែតម្រង់លីនេអ៊ែរ |
| ២០ | គង់ | របេតា | ស្រី | កំពង់ធំ | លីមីតស្វីត |
| ២១ | ប៊ិត | សម្បត្តិ | ប្រុស | កំពង់ធំ | ភាពជាប់នៃអនុគមន៍ |
| ២២ | មាន | សុខជា | ប្រុស | កំពង់ធំ | អនុគមន៍សនិទាន |
| ២៣ | សេង | គុងស៊ាំង | ប្រុស | កំពង់ធំ | ស្ថិតិនៃពីរអថេរ |
| ២៤ | ហេង | ដារា | ប្រុស | កំពង់ធំ | បំណែងចែកទ្វេធា |
| ២៥ | ផុក | ម៉េង | ប្រុស | កំពង់ស្ពឺ | អនុវត្តន៍ដេរីវេ ( កម្រិតមូលដ្ឋាន ) |

**អារម្ភកថា**

សៀវភៅកិច្ចតែងការបង្រៀនគណិតវិទ្យាថ្នាក់ទី១២ ទាំងពីរកម្រិត ដែលមិត្តអ្នកអាន កំពុងតែអាននេះ បានកើតមានឡើងក្រោមគំនិតផ្តួចផ្តើមរបស់សាស្ត្រាចារ្យគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ (N.I.E.)ជាពិសេសគឺលោកសាស្ត្រាចារ្យ ថៃ ហេង ។

នាដើមឆ្នាំសិក្សា លោកគ្រូ ថៃ ហេង បានហៅតំណាងគរុនិស្សិតគណិតវិទ្យា-រូបវិទ្យា ទាំងប្រាំក្រុម( ក្នុងមួយក្រុមយកតំណាងម្នាក់ ) មកធ្វើការចាប់យកលេខ ១ ដល់ លេខ៥ ដោយចៃដន្យ ។ តំណាងក្រុម២ របស់យើងខ្ញុំចាប់បានលេខ ៥ដែលត្រូវចាប់យកថ្នាក់ក្រោយគេសម្រាប់ការសរសេរកិច្ចតែងការបង្រៀនគណិតវិទ្យាពីថ្នាក់ទី ៧ ដល់ទី១២ (លើកលែងទី១១ ព្រោះមានស្រាប់) , ចៃដន្យអី តំណាងក្រុមផ្សេងៗចាប់យកអស់ សល់មួយសន្លឹកសម្រាប់ក្រុមយើង គឺសល់ថ្នាក់ទី១២ នេះតែម្តង, ដោយមើលឃើញថា កិច្ចតែងការថ្នាក់ទី១២ មានសល់ពីឆ្នាំមុនខ្លះៗទៅហើយ តំណាងក្រុមយើងខ្ញុំក៏បែងចែកមេរៀនមួយចំនួនដែលមិនមានពីឆ្នាំមុន បានមួយមេរៀនក្នុងគរុនិស្សិតម្នាក់ គ្រប់ៗគ្នា ។ នៅក្នុងនាទីនេះ រាល់មេរៀនដែលយើងខ្ញុំមិនបានយកមកបញ្ចូលគឺមានន័យថា យើងខ្ញុំមានរួចរាល់ទៅហើយ ដែលបន្សល់ទុកដោយគរុនិស្សិតជំនាន់មុន ។

សៀវភៅកិច្ចតែងការនេះមិនមានលក្ខណៈល្អឥតខ្ចោះនោះទេ ព្រោះម្នាក់ៗមានចំណេះដឹងខុសៗគ្នា ហើយមិនបានពិនិត្យឲ្យបានល្អិតល្អន់ទៀត ។ ឯកសារនេះគឺគ្រាន់តែជាឯកសារយោងសម្រាប់មិត្តអ្នកសិក្សាតែប៉ុណ្ណោះ ។

កិច្ចតែងការមិនមែនមានតែទម្រង់ណាមួយឲ្យដាច់ខាតនោះឡើយ តែវាអាចឲ្យយើងរចនាតាមបែបផ្សេងៗ គ្នា ។ កិច្ចតែងការគ្រាន់តែជាការត្រៀមគំនិតសម្រាប់បង្រៀនតែប៉ុណ្ណោះ វាមិនមែនត្រូវតែបង្រៀនតាមកិច្ចតែងការទាំងស្រុងនោះឡើយ ។ ការបង្រៀនគឺតាមស្ថានភាពជាក់ស្តែង ។ លំហាត់គណិតវិទ្យាមួយមិនមែនមានវិធីសាស្ត្រដោះស្រាយតែមួយបែបនោះទេ គឺអាចមានរបៀបដោះស្រាយច្រើនខុសៗគ្នា , មានលំហាត់មួយចំនួនទៀតធ្វើផ្សេងគ្នា ឃើញចម្លើយផ្សេងគ្នា តែត្រឹមត្រូវដូចគ្នា ។ ឧទាហរណ៍ ៖ សមីការបន្ទាត់ក្នុងលំហដែលកាត់តាមចំណុច $A(1,2,3)$ និង $B(0,4,2)$ គឺ ៖

$AB:\begin{cases}x=1-t\\y=2+2t\\z=3-t\end{cases},\ t\in\mathbb{R}$ ឬ $AB:\begin{cases}x=0+t\\y=4-2t\\z=2+t\end{cases},\ t\in\mathbb{R}$ (ចម្លើយត្រូវដូចគ្នា) ។

សូមអរគុណ និងសូមគោរពជូនពរមិត្តអ្នកអានឲ្យទទួលបានតែសេចក្តីសុខគ្រប់គ្នា ។ សូមឲ្យអ្នកបង្រៀនទាំងអស់ខំប្រឹង កុំទម្លាក់ដៃ ដើម្បីកុំឲ្យយុវជនជំនាន់ក្រោយៗល្ងង់ ព្រោះពួកគេជាសន្លឹកបៀដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ។

*តំណាងអ្នករៀបរៀង*

# បញ្ជីអត្ថបទ

*គណិតវិទ្យាថ្នាក់ទី១២កម្រិតមូលដ្ឋាន* *ទំព័រ*


ជំពូក១ ៖ លីមីត ........ ១

មេរៀនទី១ ៖ លីមីតនៃអនុគមន៍ ........ ១

មេរៀនទី២ ៖ ភាពជាប់នៃអនុគមន៍ ........ ១៣

ជំពូក២ ៖ ដេរីវេនៃអនុគមន៍ ........ ៤១

មេរៀនទី១ ៖ ដេរីវេនៃអនុគមន៍(ឯកសារគរុសិស្សជំនាន់មុន)........ ៤១

មេរៀនទី២ ៖ អនុវត្តន៍នៃដេរីវេ ........ ៦១

ជំពូក៣ ៖ សិក្សាអថេរភាព និងសង់ក្រាប ........ ៧១

មេរៀនទី១ ៖ អនុគមន៍សនិទាន ........ ៧១

មេរៀនទី២ ៖ អនុគមន៍អិចស្ប៉ូណង់ស្យែល (ឯកសារគរុសិស្សជំនាន់មុន)........ ៩៤

មេរៀនទី៣ ៖ អនុគមន៍លោការីត(ឯកសារគរុសិស្សជំនាន់មុន)........ ១០៨

ជំពូក៤ ៖ អាំងតេក្រាល ........ ១៣១

មេរៀនទី១ ៖ ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់ (ឯកសារគរុសិស្សជំនាន់មុន) ១៣១

មេរៀនទី២ ៖ អាំងតេក្រាលកំណត់ (ឯកសារគរុសិស្សជំនាន់មុន)........ ១៥១

ជំពូក៥ ៖ ស្ថិតិពីរអថេរ ........ ១៦៤

មេរៀនទី១ ៖ ស្ថិតិមានពីរអថេរ ........ ១៦៤

មេរៀនទី២ ៖ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ ........ ១៨១

ជំពូក៦ ៖ កោនិក ........ ១៩៤

មេរៀនទី១ ៖ ប៉ារ៉ាបូល (ឯកសារគរុសិស្សជំនាន់មុន)........ ១៩៤

មេរៀនទី២ ៖ អេលីប (ឯកសារគរុសិស្សជំនាន់មុន)........ ២១៥

មេរៀនទី៣ ៖ អ៊ីពែបូល (ឯកសារគរុសិស្សជំនាន់មុន)........ ២៣១


*គណិតវិទ្យាថ្នាក់ទី១២កម្រិតខ្ពស់*


ជំពូក១ ៖ លីមីតនៃស្វ៊ីត ........ ២៤១

មេរៀនទី១ ៖ លីមីតនៃស្វ៊ីត ........ ២៤១

ជំពូក២ ៖ ដេរីវេនៃអនុគមន៍ ........ ២៦១

មេរៀនទី១ ៖ អនុវត្តន៍ដេរីវេ ........ ២៦១

ជំពូក៣ ៖ អថេរភាព និងក្រាបនៃអនុគមន៍ ........ ២៧៦

មេរៀនទី១ ៖ អនុវត្តន៍អសនិទាន ........ ២៧៦

មេរៀនទី២ ៖ អនុវត្តន៍ត្រីកោណមាត្របម្រុះ ...... ២៩៨
ជំពូក៤ ៖ អាំងតេក្រាលកំណត់ ...... ៣១២
មេរៀនទី១ ៖ អាំងតេក្រាលកំណត់ ...... ៣១២
មេរៀនទី២ ៖ មាឌសូលីត និងប្រវែងធ្នូ ...... ៣២៤
ជំពូក៥ ៖ សមីការឌីផេរ៉ង់ស្យែល ...... ៣៣៧
មេរៀនទី១ ៖ សមីការឌីផេរ៉ង់ស្យែលលំដាប់១ ...... ៣៣៧
មេរៀនទី២ ៖ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់២ ...... ៣៦៣
ជំពូក៦ ៖ បំណែងចែកប្រូបាប ...... ៣៩៥
មេរៀនទី១ ៖ បំណែងចែកប្រូបាប ...... ៣៩៥
មេរៀនទី២ ៖ បំណែងចែកទ្វេធា ...... ៤០២
មេរៀនទី៣ ៖ បំណែងចែកណរម៉ាល់ ...... ៤១៧
ជំពូក៧ ៖ វ៉ិចទ័រក្នុងលំហ ...... ៤២៦
មេរៀនទី១ ៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ ...... ៤២៦
មេរៀនទី២ ៖ អនុវត្តន៍នៃផលគុណវ៉ិចទ័រ ...... ៤៥០
ជំពូក៨ ៖ ភាពចែកដាច់ និងវិធីចែកអឺគ្លីត ...... ៤៥៦
មេរៀនទី១ ៖ ភាពចែកដាច់ និងវិធីចែកអឺគ្លីត ...... ៤៥៦
មេរៀនទី២ ៖ បំនួនបឋម ...... ៤៦៣
មេរៀនទី៣ ៖ តួចែករួម និងពហុគុណរួម ...... ៤៧០
ជំពូក៩ ៖ សមីការប៉ារ៉ាម៉ែត និងកូអរដោនេប៉ូលែ ...... ៤៨៥
មេរៀនទី១ ៖ សមីការប៉ារ៉ាម៉ែត និងកូអរដោនេប៉ូលែ ...... ៤៨៥
*គណិតវិទ្យាថ្នាក់ទី១២(យកពីទី១១)*
មេរៀនទី១ ៖ ប្រូបាប ...... ៤៩៥
មេរៀនទី២ ៖ ប្រូបាបមានលក្ខខណ្ឌ ...... ៥២៤

# កិច្ចតែងការបង្រៀន

## បង្រៀនគណិតវិទ្យា

## ជំពូកទី ១ : លីមីត

## មេរៀនទី ១ : លីមីតនៃអនុគមន៍

I **លីមីតនៃអនុគមន៍ត្រង់ចំនួនកំណត់ និង អនន្ត**

1. **លីមីតនៃអនុគមន៍ត្រង់ចំនួនកំណត់**
2. **លីមីតនៃអនុគមន៍ត្រង់ អនន្ត**
3. **ប្រមាណវិធីលើលីមីត**

II **លីមីតនៃអនុគមន៍អសនិទាន**

## I វត្ថុបំណង

**ចំណេះដឹង:** សិស្សរៀបរាប់និយមន័យលីមីតនៃអនុគមន៍ត្រងចំនួនកំណត់ និងត្រង់អនន្តបានត្រឹមត្រូវតាមរយ:ខ្លឹមសារមេរៀន។

**ចំណិន:** សិស្សអាចគណនាលីមីតនៃអនុគមន៍ត្រង់ចំនួនកំណត់ត្រង់អនន្ត និងកំណត់ប្រមាណវិធីលើលីមីតបានត្រឹមត្រូវតាមរយ:ឧទាហរណ៍។

**ឥរិយាបថ:**សិស្សមានស្មារតីប្រុងប្រយត្ន័ក្នុងការដោះស្រាយលំហាត់។

II **រយ:ពេល:** ០២ម៉ោង ថ្ងៃ ........ទី.......... ខែ ..... ឆ្នាំ ២០.......

III **សម្ភារឧបទេស** ស ស ទំព័រទី ០១ ០៨ ។

ស គ ទំព័រទី ដល់ ។

បន្ទាត់ ប៉ារ៉ាបូល ។

IV **ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| - គ្រូគពិនិត្យ អវត្តមាន វិន័យ និង បរិស្ថាន | - ជំហានទី១ "រដ្ឋាបាលថ្នាក់" | - ប្រធានថ្នាក់ឡើងរាយការណ៍ |

| | | |
|---|---|---|
| - គ្រូសួរសំនួរ<br>បើ x ខិតជិត a ហើយ<br>អនុគមន៍y=f(x) ខិតជិតb នោះគេ<br>កំណត់បានលីមីតដូចម្តេច? | -ជំហានទី២ "រំលឹកមេរៀន"<br>$\lim_{x\to a} f(x) = b$ | -សិស្សស្តាប់ និង ឆ្លើយ<br>-កំណត់បាន<br>$\lim_{x\to a} f(x) = b$ ។ |
| - គ្រូសរសេរចំណងជើងមេរៀន<br>- គ្រូឲ្យសិស្សកំណត់និយមន័យ លីមីតនៃអនុគមន៍ត្រង់ចំនួន កំណត់<br><br>-គ្រូឲ្យសិស្សដោះស្រាយលំហាត់<br>Ex1: គេមាន f(x)=5x+2 ។<br>គេដឹងថា $\lim_{x\to -2} f(x) = 8$ ;<br>រកចំនួន$\alpha > 0$ដោយស្គាល់<br>$\varepsilon = 0.002$ដែល 0< \|x+2\|<α<br>នាំឲ្យ \| f(x)-(-8)\| <ε។<br>$E_{x2}$: អនុគមន៍ f កំណត់ដោយ<br>F(x)=$\frac{2x+1}{x-1}$ ។ បង្ហាញថា<br>$\lim_{x\to 1^+} f(x) = +\infty$ ។<br><br>-គ្រូឲ្យសិស្សកំណត់និយមន័យ លីមីតនៃអនុគមន៍នៅត្រង់ អនន្ត | ជំហានទី៣ " មេរៀនប្រចាំថ្ងៃ"<br>1.លីមីតនៃអនុគមន៍ត្រង់ចំនួនកំណត់<br>* និយមន័យ: អនុគមន៍ f មានលិមីត L កាលណា xខិតជិត a បើ ∀ε>0 មានចំនួន δ>0 ដែល0<\|x-a\|< δនាំឲ្យ<br>\| f(x)- L \| <ε<br>គេសរសេរ: $\lim_{x\to a} f(x) = L$ ។<br><br>* និយមន័យ: គេថាអនុគមន៍ f ខិតជិត a ចំពោះ∀ $M > 0$មាន $\delta > 0$<br>ដែល0< \| x-a \| <δ នាំអោយ<br>f(x)>0ឬ f(x) < - M ។ គេសរសេរ<br>$\lim_{x\to a} f(x) = +\infty$<br>ឬ $\lim_{x\to a} f(x) = -\infty$<br>ចម្លើយ $E_{x1}$:\| f(x)-(-8) \| <0.002<br>នោះ \| 5x+2+8 \| < 0.002<br>\| 5x + 10 \| < 0.002<br>5 \| x+2 \| < 0.002<br>=> \| x+2 \| <$\frac{0.002}{5} = 0.0004 = \alpha$<br>ដូចនេះ α= 0.0004 ។<br>ចម្លើយ$E_{x2}$: មាន f(x)=$\frac{2x+1}{x-1}$<br>= 2+ $\frac{3}{x-1}$<br>កំណត់ចំនួន M>0ដែល f(x)>M<br>យើងគ្រាន់តែឲ្យ$\frac{3}{x-1}$>Mឬ<br>0< x -1 < $\frac{3}{M}$នោះ$\alpha = \frac{3}{M} > 0$ ដែល | -សិស្សកត់<br>-សិស្សកំណត់បាន<br>និយមន័យ<br><br>សិស្សដោះស្រាយលំ ហាត់ដោយខ្លួនឯង ។<br><br>- សិស្សកំណត់និមន័យ បានច្បាស់លាស់ ។ |

| | | |
|---|---|---|
| - គ្រូឲ្យសិស្សដោះស្រាយលំហាត់<br>$E_x$: គេមានអនុគមន៍ f ដែល $f(x)=\frac{4x+1}{2x+1}$ ។<br>បង្ហាញថា $\lim_{x\to+\infty} f(x) = 2$<br>និង $\lim_{x\to-\infty} f(x) = 2$<br><br>-គ្រូឲ្យសរសេរប្រមាណវិធីលើលីមីត<br><br>-គ្រូដាក់លំហាត់ឲ្យសិស្សដោះស្រាយ<br>$E_x$: កំណត់តំលៃ a,b ដែល | ដែល 0< I x+1 I <α នាំឲ្យ<br>f(x)>M ដូចនេះ $\lim_{x\to1^+} f(x) = +\infty$ ។<br>2. លីមីតនៃអនុគមន៍នៅត្រង់អនន្ត:<br>-និយមន័យ: អនុគមន៍ f មានលីមីត L កាលណា x ខិតជិត$+\infty$ ឬ$-\infty$<br>គេបាន$\forall\ \varepsilon > 0$ មាន N>0 ដែល x>N ឬ x < -N នាំឲ្យ I f(x)-L I <ε ។<br>គេសរសេរ$\lim_{x\to+\infty} f(x) = L$ឬ $\lim_{x\to-\infty} f(x) = L$ ។<br>- និយមន័យ:<br>+ អនុគមន៍ f មានលីមីត$+\infty$កាលណា X ខិតទៅ$+\infty$ចំពោះ $\forall$ M>0 មានN>0 ដែលx>Nនាំឲ្យ f(x)>M ។<br>គេសរសេរ: $\lim_{x\to+\infty} f(x) = +\infty$<br>+ អនុគមន៍ f មានលីមីត$+\infty$កាលណា X ខិតទៅ$-\infty$ចំពោះ $\forall$ M>0 មានN>0 ដែលx< - N នាំឲ្យ f(x)>M ។<br>គេសរសេរ: $\lim_{x\to-\infty} f(x) = +\infty$ ។<br>ចម្លើយ $E_x$: គេបាន f<br>$F(x) - 2 = \frac{4x+1}{2x+1} - 2 = \frac{-1}{2x+1}; x \neq -\frac{1}{2}$<br>នាំឲ្យ I f(x)-2 I $= \frac{1}{I\ 2x+1}$<ε<br>នោះ I 2x+1 I > $\frac{1}{\varepsilon}$ ឬ<br>$\begin{cases} 2x+1 > \frac{1}{\varepsilon} \\ 2x+1 < -\frac{1}{\varepsilon} \end{cases}$ ឬ $\begin{cases} x > \frac{1}{2\varepsilon} - \frac{1}{2} \\ x < -\frac{1}{2\varepsilon} - \frac{1}{2} \end{cases}$<br>ឬ$\begin{cases} x > \frac{1}{2\varepsilon} \\ x < -\left(\frac{1}{2\varepsilon} + \frac{1}{2}\right) \end{cases}$<br>គេបាន$\forall\varepsilon > 0$មាន$A = \frac{1}{2\varepsilon} > 0$ ឬ<br>$A=\frac{1}{2\varepsilon} + \frac{1}{2}$ដែល $x > A$ឬ x<-A | សិស្សឡើងដោះស្រាយលំហាត់<br><br>សិស្សអនុវត្តន៍តាមការណែនាំពីគ្រូ<br><br>សិស្សដោះស្រាយលំ |

| | | |
|---|---|---|
| បំពេញលក្ខខណ្ឌ<br>$\lim_{x\to-2}\frac{x^2+ax-6}{2x^2+3x-2}=b$ ។ | នាំឲ្យ $\lvert f(x)-2\rvert<\varepsilon$ ។<br>ដូចនេះ $\lim_{x\to+\infty} f(x)=2$ និង<br>$\lim_{x\to-\infty} f(x)=2$ ។<br>3. ប្រមាណវិធីលើលីមីត<br>បើ $\lim_{x\to a} f(x)=L; \lim_{x\to a} g(x)=M$<br>និង $\lim_{x\to a} h(x)=N; N; M; L\epsilon R$<br>គេបាន:<br>ក) $\lim_{x\to a}[f(x)\pm g(x)]=L\pm M$<br>ខ) $\lim_{x\to a} f(x)+g(x)-h(x)]=L+M-N$<br>គ) $\lim_{x\to a} Kf(x)=KL; K$ ចំនួនថេរ<br>ឃ) $\lim_{x\to a}[f(x).g(x).h(x)]=L.M.N$<br>ង) $\lim_{x\to a}\frac{f(x)}{g(x)}=\frac{\lim_{x\to a} f(x)}{\lim_{x\to a} g(x)}=\frac{L}{M}; M\neq 0; g(x)\neq 0$<br>ច) $\lim_{x\to a}[f(x)]^n=L^n; n$ ចំនួនគត់វិឡាទីប<br><u>ចំលើយ:</u><br>ដោយ $\lim_{x\to-2} 2x^2+3x-2=0$<br>=> $\lim_{x\to-2}\ x^2\ ax-6=0$<br>គេបាន<br>$\lim_{x\to-2} x^2+ax-6=4-2a-6=0$<br>$=-2a=2$<br>=>a= - 1<br>ដូចនេះ: $\lim_{x\to-2}\frac{x^2+ax-6}{2x^2+3x-2}=b$<br>$\lim_{x\to-2}\frac{x^2+ax-6}{(2x-1)(x+2)}=b$<br>=>b=1<br>លីមីតនៃអនុគមន៍អសនិទាន:<br>«ជាទូទៅ:<br>$\lim_{x\to a}\sqrt[n]{x}=\sqrt[n]{a}; a\geq 0; n\epsilon N; n\geq 2$<br>$\lim_{x\to a}\sqrt[n]{x}=\sqrt[n]{a}\ a<0; n$ សេស<br>$\lim_{x\to a}\sqrt[n]{x}=\sqrt[n]{f(x)}\sqrt[n]{\lim_{x\to a} f(x)}=\sqrt[n]{L}=L^{1/n}$ | ហាត់ |
| - អោយសិស្សលក្ខណ:ទូទៅលីមីតនៃអនុគមន៍អសនិទាន<br><br>-គ្រូដាក់លំហាត់ឲ្យសិស្សដោះ | ចំលើយ $\lim_{x\to 4}\sqrt[3]{\frac{x^2-3x+4}{2x^2-x-1}}$ | - សិស្សកំណត់បាន<br>លក្ខណ:ទូទៅនៃលីមី<br>តអនុ<br>គមន៍អសនិទាន |

| | | |
|---|---|---|
| ស្រាយ:<br>គណនា$\lim_{x\to 4}\sqrt[3]{\frac{x^2-3x+4}{2x^2-x-1}}$<br><br>- គ្រូដាក់លំហាតើឲ្យសិស្សដោះស្រាយ<br>គណនា$\lim_{x\to 1}\frac{x^2-1}{x^2-3x+2}$<br><br>-ពេលប្អូនៗទៅផ្ទះវិញធ្វើលំហាត់និងើលមេរៀនបន្តទៀត | $=\sqrt[3]{\lim_{x\to 4}\frac{x^2-3x+4}{2x^2-x-1}}$<br>$=\sqrt[3]{.\frac{4^2-12+6}{2.4^2-4-1}}$<br>$=\sqrt[3]{\frac{10}{27}}=\frac{\sqrt[3]{10}}{3}$ ។<br><br>ជំហ៊ានទី៤″ពង្រឹងពុទ្ធិ″<br>$=\lim_{x\to 1}\frac{x^2-1}{x^2-3x+2}$<br>$=\lim_{x\to 1}\frac{(x-1)(x+1)}{(x-1)(x-2)}$ ; $x\neq 1$<br>= -2<br>ជំហ៊ានទិ៥ ‘បណ្តាំផ្ញើរ’ | -សិស្សដោះស្រាយលំហាត់<br><br>-សិស្សស្តាប់តាមការណែនាំយ៉ាសខ្ជាប់ខ្ជួន |

# កិច្ចតែងការបង្រៀន

- ❖ **បង្រៀនគណិតវិទ្យាថ្នាក់ទី១២**
- ❖ **ជំពូកទី១ លីមីត**
- ❖ **មេរៀនទី១ លីមីតនៃអនុគមន៍(ត)**

## III លីមីតនៃអនុគមន៍បណ្ដាក់

១.អនុគមន៍បណ្ដាក់

២.លីមីតនៃអនុគមន៍បណ្ដាក់

៣.លីមីតតាមការប្រៀបធៀប

## VI លីមីតរាងមិនកំណត់:

១.លីមីតមានរាងមិនកំណត់ $\frac{0}{0}$

២.លីមីតមានរាងមិនកំណត់ $\frac{\infty}{\infty}$

៣.លីមីតមានរាងមិនកំណត់ $+\infty-\infty$

## I វត្ថុបំណង:

- ចំណេះដឹង: សិស្សកំណត់និយមន័យលីមីតនៃអនុគមន៍បណ្ដាក់និងលីមីតនៃអនុគមន៍ រាងមិនកំណត់បានត្រឹមត្រូវតាមរយ:ខ្លឹមសារនៃមេរៀន។
- បំនិន: សិស្សដោះស្រាយលំហាត់លីមីតនៃអនុគមន៍បណ្ដាក់និងលីមីតមានរាងមិនកំណត់បានច្បាស់លាស់តាមរយ:ឧទាហរណ៍។
- ឥរិយាបថ: សិស្សចូលចិត្តដោះស្រាយលំហាត់ ។

## II រយ:ពេល: 0២ ម៉ោង ថ្ងៃ............ទី..........ខែ.......ឆ្នាំ.......

## III សម្ភារឧបទេស: បន្ទាត់

## IV ដំនើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| • គ្រូត្រួតពិនិត្យវត្តមាន វិន័យ | ជំហានទី១"រដ្ឋបាលថ្នាក់" | • ប្រធានថ្នាក់ឡើង |

| | | |
|---|---|---|
| និងបរិស្ថាន | | វាយការណ៍ |
| • គ្រូដាក់លំហាត់ឱ្យសិស្ស<br>ដោះស្រាយ:<br>$Ex$.កំណត់តម្លៃ $a$ ដើម្បីឱ្យ<br>លីមីត $\lim_{x\to1}\frac{\sqrt{x+3}-a}{x-1}$<br>ជាចំនួនថេរ ។ | ជំហានទី២“រំលឹកមេរៀន”<br>ចម្លើយ: ដោយ $x-1=0$<br>$\Rightarrow \lim_{x\to1}\sqrt{x+3}-a=0$<br>$\lim_{x\to1}\sqrt{x+3}-a=2-a=0$<br>$\Rightarrow a=2$ | • សិស្សដោះស្រាយ<br>លំហាត់ |
| • គ្រូសរសេរចំណងជើងមេ<br>រៀនលើក្តារខៀន:<br>• គ្រូឱ្យសិស្សកំណត់:<br>លក្ខណៈទូទៅនៃអនុគមន៍<br>បណ្តាក់<br>• គ្រូឱ្យសិស្សដោះស្រាយ<br>លំហាត់:<br>$Ex$:គេមាន<br>$f(x)=3x+1$និង<br>$g(x)=x^2$ ។គណនា<br>$fog(x)$ និង $gof(x)$<br>• គ្រូឱ្យសិស្សលក្ខណៈទូទៅ<br>នៃលីមីតអនុគមន៍បណ្តាក់:<br>• គ្រូដាក់លំហាត់ឱ្យសិស្ស<br>ដោះស្រាយ:<br>$Ex$:គណនា<br>$\lim_{x\to-4}\sqrt[3]{3x+4}$<br><br>• គ្រូឱ្យសិស្សកំណត់លីមី<br>តតាម<br>រយៈការប្រៀបធៀប:<br><br>• គ្រូដាក់លំហាត់សិស្សដោះ<br>ស្រាយ: | ជំហានទី“មេរៀនប្រចាំថ្ងៃ”<br>១.អនុគមន៍បណ្តាក់:<br>ជាទូទៅ: $f$ និង $g$ ជាអនុគមន៍ពីរ។អនុគម<br>ន៍បណ្តាក់នៃ $f$ និង $g$ តាងដោយ $gof$ គឺជា<br>អនុគមន៍កំណត់:<br>$gof(x)=g\left[f(x)\right]$ ។<br>ចម្លើយ: យើងបាន:<br>$*\ fog(x)=f\left[g(x)\right]=f\left(x^2\right)=3x^2+1$<br>$*\ gof(x)=g\left[f(x)\right]=g(3x+1)=(3x+1)^2$<br>$=9x^2+6x+1$ ។<br>$*$ ជាទូទៅបើ $f$ និង $g$ ជាអនុគមន៍មាន<br>លីមីត $\lim_{x\to a}g(x)=L$ និង $\lim_{x\to L}f(x)=f(L)$<br>នោះ $\lim_{x\to a}f\left[g(x)\right]=f(L)$ ។<br>ចម្លើយ: ដោយ $\lim_{x\to-4}3x+4=-8$<br>ដូចនេះ $\lim_{x\to-4}\sqrt[3]{3x+4}=\lim_{x\to-8}\sqrt[3]{x}=\sqrt[3]{(-8)}=-2$<br>បើអនុគមន៍ $f$ និង $g$ មានចំនួនពិត $A$ ដែល<br>$\lim_{x\to+\infty}g(x)=+\infty$ និង $f(x)\geq g(x);\forall x\geq A$<br>នោះ $\lim_{x\to+\infty}f(x)=+\infty$ ។<br>ចម្លើយ: បើ $x\geq4; x.x\geq4.x; x^2\geq4x$<br>$\Rightarrow \begin{matrix} x\geq2\sqrt{x} \\ x-\sqrt{x}\geq\sqrt{x}\end{matrix}$<br>ដោយ $\lim_{x\to+\infty}\sqrt{x}=+\infty$<br>ដូចនេះ $\lim_{x\to+\infty}x-\sqrt{x}=+\infty$ ។ | • សិស្សកត់អនុគមន៍<br>បណ្តាក់ $f$ និង $g$<br>$gof$<br>$x \to f(x) \to$<br>$g\ \left[f(x)\right]$<br><br><br><br>• សិស្សឡើងដោះ<br>• សិស្សឡើងដោះ<br>ស្រាយលំហាត់<br><br>• សិស្សកំណត់បាន<br>លីមីតនៃអនុគមន៍<br>បណ្តាក់...<br><br>• សិស្សឡើដោះ<br>ស្រាយលំហាត់<br>• សិស្សអាចកំណត់<br>បាន<br><br>• សិស្សឡើងដោះ<br>ស្រាយលំហាត់ |

| | | |
|---|---|---|
| $Ex$ : គេមាន<br>$f(x)=x-\sqrt{x}$<br>ចំពោះ $x\geq 4$ ។<br>• គ្រូឱសិស្សបង្ហាញពីវិធានដោះស្រាយលីមីតរាងមិនកំណត់ $\frac{0}{0}$<br>• គ្រូដាក់លំហាត់សិស្សដោះស្រាយ:<br>$Ex$ : គណនា<br>$\lim\limits_{x\to-2}\frac{x^3+3x^2+2x}{x^2-x-6}$ | • វិធានដើម្បីគណនាលីមីតរាងមិនកំណត់ $\frac{0}{0}$ គេត្រូវបំបែកភាគយកនិងភាគបែងជាផលគុណកត្តាហើយសម្រួលបន្ទប់មកគណនាលីមីតថ្មី៕<br>ចម្លើយ:<br>$=\lim\limits_{x\to-2}\frac{x^3+3x^2+2x}{x^2-x-6}$<br>$=\lim\limits_{x\to-2}\frac{x\left(x^2+3x+2\right)}{(x+2)(x-3)}$<br>$=\lim\limits_{x\to-2}\frac{x(x+2)(x+1)}{(x+2)(x-3)};x\neq-2$<br>$=\lim\limits_{x\to-2}\frac{x(x+1)}{x-3}=-\frac{2}{5}$ | • សិស្សកំណត់លីមីតរាងមិនកំណត់ $\frac{0}{0}$<br>• សិស្សឡើងដោះស្រាយលំហាត់ |
| • គ្រូឱ្យសិស្សបង្ហាញពីវិធានដោះស្រាយលីមីតរាងមិនកំណត់ $\frac{\infty}{\infty}$<br>• គ្រូដាក់លំហាត់ឱ្យសិស្សដោះស្រាយ:<br>$Ex$ : គណនា<br>$\lim\limits_{x\to+\infty}\frac{4x^4-5x}{x^2-3x+1}$<br>• គ្រូឱ្យសិស្សកំណត់វិធានដោះស្រាយលីមីតរាងមិនកំណត់ $+\infty-\infty$ | • វិធានដើម្បីគណនាលីមីតរាងមិនកំណត់ $\frac{\infty}{\infty}$ គេត្រូវដាក់តួដែលមានដឺក្រេធំជាងគេនៃភាគយកនិងភាគបែងជាកត្តារួមសិនហើយសម្រួលចោលរួចគណនាលីមីតថ្មី។<br>ចម្លើយ:<br>$\lim\limits_{x\to+\infty}\frac{x^4-5x}{x^2+3x+1}$<br>$=\lim\limits_{x\to+\infty}\frac{x^4}{x^2}$<br>$=\lim\limits_{x\to+\infty}x^2=+\infty$ | • សិស្សបង្ហាញពីលីមីតរាងមិនកំណត់ $\frac{\infty}{\infty}$<br>• សិស្សឡើងដោះស្រាយលំហាត់<br>• សិស្សកំណត់លីមីតរាង $+\infty-\infty$<br>• សិស្សឡើងដោះស្រាយ<br>• |
| • គ្រូដាក់លំហាត់ឱ្យសិស្សដោះស្រាយ:<br>$Ex$ : $\lim\limits_{x\to+\infty}\left(\sqrt{x^2+2}-x^2+1\right)$ | • វិធានៈដើម្បីគណនាលីមីតរាង $+\infty-\infty$ គេត្រូវដាក់តួមានដឺក្រេធំជាងគេជាកត្តារួមរួចគណនាលីមីតនៃកន្សោមថ្មី ។<br>ចម្លើយ: គណនា | |

| | | |
|---|---|---|
| | $\lim_{x\to+\infty}\left(\sqrt{x^2+2}-x+1\right)$<br>$=\lim_{x\to+\infty}\frac{x^2+2-x^2+2x-1}{\sqrt{x^2+2}+x+1}$<br>$=\lim_{x\to+\infty}\frac{-2x+1}{\sqrt{x^2+2}+x+1}$<br>$=\lim_{x\to+\infty}\frac{x\left(-2+\frac{1}{x}\right)}{x\left(\sqrt{1+\frac{1}{x}}+1+\frac{1}{x}\right)}$<br>$=\frac{-2}{2}=-1$ | |
| • គ្រូដាក់លំហាត់ឱ្យសិស្សដោះស្រាយ:<br>$Ex$: គណនា<br>$\lim_{x\to+\infty}\left(\sqrt{x+\sqrt{x}}-\sqrt{x}\right)$ | ជំហានទី៤"ពង្រឹងពុទ្ធិ"<br>ចម្លើយ: គណនា<br>$=\lim_{x\to+\infty}\left(\sqrt{x+\sqrt{x}}-\sqrt{x}\right)$<br>$=\lim_{x\to+\infty}\frac{x+\sqrt{x}-x}{\sqrt{x+\sqrt{x}}+\sqrt{x}}$<br>$=\lim_{x\to+\infty}\frac{\sqrt{x}}{\sqrt{x+\sqrt{x}}+\sqrt{x}}$<br>$=\lim_{x\to+\infty}\frac{\sqrt{x}}{\sqrt{x}\left(1+\frac{1}{\sqrt{x}}+1\right)}$<br>$=\frac{1}{2}$ | • សិស្សឡើងដោះស្រាយ |
| • ពេលប្អូនទៅផ្ទះវិញមេរៀនបន្តនិងឧស្សាហ៍ដោះស្រាយលំហាត់ .......។ | ជំហានទី៥"បណ្តាំផ្ញើ" | • សិស្សស្តាប់តាមការណែនាំពីគ្រូ ។ |

# កិច្ចតែងការបង្រៀន

## ❖ បង្រៀនគណិតវិទ្យាថ្នាក់ទី១២

## ❖ ជំពូកទី១ លីមីត

## ❖ មេរៀនទី១ លីមីតនៃអនុគមន៍ (តចប់)

### V លីមីតនៃអនុគមន៍មិនពិជគណិត

១.លីមីតនៃអនុគមន៍ត្រីកោណមាត្រ

២.លីមីតនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

៣.លីមីតនៃអនុគមន៍លោការីតនេពៃ

### I វត្ថុបំណង:

- ចំណេះដឹង: សិស្សអាចរៀបរាប់ពីលក្ខណ:ទូទៅរបស់លីមីតនៃអនុគមន៍ត្រីកោណមាត្រអិចស្ប៉ូនិងលោការីតបានត្រឹមត្រូវតាមរយ:ខ្លឹមសារមេរៀន។
- បំណិន: សិស្សអាចដោះស្រាយលំហាត់លីមីតនៃអនុគមន៍ត្រីកោណមាត្រអិចស្ប៉ូនិងលោការីតបានច្បាស់លាស់តាមរយ:ឧទាហរណ៍។
- ឥរិយាបថ: សិស្សចូលចិត្តដោះស្រាយលំហាត់និងបានល្អត្រឹមត្រូវ។

### II រយ:ពេល: 0២ម៉ោង ថ្ងៃ..........ទី.......ខែ......ឆ្នាំ

### III សម្ភារ:ឧបទេស:

- បន្ទាត់ ដៃកឈាន..........។
- ស.សទំព័រទី16 ដល់ ទី22 ។
- ស.គ ទំព័រទី......ដល់........។

### IV ដំណើកនាំបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពសិស្ស |
|---|---|---|
| • គ្រូត្រួតពិនិត្យវត្តមាន វិន័យនិងបរិស្ថាន។ | ជំហានទី១"រដ្ឋបាលថ្នាក់" | • ប្រធានថ្នាក់ឡើងរាយការណ៍ |
| • ដាក់លំហាត់ឱ្យដោះស្រាយ:<br>$Ex$: កំណត់តម្លៃ $a$ ដើម្បីឱ្យ $\lim_{x\to 1}\frac{\sqrt{x+3}-a}{x-1}$ ជាចំនួនថេរ | ជំហានទី២"រំលឹកមេរៀន"<br>ចម្លើយ:ដោយ $\lim_{x\to 1} x-1=0$<br>$\Rightarrow \lim_{x\to}\sqrt{x+3}-a=0$<br>យើងបាន:<br>$\lim_{x\to 1}\sqrt{x+3}-a=2-a=0$<br>$\Rightarrow a=2$ | • សិស្សឡើងដោះស្រាយ |
| • គ្រូសរសេរចំណងជើង | ជំហានទី៣"មេរៀនប្រចាំថ្ងៃ" | • សិស្សកត់ |

| | | |
|---|---|---|
| មេរៀនលើក្តាខៀន<br>• គ្រូឱ្យសិស្សកំណត់លក្ខណៈទូទៅនិងទ្រឹស្តីបទលីមីតអនុគមន៍ត្រីកោណមាត្រ | ១.លីមីតអនុគមន៍ត្រីកោណមាត្រ<br>$*$ជាទូទៅ:បើ $a$ ជាចំនួនពិតក្នុងដែនកំណត់ គេបាន:<br>$\lim\limits_{x\to a}\sin x=\sin a,\lim\limits_{x\to a}\cos x=\cos a$<br>$\lim\limits_{x\to a}\tan x=\tan a$ ។ | • សិស្សកំណត់លក្ខណៈទូទៅនិងទ្រឹស្តីបទ: |
| • គ្រូដាក់លំហាត់ឱ្យសិស្សដោះស្រាយ:<br>$Ex_1$ : គណនន<br>$\lim\limits_{x\to0}\frac{\sqrt{1+x}-\sqrt{1-x}}{\sin 3x}$ | $*$ទ្រឹស្តីបទ:បើ $x$ ជារង្វាស់មុំឬធ្នូគិតជារ៉ាដ្យង់ គេបាន:<br>ក/. $\lim\limits_{x\to0}\frac{\sin x}{x}=1$ ខ/. $\lim\limits_{x\to0}\frac{1-\cos x}{x}=0$<br>ចម្លើយ: $Ex_1$ គណនា<br>$\lim\limits_{x\to0}\frac{1-\cos x}{x^2}=\lim\limits_{x\to0}\frac{2\sin^2\frac{x}{2}}{x^2}$<br>$=\lim\limits_{x\to0}\frac{1}{2}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2$<br>$=\frac{1}{2}$<br>ចម្លើយ: $Ex_2$ : គណនា<br>$\lim\limits_{x\to0}\frac{\sqrt{1+x}-\sqrt{1-x}}{\sin 3x}=\lim\limits_{x\to0}\frac{2x}{\sin 3x\left(\sqrt{1+x}+\sqrt{1-x}\right)}$<br>$\lim\limits_{x\to0}\frac{\frac{2}{3}}{\frac{\sin 3x}{3x}\left(\sqrt{1+x}+\sqrt{1-x}\right)}$<br>$=\frac{1}{3}$ | • សិស្សឡើងដោះស្រាយ<br><br>• សិស្ស.កំណត |
| • គ្រូឱ្យសិស្សកំណត់លីមីតនៃអនុគមន៍អិចស្ប៉ូណង់ស្យែលនិងលក្ខណៈ:<br>ទៅ: | ២.លីមីតនៃអនុគមន៍អិចស្ប៉ូណង់ស្យែល:<br>ក/. $\lim\limits_{x\to+\infty}e^x=+\infty$ ខ/. $\lim\limits_{x\to-\infty}e^x=0$<br>គ/. $\lim\limits_{x\to+\infty}\frac{e^x}{x}=+\infty$<br>ជាទូទៅ:បើ $n>0$ នោះ $\lim\limits_{x\to+\infty}\frac{e^x}{x}=+\infty$<br>$\lim\limits_{x\to+\infty}\frac{x^n}{e^x}=0$<br>ចម្លើយ: $Ex_1$ : គណនា | • សិស្សឡើងដោះស្រាយលំហាត់ |

| | | |
|---|---|---|
| • គ្រូឱ្យសិស្សកំណត់លក្ខណៈទូទៅនៃលីមីតនៃលីមីតលោការីតនេពែ:<br><br>• គ្រូដាក់លំហាត់ឱ្យសិស្សដោះស្រាយ<br>$Ex$: គណនា<br>$\lim\limits_{x\to+\infty}\ell nx(\ell nx+2x)$<br>$Ex$: គណនា $\lim\limits_{x\to+\infty}\left(\dfrac{\ell nx}{x^2+x}\right)$ | $\lim\limits_{x\to+\infty}\left(x^3+x\right)e^{-x}=\lim\limits_{x\to+\infty}x^3e^{-x}\left(1+\dfrac{1}{x^2}\right)$<br>$=\lim\limits_{x\to+\infty}\dfrac{x^3}{e^x}=0$ ។<br>៣.លីមីតនៃអនុគមន៍លោការីតនេពែ:<br>ក/. $\lim\limits_{x\to+\infty}=\ell nx=+\infty$ ខ/. $\lim\limits_{x\to0^+}\ell nx=-\infty$<br>គ/. $\lim\limits_{x\to+\infty}\dfrac{\ell nx}{x}=0$ ឃ/. $\lim\limits_{x\to0}x\ell nx=0$<br>ជាទូទៅ $\lim\limits_{x\to+\infty}\dfrac{\ell nx}{x^n}=0\ ;n\geq o$<br>នាំឱ្យ $\lim\limits_{x\to0^+}x^n\ell nx=0$<br>ចម្លើយ: $Ex$: គណនា<br>$=\lim\limits_{x\to+\infty}\ell nx(\ell nx+2x)$<br>$=\lim\limits_{x\to+\infty}\ell nx\left(\lim\limits_{x\to+\infty}\ell nx+\lim\limits_{x\to+\infty}2x\right)$<br>$=+\infty$<br>ចម្លើយ: $Ex$: គណនា<br>$=\lim\limits_{x\to+\infty}\left(\dfrac{\ell nx}{x^2+x}\right)$<br>$=\lim\limits_{x\to+\infty}\dfrac{\ell nx}{x}\times\lim\limits_{x\to+\infty}\left(\dfrac{1}{x+1}\right)$<br>ដោយ $\lim\limits_{x\to+\infty}\dfrac{\ell nx}{x}=0$<br>$\lim\limits_{x\to+\infty}\left(\dfrac{1}{x+4}\right)=0$<br>ដូចនេះ $\lim\limits_{x\to+\infty}\left(\dfrac{\ell nx}{x^2+x}\right)=0$ ។ | • សិស្សកំណត់បានលីមីតអនុគមន៍លោការីត<br><br>• សិស្សឡើងដោះស្រាយលំហាត់ |
| • គ្រូដាក់លំហាត់ឱ្យសិស្សដោះស្រាយ:<br>$Ex$: គណនា<br>$\lim\limits_{x\to+\infty}\left(x\ell nx+x^2+5\right)$ | ជំហានទី៤"ពង្រឹងពុទ្ធិ"<br>ចម្លើយ: គណនា $\lim\limits_{x\to+\infty}\left(x\ell nx+x^2+5\right)$<br>$=\lim\limits_{x\to+\infty}x^2\left(\dfrac{\ell nx}{x}+1+\dfrac{5}{x^2}\right)$<br>ដោយ $\lim\limits_{x\to+\infty}x^2=+\infty$ $\lim\limits_{x\to+\infty}\left(\dfrac{\ell nx}{x}+1+\dfrac{5}{x^2}\right)=1$<br>ដូចនេះ $\lim\limits_{x\to+\infty}\left(x\ell nx+x^2+5\right)=+\infty$ ។ | • សិស្សឡើងដោះស្រាយលំហាត់ |
| • ពេលប្អូនទៅផ្ទះវិញមើលមេរៀនបន្ត រួចដោះស្រាយលំហាត់ឱ្យបានច្រើនដង ។ | ជំហានទី៥ "បណ្តាំផ្ញើ" | • សិស្សស្តាប់ការណែនាំយ៉ាងយកខ្ជាប់ខ្ជួនបំផុត ។ |

# កិច្ចតែងការបង្រៀន

## ជំពូកទី ១ លីមីត

## មេរៀនទី ២ ភាពជាប់នៃអនុគមន៍

**១.វត្ថុបំណង**ក្រោយពីរៀនមេរៀននេះចប់សិស្សមានសមត្ថភាព

-**ចំណេះដឹង**:បង្ហាញលក្ខណៈនៃអនុគមន៍ជាប់បានត្រឹមត្រូវតាមរយៈការពន្យល់ណែនាំរបស់គ្រូ និងការពិភាក្សាក្រុម ។

-**បំណិន**:អនុវត្តទ្រឹស្តីបទតម្លៃកណ្តាលក្នុងការរកឫសនៃសមីការបានត្រឹមត្រូវ តាមរយៈការពន្យល់ណែនាំ

-**កិរិយាបថ**: សិស្សពិភាក្សាក្រុមយ៉ាងយកចិត្តទុកដាក់របស់គ្រូ និងការពិភាក្សាក្រុម

**២.សម្ភារៈ**

-សៀវភៅសិស្សទំព័រ ៣៥ ដល់ ៣៧ បោះពុម្ពឆ្នាំ ២០០៩

**៤.ដំណើរការនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យសណាប់ធ្នាប់និងពង្រឹងវិន័យ | ជំហានទី១(៥-៧)នាទី<br>រដ្ឋលថ្នាក់ និងលំនឹងថ្នាក់ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូឲ្យសិស្សឲ្យនិយមន័យភាពជាប់នៃអនុគមន៍ | ជំហានទី២(៥-១០)នាទី<br>រំលឹកមេរៀនចាស់<br>និយមន័យ-អនុគមន៍ជាប់លើ$(a,b)$លុះត្រា $f$ ជាប់ចំពោះគ្រប់តម្លៃ$x$នៃចន្លោះបើក នោះអនុគមន៍ $f$ ជាប់លើចន្លោះបិទ$[a,b]$ លុះត្រាតែ $f$ ជាប់លើចន្លោះបើក$(a,b)$ មានលីមីត | សិស្សឡើងឆ្លើយ |

| | | |
|---|---|---|
| | $\lim\limits_{x\to a} f(x)=f(a);\lim\limits_{x\to b} f(x)=b$ | |
| គ្រូឲ្យសិស្សពិនិត្យឧទាហរណ៍<br><br><br><br><br><br><br><br><br><br><br><br><br><br><br>លំហាត់គំរូទី១ គេឲ្យអនុគមន៍ $f(x)=\dfrac{1-\cos x}{x^2}$ ។តើ $f$ មានបន្លាយភាពជាប់ត្រង់0ឬទេ? | ជំហានទី៣ (៦០នាទី)<br>មេរៀនថ្មី<br>៦.អនុវត្តន៍ អនុគមន៍បន្លាយភាពជាប់<br>ឧទាហរណ៍:គេមានអនុគមន៍ $f$<br>កំណត់ដោយ $f(x)=\dfrac{x^3-1}{x-1}$ ។តើ $f$ ជាអនុគមន៍ជាប់ត្រង់ $x=1$ ឬទេ?<br>ដំណោះស្រាយ<br>អនុគមន៍ $f$ ជាប់ត្រង់ $x=1$ កាលណា<br>$\lim\limits_{x\to 1} f(x)=\lim\limits_{x\to 1}\dfrac{x^3-1}{x-1}=\lim\limits_{x\to 1}(x^2+x+1)=$<br>ប៉ុន្តែ $f$ មិនកំណត់ត្រង់1ទេនាំឲ្យ $f$ មិនជាប់ត្រង់1<br>គេថា $g$ ជាបន្លាយភាពជាប់នៃអនុគមន៍ $f$ តាមភាពជាប់ត្រង់1<br>ជាទូទៅ បើ $f$ ជាអនុគមន៍មិនកំណត់ត្រង់ $x=a$ និងមានលីមីត $\lim\limits_{x\to a} f(x)=l$ នោះអនុគមន៍បន្លាយភាពជាប់នៃ $f$ តាមភាពជាប់ ត្រង់ $a$ កំណត់ដោយ<br>$g(x)=\begin{cases} f(x); x\neq 0 \\ e; x=0\end{cases}$<br>អនុគមន៍ $f$ មានន័យកាលណា $x^2\neq 0$<br>$\Leftrightarrow x\neq 0$<br>-ដែនកំណត់ $D=\mathbb{R}-\{0\}$<br>គេបាន $\lim\limits_{x\to 0} f(x)=\lim\limits_{x\to 0}\dfrac{1-\cos x}{x^2}$<br>$=\lim\limits_{x\to 0}\dfrac{2\sin^2\frac{x}{2}}{x^2}=\lim\limits_{x\to 0}\dfrac{2}{4}\left(\dfrac{\sin\frac{x}{2}}{\frac{x}{2}}\right)\left(\dfrac{\sin\frac{x}{2}}{\frac{x}{2}}\right)$ | សិស្សពិនិត្យឧទាហរណ៍យ៉ាងយកចិត្តទុកដាក់<br><br><br><br><br><br><br><br><br><br><br><br><br><br><br><br>សិស្សឡើងដោះស្រាយ និងកត់ត្រាចូលសៀវភៅ |

| | | |
|---|---|---|
| លំហាត់គំរូទី២ គេឲ្យអនុគមន៍ $f$ កំណត់ដោយ $f(x)=\begin{cases} x+\frac{\sqrt{x^2}}{x}; x\neq 0 \\ 1; x=0\end{cases}$ សិក្សាភាពជាប់នៃ $f$ ត្រង់ $x=0$ | $=\frac{2}{4}\lim_{x\to 0}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)=\frac{2}{4}=\frac{1}{2}$<br>យក $g$ ជាអនុគមន៍កំណត់ដោយ $g(x)=\begin{cases}\frac{1-\cos x}{x^2}; x\neq 0\\ \frac{1}{2}; x=0\end{cases}$<br>នោះ $g$ ជាបន្លាយភាពជាប់ត្រង់ $x=0$<br>ដំណោះស្រាយ<br>គេមាន $f(x)=\begin{cases} x+\frac{\sqrt{x^2}}{x}; x\neq 0 \\ 1; x=0\end{cases}$<br>$=\begin{cases} x+\frac{x}{x}=x+1; x>1 \\ x-\frac{x}{x}=x-1; x<1 \\ 1; x=0\end{cases}$ | |
| គ្រូឲ្យសិស្សសង្កេតឧទាហរណ៍ គេមាន $f(x)=x^2+2$ លើចន្លោះ $[0,2]$ | តាមសមតិកម្ម យើងបាន<br>$\lim_{x\to 0^+}(x+1)=1=f(0)$; $f$ ជាប់ខាងស្តាំត្រង់ $x=0$<br>$\lim_{x\to 0^-}(x-1)\neq f(0)$; $f$ មិនជាប់ខាងឆ្វេង $x=0$<br>ដូចនេះ $f$ មិនជាប់ត្រង់ $x=0$<br>៧.ទ្រឹស្តីបទតម្លៃកណ្តាល<br>គេមាន $f(x)=x^2-2$ | |
| គ្រូសរសេរទ្រឹស្តីបទដាក់លើក្តាខៀន | .បើ $x=0$ នោះ $f(0)=-2$<br>.បើ $x=2$ នោះ $f(2)=2$<br>យក $k$ ;ដែល $f(0)\leq k\leq f(2)$<br>គេបានសមីការ $x^2-2=k$ រឺ $x^2=k+2$<br>ដោយ $-2\leq k\leq 2$ នោះ $k+2\geq 0$<br>ដូចនេះនៅចន្លោះ $[0,2]$ គេបាន<br>$x=\sqrt{k+2}, \forall k / f(0)\leq k\leq f(2)$ | |

| | | |
|---|---|---|
| លំហាត់គំរូ គេមានអនុគមន៍ $f$ កំណត់ដោយ $\begin{cases} x-1; 0\le x\le 2 \\ x^2; 2< x\le 3 \end{cases}$<br>តើគ្រប់ $-1\le k\le 9$ មាន $c$ ដែល $f(c)=k$ រឺទេ? | សមីការ $x^2-2=k$ មានឫស<br>$x=c;0\le c\le 2$<br>ទ្រឹស្តីបទ បើអនុគមន៍ $f$ ជាប់លើចន្លោះបិទ $[a,b]$ និង $k$ ជាចំនួនមួយនៅចន្លោះ $f(a)$ និង $f(b)$ នោះមានចំនួនពិត $c$ មួយយ៉ាងតិចក្នុងចន្លោះបិទ $[a,b]$ ដែល $f(x)=k$<br>សំរាយបញ្ជាក់<br>អនុគមន៍ $f$ ជាប់ និងកើនលើចន្លោះបិទ $[a,b]$; $f$ កើនដាច់ខាតមានន័យថា $x<x'$ នោះ $f(x)<f(x')$ ដែល $x$ និង $x'\in[a,b]$<br>នាំឲ្យចំនួនពិត $k$ នៅចន្លោះ $f(a)$ និង $f(b)$<br>គេបាន $f(a)<k<f(b)$ និង $f$ ជាអនុគមន៍ជាប់តាមទ្រឹស្តីបទបញ្ជាក់ថាមានចំនួនពិត $c$ មួយនៅចន្លោះ $a,b$ ដែល $f(c)=k$<br>បំនកស្រាយតាមធរណីមាត្រ<br><br> | សិស្សកត់ត្រា |

| | | |
|---|---|---|
| លំហាត់គូទី២<br>ដោយប្រើទ្រឹស្តីបទតម្លៃកណ្តាលបង្ហាញថាចំពអនុគមន៍ពហុធា $f(x)=x^3+2x-1$<br>មានចំនួនពិត $c$ នៅចន្លោះ<br>$[0,1]$ ដែល $f(c)=0$<br><br>គ្រូអោយសិស្សធ្វើប្រតិបត្តិ | ដំណោះស្រាយ<br><br>តាមក្រាប $f$ ដាច់ត្រង់ 2<br>ដែលស្ថិតក្នុងចន្លោះ $[0,3]$ គេបាន<br>$f(0)=-1$<br>$f(3)=9$<br>បើ $k\in[1,4]$ នោះគ្មានតម្លៃ $c$ ដែល<br>$f(c)=k$<br>ព្រោះគ្មានតម្លៃអនុគមន៍ចន្លោះ 1 និង 4<br><br>ប្រើទ្រឹស្តីបទតំលៃកណ្តាល<br>បង្ហាញថាសមីការ<br>$x^5-3x-1=0$<br>មានរឹសយ៉ាងតិចមួយនៅ<br>ចន្លោះ $[1,2]$ | សិស្សឡើងដោះស្រាយ<br>គេមាន $f(x)=x^3+2x-1$<br>• $f(0)=0^3+2(0)-1$<br>• $f(1)=1^3+2(1)-1=2$<br>នាំអោយ $f(0).f(1)=-2<0$<br>តាមទ្រឹស្តីបទតំលៃកណ្តាល<br>$f(0).f(1)$ មានចំនួន c មួយ<br>យ៉ាងតិចក្នុងចន្លោះបិទ $[0,1]$<br>ដែល $f(c)=0$<br><br>ដំណោះស្រាយ<br>តាង<br>$f(x)=x^5-3x-1$<br>$f(1)=1-3.1-1=-3$<br>$f(2)=32-6-1=25$<br>$\Rightarrow f(1).f(2)=-3.25=-75<0$<br><br>តាមទ្រឹស្តីបទតំលៃកណ្តាល<br>$f(1).f(2)<0$ មានចំនួន c មួយ<br>យ៉ាងតិចនៅចន្លោះ $[1,2]$ ដែល<br>$f(c)=0$ |
| | ជំហានទី4<br>រំលឹកមេរៀនឡើងវិញ | |

| | | |
|---|---|---|
| លំហាត់<br>គេអោយអនុគមន៍ $f$<br>កំណត់ដោយ:<br>$f(x)=\begin{cases}x^2+2, x\geq -1\\ 2x+5, x<-1\end{cases}$<br>ស្រាយបញ្ជាក់ថា $f$<br>ជាប់លើចំនុច $x=-1$ | | ដំណោះស្រាយ<br>តាមសមតិកម្ម<br>$f(1)=(-1)^2+2-3$<br>$\bullet \lim_{x\to -1} f(x)=\lim_{x\to -1}(x^2+2)=3$<br>$=f(-1)$ $f$ ជាប់ខាងស្តាំ។<br>$\bullet \lim_{x\to -1} f(x)=\lim_{x\to -1}(2x+5)=3$<br>$=f(-1)$ $f$ ជាប់ខាងឆ្វេង។<br>ដូចនេះ $f$ ជាប់ត្រង់ $x=-1$ |
| គ្រូកត់សំនួរ<br>និងលំហាត់ដាក់លើក្តារខៀ ន<br>និងនែនាំសិស្សអោយខិតខំរៀ<br>នសូត្រ | ជំហានទី5<br>បណ្តាំផ្ញើ<br>លំហាត់ទំព័រ 40-41 លេខ 4-6 | សិស្សកត់ត្រាសំនួរ<br>និងលំហាត់ព្រមទាំ<br>ងត្រង់ត្រាប់ស្តាប់ការនែនាំរបស់គ្រូ<br>យ៉ាងយកចិត្តទុកដាក់ |

# កិច្ចតែងការបង្រៀន

**ជំពូកទី ១ លីមីត**

**មេរៀនទី១ លីមីតនៃអនុគមន៍**

5.លីមីតនៃអនុមន៍មិនពិជគណិត

5.1 លីមីតនៃអនុគមន៍ត្រីកោណមាត្រ

**១.វត្ថុបំណង**:ក្រោយពីរៀនមេរៀននេះចប់សិស្សមានសមត្ថភាព

**-ចំណេះដឹង**:គណនាលីមីតនៃអនុគមន៍ត្រីកោណមាត្របានត្រឹមត្រូវ

តាមរយៈការពន្យល់ណែនាំរបស់គ្រូ និងការពិភាក្សាក្រុម

**-បំណិន**:

**-ឥរិយាបថ**: សិស្សពិភាក្សាក្រុមយ៉ាងយកចិត្តទុកដាក់

**២.សម្ភារៈឧបទេស**

-សៀវភៅសិស្សទំព័រទី២ ដល់ ២៧

-បន្ទាត់

**៣.រយៈពេល ១h**

**៤.ដំណើរនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ឲ្យសិស្សឡើងរាយការណ៍ពី:<br>-សណ្តាប់ធ្នាប់ -អនាម័យ | ជំហានទី១(លំនឹងថ្នាក់)<br>-សណ្តាប់ធ្នាប់ -អនាម័យ | -សណ្តាប់ធ្នាប់ -អនាម័យ<br>-អវត្តមាន |

| -អវត្តមាន | -អវត្តមាន | |
|---|---|---|
| ឲ្យសិស្សឡើងកែលំហាត់គណនាលីមីត<br>ក. $\lim_{x\to-\infty}\left(\sqrt{x^2+3x-1}-\sqrt{x^2-3}\right)$<br>ខ. $\lim_{x\to+\infty}\frac{3x^4-5x}{x^2-5x+4}$ | ជំហានទី២(រំលឹកមេរៀនចាស់)<br>ដំណោះស្រាយ<br>ក. $\lim_{x\to-\infty}\left(\sqrt{x^2+3x-1}-\sqrt{x^2-3}\right)$<br>$=\lim_{x\to-\infty}\left(\frac{x^2+3x-1-x^2-3}{\sqrt{x^2+3x-1}+\sqrt{x^2-3}}\right)=-4$<br>ខ. $\lim_{x\to+\infty}\frac{3x^4-5x}{x^2-5x+4}$<br>$=\lim_{x\to+\infty}\frac{x^4\left(3-5/x^3\right)}{x^2\left(1-5/x+\infty\, 4/x^2\right)}=+\infty$ | សិស្សឡើងគណនា<br>ក.<br>$\lim_{x\to-\infty}\left(\sqrt{x^2+3x-1}-\sqrt{x^2-3}\right)$<br>$=\lim_{x\to-\infty}\left(\frac{x^2+3x-1-x^2-3}{\sqrt{x^2+3x-1}+\sqrt{x^2-3}}\right)=-4$<br>ខ. $\lim_{x\to+\infty}\frac{3x^4-5x}{x^2-5x+4}$<br>$=\lim_{x\to+\infty}\frac{x^4\left(3-5/x^3\right)}{x^2\left(1-5/x+\infty\, 4/x^2\right)}=+\infty$ |
| ឧទាហរណ៍:<br>គេមានរង្វង់ត្រីកោណមាត្រ<br><br>ចូរប្អូនសង្កេត<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\sin x$ ខិតរក $0$<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\cos x$ ខិតរក $1$<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\tan x$ ខិតរក $0$<br>-គេសរសេរ $\lim_{x\to0}\sin x=0$ ,<br>$\lim_{x\to0}\cos x=1$ , $\lim_{x\to0}\tan x=0$ | ជំហានទី៣(មេរៀនថ្មី)<br>មេរៀនទី១: **លីមីតនៃអនុគមន៍ត្រីកោណមាត្រ**<br><br>ចូរប្អូនសង្កេត<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\sin x$ ខិតរក $0$<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\cos x$ ខិតរក $1$<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\tan x$ ខិតរក $0$<br>-គេសរសេរ $\lim_{x\to0}\sin x=0$ ,<br>$\lim_{x\to0}\cos x=1$ , $\lim_{x\to0}\tan x=0$ | សិស្សសង្កេត និងស្តាប់<br><br>-កាលមុំ $x$ ខិតជិត $0$ នោះ $\sin x$ ខិតរក $0$<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\cos x$ ខិតរក $1$<br>-កាលមុំ $x$ ខិតជិត $0$ នោះ $\tan x$ ខិតរក $0$<br>-គេសរសេរ $\lim_{x\to0}\sin x=0$ ,<br>$\lim_{x\to0}\cos x=1$ , $\lim_{x\to0}\tan x=0$ |

| | | |
|---|---|---|
| គ្រូឲ្យសិស្សសង្កេតលក្ខណៈទូទៅ<br><br>គ្រូធ្វើសំរាយបញ្ជាក់ | ជាទូទៅ: បើ $a$ ជាចំនួនពិតស្ថិតនៅក្នុងដែនកំណត់នៃអនុគមន៍ត្រីកោណមាត្រ<br>គេបាន: $\lim_{x\to a}\sin x=\sin a$<br>$\lim_{x\to a}\cos x=\cos a$<br>$\lim_{x\to a}\tan x=\tan a$<br><br>ទ្រឹស្តីបទ:បើ $x$ ជារង្វាស់មុំ រឺធ្នូគិតជារ៉ាដ្យង់គេបាន<br>ក. $\lim_{x\to 0}\dfrac{\sin x}{x}=1$,<br>ខ. $\lim_{x\to 0}\dfrac{1-\cos x}{x}=0$<br>សំរាយបញ្ជាក់<br><br>ក.បើ $0<\theta<\dfrac{\pi}{2}$<br>គេបានក្រលាផ្ទៃ $\Delta OAT\geq$ ក្រលាផ្ទៃចំរៀកថាស $OAP\geq$ ផ្ទៃក្រលា $\Delta OAP$ | ជាទូទៅ: បើ $a$ ជាចំនួនពិតស្ថិតនៅក្នុងដែនកំណត់នៃអនុគមន៍ត្រីកោណមាត្រ<br>គេបាន: $\lim_{x\to a}\sin x=\sin a$<br>$\lim_{x\to a}\cos x=\cos a$<br>$\lim_{x\to a}\tan x=\tan a$ |

<table>
<tr>
<td></td>
<td>$\frac{1}{2}\times1\times\tan\theta\geq\frac{1}{2}\times1^2\cdot\theta\geq\frac{1}{2}\times1\times\sin\theta$<br>$\tan\theta\geq\theta\geq\sin\theta$<br>គុណវិសមភាពនិង $\frac{1}{\sin\theta}$ គេបាន<br>$\frac{1}{\cos\theta}\geq\frac{\theta}{\sin\theta}\geq1$<br>$\cos\theta\leq\frac{\sin\theta}{\theta}\leq1$<br>-បើ $-\frac{\pi}{2}<\theta<0$ គេបាន<br>$\cos(-\theta)\leq\frac{\sin(-\theta)}{-\theta}\leq1$<br>$\cos\theta\leq\frac{\sin\theta}{\theta}\leq1$<br>$\lim_{\theta\to0}\cos\theta\leq\lim_{\theta\to0}\frac{\sin\theta}{\theta}\leq\lim_{\theta\to0}1$<br>$1\leq\lim_{\theta\to0}\frac{\sin\theta}{\theta}\leq1$<br>ដូចនេះ $\lim_{\theta\to0}\frac{\sin\theta}{\theta}=1$</td>
<td></td>
</tr>
<tr>
<td>គ្រូឲ្យសិស្សឡើងគណនា<br>ក. $\lim_{x\to0}\frac{\sqrt{x+4}-2}{\sin5x}$<br>ខ. $\lim_{x\to0}\frac{\cos6x-\cos x}{\sin^2x}$</td>
<td>ជំហានទី៨(ពង្រឹងចំណេះដឹង)<br>គណនា ក. $\lim_{x\to0}\frac{\sqrt{x+4}-2}{\sin5x}$<br>គេបាន $\lim_{x\to0}\frac{\sqrt{x+4}-2}{\sin5x}$<br>$=\lim_{x\to0}\frac{x+4-4}{\sin5x\left(\sqrt{x+4}+2\right)}=\frac{1}{20}$<br>ខ. $\lim_{x\to0}\frac{\cos6x-\cos x}{\sin^2x}$<br>តាម<br>$\cos p-\cos q=-2\sin\frac{p+q}{2}\sin\frac{p-q}{2}$<br>នោះ<br>$\cos6x-\cos x=-2\sin\frac{6x+x}{2}\sin\frac{6x-x}{2}$<br>$=-2\sin\frac{7x}{2}\sin\frac{5x}{2}$</td>
<td>សិស្សឡើងធ្វើលំហាត់លើក្ដារខៀន<br>គណនា ក. $\lim_{x\to0}\frac{\sqrt{x+4}-2}{\sin5x}$<br>គេបាន $\lim_{x\to0}\frac{\sqrt{x+4}-2}{\sin5x}$<br>$=\lim_{x\to0}\frac{x+4-4}{\sin5x\left(\sqrt{x+4}+2\right)}=\frac{1}{20}$<br>ខ.<br>$\lim_{x\to0}\frac{\cos6x-\cos x}{\sin^2x}$<br>តាម<br>$\cos p-\cos q=-2\sin\frac{p+q}{2}\sin\frac{p-q}{2}$<br>នោះ</td>
</tr>
</table>

| | | |
|---|---|---|
| | គេបាន $\lim_{x\to 0}\frac{\cos 6x-\cos x}{\sin^2 x}$<br>$=\lim_{x\to 0}\frac{-2\sin\frac{7x}{2}\sin\frac{5x}{2}}{\sin^2 x}$<br>$=-\lim_{x\to 0}\left(\frac{2\cdot\frac{7x}{2}\cdot\frac{5x}{2}}{\frac{\sin^2 x}{x^2}\cdot x^2}\right)=-\frac{35}{2}$ | $\cos 6x-\cos x=-2\sin\frac{6x+x}{2}\sin\frac{6x-x}{2}$<br>$=-2\sin\frac{7x}{2}\sin\frac{5x}{2}$<br>គេបាន $\lim_{x\to 0}\frac{\cos 6x-\cos x}{\sin^2 x}$<br>$=\lim_{x\to 0}\frac{-2\sin\frac{7x}{2}\sin\frac{5x}{2}}{\sin^2 x}$<br>$=-\lim_{x\to 0}\left(\frac{2\cdot\frac{7x}{2}\cdot\frac{5x}{2}}{\frac{\sin^2 x}{x^2}\cdot x^2}\right)=-\frac{35}{2}$ |
| គ្រូសរសេរលំហាត់លើក្តារខៀន<br>$\lim_{x\to 0}\frac{\tan x-\sin x}{x^3}$ | ជំហានទី៥(កិច្ចការផ្ទះ)<br>ចូរគណនា $\lim_{x\to 0}\frac{\tan x-\sin x}{x^3}$ | សិស្សកត់ត្រាលំហាត់ធ្វើនៅផ្ទះ<br>ចូរគណនា $\lim_{x\to 0}\frac{\tan x-\sin x}{x^3}$ |

# កិច្ចតែងការបង្រៀន

- **មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២( កម្រិតមូលដ្ឋាន )**
- **ជំពូកទី១ :លីមីត**
- **មេរៀនទី២ : ភាពជាប់នៃអនុគមន៍**
- **ពេលវេលា : ...២...ម៉ោង ថ្ងៃ.........ទី...ខែ..............ឆ្នាំ.........**

**I.វត្ថុបំណងនៃមេរៀន**

**-ចំណេះដឹង** : បង្ហាញសញ្ញាណនៃអនុគមន៍ជាប់ បានត្រឹមត្រូវ។
កំណត់និយមន័យនៃអនុគមន៍ជាប់ត្រង់មួយចំណុចបានត្រឹមត្រូវ។

**-បំណិន** : ពន្យល់ពីសញ្ញាណនៃអនុគមន៍ជាប់ បានត្រឹមត្រូវ។
បកស្រាយនិយមន័យនៃអនុគមន៍ជាប់ត្រង់មួយចំណុច បានច្បាស់លាស់។

**-ឥរិយាបថ** :សិស្សបានបណ្ដុះស្មារតីយកចិត្តទុកដាក់ និង មានទំនួលខុសត្រូវ។

**II. ខ្លឹមសារមេរៀន** :

១.សញ្ញាណនៃអនុគមន៍ជាប់

២. ភាពជាប់ត្រង់មួយចំណុច

**III.សម្ភារៈឧទេស**

-ស . ស :ទំព័រទី២៨ដល់ទំព័រទី៣០

-ស . គ : ទំព័រទី២៨ដល់ទំព័រទី៣០

- សន្លឹកកម្រង់លំហាត់ប្រត្តិបត្តិ បន្ទាត់ ឧបករណ៍សម្រាប់គូសប៉ារ៉ាបូល

**IV.ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្ដាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ចូរឱ្យនិយមន័យលីមីតឆ្វេងនិង លីមីតស្ដាំនៃអនុគមន៍ $y=f(x)$ ត្រង់ $x_0$ ។ | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី) | -បើ $f(x)$ ខិតជិត $l$ កាលណា $x$ ខិតជិ $x_0$ ពីខាងឆ្វេងនោះ $l$ ជាលីមីតឆ្វេងនៃ $f(x)$ ។ |

| | | |
|---|---|---|
| -តើនៅពេលណាដែលអនុគមន៍ $y=f(x)$ មានលីមីតត្រង់ $x_0$ ? | | គេសរសេរ $\lim_{x\to x_0-} f(x)=L$<br>-បើ $f(x)$ ខិតជិតRកាលណា $x$ ខិតជិត $x_0$ ពីខាងស្តាំនោះ Rជាលីមីតស្តាំនៃ $f(x)$ ។<br>គេសរសេរ $\lim_{x\to x_0^+} f(x)=L$<br>-អនុគមន៍ $y=f(x)$ មានលីមីត ត្រង់ $x_0$ កាលណាលីមីតឆ្វេងស្មើនិងលីមីតស្តាំគឺ<br>$\lim_{x\to x_0-} f(x)=\lim_{x\to x_0+} f(x)=L$<br>ឬ $\lim_{x\to x_0} f(x)=L$ |
| -គូសក្រាបនៃអនុគមន៍ $y=f(x)$ លើចន្លោះ $I$ មួយដោយមិនលើកខ្មៅដៃ រួចឱ្យសិស្សសង្កេតមើល។<br>-តើក្រាបនោះជាខ្សែជាប់ ឬដាច់?<br>-បញ្ជាក់ប្រាប់សិស្សថា $f$ ជាអនុគមន៍ជាប់គ្រប់ចំណុចនៃចន្លោះ I ព្រោះខ្សែជាប់នេះគ្មានដាច់ ឬ ចន្លោះ។ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី២:**<br>**ភាពជាប់នៃអនុគមន៍**<br>១. សញ្ញាណនៃអនុគមន៍ជាប់<br><br>២.ភាពជាប់ត្រង់មួយចំណុច | -សិស្សសង្កេត<br>-ជាខ្សែជាប់<br>-សិស្សស្តាប់ និងកត់ត្រា |

| | | |
|---|---|---|
| -ណែនាំសិស្សធ្វើឧទាហរណ៍ | ឧទាហរណ៍ គេឱ្យអនុគមន៍<br>$y=f(x)=\begin{cases}x^2+7\\ x+7\end{cases}$<br>បើ $\begin{matrix}x\geq 0\\ x\prec 0\end{matrix}$<br>ក. រកដែនកំនត់នៃអនុគមន៍f<br>ខ. រក $f(0)$ ,$\lim\limits_{x\to 0^-}f(x)$<br>និង$\lim\limits_{x\to 0^+}f(x)$រួចទាញរក $\lim\limits_{x\to 0}f(x)$<br>គ. ប្រៀបធៀបតម្លៃរបស់ $f(0)$ និង<br>$\lim\limits_{x\to 0}f(x)$<br>ឃ. សង់ក្រាបតាងអនុគមន៍ f<br>ចម្លើយ<br>ក.$D=\mathbb{R}$<br>ខ.<br>$f(0)=0^2+7=7$<br>$\lim\limits_{x\to 0^-}f(x)=0+7=7$<br>$\lim\limits_{x\to 0^+}f(x)=0^2+7=7$<br>ដោយ $\lim\limits_{x\to 0^-}\lim\limits_{x\to 0}f(x)=\lim\limits_{x\to 0^+}f(x)$<br>$\Rightarrow\lim\limits_{x\to 0}f(x)=7$<br>គ.ដោយ $f(0)=7$<br>$\lim\limits_{x\to 0}f(x)=7$<br>$\Rightarrow\lim\limits_{x\to 0}f(x)=f(0)=7$<br>ឃ.សង់ក្រាប | - ក.$D=\mathbb{R}$<br>ខ.<br>$f(0)=0^2+7=7$<br>$\lim\limits_{x\to 0^-}f(x)=0+7=7$<br>$\lim\limits_{x\to 0^+}f(x)=0^2+7=7$<br>ដោយ<br>$\lim\limits_{x\to 0^-}\lim\limits_{x\to 0}f(x)=\lim\limits_{x\to 0^+}f(x)$<br>$\Rightarrow\lim\limits_{x\to 0}f(x)=7$<br>គ.ដោយ $f(0)=7$<br>$\lim\limits_{x\to 0}f(x)=7$<br>$\Rightarrow\lim\limits_{x\to 0}f(x)=f(0)=7$<br>ឃ.សង់ក្រាប |

<table>
<tr>
<td>
-តើក្រាបដែលសង់បានជាប់គ្នាត្រង់ $x=0$ ឬទេ?<br>
-បញ្ជាក់ប្រាប់សិស្សថា $f$ ជាអនុគមន៍ជាប់ត្រង់ $x=0$ ។<br>
-ដើម្បីឱ្យអនុគមន៍ $f$ មួយជាអនុគមន៍ជាប់ត្រង់ $x=c$ តើអនុគមន៍ $f$ ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?<br>
-ឱ្យសិស្សទាញនិយមន័យអនុគមន៍ជាប់ត្រង់ $x=c$ ។<br>
<br>
-ឱ្យលក្ខណៈសម្គាល់ដល់សិស្ស បើអនុគមន៍ $y=f(x)$ មិនជាប់ត្រង់ $x=c$ គេថា $f$ ជាអនុគមន៍ដាច់ត្រង់ $x=c$
</td>
<td>

<br>
-និយមន័យ អនុគមន៍ $y=f(x)$ ជាប់ត្រង់ចំណុច $x=c$ កាលណា $f$ បំពេញលក្ខខណ្ឌទាំងបីដូចខាងក្រោម<br>
. $f$ កំណត់ចំពោះ $x=c$<br>
. $f$ មានលីមីតត្រង់ $x=c$<br>
. $\lim_{x\to c} f(x)=f(c)$<br>
<br>
-សម្គាល់<br>
បើអនុគមន៍ $y=f(x)$ មិនជាប់ត្រង់ $x=c$ គេថា $f$ ជាអនុគមន៍ដាច់ត្រង់ $x=c$<br>
លំហាត់គំរូ<br>
ក.អនុគមន៍ $f$ កំណត់ដោយ
</td>
<td>
<br>
-ជាប់គ្នាត្រង់ $x=0$<br>
-សិស្សស្តាប់ និងកត់ត្រា<br>
-បំពេញលក្ខខណ្ឌបី<br>
-f កំណត់ចំពោះ $x=c$<br>
-f មានលីមីតកាលណា $x\to c$<br>
-$\lim_{x\to c} f(x)=f(c)$<br>
- និយមន័យ អនុគមន៍ $y=f(x)$ ជាប់<br>
ត្រង់ចំណុច $x=c$ កាលណា $f$ បំពេញ<br>
លក្ខខណ្ឌទាំងបីដូចខាងក្រោម<br>
. $f$ កំណត់ចំពោះ $x=c$<br>
. $f$ មានលីមីតត្រង់ $x=c$<br>
. $\lim_{x\to c} f(x)=f(c)$<br>
<br>
-សិស្សស្តាប់និងកត់ត្រា<br>
<br>
ក.តើអនុគមន៍ $f$ ជាអនុគមន៍ជាប់ត្រង់
</td>
</tr>
</table>

$f(x)=x^2-4$ ។តើ $f$ ជាអនុគមន៍ជាប់ត្រង់ $x=2$ ឬទេ?

ខ. អនុគមន៍ $g$ កំណត់ដោយ

$$g(x)=\begin{cases}-1 & ,x\prec 0\\ 1 & ,x\succ 0\end{cases}$$

តើ $g$ ជាអនុគមន៍ជាប់ត្រង់ $x=0$ ឬទេ?

(សង់ក្រាបបញ្ជាក់)

**ចម្លើយ**

ក.តើអនុគមន៍ $f$ ជាអនុគមន៍ជាប់ត្រង់ $x=2$ ឬទេ?

រក

$f(2)=2^2-4=0\ (1)$

$\lim\limits_{x\to 2^-} f(x)=2^2-4=0$

$\lim\limits_{x\to 2^+} f(x)=2^2-4=0$

ដោយ

$\lim\limits_{x\to 2^-} f(x)=\lim\limits_{x\to 2^+} f(x)=0$

$\Rightarrow \lim\limits_{x\to 2} f(x)=0\ (2)$

តាម(១)និង (២)គេបាន

$\lim\limits_{x\to 2} f(2)=0$

ដូចនេះ $f$ ជាអនុគមន៍ជាប់ត្រង់ $x=2$




ខ. តើ $g$ ជាអនុគមន៍ជាប់ត្រង់ $x=0$ ឬទេ?

$x=2$ ឬទេ?

រក

$f(2)=2^2-4=0\ (1)$

$\lim\limits_{x\to 2^-} f(x)=2^2-4=0$

$\lim\limits_{x\to 2^+} f(x)=2^2-4=0$

ដោយ

$\lim\limits_{x\to 2^-} f(x)=\lim\limits_{x\to 2^+} f(x)=0$

$\Rightarrow \lim\limits_{x\to 2} f(x)=0\ (2)$

តាម(១)និង (២)គេបាន

$\lim\limits_{x\to 2} f(2)=0$

ដូចនេះ $f$ ជាអនុគមន៍ជាប់ត្រង់

$x=2$




ខ. តើ $g$ ជាអនុគមន៍ជាប់ត្រង់

$x=0$ ឬទេ?

រក

$\lim\limits_{x\to 0^-} g(x)=-1$

$\lim\limits_{x\to 0^+} g(x)=1$

$\Rightarrow \lim\limits_{x\to 0^-} g(x)\neq \lim\limits_{x\to 0^+} g(x)$

$\Rightarrow g$ គ្មានលីមីតត្រង់ $x=0$ ទេ។

ដូចនេះ $g$ មិនជាប់ត្រង់ $x=0$ ទេ។

| | | |
|---|---|---|
| | រក<br>$\lim\limits_{x\to 0^-} g(x) = -1$<br>$\lim\limits_{x\to 0^+} g(x) = 1$<br>$\Rightarrow \lim\limits_{x\to 0^-} g(x) \neq \lim\limits_{x\to 0^+} g(x)$<br>$\Rightarrow g$ គ្មានលីមីតត្រង់ $x=0$ ទេ។<br>ដូចនេះ $g$ មិនជាប់ត្រង់ $x=0$ ទេ។<br><br> | <br> |
| -ចែកក្រុមលំហាត់ប្រតិបត្តិឱ្យសិស្សធ្វើជាដៃគូឬជាបុគ្គល<br>-គេមានអនុគមន៍<br>$f(x)=\begin{cases}3+x\ ,\ x\le 1\\ 3-x\ ,x\succ 1\end{cases}$<br>សិក្សាភាពជាប់នៃអនុគមន៍ $f$ ត្រង់ $x=1$ | **ជំហានទី៤**<br>(ពង្រឹងចំណេះដឹង ១៥នាទី) | -សិក្សាភាពជាប់<br>រក $f(1)=3+1=4$<br>$\lim\limits_{x\to 1^-} f(x)=3+1=4$<br>$\lim\limits_{x\to 1^+} f(x)=3-1=2$<br>ដោយ<br>$\lim\limits_{x\to 1^+} f(x)\neq \lim\limits_{x\to 1^-} f(x)$<br>នោះ $f$ គ្មានលីមីតត្រង់ $x=1$ ទេ។<br>ដូចនេះ អនុគមន៍ $f$ មិនជាប់ត្រង់ $x=1$ ទេ។ |
| | **ជំហានទី៥** | |

| | | |
|---|---|---|
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | (កិច្ចការផ្ទះ ៥នាទី) | -សិស្សកត់លំហាត់និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

## - មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)
## - ជំពូកទី១ : លីមីត
## - មេរៀនទី២ : ភាពជាប់នៃអនុគមន៍
## -ពេលវេលា : …២…ម៉ោង ថ្ងៃ………ទី…ខែ…………..ឆ្នាំ……….

**I.វត្ថុបំណងនៃមេរៀន**

**-ចំណេះដឹង** : -កំណត់និយមន័យអនុគមន៍ជាប់លើចន្លោះបើកនិងលើចន្លោះបិទបានត្រឹមត្រូវ។
-កំណត់និយមន័យអនុគមន៍បណ្តាក់បានត្រឹមត្រូវ។

**-បំណិន** : សិក្សាភាពជាប់នៃអនុគមន៍លើចន្លោះបើក និងលើចន្លោះបិទបានច្បាស់លាស់។
-សិក្សាភាពជាប់នៃអនុគមន៍បណ្តាក់បានត្រឹមត្រូវ។

**-ឥរិយាបថ** : សិស្សអាចយកចំណេះដឹងទាំងនេះទៅពន្យល់មិត្តភក្តិ ដោយមានភាពជឿជាក់និងមានសាមគ្គីភាព។

**II. ខ្លឹមសារមេរៀន** :

៤.ភាពជាប់លើចន្លោះ

៥. ភាពជាប់នៃអនុគមន៍បណ្តាក់

**III.សម្ភារៈឧទេស**

-ស . ស :ទំព័រទី៣២ដល់ទំព័រទី៣៤

-ស . គ : ទំព័រទី៣២ ដល់ទំព័រទី៣៤

- សន្លឹកកម្រង់លំហាត់ប្រត្តិបត្តិ សន្លឹកកម្រងសំណួរតម្រង់ទិសការពិភាក្សា។

**IV.ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| | | |

| | | |
|---|---|---|
| -តើសរសេរ $x\in(a,b)$ និង $x\in[a,b]$ មានន័យដូចម្ដេច? | <u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់ ៧នាទី) | -$x\in(a,b)$<br>មានន័យថាគឺគ្រប់តម្លៃ $x$ នៅក្នុងចន្លោះ $a$ និង $b$<br>ឬគេសរសេរ $a\prec x\prec b$ ។<br>-$x\in[a,b]$ មានន័យថាគឺគ្រប់តម្លៃ $x$ ក្នុងចន្លោះ $a$ និង $b$ ផង និងតម្លៃ $x=a$ និង $x=b$ ផង<br>ឬ គេសរសេរ $a\le x\le b$ ។ |
| -ឱ្យសិស្សសង្កេតលើឧទាហរណ៍ទី១និងទី២<br><br>-បញ្ជាក់ប្រាប់សិស្សថា $f$ ជាអនុគមន៍ជាប់លើចន្លោះបើក $(-\infty,-5)$ និងជាប់លើបើក $(-5,+\infty)$ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយះពេល៦០នាទី)<br>**មេរៀនទី២:**<br>**ភាពជាប់អនុគមន៍**<br>៤.ភាពជាប់លើចន្លោះ<br>ឧទាហរណ៍១ សិក្សាភាពជាប់នៃអនុគមន៍ $f(x)=\dfrac{2}{x+5}$<br>-ដែនកំណត់នៃអនុគមន៍ $f(Df)$<br>អនុគមន៍ $f$ គ្មានន័យកាលណា<br>$x+5\neq0\Rightarrow x\neq-5$<br>គេបាន $D_f=(-\infty,-5)\cup(-5,+\infty)$<br>នោះ $f$ ជាអនុគមន៍ជាប់គ្រប់តម្លៃ<br>$x\in(-\infty,-5)$ និង $x\in(-5,+\infty)$<br><br>ឧទាហរណ៍ សិក្សាភាពជាប់នៃអនុគមន៍ $g(x)=\begin{cases}5-x\ ,-1\le x\le 2\\ x^2-1\ ,,2\prec x\le 3\end{cases}$<br>ដោយ $y=5-x$ និង $y=x^2-1$ | -សិស្សសង្កេត<br><br>-សិស្សស្ដាប់ |

| | | |
|---|---|---|
| | ជាអនុគមន៍ពហុធា។<br>នោះ $y=5-x$ ជាប់គ្រប់ $x\in(-1,2)$ $(1)$<br>ហើយ $y=x^2-1$ ជាប់គ្រប់ $x\in(2,3)$ $(2)$<br>-ម្យ៉ាងទៀត $g(2)=5-2=3$<br>$\lim\limits_{x\to 2^-} g(x)=\lim\limits_{x\to 2^-}(5-x)=3$<br>$\lim\limits_{x\to 2^+} g(x)=\lim\limits_{x\to 2^+}(x^2-1)=3$<br>គេបាន $\lim\limits_{x\to 2^-} g(x)=\lim\limits_{x\to 2+} g(x)=g(2)$<br>នាំឱ្យ $g$ ជានុគមន៍ជាប់ត្រង់ $x=2$ $(3)$<br>តាម(1), (2) និង (3) គេថា $g$ ជាប់លើចន្លោះបើក $(-1,3)$<br>តែ $g(-1)=5-1=4$ | |
| -បញ្ជាក់ប្រាប់សិស្សថា $g$ ជាអនុគមន៍ជាប់ខាងស្តាំត្រង់ $x=-1$ ។ | $\lim\limits_{x\to 1^+} g(x)=\lim\limits_{x\to 1^+}(5-x)$<br>$\Rightarrow \lim\limits_{x\to 1^+} g(x)=g(1)=4$<br>ហើយ | |
| - បញ្ជាក់ប្រាប់សិស្សថា $g$ ជាអនុគមន៍ជាប់ខាងឆ្វេងត្រង់ $x=3$ | $g(3)=3^2-1=8$<br>$\lim\limits_{x\to 3^-} g(x)=\lim\limits_{x\to 3^-}(x^2-1)=8$<br>$\lim\limits_{x\to 3^-} g(x)=g(3)=8$ | |
| |  | |
| - ដោយ $g$ ជាអនុគមន៍ជាប់លើចន្លោះបើក $(-1,3)$<br>$g$ ខាងស្តាំត្រង់ $x=-1$ និង<br>$g$ ខាងឆ្វេងត្រង់ $x=3$<br>គេថា $g$ ជាប់លើចន្លោះបិ $[-1,3]$ | -និយមន័យ<br>-អនុគមន៍ $f$ ជាប់លើចន្លោះបើក $(a,b)$ លុះត្រាតែ $f$ ជាប់ចំពោះគ្រប់តម្លៃ $x$ ចន្លោះបើកនោះ។ | -សិស្សទាញនិយមន័យ |

| | | |
|---|---|---|
| -ណែនាំឱ្យសិស្សទាញនិយមន័យភាពជាប់នៃអនុគមន៍ $f$ លើចន្លោះបើក $(a,b)$ និងភាពជាប់នៃអនុគមន៍ $f$ លើចន្លោះបិទ $[a,b]$ ។<br><br>-ណែនាំឱ្យសិស្សធ្វើលំហាត់គំរូ | - អនុគមន៍ $f$ ជាប់លើចន្លោះបិទ $[a,b]$ លុះត្រាតែ $f$ ជាប់ចំពោះគ្រប់តម្លៃ $x$ ចន្លោះបើក $(a,b)$ និងមានលីមីត $\lim\limits_{x\to a^+} f(x)=f(a)$ និង $\lim\limits_{x\to b^-} f(x)=f(b)$ "អនុគមន៍ $f$ ជាប់ខាងស្តាំត្រង់ $x=a$ និងជាប់ខាងឆ្វេងត្រង់ $x=b$"<br><br>លំហាត់គំរូ សិក្សាភាពជាប់នៃអនុគមន៍ $f(x)=\dfrac{x+2}{x-3}$ លើចន្លោះ $(2,3)$ និង $[-2,3]$ ។<br>ចម្លើយ<br>សិក្សាភាពជាប់នៃអនុគមន៍ $f$<br>អនុគមន៍ $f$ គ្មានន័យកាលណា<br>$x-3=0 \Rightarrow x=3$<br>នាំឱ្យ $f$ ជាប់ចំពោះចំនួនពិត $x$ លើកលែងតែ $x=3$<br><br>ដូចនេះ $f$ ជាប់លើចន្លោះបើក $(2,3)$ ប៉ុន្តែមិនជាប់លើចន្លោះបិទ $[-2,3]$ ព្រោះត្រង់ $x=3$ អនុគមន៍ $f$ គ្មានន័យ។<br><br><u>៥. ភាពជាប់នៃអនុគមន៍បណ្តាក់</u><br>ឧទាហរណ៍ គេមានអនុគមន៍ $h(x)=Cos\left(x+\dfrac{\pi}{3}\right)$ លើចន្លោះ $(2,3)$ និង $[-2,3]$<br>តាង $f(x)=Cosx$ និង $g(x)=x+\dfrac{\pi}{3}$ | -អនុគមន៍ $f$ ជាប់លើចន្លោះបើក $(a,b)$ លុះត្រាតែ $f$ ជាប់ចំពោះគ្រប់តម្លៃ $x$ ចន្លោះបើកនោះ។<br>- អនុគមន៍ $f$ ជាប់លើចន្លោះបិទ $[a,b]$ លុះត្រាតែ $f$ ជាប់ចំពោះគ្រប់តម្លៃ $x$ ចន្លោះបើក $(a,b)$ និងមានលីមីត $\lim\limits_{x\to a^+} f(x)=f(a)$ និង $\lim\limits_{x\to b^-} f(x)=f(b)$ "អនុគមន៍ $f$ ជាប់ខាងស្តាំត្រង់ $x=a$ និងជាប់ខាងឆ្វេងត្រង់ $x=b$"<br><br>សិក្សាភាពជាប់នៃអនុគមន៍ $f$<br>អនុគមន៍ $f$ គ្មានន័យកាលណា<br>$x-3=0 \Rightarrow x=3$<br>នាំឱ្យ $f$ ជាប់ចំពោះចំនួនពិត $x$ លើក<br>លែងតែ $x=3$<br>ដូចនេះ $f$ ជាប់លើចន្លោះបើក $(2,3)$<br>ប៉ុន្តែមិនជាប់លើចន្លោះបិទ $[-2,3]$<br>ព្រោះត្រង់ $x=3$ អនុគមន៍ $f$ គ្មានន័យ។ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍ឱ្យសិស្សសង្កេតរបៀបតាងអនុគមន៍បណ្ដាក់ | -$g$ ជាអនុគមន៍ជាប់ត្រង់ $x=0$<br>- $f$ ជាអនុគមន៍ជាប់ត្រង់ $g(0)=\frac{\pi}{3}$<br>ដូចនេះ $h=fog$ ជាអនុគមន៍ជាប់ត្រង់ $x=0$ ។ | -សិស្សសង្កេតនិងឆ្លើយ |
| - តាង $f(x)=Cosx$ និង $g(x)=x+\frac{\pi}{3}$<br>នោះ $h(x)=f\left[g(x)\right]$ ជាអនុគមន៍បណ្ដាក់តាងដោយ<br>$(fog)(x)=f\left[g(x)\right]$ | | |
| -តើ $g(x)=x+\frac{\pi}{3}$ ជាប់ត្រង់ $x=0$ ឬទេ?ព្រោះអ្វី?<br>- $f(x)=Cosx$ ជាប់ត្រង់ $x=\frac{\pi}{3}$ ឬទេ?ព្រោះអ្វី? | | -$g$ ជាប់ត្រង់ $x=0$ ព្រោះ $g$ ជាអនុគមន៍ពហុធាជាប់គ្រប់តម្លៃ $x$ ។<br>- $f$ ជាប់ត្រង់ $x=\frac{\pi}{3}$ ព្រោះ $Cosx$ ជាប់គ្រប់តម្លៃ $x$ ។ |
| -បញ្ជាក់ប្រាប់សិស្សថា ដោយ $g(x)$ ជាប់ត្រង់ $x=0$ ហើយ $f(x)$ ជាប់ត្រង់ $x=\frac{\pi}{3}$ ដែល $g(x)=\frac{\pi}{3}$ នាំឱ្យ $h=fog$ ជាប់ត្រង់ $x=0$ ។ | -ជាទូទៅ ៖ បើអនុគមន៍ $g$ ជាប់ត្រង់ $c$ និងអនុគមន៍ $f$ ជាប់ត្រង់ $g(c)$ នោះ អនុគមន៍បណ្ដាក់ $(fog)(x)=f\left[g(x)\right]$ ជាប់ត្រង់ $c$ ។ | -សិស្សស្ដាប់ |
| -ឱ្យសិស្សពិភាក្សាគ្នាទាញសន្និដ្ឋានជាទូទៅ | លំហាត់គំរូ សិក្សាភាពជាប់នៃអនុគមន៍ $h(x)=\left\|\frac{xSinx}{x^2+2}\right\|$ ត្រង់ $x=0$<br>ចម្លើយ<br>សិក្សាភាពជាប់នៃអនុគមន៍<br>តាង $f(x)=\left\|\frac{xSinx}{x^2+2}\right\|$ និង $g(x)=\|x\|$ | -សិស្សទាញជាទូទៅ |
| -ណែនាំសិស្សសង្កេតលើលំហាត់គំរូ | ដោយ $f$ ជានុគមន៍សនិទានជាប់ត្រង់ $x=0$ និង $g$ ជាអនុគមន៍ជាប់ត្រង់ $x=0$ នាំឱ្យអនុគមន៍ $h=(gof)(x)$ ជាប់ត្រង់ $x=0$ ។ | -សិស្សសង្កេត |

| | | |
|---|---|---|
| | | |
| -ចែកកម្រង់លំហាត់ប្រតិបត្តិឱ្យសិស្សធ្វើតាមក្រុម | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>-ប្រត្តិបត្តិ<br>១.គេមានអនុគមន៍ $f$ កំណត់ដោយ $f(x)=\sqrt{\frac{2-x}{3+x}}$ តើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $(-3,2)$ និង $(-3,2]$ ឬទេ?<br>២.រកតម្លៃ $x$ ដែលធ្វើឱ្យអនុគមន៍ជាអនុគមន៍ជាប់ដែល $f(x)=\sqrt{1-x^2}$ | ១. តើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $(-3,2)$ និង $(-3,2]$ ឬទេ?<br>អនុគមន៍ $f$ មានន័យលុះត្រាតែ<br>$\frac{2-x}{3+x}\geq 0$<br>$\Leftrightarrow x\in(-3,2]$<br>ដូចនេះ $f$ ជាអនុគមន៍ជាប់លើ $(-3,2)$ និង $(-3,2]$ ។<br>២.អនុគមន៍ $f$ មានន័យកាលណា<br>$1-x^2\geq 0$<br>$\Leftrightarrow x\in[-1,1]$<br>ដូចនេះ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[-1,1]$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី) | -សិស្សកត់លំហាត់និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

## ជំពូកទី ១ លីមីត

## មេរៀនទី ២ ភាពជាប់នៃអនុគមន៍

I.**វត្ថុបំណងនៃមេរៀន**:ក្រោយពេលរៀនមេរៀននេះចប់សិស្សអាច ៖

- ចំណេះដឹង : បង្ហាញបានពីលក្ខណៈ និងប្រមាណវិធីនៃអនុគមន៍បានត្រឹមត្រូវតាមរយៈឧទាហរណ៍

-បំណិន :បកស្រាយលក្ខណៈ និងប្រមាណវិធីនៃអនុគមន៍ជាប់រយៈឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សមានស្មារតីប្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់

II. **ពេលវេលា** ០២ម៉ោង

III. **សម្ភារៈឧបទេស**

- សៀវភៅសិស្ស :ទំព័រទី ៣០ ដល់ទំព័រទី ៣១
- សៀវភៅគ្រូ : ទំព័រទី ៣០ ដល់ទំព័រទី ៣១

IV.**ខ្លឹមសារមេរៀន**

៣. លក្ខណៈនៃអនុគមន៍ជាប់

IV.**ដំណើរនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមានអនាម័យ សណ្តាប់ធ្នាប់និងវិន័យ | <u>ជំហានទី១</u> (រដ្ឋបាលថ្នាក់) | -ណាងសិស្សឡើងរាយការណ៍ |
| - ចូរឲ្យនិយមន័យភាពជាប់នៃអនុគមន៍ ។ | <u>ជំហានទី២</u> (រំលឹកមេរៀនចាស់) | និយមន័យ អនុគមន៍ $y=f(x)$ ជាប់ត្រង់ $x=c$ កាលណា $f$ បំពេញលក្ខខណ្ឌទាំងបីដូចខាងក្រោម៖<br>$f$ កំណត់ចំពោះ $x=c$<br>$f$ មានលីមីតត្រង់ $x=c$<br>$\lim_{x\to a}\left[f(x)\pm g(x)\right]=\lim_{x\to a}f(x)+\lim_{x\to a}g(x)$ |
| | ជំហានទី៣ (មេរៀនថ្មី)<br>**មេរៀនទី២ភាពជាប់នៃអនុគមន៍**<br>**៣. លក្ខណៈអនុគមន៍** | |

| | | |
|---|---|---|
| - បញ្ហាញលក្ខណៈនៃអនុមន៍ | បើអនុគមន៍ $f$ និង $g$ ជាប់ត្រង់ $x=c$<br>នោះគេបាន<br>$(1).f(x)+g(x)$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x=c$ ។<br>$(2).f(x)-g(x)$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x=c$ ។<br>$(3).f(x)\times g(x)$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x=c$ ។<br>$(4).Kf(x)$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x=c$ ។<br>$(5).\dfrac{f(x)}{g(x)}$ ជាអនុគមន៍ជាប់ត្រង់ចំណុច $x=c$ ដែល $g(x)\neq 0$ | - សង្កេត និង កត់ត្រា |
| - កំណត់ពីភាពជាប់នៃអនុគមន៍លីនេអ៊ែជាអនុគមន៍ជាប់គ្រប់ចំនួនពិត | អនុគមន៍លីនេអ៊ែជាអនុគមន៍ជាប់ចំពោះគ្រប់គ្រប់ចំនួនពិត។ | - សង្កេត និងស្តាប់ |
| - បង្ហាញពីអនុមន៍ពហុធា $p$ ជាប់គ្រប់តម្លៃ $x$ | អនុគមន៍ពហុធាដឺក្រេទី $n$ នៃ $p$ ដែល<br>$p(x)=a_0x^n+a_1x^{n-1}+...+a_n$<br>ដែល $a_1,a_2,...,a_n$ ជាចំនួនពិតហើយ $a_0\neq 0$ ជាអនុគមន៍ជាប់គ្រប់តម្លៃ $x$ ។<br>បើ $c$ ជាចំនួនពិតគេបាន<br>$\lim\limits_{x\to c}p(x)=a_0c^n+a_1c^{n-1}+...+a_n$<br>$=p(c)$<br>ដូចនេះ អនុគមន៍ $p$ ជាប់គ្រប់តម្លៃ $x$ ។ | |
| - អនុគមន៍សនិទាន $R(x)=\dfrac{p(x)}{q(x)}$<br>តើអនុគមន៍ $p$ និង $q$ ជាប់ត្រង់ $x=c$ ឬទេ? | - អនុគមន៍សនិទាន $R(x)=\dfrac{p(x)}{q(x)}$<br>ជាអនុគមន៍ជាប់ចំពោះគ្រប់តម្លៃ $x$ ដែល $q(x)\neq 0$ ។អនុគមន៍ $p$ និង $q$ ជាប់ត្រង់ $x=c$ គេបាន<br>$\lim\limits_{x\to c}p(x)=p(c),\lim\limits_{x\to c}q(x)=q(c)$<br>នោះ $\lim\limits_{x\to c}R(x)=\dfrac{p(x)}{q(x)}=R(c)$<br>គេបាន $R$ ជាអនុគមន៍ជាប់ត្រង់ $x=c$ | - អនុគមន៍ $p$ និង $q$ ជាប់ត្រង់ $x=c$ |

| | | |
|---|---|---|
| - ឲ្យសិស្សសង្កេតមើលអនុគមន៍អសនិទាន និងរកដែនកំណត់<br><br>- ដាក់លំហាត់គំរូឲ្យសិស្សធ្វើ | បើ $x=c$ នាំឲ្យ $q(x)=0$ នោះ $R(x)=\frac{p(x)}{q(x)}$ គ្មានន័យ គេបាន $R$ ជាអនុគមន៍មិនជាប់ត្រង់ $x=c$<br>បើ $x=c$ នាំឲ្យ $q(c)=0$ ទេ។<br>- អនុគមន៍រ៉ាឌីកាល $f(x)=\sqrt[n]{x}$ ជាអនុគមន៍ជាប់គ្រប់តម្លៃ $x$ ក្នុងដែនកំណត់។<br>- អនុគមន៍ត្រីកោណមាត្រ $f(x)=\sin x$ និង $g(x)=\cos x$ ជាអនុគមន៍ជាប់ចំពោះគ្រប់ចំនួនពិត។<br>- អនុគមន៍ $y=\tan x$ ជាអនុគមន៍ជាប់ចំពោះគ្រប់ $x\in\mathbb{R}$ និង $x\neq(2k+1)\frac{\pi}{2}, k\in\mathbb{Z}$ ។<br>- អនុគមន៍ $y=\cot x$ ជាអនុគមន៍ជាប់ចំពោះគ្រប់ $x\in\mathbb{R}$ និង $x\neq k\pi, k\in\mathbb{Z}$ ។<br>លំហាត់គំរូ រកតម្លៃ $x$ ដែលនាំឲ្យអនុគមន៍ខាងក្រោមជាអនុគមន៍ជាប់៖<br>ក. $f(x)=x^{14}+20x^4$<br>ខ. $g(x)=(7x^2+8)(3-x)$<br>គ. $h(x)=\frac{x+3}{x^2-3x-10}$ | - សង្កេត និងកត់ត្រា<br><br>ក. ដោយ $x^{14}$ និង $20x^4$ ជាប់គ្រប់តម្លៃ $x$ នោះ $f(x)=x^{14}+20x^4$ ជាប់គ្រប់តម្លៃ $x$ ។<br>ខ. ដោយ $(7x^2+8)$ និង $(3-x)$ ជាប់គ្រប់តម្លៃ $x$ នោះ $g(x)=(7x^2+8)(3-x)$ ជាប់គ្រប់តម្លៃ $x$ ។<br>គ. អនុគមន៍ $h(x)$ គ្មានន័យកាលណា $x^2-3x-10=0$<br>$\Rightarrow x=5, x=2$<br>ដូចនេះ $h(x)=\frac{x+3}{x^2-3x-10}$ ជាប់គ្រប់តម្លៃ $x\neq5$ និង $x\neq2$ |
| | <u>ជំហានទី ៥</u>( ពង្រឹងពុទ្ធិ ) | |

| | | |
|---|---|---|
| - ដាក់ប្រតិបត្តិឲ្យសិស្សធ្វើ | ប្រតិបត្តិ បង្ហាញថាអនុគមន៍ខាងក្រោមជាអនុគមន៍ជាប់គ្រប់តម្លៃ $x$ នៃដែនកំណត់<br>ក. $f(x)=x^4\left(x+\frac{1}{3}\right)^2$<br>ខ. $g(x)=\frac{x^2+7x-11}{x^3+6x^2+5x-12}$ | ក. $f(x)=x^4\left(x+\frac{1}{3}\right)^2$<br>ដោយ $x^4$ ជាប់គ្រប់ $x\in\mathbb{R}$<br>$\left(x+\frac{1}{3}\right)^2$ ជាប់គ្រប់ $x\in\mathbb{R}$<br>គេបាន $f(x)=x^4\left(x+\frac{1}{3}\right)^2$ ជាអនុគមន៍ជាប់គ្រប់តម្លៃ $x\in\mathbb{R}$ ។<br>ខ. $g(x)=\frac{x^2+7x-11}{x^3+6x^2+5x-12}$<br>អនុគមន៍មានន័យលុះត្រាតែ<br>$x^3+6x^2+5x-12\neq 0$<br>$\Leftrightarrow (x-1)(x+3)(x+4)\neq 0$<br>$\Rightarrow x\neq 1, x\neq -3, x\neq -4$<br>ដូចនេះ $g$ ជាអនុគមន៍ជាប់គ្រប់តម្លៃ $x$ លើកលែងតែ<br>$x=1, x=-3, x=-4$ |
| - ពេលត្រឡប់ទៅផ្ទះវិញប្អូនត្រូវធ្វើលំហាត់ផង ។ | <u>ជំហានទី ៥</u>( បណ្តាំផ្ញើរ ) | -ស្តាប់និងកត់ត្រា |

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា: គណិតវិទ្យា
- ថ្នាក់ទី១២ កម្រិតមូលដ្ឋាន
- ជំពូកទី២: អនុគមន៍ដេរីវេ
- មេរៀនទី១: អនុគមន៍ដេរីវេ
- រយពេល2h

I វត្ថុបំណង

- ចំណេះដឹង: អោយសិស្សចេះគណនាដេរីវេនៃអនុគមន៍ត្រង់ចំណុច $x_0$ និងដេរីវេនៃអនុគមន៍បណ្តាក់។
- ចំណេះធ្វើ: សិស្សធ្វើលំហាត់គណនាដេរីវេនៃអនុគមន៍ត្រង់ចំណុច $x_0$ និងបណ្តាក់បាបលឿនហើយត្រឹមត្រូវ។
- ឥរិយាបថ: សិស្សមានស្មារតីក្លាហានក្នុងការគណនាដេរីវេនៃអនុគមន៍ត្រង់ចំណុច $x_0$ និងអនុគមន៍បណ្តាក់៕

II ខ្លឹមសារមេរៀន

1. ដេរីវេត្រង់ចំណុច $x_0$
2. ដេរីវេនៃអនុគមន៍បណ្តាក់

III សំភារ:ឧបទេស

- សៀវភៅសិស្សទំព័រ $(44 \to 46)$ បោះពុម្ពឆ្នាំ2011
- សៀវភៅគ្រូទំព័រទី

IV វិធីបង្រៀន

គោលវិធីសិស្សមជ្ឈមណ្ឌល

V ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ពិនិត្យអវត្តមានអនាម័យ<br>សណ្តាប់ធ្នាប់សិស្សក្នុងថ្នាក់ | 1. ជំហានទី1 $(3\,\text{min})$<br>- រដ្ឋបាលថ្នាក់រៀន | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| | 2. ជំហានទី2 $(7\,\text{min})$<br>- រំលឹកមេរៀនចាស់ | |

| | | |
|---|---|---|
| -ចូរប្អូនសរសេររូបមន្តដេរីវេ<br>ខាងក្រោម៖<br>$-y=x^n \Rightarrow y^{'}=?$<br>$-y=u^n \Rightarrow y^{'}=?$<br>$-y=\sqrt{x} \Rightarrow y^{'}=?$<br><br>$-y=\sqrt{u} \Rightarrow y^{'}=?$ | $-y^{'}=nx^{n-1}$<br>$-y^{'}=nu^{n-1}$<br>$-y^{'}=\frac{1}{2\sqrt{x}}$<br>$-y^{'}=\frac{u^{'}}{2\sqrt{u}}$ | សិស្សសរសេររូបមន្តលើក្តារខៀន<br><br>$-y'=nx^{n-1}$<br>$-y^{'}=nu^{n-1}$<br>$-y^{'}=\frac{1}{2\sqrt{x}}$<br>$-y^{'}=\frac{u^{'}}{2\sqrt{u}}$ |
| ចែកសិស្សជាក្រុមពិភាក្សា<br>តើដេរីវេត្រង់ $x_0$ នៃអនុគមន៍ $y=f(x)$ គឺជាអ្វី?<br><br>$Ex_1$ :រកដេរីវេត្រង់ $x_0=1$ នៃអនុគមន៍ $y=x^2-2$ ។<br><br>$Ex_2$ : រកដេរីវេត្រង់ $x_0=2$ នៃអនុគមន៍ $y=x^3-1$ ។<br><br>$Ex_3$ : រកដេរីវេត្រង់ $x_0=1$ នៃអនុគមន៍ $y=\sqrt{x}$ ។<br><br>-បើ $y=f(u)$ ហើយ $u=g(x)$ តើ | 3. ជំហានទី3 $(25\,\text{min})$<br>មេរៀនប្រចាំថ្ងៃ<br><br>**ដេរីវេនៃអនុគមន៍**<br><br>1. ដេរីវេនៃអនុគមន៍ត្រង់ $x_0$<br>$-y^{'}=f(x_0)=\lim\limits_{x\to x_0}\frac{f(x)-f(x_0)}{x-x_0}$<br>$=\lim\limits_{h\to 0}\frac{f(x_0+h)-f(x_0)}{h}$<br><br>$-f^{'}(1)=2$<br><br>$-f^{'}(2)=12$<br><br>$-f^{'}(1)=\frac{1}{2}$<br><br>2. ដេរីវេនៃអនុគមន៍បណ្តាក់<br>$y=\frac{d}{dx}f[u(x)]=f'(u)\times u'(x)$<br>$=\frac{dy}{du}\times\frac{du}{dx}$<br>$y'=8x(x^2+21)^3$ | សិស្សពិភាក្សាតាមក្រុម<br>ជាផលធៀបរវាងកំណើនអនុគមន៍<br>និងកំណើនអថេរ។<br>$f^{'}(x)=\lim\limits_{\Delta x\to 0}\frac{\Delta y}{\Delta x}$<br>$=\lim\limits_{x\to x_0}\frac{f(x)-f(x_0)}{x-x_0}$<br>$=\lim\limits_{h\to 0}\frac{f(x_0+h)-f(x_0)}{h}$<br>$-f^{'}(1)=\lim\limits_{x\to 1}\frac{f(x)-f(1)}{x-1}$<br>$=\lim\limits_{x\to 1}\frac{x^2-2+1}{x-1}=2$<br>$-f^{'}(2)=\lim\limits_{x\to 2}\frac{f(x)-f(2)}{x-2}$<br>$=\lim\limits_{x\to 2}\frac{x^3-8}{x-2}=12$<br>$-f^{'}(1)=\lim\limits_{x\to 1}\frac{f(x)-f(1)}{x-1}$<br>$=\lim\limits_{x\to 1}\frac{\sqrt{x}-1}{x-1}=\frac{1}{2}$<br>$y'=\frac{d}{dx}f[u(x)]=f'(u)\times u'(x)$<br>$\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$<br>$y=(x^2+21)^4$<br>$u=x^2+21\Rightarrow\frac{du}{dx}2x$ |

| | | |
|---|---|---|
| $y' = \frac{d}{dx} f[u(x)] = ?$<br>$Ex$ គណនាដេរីវេនៃអនុគមន៍<br>ក. $y = (x^2+21)^4$<br>ខ. $y = (x^3+2x-1)$<br>គ. $-y = \sqrt{x^4-1}$<br><br>តាមរូបមន្តនិងឧទាហរណ៍ខាងលើនេះ តើប្អូនអាចទាញដេរីវេនៃអនុគមន៍ $y = u^n$ ដែល $u$ ជាអនុគមន៍នៃ $x$ បាន យ៉ាងដូចម្តេច?<br>$Ex$ : គណនាដេរីវេនៃអនុគមន៍<br>ក. $y = (x^2+2)^{80}$<br>ខ) $y = 4\sqrt[4]{x^2+2x+5}$ | $y' = 11(3x^2+2)(x^3+2x-1)^{10}$<br><br>$-y' = \frac{2x^3}{\sqrt{x^4-1}}$<br><br>$-y = u^n \Rightarrow y' = nu'u^{n-1}$<br><br>$y' = 160x(x^2+2)^{79}$<br><br>$y' = \frac{2(x+1)}{(x^2+2x+5)^{\frac{3}{4}}}$ | តាង<br>$y = u^4 \Rightarrow \frac{dy}{du} = 4u^3$<br>$\Rightarrow y' = \frac{dy}{dx} = \frac{dy}{du} \times \frac{du}{dx}$<br>$= 8x(x^2+21)^3$<br>$y = (x^3+2x-1)'$<br>តាង $u = x^3+2x-1$<br>$\frac{du}{dx} = 3x^2+2$<br>$y \pm u'' \Rightarrow \frac{dy}{du} = 11u^{10}$<br>$\Rightarrow y' = \frac{dy}{dx} = \frac{dy}{du} \times \frac{du}{dx}$<br>$= 11(3x+2)(x^3+2x-1)^{10}$<br>$-y = \sqrt{x^4-1}$<br>តាង $u = x^4-1$<br>$\frac{du}{dx} = 4x^3 \Rightarrow y = \sqrt{u}$<br>$\frac{dy}{du} = \frac{1}{2\sqrt{u}}$<br>$\Rightarrow y' = \frac{dy}{dx} = \frac{dy}{du} \times \frac{du}{dx} = \frac{2x^3}{\sqrt{x^4-1}}$<br>$y = u^n$ ដោយ $u$ ជាអនុគមន៍នៃ $x$ នោះ: $\frac{du}{dx} = u'$<br>$\Rightarrow y' = \frac{dy}{dx} = \frac{dy}{du} \times \frac{du}{dx}$<br>$y' = nu^{n-1}u'$<br>$y' = nu'u^{n-1}$<br>$y = (x^2+2)^{80}$ មានរាង<br>$y = u^n; u = x^2+2; n = 80$<br>$\Rightarrow y' = 80(x^2+2)'(x^2+2)^{80-1}$<br>$y' = 160x(x^2+2)^{79}$<br><br>$y = 4\sqrt[4]{x^2+2x+5}$<br>$= 4(x^2+2x+5)^{\frac{1}{4}}$<br>រាង $y = u^n; u = x^2+2x+5; n = 4$<br>$\Rightarrow y' = 4 \times \frac{1}{4}(x^2+2x+5)'$ |

| | | |
|---|---|---|
| | | $\times\left(x^2+2x+5\right)^{\frac{1}{4}-1}$<br>$y'=\left(2x+2\right)\left(x^2+2x+5\right)^{-\frac{3}{4}}$<br>$y'=\frac{2\left(x+1\right)}{\left(x^2+2x+5\right)^{\frac{3}{4}}}$ |
| -រកដេរីវេនៃអនុគមន៍<br>$y=4x+1$ ត្រង់ $x_0=1$<br>-រកដេរីវេនៃអនុគមន៍<br>ក) $y=\left(x^2+5x\right)^{10}$<br><br>ខ) $y=\sqrt{x^2+x+1}$ | 4 ជំហានទី 4(12min)<br>ពង្រឹងពុទ្ធិ<br>$-f'(1)=4$<br><br>$-y'=10\left(2x+5\right)\left(x^2+5x\right)^9$<br><br>$-y'=\frac{2x+1}{2\sqrt{x^2+x+1}}$ | $f'(1)=\lim_{x\to1}\frac{f(x)-f(1)}{x-1}$<br>$=\lim_{x\to1}\frac{4x-4}{x-1}$<br>$-y=\left(x^2+5x\right)^{10}$ រាង $y=u^n$<br>ដែល $u=x^2+5x;n=10$<br>$y'=\frac{dy}{dx}=10\left(x^2+5x\right)'\left(x^2+5x\right)^{10-1}$<br>$=10\left(2x+5\right)\left(x^2+5x\right)^9$<br>$-y=\sqrt{x^2+x+1}=\left(x^2+x+1\right)^{\frac{1}{2}-1}$<br>រាង $y=u^n;u=x^2+x+1;n=\frac{1}{2}$<br>$\Rightarrow y'=\frac{dy}{dx}=\frac{1}{2}\left(x^2+x+1\right)'$<br>$\times\left(x^2+x+1\right)^{\frac{1}{2}-1}$ |
| -ប្អូនៗទៅផ្ទះវិញធ្វើលំហាត់ទី1;2ទំព័រ54។ | 5 ជំហានទី 5(3min)<br>-បណ្តាំផ្ញើ | -សិស្សយកបណ្តាំផ្ញើរបស់គ្រូទៅអនុវត្តន៍។ |

# កិច្ចតែងការបង្រៀន

- *មុខវិជ្ជា: គណិតវិទ្យា*
- ថ្នាក់ទី១២ កម្រិតមូលដ្ឋាន
- ជំពូកទី២: អនុគមន៍ដេរីវេ
- មេរៀនទី១: អនុគមន៍ដេរីវេ
- រយៈពេល $2h$

I វត្ថុបំណង

- ចំណេះដឹង: អោយសិស្សចេះគណនាដេរីវេនៃអនុគមន៍ត្រីកោណមាត្រស៊ីនុស កូស៊ីនុស តង់សង់និងកូតង់សង់។
- ចំណេះធ្វើ: សិស្សធ្វើលំហាត់គណនាដេរីវេនៃអនុគមន៍ត្រីកោណមាត្រស៊ីនុស កូស៊ីនុស តង់សង់និងកូតង់សង់ បាបលឿនហើយត្រឹមត្រូវ។
- ឥរិយាបថ:
  សិស្សមានស្មារតីក្លាហានក្នុងការគណនាដេរីវេនៃអនុគមន៍ត្រីកោណមាត្រ

II ខ្លឹមសារមេរៀន

3. ដេរីវេនៃអនុគមន៍ត្រីកោណមាត្រ

3.1 ដេរីវេនៃអនុគមន៍ស៊ីនុសនិងកូស៊ីនុស

3.2 ដេរីវេនៃអនុគមន៍តង់សង់និងកូតង់សង់

III សំភារ:ឧបទេស

- សៀវភៅសិស្សទំពរ័ $(46 \to 50)$ បោះពុម្ពឆ្នាំ2011
- សៀវភៅគ្រូទំពរ័ទី

IV វិធីបង្រៀន

គោលវិធីសិស្សមជ្ឈមណ្ឌល

V ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមានអនាម័យ សណ្តាប់ធ្នាប់សិស្សក្នុងថ្នាក់ | ជំហានទី 1<br>លំនឹងថ្នាក់ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| | | |

| | | |
|---|---|---|
| ជាទូទៅ: $y=u^n$ ដែល $u$ ជា អនុគមន៍នៃ $x$ នោះ $\frac{dy}{dx}=?$ | ជំហានទី 2<br>រំលឹកមេរៀន<br>ដោយ $y=u^n$ ដែល $u$ ជា អនុគមន៍នៃ $x$ នោះ<br>$\frac{dy}{dx}=nu^{n-1}\times\frac{du}{dx}=nu^{n-1}\times u'$ | -ដោយ $y=u^n$ ដែល $u$ ជាអនុគមន៍ នៃ $x$ នោះ<br>$\frac{dy}{dx}=nu^{n-1}\times\frac{du}{dx}=nu^{n-1}\times u'$ |
| -ដាក់ឧទាហរណ៍អោយសិស្សសង្កេត<br>$Ex_1$ :គេអោយអនុគមន៍ $y=\sin x$ កំនត់ចំពោះគ្រប់ $x\in\mathbb{R}$<br>-ណែនាំសិស្សអោយរកដេរីវេ<br>$y=\sin x\Rightarrow y'=?$ | ជំហានទី 3<br>មេរៀនថ្មី<br>3 ដេរីវេនៃអនុគមន៍ត្រីកោណមាត្រ<br>3.1ដេរីវេនៃអនុគមន៍ស៊ីនុសនិងកូស៊ីនុស<br>$Ex_1$ :គេអោយអនុគមន៍ $y=\sin x$ កំនត់ចំពោះគ្រប់ $x\in\mathbb{R}$<br>គេបាន $y'=\lim_{h\to0}\frac{\sin(x+h)-\sin x}{h}$<br>$=\lim_{h\to0}\frac{2\sin\frac{h}{2}\cos(x+h)}{h}$<br>$=\lim_{h\to0}\left[\frac{\sin\frac{h}{2}}{\frac{h}{2}}\cos\left(x+\frac{h}{2}\right)\right]$<br>$=1\times\cos x=\cos x$ | សិស្សសង្កេតមើលឧទាហរណ៍ គេបាន<br>$y'=\lim_{h\to0}\frac{\sin(x+h)-\sin x}{h}$<br>$=\lim_{h\to0}\frac{2\sin\frac{h}{2}\cos(x+h)}{h}$<br>$=\lim_{h\to0}\left[\frac{\sin\frac{h}{2}}{\frac{h}{2}}\cos\left(x+\frac{h}{2}\right)\right]$<br>$=1\times\cos x=\cos x$ |
| $Ex_2$ : គេអោយ $y=\cos x$ កំណត់ចំពោះគ្រប់ $x\in\mathbb{R}$<br>-ណែនាំសិស្សអោយគណនា<br>$y=\cos x\Rightarrow y'=?$ | ដូចនេះ $y'=\cos x$<br>$Ex_2$ : គេអោយ $y=\cos x$ កំណត់ចំពោះគ្រប់ $x\in\mathbb{R}$<br>គេបាន $y'=\lim_{h\to0}\frac{\cos(x+h)-\cos x}{h}$<br>$=\lim_{h\to0}\frac{-2\sin\frac{h}{2}\left[\sin\left(x+\frac{h}{2}\right)\right]}{h}$<br>$=\lim_{h\to0}\left[\frac{-\sin\frac{h}{2}}{\frac{h}{2}}\sin\left(x+\frac{h}{2}\right)\right]$<br>$=-1\times\sin x=-\sin x$<br>ដូចនេះ $y'=-\sin x$ | ដូចនេះ $y'=\cos x$<br>សិស្សដេរីវេ $y=\cos x$<br>$y'=\lim_{h\to0}\frac{\cos(x+h)-\cos x}{h}$<br>$=\lim_{h\to0}\frac{-2\sin\frac{h}{2}\left[\sin\left(x+\frac{h}{2}\right)\right]}{h}$<br>$=\lim_{h\to0}\left[\frac{-\sin\frac{h}{2}}{\frac{h}{2}}\sin\left(x+\frac{h}{2}\right)\right]$<br>$=-1\times\sin x=-\sin x$<br>ដូចនេះ $y'=-\sin x$ |

| | | |
|---|---|---|
| $Ex_3$ : គេអោយ<br>$y=\sin\left(x^2-3\right)$<br>អោយសិស្សគណនា $y'$<br><br>-<br>អោយសិស្សទាញរករាងទូទៅនៃអនុគមន៍ដេរីវេ<br>អនុគមន៍ត្រីកោណមាត្រ<br>ត្រង់ដេរីវេនៃអនុគមន៍<br>ស៊ីនុសនិងកូស៊ីនុស<br><br>អោយសិស្សដោះស្រាយលំហាត់គំរូ<br>1.គណនាដេរីវេនៃអនុគមន៍ចំពោះគ្រប់<br>$x\in\mathbb{R}$<br>ក).<br>$f(x)=\sin x-x\cos x$<br>ខ<br>$f(x)=\cos^2 x+x\sin x$<br>2. គណនាដេរីវេនៃអនុគមន៍ខាងក្រោម | $Ex_3$ : គេអោយ $y=\sin\left(x^2-3\right)$<br>គេតាង $u=-3+x^2; y=\sin x$<br>គេបាន $\frac{du}{dx}=2x$ និង $\frac{dy}{du}=\cos u$<br>$\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$<br>$=2x\times\cos u$<br>$=2x\cos\left(x^2-3\right)$<br>ដូចនេះ $y'=2x\cos\left(x^2-3\right)$<br><br>ជាទូទៅ<br>បើ $y=\sin x\Rightarrow y'=\cos x$<br>បើ $y=\cos x\Rightarrow y'=-\sin x$<br>បើ $y=\sin u\Rightarrow y'=u'\sin u$<br>បើ $y=\cos u\Rightarrow y'=-u'\sin u$<br>លំហាត់គំរូ1<br>1គណនាដេរីវេនៃអនុគមន៍<br>ចំពោះគ្រប់ $x\in\mathbb{R}$<br><br>ក). $f(x)=\sin x-x\cos x$<br>ខ). $f(x)=\cos^2 x+x\sin x$<br>**<u>ចម្លើយ</u>**<br>ក) $f(x)=\sin x-x\cos x$<br>ដោយ $(u+v)'=u'+v'$<br>$(u\times v)'=u'v+v'u$<br>គេបាន<br>$f'(x)=\cos x-\left[x'\cos x+(\cos x)'x\right]$<br>$=\cos x-\cos x+x\sin x$<br>$=x\sin x$<br>ដូចនេះ $f'(x)=x\sin x$<br>ខ) $f(x)=\cos^2 x+x\sin x$<br>ដោយ $(u+v)'=u'+v'$<br>$(u\times v)'=u'v+v'u$<br>គេបាន $f'(x)=2\cos x(\cos x)'$ | -គណនា $y'$ ចំពោះ<br>$y=\sin\left(x^2-3\right)$<br>គេតាង $u=-3+x^2; y=\sin x$<br>គេបាន $\frac{du}{dx}=2x$ និង $\frac{dy}{du}=\cos u$<br>$\frac{dy}{dx}=\frac{dy}{du}\times\frac{du}{dx}$<br>$=2x\times\cos u$<br>$=2x\cos\left(x^2-3\right)$<br>ដូចនេះ $y'=2x\cos\left(x^2-3\right)$<br>ជាទូទៅ<br>បើ $y=\sin x\Rightarrow y'=\cos x$<br>បើ $y=\cos x\Rightarrow y'=-\sin x$<br>បើ $y=\sin u\Rightarrow y'=u'\sin u$<br>បើ $y=\cos u\Rightarrow y'=-u'\sin u$<br>ដោះស្រាយលំហាត់គំរូ1<br>1គណនាដេរីវេនៃអនុគមន៍<br>ចំពោះគ្រប់ $x\in\mathbb{R}$<br>ក). $f(x)=\sin x-x\cos x$<br>ដោយ $\begin{cases}(u+v)'=u'+v'\\(u.v)'=u'v+v'u\end{cases}$<br>គេបាន<br>$f'(x)=\cos x-$<br>$\left[x'\cos x+(\cos x)'x\right]$<br>$=\cos x-\cos x+x\sin x$<br>$=x\sin x$<br>ដូចនេះ $f'(x)=x\sin x$<br>ខ). $f(x)=\cos^2 x+x\sin x$<br>$(u^n)'=nu^{n-1}\times u'$<br>$(u+v)'=u'+v'$<br>$(u\times v)'=u'v+v'u$<br>គេបាន $f'(x)=2\cos x(\cos x)'$<br>$+\left[x'\sin x+x(\sin x)'\right]$<br>$=-2\cos x\sin x+(\sin x+\cos x)$<br>$=-\sin 2x+\sin x+\cos x$<br>ដូចនេះ |

ក). $f(x)=-3x^4$

$+\sin(2x^3-1)$

$+\left[x'\sin x+x(\sin x)'\right]$

$=-2\cos x\sin x+(\sin x+\cos x)$

$=-\sin 2x+\sin x+\cos x$

ដូចនេះ

$f'(x)=-\sin 2x+\cos x+\sin x$

## លំហាត់ទី២

គណនាអនុគមន៍ខាងក្រោម:

ក) $f(x)=-3x^4+\sin(2x^3-1)$

ខ) $f(x)=x^2\cos(3x+1)$

## ចម្លើយ

ក) $f(x)=-3x^4+\sin(2x^3-1)$

តាមរូបមន្ត $(x^n)'=nx^{n-1}$

$(\sin u)'=u'\cos u$

$f'(x)=-12x^3+6x^2\cos(2x^3-1)$

ដូចនេះ

$f'(x)=-12x^3+6x^2\cos(2x^3-1)$

ខ) $f(x)=x^2\cos(3x+1)$

តាមរូបមន្ត $(u\times v)'=u'v+v'u$

$(\cos u)'=-u'\sin u$

គេបាន

$f'(x)=(x^2)'\cos(3x+1)$

$+x^2\left[\cos(3x+1)\right]$

$=2x\cos(3x+1)$

$+x^2\left[-3\sin(3x+1)\right]$

$=2x\cos(3x+1)-3x^2\sin(3x+1)$

ដូចនេះ

$f'(x)=2x\cos(3x+1)$

$-3x^2\sin(3x+1)$

## ប្រតិបត្តិ

គណនាដេរីវេនៃអនុគមន៍ខាងក្រោម:

ក) $f(x)=x^3\cos x+2\sin x$

ខ) $f(x)=\cos(5x^4-3)+x\sin 2x$

$f'(x)=-\sin 2x+\cos x+\sin x$

## ចម្លើយ

ក) $f(x)=-3x^4+\sin(2x^3-1)$

តាមរូបមន្ត $(x^n)'=nx^{n-1}$

$(\sin u)'=u'\cos u$

ដូចនេះ

$f'(x)=-12x^3+6x^2\cos(2x^3-1)$

ខ) $f(x)=x^2\cos(3x+1)$

$f'(x)=-12x^3+6x^2\cos(2x^3-1)$

តាមរូបមន្ត $(u\times v)'=u'v+v'u$

$(\cos u)'=-u'\sin u$

គេបាន

$f'(x)=(x^2)'\cos(3x+1)$

$+x^2\left[\cos(3x+1)\right]$

$=2x\cos(3x+1)$

$+x^2\left[-3\sin(3x+1)\right]$

$=2x\cos(3x+1)-3x^2\sin(3x+1)$

ដូចនេះ

$f'(x)=2x\cos(3x+1)$

$-3x^2six(3x+1)$

| | | |
|---|---|---|
| អោយសិស្សពិភាក្សា<br>ប្រតិបត្តិ<br>គណនាដេរីវេនៃ<br>អនុគមន៍ខាងក្រោម:<br>ក) $f(x)=x^3\cos x+2\sin x$<br><br>ខ)<br>$f(x)=\cos\left(5x^4-3\right)$<br>$+x\sin 2x$ | | ពិភាក្សារួចឡើងធ្វើ<br>ក) $f(x)=x^3\cos x+2\sin x$<br>តាមរូបមន្ត $(u+v)'=u'+v'$<br>$(u\times v)'=u'v+v'u$<br>$+\left[(2)'\sin x+2(\sin x)'\right]$<br>$=3x^2\cos x-x^3\sin x+2\cos x$<br>ដូចនេះ<br>$f'(x)=3x^2\cos x-x^3\sin x$<br>$+2\cos x$<br>ខ) $f(x)=\cos\left(5x^4-3\right)+x\sin 2x$<br>$f'(x)=\left[\cos\left(5x^4-3\right)\right]'$<br>$+[x\sin 2x]'$<br>$=-20x^3\sin\left(5x^4-3\right)$<br>$+\sin 2x+2x\cos 2x$<br>ដូចនេះ<br>$f'(x)=-20x^3\sin\left(5x^4-3\right)$<br>$+\sin 2x+2x\cos 2x$ |
| អោយឧទាហរណ៍សិស្ស<br>Ex$_1$ គេអោយ $y=\tan x$<br>ចំពោះ $x\neq\frac{\pi}{2}+k\pi,k\in\mathbb{Z}$<br>អោយសិស្សគណនា $y'$ | 3.2ដេរីវេអនុគមន៍តង់សង់និងកូតង់សង់<br>Ex$_1$ គេអោយ $y=\tan x$ ចំពោះ<br>$x\neq\frac{\pi}{2}+k\pi,k\in\mathbb{Z}$<br>គេអាចសរសេរ $y=\frac{\sin x}{\cos x}$<br>គេបាន $y'=\left(\frac{\sin x}{\cos x}\right)'$<br>$=\frac{(\sin x)'\cos x-(\cos x)'\sin x}{\cos^2 x}$<br>$=\frac{\cos x\cos x+\sin x\sin x}{\cos^2 x}$<br>$=\frac{\cos^2 x+\sin^2 x}{\cos^2 x}$<br>$=\frac{1}{\cos^2 x}=1+\tan^2 x$ | គណនា $y'$ ដោយ $y=\tan x$<br>ចំពោះ $x\neq\frac{\pi}{2}+k\pi,k\in\mathbb{Z}$<br>ដោយ $y=\tan x$ គេអាចសរសេរ<br>$y=\frac{\sin x}{\cos x}$ គេបាន $y'=\left(\frac{\sin x}{\cos x}\right)'$<br>$=\frac{(\sin x)'\cos x-(\cos x)'\sin x}{\cos^2 x}$<br>$=\frac{\cos x\cos x+\sin x\sin x}{\cos^2 x}$<br>$=\frac{\cos^2 x+\sin^2 x}{\cos^2 x}$<br>$=\frac{1}{\cos^2 x}=1+\tan^2 x$<br><br>ដូចនេះ $y'=\frac{1}{\cos^2 x}=1+\tan^2 x$ |

| | | |
|---|---|---|
| អោយឧទាហរណ៍សិស្ស<br>Ex₂គេអោយ $y=\cot x$<br>ចំពោះ $x\neq k\pi, k\in\mathbb{Z}$<br>អោយសិស្សគណនា $y'$ | ដូចនេះ $y'=\frac{1}{\cos^2 x}=1+\tan^2 x$<br>Ex₂គេអោយ $y=\cot x$<br>ចំពោះ $x\neq k\pi, k\in\mathbb{Z}$<br>គេអាចសរសេរ $y=\left(\frac{\cos x}{\sin x}\right)$<br>$y'=\left(\frac{\cos x}{\sin x}\right)'$<br>$=\frac{(\cos x)'\sin x-(\sin x)'\cos x}{\sin^2 x}$<br>$=\frac{-\sin x\sin x-\cos x\cos x}{\sin^2 x}$<br>$=-\left(\frac{\sin^2 x+\cos^2 x}{\sin^2 x}\right)$<br>$=-\frac{1}{\sin^2 x}=-\left(1+\cot^2 x\right)$<br>ដូចនេះ $y'=-\frac{1}{\sin^2 x}=-\left(1+\cot^2 x\right)$<br><br>ជាទូទៅ<br>បើ $y=\tan x$ នោះ $y'=\frac{1}{\cos^2 x}$<br>$=1+\tan^2 x$<br>បើ $y=\cot x$ នោះ $y'=-\frac{1}{\sin^2}$<br>$=-\left(1+\cot^2 x\right)$<br>បើ $y=\tan u$ នោះ $y'=\frac{u'}{\cos^2 u}$<br>$=u'\left(1+\tan^2 u\right)$<br>បើ $y=\cot u$ នោះ $y'=-\frac{u'}{\sin^2 u}$<br>$=-u'\left(1+\cot^2 u\right)$<br><br><u>លំហាត់គំរូ1</u><br>ក) $f(x)=x^3\tan x$<br>ខ) $f(x)=(2+\cot x)^3$ | គណនា $y'$ ដោយ $y=\cot x$<br>ចំពោះ $x\neq k\pi, k\in\mathbb{Z}$<br>គេអាចសរសេរ $y=\left(\frac{\cos x}{\sin x}\right)$<br>$y'=\left(\frac{\cos x}{\sin x}\right)'$<br>$=\frac{(\cos x)'\sin x-(\sin x)'\cos x}{\sin^2 x}$<br>$=\frac{-\sin x\sin x-\cos x\cos x}{\sin^2 x}$<br>$=-\left(\frac{\sin^2 x+\cos^2 x}{\sin^2 x}\right)$<br>$=-\frac{1}{\sin^2 x}=-\left(1+\cot^2 x\right)$<br>ដូចនេះ $y'=-\frac{1}{\sin^2 x}$<br>$=-\left(1+\cot^2 x\right)$<br>ជាទូទៅ<br>បើ $y=\tan x$ នោះ $y'=\frac{1}{\cos^2 x}$<br>$=1+\tan^2 x$<br>បើ $y=\cot x$ នោះ $y'=-\frac{1}{\sin^2}$<br>$=-\left(1+\cot^2 x\right)$<br>បើ $y=\tan u$ នោះ $y'=\frac{u'}{\cos^2 u}$<br>$=u'\left(1+\tan^2 u\right)$<br>បើ $y=\cot u$ នោះ $y'=-\frac{u'}{\sin^2 u}$<br>$=-u'\left(1+\cot^2 u\right)$<br><br>ដោះស្រាយលំហាត់គំរូ<br>ក) $f(x)=x^3\tan x$<br>តាមរូបមន្ត $(u\times v)'=u'v+v'u$<br>គេបាន |

| | | |
|---|---|---|
| អោយសិស្សដោះស្រាយលំហាត់គំរូ<br>រកដេរីវេនៃអនុគមន៍ខាងក្រោម<br>ក) $f(x)=x^3\tan x$<br>ខ) $f(x)=(2+\cot x)^3$<br><br>អោយសិស្សពិភាក្សាដោះ<br>ស្រាយលំហាត់ប្រតិបត្តិ<br>រកដេរីវេនៃអនុគមន៍ខាងក្រោម<br>ក) $f(x)=3x^2\tan^3 x$<br>ខ) $f(x)=(1+\tan x)^2$<br>គ)<br>$f(x)=3\cot(x^4-3)$<br>ឃ) | រកដេរីវេនៃអនុគមន៍ខាងលើ<br>ចម្លើយ<br>ក) $f(x)=x^3\tan x$<br>តាមរូបមន្ត $(u\times v)'=u'v+v'u$<br>គេបាន<br>$f'(x)=(x^3)'\tan x+x^3(\tan x)'$<br>$=3x^2\tan x+x^3\frac{1}{\cos^2 x}$<br>ដូចនេះ<br>$f'(x)=3x^2\tan x+x^3\frac{1}{\cos^2 x}$<br>ខ) $f(x)=(2+\cot x)^3$<br>តាមរូបមន្ត $u^n=u'nu^{n-1}$<br>$(u+v)'=u'+v'$ គេបាន<br>$f'(x)=3(2+\cot x)^2\left(-\frac{1}{\sin^2 x}\right)$<br>ដូចនេះ $f'(x)=-\frac{3(2+\cot x)^2}{\sin^2 x}$<br>ប្រតិបត្តិ<br>រកដេរីវេនៃអនុគមន៍ខាងក្រោម<br>ក) $f(x)=3x^2\tan^3 x$<br>ខ) $f(x)=(1+\tan x)^2$<br>គ) $f(x)=3\cot(x^4-3)$<br>ឃ) $f(x)=x\tan(2x^2-3)$ | $f'(x)=(x^3)'\tan x+x^3(\tan x)'$<br>$=3x^2\tan x+x^3\frac{1}{\cos^2 x}$<br>ដូចនេះ<br>$f'(x)=3x^2\tan x+x^3\frac{1}{\cos^2 x}$<br>ខ) $f(x)=(2+\cot x)^3$<br>តាមរូបមន្ត $u^n=u'nu^{n-1}$<br>$(u+v)'=u'+v'$ គេបាន<br>$f'(x)=3(2+\cot x)^2\left(-\frac{1}{\sin^2 x}\right)$<br>ដូចនេះ $f'(x)=-\frac{3(2+\cot x)^2}{\sin^2 x}$<br>ពិភាក្សារួចឡើងធ្វើ<br>ក) $f(x)=3x^2\tan^3 x$<br>តាមរូបមន្ត $(u\times v)'=u'v+v'u$<br>$f'(x)=(3x^2)'\tan^3 x$<br>$+3x^2(\tan^3 x)'$<br>$=6x\tan^3 x+\tan^2 x\frac{9x^2}{\cos^2 x}$<br>ដូចនេះ<br>$f'(x)=6x\tan^3 x+\tan^2 x\frac{9x^2}{\cos^2 x}$<br>ខ) $f(x)=(1+\tan x)^2$<br>តាមរូបមន្ត $u^n=nu^{n-1}u'$<br>គេបាន $f'(x)=\left[(1+\tan x)^2\right]'$<br>$=2(1+\tan x)\frac{1}{\cos^2 x}$<br>ដូចនេះ $f'(x)=\frac{2(1+\tan x)}{\cos^2 x}$<br>គ) $f(x)=3\cot(x^4-3)$<br>$f'(x)=\left[3\cot(x^4-3)\right]'$ |

| | | |
|---|---|---|
| $f(x)=x\tan\left(2x^2-3\right)$ | | $=3\left[-\dfrac{4x^3}{\sin^2\left(x^4-3\right)}\right]$<br>ដូចនេះ $f'(x)=-\dfrac{12x^3}{\sin^2\left(x^4-3\right)}$<br>ឃ) $f(x)=x\tan\left(2x^2-3\right)$<br>$f'(x)=\left[x\tan\left(2x^2-3\right)\right]'$<br>$=(x)'\tan\left(2x^2-3\right)$<br>$+x\left[\tan\left(2x^2-3\right)\right]'$<br>$=\tan\left(2x^2-3\right)$<br>$+x\left[4x\dfrac{1}{\cos^2\left(2x^2-3\right)}\right]$<br>ដូចនេះ $f'(x)=\tan\left(2x^2-3\right)+\dfrac{4x^2}{\cos^2\left(2x^2-3\right)}$ |
| សួរសិស្សថាតើបើ<br>$y=\tan x, y=\cos x,$<br>$y=\sin x, y=\cot x$<br>$y=\tan u, y=\sin u,$<br>$y=\cos x, y=\cot u$<br>តើ $y'$ វាស្មើនឹងប៉ុន្មានបើ<br>$y=\tan x$ ចំពោះ<br>$x\neq\dfrac{\pi}{2}+k\pi$<br>$y=\cot x$ ចំពោះ<br>$x\neq k\pi, k\in\mathbb{Z}$ | **<u>ជំហានទី4</u>**<br>**<u>ពង្រឹងចំនេះដឹង</u>**<br>$y=\tan x\Rightarrow y'=\dfrac{1}{\cos^2 x}=1+\tan^2 x$<br>$y=\cos x\Rightarrow y'=-\sin x$<br>$y=\cot x\Rightarrow y'=-\dfrac{1}{\sin^2 x}$<br>$=-\left(1+\cot^2 x\right)$<br>$y=\sin x\Rightarrow y'=\cos x$<br>$y=\tan u\Rightarrow y'=\dfrac{u'}{\cos^2 u}$<br>$y=\sin u\Rightarrow y'=\cos u$<br>$y=\cot u\Rightarrow y'=-\dfrac{u'}{\sin^2 u}$<br>$y=\cos u\Rightarrow y'=-u'\sin u$ | |
| អោយសិស្សធ្វើលំហាត់ក្នុងសៀវភៅទំព័រទី៥៥ | **<u>ជំហានទី5</u>**<br><u>បណ្តាំផ្ញើ</u><br>អោយសិស្សធ្វើលំហាត់ក្នុង | ស្តាប់រួចយកលំហាត់ដែលគ្រូដាក់អោយធ្វើនៅផ្ទះ |

| | | |
|---|---|---|
| ត្រង់លេខ៨និង៩ | សៀវភៅទំព័រទី៥៥ត្រង់លេខ៨និង៩ | |

# កិច្ចតែងការបង្រៀន

- *មុខវិជ្ជា: គណិតវិទ្យា*
- ថ្នាក់ទី១២ កម្រិតមូលដ្ឋាន
- ជំពូកទី២: ដេរីវេនៃអនុគមន៍
- មេរៀនទី១: ដេរីវេនៃអនុគមន៍
- រយពេល2h

I វត្ថុបំណង

- ចំណេះដឹង: អោយសិស្សចេះគណនាដេរីវេទី២និងដេរីវេលំដាប់ខ្ពស់
- ចំណេះធ្វើ: សិស្សធ្វើលំហាត់គណនាដេរីវេទី២និងដេរីវេលំដាប់ខ្ពស់ បាបលឿនហើយត្រឹមត្រូវ។
- ឥរិយាបថ: សិស្សមានស្មារតីក្លាហានក្នុងការគណនាដេរីវេទី២និងដេរីវេលំដាប់ខ្ពស់៕

II ខ្លឹមសារមេរៀន

4 ដេរីវេលំដាប់ខ្ពស់

4.1 ដេរីវេទី២នៃអនុគមន៍

4.2 ដេរីវេលំដាប់ខ្ពស់

III សំភារ:ឧបទេស

- សៀវភៅសិស្សទំព័រ $(51 \to 53)$ បោះពុម្ពឆ្នាំ2011
- សៀវភៅគ្រូទំព័រទី

IV វិធីបង្រៀន

គោលវិធីសិស្សមជ្ឈមណ្ឌល

V សកម្មភាពបង្រៀន និងរៀន

| សកម្មភាពគ្រូបង្រៀន | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមានអនាម័យ សណ្តាប់ធ្នាប់សិស្សក្នុងថ្នាក់ | ជំហានទី១<br>លំនឹងថ្នាក់រៀន | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូអោយសិស្សឡើងធ្វើលំហាត់គណនាដេរីវេនៃអនុគមន៍ខាងក្រោម<br>ក) $f(x)=x^3\tan x$<br>ខ) $f(x)=3x^2+\tan\left(x^3-1\right)$ | ជំហានទី២<br>រំលឹកមេរៀនចាស់<br>គណនាដេរីវេនៃអនុគមន៍ខាងក្រោម<br>ក) $f(x)=x^3\tan x$<br>ខ) $f(x)=3x^2+\tan\left(x^3-1\right)$<br>ក) $f(x)=x^3\tan x$ | សិស្សឡើងធ្វើលំហាត់<br>ក) $f(x)=x^3\tan x$<br>តាមរូបមន្ត<br>$(uv)'=u'v+v'u$<br>គេបាន |

| | | |
|---|---|---|
| | តាមរូបមន្ត $(uv)' = u'v + v'u$<br>គេបាន<br>$f'(x) = (x^3)'\tan x + x^3(\tan x)'$<br>$= 3x^2\tan x + \frac{x^3}{\cos^2 x}$<br>ដូចនេះ<br>$f'(x) = 3x^2\tan x + \frac{x^3}{\cos^2 x}$ | $f'(x) = (x^3)'\tan x$<br>$+ x^3(\tan x)'$<br>$= 3x^2\tan x + \frac{x^3}{\cos^2 x}$<br>ដូចនេះ<br>$f'(x) = 3x^2\tan x + \frac{x^3}{\cos^2 x}$ |
| គ្រូសរសេរចំណងជើងមេរៀនថ្មីដាក់លើក្តារខៀន<br>គ្រូអោយសិស្សសង្កេតលើឧទាហរណ៍ទី១<br>គេអោយអនុគមន៍<br>$f(x) = x^4 - 3x^2 + 1$<br>$f'(x) = 4x^3 - 6x$<br>$f''(x) = 12x^2 - 6$<br>ដូចនេះ $f''(x) = 12x^2 - 6$<br>គ្រូពន្យល់និងប្រាប់លក្ខណះទូទៅនៃដេរីវេទី២ នៃអនុគមន៍ $y = f(x)$ កំនត់តាងតាងដោយ $y'' = f''(x)$<br>ឬ $\frac{d^2y}{dx^2}$<br>គ្រូអោយសិស្សពិនិត្យលើលំហាត់គំរូទី១<br>គណនា $f'(x)$ និង $f''(x)$ នៃអនុគមន៍ខាងក្រោម<br>ក) $f(x) = x^3 - 12x + 1$<br>ខ) $f(x) = \frac{x^2}{x^2 - 9}$<br>__ចម្លើយ__<br>ក) $f(x) = x^3 - 12x + 1$ | __ជំហានទី៣__<br>មេរៀនថ្មី<br>4 ដេរីវេលំដាប់ខ្ពស់<br>4.1 ដេរីវេទី២នៃអនុគមន៍<br><br>ឧទាហរណ៍ទី១គេអោយអនុគមន៍ $f(x) = x^4 - 3x^2 + 1$<br>$f'(x) = 4x^3 - 6x$<br>$f''(x) = 12x^2 - 6$<br>ដូចនេះ $f''(x) = 12x^2 - 6$<br><br>__ជាទូទៅ__<br>ដេរីវេទី២នៃអនុគមន៍ $y = f(x)$ កំនត់តាងដោយ $y'' = f''(x)$<br>ឬ $\frac{d^2y}{dx^2}$<br><br>លំហាត់គំរូទី១<br>គណនា $f'(x)$ និង $f''(x)$ នៃអនុគមន៍ខាងក្រោម<br>ក) $f(x) = x^3 - 12x + 1$<br>ខ) $f(x) = \frac{x^2}{x^2 - 9}$<br>__ចម្លើយ__<br>ក) $f(x) = x^3 - 12x + 1$<br>គេបាន $f'(x) = 3x^2 - 12$ | សិស្សយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់និងសិស្សសង្កេតនិងកត់ត្រាចូលសៀវភៅ<br><br>សិស្សស្តាប់ការនែនាំរបស់គ្រូ<br><br>សិស្សពិនិត្យយ៉ាងយកចិត្តទុកដាក់ហើយចំលងលំហាត់គំរូនេះដាក់ក្នុងសៀវភៅ |

| | | |
|---|---|---|
| គេបាន $f'(x)=3x^2-12$<br>នោះ $f''(x)=6x$<br>ដូចនេះ $f'(x)=3x^2-12$<br>$f''(x)=6x$<br>ខ) $f(x)=\frac{x^2}{x^2-9}$<br>គេបាន<br>$f'(x)=\frac{2x(x^2-9)-x^2\times 2x}{(x^2-9)^2}$<br>$=-\frac{18x}{(x^2-9)^2}$<br>$f''(x)=\frac{-18(x^2-9)}{(x^2-9)^4}$<br>$+\frac{18x\times 2(x^2-9)2x}{(x^2-9)^4}$<br>$=\frac{-18(x^2-9)(x^2-9-4x^2)}{(x^2-9)^4}$<br>$=\frac{54(x^2+3)}{(x^2-9)^3}$<br>ដូចនេះ $f'(x)=-\frac{18x}{(x^2-9)^2}$<br>$f''(x)=\frac{54(x^2+3)}{(x^2-9)^3}$<br>គ្រូអោយសិស្សសង្កេត លំហាត់គំរូទី២<br>រក $y'$ និងយ $y''$ ជាអនុគមន៍នៃ $x$ និង $y$<br>ក) $x^2+y^2=4$<br>ខ) $xy+y^2-x^2=5$<br>ចម្លើយ<br>ក. រក $y'$ នៃ $x^2+y^2=4$ ដេរីវេ អង្គទាំងពីរ<br>$\frac{d}{dx}(x^2+y^2)=\frac{d}{dx}(4)$ | នោះ $f''(x)=6x$<br>ដូចនេះ $f'(x)=3x^2-12$<br>$f''(x)=6x$<br>ខ) $f(x)=\frac{x^2}{x^2-9}$<br>គេបាន<br>$f'(x)=\frac{2x(x^2-9)-x^2\times 2x}{(x^2-9)^2}$<br>$=-\frac{18x}{(x^2-9)^2}$<br>$f''(x)=-\frac{18(x^2-9)^2+54x^2(x^2-9)}{(x^2-9)^4}$<br>$=\frac{-18(x^2-9)(x^2-9-4x^2)}{(x^2-9)^4}$<br>$=\frac{54(x^2+3)}{(x^2-9)^3}$<br>ដូចនេះ $f'(x)=-\frac{18x}{(x^2-9)^2}$<br>$f''(x)=\frac{54(x^2+3)}{(x^2-9)^3}$<br>លំហាត់គំរូទី២<br>រក $y'$ និងយ $y''$ ជាអនុគមន៍នៃ $x$ និង $y$<br>ក) $x^2+y^2=4$<br>ខ) $xy+y^2-x^2=5$<br>ចម្លើយ<br>ក. រក $y'$ នៃ $x^2+y^2=4$ ដេរីវេ អង្គទាំងពីរ<br>$\frac{d}{dx}(x^2+y^2)=\frac{d}{dx}(4)$<br>$\frac{d}{dx}(x^2)+\frac{d}{dx}(y^2)=\frac{d}{dx}(4)$ | សិស្សពិនិត្យនិងតាមដាន លើលំហាត់គំរូទី២យ៉ាង ម៉ត់ចត់និងកត់ត្រាចូលក្នុង សៀវភៅ។ |

<table>
<tr>
<td>
$\frac{d}{dx}\left(x^2\right)+\frac{d}{dx}\left(y^2\right)=\frac{d}{dx}(4)$<br>
$2x+2y\frac{dy}{dx}=0$<br>
$2x+2yy'=0, \frac{dy}{dx}=y'$<br>
ដូចនេះ $y'=-\frac{x}{y}$ បើ $y\neq 0$<br>
រក $y''$ នៃ $x^2+y^2=4$<br>
$x+yy'=0$ នោះ $y''=\frac{-1-\left(y'\right)^2}{y}$<br>
ដោយ $y'=-\frac{x}{y}, y\neq 0$<br>
ដូចនេះ $y''=-\frac{x^2+y^2}{y^3}$<br>
ខ) $xy+y^2-x^2=5$<br>
រក $y'$ នៃ $xy+y^2-x^2=5$<br>
ដេរីវេអង្គទាំងពីរ<br>
គេបាន<br>
$\frac{d}{dx}\left(xy+y^2-x^2\right)=\frac{d}{dx}(5)$<br>
$\left(y+xy'\right)+2yy'-2x=0$<br>
$y+\left(x+2y\right)y'-2x=0$<br>
ដូចនេះ $y'=\frac{2x-y}{x+2y}$<br>
រក $y''$ នៃ $xy+y^2-x^2=5$<br>
គេបាន<br>
$y'+y'+xy''+2y'y'+1yy''-2=0$<br>
$\left(x+2y\right)y''=2-2y'-2\left(y'\right)^2$<br>
$y''=\frac{2-2y'-2\left(y'\right)^2}{x+2y}$<br>
ដោយ $y'=\frac{2x-y}{x+2y}$ នាំអោយ<br>
$y''=\frac{2\left(x+2y\right)^2-2\left(2x-y\right)}{(x+2y)^3}$<br>
$\times\frac{(x+2y)-2\left(2x-y\right)^2}{(x+2y)^3}$<br>
$=\frac{10\left(xy+y^2-x^2\right)}{(x+2y)^3}=\frac{50}{\left(x+2y\right)^3}$
</td>
<td>
$2x+2y\frac{dy}{dx}=0$<br>
$2x+2yy'=0, \frac{dy}{dx}=y'$<br>
ដូចនេះ $y'=-\frac{x}{y}$ បើ $y\neq 0$<br>
រក $y''$ នៃ $x^2+y^2=4$<br>
$x+yy'=0$ នោះ<br>
$y''=\frac{-1-\left(y'\right)^2}{y}$<br>
ដោយ $y'=-\frac{x}{y}, y\neq 0$<br>
ដូចនេះ $y''=-\frac{x^2+y^2}{y^3}$<br>
ខ) $xy+y^2-x^2=5$<br>
រក $y'$ នៃ $xy+y^2-x^2=5$<br>
ដេរីវេអង្គទាំងពីរ<br>
$\frac{d}{dx}(xy)+\frac{d}{dx}\left(y^2\right)-\frac{d}{dx}x^2=\frac{d}{dx}(5)$<br>
គេបាន<br>
$\frac{d}{dx}\left(xy+y^2-x^2\right)=\frac{d}{dx}(5)$<br>
$\left(y+xy'\right)+2yy'-2x=0$<br>
$y+\left(x+2y\right)y'-2x=0$<br>
ដូចនេះ $y'=\frac{2x-y}{x+2y}$<br>
រក $y''$ នៃ $xy+y^2-x^2=5$<br>
គេបាន<br>
$y'+y'+xy''+2y'y'+1yy''-2=0$<br>
$\left(x+2y\right)y''=2-2y'-2\left(y'\right)^2$<br>
$y''=\frac{2-2y'-2\left(y'\right)^2}{x+2y}$<br>
ដោយ $y'=\frac{2x-y}{x+2y}$ នាំអោយ<br>
$y''=\frac{2\left(x+2y\right)^2-2\left(2x-y\right)}{(x+2y)^3}$<br>
$\times\frac{(x+2y)-2\left(2x-y\right)^2}{(x+2y)^3}$
</td>
<td>
សិស្សពិនិត្យលើលំហាត់គំរូយ៉ាងយកចិត្តទុកដាក់យល់នូវអ្វីដែលគ្រូពន្យល់និងកត់ត្រាចូលក្នុងសៀវភៅបានល្អ។<br>
ក) $y=x^4-3x^2+x^{-2}$
</td>
</tr>
</table>

| | | |
|---|---|---|
| គ្រូអោយសិស្សឡើងធ្វើប្រតិបត្តិ គណនាដេរីវេទី២នៃអនុគមន៍ខាងក្រោម<br>ក) $y=x^4-3x^2+x^{-2}$<br>ខ) $f(x)=\sin 3x^2+1$<br><br>គ្រូហៅឈ្មោះសិស្ស អោយឡើងធ្វើលំហាត់ ប្រតិបត្តិទី២ | $=\frac{10\left(xy+y^2-x^2\right)}{(x+2y)^3}=\frac{50}{(x+2y)^3}$<br><br>ប្រតិបត្តិទី១<br>គណនាដេរីវេទី២នៃអនុគមន៍ខាងក្រោម<br>ក) $y=x^4-3x^2+x^{-2}$<br>ខ) $f(x)=\sin 3x^2+1$<br><br>ប្រតិបត្តិទី២<br>រក $y'$ និងយ $y''$ ជាអនុគមន៍នៃ $x$ និង $y$<br>ក) $xy+yx^2=2$<br>ខ) $4xy=x^2+y^2$ | $y'=4x^3-6x-2x$<br>$y'=4x^3-8x$<br>$y''=12x^2-8$<br>ដូចនេះ $y'=4x^3-8x$<br>$y''=12x^2-8$<br>$f(x)=\sin 3x^2+1$<br>$f'(x)=\left(\sin 3x^2+1\right)'$<br>$=6x\cos 3x^2$<br>$f''(x)=6\cos 3x^2$<br>$+\left(-36x^2\sin 3x^2\right)$<br>ដូចនេះ $f'(x)=6\cos 3x^2$<br>$f''(x)=6\cos 3x^2$<br>$-36x^2\sin 3x^2$<br><br>សិស្សឡើងធ្វើលំហាត់ ប្រតិបត្តិនិងចំលងចូល ក្នុងសៀវភៅបានយ៉ាងល្អ<br>ក) $xy+yx^2=2$<br>គេបាន<br>$\frac{d}{dx}(xy)+\frac{d}{dx}\left(yx^2\right)=\frac{d}{dx}(2)$<br>$y+xy'+y'x^2+2xy=0(1)$<br>$y'\left(x+x^2\right)=-y-2xy$<br>នាំអោយ $y'=\frac{-(y+2xy)}{x+x^2}$<br>តាម $(1)$ គេបាន<br>$\left(y+xy'+y'x^2+2xy\right)'=0$<br>$y'+y'+xy''+y''x^2$<br>$+2xy'+2y+2xy'=0$<br>$y''\left(x+y^2\right)=-2y'-4xy'-y$<br>$=-2y'(1+2x)-2y$<br>$y''=\frac{2y(1+2x)^2}{\left(x+x^2\right)}-\frac{2y}{x+x^2}$ |

| | | |
|---|---|---|
| គ្រូអោយសិស្សកត់ចំណាំគឺគេប្រើទំរង់ $f^{(n)}$ ចាប់ពី $n=4$ តទៅ។ គ្រូអោយសិស្សពិនិត្យតាមដានលើលំហាត់គំរូទី១ គណនាដេរីវេទី៤នៃ $f(x)=x^4+3x$ | 4.2 ដេរីវេលំដាប់ខ្ពស់ ឧទាហរណ៍ គេអោយអនុគមន៍ $f(x)=3x^5-7x^3+x-10$ គេបាន $f'(x)=15x^4-21x^2+1$ $f''(x)=60x^3-42x$ $f'''(x)=180x^2-42$ $f^{(4)}=360x$ $f^{(5)}=360$ $f^{(6)}=0$ <u>ជាទូទៅ</u> ដេរីវេនៃអនុគមន៍ $y=f(x)$ អាចមានដេរីវេខ្លួនឯងទៀតគេហៅថាដេរីវេបន្តបន្ទាប់ថាដេរីវេទី១ ទី២......ទី $n$ គេតាងដោយ $f', f'',......, f^{(n)}$ ។ លំហាត់គំរូទី១ គណនាដេរីវេទី៤នៃ $f(x)=x^4+3x$ យើងបាន | ខ) $4xy=x^2+y^2$ $\frac{d}{dx}(4xy)=\frac{d}{dx}(x^2+y^2)$ រឺ $\frac{d}{dx}(x^2)+\frac{d}{dx}(y^2)=\frac{d}{dx}(4xy)$ សិស្សបានដឹងនិងកត់ចំណាំ |

| | | |
|---|---|---|
| | $f'(x)=4x^3+3$<br>$f''(x)=12x^2, f'''(x)=24x$<br>$f^{(4)}(x)=24$<br>ដូចនេះ $f^{(4)}(x)=24$ | |
| គ្រូរកសិស្សដែលស្ម័គ្រចិត្តឡើងធ្វើលំហាត់ប្រតិបត្តិចំនួនពីរនាក់និងពន្យល់អំពីរបៀបដែលខ្លួនបានធ្វើដល់មិត្តរួមថ្នាក់។ | <u>ជំហានទី៤</u><br><u>ពង្រឹងពុទ្ធិ</u><br>គណនាដេរីវេទី៥នៃអនុគមន៍ខាងក្រោម<br>ក) $f(x)=\cos 3x-5x^7$<br>ខ) $f(x)=2x^4-\sin 4x$ | $f(x)=\cos 3x-5x^7$<br>$f'(x)=-3\sin 3x-35x^6$<br>$f''(x)=-9\cos x-210x^5$<br>$f'''(x)=27\sin 3x-1050x^4$<br>$f^{(4)}(x)=81\cos 3x-4200x$<br>$f^{(5)}(x)=-243six3x$<br>$-12600x^2$<br><br>ខ) $f(x)=2x^4-\sin 4x$<br>$f'(x)=8x^3-4\cos 4x$<br>$f''(x)=24x^2+16\sin 4x$<br>$f'''(x)=48x+64\cos 4x$<br>$f^{(4)}(x)=48-256\sin 4x$<br>$f^{(5)}(x)=-1024\cos 4x$ |
| គ្រូផ្ដែផ្ដាំនិងសួរពីចំណាប់អារម្មណ៍របស់អំពីមេរៀនដែលរៀនរួចនិងដាក់កិច្ចការផ្ទះដល់សិស្ស។ | ជំហានទី៥<br>បណ្ដាំផ្ញើ<br>គ្រូដាក់កិច្ចការផ្ទះអោយសិស្សធ្វើសៀវភៅសិស្សទំព័រ៥៥លំហាត់លេខ៩ចំនុចក,ខ,គ | សិស្សស្ដាប់ហើយកត់ត្រាទុក។ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតមូលដ្ឋាន)

## ជំពូកទី២ ដេរីវេនៃអនុគមន៍

## មេរៀនទី២អនុវត្តន៍ដេរីវេ

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹងៈ សិស្សចេះដេរីវេបានល្អនិងកាន់តែច្បាស់ក្នុងការបកស្រាយរូបមន្តដេរីវេ
- បំណិនៈ សិស្សប្រើដេរីវេក្នុងការគណនាតម្លៃបរមា
- ឥរិយាបថៈ សិស្សមានស្មារតីក្លាហានក្នុងការគណនាដេរីវេយ៉ាងងាយស្រួល

### II. ពេលវេលា

២ម៉ោង ថ្ងៃ.........ទី.......ខែ..........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្សៈ ទំព័រ ៥៦-៥៨
- សៀវភៅគ្រូៈទំព័រ

### IV. ខ្លឹមសារមេរៀន

1. **អនុវត្តន៍ក្នុងការគណនាតម្លៃបរមា**

### V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| ជំហានទី២ (រំលឹកមេរៀនចាស់) | | |
| -គ្រូអោយសិស្សឡើងធ្វើលំហាត់<br>គណនាដេរីវេនៃអនុគមន៍<br>$y=\left(x^3-6x\right)^4$ | គណនាដេរីវេនៃអនុគមន៍<br>$y=\left(x^3-6x\right)^4$ | $y=\left(x^3-6x\right)^4$<br>តាង $u=x^3-6x$ នាំអោយ<br>$y=u^4$<br>គេបាន $y'=4u^3u'$<br>$=4\left(x^3-6x\right)^3\left(x^3-6x\right)'$<br>$=4\left(x^3-6x\right)^3\left(3x^2-6\right)$<br>$=12\left(3x^2-6\right)\left(x^3-6x\right)^3$ |

<table>
<tr><th colspan="3">ជំហានទី៣ (មេរៀនថ្មី)</th></tr>
<tr>
<td>-គ្រូអោយសិស្សសង្កេតមើលឧទាហរណ៍១គ្រូសួរសិស្ស:<br>តើក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់មួយបានចំណាយប្រាក់ចំនួនប៉ុន្មានសំរាប់ផលិតសំភារៈមួយគ្រឿង?<br>គ្រូពន្យល់និងកែលំហាត់</td>
<td>**អនុវត្តន៍នៃដេរីវេ**<br><br>1. **អនុវត្តន៍ក្នុងការគណនាតម្លៃបរមា**<br>លំហាត់គំរូ១: ក្រុមហ៊ុនផលិតសំភារៈមួយប្រើប្រាស់មួយបានចំណាយប្រាក់២ពាន់រៀលសំរាប់ផលិតសំភារៈ១គ្រឿង។គេដឹងថាបើក្រុមហ៊ុនលក់សំភារៈ១គ្រឿងតម្លៃ៥ពាន់រៀលនោះក្នុងមួយខែលក់អស់៤០០០គ្រឿង។<br>អ្នកគ្រប់គ្រងក្រុមហ៊ុនបានសង្កេតឃើញថាកាលណាតម្លៃសំភារៈកើនឡើងម្តង១ពាន់រៀលនោះបរិមាណសំភារៈលក់ចេញក្នុង១ខែថយចុះម្តង៤០០គ្រឿងដែលក្រុមហ៊ុនត្រូវលក់ដើម្បីទទួលបានប្រាក់ចំនេញជាអតិបរមា។<br><u>ចម្លើយ</u><br>តាង $x$ ជាតម្លៃលក់សម្ភារៈ១គ្រឿង និង $P(x)$ ជាអនុគមន៍ប្រាក់ចំនេញសរុប<br>ប្រាក់ចំនេញសរុប=ប្រាក់ចំនេញក្នុង១គ្រឿង$\times$បរិមាណសម្ភារៈ<br>តាមសម្មតិកម្មគេបាន<br>ប្រាក់ចំនេញក្នុង១គ្រឿង$=x-2$ ពាន់រៀល<br>បរិមាណសម្ភារៈលក់បានក្នុង១ខែ<br>$=4000-400(x-5)$<br>គេបាន<br>$P(x)=(x-2)\left[4000-400(x-5)\right]$<br>$=400(x-2)(10-x+5)$<br>$=400(x-2)(15-x)$</td>
<td>-សិស្សមើលនិងគិតពិភាក្សាលើលំហាត់<br><u>ចម្លើយ</u><br>តាង $x$ ជាតម្លៃលក់សម្ភារៈ១គ្រឿងនិង $P(x)$ ជាអនុគមន៍ប្រាក់ចំនេញសរុប<br>ប្រាក់ចំនេញសរុប=ប្រាក់ចំនេញក្នុង១គ្រឿង$\times$បរិមាណសម្ភារៈ<br>តាមសម្មតិកម្មគេបាន<br>ប្រាក់ចំនេញក្នុង១គ្រឿង<br>$=x-2$ ពាន់រៀល<br>បរិមាណសម្ភារៈលក់បានក្នុង១ខែ<br>$=4000-400(x-5)$<br>គេបាន<br>$P(x)=(x-2)[4000-400$<br>$\times(x-5)]$</td>
</tr>
</table>

<table>
<tr>
<td></td>
<td>
$P'(x)=400(15-x)-400(x-2)$<br>
$=400(15-x-x+2)$<br>
$=400(17-2x)$<br>
$=400(15-x-x+2)$<br>
$=400(17-2x)$<br>
$P'(x)=0$ សមមូល $17-2x=0$<br>
$\Rightarrow x=\frac{17}{2}=8.5$<br>
$P(8.5)=400(8.5-2)(15-8.5)$<br>
$=16900$ ពាន់រៀល<br>
<br>
$x$ : 8.5<br>
$P'(x)$ : 0<br>
$P(x)$ : ↗ អតិ ↘<br>
<br>
ដូចនេះដើម្បីឲ្យក្រុមហ៊ុនចំនេញបានជាអតិបរមាចំនួន 16900 ពាន់រៀលក្រុមហ៊ុនត្រូវលក់សំភារៈ១គ្រឿងតម្លៃ 8500 ។
</td>
<td>
$=400(x-2)(10-x+5)$<br>
$=400(x-2)(15-x)$<br>
$P'(x)=400(15-x)$<br>
$-400(x-2)$<br>
$=400(15-x-x+2)$<br>
$=400(17-2x)$<br>
$=400(15-x-x+2)$<br>
$=400(17-2x)$<br>
$P'(x)=0 \Leftrightarrow 17-2x=0$<br>
$\Rightarrow x=\frac{17}{2}=8.5$<br>
$P(8.5)=400(8.5-2)$<br>
$\times(15-8.5)$<br>
$=16900$ ពាន់រៀល<br>
<br>
$x$ : 8.5<br>
$P'(x)$ : 0<br>
$P(x)$ : ↗ អតិ ↘<br>
<br>
ដូចនេះដើម្បីឲ្យក្រុមហ៊ុនចំនេញបានជាអតិបរមាចំនួន 16900 ពាន់រៀលក្រុមហ៊ុនត្រូវលក់សំភារៈ១គ្រឿងតម្លៃ 8500 ។
</td>
</tr>
<tr>
<td colspan="3">ជំហានទី៤ (ពង្រឹងចំណេះដឹង)</td>
</tr>
<tr>
<td>-គ្រូអោយសិស្សពិភាក្សាតាមក្រុមរួចឡើងដោះស្រាយលំហាត់គំរូ៣។</td>
<td>
លំហាត់គំរូ៣:<br>
គេសង់ជម្រកមួយរាងកោនបរិវត្តដែលមានមាឌ $V$ ។គណនាផលធៀបរង្វាស់កម្ពស់នៃកោននិងកាំថាសបាតដើម្បីជម្រកនោះមានផ្ទៃក្រលាខាងអប្បបរមា។<br>
<u>ចម្លើយ</u><br>
តាង $\begin{cases} SO=y\,,\,y>0 \\ OA=AB=x\,,\,x>0 \end{cases}$
</td>
<td>
-សិស្សរកលំហាត់រួចពិភាក្សាដើម្បីរកដំណោះស្រាយ<br>
<br>
<u>ចម្លើយ</u><br>
តាង $\begin{cases} SO=y\,,\,y>0 \\ OA=AB=x\,,\,x>0 \end{cases}$
</td>
</tr>
</table>




គេមាន $V=\frac{1}{3}\pi x^2 y$ នោះ

$y=\frac{3V}{\pi x^2}$

គណនា $SA$ និង $SB$ ដោយ

$SA=SB$ ត្រីកោណ $SOA$ កែងត្រង់ $O$ គេបាន

$SA^2=SO^2+OA^2$

$=\frac{9V^2}{\pi^2x^4}+x^2$

$=\frac{9V^2+\pi^2x^6}{\pi^2x^4}$

$SA=\frac{\sqrt{9V^2+\pi^2x^6}}{\pi x^2}$

ដោយ $P=2\pi x$ បរិមាត្របាតកោណ

បើ $S(x)$ ជាផ្ទៃក្រលាខាងនៃកោណគេបាន

$S'(x)=\frac{3\pi^2x^6-9V^2-\pi^2x^6}{x^2\sqrt{9V^2+\pi^2x^6}}$

$=\frac{2\pi^2x^6-9V^2}{x^2\sqrt{9V^2-\pi^2x^6}}$

$S'(x)=0$ នោះ $2\pi^2x^6-9V^2=0$

$x^6=\frac{9V^2}{2\pi^2}\Rightarrow x=\sqrt{\frac{9V^2}{2\pi^2}}$

| $x$ | $\frac{3V}{\sqrt{2}\pi}$ |
|---|---|
| $S'(x)$ | 0 |
| $S(x)$ | ↘ អប្ប ↗ |




គេមាន $V=\frac{1}{3}\pi x^2 y$ នោះ

$y=\frac{3V}{\pi x^2}$

គណនា $SA$ និង $SB$ ដោយ

$SA=SB$ ត្រីកោណ $SOA$ កែងត្រង់ $O$ គេបាន

$SA^2=SO^2+OA^2$

$=\frac{9V^2}{\pi^2x^4}+x^2$

$=\frac{9V^2+\pi^2x^6}{\pi^2x^4}$

$SA=\frac{\sqrt{9V^2+\pi^2x^6}}{\pi x^2}$

ដោយ $P=2\pi x$ បរិមាត្របាតកោណ

បើ $S(x)$ ជាផ្ទៃក្រលាខាងនៃកោណ គេបាន

$S'(x)=\frac{3\pi^2x^6-9V^2-\pi^2x^6}{x^2\sqrt{9V^2+\pi^2x^6}}$

$=\frac{2\pi^2x^6-9V^2}{x^2\sqrt{9V^2-\pi^2x^6}}$

$S'(x)=0$ នោះ

$2\pi^2x^6-9V^2=0$

$x^6=\frac{9V^2}{2\pi^2}\Rightarrow x=\sqrt{\frac{9V^2}{2\pi^2}}$

<table>
<tr>
<td></td>
<td>ផលធៀប $\frac{y}{x}=\frac{3V}{\pi x^3}$<br>$=\frac{3V}{\pi\sqrt{\frac{9V^2}{2\pi^2}}}$<br>$=\sqrt{2}$<br>ដូចនេះដើម្បីឲ្យក្រលាផ្ទៃនៃជម្រកអប្បបរមាលុះត្រាតែផលធៀបកំពស់និងកាំថាសបាតនៃជម្រកស្មើនឹង $\sqrt{2}$</td>
<td><table><tr><td>$x$</td><td>$\frac{3V}{\sqrt{2\pi}}$</td></tr><tr><td>$S'(x)$</td><td>0</td></tr><tr><td>$S(x)$</td><td>↘ អប្ប ↗</td></tr></table>ផលធៀប $\frac{y}{x}=\frac{3V}{\pi x^3}$<br>$=\frac{3V}{\pi\sqrt{\frac{9V^2}{2\pi^2}}}$<br>$=\sqrt{2}$<br>ដូចនេះដើម្បីឲ្យក្រលាផ្ទៃនៃជម្រកអប្បបរមាលុះត្រាតែផលធៀបកំពស់និងកាំថាសបាតនៃជម្រកស្មើនឹង $\sqrt{2}$</td>
</tr>
<tr><td colspan="3" align="center">ជំហានទី៥ (បណ្តាំផ្ញើ)</td></tr>
<tr>
<td>-អោយសិស្សធ្វើលំហាត់លេខ១និង២ ទំព័រ៦១</td>
<td align="center">កិច្ចការផ្ទះ</td>
<td>-សិស្សស្តាប់និងកត់ត្រា</td>
</tr>
</table>

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតមូលដ្ឋាន)

## ជំពូកទី២ ដេរីវេនៃអនុគមន៍

## មេរៀនទី២អនុវត្តន៍ដេរីវេ (ត)

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សកំណត់បានពីល្បឿនខណៈនិងសំទុះខណៈបានត្រឹមត្រូវតាមឧទាហរណ៍
- បំណិន: សិស្សគណនាតំលៃល្បឿនខណៈនិងសំទុះខណៈបានត្រឹមត្រូវតាមឧទាហរណ៍។
- ឥរិយាបថ: សិស្សមានស្មារតីប្រុងប្រយ័ត្នចំពោះការគណនាតំលៃល្បឿនខណៈនិងសំទុះខណៈ

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ៥៩-៦១
- សៀវភៅគ្រូ: ទំព័រ

### IV. ខ្លឹមសារមេរៀន

2. ល្បឿនខណៈនិងសំទុះខណៈ

### V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| ជំហានទី២ (រំលឹកមេរៀនចាស់) | | |
| -រកពីរចំនួនដែលមានផលបូកស្មើ110 ហើយផលគុណមានតំលៃអតិបរមារួចគណនាតំលៃអតិបរមានោះ។ | | -សិស្សឡើងបកស្រាយតាង $x, y$ ជាចំនួនដែលត្រូវរក |

<table>
<tr><td></td><td></td><td>សម្មតិកម្ម<br>$x+y=110\Leftrightarrow y=110-x$<br>$P=x\cdot y$<br>$\Rightarrow P(x)=x(110-x)$<br>$P(x)=110x-x^2$<br>$P'(x)=110-2x$<br>$P'(x)=0\Rightarrow 110-2x=0$<br>$\Rightarrow x=\frac{110}{2}=55$<br>$\Rightarrow y=110-55=55$<br>$\Rightarrow P(55)=55^2=3025$<br>ដូចនេះ $x=y=55$<br>$P(55)=3025$</td></tr>
<tr><td colspan="3">ជំហានទី៣ (មេរៀនថ្មី)</td></tr>
<tr><td>-តើល្បឿនជាអ្វីនៃចម្ងាយចរ?<br><br>-រួចហៅនិយមន័យអោយសិស្សកត់<br><br>-គ្រូផ្តល់លំហាត់គំរូដល់សិស្ស<br><br>-ពន្យល់សិស្សអោយធ្វើដេរីវេរួចជំនួសតំលៃ $t$ ចូល</td><td>មេរៀនទី២ អនុវត្តន៍ដេរីវេ<br>2. ល្បឿននិងសំទុះនៃចលនា<br>2.1.ល្បឿននៃចលនា<br><br>-ល្បឿននៃចលនានៅខណ:មួយគឺ $V(t)=\frac{ds}{dt}=S'(t)$ ដែល $S(t)$ ជាចំងាយចរនៅខណ:$t$<br><br>លំហាត់: គេទំលាក់គ្រាប់មួយអោយដោយសមីការ<br>$S(t)=4t^2-2t+2$<br>ដែល $t(s)$ ; $S(m)$ ។<br>ចូរកំណត់ល្បឿនពេល<br>$t=1s$ , $t=3s$<br><u>ចម្លើយ</u></td><td>-ល្បឿនជាដេរីវេទី១នៃចម្ងាយចរ<br>-ល្បឿននៃចលនានៅខណ:មួយគឺ<br>$V(t)=\frac{ds}{dt}=S'(t)$ ដែល $S(t)$ ជាចំងាយចរនៅខណ: $t$<br><br>លំហាត់: គេទំលាក់គ្រាប់មួយអោយដោយសមីការ<br>$S(t)=4t^2-2t+2$<br>ដែល $t(s)$ ; $S(m)$ ។<br>ចូរកំណត់ល្បឿនពេល<br>$t=1s$ , $t=3s$<br><u>ចម្លើយ</u></td></tr>
</table>

| | | |
|---|---|---|
| | កំណត់ល្បឿន<br>គេមាន $S(t)=4t^2-2t+2$<br>$V(t)=S'(t)=8t-2$<br>$V(1)=8-2=6\,m/s$<br>$V(3)=8\times3-2=22\,m/s$<br>ដូចនេះ<br>បើ $t=1s\Rightarrow V=6\,m/s$<br>បើ $t=3s\Rightarrow V=22\,m/s$ | កំណត់ល្បឿន<br>គេមាន $S(t)=4t^2-2t+2$<br>$V(t)=S'(t)=8t-2$<br>$V(1)=8-2=6\,m/s$<br>$V(3)=8\times3-2=22\,m/s$<br>ដូចនេះ<br>បើ $t=1s\Rightarrow V=6\,m/s$<br>បើ $t=3s\Rightarrow V=22\,m/s$ |
| -តើសំទុះជាអ្វីនៃល្បឿននិងចំងាយ?<br>-ផ្តល់និយមន័យអោយសិស្ស<br>-ផ្តល់ឧទាហរណ៍ | **2.2. សំទុះនៃចលនា**<br>-សំទុះនៃចលនានៅខណៈ$t$ គឺ $a(t)=\frac{dv}{dt}$ រឺ $a(t)=S''(t)$ នៃចលនានៅខណៈ$t$<br>-ឧទាហរណ៍: រថយន្តមួយមានល្បឿន$V(t)=2t^2+3t+5$ ។<br>គណនាសំទុះពេល$t=1s$ ,$t=2s$<br><u>ចម្លើយ</u><br>គេបាន $a(t)=\frac{dv}{dt}=4t+3$<br>ចំពោះ$t=1s\Rightarrow a=7\,m/s^2$<br>ចំពោះ$t=2s\Rightarrow a=11m/s^2$<br>ដូចនេះ<br>បើ$t=1s\Rightarrow a=7\,m/s^2$<br>បើ$t=2s\Rightarrow a=11m/s^2$ | -គឺជា<br>$a=\frac{dv}{dt}=\frac{d^2s}{dt^2}=S''(t)$<br>-សំទុះនៃចលនានៅខណៈ$t$ គឺ $a(t)=\frac{dv}{dt}$ រឺ $a(t)=S''(t)$ នៃចលនានៅខណៈ$t$<br>-ឧទាហរណ៍: រថយន្តមួយមានល្បឿន<br>$V(t)=2t^2+3t+5$ ។<br>គណនាសំទុះពេល<br>$t=1s$ ,$t=2s$<br><u>ចម្លើយ</u><br>គេបាន $a(t)=\frac{dv}{dt}=4t+3$<br>ចំពោះ$t=1s\Rightarrow a=7\,m/s^2$<br>ចំពោះ$t=2s\Rightarrow a=11m/s^2$<br>ដូចនេះ<br>បើ$t=1s\Rightarrow a=7\,m/s^2$<br>បើ$t=2s\Rightarrow a=11m/s^2$ |
| -ផ្តល់ឧទាហរណ៍ទី២<br>-រួចពន្យល់សិស្សអោយឡើងធ្វើដោះស្រាយ | -ឧទាហរណ៍: ចលនាមួយមានសមីការ$S(t)=2t^3+3t^2-6t+3$ ដែល$S$ គិតជា$(m)$ , $t$ គិតជា$(s)$ ។ | -ឧទាហរណ៍: ចលនាមួយមានសមីការ<br>$S(t)=2t^3+3t^2-6t+3$ |

| | | |
|---|---|---|
| | ក.គណនាល្បឿនពេល<br>$t_1 = 1s$ , $t_2 = 4s$<br>ខ.គណនាសំទុះពេល<br>$t = 0s$ , $t = 2s$<br><u>ចម្លើយ</u><br>ក. គណនាល្បឿន$V$<br>គេមាន $S(t) = 2t^3 + 3t^2 - 6t + 3$<br>$V(t) = \frac{ds}{dt} = 6t^2 + 6t - 6$<br>-បើ $t = 1s \Rightarrow V = 6\,m/s$<br>-បើ $t = 4s \Rightarrow V = 114\,m/s$<br>ខ. គណនាសំទុះ$a$<br>គេមាន$V(t) = 6t^2 + 6t - 6$<br>$a(t) = \frac{dv}{dt} = 12t + 6$<br>-បើ $t = 0s \Rightarrow a = 6\,m/s^2$<br>-បើ $t = 2s \Rightarrow a = 30\,m/s^2$ | ដែល $S$ គិតជា$(m)$ , $t$ គិតជា $(s)$ ។<br>ក.គណនាល្បឿនពេល<br>$t_1 = 1s$ , $t_2 = 4s$<br>ខ.គណនាសំទុះពេល<br>$t = 0s$ , $t = 2s$<br><u>ចម្លើយ</u><br>ក. គណនាល្បឿន$V$<br>គេមាន<br>$S(t) = 2t^3 + 3t^2 - 6t + 3$<br>$V(t) = \frac{ds}{dt} = 6t^2 + 6t - 6$<br>-បើ $t = 1s \Rightarrow V = 6\,m/s$<br>-បើ $t = 4s \Rightarrow V = 114\,m/s$<br>ខ. គណនាសំទុះ$a$<br>គេមាន$V(t) = 6t^2 + 6t - 6$<br>$a(t) = \frac{dv}{dt} = 12t + 6$<br>-បើ $t = 0s \Rightarrow a = 6\,m/s^2$<br>-បើ $t = 2s \Rightarrow a = 30\,m/s^2$ |
| ជំហានទី៤ (ពង្រឹងចំណេះដឹង) | | |
| -ផ្តល់លំហាត់អោយសិស្សឡើងបកស្រាយ<br>-លំហាត់: ចលនាមួយអោយដោយសមីការ<br>$S(t) = 2t^2 + 4 + \sin\frac{\pi}{2}t$<br>ក. គណនាល្បឿនពេល$t = 0$<br>ខ. គណនាសំទុះពេល$t = 3s$ | | -សិស្សរកត់លំហាត់<br>ក. គណនាល្បឿន$t = 0$<br>គេមាន<br>$S(t) = 2t^2 + 4 + \sin\frac{\pi}{2}t$<br>$V = \frac{dx}{dt} = 4 + \frac{\pi}{2}\cos\frac{\pi}{2}t$<br>បើ$t = 0 \Rightarrow V = \frac{\pi}{2}\,m/s$<br>ខ. គណនាសំទុះ$a$<br>គេមាន |

| | | |
|---|---|---|
| | | $V(t)=4t+\frac{\pi}{2}\cos\frac{\pi}{2}t$<br>$a(t)=\frac{dv}{dt}=4-\frac{\pi^2}{4}\sin\frac{\pi}{2}t$<br>បើ $t=3s$ នោះ<br>$a=\left(4+\frac{\pi^2}{4}\right)m/s^2$ |
| ជំហានទី៥ (បណ្តាំផ្ញើ) | | |
| -ចូរប្អូនដោះស្រាយលំហាត់នៅទំព័រ៦១-៦២នៅផ្ទះ។ | កិច្ចការផ្ទះ | -សិស្សស្តាប់ការណែនាំរបស់គ្រូ |

# កិច្ចតែងការ

- ❖ មុខវិជ្ជា: គណិតវិទ្យាថ្នាក់ទី ១២ មូលដ្ឋាន
- ❖ ជំពូកទី៣: សិក្សាអថេរភាព និងសង់ក្រាប
- ❖ មេរៀនទី១: អនុគមន៍សនិទាន
- ❖ រយៈពេល២: ម៉ោង

*I* **វត្ថុបំណង**

- ➢ ចំណេះដឹង: ចេះរកអាស៊ីមតូតទ្រេត តាមរយៈការណែនាំពន្យល់របស់គ្រូ
- ➢ បំណិន: សិស្សអាចដោះស្រាយលំហាត់បានដោយខ្លួនតាមរយលំហាត់គំរូ។
- ➢ ឥរិយាបទ: សិស្សមានស្មារតីក្លាហានក្នុងការ ដោះស្រាយលំហាត់បានដោយខ្លួន។

*II* **ខ្លឹមសារមេរៀន**

**ជំពូកទី៣: សិក្សាអថេរភាគ និងសង់ក្រាប**

**មេរៀនទី១: អនុគមន៍សនិទាន**

**១. អនុគមន៍** $y=\dfrac{ax^2+bx+c}{px+q}$

**១.១ អាស៊ីមតូតទ្រេត**

*III* **សម្ភារ:**

- ➢ សៀវភៅសិស្សទំព័រទី (64⟶ 66)បោះពុម្ពឆ្នាំ 2010
- ➢ សំភារ:ឧបទេស: ហ្វឺត បន្ទាត់ក្រិត ក្រដាស

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| - ពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ និងអនាម័យសិស្ស | ☛ជំហានទី១: (រដ្ឋបាលថ្នាក់) | – ប្រធានថ្នាក់ឡើងរាយការណ៍ |
| គណនាលីមីត<br>1) $\lim\limits_{x\to+\infty}\dfrac{x^2+3x}{x}$<br>2) $\lim\limits_{x\to-\infty}\dfrac{x^2+3x+5}{x^2+2x}$ | ☛ជំហានទី២:<br>(រំលឹកមេរៀនចាស់)<br>1. $\lim\limits_{x\to+\infty}\dfrac{x^2+3x}{x}$<br>$=\lim\limits_{x\to\infty}x\left(1+\dfrac{3}{x}\right)$<br>$=+\infty$ | សិស្សឆ្លើយ:<br>1. $\lim\limits_{x\to+\infty}\dfrac{x^2+3x}{x}$<br>$=\lim\limits_{x\to\infty}x\left(1+\dfrac{3}{x}\right)$<br>$=+\infty$ |

| | | |
|---|---|---|
| | 2. $\lim\limits_{x\to-\infty}\frac{x^2+3x+5}{x^2+2x}$ <br> $=\lim\limits_{x\to-\infty}\left(\frac{1+\frac{3}{x}+\frac{5}{x^2}}{1+\frac{2}{x}}\right)$ <br> $=1$ | 2. $\lim\limits_{x\to-\infty}\frac{x^2+3x+5}{x^2+2x}$ <br> $=\lim\limits_{x\to-\infty}\left(\frac{1+\frac{3}{x}+\frac{5}{x^2}}{1+\frac{2}{x}}\right)$ <br> $=1$ |
| ណែនាំសិស្សធ្វើ លំហាត់គំរូ: <br> ឧទាហរណ៍: រកអាស៊ីមតូតទ្រេត នៃក្រាមតាងអនុគមន៍ <br> $y=f(x)=\frac{x^2+2x+3}{x+1}$ <br> _ | ☛ជំហានទី៣: <br> (ខ្លឹមសាមេរៀន) <br> **១. អនុគមន៍** <br> $y=\frac{ax^2+bx+c}{px+q}$ <br> **១.១ អាស៊ីមតូតទ្រេត** <br> ចម្លើយ: <br> ដើម្បីរកអាស៊ីមតូតទ្រេត <br> គេចែក $x^2+2x+3$ និង $x+1$ គេបាន: <br> $y=\frac{x^2+2x+3}{x+1}$ <br> $=x+1+\frac{2}{x+1}$ <br> $\Rightarrow y-(x+1)=\frac{2}{x+1}$ <br> គេបាន: <br> $\lim\limits_{x\to\pm\infty}\left[y-(x+1)\right]$ <br> $=\lim\limits_{x\to\pm\infty}\frac{2}{x+1}=0$ <br> <u>ដូចនេះ</u> បន្ទាត់ $y=x+1$ ជាអាស៊ីមតូត ទ្រេត។ | សិស្សឆ្លើយ: <br> ចម្លើយ: <br> ដើម្បីរកអាស៊ីមតូតទ្រេត <br> គេចែក $x^2+2x+3$ និង $x+1$ គេបាន: <br> $y=\frac{x^2+2x+3}{x+1}$ <br> $=x+1+\frac{2}{x+1}$ <br> $\Rightarrow y-(x+1)=\frac{2}{x+1}$ <br> គេបាន: <br> $\lim\limits_{x\to\pm\infty}\left[y-(x+1)\right]$ <br> $=\lim\limits_{x\to\pm\infty}\frac{2}{x+1}=0$ <br> <u>ដូចនេះ</u> បន្ទាត់ $y=x+1$ ជាអាស៊ីមតូត ទ្រេត។ <br> <u>សិស្សឆ្លើយ</u> |

| | | |
|---|---|---|
| លំហាត់គំរូ: រកសមីការអាស៊ីម ទ្រេតនៃអនុគមន៍<br>$y=\sqrt{4x^2+x+5}$ | <u>ចម្លើយ:</u> រកមេគុណនៃបន្ទា $y=ax+b$ គេបាន:<br>$a=\lim\limits_{x\to+\infty}\dfrac{f(x)}{x}$<br>$=\lim\limits_{x\to+\infty}\dfrac{\sqrt{4x^2+x+5}}{x}$<br>$=\lim\limits_{x\to+\infty}\dfrac{x\sqrt{4+\left(\frac{1}{x}\right)+\frac{5}{x^2}}}{x}$<br>$=2$<br>$b=\lim\limits_{x\to+\infty}\left[f(x)-ax\right]$<br>$=\lim\limits_{x\to+\infty}\left(\sqrt{4x^2+x+5}-2x\right)$<br>$=\lim\limits_{x\to+\infty}\left(\sqrt{4x^2+x+5}-2x\right)$<br>$\times\dfrac{\left(\sqrt{4x^2+x+5}+2x\right)}{\left(\sqrt{4x^2+x+5}+2x\right)}$<br>$=\lim\limits_{x\to+\infty}\dfrac{x\left(1+\frac{5}{x}\right)}{x\left(\sqrt{4+\frac{1}{x}+\frac{5}{x^2}}+2\right)}$<br>$=\dfrac{1}{4}$<br>ដូចនេះ<br>សមីការអាស៊ីមតូតទ្រេត<br>$y=2x+\dfrac{1}{4}$ | |

| | | |
|---|---|---|
| <br><br><br><br><br><br><br><br><br><br>លំហាត់គំរូ<br>-រកសមីការអាស៊ីមតូតទ្រេតនៃអនុគនម៍:<br>$f\left(x\right)=\frac{x^2-5x+7}{x-2}$ | ជាទូទៅ បើ<br>$\lim\limits_{x\to\pm\infty}\frac{f\left(x\right)}{x}=a$ &<br>$\lim\limits_{x\to\pm\infty}\left[f\left(x\right)-ax\right]=b$<br><br>នោះបន្ទាត់មានសមីការ<br>សមីការ $y=ax+b$<br>ជាអាស៊ីមតូតទ្រេតនៃក្រាបតាង $f$ ។<br><br>-គេមាន<br>$f\left(x\right)=\frac{x^2-5x+7}{x-2}$<br>$=x-3+\frac{1}{x-2}$<br>គេបាន:<br>$\lim\limits_{x\to\pm\infty}\frac{1}{x-2}=0$<br>ដូចនេះ បន្ទាត់<br>$y=x-3$ ជាអាស៊ីត<br><br>តូតទ្រេតនៃក្រាប។ | |
| គ្រូដាក់លំហាត់ឲ្យសិស្សឡើងដោះស្រាយ។<br>រកសមីការអាស៊ីមទ្រេតនៃអនុគន៍:<br>$y=\frac{x^2-4x+7}{x-2}$ | ☛<u>ជំហានទី៥</u>:<br>(ពង្រឹងពុទ្ធិ)<br>លំហាត់:<br>រកសមីការអាស៊ីមទ្រេតនៃអនុគន៍: | −ធ្វើលំហាត់ប្រតិបត្តិ |

| | | |
|---|---|---|
| | $y = \dfrac{x^2 - 4x + 7}{x - 2}$ | |
| សិស្សធ្វើលំហាត់ប្រតិបត្តិ(ខ)&(គ ) | ☛<u>ជំហានទី៥</u>: (បណ្តាំផ្ញើរ) លំហាត់ប្រតិបត្តិ (ខ )និង (គ )ទំព័រ66។ | កត់ត្រាលេខលំហាត់។ |

# កិច្ចតែងការ

- ❖ **មុខវិជ្ជា:　គណិតវិទ្យាថ្នាក់ទី១២ កំរិតមូលដ្ឋាន**
- ❖ **ជំពូកទី៣:　សិក្សាអថេរភាព និងសង់ក្រាប**
- ❖ **មេរៀនទី១:　អនុគមន៍សនិទាន**
- ❖ **រយៈពេល :　២ម៉ោង**

$I)$ ***វត្ថុបំណង***

- ➢ ចំណេះដឹង: ចេះរកអាស៊ីមតូតទ្រេត សិក្សាអថេរភាព និងសង់ក្រាបនសអនុគមន៍ តាមរយការណែនាំពន្យល់របស់គ្រូ។
| − គ្រូឲ្យសិស្សពិនិត្យមើលលំហាត់ | ជំហាន់ទី3: <br> ខ្លឹមសារមេរៀន <br> 3)អនុវត្តន៍ | |

<table>
<tr>
<td>គំរូទី១<br><br><br><br><br><br><br><br><br><br><br><br><br><br>–គ្រូពន្យល់តម្លៃប៉ារ៉ាម៉ែត m ហើយឲ្យសិស្សឡើងធ្វើលំហាត់សំនួរ ក។<br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br><br>–ឲ្យសិស្សចេះរកចំនុចនឹងលើខ្សែ</td>
<td>ឧទាហរណ៍:គេឲ្យអនុ. $y=\frac{mx^2+1}{x}$ ដែលមានក្រាប $c_m$<br>ក/សិក្សាអថេរភាពនិងសង់ក្រាប ចំពោះ $m=1$។<br>ខ/កំណត់តម្លៃ $m$ ដើម្បីឲ្យអនុ.កើន ក្នុងចន្លោះ $\left[\frac{1}{2};+\infty\right)$<br>គ/តើមានចំនុចនឹងដែលស្ថិតនៅក្រោមក្រាប $c_m$ ចំពោះគ្រប់ m ឬទេ។<br>ឃ/ដោយប្រើក្រាប $c_1$ កំណត់តម្លៃ $a$ ដើម្បីឲ្យ $x^2-ax+1>0$ ចំពោះ $\forall x>0$<br>–សិក្សាអថេរភាពនិងសង់ក្រាប ចំពោះ $m=1$<br>$c_1: y=\frac{x^2+1}{x}$<br>• ដែនកំណត់ $D=\Re-\{0\}$<br>• ទិសដៅអថេរភាព<br>–ដេរីវេ $y'=\frac{x^2-1}{x^2}$<br>$f'(x)=0\Rightarrow x=\pm1$<br>តារាងសញ្ញាណដេរីវេ<br>
<table>
<tr><td>$x$</td><td>$-\infty$</td><td>$-1$</td><td>$0$</td><td>$1$</td><td>$+\infty$</td></tr>
<tr><td>$f'(x)$</td><td>+</td><td>−</td><td>||</td><td>−</td><td>+</td></tr>
<tr><td>$f(x)$</td><td>↗</td><td>↘</td><td>||</td><td>↘</td><td>↗</td></tr>
</table>
ចំពោះ $x=-1$ អនុ.មានអតិបរមាគឺ<br>ចំពោះ $x=1$ អនុ.មានអតិបរមាគឺ<br>$f(-1)=2$<br>គណនាលីមីត<br>$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\frac{x^2-1}{x}=\pm\infty$<br>–អាស៊ីមតូត<br>នោះ $x=0$ ជាអស៊ីមតូតឈរ<br>គ/រកចំនុចនឹងដែលក្រាប $(c_m)$ ទាំង</td>
<td></td>
</tr>
</table>

| | | |
|---|---|---|
| កោងប៉ារ៉ាម៉ែតចំពោះគ្រប់តម្លៃប៉ារ៉ាម៉ែត $m$ ។<br><br>–ឲ្យសិស្សចេះប្រើខ្សែកោងដើម្បីទាញរកចម្លើយវិសមីការ។<br><br>–គ្រូចែកសិស្សជាក្រុមតូចៗដើម្បីពិភាក្សាលំហាត់គំរូទី2។<br>–គ្រង់សំនួរ ក គ្រូបំផុសសិស្សអំពីប្លង់សិក្សាអថេរភាព។<br>• ដែនកំណត់<br>• ទិសដៅអថេរភាព<br>–រកដេរីវេគឺ $f'(x)$<br>–រកបរមា(អតិ និងអប្ប)<br>–គណនាលីមីត<br>–អាស៊ីមតូត<br>• តារាងអថេរភាព<br>• សំណង់ក្រាប | អស់កាត់តាមចំនុចនោះ<br>តាង $A(x_A,y_A)$ ជាចំនុចដែលក្រាប $c_m$ ទាំងអស់កាត់តាម<br>គេបាន<br>$y_A=\frac{mx_A+1}{x_A};\forall m\in R\ \&\ x\neq 0$<br>នោះ: $x_Ay_A=mx_A^2+1$<br>$\forall m\in R$<br>$\begin{cases}x_A^2=0\\ x_Ay_A-1=0\end{cases}$ គ្មានឬស<br>ដូចនេះគ្មានចំនុចនិង A ទេ<br>ឃ/កំណត់ $a$ ដើម្បីអោយ $x^2-ax+1>0$ ចំពោះ $\forall x>0$<br>គេបាន $x^2-ax+1>0\ \forall x>0$<br>គេបាន $\frac{x^2+1}{x}>a$ តាមក្រាបគេឃើញថា $\frac{x^2+1}{x}>a$ ចំពោះ $\forall x>0$<br>កាលណា $a<2$<br>លំហាត់គំរូទី2:គេឲ្យអនុគមន៍<br>$f:y=\frac{x^2-x+2}{x-1}$<br>ក/សិក្សាអថេរភាព និងសង់ក្រាប $c$ នៃអនុគមន៍។<br>ខ/ដោយប្រើក្រាប $c$ ទាញរកក្រាបរបស់អនុគមន៍ $y=\left\|\frac{x^2-x+2}{x-1}\right\|$ ។<br>ឃ/ដោយប្រើក្រាប $c$ សិក្សាទៅតាមតម្លៃ $m$ នូវចំនួនឬសនៃសមីការ $x^2-\|x\|+2=m(\|x\|-1)$ ។ | –ក/សិក្សាអថេរភាព និងសង់ក្រាប<br>$c:y=\frac{x^2-x+2}{x-1}=x+\frac{2}{x-1}$<br>• ដែនកំណត់ $D=R-\{1\}$<br>• ទិសដៅអថេរភាព<br>ដេរីវេ $f'(x)=\frac{x^2-x-1}{(x-1)^2}$<br>$f'(x)=0$ គេបាន $\frac{x^2-x-1}{(x-1)^2}=0$<br>នាំឲ្យ $x=1+\sqrt{2};x=1-\sqrt{2}$<br>–ចំនុចអតិបរមា<br>ចំពោះ $x=1-\sqrt{2}$ អនុគមន៍មានតម្លៃអតិបរមាធៀប<br>$f(1-\sqrt{2})=\frac{(1-\sqrt{2})^2-(1-\sqrt{2})+2}{1-\sqrt{2}-1}$<br>$=1-2\sqrt{2}$ |

–គ្រូឲ្យសំគាល់ដល់សិស្សថាៈគេអាចរកផ្ចិតឆ្លុះ $I$ នៃក្រាបតាមរូប

ចំពោះ $x=1+\sqrt{2}$ អនុគមន៍មានតម្លៃអប្បបរមាធៀប

$$f\left(1+\sqrt{2}\right)=\frac{\left(1+\sqrt{2}\right)^2+\left(1-\sqrt{2}\right)+2}{1+\sqrt{2}-1}$$
$$=2\sqrt{2}+1$$

–គណនាលីមីត

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\left(x+\frac{2}{x-1}\right)=\pm\infty$$

និង $\lim_{x\to 1} f(x)=\lim_{x\to 1}\frac{2}{x-1}=\pm\infty$

–អាស៊ីមតូតៈដោយ

$$\lim_{x\to 1} f(x)=\lim_{x\to 1}\frac{2}{x-1}=\pm\infty$$

នោះ $x=1$ ជាអស៊ីមតូតឈរ។

អនុ. $f(x)=x+\frac{2}{x-1}$ គេបាន

$$\lim_{x\to\pm\infty}\left[f(x)-x\right]=\lim_{x\to\pm\infty}\frac{2}{x-1}=0$$

នាំឲ្យ $y=x$ ជាអាស៊ីមតូតទ្រេតនៃក្រាប។

• តារាងអថេរភាព

| $x$ | $-\infty$ | | $1-\sqrt{2}$ | | $1$ | | $1+\sqrt{2}$ | | $+\infty$ |
|---|---|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | ‖ | $-$ | $0$ | $+$ | |
| $f(x)$ | $-\infty$ | ↗ | $1-2\sqrt{2}$ | ↘ $-\infty$ | ‖ | $+\infty$ ↘ | $1+2\sqrt{2}$ | ↗ | $+\infty$ |

• សំណង់ក្រាប

–បើ $y=0$ នោះ $\frac{x^2-x+2}{x-1}=0$ ឬ

$x^2-x+2=0$ សមីការគ្មានឫស ក្រាបមិនកាត់អ័ក្ស $0x$ ទេ។

–បើ $x=0$ នោះ $\frac{0^2-0+2}{0-1}=-2$ ។

–ផ្ចិតឆ្លុះ :អាស៊ីមតូតឈរ $x=1$ និង អាស៊ីមតូតទ្រេត $y=x$ កាត់គ្នាត្រង់ $I(1,1)$ ។

មន្តមួយទៀតគឺ

$f(2a+x)-f(x)=2b$ ដែល

$I(a,b)$ ។

តាមរូបមន្តប្តូរអ័ក្ស $x=1+X$

$y=1+Y$

គេបាន

$Y=1+X+\frac{2}{1+X-1}-1$

$=X+\frac{2}{X}$

$F(-X)=-X+\frac{2}{-X}=-\left(X+\frac{2}{X}\right)$

$=-F(X)$

នាំឲ្យ $F(X)$ ជាអនុគមន៍សេស។

ដូចនេះ $I(1,1)$ ជាផ្ចិតឆ្លុះរបស់ក្រាប $c$ ។

ខ/ទាញរកក្រាបរបស់អនុគមន៍

$y=\left|\frac{x^2-x+2}{x-1}\right|$

គេមាន $y=\left|\frac{x^2-x+2}{x-1}\right|$

សញ្ញានៃ $\frac{x^2-x+2}{x-1}, x^2-x+2>0$

ចំពោះគ្រប់ $x\in R$ ព្រោះ $\Delta=1-8<0$

ដូចនេះប្រភាគមានសញ្ញាដូច $x-1$

| $x$ | $-\infty$ | | $1$ | | $+\infty$ |
|---|---|---|---|---|---|
| $\frac{x^2-x+2}{x-1}$ | | $-$ | ‖ | $+$ | |

$-$ បើ $x>1, \frac{x^2-x+2}{x-1}>0$

$y=\left|\frac{x^2-x+2}{x-1}\right|=\frac{x^2-x+2}{x-1}$ ។

មែកនៃ $y=\left|\frac{x^2-x+2}{x-1}\right|$ ជាមែកនៃ

$y=\frac{x^2-x+2}{x-1}$ ។

$-$ បើ $x<1, \frac{x^2-x+2}{x-1}<0$

$y=\left|\frac{x^2-x+2}{x-1}\right|=-\left(\frac{x^2-x+2}{x-1}\right)$ ។

| | | |
|---|---|---|
| | | មែកនៃ $y=\left\|\frac{x^2-x+2}{x-1}\right\|$ ឆ្លុះគ្នានឹងមែកនៃ $y=\frac{x^2-x+2}{x-1}$ ធៀបនឹងអ័ក្សអាប់ស៊ីស។<br>ដូចនេះក្រាប $y=\left\|\frac{x^2-x+2}{x-1}\right\|$ ជាប្រជុំនៃមែកនៅខាងលើអ័ក្សអាប់ស៊ីស ដែលមែកជារបស់ $y=\frac{x^2-x+2}{x-1}$ និងមែកមួយទៀតបានដោយបំលែងឆ្លុះធៀបនិងអ័ក្សអាប់ស៊ីសនៃមែករបស់ $y=\frac{x^2-x+2}{x-1}$ ដែលត្រូវនឹង $x<1$។<br>គ/ពិភាក្សាតាមតម្លៃ $m$ :<br>$x^2-\|x\|+2=m(\|x\|-1)$ សមមូល<br>$\frac{x^2\|x\|+2}{\|x\|-1}=m$<br>អង្គខាងឆ្វេងជាក្រាប<br>$C_2: y=\frac{x^2-\|x\|+2}{\|x\|-1}$<br>គេមាន $y=\frac{x^2-\|x\|+2}{\|x\|-1}=$<br>$\begin{cases}\frac{x^2-x+2}{x-1} & \text{បើ } x\ge 0\\ \frac{x^2+x+2}{-x-1} & \text{បើ } x<0\end{cases}$<br>ដូចនេះក្រាប $C_2: y=\frac{x^2-\|x\|+2}{\|x\|-1}$ មានក្រាបមួយផ្នែកជារបស់ $y=\frac{x^2-x+2}{x-1}$ ផ្នែក $x\ge o$ (មិនយកផ្នែក $x<0$ ទេ)ហើយមួយផ្នែកទៀតជាក្រាបឆ្លុះរបស់ $y=\frac{x^2-x+2}{x-1}$ ផ្នែក $x\ge o$ ធៀបនិងអ័ក្ស $0y$ ។<br>គូសបន្ទាត់ $D: y=m$ គេឃើញថា: |

| | | |
|---|---|---|
| | | – បើ $m<-2$: មានឬសពីរផ្សេងគ្នា។<br>– បើ $m=-2$: មានឬសឌុបមួយ។<br>– បើ $-2<m<2\sqrt{2}+1$: គ្មានឬស។<br>– បើ $m=2\sqrt{2}+1$: មានឬសឌុបពីរ។<br>– បើ $m>2\sqrt{2}+1$: មានឬសបួន។ |
| – | ជំហាន់ទី4:<br>ពង្រឹងពុទ្ធិ | |
| – មើលមេរៀនថ្មី | ជំហាន់ទី5:<br>បណ្តាំផ្ញើរ | |

# កិច្ចតែងការបង្រៀន

**ជំពូក ទី...៤....**

មេរៀនទី...១... **ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**

**- មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)**

**- ជំពូកទី៤ : អាំងតេក្រាល**

**- មេរៀនទី១ : ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**

**- បង្រៀនដោយ : សាស្ត្រាចារ្យ ..............................**

**I.**វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : សិស្សកំណត់និយមន័យព្រីមីទីវនៃអនុគមន៍តាមរយៈការបង្ហាញរបស់គ្រូ។

-បំណិន : សិស្សអនុវត្តទ្រឹស្តីបទព្រីមីទីវក្នុងការដោះស្រាយលំហាត់បានត្រឹមត្រូវ តាមរយៈការពន្យល់របស់គ្រូ។

-ឥរិយាបថ : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយៈការណែនាំរបស់គ្រូ។

**II.**ពេលវេលា: ...២...ម៉ោង ថ្ងៃ.................ទី................ខែ...............ឆ្នាំ...........

**III.**សម្ភារៈឧទេស

-ស . ស :ទំព័រទី.១១០.. ដល់ទំព័រទី.១១២...

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-

**IV.**ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងធ្វើលំហាត់ គណនាដេរីវេនៃអនុគមន៍<br>ក/ $y=x^3+3x^2-4x-6$<br>ខ/ $y=e^{\frac{1}{x}}$ | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី)<br>គណនាដេរីវេនៃអនុគមន៍<br>ក/ $y=x^3+3x^2-4x-6$<br>$y'=3x^2+6x-4$<br>ខ/ $y=e^{\frac{1}{x}}\Rightarrow y'=-\frac{e^{\frac{1}{x}}}{x^2}$ | -សិស្សឡើងគណនា គណនាដេរីវេនៃអនុគមន៍<br>ក/ $y=x^3+3x^2-4x-6$<br>$y'=3x^2+6x-4$<br>ខ/ $y=e^{\frac{1}{x}}\Rightarrow y'=-\frac{e^{\frac{1}{x}}}{x^2}$ |

| | | |
|---|---|---|
| <br><br>-ណែនាំសិស្សឲ្យសង្កេត<br>លើឧទាហរណ៍<br>ឧ១- គេទម្លាក់វត្ថុមួយពីទី<br>ដែលមានកម្ពស់ $h$ មក។នៅខ<br>ណះ<br>ពេល $t_0=0$ វត្ថុនោះមានល្បឿន<br>$V(0)=0$ ។ក្រោមចលនាទម្លាក់<br>នៅខណះពេល $t$ អង្គធាតុផ្លាស់ទី<br>ដោយល្បឿន $V(t)=gt$ ដែល<br>$g$ ជាសំទុះនៃទម្លាក់សេរី។<br>គណនា<br>ចម្ងាយចរនៃវត្ថុនៅខណះពេល $t$<br>។<br>ឧ២- រក $F(x)$ ដែល<br>$F'(x)=2x$<br><br>-ឲ្យសិស្សទាញរកនិយមន័យ<br>ព្រីមីទីវតាមឧទាហរណ៍ខាងលើ<br><br>-គ្រូឲ្យសិស្សសង្កេតលំហាត់គំរូ<br>លំហាត់គំរូ៖ គេមាន<br>$F(x)=x^3+x^2+x$ និង<br>$f(x)=3x^2+2x+1$ ។<br>បង្ហាញថា $F(x)$ ជាព្រីមីទីវនៃ<br>$f(x)$<br>-គ្រូដាក់លំហាត់ប្រតិបត្តិ<br>ក/ រកព្រីមីទីវ $F(x)$ នៃ<br>$f(x)=\sin x$ ចំពោះគ្រប់ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយះពេល៦០នាទី)<br>**មេរៀនទី១:**<br>**ព្រីមីទីវនិងអាំងតេក្រាលមិនកំណត់**<br>១. ព្រីមីទីវ<br>១.១ និយមន័យ<br>ដំណោះស្រាយ<br>១-តាង $S(t)$ ជាចម្ងាយចរនៅខណះ<br>ពេល $t$ ។ យើងដឹងថា<br>$V(t)=\lim\limits_{\Delta x\to 0}\frac{\Delta S}{\Delta x}=S'(x)$<br>ដូចនេះ គេត្រូវរក $S(t)$ ដែលមាន<br>$S'(t)=V(t)=gt$ គេបាន<br>$S(t)=\frac{1}{2}gt^2$ ព្រោះ $S'(t)=gt$<br>$S(t)$ ដែលបានរកឃើញហៅថា<br>ព្រីមីទីវនៃ $V(t)=gt$<br><br>ឧ២- គេបាន $F(x)=x^2$ ព្រោះ<br>$F'(x)=2x$ គេថា $F(x)=x^2$<br>ជាព្រីមីទីវនៃ $F'(x)=2x$<br>និយមន័យ៖ $F(x)$ ជាព្រីមីទីវនៃ $f(x)$<br>កាលណា $F'(x)=f(x)$ ចំពោះគ្រប់<br>តម្លៃ $x$ ក្នុងដែនកំណត់នៃអនុគមន៍ $f$<br>ចម្លើយ៖<br>យើងមាន $F(x)=x^3+x^2+x$<br>គេបាន<br>$F'(x)=3x^2+2x+1=f(x)$<br>ដូចនេះ $F(x)$ ជាព្រីមីទីវនៃ $f(x)$<br><br>ក/ រកព្រីមីទីវ $F(x)$ គេមាន | <br><br>-សិស្សស្តាប់គ្រូពន្យល់<br>និងកត់ត្រា<br>ដំណោះស្រាយ<br>តាង $S(t)$ ជាចម្ងាយចរនៅខ<br>ណះពេល $t$ ។ យើងដឹងថា<br>$V(t)=\lim\limits_{\Delta x\to 0}\frac{\Delta S}{\Delta x}=S'(x)$<br>ដូចនេះ<br>គេត្រូវរក $S(t)$ ដែលមាន<br>$S'(t)=V(t)=gt$ គេបាន<br>$S(t)=\frac{1}{2}gt^2$<br>ព្រោះ $S'(t)=gt$<br>$S(t)$ ដែលបានរកឃើញហៅ<br>ថា ព្រីមីទីវនៃ $V(t)=gt$<br><br>ឧ២- គេបាន $F(x)=x^2$ ព្រោះ<br>$F'(x)=2x$<br><br>-សិស្សទាញរកនិយមន័យ<br>ព្រីមីទីវ<br><br>-សិស្សសង្កេតលើលំហាត់គំរូ<br>ចម្លើយ៖យើងមាន<br>$F(x)=x^3+x^2+x$ គេបាន<br>$F'(x)=3x^2+2x+1=f(x)$<br>ដូចនេះ $F(x)$ ជាព្រីមីទីវនៃ<br>$f(x)$<br>-សិស្សឡើងដោះស្រាយ |

| | | |
|---|---|---|
| $x\in IR$ ។<br>ខ/ រកព្រីមីទីវ $G(x)$ នៃ<br>$f(x)=\dfrac{1}{x^2}$ ចំពោះ<br>$x\in(-\infty,0)\cup(0,+\infty)$ ។<br><br>គ/ អនុគមន៍ $H$ កំណត់លើ<br>$]0,+\infty[$ ដោយ<br>$H(x)=(x+1)e^{-\frac{1}{x}}$ ។ បង្ហាញ<br>ថា $H$ ជាព្រីមីទីវមួយនៃ<br>$h(x)=\dfrac{x^2+x+1}{x^2}e^{-\frac{1}{x}}$<br><br>-គ្រូឲ្យសិស្សសង្កេតឧទាហរណ៍រួចទាញរកទ្រឹស្តីបទ<br>ឧ- គេមានអនុគមន៍បីផ្សេងគ្នា<br>$F(x)=x^2$<br>$G(x)=x^2+2008$<br>$H(x)=x^2-29$<br>បង្ហាញថាអនុគមន៍ទាំងនបីជាព្រីមីទីវនៃអនុគមន៍តែមួយ។ | $F'(x)=f(x)=\sin x$ នាំអោយ<br>$F(x)=-\cos x$<br>ដូចនេះ $F(x)=-\cos x$<br>ខ/ រកព្រីមីទីវ $G(x)$ គេមាន<br>$G'(x)=f(x)=\dfrac{1}{x^2}$ នាំអោយ<br>$G(x)=-\dfrac{1}{x}$<br>ដូចនេះ $G(x)=-\dfrac{1}{x}$<br>គ/ បង្ហាញ ថា $H$ ជាព្រីមីទីវមួយនៃ<br>$h(x)$ យើងមាន $H(x)=(x+1)e^{-\frac{1}{x}}$<br>នាំឲ្យ<br>$H'(x)=e^{-\frac{1}{x}}+(-\frac{1}{x})'e^{-\frac{1}{x}}(x+1)$<br>$=e^{-\frac{1}{x}}+\dfrac{1}{x^2}e^{-\frac{1}{x}}(x+1)$<br>$=e^{-\frac{1}{x}}(1+\dfrac{1}{x}+\dfrac{1}{x^2})$<br>$=\dfrac{x^2+x+1}{x^2}e^{-\frac{1}{x}}=h(x)$<br>ដូចនេះ $H$ ជាព្រីមីទីវមួយនៃ $h(x)$ លើ $(0,+\infty)$<br>១.២ ទ្រឹស្តីបទ<br>ដំណោះស្រាយ<br>យើងមាន៖<br>$F'(x)=G'(x)=H'(x)=2x$<br>ដោយអនុគមន៍ទាំងបីមានដេរីវេស្មើគ្នា នោះវាជាព្រីមីទីវនៃអនុគមន៍ $f(x)=2x$ តែមួយ។ គេថា $f(x)=2x$ មានព្រីមីទីវច្រើនរាប់មិនអស់ដែលខុសគ្នាត្រង់តួចំនួនពិតថេរ។ | ក/ រកព្រីមីទីវ $F(x)$ គេមាន<br>$F'(x)=f(x)=\sin x$<br>នាំអោយ $F(x)=-\cos x$<br>ដូចនេះ $F(x)=-\cos x$<br>ខ/ រកព្រីមីទីវ $G(x)$ គេមាន<br>$G'(x)=f(x)=\dfrac{1}{x^2}$<br>នាំអោយ $G(x)=-\dfrac{1}{x}$<br>ដូចនេះ $G(x)=-\dfrac{1}{x}$<br>គ/ បង្ហាញ<br>ថា $H$ ជាព្រីមីទីវមួយនៃ $h(x)$<br>យើងមាន $H(x)=(x+1)e^{-\frac{1}{x}}$<br>នាំឲ្យ $H'(x)$<br>$=e^{-\frac{1}{x}}+\dfrac{1}{x^2}e^{-\frac{1}{x}}(x+1)$<br>$=e^{-\frac{1}{x}}(1+\dfrac{1}{x}+\dfrac{1}{x^2})$<br>$=\dfrac{x^2+x+1}{x^2}e^{-\frac{1}{x}}=h(x)$ ដូចនេះ $H$ ជាព្រីមីទីវមួយនៃ $h(x)$ លើ $(0,+\infty)$<br><br>-សិស្សសង្កេតលើឧទាហរណ៍រួចទាញរកទ្រឹស្តីបទ |

| | | |
|---|---|---|
| | គេតាងព្រីមីទីវនៃ $2x$ ដោយ $x^2+c$<br>ដែល $c$ ជាចំនួនពិតថេរ។<br>ទ្រឹស្តីបទ៖ បើ $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$ នោះសំណុំព្រីមីទីវទាំងអស់នៃ $f$ មានទម្រង់ទូទៅ $F(x)+c$ ដែល $c$ ជាចំនួនពិតថេរ។ | |
| -ឲ្យសិស្សឡើងស្រាយទ្រឹស្តីបទ | សម្រាយបញ្ជាក់៖ គេមានអនុគមន៍ $(F(x)+c)'=F'(x)=f(x)$ ព្រោះ $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$ នោះ $F(x)+c$ ក៏ជាព្រីមីទីវមួយនៃ $f(x)$ ដែរ។ | -សិស្សកត់ត្រា |
| -ឲ្យសិស្សឡើងធ្វើលំហាត់គំរូ<br>លំហាត់គំរូ១៖<br>រកព្រីមីទីវ $F(x)$ នៃ $f(x)=x^2$ ដែល $f(3)=2$ ។ | ចម្លើយ៖ យើនមាន $f(x)=x^2$<br>នោះនាំឲ្យ $F(x)=\frac{1}{3}x^3+c$<br>ដោយ $f(3)=2$ គេបាន<br>$2=\frac{1}{3}3^3+c\Rightarrow c=-7$<br>ដូចនេះ $F(x)=\frac{1}{3}x^3-7$ | -សិស្សឡើងធ្វើលំហាត់គំរូ<br>យើនមាន $f(x)=x^2$<br>នោះនាំឲ្យ $F(x)=\frac{1}{3}x^3+c$<br>ដោយ $f(3)=2$ គេបាន<br>$2=\frac{1}{3}3^3+c\Rightarrow c=-7$<br>ដូចនេះ $F(x)=\frac{1}{3}x^3-7$ |
| -ឲ្យលក្ខណៈសម្គាល់ដល់សិស្ស | សំគាល់៖ គេអាចគណនាចំនួនថេរ $c$ បានកាលណាគេស្គាល់តម្លៃព្រីមីទីវចំពោះតម្លៃ $x$ ណាមួយ។ | -សិស្សកត់ត្រា |
| លំហាត់គំរូ២៖<br>ក/ ដោយប្រើដេរីវេ បង្ហាញថា អនុគមន៍ $G(x)=\frac{3}{2}x^2+4x$ ជាព្រីមីទីវមួយនៃអនុគមន៍ដែលនឹងត្រូវកំណត់។<br>ខ/ ដោយប្រើលទ្ធផលនូវសំនួរ «ក» ចូរបង្ហាញថា $F(x)=\frac{1}{6}(3x+4)^2$ គឺជាព្រីមីទីវនៃអនុគមន៍ $f$ ដែរ។ | ចម្លើយ៖ ក/ យើងមាន<br>$G(x)=\frac{3}{2}x^2+4x$ នោះគេបាន<br>$G'(x)=3x+4$<br>ដូចនេះ<br>$G(x)$ ជាព្រីមីទីវនៃ $f(x)=3x+4$<br>ខ/ យើងមាន $F(x)=\frac{1}{6}(3x+4)^2$<br>នាំឲ្យ<br>$F'(x)=\frac{1}{6}6(3x+4)=3x+4$ | ក/ យើងមាន<br>$G(x)=\frac{3}{2}x^2+4x$<br>នោះគេបាន $G'(x)=3x+4$<br>ដូចនេះ<br>$G(x)$ ជាព្រីមីទីវនៃ<br>$f(x)=3x+4$<br>ខ/ យើងមាន<br>$F(x)=\frac{1}{6}(3x+4)^2$<br>នាំឲ្យ |

| | | |
|---|---|---|
| -ឲ្យសិស្សកត់ត្រា | ដោយ $G(x)$ ជាព្រីមីទីវនៃ $f(x)=3x+4$ នោះ $F(x)$ ក៏ជាព្រីមីទីវនៃ $f(x)=3x+4$ ដែរ។ | $F'(x)=\frac{1}{6}6(3x+4)=3x+4$ <br>ដោយ $G(x)$ ជាព្រីមីទីវនៃ $f(x)=3x+4$ <br>នោះ $F(x)$ ក៏ជាព្រីមីទីវនៃ $f(x)=3x+4$ ដែរ។ <br>-សិស្សកត់ត្រា |
| -ឲ្យសិស្សធ្វើលំហាត់ប្រតិបត្តិក/ រកព្រីមីទីវ $F(x)$ នៃ $f(x)=\cos x+1$ ដែល $f(\frac{\pi}{3})=3$ ។ | <u>ជំហានទី៤</u> <br>(ពង្រឹងចំណេះដឹង ១៥នាទី) <br>ចម្លើយ៖ ព្រីមីទីវនៃ $f(x)=\cos x+1$ គឺ $F(x)=\sin x+x+c$ ព្រោះ $F'(x)=\cos x+1$ ដោយ $f(\frac{\pi}{3})=3$ <br>នាំឲ្យ $3=\sin\frac{\pi}{3}+\frac{\pi}{3}+c$ <br>គេបាន $c=\frac{6-\sqrt{3}}{2}-\frac{\pi}{3}$ <br>ដូចនេះ <br>$F(x)=\sin x+x+\frac{6-\sqrt{3}}{2}-\frac{\pi}{3}$ | -សិស្សឡើងដោះស្រាយ <br>ព្រីមីទីវនៃ $f(x)=\cos x+1$ <br>$F(x)=\sin x+x+c$ ព្រោះ <br>$F'(x)=\cos x+1$ ដោយ <br>$f(\frac{\pi}{3})=3$ នាំឲ្យ <br>$3=\sin\frac{\pi}{3}+\frac{\pi}{3}+c$ <br>គេបាន $c=\frac{6-\sqrt{3}}{2}-\frac{\pi}{3}$ <br>ដូចនេះ <br>$F(x)=\sin x+x+\frac{6-\sqrt{3}}{2}-\frac{\pi}{3}$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ <br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u> <br>(កិច្ចការផ្ទះ ៥នាទី) <br>លំហាត់៖ បង្ហាញថាអនុគមន៍ $F(x)=\frac{x^2}{x^2+5x}$ និង $G(x)=\frac{-5}{x+5}$ ជាព្រីមីទីវនៃអនុគមន៍តែមួយ។ | -សិស្សកត់លំហាត់ និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**…៤….

មេរៀនទី…១… **ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**

**- មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)**

**- ជំពូកទី៤ : អាំងតេក្រាល**

**- មេរៀនទី១ : ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**

**- បង្រៀនដោយ : សាស្ត្រាចារ្យ ................................**

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : សិស្សកំណត់និយមន័យអាំងតេក្រាលមិនកំណត់ នៃអនុគមន៍តាមរយៈការបង្ហាញរបស់គ្រូ។

-បំណិន : សិស្សអនុវត្តរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់ក្នុងការដោះស្រាយលំហាត់បានត្រឹមត្រូវតាមរយៈការពន្យល់របស់គ្រូ។

-ឥរិយាបថ : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយៈការណែនាំរបស់គ្រូ។

II.ពេលវេលា: …២…ម៉ោង ថ្ងៃ……………..ទី……………..ខែ………….ឆ្នាំ……….

III.សម្ភារៈឧទេស

-ស . ស :ទំព័រទី.១១០.. ដល់ទំព័រទី.១១២...

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-តារាងរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -បើ $F'(x)=f(x)$ នោះ $F(x)$ ហៅថាអ្វីនៃ $f(x)$? | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី)<br>$F(x)$ ហៅថាជាព្រីមីទីវនៃ $f(x)$ | $F(x)$ ហៅថាជាព្រីមីទីវនៃ $f(x)$ |
| | ជំហានទី៣ | |

| | | |
|---|---|---|
| | (មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី១:**<br>**ព្រីមីទីវនិងអាំងតេក្រាលមិនកំណត់**<br>២. អាំងតេក្រាលមិនកំណត់<br>១.១ និយមន័យ | |
| -ណែនាំសិស្សឲ្យសង្កេតលើឧទាហរណ៍<br>ឧ១-គេមានអនុគមន៍ $H,G$ និង $F$ ដែលកំណត់ដោយ<br>$H(x)=x^4+x^3+7$<br>$G(x)=x^4+x^3+2002$ និង<br>$F(x)=x^4+x^3+c$ ដែល $c$<br>-តើ $H(x)$ $G(x)$ និង $F(x)$ ជាព្រីមីទីវនៃអនុគមន៍ $f(x)=4x^3+3x^2$ ឬទេ? | ដំណោះស្រាយ<br>គេបាន $H'(x)=4x^3+3x^2=f(x)$<br>$G'(x)=4x^3+3x^2=f(x)$ និង<br>$F'(x)=4x^3+3x^2=f(x)$<br>ដូចនេះ $H(x)$ $G(x)$ និង $F(x)$ ជាព្រីមីទីវនៃអនុគមន៍<br>$f(x)=4x^3+3x^2$ | -សិស្សសង្កេតលើឧទាហរណ៍រួចកត់ត្រា |
| -តើសំណុំព្រីមីទីវទាំងអស់ហៅថាអ្វី? | -ហៅថាអាំងតេក្រាលមិនកំណត់ | -ហៅថាអាំងតេក្រាលមិនកំណត់ |
| -គ្រូឲ្យសិស្សទាញរកនិយមន័យអាំងតេក្រាលមិនកំណត់ | និយមន័យ៖ បើ $F(x)$ ជាព្រីមីទីវនៃ $f(x)$ នោះអាំងតេក្រាលមិនកំណត់នៃ $f(x)$ កំណត់ដោយ<br>$\int f(x)dx=F(x)+c$ ដែល $c$ ជាចំនួនពិតថេរ។ | -ទាញរកនិយមន័យ |
| -គ្រូឲ្យឧទាហរណ៍ទី២ | -ឧទាហរណ៍ទី២៖<br>គេសង្កេតឃើញថាព្រីមីទីវនៃអនុគមន៍ $f(x)=4x^3+3x^2$ គឺជាអនុគមន៍ $F(x)=x^4+x^3+c$ ដែល $c$ ជាចំនួនពិតថេរ។ ដូចនេះ<br>$\int(4x^3+3x^2)dx=x^4+x^3+c$<br>ដែល $c$ ជាចំនួនពិតថេរ។ | -សង្កេតលើឧទាហរណ៍ទី២ |

| | | |
|---|---|---|
| -ឲ្យសិស្សពិភាក្សាជាដៃគូ រួចឡើងរកដេរីវេនៃអនុគមន៍<br>១/ $F(x)=5x$<br>២/ $F(x)=-4x+9$<br>-រួចទាញរកអាំងតេក្រាល នៃអនុគមន៍និមួយៗ<br><br>-ឲ្យសិស្សទាញរកជាទូទៅ<br>$\int kdx=?$ បើ $k\neq 0$<br><br>-ឲ្យសិស្សគណនា $\int dx$<br>-ឲ្យសិស្សសង្កេតតាមការពន្យល់របស់គ្រូ<br><br>-បែងចែកសិស្សជា៤ក្រុមឲ្យគណនាដេរីវេនៃអនុគមន៍ខាងក្រោម៖<br>1- $F(x)=\frac{1}{2}x^2$<br>2- $F(x)=\frac{1}{3}x^3$<br>3- $F(x)=-\frac{1}{x}$<br>4- $F(x)=-\frac{1}{x}+5$<br>រួចឲ្យសិស្សទាញរកអាំងតេក្រា | ១.២ រូបមន្តគ្រឹះនៃអាំងតេក្រាលមិនកំណត់<br>ចម្លើយ៖ ១/ $F(x)=5x$<br>$\Rightarrow F'(x)=5$ គេកំណត់បាន<br>$\int 5dx=5x+c$<br>២/ $F(x)=-4x+9$<br>$\Rightarrow F'(x)=-4$ គេកំណត់បាន<br>$\int(-4)dx=-4x+c$<br><br>ជាទូទៅ៖<br>បើ $k\neq 0$ នោះ $\int kdx=kx+c$<br>ដែល $c$ ជាចំនួនពិតថេរ<br>សម្គាល់៖ $\int dx=x+c;c\in IR$<br>-ដោយ $\int f(x)dx=F(x)+c$<br>$\Leftrightarrow f(x)=[F(x)+c]'$<br>គេបាន<br>$[k\int f(x)dx]'=k[\int f(x)dx]'$<br>$=k[F(x)+c]'=kf(x)$<br>ជាទូទៅ៖ បើ $k\neq 0$ នោះ៖<br>$\int kf(x)dx=k\int f(x)dx$<br>1- $F(x)=\frac{1}{2}x^2\Rightarrow F'(x)=x$<br>នោះ៖ $\int xdx=\frac{1}{2}x^2+c$<br>2- $F(x)=\frac{1}{3}x^3\Rightarrow F'(x)=x^2$<br>នោះ៖ $\int x^2dx=\frac{1}{3}x^3+c$<br>3- $F(x)=-\frac{1}{x}\Rightarrow F'(x)=\frac{1}{x^2}$<br>នោះ៖ $\int\frac{1}{x^2}dx=-\frac{1}{x}+c$ | -សិស្សពិភាក្សា រួចឡើងគណនា<br>១/ $F(x)=5x$<br>$\Rightarrow F'(x)=5$ គេកំណត់បាន<br>$\int 5dx=5x+c$<br>២/ $F(x)=-4x+9$<br>$\Rightarrow F'(x)=-4$ គេកំណត់បាន<br>$\int(-4)dx=-4x+c$<br>-ទាញរកលក្ខណះជាទូទៅ<br><br>$\int dx=x+c;c\in IR$<br>-សិស្សសង្កេត<br><br>-សិស្សពិភាក្សា រួចឡើងគណនា<br>1- $F(x)=\frac{1}{2}x^2\Rightarrow F'(x)=x$<br>2- $F(x)=\frac{1}{3}x^3\Rightarrow F'(x)=x^2$<br>3- $F(x)=-\frac{1}{x}\Rightarrow F'(x)=\frac{1}{x^2}$<br>4- $F(x)=-\frac{1}{x}+5\Rightarrow F'(x)=\frac{1}{x^2}$ |

| | | |
|---|---|---|
| លនៃដេរីវេ នៃអនុគមន៍និមួយៗ<br><br>បែងចែកសិស្សជា៤ក្រុមដដែល គណនាដេរីវេនៃអនុគមន៍ខាងក្រោម៖<br>1- $F(x)=\frac{x^2}{2}+e^x-5$<br>2- $F(x)=2\sqrt{x}$<br>-រូចទាញរកអាំងតេក្រាល នៃអនុគមន៍និមួយៗ<br><br>-តាមរូបមន្ត<br>$\int kf(x)dx=k\int f(x)dx$<br>ឲ្យសិស្សទាញរក<br>$\int[c_1f_1(x)+c_2f_2(x)+.......+c_nf_n(x)]dx$<br>-<br>ដាក់លំហាត់គំរូដោយកែឲ្យសិស្ស | 4- $F(x)=-\frac{1}{x}+5\Rightarrow F'(x)=\frac{1}{x^2}$<br>នោះ៖ $\int\frac{1}{x^2}dx=-\frac{1}{x}+c$<br>ជាទូទៅ៖<br>$\int x^n dx=\frac{x^{n+1}}{n+1}+c;c\in IR,n\neq-1$<br>$\int\frac{1}{x^2}dx=-\frac{1}{x}+c;c\in IR$<br>1- $F(x)=\frac{x^2}{2}+e^x-5$<br>$\Rightarrow F'(x)=x+e^x$<br>នោះ៖ $\int(x+e^x)dx=\frac{1}{2}x^2+e^x+c$<br>2- $F(x)=2\sqrt{x}\Rightarrow F'(x)=\frac{1}{\sqrt{x}}$<br>នោះ៖ $\int\frac{1}{\sqrt{x}}dx=2\sqrt{x}+c$<br>ជាទូទៅ៖<br>$\int[f(x)\pm g(x)]dx=\int f(x)dx\pm\int g(x)dx$<br>$\int\frac{1}{\sqrt{x}}dx=2\sqrt{x}+c;c\in IR$<br>គេទាញបាន<br>$\int[c_1f_1(x)+c_2f_2(x)+.......+c_nf_n(x)]dx$<br>$=c_1\int f_1(x)dx+c_2\int f_2(x)dx+.......+c_n\int f_n(x)dx$<br>លំហាត់គំរូ៖ គណនាអាំងតេក្រាល<br>1- $\int 8x^2dx$ 2- $\int(3e^x+\frac{1}{4}x^2-6)dx$<br>ចម្លើយ៖ គណនាអាំងតេក្រាល<br>1- $\int 8x^2dx=8\frac{x^{2+1}}{2+1}+c=\frac{8}{3}x^3+c$<br>2- $\int(3e^x+\frac{1}{4}x^2-6)dx=3\int e^xdx+\frac{1}{4}\int x^2dx-\int 6dx$<br>$=3e^x+\frac{1}{4}\frac{x^3}{3}-6x+c=3e^x+\frac{x^3}{12}-6x+c$ | -សិស្សពិភាក្សា រួចឡើងគណនា<br>1- $F(x)=\frac{x^2}{2}+e^x-5$<br>$\Rightarrow F'(x)=x+e^x$<br>នោះ៖ $\int(x+e^x)dx=\frac{1}{2}x^2+e^x+c$<br>2- $F(x)=2\sqrt{x}\Rightarrow F'(x)=\frac{1}{\sqrt{x}}$<br>នោះ៖ $\int\frac{1}{\sqrt{x}}dx=2\sqrt{x}+c$<br><br>ដោយ $\int kf(x)dx=k\int f(x)dx$<br>ហើយ $\int kf(x)dx=k\int f(x)dx$<br>គេបាន<br>$\int[c_1f_1(x)+c_2f_2(x)+.......+c_nf_n(x)]dx$<br>$=c_1\int f_1(x)dx+c_2\int f_2(x)dx+.......+c_n\int f_n(x)dx$<br>-សិស្សសង្កេត និងកត់ត្រា |

| | | |
|---|---|---|
| -ឲ្យសិស្សពីរនាក់ឡើងគណនា<br>-$F'(x)$ កាលណា<br>$F(x)=\ln\|x\|;(x>0)$<br>-$G'(x)$ កាលណា<br>$G(x)=\ln\|x\|;(x<0)$ | 2.3 អាំងតេក្រាលមិនកំណត់<br>នៃ $y=e^x$ និង $y=\frac{1}{x}$<br>ឧ- បើ $x>0\Rightarrow F(x)=\ln x$<br>គេបាន $\Rightarrow F'(x)=\frac{1}{x}$<br>- បើ $x<0\Rightarrow G(x)=\ln(-x)$<br>គេបាន $\Rightarrow G'(x)=\frac{1}{x}$ | $F'(x)=\frac{1}{x}$<br>$G'(x)=\frac{1}{x}$<br>គេបាន $F'(x)=G'(x)$ |
| -ឲ្យសិស្សទាញរក<br>$\int\frac{1}{x}dx=........?$ | យើងសង្កេតឃើញថា<br>$F(x)=\ln x;(x>0)$ និង<br>$G(x)=\ln x;(x<0)$ មាន<br>$F'(x)=G'(x)=\frac{1}{x}$<br>ដូច្នេះ<br>$\int\frac{1}{x}dx=\ln\|x\|+c;c\in IR;x\neq 0$ | $\int\frac{1}{x}dx=\ln\|x\|+c;c\in IR;x\neq 0$ |
| -ឲ្យសិស្សពីរនាក់ឡើងគណនា<br>-$F'(x)$ កាលណា $F(x)=e^x+8$<br>-$F'(x)$ កាលណា $F(x)=e^x+c$<br>-ឲ្យសិស្សទាញរក<br>$\int e^x dx=........?$ | ដោយ $F(x)=e^x+8\Rightarrow F'(x)=e^x$<br>$F(x)=e^x+c\Rightarrow F'(x)=e^x$<br>ដូច្នេះ $\int e^x dx=e^x+c;c\in IR$ | $F(x)=e^x+8\Rightarrow F'(x)=e^x$<br>$F(x)=e^x+c\Rightarrow F'(x)=e^x$<br>គេបាន<br>$\int e^x dx=e^x+c;c\in IR$ |
| -ដាក់លំហាត់គំរូឲ្យសិស្សអនុវត្ត តាមរូបមន្តដោយកែឲ្យនូវលំ ហាត់ទី១<br>1- $\int 3e^x dx=3e^x+c$<br>រួចឲ្យសិស្សកែលំហាត់ទី២ ៣ | លំហាត់គំរូ៖ គណនាអាំងតេក្រាល<br>1- $\int 3e^x dx$ 2- $\int\frac{6}{x}dx$<br>3- $\int(6e^x-\frac{10}{x}+\frac{4}{x})dx$<br>ចម្លើយ៖ 1- $\int 3e^x dx=3e^x+c$<br>2- $\int\frac{6}{x}dx=6\int\frac{1}{x}dx=6\ln\|x\|+c$<br>3- $\int(6e^x-\frac{10}{x}+\frac{4}{x})dx$<br>$=6\int e^x dx-10\int\frac{1}{x}dx+4\int\frac{1}{x}dx$ | -សង្កេតគ្រូណែនាំ<br>រួចធ្វើលំហាត់ទី២ ៣<br>2- $\int\frac{6}{x}dx=6\int\frac{1}{x}dx=6\ln\|x\|+c$<br>3- $\int(6e^x-\frac{10}{x}+\frac{4}{x})dx$<br>$=6\int e^x dx-10\int\frac{1}{x}dx+4\int\frac{1}{x}dx$<br>$=6e^x-6\ln\|x\|+c$ |

| | | |
|---|---|---|
| | $=6e^x-10\ln\lvert x\rvert+4\ln\lvert x\rvert+c$<br>$=6e^x-6\ln\lvert x\rvert+c$ | |
| -ឲ្យសិស្សសរសេររូបមន្តគ្រឹះនៃអាំងតេក្រាលមិនកំណត់ខាងក្រោម៖<br>1- $\int kdx=?$<br>2- $\int x^n dx=?$ បើ $n\neq -1$<br>3- $\int \frac{1}{x^2}dx=?$<br>4- $\int[f(x)\pm g(x)]dx=?$ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>1- $\int kdx=kx+c$<br>2- $\int x^n dx=\frac{x^{n+1}}{n+1}+c$ បើ $n\neq -1$<br>3- $\int \frac{1}{x^2}dx=-\frac{1}{x}+c$<br>4- $\int[f(x)\pm g(x)]dx=\int f(x)dx\pm\int g(x)dx$ | -សិស្សឡើងសរសេររូបមន្ត<br>1- $\int kdx=kx+c$<br>2- $\int x^n dx=\frac{x^{n+1}}{n+1}+c$ បើ $n\neq -1$<br>3- $\int \frac{1}{x^2}dx=-\frac{1}{x}+c$<br>4- $\int[f(x)\pm g(x)]dx$<br>$=\int f(x)dx\pm\int g(x)dx$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី)<br>លំហាត់៖ គណនាអាំងតេក្រាល<br>ក/ $\int(7x^6+5x^4-8)dx$<br>ខ/ $\int(2x^2-\frac{1}{x^2}+\frac{2}{\sqrt{x}}+1)dx$<br>គ/ $\int(x^2+2\sqrt{x})dx$ | -សិស្សកត់លំហាត់<br>និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៤....

មេរៀនទី...១... **ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**

- **មុខវិជ្ជា** : **គណិតវិទ្យា** **ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)**
- **ជំពូកទី៤** : **អាំងតេក្រាល**
- **មេរៀនទី១** : **ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**
- **បង្រៀនដោយ : សាស្ត្រាចារ្យ** ................................

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : សិស្សកំណត់បានរូបមន្តអាំងតេក្រាលមិនកំណត់ នៃអនុគមន៍ត្រីកោណមាត្រ តាមរយៈការបង្ហាញរបស់គ្រូ។

-បំណិន : សិស្សអនុវត្តរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់នៃអនុគមន៍ត្រីកោណមាត្រ ក្នុងការដោះស្រាយលំហាត់បានត្រឹមត្រូវ តាមរយៈការពន្យល់របស់គ្រូ។

-ឥរិយាបថ : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយៈការណែនាំរបស់គ្រូ។

II.ពេលវេលា: ...២...ម៉ោង ថ្ងៃ.................ទី.................ខែ..............ឆ្នាំ..........

III.សម្ភារៈឧទេស

-ស . ស :ទំព័រទី.១១៧.. ដល់ទំព័រទី.១១៨...

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-តារាងរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងធ្វើលំហាត់ គណនា៖<br>ក/ $\int(3x^5+2x^2+x)dx$ | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី)<br>ចម្លើយ៖<br>ក/ $\int(3x^5+2x^2+x)dx$<br>$=\frac{1}{2}x^6+\frac{2}{3}x^3+\frac{1}{2}x^2+c$ | ក/ $\int(3x^5+2x^2+x)dx$<br>$=3\int x^5dx+2\int x^2dx+\int xdx$ |

| | | |
|---|---|---|
| ខ/ $\int (\frac{1}{x^4}+\frac{2}{x})dx$ | ខ/ $\int (\frac{1}{x^4}+\frac{2}{x})dx$<br>$=-\frac{1}{3x^3}+2\ln\|x\|+c$ | $=\frac{1}{2}x^6+\frac{2}{3}x^3+\frac{1}{2}x^2+c$<br>ខ/ $\int (\frac{1}{x^4}+\frac{2}{x})dx$<br>$=\int x^{-4}dx+2\int\frac{1}{x}dx$<br>$=-\frac{1}{3x^3}+2\ln\|x\|+c$ |
| -ដាក់ឧទាហរណ៍ឲ្យសិស្សគណនាដេរីវេនៃអនុគមន៍ខាងក្រោម៖<br>$F(x)=-\cos x+5$<br>$F(x)=-\cos x-7$<br>$F(x)=-\cos x+c$<br><br>-សួរសិស្សឲ្យទាញរក<br>$\int \sin xdx=?$<br>-ដាក់ឧទាហរណ៍ឲ្យសិស្សគណនាដេរីវេនៃអនុគមន៍ខាងក្រោម៖<br>$F(x)=\sin x+4$<br>$F(x)=\sin x-10$<br>សួរសិស្សបើ<br>$F(x)=\sin x+c$ តើ<br>$F'(x)=?$<br>-សួរសិស្សឲ្យទាញរក<br>$\int \cos xdx=?$ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី១:**<br>**ព្រីមីទីវនិងអាំងតេក្រាលមិនកំណត់**<br>២.៤ អាំងតេក្រាលមិនកំណត់នៃអនុគមន៍ត្រីកោណមាត្រ<br>បើ $F(x)=-\cos x+5$ នោះ<br>$F'(x)=\sin x$<br>បើ $F(x)=-\cos x-7$ នោះ<br>$F'(x)=\sin x$<br>បើ $F(x)=-\cos x+c$ នោះ<br>$F'(x)=\sin x$<br>រូបមន្ត៖<br>$\int \sin xdx=-\cos x+c; c\in IR$<br>ចម្លើយ៖ $F(x)=\sin x+4$<br>$\Rightarrow F'(x)=\cos x$<br>$F(x)=\sin x-10$<br>$\Rightarrow F'(x)=\cos x$<br><br>$F(x)=\sin x+c$<br>$\Rightarrow F'(x)=\cos x$<br>រូបមន្ត៖<br>$\int \cos xdx=\sin x+c; c\in IR$ | -សង្កេតរួចគណនា<br><br>-$\int \sin xdx=-\cos x+c$<br><br>សិស្សគណនា៖<br>$F(x)=\sin x+4$<br>$\Rightarrow F'(x)=\cos x$<br>$F(x)=\sin x-10$<br>$\Rightarrow F'(x)=\cos x$<br>$F(x)=\sin x+c$<br>$\Rightarrow F'(x)=\cos x$<br>សិស្សទាញរក<br>$\int \cos xdx=\sin x+c$ |

| | | |
|---|---|---|
| ដាក់ឧទាហរណ៍ឲ្យសិស្សគណនាដេរីវេនៃអនុគមន៍ខាងក្រោម៖<br>$F(x)=\tan x+2$<br>$F(x)=\tan x-3$ | ចម្លើយ៖ $F(x)=\tan x+2$<br>$\Rightarrow F'(x)=\frac{1}{\cos^2 x}$<br>$F(x)=\tan x-3$<br>$\Rightarrow F'(x)=\frac{1}{\cos^2 x}$ | សិស្សគណនា៖<br>$F(x)=\tan x+2$<br>$\Rightarrow F'(x)=\frac{1}{\cos^2 x}$<br>$F(x)=\tan x-3$<br>$\Rightarrow F'(x)=\frac{1}{\cos^2 x}$ |
| -សួរសិស្សឲ្យទាញរក<br>$\int\frac{1}{\cos^2 x}dx=?$<br>ដាក់ឧទាហរណ៍ឲ្យសិស្សគណនាដេរីវេនៃអនុគមន៍ខាងក្រោម៖<br>$F(x)=-\cot x+1$<br>$F(x)=-\cot x-5$ | រូបមន្ត៖<br>$\int\frac{1}{\cos^2 x}dx=\tan x+c; c\in IR$<br>ចម្លើយ៖ $F(x)=-\cot x+1$<br>$\Rightarrow F'(x)=\frac{1}{\sin^2 x}$<br>$F(x)=-\cot x-5$<br>$\Rightarrow F'(x)=\frac{1}{\sin^2 x}$ | សិស្សទាញរក<br>$\int\frac{1}{\cos^2 x}dx=\tan x+c$<br>សិស្សគណនា<br>$F(x)=-\cot x+1$<br>$\Rightarrow F'(x)=\frac{1}{\sin^2 x}$<br>$F(x)=-\cot x-5$<br>$\Rightarrow F'(x)=\frac{1}{\sin^2 x}$ |
| -សួរសិស្សឲ្យទាញរក<br>$\int\frac{1}{\sin^2 x}dx=?$<br>-ឲ្យលំហាត់គំរូដល់សិស្ស<br>លំហាត់៖ គណនាអាំងតេក្រាល<br>ក/ $A=\int(5\sin x-3\cos x)dx$<br>ខ/ $B=\int(\frac{2}{\cos^2 x}+\frac{3}{\sin^2 x})dx$<br>គ/ $C=\int(\tan x+\cot x)^2dx$ | រូបមន្ត៖<br>$\int\frac{1}{\sin^2 x}dx=-\cot x+c; c\in IR$<br>ចម្លើយ៖ គណនាអាំងតេក្រាល<br>ក/ $A=\int(5\sin x-3\cos x)dx$<br>$=5\int\sin xdx-3\int\cos xdx$<br>$=-5\cos x-3\sin x+c$<br>ខ/ $B=\int(\frac{2}{\cos^2 x}+\frac{3}{\sin^2 x})dx$<br>$=2\int\frac{1}{\cos^2 x}dx+3\int\frac{1}{\sin^2 x}dx$<br>$=2\tan x-3\cot x+c$<br>គ/ $C=\int(\tan x+\cot x)^2dx$<br>$=\int(\tan^2 x+2+\cot^2 x)dx$<br>$=\int\frac{1}{\cos^2 x}dx+\int\frac{1}{\sin^2 x}dx$<br>$=\tan x-\cot x+c$ | សិស្សទាញរក<br>$\int\frac{1}{\sin^2 x}dx=-\cot x+c$<br>-សិស្សសង្កេតលើលំហាត់គំរូរួចកត់ត្រា |

| | | |
|---|---|---|
| -ចែកសិស្សជាបួនក្រុម រួចឲ្យសិស្សគណនាលំហាត់ប្រតិបត្តិ<br>ប្រតិបត្តិ៖ គណនាអាំងតេក្រាល<br>ក/ $A=\int(\frac{2}{3}\cos x+\sin x)dx$<br>ខ/ $B=\int(\frac{4}{\cos^2 x}+\frac{1}{\sin^2 x}-5)dx$<br>គ/ $C=\int(1+\cos x)dx$<br>ឃ/ $D=\int(3\sin+5\cos x)dx$ | ចម្លើយ៖<br>ក/ $A=\int(\frac{2}{3}\cos x+\sin x)dx$<br>$=\frac{2}{3}\sin x-\cos x+c$<br>ខ/ $B=\int(\frac{4}{\cos^2 x}+\frac{1}{\sin^2 x}-5)dx$<br>$=4\tan x-\cot x-5x+c$<br>គ/ $C=\int(1+\cos x)dx$<br>$=x+\sin x+c$<br>ឃ/ $D=\int(3\sin x+5\cos x)dx$<br>$=-3\cos x+5\sin x+c$ | សិស្សពិភាក្សាគ្នាតាមក្រុម រួចតំណាងក្រុមឡើងសរសេរចម្លើយលើក្ដារខៀន |
| -ឲ្យសិស្សឆ្លើយនឹងសំនួរខាងក្រោម<br>1- $\int\sin x=?$<br>2- $\int\cos x dx=?$<br>3- $\int\frac{1}{\cos^2 x}dx=?$<br>4- $\int\frac{1}{\sin^2 x}dx=?$ | **<u>ជំហានទី៤</u>**<br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>ចម្លើយ៖<br>1- $\int\sin x=-\cos x+c$<br>2- $\int\cos x dx=\sin x+c$<br>3- $\int\frac{1}{\cos^2 x}dx=\tan x+c$<br>4- $\int\frac{1}{\sin^2 x}dx=-\cot x+c$ | -សិស្សឡើងសរសេររូបមន្ត<br>1- $\int\sin x=-\cos x+c$<br>2- $\int\cos x dx=\sin x+c$<br>3- $\int\frac{1}{\cos^2 x}dx=\tan x+c$<br>4- $\int\frac{1}{\sin^2 x}dx=-\cot x+c$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | **<u>ជំហានទី៥</u>**<br>(កិច្ចការផ្ទះ ៥នាទី)<br>លំហាត់៖ គណនាអាំងតេក្រាល<br>ក/ $\int\frac{\cos 2x}{\sin^2 x\cos^2 x}dx$<br>ខ/ $\int\frac{dx}{\sin^2 x\cos^2 x}$ | -សិស្សកត់លំហាត់ និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៤....

មេរៀនទី...១... **ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**

- **មុខវិជ្ជា** : **គណិតវិទ្យា** **ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)**
- **ជំពូកទី៤** : **អាំងតេក្រាល**
- **មេរៀនទី១** : **ព្រីមីទីវ និងអាំងតេក្រាលមិនកំណត់**
- **បង្រៀនដោយ : សាស្ត្រាចារ្យ** ...............................

**I.**<u>វត្ថុបំណងនៃមេរៀន</u>

-ចំណេះដឹង : សិស្សកំណត់បានរបៀបគណនាអាំងតេក្រាលដោយប្រើអថេរជំនួយ និងរូបមន្តអាំងតេក្រាលដោយផ្នែក តាមរយៈការបង្ហាញរបស់គ្រូ។

-បំណិន : សិស្សអនុវត្តគណនាអាំងតេក្រាលដោយប្រើអថេរជំនួយ និងអាំងតេក្រាលដោយផ្នែកក្នុងការ ដោះស្រាយលំហាត់បានត្រឹមត្រូវ តាមរយៈការពន្យល់របស់គ្រូ។

-ឥរិយាបថ : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយៈការណែនាំរបស់គ្រូ។

**II.**<u>ពេលវេលា:</u> ...២...ម៉ោង ថ្ងៃ.................ទី.................ខែ..............ឆ្នាំ...........

**III.**<u>សម្ភារៈឧទេស</u>

-ស . ស :ទំព័រទី.១១៩.. ដល់ទំព័រទី.១២២...

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-តារាងរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់

**IV.**<u>ដំណើកនាំមេរៀន</u>

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | <u>ជំហានទី១</u><br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងធ្វើលំហាត់ | <u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់ ៧នាទី)<br>ចម្លើយៈ | សិស្សឡើងគណនា |

| | | |
|---|---|---|
| គណនាអាំងតេក្រាល៖<br>ក/ $\int \frac{\cos 2x}{\sin^2 x\cos^2 x}dx$<br>ខ/ $\int \frac{dx}{\sin^2 x\cos^2 x}$ | ក/ $\int \frac{\cos 2x}{\sin^2 x\cos^2 x}dx$<br>$=\int \frac{\cos^2 x-\sin^2 x}{\cos^2 x\sin^2 x}dx$<br>$=\int (\frac{1}{\sin^2 x}-\frac{1}{\cos^2 x})dx$<br>$=-\cot x-\tan x+c$<br>ខ/ $\int \frac{dx}{\sin^2 x\cos^2 x}$<br>$=\int (\frac{1}{\cos^2 x}+\frac{1}{\sin^2 x})dx$<br>$=\tan x-\cot x+c$ | ក/ $\int \frac{\cos 2x}{\sin^2 x\cos^2 x}dx$<br>$=\int \frac{\cos^2 x-\sin^2 x}{\cos^2 x\sin^2 x}dx$<br>$=\int (\frac{1}{\sin^2 x}-\frac{1}{\cos^2 x})dx$<br>$=-\cot x-\tan x+c$<br>ខ/ $\int \frac{dx}{\sin^2 x\cos^2 x}$<br>$=\int (\frac{1}{\cos^2 x}+\frac{1}{\sin^2 x})dx$<br>$=\tan x-\cot x+c$ |
| -ដាក់ឧទាហរណ៍ឲ្យសិស្ស<br>គណនាអាំងតេក្រាល<br>$\int (x^2+1)^5 xdx$<br>-ណែនាំសិស្សឲ្យតាង<br>$t=x^2+1$<br>-ដាក់ឧទាហរណ៍ឲ្យសិស្ស<br>គណនាអាំងតេក្រាល<br>ក/ $A=\int \sin(2x+1)dx$<br>ខ/ $B=\int \sin^2 x\cos xdx$ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី១:**<br>**ព្រីមីទីវនិងអាំងតេក្រាលមិនកំណត់**<br>២.៥ ការគណនាអាំងតេក្រាលមិនកំណត់ដោយប្រើអថេរជំនួយ និងអាំងតេក្រាលដោយផ្នែក<br>ក/ ការគណនាអាំងតេក្រាលដោយប្រើអថេរជំនួយ<br>ចម្លើយ៖ $\int (x^2+1)^5 2xdx$<br>តាង $t=x^2+1\Rightarrow dt=2xdx$<br>គេបាន $\int (x^2+1)^5 2xdx$<br>$=\int t^5dt=\frac{1}{6}t^6+c=\frac{(x^2+1)^6}{6}+c$<br>ចម្លើយ៖ គណនា<br>ក/ $A=\int \sin(2x+1)dx$<br>តាង $u=2x+1\Rightarrow du=2dx$<br>គេបាន $A=\frac{1}{2}\int \sin tdt$<br>$=-\frac{1}{2}\cos t+c=-\frac{1}{2}\cos(2x+1)+c$ | -សង្កេតរួចគណនា<br>$\int (x^2+1)^5 2xdx$<br>តាង $t=x^2+1\Rightarrow dt=2xdx$<br>គេបាន $\int (x^2+1)^5 2xdx$<br>$=\int t^5dt=\frac{1}{6}t^6+c=\frac{(x^2+1)^6}{6}$<br>-សិស្សគណនា<br>ក/ $A=\int \sin(2x+1)dx$<br>តាង<br>$u=2x+1\Rightarrow du=2dx$<br>គេបាន $A=\frac{1}{2}\int \sin tdt$ |

| | | |
|---|---|---|
| | ខ/ $B=\int \sin^2 x\cos x dx$<br>តាង $t=\sin x \Rightarrow dt=\cos x dx$<br>គេបាន $B=\int t^2 dt=\frac{1}{3}t^3+c$<br>$=\frac{1}{3}\sin^3 x+c$ | $=-\frac{1}{2}\cos t+c=-\frac{1}{2}\cos(2x+1)$<br>ខ/ $B=\int \sin^2 x\cos x dx$<br>តាង<br>$t=\sin x \Rightarrow dt=\cos x dx$<br>គេបាន $B=\int t^2 dt=\frac{1}{3}t^3+c$<br>$=\frac{1}{3}\sin^3 x+c$ |
| -ឲ្យសិស្សពិភាក្សាទាញរកវិធាន ដើម្បីគណនាអាំងតេក្រាលដោយប្រើអថេរជំនួយ | វិធាន៖ ដើម្បីគណនាអាំងតេក្រាល ដោយប្រើអថេរជំនួយគេត្រូវ៖<br>-តាង $t=f(x)$ រួចរក $dt=f'(x)dx$<br>-ជំនួស $f(x)$ ដោយ $t$ រួចគណនា អាំងតេក្រាលធៀបនឹងអថេរ $t$<br>-ជំនួស $t$ ដោយ $f(x)$ វិញនោះគេបាន ចម្លើយជាអនុគមន៍នៃ $x$ ។ | ពិភាក្សារួចទាញរកវិធាន |
| -ដាក់លំហាត់គំរូឲ្យសិស្ស ពិភាក្សាដោះស្រាយ<br>លំហាត់៖ គណនាអាំងតេក្រាល ខាងក្រោម៖<br>ក/ $A=\int (x^2+3x-1)^4(2x+3)dx$<br>ខ/ $B=\int 8x^3\sin x^4 dx$ | ចម្លើយ៖ គណនា<br>ក/ $A=\int (x^2+3x-1)^4(2x+3)dx$<br>តាង $t=x^2+3x-1$ នាំអោយ<br>$dt=(2x+3)dx$<br>គេបាន $A=\int t^4 dt=\frac{1}{5}t^5+c$<br>$=\frac{1}{5}(x^2+3x-1)^5+c$<br>ខ/ $B=\int 8x^3\sin x^4 dx$<br>តាង $t=x^4 \Rightarrow dt=4x^3dx$<br>គេបាន $B=\int 2\sin t dt$<br>$=-2\cos t+c=-2\cos x^4+c$ | -ពិភាក្សាគ្នារួចដោះស្រាយ<br>ក/ $A=\int (x^2+3x-1)^4(2x+3)dx$<br>តាង $t=x^2+3x-1$ នាំអោយ<br>$dt=(2x+3)dx$<br>គេបាន $A=\int t^4 dt=\frac{1}{5}t^5+c$<br>$=\frac{1}{5}(x^2+3x-1)^5+c$<br>ខ/ $B=\int 8x^3\sin x^4 dx$<br>តាង $t=x^4 \Rightarrow dt=4x^3dx$<br>គេបាន $B=\int 2\sin t dt$<br>$=-2\cos t+c=-2\cos x^4+c$ |
| បង្ហាញសិស្ស គេមានអនុគមន៍ ពីរ $f$ និង $g$ ដែលមានដេរីវេ $f'$ | ខ/ អាំងតេក្រាលដោយផ្នែក | សិស្សសង្កេតមើលការបង្ហាញរបស់គ្រូរួចទាញរក $(fg)'$ |

| | | |
|---|---|---|
| និង $g'$<br>អោយសិស្សគណនា $(fg)'=?$<br>អោយសិស្សបំពាក់អាំងតេក្រាលលើអង្គទាំងពីរធៀបនឹង $x$<br>រួចទាញរក $\int(f'g)dx$<br>-ណែនាំសិស្សឲ្យស្គាល់អាំងតេក្រាលដោយផ្នែក<br>-ដាក់លំហាត់គំរូឲ្យសិស្សគណនាអាំងតេក្រាល<br>ក/ $A=\int xe^x dx$<br>ខ/ $B=\int \ln x dx$<br>គ/ $C=\int(3x+2)\sin x dx$<br>ឃ/ $D=\int e^x\cos x dx$ | គេបាន $(fg)'=f'g+g'f$<br>$\int(fg)'dx=\int(f'g+g'f)dx$<br>នាំឲ្យ $\int(f'g)dx=fg-\int g'f dx$<br><br>រូបមន្ត៖ $\int(f'g)dx=fg-\int g'f dx$<br>ហៅថាអាំងតេក្រាលដោយផ្នែក<br>ចម្លើយ៖ គណនាអាំងតេក្រាលខាងក្រោម៖<br>ក/ $A=\int xe^x dx$<br>តាង $f(x)=x\Rightarrow f'(x)=1$<br>$g'(x)=e^x\Rightarrow g(x)=e^x$<br>គេបាន $A=xe^x-\int e^x dx$<br>$=(x-1)e^x+c$<br>ខ/ $B=\int \ln x dx$<br>តាង $f(x)=\ln x\Rightarrow f'(x)=\frac{1}{x}$<br>$g'(x)=1\Rightarrow g(x)=x$<br>គេបាន $B=x\ln x-\int dx$<br>$=(\ln x-1)x+c$<br>គ/ $C=\int(3x+2)\sin x dx$<br>តាង $f(x)=3x+2\Rightarrow f'(x)=3$<br>$g'(x)=\sin x\Rightarrow g(x)=-\cos x$<br>គេបាន<br>$C=-(3x+2)\cos x+\int 3\cos x dx$<br>$=-(3x+2)\cos x+3\sin x+c$<br>ឃ/ $D=\int e^x\cos x dx$<br>តាង $f(x)=e^x\Rightarrow f'(x)=e^x$<br>$g'(x)=\cos x\Rightarrow g(x)=\sin x$<br>គេបាន $D=e^x\sin x-\int e^x\sin x dx$ | $(fg)'=f'g+g'f$<br>$\int(fg)'dx=\int(f'g+g'f)dx$<br>នាំឲ្យ $\int(f'g)dx=fg-\int g'f dx$<br><br>សិស្សស្ដាប់រួចកត់ត្រា<br><br>សិស្សពិភាក្សាគ្នាដោះស្រាយលំហាត់ |

| | | |
|---|---|---|
| | តាង $f(x)=e^x \Rightarrow f'(x)=e^x$<br>$g'(x)=\sin x \Rightarrow g(x)=-\cos x$<br>គេបាន<br>$D=e^x\sin x-[-e^x\cos x+\int \cos x e^x dx]$<br>$D=e^x\sin x+e^x\cos x-D$<br>$D=\frac{1}{2}e^x(\sin x+\cos x)+c$ | |
| -ឲ្យសិស្សឆ្លើយនឹងសំនួរ<br>តើ $\int f(x)g'(x)dx=?$ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>ចម្លើយ៖<br>$\int f(x)g'(x)dx=f(x)g(x)-\int g(x)f'(x)dx$ | -សិស្សឡើងសរសេររូបមន្ត<br>$\int f(x)g'(x)dx$<br>$=f(x)g(x)-\int g(x)f'(x)dx$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី)<br>លំហាត់៖ គណនាអាំងតេក្រាល<br>ក/ $I=\int(-2x+1)\cos x dx$<br>ខ/ $J=\int(5x-4)\ln x dx$ | -សិស្សកត់លំហាត់<br>និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៤....

មេរៀនទី...២... **អាំងតេក្រាលកំណត់**

- **មុខវិជ្ជា** : **គណិតវិទ្យា** **ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)**
- **ជំពូកទី៤** : **អាំងតេក្រាល**
- **មេរៀនទី២** : **អាំងតេក្រាលកំណត់**
- **បង្រៀនដោយ : សាស្ត្រាចារ្យ** ................................

## I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : សិស្សកំណត់បាននិយមន័យអាំងតេក្រាលនៃអនុគមន៍ជាប់លើចន្លោះបិទមួយតាមរយៈការបង្ហាញរបស់គ្រូ។

-បំណិន : សិស្សអនុវត្តគណនាអាំងតេក្រាលកំណត់បាន ត្រឹមត្រូវតាមលក្ខណៈគ្រឹះ និង ការពន្យល់ដោយលើកឧទាហរណ៍ របស់គ្រូ។

-ឥរិយាបថ : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយៈការណែនាំរបស់គ្រូ។

II.ពេលវេលា: ...២...ម៉ោង ថ្ងៃ...............ទី...............ខែ............ឆ្នាំ..........

## III.សម្ភារៈឧទេស

-ស . ស :ទំព័រទី.១៣២.. ដល់ទំព័រទី..១៣៤..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-តារាងរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់

## IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | <u>ជំហានទី១</u><br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងធ្វើលំហាត់ | <u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់ ៧នាទី)<br>ចម្លើយៈ | សិស្សឡើងគណនា |

| | | |
|---|---|---|
| ១/ បង្ហាញថា<br>$F(x)=3x^3-7x$<br>ជាព្រីមីទីវនៃ $f(x)=9x^2-7$<br>២/ គណនាអាំងតេក្រាល<br>$\int(2x^3-5x^2+3x+1)dx$ | ១/ យើងមាន $F(x)=3x^3-7x$<br>$F'(x)=9x^2-7=f(x)$<br>នោះ $F(x)$ ជាព្រីមីទីវនៃ $f(x)$ ។<br>២/ $\int(2x^3-5x^2+3x+1)dx$ | ១/យើងមាន $F(x)=3x^3-7x$<br>$F'(x)=9x^2-7=f(x)$<br>នោះ $F(x)$ ជាព្រីមីទីវនៃ<br>$f(x)$ ។<br>២/ $\int(2x^3-5x^2+3x+1)dx$ |
| វត្ថុមួយផ្លាស់ទីតាមទិសដេក<br>ដោយល្បឿន<br>$V(t)=5+3t^2\,m/mn$ ។ រកកំ<br>ណើនចម្ងាយនៃវត្ថុដែលត្រូវនឹង<br>កំណើនពេលពីខណៈ $t=3mn$<br>និង $t=5mn$ ។<br>-អោយសិស្សទាញរកនិយម<br>ន័យនៃអាំងតេក្រាលកំណត់ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី២: អាំងតេក្រាលកំណត់**<br>១-និយមន័យ<br>ដំណោះស្រាយ<br>តាង $S(t)$ ជាចម្ងាយចរនៃបំលាស់ទី<br>$\Rightarrow S'(t)=V(t)$ នោះ<br>$S(t)=\int V(t)dt=\int(5+3t^2)dt$<br>$S(t)=5t+t^3+c$<br>-ចម្ងាយចរនៃវត្ថុខណៈ $t=3mn$ គឺ<br>$S(3)=5\times3+3^3+c=42+c$<br>-ចម្ងាយចរនៃវត្ថុខណៈ $t=5mn$ គឺ<br>$S(5)=5\times5+5^3+c=150+c$<br>ដូចនេះ កំណើនចម្ងាយចរចន្លោះ<br>$t=3mn$ និង $t=5mn$ គឺ<br>$S(5)-S(3)=(150+c)-(42+c)=108m$<br>+ បើ $F(x)$ និង $G(x)$ ជាព្រីមីទីវនៃ<br>$f(x)$ នោះគេបាន $F(x)=G(x)+c$<br>$\Rightarrow F(a)=G(a)+c$<br>$F(b)=G(b)+c$<br>គេបាន $F(b)-F(a)=G(b)-G(a)$<br>ផលដក $F(b)-F(a)$ ហៅថាអាំងតេ<br>ក្រាលកំណត់ពី $a$ ទៅ $b$ នៃអនុគមន៍<br>$y=f(x)$ ។គេកំណត់សរសេរ<br>$\int_a^b f(x)dx=F(b)-F(a)$ | សិស្សសង្កេតលើឧទាហរណ៍<br>និងឆ្លើយសំនួរគ្រូ<br>$\Rightarrow S'(t)=V(t)$ នោះ<br>$S(t)=\int V(t)dt=\int(5+3t^2)dt$<br>$S(t)=5t+t^3+c$<br>-ចម្ងាយចរនៃវត្ថុខណៈ $t=3mn$ គឺ<br>$S(3)=5\times3+3^3+c=42+c$<br>-ចម្ងាយចរនៃវត្ថុខណៈ $t=5mn$ គឺ<br>$S(5)=5\times5+5^3+c=150+c$<br>ដូចនេះ កំណើនចម្ងាយចរ<br>ចន្លោះ $t=3mn$ និង $t=5mn$ គឺ<br>$S(5)-S(3)=(150+c)-(42+c)$<br>-សិស្សកត់ត្រា |

| | | |
|---|---|---|
| ដាក់លំហាត់ប្រតិបត្តិ<br>ប្រតិបត្តិៈ គណនាអាំងតេក្រាលកំណត់ខាងក្រោមៈ<br>១/ $\int_{-2}^{1} 4x^3dx$<br>២/ $\int_{1}^{4}(2x^2-4x+5)dx$<br>៣/ $\int_{1}^{3}(x^2+\frac{1}{x}-e^x)dx$ | និយមន័យៈ អាំងតេក្រាលមិនកំណត់ពីរ $a$ ទៅ $b$ នៃអនុគមន៍ $y=f(x)$ គឺជាកំណើននៃអនុគមន៍ព្រីមីទីវនៃ $F(x)$ ដែលត្រូវនឹងកំណើន $x$ ពី $a\to b$ គេកំណត់សរសេរ<br>$\int_a^b f(x)dx=[F(x)]_a^b=F(b)-F(a)$<br>ចម្លើយៈ<br>១/ $\int_{-2}^{1} 4x^3dx=\left[x^4\right]_{-2}^{1}=16-1=15$<br>២/ $\int_{1}^{4}(2x^2-4x+5)dx$<br>$=[\frac{2}{3}x^3-2x^2+5x]_1^4$<br>$=(\frac{2}{3}\times4^3-2\times4^2+5\times4)-(\frac{2}{3}\times1^3-2\times1^2+5\times1)$<br>$=\frac{128}{3}-32+20-\frac{2}{3}-2+5=33$<br>៣/ $\int_{1}^{3}(x^2+\frac{1}{x}-e^x)dx$<br>$=\frac{1}{3}x^3+\ln\lvert x\rvert-e^x$<br>$=(\frac{1}{3}.27+\ln3-e^3)-(\frac{1}{3}+\ln1-e)$<br>$=\frac{26}{3}+\ln3-e^3+e$ | ១/ $\int_{-2}^{1} 4x^3dx=\left[x^4\right]_{-2}^{1}$<br>$=16-1=15$<br>២/ $\int_{1}^{4}(2x^2-4x+5)dx$<br>$=[\frac{2}{3}x^3-2x^2+5x]_1^4$<br>$=(\frac{2}{3}\times4^3-2\times4^2+5\times4)-(\frac{2}{3}\times1^3-2\times1^2+5\times1)$<br>$=\frac{128}{3}-32+20-\frac{2}{3}-2+5=33$<br>៣/ $\int_{1}^{3}(x^2+\frac{1}{x}-e^x)dx$<br>$=\frac{1}{3}x^3+\ln\lvert x\rvert-e^x$<br>$=(\frac{1}{3}.27+\ln3-e^3)-(\frac{1}{3}+\ln1-e)$<br>$=\frac{26}{3}+\ln3-e^3+e$ |
| -ឲ្យសិស្សឡើងដោះស្រាយលំហាត់ប្រតិបត្តិ<br>គណនាអាំងតេក្រាល<br>ក/ $\int_{1}^{0}(-3x^5-3x^2+2x+5)dx$<br>ខ/ $\int_{1}^{0}(\sqrt{x}-\frac{4}{\sqrt{x}})dx$<br>គ/ $\int_{1}^{0}(1+\frac{1}{x}+\frac{1}{x^2})dx$ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>ចម្លើយៈ<br>ក/ $\int_{1}^{0}(-3x^5-3x^2+2x+5)dx$<br>$=\left[-\frac{1}{2}x^6-x^3+x^2+5x\right]_0^1$<br>$=0-(-\frac{1}{2}1^6-1^3+1^2+5.1)=-\frac{9}{2}$<br>ខ/ $\int_{1}^{0}(\sqrt{x}-\frac{4}{\sqrt{x}})dx$ | -សិស្សឡើងគណនាលំហាត់<br>ក/ $\int_{1}^{0}(-3x^5-3x^2+2x+5)dx$<br>$=\left[-\frac{1}{2}x^6-x^3+x^2+5x\right]_0^1$<br>$=0-(-\frac{1}{2}1^6-1^3+1^2+5.1)=-\frac{9}{2}$<br>ខ/ $\int_{1}^{0}(\sqrt{x}-\frac{4}{\sqrt{x}})dx$ |

| | | |
|---|---|---|
| | $=[\frac{2}{3}x^{\frac{3}{2}}-8x^{\frac{1}{2}}]_1^0=\frac{22}{3}$<br>គ/ $\int_1^2(1+\frac{1}{x}+\frac{1}{x^2})dx$<br>$=\left[x+\ln\lvert x\rvert-\frac{1}{x}\right]_1^2$<br>$=(2+\ln2-\frac{1}{2})-(1+\ln1-1)=\frac{3}{2}+\ln2$ | $=[\frac{2}{3}x^{\frac{3}{2}}-8x^{\frac{1}{2}}]_1^0=\frac{22}{3}$<br>គ/ $\int_1^2(1+\frac{1}{x}+\frac{1}{x^2})dx$<br>$=\left[x+\ln\lvert x\rvert-\frac{1}{x}\right]_1^2$<br>$=(2+\ln2-\frac{1}{2})-(1+\ln1-1)$<br>$=\frac{3}{2}+\ln 2$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី)<br>លំហាត់៖ គណនាអាំងតេក្រាល<br>$\int_1^2(\frac{1}{x^2}-3)dx$ | -សិស្សកត់លំហាត់<br>និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៤....

មេរៀនទី...២... **អាំងតេក្រាលកំណត់**

- **មុខវិជ្ជា** : **គណិតវិទ្យា** **ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)**
- **ជំពូកទី៤** : **អាំងតេក្រាល**
- **មេរៀនទី២** : **អាំងតេក្រាលកំណត់**
- **បង្រៀនដោយ : សាស្ត្រាចារ្យ** ................................

## I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : សិស្សប្រាប់បានពីការអាំងតេក្រាលកំណត់តាមលក្ខណៈគ្រឹះ និងដោយប្តូរអថេរបានត្រឹមត្រូវតាមរយៈការបង្ហាញរបស់គ្រូ។

-បំណិន : សិស្សអនុវត្តគណនាអាំងតេក្រាលកំណត់តាមលក្ខណៈគ្រឹះ និងដោយប្តូរអថេរបានត្រឹមត្រូវតាមរយៈឧទាហរណ៍របស់គ្រូ។

-ឥរិយាបថ : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយៈការណែនាំរបស់គ្រូ។

II.ពេលវេលា: ...២...ម៉ោង ថ្ងៃ...............ទី...............ខែ............ឆ្នាំ..........

## III.សម្ភារៈឧទេស

-ស . ស :ទំព័រទី.១៣៤.. ដល់ទំព័រទី..១៣៧..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-តារាងរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់

## IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី) | |

| | | |
|---|---|---|
| -ឲ្យសិស្សឡើងធ្វើលំហាត់ $\int_1^2 (\frac{1}{x^2}-3)dx$ | ចម្លើយ៖ $\int_1^2 (\frac{1}{x^2}-3)dx = (-\frac{1}{x}-3x)\Big\|_1^2$ $= (-\frac{1}{2}-6)-(-1-3) = -\frac{5}{2}$ | សិស្សឡើងគណនា $\int_1^2 (\frac{1}{x^2}-3)dx = (-\frac{1}{x}-3x)\Big\|_1^2$ $= (-\frac{1}{2}-6)-(-1-3) = -\frac{5}{2}$ |
| -អោយសិស្សសង្កេតលើឧទាហរណ៍ទី១នៅ ទំព័រ ១៣៤<br>Ex1 គេអោយ $f(x)=4x^3$<br>ក/ គណនា $\int_1^{-2} f(x)dx$<br>ខ/ គណនា $\int_{-2}^{1} f(x)dx$<br><br>-អោយសិស្សទាញរកលក្ខណះ<br><br>-អោយសិស្សទាញរកសម្រាយបញ្ជាក់<br><br>-អោយសិស្សគណនា $\int_1^1 e^x dx$<br><br>-អោយសិស្សទាញរកលក្ខណះ<br>-អោយសិស្សទាញរកសម្រាយ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយះពេល៦០នាទី)<br>**មេរៀនទី២: អាំងតេក្រាលកំណត់**<br>២- លក្ខណះ<br>ដំណោះស្រាយ<br>ក/ គណនា $\int_1^{-2} f(x)dx$<br>$=\int_1^{-2} 4x^3dx = [x^4]\Big\|_1^{-2} = 16-1 = 15$<br>ខ/ គណនា $\int_{-2}^{1} f(x)dx$<br>$=\int_{-2}^{1} 4x^3dx = [x^4]\Big\|_{-2}^{1} = 1-16 = -15$<br>លក្ខណះ បើអនុគមន៍ $f$ កំណត់និងជាប់លើចន្លោះ $[a,b]$ នោះ<br>$\int_a^b f(x)dx = -\int_b^a f(x)dx$<br>សម្រាយបញ្ជាក់៖<br>$\int_a^b f(x)dx = F(b)-F(a)$<br>$\int_b^a f(x)dx = F(a)-F(b)$<br>$=-[F(b)-F(a)] = -\int_a^b f(x)dx$<br>នោះគេបាន $\int_a^b f(x)dx = -\int_b^a f(x)dx$<br>ចម្លើយ៖<br>$\int_1^1 e^x dx = \left[e^x\right]_1^1 = e-e = 0$<br>ជាទូទៅ៖ $\int_a^a f(x)dx = 0$<br>សម្រាយ៖ $\int_a^a f(x)dx = [F(x)]_a^a$ | សិស្សសង្កេតលើឧទាហរណ៍ និងឆ្លើយសំនួរគ្រូ<br>ក/ គណនា $\int_1^{-2} f(x)dx$<br>$=\int_1^{-2} 4x^3dx = [x^4]\Big\|_1^{-2} = 16-1 = 15$<br>ខ/ គណនា $\int_{-2}^{1} f(x)dx$<br>$=\int_{-2}^{1} 4x^3dx = [x^4]\Big\|_{-2}^{1} = 1-16 = -15$<br>-ទាញរកលក្ខណះគ្រឹះ<br><br>-ទាញរកសម្រាយបញ្ជាក់<br><br>-ទាញរកសម្រាយបញ្ជាក់<br>$\int_1^1 e^x dx = \left[e^x\right]_1^1 = e-e = 0$<br>ទាញរក $\int_a^a f(x)dx = 0$<br>ទាញរកសម្រាយបញ្ជាក់ |

| | | |
|---|---|---|
| បញ្ជាក់<br><br><br>-អោយសិស្សគណនា<br>$\int_0^4 3e^x dx$ និង<br>$\int_0^2 3e^x dx+\int_2^4 3e^x dx$<br><br><br>-អោយសិស្សទាញរកលក្ខណៈជាទូទៅ<br><br>-អោយសិស្សទាញរកសម្រាយបញ្ជាក់<br><br><br>-ឲ្យសិស្សពិនិត្យឧទាហរណ៍ និងលំហាត់ដោះស្រាយ<br><br><br><br><br><br>-អោយសិស្សធ្វើការសន្និដ្ឋាន អោយសិស្សពិនិត្យសម្រាយបញ្ជាក់ | $=F(a)-F(a)=0$<br><br><br>ចម្លើយ៖<br>$\int_0^4 3e^xdx=\left[3e^x\right]_0^4=3e^4-3$<br>$\int_0^2 3e^xdx+\int_2^4 3e^xdx$<br>$=\left[3e^x\right]_0^2+\left[3e^x\right]_2^4$<br>$=3e^2-3+3e^4-3e^2=3e^4-3$<br>ជាទូទៅ៖ បើ $f$ កំណត់និងជាប់លើចន្លោះ $[a,c]$ ដែល $a<b<c$ នោះ<br>$\int_a^b f(x)dx+\int_b^c f(x)dx=\int_a^c f(x)dx$<br>សម្រាយបញ្ជាក់៖<br>$\int_a^b f(x)dx+\int_b^c f(x)dx$<br>$F(b)-F(a)+F(c)-F(b)$<br>$=F(c)-F(a)=\int_a^c f(x)dx$<br>លំហាត់៖ បង្ហាញថា<br>$\int_0^{\frac{\pi}{3}} 3\sin xdx=3\int_0^{\frac{\pi}{3}}\sin xdx$<br>យើងមាន $\int_0^{\frac{\pi}{3}}3\sin xdx=[-3\cos x]_0^{\frac{\pi}{3}}$<br>$=-3\cos\frac{\pi}{3}+3\cos 0^\circ=-\frac{3}{2}+3=\frac{3}{2}$<br>ហើយ $3\int_0^{\frac{\pi}{3}}\sin xdx=3[-\cos x]_0^{\frac{\pi}{3}}$<br>$=3(-\cos\frac{\pi}{3}+\cos 0^\circ)=3(-\frac{1}{2}+1)=\frac{3}{2}$<br>ជាទូទៅ៖ $\int_a^b kf(x)dx=k\int_a^b f(x)dx$<br>សម្រាយបញ្ជាក់៖<br>$k\int_a^b f(x)dx=k[F(b)-F(a)]$<br>$=kF(b)-kF(a)=\int_a^b kf(x)dx$ | $\int_a^a f(x)dx=[F(x)]_a^a$<br>$=F(a)-F(a)=0$<br>សិស្សគណនា<br>$\int_0^4 3e^xdx=\left[3e^x\right]_0^4=3e^4-3$<br>$\int_0^2 3e^xdx+\int_2^4 3e^xdx$<br>$=\left[3e^x\right]_0^2+\left[3e^x\right]_2^4$<br>$=3e^2-3+3e^4-3e^2=3e^4-$<br>-ទាញរកលក្ខណៈទូទៅ<br><br><br>-ពិនិត្យនិងធ្វើសម្រាយបញ្ជាក់<br><br><br><br>ពិនិត្យឧទាហរណ៍រួចគណនា<br>យើងមាន<br>$\int_0^{\frac{\pi}{3}}3\sin xdx=[-3\cos x]_0^{\frac{\pi}{3}}$<br>$=-3\cos\frac{\pi}{3}+3\cos 0^\circ=-\frac{3}{2}+3=\frac{3}{2}$<br>ហើយ<br>$3\int_0^{\frac{\pi}{3}}\sin xdx=3[-\cos x]_0^{\frac{\pi}{3}}$<br>$=3(-\cos\frac{\pi}{3}+\cos 0^\circ)=3(-\frac{1}{2}+1)=\frac{3}{2}$<br>ធ្វើការសន្និដ្ឋានភាពទូទៅមួយ<br>ពិនិត្យលើការស្រាយបញ្ជាក់<br><br><br>ពិនិត្យលក្ខណៈទូទៅ |

| | | |
|---|---|---|
| -អោយសិស្សសង្កេតលក្ខណៈទូទៅចំណុច (ង) | ជាទូទៅ៖ បើគេមាន $\int_a^b f(x)dx$ និង $\int_a^b g(x)dx$ នោះគេបាន<br>$\int_a^b [f(x)\pm g(x)]dx=\int_a^b f(x)dx\pm\int_a^b g(x)dx$ | |
| -អោយសិស្សសង្កេតលើសម្រាយបញ្ជាក់ | សម្រាយបញ្ជាក់៖<br>$\int_a^b [f(x)\pm g(x)]dx=[F(b)\pm G(b)]-[F(a)\pm G(a)]$<br>$=[F(b)-F(a)]\pm[G(b)-G(a)]$<br>$=\int_a^b f(x)dx\pm\int_a^b g(x)dx$ | -ពិនិត្យលើការស្រាយបញ្ជាក់របស់គ្រូ |
| -អោយសិស្សពិនិត្យលើឧទាហរណ៍<br>ឧ៖ គណនា<br>$\int_2^4(4x-5)dx+\int_2^4(5-6x)dx$ | ចម្លើយ៖ $\int_2^4(4x-5)dx+\int_2^4(5-6x)dx$<br>$=\int_2^4(4x-5+5-6x)dx=\int_2^4(-2x)dx$<br>$=(-x^2)\Big\vert_2^4=-16+4=-12$ | -ពិនិត្យលើឧទាហរណ៍ដែលគ្រូដាក់អោយ |
| -អោយសិស្សពិនិត្យលក្ខណៈទូទៅចំណុច (ច)និងឧទាហរណ៍<br>គណនា៖ $\int_2^4(\frac{3}{x^2}+\frac{1}{2}x)dx$ | ជាទូទៅ៖<br>$\int_a^b[\alpha f(x)\pm\beta g(x)]dx=\alpha\int_a^b f(x)dx\pm\beta\int_a^b g(x)dx$<br>ចម្លើយ៖<br>$\int_2^4(\frac{3}{x^2}+\frac{1}{2}x)dx=\int_2^4\frac{3}{x^2}dx+\int_2^4\frac{1}{2}xdx$<br>$=(-\frac{3}{x})\Big\vert_2^4+(\frac{1}{4}x^2)\Big\vert_2^4=(-\frac{3}{4}+\frac{3}{2})+(4-1)$<br>$=\frac{3}{4}+3=\frac{15}{4}$ | -ពិនិត្យលើឧទាហរណ៍ដែលគ្រូដាក់អោយ |
| -ឲ្យសិស្សសង្កេតលើលក្ខណៈទូទៅ | ២- គណនាអាំងតេក្រាលកំណត់ដោយប្តូរអថេរ<br>ជាទូទៅ៖ បើ $u=g(x)$ ជាប់និងមានដេរីវេលើ $[a,b]$ នោះគេបាន<br>$\int_a^b f[g(x)]g'(x)dx=\int_{g(a)}^{g(b)}f(u)du$ ។ | សង្កេតលើលក្ខណៈទូទៅ |
| -អោយសិស្សធ្វើលំហាត់គំរូ<br>លំហាត់គំរូ៖ គណនា<br>ក/ $\int_0^2 x(x^2+1)^3dx$<br>ខ/ $\int_1^2\frac{3x^2}{(x^3+1)^2}dx$ | ចម្លើយ៖ ក/ $\int_0^2 x(x^2+1)^3dx$<br>តាង $u=x^2+1\Rightarrow du=2xdx$<br>បើ $x=0\Rightarrow u=1$<br>បើ $x=2\Rightarrow u=5$<br>គេបាន $\int_0^2 x(x^2+1)^3dx=\int_1^5\frac{1}{2}u^3du$ | -សិស្សអនុវត្តធ្វើលំហាត់<br>ក/ $\int_0^2 x(x^2+1)^3dx$<br>តាង $u=x^2+1\Rightarrow du=2xdx$<br>បើ $x=0\Rightarrow u=1$<br>បើ $x=2\Rightarrow u=5$<br>គេបាន |

| | | |
|---|---|---|
| | $=\frac{1}{8}u^4\Big\|_1^5=\frac{625}{8}-\frac{1}{8}=78$<br>ខ/ $\int_1^2\frac{3x^2}{(x^3+1)^2}dx$<br>តាង $u=x^3+1\Rightarrow du=3x^2dx$<br>បើ $x=1\Rightarrow u=2$<br>បើ $x=2\Rightarrow u=9$<br>គេបាន $\int_1^2\frac{3x^2}{(x^3+1)^2}dx=\int_2^9\frac{du}{u^2}$<br>$=(-\frac{1}{u})\Big\|_2^9=-\frac{1}{9}+\frac{1}{2}=\frac{7}{18}$ | $\int_0^2 x(x^2+1)^3dx=\int_1^5\frac{1}{2}u^3du$<br>$=\frac{1}{8}u^4\Big\|_1^5=\frac{625}{8}-\frac{1}{8}=78$<br>ខ/ $\int_1^2\frac{3x^2}{(x^3+1)^2}dx$<br>តាង $u=x^3+1\Rightarrow du=3x^2dx$<br>បើ $x=1\Rightarrow u=2$<br>បើ $x=2\Rightarrow u=9$<br>គេបាន $\int_1^2\frac{3x^2}{(x^3+1)^2}dx=\int_2^9\frac{du}{u^2}$<br>$=(-\frac{1}{u})\Big\|_2^9=-\frac{1}{9}+\frac{1}{2}=\frac{7}{18}$ |
| -ចែកសិស្សជាបួនក្រុមតូចៗឲ្យធ្វើលំហាត់ប្រតិបត្តិគណនាអាំងតេក្រាល<br>ក/ $\int_0^4\frac{x+1}{(x^2+2x+2)^3}dx$<br>ខ/ $\int_1^2(\frac{x+2}{\sqrt{x^2+4x+1}})dx$<br>គ/ $\int_1^4\frac{e^{\sqrt{x}}}{\sqrt{x}}dx$<br>-តំណាងក្រុមឡើងរាយការណ៍ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>ចម្លើយ៖<br>ក/ $\int_0^4\frac{x+1}{(x^2+2x+2)^3}dx$<br>តាង $u=x^2+2x+2\Rightarrow du=2(x+1)dx$<br>បើ $x=0\Rightarrow u=2$<br>បើ $x=4\Rightarrow u=26$<br>គេបាន $\int_0^4\frac{x+1}{(x^2+2x+2)^3}dx=\int_2^{26}\frac{du}{2u^3}$<br>$=(-\frac{1}{4u^2})\Big\|_2^{26}=-\frac{1}{2704}+\frac{1}{16}=\frac{168}{2704}$<br>ខ/ $\int_1^2(\frac{x+2}{\sqrt{x^2+4x+1}})dx$<br>តាង $u=x^2+4x+1\Rightarrow du=2(x+2)dx$<br>បើ $x=1\Rightarrow u=6$<br>បើ $x=2\Rightarrow u=13$<br>គេបាន $\int_1^2(\frac{x+2}{\sqrt{x^2+4x+1}})dx=\int_6^{13}\frac{du}{2\sqrt{u}}$<br>$=\sqrt{u}\Big\|_6^{13}=\sqrt{13}-\sqrt{6}$ | -សិស្សឡើងគណនាលំហាត់<br>ក/ $\int_0^4\frac{x+1}{(x^2+2x+2)^3}dx$<br>តាង $u=x^2+2x+2\Rightarrow du=2(x+1)dx$<br>បើ $x=0\Rightarrow u=2$<br>បើ $x=4\Rightarrow u=26$<br>គេបាន $\int_0^4\frac{x+1}{(x^2+2x+2)^3}dx=\int_2^{26}\frac{du}{2u^3}$<br>$=(-\frac{1}{4u^2})\Big\|_2^{26}=-\frac{1}{2704}+\frac{1}{16}=\frac{168}{2704}$<br>ខ/ $\int_1^2(\frac{x+2}{\sqrt{x^2+4x+1}})dx$<br>តាង $u=x^2+4x+1\Rightarrow du=2(x+2)dx$<br>បើ $x=1\Rightarrow u=6$<br>បើ $x=2\Rightarrow u=13$<br>គេបាន $\int_1^2(\frac{x+2}{\sqrt{x^2+4x+1}})dx=\int_6^{13}\frac{du}{2\sqrt{u}}$<br>$=\sqrt{u}\Big\|_6^{13}=\sqrt{13}-\sqrt{6}$<br>គ/ $\int_1^4\frac{e^{\sqrt{x}}}{\sqrt{x}}dx$ |

| | | |
|---|---|---|
| | គ/ $\int_1^4 \frac{e^{\sqrt{x}}}{\sqrt{x}}dx$<br>តាង $u=\sqrt{x} \Rightarrow du=\frac{1}{2\sqrt{x}}dx$<br>បើ $x=1 \Rightarrow u=1$<br>បើ $x=4 \Rightarrow u=2$<br>គេបាន $\int_1^4 \frac{e^{\sqrt{x}}}{\sqrt{x}}dx=\int_1^2 2e^u du$<br>$=2e^u\Big\|_1^2=2e(e-1)$ | តាង $u=\sqrt{x} \Rightarrow du=\frac{1}{2\sqrt{x}}dx$<br>បើ $x=1 \Rightarrow u=1$<br>បើ $x=4 \Rightarrow u=2$<br>គេបាន $\int_1^4 \frac{e^{\sqrt{x}}}{\sqrt{x}}dx=\int_1^2 2e^u du$<br>$=2e^u\Big\|_1^2=2e(e-1)$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី)<br>លំហាត់៖ គណនាអាំងតេក្រាលនៅទំព័រទី១៣៩ លំហាត់ទី២ និងទី៤ ពី(ក)ដល់ (ជ)។ | -សិស្សកត់លំហាត់ និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៤....

មេរៀនទី...២... **អាំងតេក្រាលកំណត់**

- **មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)**
- **ជំពូកទី៤ : អាំងតេក្រាល**
- **មេរៀនទី២ : អាំងតេក្រាលកំណត់**
- **បង្រៀនដោយ : សាស្ត្រាចារ្យ** ................................

## I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង : សិស្សប្រាប់បានពីរូបមន្តអាំងតេក្រាលដោយផ្អែកបានត្រឹមត្រូវតាមរយះការបង្ហាញរបស់គ្រូ។

-បំណិន : សិស្សអនុវត្តគណនាអាំងតេក្រាលដោយផ្អែកបានត្រឹមត្រូវតាមរយះឧទាហរណ៍របស់គ្រូ។

-ឥរិយាបថ : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយះការណែនាំរបស់គ្រូ។

II.ពេលវេលា: ...២...ម៉ោង ថ្ងៃ................ទី................ខែ.............ឆ្នាំ..........

## III.សម្ភារៈឧទេស

-ស . ស :ទំព័រទី.១៣៧.. ដល់ទំព័រទី..១៣៨..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-តារាងរូបមន្តគ្រឹះអាំងតេក្រាលមិនកំណត់

## IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ត្រួតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | <u>ជំហានទី១</u><br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងធ្វើលំហាត់ | <u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់ ៧នាទី)<br>ចម្លើយះ | សិស្សឡើងគណនា |

| | | |
|---|---|---|
| $\int_0^2 x(x^2+1)^3dx$ | គណនា $\int_0^2 x(x^2+1)^3dx$<br>តាង $u=x^2+1\Rightarrow du=2xdx$<br>បើ $x=0\Rightarrow u=1$<br>បើ $x=2\Rightarrow u=5$<br>គេបាន $\int_0^2 x(x^2+1)^3dx=\int_1^5\frac{1}{2}u^3du$<br>$=\frac{x^4}{8}\Big\|_1^5=\frac{625}{8}-\frac{1}{8}=78$ | តាង $u=x^2+1\Rightarrow du=2xdx$<br>បើ $x=0\Rightarrow u=1$<br>បើ $x=2\Rightarrow u=5$<br>គេបាន<br>$\int_0^2 x(x^2+1)^3dx=\int_1^5\frac{1}{2}u^3du$<br>$=\frac{x^4}{8}\Big\|_1^5=\frac{625}{8}-\frac{1}{8}=78$ |
| - គេអោយអនុគមន៍ $f$ និង $g$ ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ និងមានដេរីវេលើចន្លោះ $(a,b)$ នោះអោយសិស្សរក<br>$\int_a^b f(x)g'(x)dx$<br>-គ្រូអោយក្រុមពិភាក្សាធ្វើសម្រាយបញ្ជាក់រូបមន្តខាងលើ<br><br>-ឲ្យសិស្សអានប្រធានលំហាត់ ២ឬ៣ចប់<br><br>-អោយសិស្សធ្វើលំហាត់គំរូ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី២: អាំងតេក្រាលកំណត់**<br>៤- រូបមន្តអាំងតេក្រាលដោយផ្នែក អនុគមន៍ $f$ និង $g$ ជាអនុគមន៍ជាប់លើចន្លោះ $[a,b]$ និងមានដេរីវេលើចន្លោះ $(a,b)$ នោះ $\int_a^b f(x)g'(x)dx$<br>$=[f(x)g(x)]_a^b-\int_a^b g(x)f'(x)dx$<br>សម្រាយបញ្ជាក់៖<br>$[f(x).g(x)]=f'(x).g(x)+f(x).g'(x)$<br>$\int_a^b[f(x).g(x)]'dx=\int_a^b f(x).g'(x)dx+\int_a^b g'(x)f(x)dx$<br>$\Leftrightarrow[f(x)g(x)]_a^b=\int_a^b f(x).g'(x)dx+\int_a^b g'(x)f(x)dx$<br>$\Rightarrow\int_a^b f(x).g'(x)dx=[f(x)g(x)]_a^b-\int_a^b g'(x)f(x)dx$<br>៥- អនុវត្តន៍<br>+ក្រុមហ៊ុនលក់រថយន្តមួយទទួលប្រាក់ចំណេញតាមបំរែបំរួលនៃរថយន្តដែលបានលក់។ អត្រាប្រាក់ចំណេញបន្ថែម កំណត់បានអនុគមន៍ $P(x)=30-0.28x$ ដែល $x$ ជាចំនួនរថយន្ត និង $P(x)$ គិត ជាសែនរៀល។ រកបម្រែបម្រួលនៃប្រាក់ចំណេញពីការលក់រថយន្តចាប់ពីចំនួន10 ទៅ30 គ្រឿង។ | សង្កេតលើរូបមន្ត<br>$\int_a^b f(x)g'(x)dx$<br>$=[f(x)g(x)]_a^b-\int_a^b g(x)f'(x)dx$<br><br>-ក្រុមពិភាក្សាធ្វើសម្រាយបញ្ជាក់រូបមន្ត<br><br>-សិស្សម្នាក់ៗអានលំហាត់២ ឬបីចប់ដោយប្រុងប្រយ័ត្ន |

| | | |
|---|---|---|
| -ឲ្យសិស្សពិភាក្សាធ្វើលំហាត់<br>តាមក្រុម | ចម្លើយ៖<br>បម្រែបម្រួលនៃប្រាក់ចំណេញពីការ<br>លក់រថយន្តចាប់ពីចំនួន$10$ ទៅ$30$<br>គ្រឿងអាចគណនាតាមអាំងតេក្រាល<br>កំណត់នៃអនុគមន៍ប្រាក់ចំណេញ<br>បន្ថែម $P(x)=30-0.28x$ពី$10$ ទៅ$30$<br>គេបាន $\int_{10}^{30}P(x)dx=\int_{10}^{30}(30-0.28x)dx$<br>$=[30x-\frac{0.28x^2}{2}]_{10}^{30}=(900-0.28\times450)-(300-0.28\times50)$<br>$=488$<br>ដូចនេះ បម្របម្រួលនៃប្រាក់ចំណេញ<br>ពីការលក់រថយន្តចាប់ពីចំនួន$10$ ទៅ$30$<br>គ្រឿងគឺ 48 800 000រៀល | សិស្សពិភាក្សាគ្នាតាមក្រុមធ្វើ<br>លំហាត់យ៉ាងសកម្មដោយមាន<br>គ្រូជួយពន្យល់នូវចម្ងល់ |
| -គ្រូឲ្យសិស្សធ្វើលំហាត់<br>$A=\int_0^{\frac{\pi}{2}}x\cos xdx$ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>ចម្លើយ៖<br>$A=\int_0^{\frac{\pi}{2}}x\cos xdx$<br>តាង $f(x)=x\Rightarrow f'(x)=1$<br>គេបាន $A=\int_0^{\frac{\pi}{2}}x\cos xdx=[x\sin x]_0^{\frac{\pi}{2}}-\int_0^{\frac{\pi}{2}}\sin xdx$<br>$=\frac{\pi}{2}\sin\frac{\pi}{2}-0+[\cos]_0^{\frac{\pi}{2}}$<br>$=\frac{\pi}{2}+0+0-1=\frac{\pi}{2}-1$ | -សិស្សឡើងគណនាលំហាត់<br>$A=\int_0^{\frac{\pi}{2}}x\cos xdx$<br>តាង $f(x)=x\Rightarrow f'(x)=1$<br>គេបាន $A=\int_0^{\frac{\pi}{2}}x\cos xdx=[x\sin x]_0^{\frac{\pi}{2}}-\int_0^{\frac{\pi}{2}}\sin xdx$<br>$=\frac{\pi}{2}\sin\frac{\pi}{2}-0+[\cos]_0^{\frac{\pi}{2}}$<br>$=\frac{\pi}{2}+0+0-1=\frac{\pi}{2}-1$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀន<br>ឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី)<br>លំហាត់៖ គណនាអាំងតេក្រាល<br>$\int_0^4 xe^x dx=?$ | -សិស្សកត់លំហាត់<br>និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២( កម្រិតមូលដ្ឋាន )
- ជំពូកទី៥ : ស្ថិតិពីរអថេរ
- មេរៀនទី១ : ស្ថិតិមានពីរអថេរ
- បង្រៀនដោយ ៖ សាស្ត្រាចារ្យ ..............

I.**វត្ថុបំណងនៃមេរៀន**

**-ចំណេះដឹង** : សិស្សកំណត់និយមន័យនៃស្ថិតិមានពីអថេរបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

**-ចំណិន** : សិស្សបកស្រាយបាន ស្ថិតិមានពីរអថេរជាចំណុចតាមរយៈការណែនាំរបស់គ្រូ។

**-ឥរិយាបថ** : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយះការណែនាំរបស់គ្រូ។

II. **ខ្លឹមសារមេរៀន** : ពេលវេលា: ...២...ម៉ោង ថ្ងៃ.........ទី...ខែ.............ឆ្នាំ..........

១,សញ្ញាណស្ថិតិមានពីរអថេរ

២,បំណកស្រាយស្ថិតិមានពីរអថេរតាមក្រាប

III.**សម្ភារៈឧទេស**

-ស . ស :ទំព័រទី.១៤៦ ដល់ទំព័រទី១៥០

-ស . គ : ទំព័រទី១៤៦ ដល់ទំព័រទី១៥០

IV.**ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងដៅចំណុចទិន្នន័យលើក្តារខៀន<br>-គេមានតារាងទិន្នន័យ | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី) | -សិស្សឡើងដៅចំណុច |

<table>
<tr>
<td>
<table>
<tr><td>$x_i$</td><td>$-2$</td><td>$-1$</td><td>$0$</td><td>$1$</td><td>$2$</td></tr>
<tr><td>$y_i$</td><td>$0$</td><td>$2$</td><td>$3$</td><td>$1$</td><td>$-1$</td></tr>
</table>
-ចូរដៅចំណុចតាងទិន្នន័យខាងខាងលើក្នុងតម្រុយកែង
</td>
<td></td>
<td>
</td>
</tr>
<tr>
<td>-ដាក់ឧទាហរណ៍ណែនាំសិស្សឱ្យសង្កេតតារាងទិន្នន័យ<br><br>-ចូរបកស្រាយទិន្នន័យក្នុងតារាង</td>
<td>
<u>ជំហានទី៣</u><br>
(មេរៀនថ្មី រយៈពេល៦០នាទី)<br>
មេរៀនទី១:<br>
ស្ថិតិមានពីរអថេរ<br>
១.សញ្ញាណស្ថិតិមានពីរអថេរ<br>
១.១ ឧទាហរណ៍<br>
ឧទាហរណ៍: តារាងខាងក្រោមជាតារាងចំនួនសៀវភៅដែលរោងពុម្ពបានបោះពុម្ពទៅតាមឆ្នាំនិមួយៗ(ចំនួនសៀវភៅជាម៉ឺនក្បាល)
<table>
<tr><td>ឆ្នាំ</td><td>1</td><td>2</td><td>3</td><td>4</td></tr>
<tr><td>ចំនួន ស.ភ</td><td>48</td><td>48.4</td><td>49.5</td><td>48.9</td></tr>
</table>
-ការបកស្រាយតារាងទិន្នន័យ<br>
-ឆ្នាំទី១ រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 48ម៉ឺនក្បាល<br>
-ឆ្នាំទី២ រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 48.4 ម៉ឺនក្បាល<br>
-ឆ្នាំទី៣ រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 49.5 ម៉ឺនក្បាល<br>
-ឆ្នាំទី4 រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 48.9 ម៉ឺនក្បាល
</td>
<td>-សង្កេតឧទាហរណ៍<br><br>-បកស្រាយទិន្នន័យ<br>
-ឆ្នាំទី១<br>
រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 48ម៉ឺនក្បាល<br>
-ឆ្នាំទី២<br>
រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 48.4 ម៉ឺនក្បាល<br>
-ឆ្នាំទី៣<br>
រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 49.5 ម៉ឺនក្បាល</td>
</tr>
</table>

<table>
<tr>
<td>-ប្រាប់សិស្សថា ចំនួនសៀវភៅដែលបានបោះពុម្ពមានទំនាក់ទំនង និងឆ្នាំបោះពុម្ព។ ការសិក្សាបែបនេះហៅថា ស្ថិតិមានពីរអថេរ។</td>
<td>-តាមតារាងទិន្នន័យ ចំនួនសៀវភៅដែលបានបោះពុម្ពមានទំនាក់ទំនង និងឆ្នាំបោះពុម្ព។ ការសិក្សាបែបនេះហៅថា ស្ថិតិមានពីរអថេរ។<br>-លំហាត់គំរូ ក្នុងបណ្តាតារាងខាងក្រោមតើមួយណាជាស្ថិតិមានពីរអថេរ។<br>ក. ពិន្ទុសិស្សក្នុងថ្នាក់រៀនមួយ
<table>
<tr><td>ពិន្ទុ</td><td>4</td><td>5</td><td>6</td><td>7</td><td>8</td></tr>
<tr><td>ចំនួនសិស្ស</td><td>5</td><td>9</td><td>12</td><td>7</td><td>4</td></tr>
</table>
ខ. ប្រាក់ចំណេញរបស់ក្រុមហ៊ុនមួយតាមឆ្នាំនិមួយៗ (គិតជាលានរៀល)
<table>
<tr><td>ឆ្នាំ</td><td>2005</td><td>2006</td><td>2007</td><td>2008</td></tr>
<tr><td>ប្រាក់ចំណេញ</td><td>10</td><td>12</td><td>11</td><td>15</td></tr>
</table>
គ.ចំនួនកូននៅក្នុងគ្រួសារ និងចំនួនគ្រួសារ
<table>
<tr><td>ចំនួនកូន</td><td>0</td><td>1</td><td>2</td><td>3</td><td>4</td></tr>
<tr><td>ចំនួនគ្រួសារ</td><td>3</td><td>5</td><td>7</td><td>8</td><td>4</td></tr>
</table>
-ចម្លើយ<br>-តារាងទិន្នន័យ ខ ជាតារាងស្ថិតិមានពីរអថេរ ពីព្រោះប្រាក់ចំណេញមានទំនាក់ទំនងទៅនឹងឆ្នាំនិមួយៗ។</td>
<td>-ឆ្នាំទី4 រោងពុម្ពបានបោះពុម្ពសៀវភៅចំនួន 48.9 ម៉ឺនក្បាល<br>-សិស្សស្តាប់ និងសង្កេត<br><br>តារាងទិន្នន័យ ខ ជាតារាងស្ថិតិមានពីរអថេរ ពីព្រោះ ប្រាក់ចំណេញមានទំនាក់ទំនងទៅនឹងឆ្នាំនិមួយៗ។<br>-ចំណែកតារាងទិន្នន័យ ក និង គ</td>
</tr>
</table>

-ចែកក្រដាសលំហាត់ប្រត្តិបត្តិឱ្យសិស្សដោះស្រាយតាមក្រុម

-ដាក់លំហាត់គំរូណែនាំសិស្សពិភាក្សាគ្នា បកស្រាយ

-ចំណែកតារាងទិន្នន័យ ក និង គ ជាស្ថិតិមានមួយអថេរ។

**១.២ ,ចំណកស្រាយស្ថិតិមានពីរអថេរតាមក្រាប**

<u>លំហាត់គំរូ</u> ៖ ការកត់ត្រាទុកនៅក្នុងក្រុមហ៊ុនមួយសម្រាប់រយៈពេល ៥ ឆ្នាំចុងក្រោយនេះបានបង្ហាញពីទំនាក់ទំនងរវាងចំនួនឯកតានៃផលិតផលដែលបានលក់(គិតជាពាន់ឯកតា) និងតម្លៃនៃផលិតផលគិតជាពាន់រៀល។

| | | | | | |
|---|---|---|---|---|---|
| Pតម្លៃ | 8.80 | 8 | 7.50 | 6.90 | 6.20 |
| Xចំនួនឯកតា | 3.8 | 5.2 | 7.3 | 8 | 9.6 |

-ចូរបកស្រាយស្ថិតិមានពីរអថេរខាងលើជាចំណុច។

ចម្លើយ

នៅក្នុងតម្រុយកែងមួយ គេក្រិតតម្លៃលក់នៃផលិតផលនៅលើអ័ក្សអាប់ស៊ីស ហើយចំនួនឯកតានៃផលិតផលនោលើអ័ក្សអរដោនេ។

គេបាន

ជាស្ថិតិមានមួយអថេរ។

-ដោះស្រាយ

<table>
<tr>
<td></td>
<td>
</td>
<td></td>
</tr>
<tr>
<td>-ឲ្យសិស្សធ្វើលំហាត់នៅលើក្តារខៀន</td>
<td><u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>-គេឱ្យតារាងទិន្នន័យ<br>
<table>
<tr><td>$x_i$</td><td>1</td><td>2</td><td>3</td><td>4</td><td>5</td></tr>
<tr><td>$y_i$</td><td>0</td><td>1</td><td>2</td><td>1</td><td>3</td></tr>
</table>
-ចូរបកស្រាយទិន្នន័យខាងលើជាចំនុច</td>
<td>
</td>
</tr>
<tr>
<td>-គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់</td>
<td><u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី)</td>
<td>-សិស្សកត់លំហាត់ និងអនុវត្តតាម</td>
</tr>
</table>

# កិច្ចតែងការបង្រៀន

## - មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២( កម្រិតមូលដ្ឋាន )
## - ជំពូកទី៥ : ស្ថិតិពីរអថេរ
## - មេរៀនទី១ : ស្ថិតិមានពីរអថេរ

**I.វត្ថុបំណងនៃមេរៀន**

**-ចំណេះដឹង** : សិស្សប្រាប់បានពីរចំណុចមធ្យមបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

**-បំណិន** : សិស្សរកបានសមីការបន្ទាត់ដែលកាត់តាមចំណុចណាមួយ និងចំណុចមនុស្សតាមរយៈលំហាត់គំរូបានត្រឹមត្រូវ។

**-ឥរិយាបថ** : សិស្សសហការដោះស្រាយលំហាត់ដោយយកចិត្តទុកដាក់ខ្ពស់។

**II. ខ្លឹមសារមេរៀន** : ពេលវេលា: ...២...ម៉ោង ថ្ងៃ.........ទី...ខែ.............ឆ្នាំ...........

១.៣ ចំណុចមធ្យម

**III.សម្ភារៈឧទេស**

-ស . ស :ទំព័រទី.១៥០ ដល់ទំព័រទី១៥២

-ស . គ : ទំព័រទី១៥០ ដល់ទំព័រទី១៥២

**IV.ដំណើរការនាំមេរៀន**

<table>
<tr><th>សកម្មភាពគ្រូ</th><th>ខ្លឹមសាមេរៀន</th><th>សកម្មភាពសិស្ស</th></tr>
<tr><td>-គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់</td><td><u>ជំហានទី១</u><br>(រដ្ឋបាលថ្នាក់ ៣នាទី)</td><td>-<br>ប្រធានថ្នាក់ឡើងរាយការណ៍</td></tr>
<tr><td>-ដាក់លំហាត់ឱ្យសិស្សធ្វើ<br>គេមានតារាងទិន្នន័យ<br>
<table><tr><td>$x_i$</td><td>1</td><td>2</td><td>3</td><td>4</td><td>5</td></tr><tr><td>$y_i$</td><td>2</td><td>3</td><td>1</td><td>2</td><td>3</td></tr></table>
<br>ក.សរសេរទិន្នន័យខាងលើជាគូ</td><td><u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់ ៧នាទី)</td><td>-ចម្លើយ<br>ក. $(1,2),(2,3),(3,1),(4,3),(5,3)$<br>ខ. ដៅចំណុច</td></tr>
</table>

មានលំដាប់

ខ. បកស្រាយស្ថិតិមានពីរអថេរ ដោយចំណុច




-ដាក់ឧទាហរណ៍ ណែនាំសិស្ស រកចំនុចមធ្យម $M\left(\bar{x},\bar{y}\right)$

**ជំហានទី៣**

(មេរៀនថ្មី រយះពេល៦០នាទី)

## មេរៀនទី១:
## ស្ថិតិមានពីរអថេរ

### ១.៣ ចំណុចមធ្យម

-ឧទាហរណ៍ បើគេតាង $x_i$ ជាអថេរនៃឆ្នាំបោះពុម្ព ហើយ $y_i$ ជាចំនួនសៀវភៅដែលបោះពុម្ពនោះគេបានតារាងទិន្នន័យ

| $x_i$ | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|
| $y_i$ | 48 | 48.4 | 49.5 | 48.9 | 49.3 | 48.7 |

-បើតាង $M\left(\bar{x},\bar{y}\right)$ ជាមធ្យមនៃចំនុចទាំង ៦ដែល $\bar{x}$ និង $\bar{y}$ ជាមធ្យមរៀងគ្នានៃអថេរ $x_i$ និង $y_i$

-តើ $\bar{x}$ =?

-តើ $\bar{y}$ =?

-តើចំណុចមធ្យម M = ?

-តាង $M\left(\bar{x},\bar{y}\right)$ ជាចំនុចមធ្យមនៃចំនុចទាំង ៦ ដែល $\bar{x}$ និង $\bar{y}$ ជាមធ្យមរៀងគ្នានៃអថេរ $x_i$ និង $y_i$

គេបាន $\bar{x}=\frac{1+2+3+4+5+6}{6}=3.5$

$$\bar{y}=\frac{48+48.4+49.5+48.9+49.3+48.7}{6}$$

$$=48.8$$

ដូចនេះ ចំណុចមធ្យមកំណត់ដោយ

$M\left(3.5{,}48.8\right)$

-លំហាត់គំរូ តារាងខាងក្រោមជាតារាងស្ថិតិមានពីរអថេរ

គេបាន

$\bar{x}=\frac{1+2+3+4+5+6}{6}=3.5$

$\bar{y}=\frac{48+48.4+49.5+48.9}{6}$

$\frac{49.3+47.7}{6}=48.8$

ដូចនេះ:

ចំណុចមធ្យមកំណត់ដោយ

$M\left(3.5{,}48.8\right)$

| $x_i$ | 2 | 4 | 6 | 8 | 9 | 10 |
|---|---|---|---|---|---|---|
| $y_i$ | 7 | 10 | 13 | 15 | 20 | 28 |

ក. បកស្រាយស្ថិតិមានពីរអថេរខាងលើជាចំណុច

ខ. រកចំណុចមធ្យម $M$

គ. រកសមីការបន្ទាត់ដែលកាត់តាមចំណុច $M$ និងចំណុច $(6\,,13)$

-តើប្អូនដៅចំណុចដែលមានកូអរដោនេដូចម្តេច?

-ចូរប្អូនដៅចំណុចលើអ័ក្ស

**ចម្លើយ**

ក. ដៅចំណុចដែលមានកូអរដោនេ

$(2\,,7)\,,(4\,,10)\,,(6\,,13)\,,(8\,,15)$

$(9\,,20)\,,(10\,,28)$ ក្នុងតម្រុយកែង




-តើចំណុចមធ្យមកំណត់ដូចម្តេច?

-តើ $\bar{x}$ = ?

-តើ $\bar{y}$ = ?

-តើគេបាន $M$ ?

ខ. ចំណុចមធ្យមកំណត់ដោយ $M\left(\bar{x},\bar{y}\right)$

គេបាន

$$\bar{x}=\frac{2+4+6+8+9+10}{6}=6.5$$

$$\bar{y}=\frac{7+10+13+15+20+28}{6}=15.5$$

ដូចនេះ $M\ (6.5\,,15.5\ )$

| | | |
|---|---|---|
| -តើសមីការបន្ទាត់ដែលកាត់តាមចំណុច $M\ (6.5\ ,15.5\ )$ និងចំណុច $(6\ ,13)$ កំណត់ដូចម្តេច?<br>-ចូរប្អូនរកតម្លៃ $y$ ?<br><br>-តើ $y=?$<br><br><br><br><br>-លំហាត់<br>-ចែកសន្លឹកលំហាត់ប្រត្តិបត្តិឱ្យសិស្សធ្វើតាមក្រុម | គ. សមីការបន្ទាត់ដែលកាត់តាមចំណុច $M\ (6.5\ ,15.5\ )$ និងចំណុច $(6\ ,13)$<br>-សមីការបន្ទាត់ដែលកាត់តាមចំណុច $M\ (6.5\ ,15.5\ )$ និងចំណុច $(6\ ,13)$ កំណត់ដោយ<br>$\frac{y-13}{x-6}=\frac{13-15.5}{6-6.5}=\frac{-2.5}{-0.5}=5$<br>$\Rightarrow y-13=5(x-6)$<br>$y=5x-17$<br>ដូចនេះ សមីការបន្ទាត់គឺ<br>$y=5x-17$ | គ. សមីការបន្ទាត់ដែលកាត់តាមចំណុច $M\ (6.5\ ,15.5\ )$ និងចំណុច $(6\ ,13)$<br>-សមីការបន្ទាត់ដែលកាត់តាមចំណុច $M\ (6.5\ ,15.5\ )$ និងចំណុច $(6\ ,13)$ កំណត់ដោយ<br>$\frac{y-13}{x-6}=\frac{13-15.5}{6-6.5}=\frac{-2.5}{-0.5}=5$<br>$\Rightarrow y-13=5(x-6)$<br>$y=5x-17$<br>ដូចនេះ សមីការបន្ទាត់គឺ<br>$y=5x-17$<br><br>-ដោះស្រាយ |

<table>
<tr>
<td>
-ដាក់លំហាត់ឱ្យសិស្សឡើងធ្វើ<br>
-គេមានតារាងនៃស្ថិតិពីរអថេរ ដូចខាងក្រោម<br>
<table>
<tr><td>$x_i$</td><td>0</td><td>1</td><td>2</td><td>3</td><td>4</td></tr>
<tr><td>$y_i$</td><td>2</td><td>2,5</td><td>3,5</td><td>4</td><td>6</td></tr>
</table>
ក. រកចំណុចមធ្យម<br>
ខ.រកសមីការបន្ទាត់ដែលកាត់តាមចំណុចមធ្យមនិង $(3\ ,\ 4)$
</td>
<td>
ជំហានទី៤<br>
(ពង្រឹងចំណេះដឹង ១៥នាទី)
</td>
<td>
ចម្លើយ<br>
-រកចំណុចមធ្យម $M\left(\overline{x},\overline{y}\right)$<br>
$\overline{x}=\dfrac{0+1+2+3+4}{5}=2$<br>
$\overline{y}=\dfrac{2+2.5+3.5+4+6}{5}$<br>
$=3.6$<br>
ដូចនេះ $M(2\ ,\ 3.6)$<br>
ខ.សមីការបន្ទាត់ដែលកាត់តាមចំណុច $M\ (2\ ,\ 3.6\ )$ និងចំណុច $(3\ ,\ 4)$ កំណត់ដោយ<br>
$\dfrac{y-4}{x-3}=\dfrac{4-2}{4-3.6}=\dfrac{2}{0.4}=5$<br>
$\Rightarrow\ y-4=5(x-3)$<br>
$y=5x-11$<br>
ដូចនេះ $y=5x-11$
</td>
</tr>
<tr>
<td>
-គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>
-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់
</td>
<td>
<u>ជំហានទី៥</u><br>
(កិច្ចការផ្ទះ ៥នាទី)
</td>
<td>
-សិស្សកត់លំហាត់ និងអនុវត្តតាម
</td>
</tr>
</table>

# កិច្ចតែងការបង្រៀន

- **មុខវិជ្ជា** : **គណិតវិទ្យា** **ថ្នាក់ទី ១២( កម្រិតមូលដ្ឋាន )**
- **ជំពូកទី៥** : **ស្ថិតិពីរអថេរ**
- **មេរៀនទី១** : **ស្ថិតិមានពីរអថេរ**

I.**វត្ថុបំណងនៃមេរៀន**

**-ចំណេះដឹង** : សិស្សកំណត់និយមន័យនៃបន្ទាត់តម្រែតម្រង់លីនេអ៊ែបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

**-ចំណិន** : សិស្សរកបានសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែតាមរយៈលំហាត់បានត្រឹមត្រូវ។

**-ឥរិយាបថ** : សិស្សមានស្មារតីយកចិត្តទុកដាក់រៀនសូត្រតាមរយះការណែនាំរបស់គ្រូ។

II. **ខ្លឹមសារមេរៀន** : ពេលវេលា: ...២...ម៉ោង ថ្ងៃ.........ទី...ខែ..............ឆ្នាំ..........

២.សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

២.១ បន្ទាត់តម្រែតម្រង់លីនេអ៊ែ

២.២ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

III.**សម្ភារៈឧទេស**

-ស . ស :ទំព័រទី.១៤៦ ដល់ទំព័រទី១៥០

-ស . គ : ទំព័រទី១៤៦ ដល់ទំព័រទី១៥០

-សន្លឹកកម្រង់លំហាត់ប្រត្តិបត្តិ

IV.**ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើសមីការបន្ទាត់ដែលមានមេគុណប្រាប់ទិស $a=\frac{y_2-y_1}{x_2-x_1}$ | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី) | -មានរាង $y=a\left(x-x_0\right)+y_0$<br>-រកចំណុចមធ្យម $M\left(\overline{x},\overline{y}\right)$ |

ហើយកាត់តាម $(x_0 , y_0)$ មានរាងដូចម្ដេច ?

-គេមានតារាងនៃស្ថិតិពីរអថេរ ដូចខាងក្រោម

| $x_i$ | 0 | 2 | 3 | 4 | 6 |
|---|---|---|---|---|---|
| $y_i$ | 7 | 15 | 10 | 20 | 8 |

ក. រកចំណុចមធ្យម

ខ.រកសមីការបន្ទាត់ដែលកាត់តាមចំណុចមធ្យមនិង $(5 , 14)$

$$\bar{x} = \frac{0+2+3+4+6}{5} = 3$$

$$\bar{y} = \frac{7+15+10+20+8}{5}$$

$=12$

ដូចនេះ $M(3 , 12)$

ខ.សមីការបន្ទាត់ដែលកាត់តាមចំណុច $M(3 , 12)$ និងចំណុច $(5 , 14)$ គេបាន

$$\frac{y-14}{x-3} = \frac{14-12}{5-3} = \frac{2}{2} = 1$$

$$\Rightarrow y - 14 = x - 3$$

$$y = x + 11$$

-ដាក់ឧទាហរណ៍ ណែនាំសិស្សបលស្រាយស្ថិតិមានពីរអថេរជាចំណុច

<u>ជំហានទី៣</u>

(មេរៀនថ្មី រយះពេល៦០នាទី)

**មេរៀនទី១:**

**ស្ថិតិមានពីរអថេរ**

២.សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

២.១ បន្ទាត់តម្រែតម្រង់លីនេអ៊ែ

-ឧទាហរណ៍ គេមានតារាងស្ថិតិពីរអថេរខាងក្រោម

| ឆ្នាំបោះពុម្ព | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|
| ចំនួន ស.ភ (ជាម៉ឺនក្បាល) | 48 | 48,4 | 49,5 | 48,9 | 49,3 | 48,7 |

-ឱ្យសិស្សឡើងដៅចំណុច

-បកស្រាយទិន្នន័យពីរអថេរជាចំណុច

| | | |
|---|---|---|
| -ចូរប្អូនសង្កេតចំណុចទាំង៦<br>ហើយសង់បន្ទាត់ d មួយដែល<br>នៅជិតចំណុចទាំងនោះបំផុត<br><br>-ប្រាប់សិស្សថា បន្ទាត់d ហៅថា<br>បន្ទា<br>បន្ទាត់នេះអាចឱ្យគេធ្វើការប៉ាន់<br>ស្មាន<br>បាននូវចំនួនសៀវភៅដែលនឹង<br>ត្រូវបោះពុម្ពនៅពេលខាងមុខ។<br>ត់តម្រែតម្រង់លីនេអ៊ែ។<br><br>-ទាញជាទូទៅឱ្យសិស្សសង្កេត | <br>-តាមក្រាបគេសង្កេតឃើញថា ចំណុច<br>ទាំង ៦នៅរាយប៉ាយមិនស្ថិតនៅលើ<br>បន្ទាត់តែមួយ។ឥឡូវគេចង់សង់បន្ទាត់<br>D មួយដែលស្ថិតនៅជិតបំផុតទៅនឹង<br>ចំណុចទាំង ៦។ គេត្រូវរំកិលបន្ទាត់ d<br>លៃយ៉ាងណាឱ្យចម្ងាយទាំងនោះទៅ<br>បន្ទាត់មានប្រវែងតូចបំផុត។<br>បន្ទាត់ d ហៅថាបន្ទាត់តម្រែតម្រង់លីនេ<br>អ៊ែ។<br>បន្ទាត់ដែលសង់បានអាចឱ្យគេធ្វើការប៉ា<br>ន់ស្មាន បាននូវចំនួនសៀវភៅដែលនឹង<br>ត្រូវបោះពុម្ពនៅពេលខាងមុខ។<br><br>២.២ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ<br>-ជាទូទៅ  ដើម្បីរក សមីការបន្ទាត់<br>តម្រែតម្រង់លីនេអ៊ែគេត្រូវរកចំណុច<br>មធ្យមពីរ<br>- តម្រៀបចំណុចទិន្នន័យពីរអាប់ស៊ីស<br>តូចទៅអាប់ស៊ីសធំ។<br>-ចែកចំណុចទិន្នន័យជាពីរក្រុមស្មើគ្នា | -សង្កេត<br><br>-សង្កេត |

| | | |
|---|---|---|
| | បើចំណុចទិន្នន័យជាចំនួនគូ។ តែបើចំណុចទិន្នន័យជាចំនួនសេសគេចែកចំណុចទាំងនោះជាពីរក្រុមមិនស្មើគ្នា។<br>-រកចំណុចមធ្យមនៃក្រុមនីមួយៗ<br>-សរសេរសមីការបន្ទាត់ដែលកាត់តាមចំណុចមធ្យមទាំងពីរ។ | |
| -ដាក់លំហាត់គំរូណែនាំសិស្សដោះស្រាយ | លំហាត់គំរូ ទិន្នន័យក្នុងតារាងខាងក្រោមជាស្ថិតិមានពីរអថេរ | |

| $x_i$ | 2 | 4 | 6 | 8 | 9 |
|---|---|---|---|---|---|
| $y_i$ | 7 | 10 | 11 | 13 | 17 |

| | | |
|---|---|---|
| | ក. ដៅចំណុចទិន្នន័យក្នុងតម្រុយកែង<br>ខ. ចែកចំណុចទិន្នន័យជាពីរក្រុមរួចសរសេរសមីការដែលកាត់តាមចំណុចមធ្យមនៃក្រុមទាំងពីរ។ | -ដៅចំណុច |
| -ចូរប្អូនដៅចំណុចលើអ័ក្ស | ចម្លើយ<br>ក. ដៅចំណុចទិន្នន័យ | |




| | | |
|---|---|---|
| -តើគេចែកទិន្នន័យជាប៉ុន្មានក្រុម?អ្វីខ្លះ? | ខ. ចែកចំណុចទិន្នជាពីក្រុម | |
| - បើតាង $M_1\left(\overline{x_1}\,,\overline{y_1}\right)$ ជាមធ្យម | -ក្រុមទី១ $(2\,,7),(4\,,10),(6,11),(8\,,13)$ | |

| | | |
|---|---|---|
| ចំណុចនៃក្រុមទី១<br>-តើ $\overline{x_1}$ =?<br>-តើ $\overline{y_1}$ =?<br>-តើគេបាន $M_1$ = ?<br><br>- បើតាង $M_2\left(\overline{x_2}\ ,\overline{y_2}\right)$ ជាមធ្យម ចំណុចនៃក្រុមទី១<br>-តើ $\overline{x_2}$ =?<br>-តើ $\overline{y_2}$ =?<br>-តើគេបាន $M_2$ = ?<br><br>-តើសមីការដែលកាត់តាម ចំណុច $M_1$ និង $M_2$ មានរាងដូច ម្ដេច?<br><br>-ចែកស្លឹកលំហាត់ប្រត្តិបត្តិ ឱ្យសិស្សដោះស្រាយតាមក្រុម | -ក្រុមទី២ $(9\ ,17),(12\ ,19),(14\ ,23)$<br>តាង $M_1\left(\overline{x_1}\ ,\overline{y_1}\right)$ ជាមធ្យមចំណុចនៃក្រុមទី១ ដែល<br>$\overline{X_1}=\frac{2+4+6+8}{4}=5$<br>$\overline{Y_1}=\frac{7+10+11+13}{4}=10.25$<br>ដូចនេះ $M_1\ (5\ ,10.25)$<br>តាង $M_2\left(\overline{x_2}\ ,\overline{y_2}\right)$ ជាមធ្យមចំណុចនៃក្រុមទី២ ដែល<br>$\overline{X_2}=\frac{9+12+14}{3}=11.67$<br>$\overline{Y_2}=\frac{17+19+23}{3}=19.67$<br>ដូចនេះ $M_2\ (11.67\ ,19.67)$<br>សមីការដែលកាត់តាមចំណុច $M_1$ និង $M_2$ គឺ<br>$\frac{y-10.25}{x-5}=\frac{10.25-19.67}{5-11.67}$<br>$y-10.25=1.41(x-5)$<br>$\Rightarrow y1.41x-3.2$<br>ដូចនេះសមីការដែលកាត់តាមចំណុចមធ្យមទាំងពីរគឺ<br>$y=1.41x-3.2$ | <br><br><br><br><br><br><br><br><br><br><br><br><br><br><br>-ធ្វើតាមក្រុម |

| | | |
|---|---|---|
| -ឲ្យសិស្សធ្វើលំហាត់<br>-គេមានតារាងស្ថិតិមានពីរអថេរ<br><br>$x_i$: -2, -1, 0, 1, 2, 3<br>$y_i$: 2, -2, 1, 0, 3, 2<br><br>ក. រកចំណុចមធ្យម $M_1$ និង $M_2$<br>ខ. រកសមីការបន្ទាត់តម្រែតតម្រង់លីនេអ៊ែដែលកាត់តាមចំណុចមធ្យមទាំងពីរ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី) | ចម្លើយ<br>. ចែកចំណុចទិន្នជាពីក្រុម<br>-ក្រុមទី១<br>$(-2\ ,\ 2),(-1\ ,-2),(0,\ 1)$<br>-ក្រុមទី២<br>$(1,0\ ),(2\ ,3),(3\ ,2)$<br>តាង $M_1(\overline{x_1}\ ,\overline{y_1})$ ជាមធ្យមចំណុចនៃក្រុមទី១ ដែល<br>$\overline{X_1}=\frac{-2-1+0}{3}=-1$<br>$\overline{Y_1}=\frac{2-2+1}{3}=0.33$<br>ដូចនេះ $M_1\ (-1\ ,\ 0.33)$<br>តាង $M_2(\overline{x_2}\ ,\overline{y_2})$ ជាមធ្យមចំណុចនៃក្រុមទី២ ដែល<br>$\overline{X_2}=\frac{1+2+3}{3}=2$<br>$\overline{Y_2}=\frac{0+3+2}{3}=1.67$<br>ដូចនេះ $M_2\ (2\ ,1.67)$<br>ខ.សមីការដែលកាត់តាមចំណុច $M_1(-1\ ,\ 0.33)$ និង $M_2(2\ ,1.67)$ គឺ<br>$\frac{y-0.33}{x+1}=\frac{1.67-0.33}{2+1}$<br>$y-0.33=0.45(x+1)$<br>$\Rightarrow y=\ 0.45x+0.78$<br>ដូចនេះសមីការដែលកាត់តាមចំណុចមធ្យមទាំងពីរគឺ<br>$y=0.45x+0.78$ |
| | <u>ជំហានទី៥</u> | |

| | | |
|---|---|---|
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យ | (កិច្ចការផ្ទះ ៥នាទី) | -សិស្សកត់លំហាត់<br>និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

## ជំពូកទី ៥ ស្ថិតិពីរអថេរ

## មេរៀនទី ២ សមីការបន្ទាត់តំរែតម្រង់លីនេអ៊ែ

**I. វត្ថុបំណងនៃមេរៀន**: ក្រោយពេលរៀនមេរៀននេះចប់សិស្សអាច ៖

- ចំណេះដឹង : បង្ហាញបានពីទំនាក់ទំនងលីនេអ៊ែបានត្រឹមត្រូវតាមរយៈឧទាហរណ៍
- បំណិន : កំណត់បានពីទំនាក់ទំនងលីនេអ៊ែតាមរយៈឧទាហរណ៍បានត្រឹមត្រូវ
- ឥរិយាបថ : សិស្សមានស្មារតីប្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់

**II. ពេលវេលា** ០២ម៉ោង

**III. សម្ភារៈឧបទេស**

- សៀវភៅសិស្ស :ទំព័រទី ១៥៨ ដល់ទំព័រទី ១៥៩
- សៀវភៅគ្រូ : ទំព័រទី ១៥៨ ដល់ទំព័រទី ១៥៩

**IV.ខ្លឹមសារមេរៀន**

១. ទំនាក់ទំនងលីនេអ៊ែ

**IV. ដំណឹកនាំមេរៀន**

<table>
<tr><th>សកម្មភាពគ្រូ</th><th>ខ្លឹមសាមេរៀន</th><th>សកម្មភាពសិស្ស</th></tr>
<tr><td>-ពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ</td><td><u>ជំហានទី១</u> (រដ្ឋបាលថ្នាក់)</td><td>-ណាងសិស្សឡើងរាយការណ៍</td></tr>
<tr><td>- បង្ហាញទិន្នន័យនៃស្ថិតិមានពីរអថេរ
<table>
<tr><td>$x_i$</td><td>0</td><td>1</td><td>2</td><td>3</td><td>4</td><td>5</td></tr>
<tr><td>$y_i$</td><td>2</td><td>1</td><td>3</td><td>4</td><td>3</td><td>4</td></tr>
</table>
រំលឹកពីជំហានបន្តបន្ទាប់នៃការដៅចំណុចទិន្នន័យ និង ការកំណត់សមីការបន្ទាត់ដែលកាត់តាមចំណុចមធ្យមទាំងពីរ។</td><td><u>ជំហានទី២</u> (រំលឹកមេរៀនចាស់)</td><td>- ដៅចំណុច


- ចែកទិន្នន័យជាក្រុម<br>- ក្រុមទី១ $(0,2),(1,1),(2,3)$<br>- ក្រុមទី២ $(3,4),(4,3),(5,4)$<br>- រកចំណុចមធ្យមនៃក្រុមនីមួយ<br>ក្រុមទី១ $M_1\left(\overline{x_1},\overline{y_1}\right)$</td></tr>
</table>

$\overline{x_1} = \frac{0+1+2}{3} = 1$

$\overline{y_1} = \frac{2+1+3}{3} = 2$

ដូចនេះ $M_1(1,2)$ ។

ក្រុមទី២ $M_2\left(\overline{x_2}, \overline{y_2}\right)$

$\overline{x_2} = \frac{3+4+5}{3} = 4$

$\overline{y_2} = \frac{4+3+4}{3} = 3.6$

ដូចនេះ $M_2(4, 3.6)$

- សមីការបន្ទាត់តាមចំណុច $M_1$ និង $M_2$

$\frac{y-2}{x-1} = \frac{3.6-2}{4-1}$

$\frac{y-2}{x-1} = \frac{1.6}{3}$

$3y - 6 = 1.6x - 1.6$

$3y = 1.6 - 1.6 + 6$

$y = 0.53x + 1.46$

ដូចនេះ $y = 0.53x + 1.46$

---

<u>ជំហានទី៣</u> (មេរៀនថ្មី)

## មេរៀនទី២ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

### ១. ទំនាក់ទំនងលីនេអ៊ែ

- ដាក់ឧទាហរណ៍

ឧទាហរណ៍ ក្រុមហ៊ុនមួយបានកំណត់ប្រាក់បៀវត្សសម្រាប់បុគ្គលិកទៅតាមចំនួនឆ្នាំនៃអតីតភាពដែលបានបម្រើការងារក្នុងក្រុមហ៊ុន ។

- កត់ត្រានិងសង្កេត

| $x_1$ | 0 | 1 | 2 | 3 |
|---|---|---|---|---|
| $y_1$ | 120 | 170 | 220 | 270 |

- ឲ្យសិស្សដៅចំណុចទាំងបី

• ដៅចំណុច $(0,120), (1,170)$, $(2,220)$ និង $(3,270)$



<table>
<tr>
<td>
- បញ្ជាក់ប្រាប់សិស្សដូចមានក្នុងខ្លឹមសារមេរៀន<br><br>
- ឲ្យសិស្សទាញជាទូទៅ<br><br>
- ដាក់លំហាត់គំរូនិងណែនាំឲ្យសិស្សធ្វើ<br><br>
-
</td>
<td>


<br>
តាមផលធៀប $\frac{170-120}{1-0}=\frac{220-170}{2-1}$ នេះបញ្ជាក់ថាគ្រប់ចំណុចទាំងអស់ស្ថិតនៅលើបន្ទាត់តែមួយដែលមានប្រាប់ទិសស្មើនឹង 50 ហើយមានសមីការ $\frac{y-120}{x-0}=50$<br>
$\Rightarrow y=50x+120$<br>
ដូចនេះសមីការ $y=50x+120$ ជាទំនាក់ទំនងរវាង $x$ និង $y$ ដែលហៅថា(ទំនាក់ទំនងលីនេអ៊ែ)។<br>
ជាទូទៅ សមីការ $y=ax+b$ ជាទំនាក់ទំនងរវាង $x$ និង $y$ ដែលហៅថា (ទំនាក់ទំនងលីនេអ៊ែ)។<br>
លំហាត់គំរូ បំពេញចន្លោះខាងក្រោម រួចរកសមីការបន្ទាត់ដែលកាត់តាមចំណុចទិន្នន័យទាំងនេះបើមាន<br>
ក.
<table>
<tr><td>$x_i$</td><td>1</td><td>3</td><td>2</td><td>6</td><td>7</td></tr>
<tr><td>$y_i$</td><td>-1</td><td>5</td><td>2</td><td></td><td>17</td></tr>
</table>
ខ.
<table>
<tr><td>$x_i$</td><td>7</td><td>5</td><td>4</td><td>3</td><td>6</td></tr>
<tr><td>$y_i$</td><td>9</td><td></td><td>6</td><td>2</td><td>7</td></tr>
</table>
</td>
<td>
- សង្កេត<br><br>
ជាទូទៅ សមីការ $y=ax+b$ ជាទំនាក់ទំនងរវាង $x$ និង $y$ ដែលហៅថា(ទំនាក់ទំនងលីនេអ៊ែ)។<br>
ចម្លើយ<br>
ក. ចំណុចទិន្នន័យ $(1,-1)$, $(3,3),(2,2),(7,17)$<br>
គេបានផលធៀប<br>
$\frac{5+1}{3-1}=3,\frac{2-5}{2-3}=3$ និង $\frac{17-2}{7-2}=3$<br>
ដោយផលធៀបស្មើនិង 3នោះចំណុចទាំងអស់នេះស្ថិតនៅលើបន្ទាំត់តែមួយ<br>
គេបាន $\frac{y+1}{x-1}=3\Rightarrow y=3x-4$<br>
- បើ $x=6\Rightarrow y=3\times 6-4=14$<br>
ដូចនេះ សមីការបន្ទាត់ដែលកាត់តាមចំណុចទាំងនោះគឺ<br>
$y=3x-4$<br>
ខ. ចំណុចទិន្នន័យ $(7,9),(4,6)$ $(3,2),(6,7)$<br>
គេបានផលធៀប $\frac{6-9}{4-7}=1$<br>
$\frac{2-6}{3-4}=4$
</td>
</tr>
</table>

<table>
<tr>
<td></td>
<td></td>
<td>ដោយ $\frac{6-9}{4-7}\neq\frac{2-6}{3-4}$<br>គេអាចសន្និដ្ឋានថាចំណុចទាំង៤ មិនស្ថិតនៅលើបន្ទាត់តែមួយទេ។ ប៉ុន្តែគេត្រូវការបន្ទាត់ដើម្បីប៉ាន់ស្មានតម្លៃ $y$ ទៅតាមតម្លៃ $x$</td>
</tr>
<tr>
<td>- ចូរបំពេញចន្លោះខាងក្រោម
<table>
<tr><td>$x_i$</td><td>0</td><td>1</td><td>2</td><td>3</td><td>4</td></tr>
<tr><td>$y_i$</td><td>-1</td><td>1</td><td></td><td>5</td><td>7</td></tr>
</table>
</td>
<td><u>ជំហានទី ៤</u>( ពង្រឹងពុទ្ធិ )</td>
<td>- គេបានផលធៀប $\frac{1+1}{1-0}=2$<br>$\frac{5-1}{3-1}=2,\frac{7-5}{4-3}=2$<br>- ដោយផលធៀបមានតម្លៃស្មើនិង២ថេរ ដូចនេះចំណុចទាំងអស់ស្ថិតលើបន្ទាត់តែមួយ។<br>គេបាន $\frac{y+1}{x-0}=2\Rightarrow y=2x-1$<br>បើ $x=2\Rightarrow y=2\times2-1=3$<br>ដូចនេះ ចន្លោះដែលត្រូវបំពេញគឺ $y=3$</td>
</tr>
<tr>
<td>- ពេលត្រឡប់ទៅផ្ទះវិញប្អូនត្រូវធ្វើលំហាត់ផង ។</td>
<td><u>ជំហានទី ៥</u>( បណ្តាំផ្ញើរ )</td>
<td>-ស្តាប់និងកត់ត្រា</td>
</tr>
</table>

# កិច្ចតែងការបង្រៀន

## ជំពូកទី ៥ ស្ថិតិពីរអថេរ

## មេរៀនទី ២ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

**I. វត្ថុបំណងនៃមេរៀន**: ក្រោយពេលរៀនមេរៀននេះចប់សិស្សអាច ៖

- ចំណេះដឹង : កំណត់បានសមីការបន្ទាត់ បានត្រឹមត្រូវតាមរយះឧទាហរណ៍
- បំណិន :រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែតាមរយៈរូបមន្តបានត្រឹមត្រូវ
- ឥរិយាបថ : មានស្មារតីសហការគ្នាក្នុងការដោះស្រាយលំហាត់

**II. ពេលវេលា** ០២ម៉ោង

**III. សម្ភារៈឧបទេស**

- សៀវភៅសិស្ស : ទំព័រទី ១៦០ ដល់ទំព័រទី ១៦៦
- សៀវភៅគ្រូ : ទំព័រទី ១៦០ ដល់ទំព័រទី ១៦៦

**IV.ខ្លឹមសារមេរៀន**

២. សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

**IV. ដំណើរនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមាន អនាម័យ សណ្ដាប់ធ្នាប់ និង វិន័យ | <u>ជំហានទី១</u> (រដ្ឋបាលថ្នាក់) | -ណាងសិស្សឡើងរាយការណ៍ |
| - តើសមីការបន្ទាត់ដែលមានទម្រង់ $y = ax + b$ ជាទំនាក់ទំនង<br>រវាង $x$ និង $y$ ហៅថាអ្វី? | <u>ជំហានទី២</u> (រំលឹកមេរៀនចាស់) | - សមីការបន្ទាត់ដែលមានទម្រង់ $y = ax + b$ ជាទំនាក់ទំនងរវាង $x$ និង $y$ ហៅថា(ទំនាក់ទំនងលីនេអ៊ែ) |
| - ប្រាប់សិស្សពីសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ | <u>ជំហានទី៣</u> (មេរៀនថ្មី)<br>មេរៀនទី២ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ<br>២. សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ<br>$\therefore$ បើគេមានចំណុចទិន្នន័យ $(x_1, y_1)$ $(x_2, y_2), (x_3, y_3), \ldots (x_n, y_n)$ នោះ សមីការតម្រែតម្រង់លីនេអ៊ែមានរាង | - សិស្សសង្កេត និងកត់ត្រា |

- ដាក់ឧទាហរណ៍ណែនាំសិស្សឲ្យដោះស្រាយ

$y = ax + b$ ដែល

$$a = \frac{n\sum_{i=1}^{n} x_i y_i - \left(\sum_{i=1}^{n} x_i\right)\left(\sum_{i=1}^{n} y_i\right)}{n\sum_{i=1}^{n} x_i^2 - \left(\sum_{i=1}^{n} x_i\right)^2}$$

និង $b = \frac{1}{n}\left(\sum_{i=1}^{n} y_i - a\sum_{i=1}^{n} x_i\right)$។

$\therefore$ សម្គាល់ $b = \frac{1}{n}\left(\sum_{i=1}^{n} y_i - a\sum_{i=1}^{n} x_i\right)$

$b = \overline{y} - a\overline{x}$ ឬ $\overline{y} = a\overline{x} + \overline{y}$ មានន័យថាបន្ទាត់តម្រែតម្រង់លីនេអ៊ែកាត់តាមចំណុចមធ្យម $\left(\overline{x}, \overline{y}\right)$។

ឧទាហរណ៍ រកសមីការតម្រែតម្រង់លីនេអ៊ែនៃទន្និន័យក្នុងតារាងខាងក្រោម៖

| | | | | |
|---|---|---|---|---|
| $x_i$ | 1 | 1 | 2 | 4 |
| $y_i$ | 1 | 2 | 2 | 6 |

- តាមទិន្នន័យខាងលើគេបានតារាងដូចខាងក្រោម

| $x_i$ | $y_i$ | $x_i y_i$ | $x_i^2$ |
|---|---|---|---|
| 1 | 1 | 1 | 1 |
| 1 | 2 | 2 | 1 |
| 2 | 2 | 4 | 4 |
| 4 | 6 | 24 | 16 |
| 8 | 11 | 31 | 22 |

សមីការតម្រែតម្រង់លីនេអ៊ែមានរូបមន្ត $y = ax + b$

$$a = \frac{n\sum_{i=1}^{n} x_i y_i - \left(\sum_{i=1}^{n} x_i\right)\left(\sum_{i=1}^{n} y_i\right)}{n\sum_{i=1}^{n} x_i^2 - \left(\sum_{i=1}^{n} x_i\right)^2}$$

$$= \frac{4(31) - 8(11)}{4(22) - 8^2} = \frac{36}{24} = 1.5$$

$$b = \frac{1}{n}\left(\sum_{i=1}^{n} y_i - a\sum_{i=1}^{n} x_i\right)$$

- ដាក់លំហាត់គំរូឲ្យសិស្សធ្វើ

លំហាត់គំរូ តាមរបាយការណ៍មន្ត្រីម្នាក់មកពីក្រសួងទេសចរណ៍បានឲ្យដឹងថាចំនួនទេសចរណ៍ដែលមកកំសាន្តតាងដោយតារាងខាងក្រោម

| $x_i$ ឆ្នាំ | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|
| $y_i$ ម៉ឺន | 25.7 | 26.3 | 29.7 | 34.2 | 38.3 |

បើ $x=0$ តាងឆ្នាំ 2005

ក. រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

ខ. ចូរធ្វើការប៉ាន់ស្មានចំនួនទេសចរណ៍ដែលនឹងមកកំសាន្តក្នុងឆ្នាំ 2010 ។

$$=\frac{1}{4}\left(\sum_{i=1}^{4}y_i-a\sum_{i=1}^{4}x_i\right)$$

$$=\frac{1}{4}(11-1.5\times 8)$$

$$=\frac{1}{4}(11-12)=0.25$$

ដូចនេះសមីការតម្រែតម្រង់លីនេអ៊ែ $y=1.5x-0.25$

បើ $x=0$ តាងឆ្នាំ2005នោះគេបានចំណុចទិន្នន័យ $(0,26.3)$ $(1,26.3),(2,29.7),(3,34.2)$ និង $(4,38.3)$ ។

ក. សមីការបន្ទាត់មានរាង

$y=ax+b$

សង់តារាង

| $x_i$ | $y_i$ | $x_iy_i$ | $x_i^2$ |
|---|---|---|---|
| 0 | 25.7 | 0 | 0 |
| 1 | 26.3 | 26.3 | 1 |
| 2 | 29.7 | 59.4 | 4 |
| 3 | 34.2 | 102.6 | 9 |
| 4 | 38.3 | 153.2 | 16 |
| 10 | 154.2 | 341.5 | 30 |

គេបាន

$$a=\frac{5(341.5)-10(154.2)}{5(30)-10^2}$$

$$=3.31$$

$$b=\frac{1}{5}(154.2-3.31\times 10)$$

$$=24.22$$ ។

ដូចនេះ

សមីការបន្ទាត់តម្រែតម្រង់លីនេ

- ដាក់លំហាត់ប្រតិបត្តឲ្យសិស្សពិភាក្សាដោះស្រាយ

∴ ប្រតិបត្តិ ក្រុមហ៊ុនមួយលក់រថយន្តដែលបានប្រើប្រាស់រួចៗតម្លៃលក់បញ្ចុះទៅតាមចំនួនឆ្នាំដែលបានប្រើប្រាស់។តាង $x_i$ ជាចំនួនឆ្នាំដែលបានប្រើប្រាស់ និង $y_i$ តាងតម្លៃលក់(ឯកតាជាលានរៀល)

| $x_i$ | 2 | 4 | 5 | 5 | 5 |
|---|---|---|---|---|---|
| $y_i$ | 169 | 103 | 85 | 82 | 89 |
| 5 | 6 | 6 | 6 | 7 | 7 |
| 98 | 66 | 95 | 169 | 70 | 49 |

អ៊ែ គឺ $y=3.31x+24.22$ ។

ខ. ឆ្នាំ 2010 ត្រូវនិង $x=5$

បើ $x=5$ នោះ

$y=3.31\times 5+24.22=40.77$

ដូចនេះ ចំនួនទេសចរណ៍មកកំសាន្តក្នុងឆ្នាំ 2010 គឺ40.77 ម៉ឺននាក់ ។

ក. រកសមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

សមីការបន្ទាត់មានរាងទូទៅ

$y=ax+b$

ចំណុចទិន្នន័យស្មើនឹង 11នោះ គេបាន $n=11$

| $x_i$ | $y_i$ | $x_iy_i$ | $x_i^2$ |
|---|---|---|---|
| 2 | 169 | 338 | 4 |
| 4 | 103 | 412 | 16 |
| 5 | 85 | 425 | 25 |
| 5 | 82 | 410 | 25 |
| 5 | 89 | 445 | 25 |
| 5 | 98 | 490 | 25 |
| 6 | 66 | 396 | 36 |
| 6 | 95 | 570 | 36 |
| 6 | 169 | 1014 | 36 |
| 7 | 70 | 490 | 49 |
| 7 | 49 | 343 | 49 |
| 58 | 1075 | 5333 | 326 |

$$a=\frac{11(5333)-58(1075)}{11(326)-(58)^2}$$

$=-16.60$

$$b=\frac{1}{11}\left(1075-(-16.60)58\right)$$

$=185.25$

ដូចនេះ សមីការបន្ទាត់តម្រែ

| | | |
|---|---|---|
| | | តម្រង់លីនេអ៊ែមានរាង<br>$y=-16.60x+185.25$<br>ខ. តម្លៃរថយន្តដែលមានណាស់ 3ឆ្នាំ និង 5ឆ្នាំ<br>បើ $x=3$ នោះ<br>$y=-16.60(3)+185.25$<br>$=135.45$<br>បើ $x=5$ នោះ<br>$y=16.60(5)+185.25$<br>$=102.25$<br>ដូចនេះ តម្លៃរថយន្តដែលមាន សំណាស់៣ឆ្នាំ ស្មើនឹង $135.45$ លានរៀល។<br>ចំណាស់៥ឆ្នាំស្មើនឹង $102.25$ លានរៀល។ |
| តើសមីការបន្ទាត់តម្រែតម្រង លីនេអ៊ែមានរាងដូចម្តេច? ហើយរក $a,b$ | <u>ជំហានទី ៤</u>( ពង្រឹងពុទ្ធិ ) | សមីការបន្ទាត់តម្រែតម្រង់ លីនេអ៊ែមានរាង $y=ax+b$<br>$a=\dfrac{n\sum_{i=1}^{n}x_iy_i-\left(\sum_{i=1}^{n}x_i\right)\left(\sum_{i=1}^{n}y_i\right)}{n\sum_{i=1}^{n}x_i^2-\left(\sum_{i=1}^{n}x_i\right)^2}$<br>$b=\dfrac{1}{n}\left(\sum_{i=1}^{n}y_i-a\sum_{i=1}^{n}x_i\right)$ |
| - ធ្វើលំហាត់លេខ ៥ទំព័រទី ១៧៣ ដាក់ក្នុងសៀវភៅ | <u>ជំហានទី៥</u> (បណ្តាំផ្ញើ) | - ស្តាប់ និងកត់ត្រា |

# កិច្ចតែងការបង្រៀន

## ជំពូកទី ៥ ស្ថិតិពីរអថេរ

## មេរៀនទី ២ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ

**I. វត្ថុបំណងនៃមេរៀន**: ក្រោយពេលរៀនមេរៀននេះចប់សិស្សអាច ៖

- ចំណេះដឹង : កំណត់បានពីរូបមន្តមេគុណតម្រែតម្រង់លីនេអ៊ែបានត្រឹមត្រូវតាមរយៈឧទាហរណ៍
- បំណិន :ដោះស្រាយលំហាត់តាមរយៈរូបមន្តបានត្រឹមត្រូវ
- ឥរិយាបថ : មានស្មារតីសហការគ្នាក្នុងការដោះស្រាយលំហាត់

**II. ពេលវេលា** ០២ម៉ោង

**III. សម្ភារៈឧបទេស**

- សៀវភៅសិស្ស :ទំព័រទី ១៦៦ ដល់ទំព័រទី ១៧០
- សៀវភៅគ្រូ : ទំព័រទី ១៦៦ ដល់ទំព័រទី ១៧០

**IV.ខ្លឹមសារមេរៀន**

៣. មេគុណតម្រែតម្រង់លីនេអ៊ែ

**IV. ដំណើរការមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | <u>ជំហានទី១</u> (រដ្ឋបាលថ្នាក់) | -ណាងសិស្សឡើងរាយការណ៍ |
| - តើសមីការបន្ទាត់តម្រង់តម្រង់លីនេអ៊ែមានរាងដូចម្តេច? | <u>ជំហានទី២</u> (រំលឹកមេរៀនចាស់) | សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែមានរាង $y = ax + b$<br>$a = \dfrac{n\sum_{i=1}^{n} x_i y_i - \left(\sum_{i=1}^{n} x_i\right)\left(\sum_{i=1}^{n} y_i\right)}{n\sum_{i=1}^{n} {x_i}^2 - \left(\sum_{i=1}^{n} x_i\right)^2}$<br>$b = \dfrac{1}{n}\left(\sum_{i=1}^{n} y_i - a\sum_{i=1}^{n} x_i\right)$ |
| | <u>ជំហានទី៣</u> (មេរៀនថ្មី)<br>**មេរៀនទី២ សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែ**<br>**៣. គុណតម្រែតម្រង់លីនេអ៊ែ** | |

- ប្រាប់សិស្សពីរូបមន្តមេគុណតម្រែតម្រង់លីនេអ៊ែ

∴ មេគុណតម្រែតម្រង់លីនេអ៊ែកំណត់រូបមន្ត

$$r=\frac{n\sum_{i=1}^{n}x_iy_i-\sum_{i=1}^{n}x_i\sum_{i=1}^{n}y_i}{\sqrt{n\sum_{i=1}^{n}x_i^2-\left(\sum_{i=1}^{n}x_i\right)^2}\times\sqrt{n\sum_{i=1}^{n}y_i^2-\left(\sum_{i=1}^{n}y_i\right)^2}}$$

តម្លៃ $r$ អាចប្រែប្រួលក្នុងចន្លោះ $-1\le r\le 1$

តម្លៃ $r$ ហៅថាមេគុណតម្រែតម្រង់លីនេអ៊ែ

បើ $r>0$ បញ្ជាក់ថា $y$ កើនទៅតាមតម្លៃ $x$ ។

បើ $r<0$ បញ្ជាក់ថា $y$ ថយទៅតាមតម្លៃ $x$ ។

បើ $r=1$ ឬ $r=-1$ ចំណុចទិន្នន័យស្ថិតនៅលើបន្ទាត់តម្រែតម្រង់លីនេអ៊ែមានន័យថា $x$ និង $y$ មានទំនាក់ទំនងគ្នាឥតខ្ចោះ។

បើ $x=0.9$ ឬ $x=-0.9$ គេថា $x$ និង $y$ មានទំនាក់ទំនងយ៉ាងខ្លាំង។សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែអាចយកមកប៉ាន់ស្មានបានល្អ។

បើ $x=0.4$ ឬ $x=-0.4$ គេថា $x$ និង $y$ មានទំនាក់ទំនងយ៉ាងខ្សោយ។សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែពុំបានលទ្ធផលល្អទេ។

បើ $r=0$ គេថា $x$ និង $y$ គ្មានទំនាក់ទំនងគ្នា។ដូចនេះ គេមិនអាចប្រើប្រាស់សមីការបន្ទាត់តម្រែតម្រង់លីនេអ៊ែដើម្បីធ្វើការប៉ាន់ស្មានលទ្ធផងបានឡើយ។

- ស្តាប់និងសង្កេត

- ដាក់ឧទាហរណ៍មកពន្យល់និងណែនាំសិស្ស

ឧទាហរណ៍ រកមេគុណតម្រែតម្រង់លីនេអ៊ែនៃទិន្និន័យក្នុងតារាងខាងក្រោម

| $x_i$ | 1 | 2 | 3 | 4 |
|---|---|---|---|---|
| $y_i$ | 2 | 4 | 4 | 6 |

រកមេគុណតម្រែតម្រង់លីនេអ៊ែតាមរូបមន្ត

$$r=\frac{n\sum_{i=1}^{n}x_iy_i-\sum_{i=1}^{n}x_i\sum_{i=1}^{n}y_i}{\sqrt{n\sum_{i=1}^{n}x_i^2-\left(\sum_{i=1}^{n}x_i\right)^2}\times\sqrt{n\sum_{i=1}^{n}y_i^2-\left(\sum_{i=1}^{n}y_i\right)^2}}$$

ដែល $n=4$ គេបាន

តារាងផងបូកដូចខាងក្រោម

| $x_i$ | $y_i$ | $x_iy_i$ | $x_i^2$ | $y_i^2$ |
|---|---|---|---|---|
| 1 | 2 | 2 | 1 | 4 |
| 2 | 4 | 8 | 4 | 16 |

| | | | | |
|---|---|---|---|---|
| 3 | 4 | 12 | 9 | 16 |
| 4 | 6 | 24 | 16 | 36 |
| 10 | 16 | 46 | 30 | 72 |

គេបាន

$$r=\frac{4\times46-(10\times16)}{\sqrt{4\times30-10^2}\times\sqrt{4\times72-16^2}}$$

$r=0.95$

ដោយ $r=0.95$ ដូចនេះគេអាចនិយាយថា $x$ និង $y$ មានទំនាក់ទំនងគ្នាខ្លាំង។

- ដាក់លំហាត់គំរូឲ្យសិស្សពិភាក្សាគ្នា

លំហាត់គំរូ ទិន្នន័យខាងក្រោមជាតារាងទិន្នន័យទំនាក់ទំនងរវាងចំណូលសរុបប្រចាំសប្តាហ៍គិតជាពាន់ដុល្លា និងពិន្ទុតេស្តរបស់បុគ្គលិក

| អ្នកលក់ | $x_i$ ពិន្ទុតេស្ត | $y_i$ ប្រាក់$ |
|---|---|---|
| លោកA | 4 | 5 |
| លោកB | 7 | 12 |
| លោកC | 3 | 4 |
| លោកD | 6 | 8 |
| លោកE | 10 | 11 |

គណនាមេគុណតម្រែតម្រង់លីនេអ៊ែ។

គណនាមេគុណតម្រែតម្រង់លីនេអ៊ែ

តាមរូបមន្ត

$$r=\frac{n\sum_{i=1}^{n}x_iy_i-\sum_{i=1}^{n}x_i\sum_{i=1}^{n}y_i}{\sqrt{n\sum_{i=1}^{n}x_i^2-\left(\sum_{i=1}^{n}x_i\right)^2}\times\sqrt{n\sum_{i=1}^{n}y_i^2-\left(\sum_{i=1}^{n}y_i\right)^2}}$$

ដោយ $n=5$ គេបានតារាងផលបូកដូចខាងក្រោម

| $x_i$ | $y_i$ | $x_iy_i$ | $x_i^2$ | $y_i^2$ |
|---|---|---|---|---|
| 4 | 5 | 20 | 16 | 25 |
| 7 | 12 | 84 | 47 | 144 |
| 3 | 4 | 12 | 9 | 16 |
| 6 | 8 | 48 | 36 | 36 |
| 10 | 11 | 110 | 110 | 100 |
| 30 | 40 | 274 | 210 | 370 |

គេបាន

$$r=\frac{5\times274-30\times40}{\sqrt{5\times210-30^2}\times\sqrt{5\times370-40^2}}$$

$$=\frac{170}{\sqrt{150\times250}}=0.88$$

ដោយ $r=0.88$ បញ្ជាក់ថាមានទំនាក់ទំនងយ៉ាងខ្លាំងរវាងពិន្ទុតែសរបស់បុគ្គលិក និងប្រាក់ចំណូលប្រចាំសប្តាហ៍មានន័យ

| | | |
|---|---|---|
| | | ថាតែសបុគ្គលិករបស់អ្នកធ្វើ តែសមានសុពលភាព។ |
| - តើមេគុណតម្រែតម្រង់លី នេអ៊ែមានរូបមន្តដូចម្តេច? | <u>ជំហានទី ៤</u>( ពង្រឹងពុទ្ធិ ) | មេគុណតម្រែតម្រង់លីនេអ៊ែ មានរូបមន្ត $r=\dfrac{n\sum_{i=1}^{n}x_iy_i-\sum_{i=1}^{n}x_i\sum_{i=1}^{n}y_i}{\sqrt{n\sum_{i=1}^{n}{x_i}^2-\left(\sum_{i=1}^{n}x_i\right)^2}\times\sqrt{n\sum_{i=1}^{n}{y_i}^2-\left(\sum_{i=1}^{n}y_i\right)^2}}$ |
| - ពេលត្រឡប់ទៅផ្ទះវិញប្អូន ត្រូវ ធ្វើលំហាត់ផង ។ | <u>ជំហានទី ៥</u>( បណ្តាំផ្ញើរ ) | -ស្តាប់និងកត់ត្រា |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**…១….

មេរៀនទី…១….      **ប៉ារ៉ាបូល**

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង :សិស្សបង្ហាញសញ្ញាណស៊្វីតចំនួនពិត ស៊្វីតរាប់អស់ និង ស៊្វីតអនន្តតួ រយ:ឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយ:ឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

II.ពេលវេលា: ១….ម៉ោង ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ……….

III.សម្ភារ:ឧទេស

-ស . ស :ទំព័រទី.១៧៨.. ដល់ទំព័រទី..១៧៩..

-ស . គ : ទំព័រទី… ដល់ទំព័រទី….

-បន្ទាត់

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | *ជំហានទី១* (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>តើប្អូនបានសិក្សាអំពីប៉ារ៉ាបូលដែរឬទេ?<br>គ្រូពន្យល់មេរៀនថ្មីឲ្យសិស្ស<br><br>តើនៅក្រៅសំណុំ $\mathbb{R}$ មាន សំណុំអ្វីខ្លះ? | *ជំហានទី២* (រំលឹកមេរៀនចាស់)<br>ដោយមេរៀនថ្មីមិនបាច់រំលឹកមេរៀនចាស់ | សិស្សឆ្លើយនិងសង្កេត |
| គ្រូសរសេរមេរៀនថ្មី | *ជំហានទី៣* (មេរៀនថ្មី)<br>*មេរៀនទី.១. ប៉ារ៉ាបូល* | |

<table>
<tr>
<td>បង្ហាញរូបភាពដើម្បីឲ្យសិស្សជឿ</td>
<td>$I$ សេក្តីចផ្តើម<br>គេឲ្យប្លង់មួយកាត់តាមកោនបរិវត្តមានរាងជារង្វង់(មិនកាត់តាមកំពូល)ហើយស្រប និងជនេតកោណនោះ។ប្រសព្វដែលបានមកនេះមានជាខ្សែកោងមួយដែលហៅថាប៉ារ៉ាប៉ូល។ដូចនេះប៉ារ៉ាប៉ូលជាកោនិមួយ។<br>បង្ហាញរូបភាពដើម្បីឲ្យសិស្សជឿ<br><br><br>២/និយមន័យ<br>ប៉ារ៉ាប៉ូលជាសំនុំចំនុចនៅក្នុងប្លង់ដែលមានចំងាយស្មើពីចំនុចនឹង $F$ មួយនិងបន្ទាត់នឹង $(\Delta)$ មួយនៅក្នុងប្លង់នោះ។ ចំនុចនឹង $F$ ហៅថាកុំណុំនិង បន្ទាត់នឹង $(\Delta)$ ហៅថាបន្ទាត់ប្រាប់ទិស។</td>
<td></td>
</tr>
<tr>
<td>សកម្មភាពនៅចំនុចនេះគ្រូត្រូវបង្ហាញសិស្សពីឧបករណ៍សំរាប់គូរប៉ារ៉ាប៉ូល</td>
<td><br></td>
<td>សិស្សមានសំភារៈឧបទេសគ្រប់ៗគ្នា</td>
</tr>
</table>

| | | |
|---|---|---|
| បំផុសគំនិតឲ្យសិស្សឆ្លើយ<br>១.បន្ទាត់ដែលកាត់តាមកំណុំ $F$ ហើយកែងនឹងបន្ទាត់ប្រាប់ទិស $(\Delta)$ ហៅថាអ្វី?<br>២.ចំណុច $V$ ដែលស្ថិតនៅលើអក្ស័ឆ្លុះនិងជាចំណុចកណ្ដាលនៃអង្កេតដែលភ្ជាប់កំណុំ $F$ និងបន្ទាត់ប្រាប់ទិស $\Delta$ ហៅថាអ្វី?<br>៣.ចំងាយពីកំណុំទៅកំពូលប៉ារ៉ាប៉ូលហៅថាអ្វី? |  | សិស្សឆ្លើយ<br>១.ហៅថាអ័ក្សឆ្លុះនៃប៉ារ៉ាប៉ូល។<br>២.ហៅថាកំពូលនៃប៉ារ៉ាប៉ូល<br>៣.ហៅថាប៉ារ៉ាម៉ែត $P$ |
| គ្រូសួរតើប៉ារ៉ាបូលជាកោនិចដែរឬទេ?<br>តើគេអាចគូរប៉ារ៉ាប៉ូលមួយដោយមិនស្គាល់កំពូលកំណុំនិងបន្ទាត់<br>ប្រាប់ទិសបានដែរឬទេ? | *<u>ជំហានទី៤</u>* (ពង្រឹងចំណេះដឹង)<br>គេមិនអាចគូរបាននូវប៉ារ៉ាប៉ូលមួយដោយមិនស្គាល់កំពូលឬកំណុំនិងបន្ទាត់ប្រាប់ទិសបានទេ | .ប៉ារ៉ាបូលជាប្រភេទកោនិក<br>.គេមិនអាចគូរបានទេ |
| គ្រូប្រាប់សិស្សឲ្យអានមេរៀននិង<br>ត្រៀមសំភារៈសំរាប់ប្រើនូវមេរៀនក្រោយ។<br>ឲ្យសិស្សសង់ប៉ារ៉ាបូលម្នាក់មួយ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ) | សិស្សអនុវត្តន៍ |

| | | |
|---|---|---|
| | c<br>d<br>D | c<br>d<br>D |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៦.

*មេរៀនទី...១....* *ប៉ារ៉ាបូល(ត)*

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង:សិស្សប្រាប់ពីសមីការស្តង់ដាជាប៉ារ៉ាបូលដែលមានកំពូលជាគល់អ័ក្សកូអរដោនេតាមឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយ:ឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

II.ពេលវេលា: ...២....ម៉ោង ថ្ងៃ.................ទី.................ខែ..............ឆ្នាំ..........

III.សម្ភារ:ឧទេស

-ស . ស :ទំព័រទី.១៧៩.. ដល់ទំព័រទី..៨..

-ស . គ : ទំព័រទី១៧៩... ដល់ទំព័រទី....

-បន្ទាត់

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | *ជំហានទី១* (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ ឲ្យសិស្សឲ្យនិយមន័យ បន្ទាត់ប្រាប់ទិស | *ជំហានទី២* (រំលឹកមេរៀនចាស់)<br>និយមន័យ: ប៉ារ៉ាបូលជាសំណុំចំនុចនៅក្នុងប្លង់ដែលមានចំងាយស្មើពីចំនុចនឹង $F$ មួយនិងបន្ទាត់និង $\Delta$ មួយនៅក្នុងប្លង់នោះ។ចំនុចនឹង $F$ ហៅថាកំណុំនិងបន្ទាត់ $\Delta$ ហៅថាបន្ទាត់ប្រាប់ទិស។ | សិស្សឆ្លើយ |
| .គ្រូសរសេរចំនងជើ | *ជំហានទី៣* (មេរៀនថ្មី)<br>*មេរៀនទី.១. សមីការនៃប៉ារ៉ាបូល* | .សិស្សសង្កេត |

| | | |
|---|---|---|
| ង<br><br><br><br>.គ្រូគូររូបរួចពន្យល់ | ៣.១សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលជាគល់ជាអ័ក្សកូរដោនេ<br><br>ក.ករណីបន្ទាត់ប្រាប់ទិស $\Delta$ ស្របនិងអ័ក្សអរដោនេ<br><br>.គេអាចប្រើនិយមន័យដើម្បីរកសមីការប៉ារ៉ាបូល។សមីការនោះអាស្រ័យលើកំណុំ<br>និងបន្ទាត់ប្រាប់ទិស។ឧបមាថាប៉ារ៉ាបូលមានកំពូល $V$ ជាគល់អ័ក្សកូរអរដោនេនិងកំណុំ $F$ មានចំងាយ $p$ ឯកតានោះ $F(p;0)$ និងបន្ទាត់ប្រាប់ទិស $\Delta$ មានសមីការ $x=-p$ ។<br>តាង $p(x;y)$ ជាចំនុចមួយស្ថិតនៅលើប៉ារ៉ាបូល។<br>បើ $D$ ជាចំនុចមួយមានមានកូអរដោនេ $(-p;y)$ គេបាន<br>$PF=PD$<br>$\sqrt{(x-p)^2+y^2}=\sqrt{(x+p)^2}$<br>(ប្រើរូបមន្តចំងាយរវាងពីចំនុច)<br>$(x-p)^2+y^2=(x+p)^2$ (លើកអង្គទាំងពីរជាំគោល)<br>$x^2-2xp+p^2+y^2=x^2=2xp+p^2$ | <br><br><br><br>សិស្សសង្កេត |

$y^2 = 4px$ នោះជាសមីការស្តង់ដានៃប៉ារ៉ាបូល
ដែលមានកំពូល $V(0;0)$ និងកំណុំ $F(p;0)$ ស្ថិតនៅអ័ក្សអាប់ស៊ីស។

ខ.<u>ករណីបន្ទាត់ប្រាប់ទិស $\Delta$ ស្របនឹងអ័ក្សអាប់ស៊ីស:</u>




ដូចគ្នានេះដែរសមិការស្តង់ដានៃប៉ារ៉ាបូល
ដែលមានកំពូល $V(0;0)$ និងកំណុំ $F(0;p)$ ស្ថិតនៅអ័ក្សអរដោនេគឺ $x^2 = 4py$
នៅក្នុងសមីការទាំងនេះ $p$ អាចជាចំនួនវិជ្ជាមានឬអវិជ្ជាមាន។

ជាទូទៅ:

សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលជាគល់អ័ក្សកូអរដោនេ

១.បើអ័ក្សឆ្លុះជាអ័ក្សអរដោនេនោះប៉ារ៉ាបូល
មានសមីការ $x^2 = 4py$ ហើយមានកំណុំ $F(0;p)$
និងបន្ទាត់ប្រាប់ទិសមានសមីការ $y = -p$ ។

.បើ $p > 0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $y > 0$

.បើ $p < 0$ នោះប៉ារ៉ាបូលបែរភាពផត

| | | |
|---|---|---|
| គ្រូដាក់ឧទាហរណ៍គំរូរកសមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំណុំត្រង់ចំនុច $(-2;0)$ និងបន្ទាត់ប្រាបទិសមាន $x=2$ សមីការ | ទៅរកទិស $y<0$<br>២.បើអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីសនោះសមីការមានស្តង់ដា $y^2=4xp$ ហើយមាន $F(p;0)$ និងបន្ទាត់ប្រាប់ទិស $x=-p$<br>.បើ $p>0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $x>0$<br>.បើ $p<0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $x<0$<br><br><br>កំណុំស្ថិតនៅលើអ័ក្សអាប់ស៊ីសនោះអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីស។ដោយកំពូលស្ថិតលើអ័ក្សឆ្លុះជាចំនុចកណ្តាលរវាងកំណុំនិងបន្ទាត់ប្រាប់ទិសនោះកំពូលជាគល់អ័ក្សកូអរដោនេ។ ប៉ារ៉ាបូលមានសមីការ $y^2=4xp$ ដែល $p=-2$ ដូចនេះសមីការស្តង់ដាគឺ $y^2=-8x$ | សិស្សមើលនិងសង្កេត |
| .ប៉ារ៉ាបូលមួយមានកំពូលនៅត្រង់ចំនុច $(0;0)$ និងកំណុំស្ថិតនៅលើអ័ក្សអរដោនេ<br>ក/រកសមីការស្តង់ដានៃប៉ារ៉ាបូលហើយកាត់ | *ជំហានទី៤* (ពង្រឹងចំណេះដឹង)<br> | សិស្សអនុវត្ត |

| | | |
|---|---|---|
| តាមចំនុច $A(4;12)$<br>ខ/រកតម្លៃ $y_1$ បើ $B(3;y_1)$ ស្ថិតនៅលើប៉ារ៉ាបូល | ក/ដោយប៉ារ៉ាបូលនោះមានកំពូលត្រង់ $(0;0)$ និងកមណ្ដុំស្ថិតនៅលើអ័ក្សអរដោនេនោះអ័ក្សអរដោនេជាអ័ក្សឆ្លុះនៃប៉ារ៉ាបូល។គេបានសមីការប៉ារ៉ាបូលគឺ $x^2=4yp$ ដោយ $A(4;12)$ ស្ថិតនៅលើប៉ារ៉ាបូលនោះកូអរដោនេរបស់វាផ្ទៀង<br>$x^2=4yp$<br>ផ្ទាត់សមីការ $\Leftrightarrow 4^2=4p(12)$<br>$\Leftrightarrow 16=48p \Rightarrow p=\frac{1}{3}$<br>ដូចនេះសមីការស្តង់ដានៃប៉ារ៉ាបូលគឺ<br>$x^2=\frac{4}{3}y$<br>ខ.រកតម្លៃ $y_1$<br>ជំនួស $x=3$ និង $y=y_1$ ក្នុងសមីការ $y=\frac{7}{4}x^2$<br>គេបាន $y_1=\frac{3}{4}(3)^2=\frac{27}{4}$ ដូចនេះបើស្ថិតនៅលើប៉ារ៉ាបូលនោះ $y_1=\frac{27}{4}$ | |
| .គ្រូឲ្យសិស្សធ្វើលំហាត់ប្រត្តិបត្តិ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>រកកូអរដោនេកំពូលកំណុំនឹងសមីការបន្ទាត់ប្រាប់ទិសនៃប៉ារ៉ាបូល $y^2=-6x$ រួចសង់ប៉ារ៉ាបូលនោះ។ | សិស្សអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៦....

មេរៀនទី...១.... ប៉ារ៉ាបូល

៣.២សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលខុសពីគល់អ័ក្ស

ក.ករណីបន្ទាត់ប្រាប់ទិស$(\Delta)$ ស្របនិងអ័ក្សអរដោនេ

ខ. ករណីបន្ទាត់ប្រាប់ទិស$(\Delta)$ ស្របនិងអ័ក្សអាប់ស៊ីស

**I.**វត្ថុបំណងនៃមេរៀន

-ចំណេះដឹង :សិស្សបង្ហាញនិយមន័យនៃប៉ារ៉ាបូលតាមរយ:ឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយ:ឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

**II.**ពេលវេលា: ...២....ម៉ោង ថ្ងៃ...............ទី...............ខែ............ឆ្នាំ..........

**III.**សម្ភារ:ឧទេស

-ស . ស :ទំព័រទី.២.. ដល់ទំព័រទី..៤..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-បន្ទាត់ ខ្សែម៉ែត្រ

**IV.**ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | *ជំហានទី១* (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>តើសមីការស្តង់ដាប៉ារ៉ាបូលដែលមានកំពូលជាគល់អ័ក្សកូអរដោនេនិងអ័ក្សឆ្លុះជាអ័ក្សអរដោនេមានរាង | *ជំហានទី២* (រំលឹកមេរៀនចាស់)<br>.សមីការប៉ារ៉ាបូលមានរាង:<br>+បើអ័ក្សឆ្លុះជាអ័ក្សអរដោនេនោះប៉ារ៉ាបូលមានសមីការស្តង់ដា $x^2 = 4yp$<br>មានកំណុំ $F(0;p)$ និងបន្ទាត់ប្រាប់ទិសមានសមីការ $y = -p$ ។ | សិស្សឆ្លើយ<br>+បើអ័ក្សឆ្លុះជាអ័ក្សអរដោនេនោះ<br>ប៉ារ៉ាបូលមានសមីការស្តង់ដា<br>$x^2 = 4yp$<br>មានកំណុំ $F(0;p)$ និងបន្ទាត់ |

| | | |
|---|---|---|
| ដូចម្តេច?<br>បើ $p>0; p<0$ សមីការប៉ារ៉ាបូលមានភាពផតដូចម្តេច?<br><br>តើសមីការស្តង់ដាប៉ារ៉ាបូលដែលមានកំពូលជាគល់អ័ក្សកូអរដោនេនិងអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីសមានរាងដូចម្តេច?<br>បើ $p>0; p<0$ សមីការប៉ារ៉ាបូលមានភាពផតដូចម្តេច? | .បើ $p>0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $y>0$<br>.បើ $p<0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $y<0$<br>+បើអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីសនោះសមីការមានស្តង់ដា $y^2=4xp$ ហើយមាន $F(p;0)$ និងបន្ទាត់ប្រាប់ទិស $x=-p$<br>.បើ $p>0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $x>0$ $V$<br>.បើ $p<0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $x<0$ | ប្រាប់ទិសមានសមីការ $y=-p$ ។<br>.បើ $p>0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $y>0$<br>.បើ $p<0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $y<0$<br>.បើអ័ក្សឆ្លុះជាអ័ក្សអាប់ស៊ីសនោះសមីការមានស្តង់ដា $k$<br>$y^2=4xp$ $k$<br>ហើយមាន $F(p;0)$ និងបន្ទាត់ប្រាប់ទិស $x=-p$<br>.បើ $p>0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $x>0$<br>.បើ $p<0$ នោះប៉ារ៉ាបូលបែរភាពផតទៅរកទិស $x<0$ |
| គ្រូសរសេរមេរៀនថ្មីនិងបកស្រាយរូបមន្ត | *<u>ជំហានទី៣</u>* (មេរៀនថ្មី)<br>*មេរៀនទី.១. ប៉ារ៉ាបូល*<br>*៣.២<u>សមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលខុសពីគល់អ័ក្សកូអរដោនេ</u>*<br>*ក/<u>ករណីបន្ទាត់ប្រាប់ទិស</u>* $(\Delta)$ *<u>ស្របនិងអ័ក្សអរដោនេ</u>*<br>គេប្រើនិយមន័យប៉ារ៉ាបូលដើម្បីរកសមីការស្តង់ដាមានកំពូល $V(h;k)$ និង $p$ ជាចំងាយពីកំពូលទៅកំណុំនិងបន្ទាត់ប្រាប់ទិស។ | សិស្សស្តាប់និងកត់ត្រា |




តាងចំនុច $p$ ជាចំងាយពីកំពូលទៅកំណុំនិងទៅបន្ទាត់ប្រាប់ទិស។ បើអ័ក្សឆ្លុះជាអ័ក្សដេកនោះកូអរដោនេនៃកំណុំគឺ $F(h+p;k)$ និងសមីការបន្ទាត់ប្រាប់ទិសគឺ $x=h-p$ ។

តាង $(\Delta)$ ជាចំនុចមួយនៅលើប៉ារ៉ាបូល បើ $(\Delta)$ ជាចំនុចមួយមានកូអរដោនេ $(\Delta)$ គេបាន

$PF=PD$

$PF=\sqrt{(x-h-p)^2+(y-k)^2}$

$PD=\sqrt{(x-h+p)^2+(y-y)^2}$

$\sqrt{(x-h-p)^2+(y-k)^2}=\sqrt{(x-h+p)^2}$

លើកអង្គទាំងពីរជាការេយើងបាន

$$(x-h-p)^2+(y-k)^2=(x-h+p)^2$$

$$(x-h)^2-2p(x-h)+p^2+(y-k)^2=$$

$$(x-h)^2+2p(x-h)+p^2$$

$$(y-k)^2=4p(x-h)$$

យើងបានសមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូល $(h;k)$ និងអ័ក្សឆ្លុះជាអ័ក្សដេកមានរាង $(y-k)^2=4p(x-h)$

+ករណីប៉ារ៉ាបូលបែរភាពផតទៅរកទិស $x>0\,;x<0$

| | | |
|---|---|---|
| | <br><br>បន្ទាត់ប្រាប់ទិស(Δ): $x = h - p$ អ័ក្សឆ្លុះជាអ័ក្សដេក $p > 0$<br>+ ករណីប៉ារ៉ាបូលបែរភាពផតទៅរកទិស $x < 0$<br><br><br>បន្ទាត់ប្រាប់ទិស(Δ): $x = h - p$ អ័ក្សឆ្លុះជាអ័ក្សដេក $p < 0$<br>ខ.<u>ករណីបន្ទាត់ប្រាប់ទិសស្របនិងអ័ក្សអាប់ស៊ីស</u><br>គេប្រើនិយមន័យនៃប៉ារ៉ាបូលដើម្បីរកសមីការនៃប៉ារ៉ាបូលដែលមានកំពូល $V(h;k)$ | |




បន្ទាត់ប្រាប់ទិស $\Delta : y = k - p$

អ័ក្សឆ្លុះជាអ័ក្សឈរ: $p > 0$

តាង $D$ ជាចំងាយពីកំពូលទៅកំណុំនិង ទៅបន្ទាត់ប្រាប់ទិស។

បើអ័ក្សឆ្លុះជាអ័ក្សឈរកូអរដោនេនៃ កំណុំគឺ $F(h;k+p)$ និងសមីការបន្ទាត់ ប្រាប់ទិសគឺ $y = k - p$ ។

តាង $p(x;y)$ ជាចំនុចមួយនៅលើប៉ារ៉ាបូល។

បើ $D$ ជាចំនុចមួយមានកូអរដោនេ $(x;k-p)$ គេបាន

$PF = PD$

$\sqrt{(x-h)^2+(y-k-p)^2} = \sqrt{(y-k+p)^2}$

លើកអង្គទាំងពីរជាការេយើងបាន

$(x-h)^2+(y-k-p)^2=(y-k+p)^2$

$(x-h)^2-2p(y-k)+p^2+(y-k)^2=$

$(y-k)^2+2p(y-k)+p^2$

$(x-h)^2=4p(y-k)$

យើងបានសមីការស្តង់ដានៃប៉ារ៉ាបូល ដែលមានអ័ក្សឆ្លុះជាអ័ក្សឈរ

+ករណី $p < 0$ ប៉ារ៉ាបូលបេរភាពផតទៅរក $y < 0$

| | | |
|---|---|---|
| លំហាត់អនុវត្តន៍<br>ក/ចូររកសមីការស្តង់ដានៃប៉ារ៉ាបូលដែលមានកំពូលត្រង់ចំនុច $(2;1)$ និងកំណុំ $(2;4)$ រួចសង់ប៉ារ៉ាបូល<br>ខ/រកកូអរដោនេនៃកំពុលកំណុំនិងសមីការបន្ទាត់ប្រាប់ទិសនៃប៉ារ៉ាបូល $(y-2)^2=4(x+1)$ រួចសង់។ | <br>បន្ទាត់ប្រាប់ទិស $\Delta: y=k-p$<br>អ័ក្សឆ្លុះជាអ័ក្សឈរៈ $p<0$ | សិស្សឆ្លើយ<br>សមីការស្តង់ដាគឺ<br>$(x-2)^2=12(y-1)$<br>សំណង់ប៉ារ៉ាបូល<br>ខ/រកកូអរដោនេកំពូល កំណុំនិងសមីការបន្ទាត់ប្រាប់ទិសមាន<br>$(h;k)=(-1;2)$<br>$(h+p;k)=(0;2)$<br>$x=h-p=x-2$ |
| ចូរប្អូនធ្វើលំហាត់ប្រត្តិបត្តិ ទី១ ទី២ទំព័រទី១៨៤ | <u>ជំហានទី៤</u> (ពង្រឹងចំណេះដឹង) | សិស្សពិភាក្សាជាក្រុម |
| សិស្សធ្វើលំហាត់ទំព័រ១៨៩ ទី៤ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ) | សិស្សឲ្យម៉ោងក្រោយ |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៦.... មេរៀនទី...១.... **ប៉ារ៉ាបូល**

(៣.៣ សមីការទូទៅនៃប៉ារ៉ាបូល)

**I.**វត្ថុបំណងនៃមេរៀន

-ចំណេះដឹង :សិស្សសរសេរសមីការទូទៅនៃប៉ារ៉ាបូល បម្លែងរាងទូទៅនៃប៉ារ៉ាបូលជាទម្រង់ស្តង់ដានិងពីសមីការស្តង់ដាទៅរាងទូទៅតាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

**II.**ពេលវេលា: ...១....ម៉ោង ថ្ងៃ..................ទី..................ខែ...............ឆ្នាំ............

**III.**សម្ភារៈឧទេស

-ស . ស :ទំព័រទី.១៨៤.. ដល់ទំព័រទី..១៨៥..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-បន្ទាត់

**IV.**ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | *ជំហានទី១* (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>+រូបមន្តឯកលក្ខណភាព $(a+b)^2;(a-b)^2$<br>+ឲ្យសរសេរកន្សោម $A=x^2+6x+9$ ជារាងឯកលក្ខណភាព<br>+ធ្វើដូចម្តេចដើម្បីរកតួ $b$ ?<br>+តើសមីការ $(x-h)^2=4p(y-k)$ និង | *ជំហានទី២* (រំលឹកមេរៀនចាស់) | សិស្សឆ្លើយ<br>+ $(a+b)^2=a^2+2ab+b^2$<br>$(a-b)^2=a^2-2ab+b^2$<br>+ $A=(x+3)^2$<br>+យើងយកមេគុណដែលជាប់ $x$ ចែកនិង $2$ ។<br>+សមីការ $(x-h)^2=4p(y-k)$ សម្គាល់ប៉ារ៉ាបូលមានអ័ក្សឆ្លុះជាអ័ក្សឈរ។<br>សមីការ $(y-k)^2=4p(x-h)$ |

| | | |
|---|---|---|
| $(y-k)^2=4p(x-h)$<br>សម្គាល់អ្វីខ្លះនៃប៉ារ៉ាបូល | | សម្គាល់ប៉ារ៉ាបូលមានអ័ក្សឆ្លុះជាអ័ក្សដេក។ |
| គ្រូសរសេរឧទាហរណ៍ជាលំហាត់គំរូដល់សិស្ស<br>$Ex_1$ បម្លែងសមីការប៉ារ៉ាបូល $y^2+8y-8x=0$ ជាទម្រង់ស្តង់ដា។<br>.លើកអង្គមានអញ្ញាត $y$ និង $x$ ទៅម្ខាងម្នាកនៃសញ្ញាស្មើ<br>.សង្កេតឃើញតួ $y$ ស្មើប៉ុន្មាន<br>.ថែមអង្គទាំងពីរនិងតម្លៃ $b^2$<br>.គេបានទម្រង់មួយ<br>$Ex_2$ រកកំពូល កំណុំ និង សមីការបន្ទាត់ប្រាប់ទិស រួចសង់ប៉ារ៉ាបូលនោះ?<br>+ត្រូវធ្វើដូចម្តេចដើម្បីរកកំពូល កំណុំ និង សមីការបន្ទាត់ប្រាប់ទិស?<br>ឲ្យសិស្សសង្កេត<br><br>+តើកំពូល កំណុំនិងសមីការបន្ទាត់ប្រាប់ទិសមានរាងដូចម្តេច?<br>+គេបានកំពូល កំណុំនិងបន្ទាត់ប្រាប់ទិសគឺ | *ដំហានទី៣* (មេរៀនថ្មី)<br>*មេរៀនទី.១. ប៉ារ៉ាបូល(ត)*<br>*៣.៣ សមីការទូទៅនៃប៉ារ៉ាបូល*<br>$Ex_1$ បម្លែងសមីការប៉ារ៉ាបូល $y^2+8y-8x=0$ ជាទម្រង់ស្តង់ដា<br>$y^2+8y=8x$<br>គេបានតួ $b=\frac{8}{2}=4$<br>$y^2+8y+16=8x+16$<br>$(y+4)^2=8(x+2)$<br>$(y+4)^2=8(x+2)$<br>$(y-(-4))^2=8(x-(-2))$<br>$(y-k)^2=4p(x-h)$<br><br>គេបាន $h=-2;k=-4;p=2>0$<br>.កំពូល $V(h;k)=V(-2;-4)$<br>.កំណុំ $F(h+p;k)=(0;-4)$<br>.បន្ទាត់ប្រាប់ទិស $(x=h-p)=(x=-4)$<br>តារាងតំលៃ $x$: $0$ ; $y$: $y=0$, $y=-8$<br> | សិស្សកត់ត្រា<br><br>+ត្រូវរក $h;k;p$ រួចសរសេរនិងឲ្យតម្លៃលេខដែលត្រូវការ។<br>យើងត្រូវផ្ទឹមវានិងសមីការស្តង់ដាប៉ារ៉ាបូលដែលត្រូវគ្នា។<br><br>+មានរាងដូចជា៖<br>.កំពូល $(h;k)$<br>.កំណុំ $(h+p;k)$<br>.បន្ទាត់ប្រាប់ទិស $(x=h-p)$ |

<table>
<tr>
<td>+តើគេសង់ប៉ារ៉ាបូលយ៉ាងដូចម្តេច?</td>
<td></td>
<td>គូសតំរុយកែងអរតូណារមេក្នុងប្លង់</td>
</tr>
<tr>
<td>+ប្រតិបត្តិ:<br>រកកូរដោនេកំពូល កំណុំនិងសមីការបន្ទាត់ប្រាប់ទិសនៃប៉ារ៉ាបូល<br>$y=-\frac{1}{2}x^2-x+\frac{1}{2}$</td>
<td><u>ជំហានទី៤</u> (ពង្រឹងចំណេះដឹង)</td>
<td>សិស្សឆ្លើយ<br>$y=-\frac{1}{2}x^2-x+\frac{1}{2}$<br>$-2y=-x^2+2x$<br>$-2y+1=x^2+2x$<br>$-2y+2=x^2+2x+1$<br>$-2(y-1)=(x+1)^2$<br>ផ្ទឹមនិងសមីការ $(x-h)^2=4p(y-k)$<br>គេបាន $h=-1; k=1; p=-\frac{1}{2}$<br>.កំពូល $V(h;k)=(-1;1)$<br>.កំណុំ $F(h;k+p)=\left(-1;\frac{1}{2}\right)$<br>.បន្ទាត់ប្រាប់ទិស $y=k-p=\frac{3}{2}$<br>.សង់<br>$\begin{array}{c|cc} x & -1 & 0 \\ \hline y & -1 & \frac{1}{2} \end{array}$<br></td>
</tr>
<tr>
<td>គ្រូឲ្យសិស្សធ្វើលំហាត់ទិ២និងទី៣</td>
<td><u>ជំហានទី៥</u> (កិច្ចការផ្ទះ)</td>
<td>សិស្សឲ្យកិច្ចការម៉ោងក្រោយ</td>
</tr>
</table>

# កិច្ចតែងការបង្រៀន

**ជំពូក ទី**…៦…

មេរៀនទី…១…. **ប៉ារ៉ាបូល**

(៤.លក្ខណៈអុបទិចនៃប៉ារ៉ាបូល)

**I.**<u>វត្ថុបំណងនៃមេរៀន</u>

-ចំណេះដឹង :សិស្សស្គាល់មុំចំណាំងប៉ះនិងនៃប៉ារ៉ាបូលតាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

**II.**<u>ពេលវេលា:</u> …២….ម៉ោង ថ្ងៃ……………..ទី……………..ខែ…………..ឆ្នាំ……….

**III.**<u>សម្ភារៈឧទេស</u>

-ស . ស :ទំព័រទី.១៨៦.. ដល់ទំព័រទី..១៨៧..

-ស . គ : ទំព័រទី… ដល់ទំព័រទី….

-បន្ទាត់

**IV.**<u>ដំណើកនាំមេរៀន</u>

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | *<u>ជំហានទី១</u>* (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>*ដូចម្តេចដែលហៅថាត្រីកោណសមបាត?<br>*ដូចម្តេចដែលហៅថាមុំត្រូវគ្នា?<br>*បើគេស្គាល់ $k$ ជាមេគុណប្រាប់ទិសរបស់បន្ទាត់និងចំនុច $M(a;b)$ តើសមីការបន្ទាត់មានរាងដូចម្តេច? | *<u>ជំហានទី២</u>* (រំលឹកមេរៀនចាស់) | សិស្សឆ្លើយ<br>*ត្រីកោណមានប្រវែងជ្រុងពីរស្មើគ្នាជាត្រីកោណសមបាទ។<br>*មុំត្រូវគ្នាជាមុំដែលមានជ្រុងមួយស្របគ្នាហើយជ្រុងមួយទៀតជាបន្ទាត់ឬមកាត់កំពូលនោះ។<br><br><br>$\alpha=\beta$ មុំត្រូវគ្នា |

| | | |
|---|---|---|
| *បើអនុគមន៍ $f$ មានដេរីវេ ត្រង់ $(x_0)$ ដែល $f'(x_0)$ កំនត់។តើអាចនិយាយថា ដូចម្តេចចំពោះ $f'(x_0)$ ?<br>*រូបមន្តរវាងចំងាយពីរចំនុច បើ $A(x_A;y_A)$ និង $B(x_B;y_B)$ រក $\|AB\|$ ? | | * $y = k(x-a)+b$<br><br>* $f'(x_0)$ ជាមេគុណប្រាប់ទិសនៃ $f(x)$ ត្រង់ $x_0$ ។<br><br>* $\|AB\| = \sqrt{(x_B-x_A)^2+(y_B-y_A)^2}$ |
| គ្រូសរសេរមេរៀនថ្មី<br>*មេរៀនទី.១.* **ប៉ារ៉ាបូល** | <u>*ជំហានទី៣*</u> (មេរៀនថ្មី)<br>*មេរៀនទី.១.* **ប៉ារ៉ាបូល**<br>៤.លក្ខណអុបទិចនៃប៉ារ៉ាបូល<br>*ប៉ារ៉ាបូលមានសមីការ $x^2=4py$ មានកំណុំ $F(0;p)$ ។<br>*គូសបន្ទាត់ $(l)$ ប៉ះប៉ារ៉ាបូលត្រង់ $p(x_0;y_0)$<br>*តាង $\alpha$ មុំផ្គុំរវាង $(l)$ និងអង្កត់ $FP$<br>$\beta$ មុំផ្គុំរវាង $(l)$ និងបន្ទារត់ឈរកាត់តាម $p$ ស្របនិងអ័ក្សឆ្លុះ។<br><br><br>*បន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ $p(x_0;y_0)$ មានមេគុណប្រាប់ទិស $y'=\frac{2x_0}{4p}=\frac{x_0}{2p}$ ហើយសមីការបន្ទាត់ប៉ះគឺ $y-y_0=\frac{x_0}{2p}(x-x_0)$ | សិស្សសង្កេតនិងកត់ត្រា |

| | | |
|---|---|---|
| | *បើបន្ទាត់ប៉ះនេះកាត់អ័ក្សអរដោនេត្រង់ $Q(0;q)$ គេបាន៖<br>$q = y_0 - \frac{x_0}{p} = \frac{x_o^2}{4p} - \frac{x_o^2}{2p} = -\frac{x_o^2}{4p}$<br>*ប្រវែងអង្កត់ $FQ$ គឺ $p - q = p + \frac{x_o^2}{4p}$<br><br>*តាមរូបមន្តរវាងចំងាយពីរចំនុច $FP$<br>$\sqrt{x_o^2 + (y_o - p)^2} = \sqrt{x_o^2 + \left(\frac{x_o^2}{4p} - p\right)^2}$<br>$\sqrt{\left(\frac{x_o^2}{4p}\right)^2 + 2\frac{x_o^2}{4p}p + p^2} = \frac{x_o^2}{4p} + p$<br><br>* $\triangle FQP$ ជាត្រីកោណសមបាត $\Rightarrow \alpha = \beta$<br>សន្និដ្ឋាន: បន្ទាត់ស្របនិងអ័ក្សឆ្លុះនៃប៉ារ៉ាបូលដែលកាត់ប៉ារ៉ាបូលត្រង់ $p$ និងបន្ទាត់ $PF$ ផ្គុំជាមួយបន្ទាត់ប៉ះប៉ារ៉ាបូលត្រង់ចំនុច $p$ បានមុំស្មើគ្នា។ | |
| ឲ្យសិស្សធ្វើលំហាត់ទី២និង៣ | <u>*ជំហានទី៤*</u> (ពង្រឹងចំណេះដឹង) | សិស្សអនុវត្តន៍ជាក្រុម |
| | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>ធ្វើលំហាត់នៅសល់ | |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៦....

មេរៀនទី...២.... **អេលីប**

(១.សេចក្ដីផ្ដើម ២.និយមន័យនៃអេលីប)

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង :សិស្សបង្ហាញសញ្ញាណនៃអេលីបនិងកំនត់និយមន័យនៃអេលីបតាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

II.ពេលវេលា: ...២....ម៉ោង ថ្ងៃ..................ទី..................ខែ................ឆ្នាំ...........

III.សម្ភារ:ឧទេស

-ស . ស :ទំព័រទី.២.. ដល់ទំព័រទី..៤..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-បន្ទាត់ កូនបាល់ ខ្សែម៉ែត្រ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្ដាប់ធ្នាប់ និង វិន័យ | *ជំហានទី១* (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្ដាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| .គ្រូឲ្យសិស្សឡើងសង់រូបកោណផ្កាប់និងផ្ងា។ គ្រូឲ្យសិស្សសរសេររូបមន្តគណនាមាឌកោណនិងផ្ទៃបាតនៃកោណ។ | *ជំហានទី២* (រំលឹកមេរៀនចាស់)<br><br><br>ផ្ចិត $I$ កាំ $R$<br><br><br>ផ្ចិត $I'$ កាំ $R'$ | សិស្សសង់រូប<br>គូសរូប<br>$V=\frac{1}{3}S_b.h$<br>. $S_b=\pi R^2$<br>$S_b \rightarrow$ ផ្ទៃបាត $\pi=3,14$<br>$h \rightarrow$ កំពស់ $R\rightarrow$ កាំបាត |

| | | |
|---|---|---|
| គ្រូលើករូបដែលសិស្សបានសង់ជាថ្មីដោយដាក់ឲ្យកំពូលនៃកោនទាំងពីរត្រួតស៊ីគ្នានិងឲ្យកំពស់នៃកោណមួយជាបន្លាយនៃកំពស់របស់កោណមួយទៀត<br>គ្រូពន្យល់ប្រាប់សិស្សថារូបនេះជារូបកោណបរិវត្តន៍ដែល $II'$ ជាអ័ក្សកោណគ្រូឲ្យសិស្សពិនិត្យនូវពេលដែលគេយកប្លង់មួយទៅកាត់កោននោះមុខកាត់ដែលទទួលបានត្រូវបានគេកំណត់ថាជាអេលីប។<br><br>.គ្រូឲ្យឧទាហរណ៍ហើយពន្យល់ | *ជំហានទី៣* (មេរៀនថ្មី)<br>*មេរៀនទី*.១. **អេលីប**<br>១.សេចក្តីផ្តើម<br>គូររូប<br><br>ប្លង់មួយកាត់កោនបរិវត្តន៍ដែលមានបាទជារង្វង់ហើយមិនកែងនិងអ័ក្សកោននោះផ្នែកប្រសព្វដែលបានជារូបធរណីមាត្រមួយហៅថាអេលីប<br><br>២.និយមន័យ:<br>$Ex$ គេអាចសង់ងេលីបនៅលើក្រដាសដូចរូបខាងក្រោមៈ<br>ដំបូងគេដោតម្ជុលពីរនៅលើក្រដាសនៅត្រង់ចំណុចពីរផ្សេងគ្នា $F_1$ និង $F_2$ ហើយភ្ជាប់ចង់ខ្សែទាំងសងខាងទៅនឹងម្ជុលទាំងពីរនោះ។<br>បន្ទាប់មកទាញចុងខ្មៅដៃឲ្យខ្សែនោះតឹងដោយខ្មៅដៃនៅត្រង់ចំណុច $P$ គេរំកិលចុងខ្មៅដៃលើក្រដាសរក្សាឲ្យតឹងជានិច្ច។<br> | សិស្សស្តាប់គ្រូពនយល់<br><br>.សិស្សស្តាប់គ្រូពន្យល់ |

| | | |
|---|---|---|
| | <u>និយមន័យ:</u>អេលីបជាសំណុំចំនុច<br>នៅក្នុងប្លង់ដែលមានផលបូកចម្ងាយ<br>ពីចំនុចនោះទៅចំនុចនិងជាចំនួនថេរ។<br><br>.ចំនុចនឹងពីរ $F_1$ និង $F_2$ ហៅថាកំនុំ។<br>តាង $V_1$ និង $V_2$ ជាចមនុចប្រសព្វរវាង<br>បន្ទាត់ $F_1F_2$ និងអេលីប។<br>តាង $B_1$ និង $B_2$ ជាចំនុចប្រសព្វរវាង<br>មេដ្យាទ័រនៃអង្កត់ $F_1F_2$ និងអេលីប។<br>. $V_1$ និង $V_2$ ហៅថាកំពូលនៃអេលីប<br>.អង្កត់ $V_1V_2$ ហៅថាអ័ក្សធំនៃអេលីប<br>ហើយគេតាង $V_1V_2=2a;(a>0)$ អ័ក្សធំ<br>កាត់តាមកំនុំនៃអេលីប<br>.អង្កត់ $B_1B_2$ ហៅថាអ័ក្សតូចនៃអេលីប<br>ហើយគេតាង $B_1B_2=2b$ ដែល $a>b>0$<br>. $V_1V_2$ ប្រសព្វគ្នាត្រង់ចំនុច $O$ ហៅថា<br>ផ្ចិតអេលីប។<br>. $OV_1=OV_2=a$ និង $OV_2$ ហៅថាកន្លះ<br>អ័ក្សធំដែល $OV_1=OV_2=a$ ។<br>.$OB_1$ និង $OB_2$ ហៅថាកន្លះអ័ក្សតូច<br>ដែល $OB_1=OB_2=b$ ។<br>.តាង $F_1F_2=c$<br>.អ័ក្សធំនិងអ័ក្សតូចជាអ័ក្សឆ្លុះនៃ | សិស្សស្តាប់គ្រូពន្យល់ |

| | | |
|---|---|---|
| គ្រូធ្វើបំណាកស្រាយតាមនិយមន័យនូវផលបូកប្រវែងពី $F_1$ ទៅ $P$ និងពី $F_2$ ទៅ $P$ ។<br><br>គ្រូពន្យល់សង្កត់ធ្ងន់ទៅលើផលបូកចំងាយនោះគឺស្មើចំនួនថេរ $2a$ សំដៅទៅលើចំងាយពីកំពូល $V_1$ និង $V_2$ ។<br><br>គ្រូឲ្យសិស្សឡើងសង់រូបអេលីបផ្ចិត $O$ កំនុំ $F_1$ និង $F_2$ និងកំពូល $V_1V_2$ ។<br>គ្រូពន្យល់ថា $P$ ជាចំនុចនៅលើអេលីប | អេលីប។<br><br>ឧបមា $P$ នៅត្រង់ $V_1$ គេបាន<br>$PF_1+PF_2$<br>$=V_1F_1+V_1F_2$<br>$=V_2F+V_1F_2$<br>$=V_1V_2=2a$<br>បើ $P$ នៅត្រង់ $B_1$ គេបាន<br>$PF_1+PF_2=B_1F_1+B_1F_2=2B_1F_2$<br>តាមនិយមន័យគេបាន<br>$2B_1F_2=2a \Rightarrow B_1F_2=a$<br>$\Delta\perp OB_1F_2$ តាមទ្រឹស្តីពីតាក័រគេបាន<br>$B_1F_2^{\,2}=OB_1^2+OF_2^{\,2}$ ឬ $a^2=b^2+c^2$<br><br>(រូបដូចខាងលើ) | សិស្សឡើងសង់រូប |
| គ្រូឲ្យសិស្សឡើងធ្វើលំហាត់ | *ជំហានទី៤* (ពង្រឹងចំណេះដឹង)<br>ពង្រឹងចំពោះដឹង<br>លំហាត់<br>ក/គណនាផលបូកចំងាយពី $F_1$ ទៅ $P$ និងពី $F_2$ ទៅ $P$ នៅត្រង់ $V_2$ (រូបដែលសង់ហើយ)<br>ខ/បើ $P$ នៅត្រង់ $B_2$ តាមនិយមន័យរកប្រវែងពី $O$ ទៅ $B_2$ ហើយទាញ | សិស្សធ្វើលំហាត់ |

| | | |
|---|---|---|
| | បង្ហាញថា $a^2=b^2+c^2$ | |
| គ្រូដាក់លំហាត់ឲ្យសិស្សធ្វើនៅផ្ទះ។ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ)<br>លំហាត់៖<br>គេឲ្យអេលីបមួយដែលមានចម្ងាយពីផ្ចិតទៅកំណុំស្មើ 2 និងពីផ្ចិតទៅកំពូលស្មើ 3 ។<br>ក/គណនាផលបូលចម្ងាយពីកំណុំទាំងពីរទៅចំណុច $P$ ដែលនៅត្រង់កំពូលនៃអេលីប។<br>ខ/គណនាប្រវែងកន្លះអ័ក្សតូចនៃអេលីប។<br>(ផ្ចិតអេលីប $I\ (0;0)$) | |

# **កិច្ចតែងការបង្រៀន**

**ជំពូក ទី**...១....

មេរៀនទី...២.... **អេលីប**

## ៣.សមីការអេលីប

### ៣.១ សមីការស្តង់ដានៃអេលីបដែលមានផ្ចិតជាគល់អ័ក្ស

I.<u>វត្ថុបំណងនៃមេរៀន</u>

-ចំណេះដឹង :សិស្សកំណត់សមីការស្តង់ដានៃអេលីបបានត្រឹមត្រូវតាមរយៈការបកស្រាយពន្យល់របស់គ្រូ។

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

II.<u>ពេលវេលា:</u> ...២....ម៉ោង ថ្ងៃ................ទី................ខែ.............ឆ្នាំ..........

III.<u>សម្ភារៈឧទេស</u>

-ស . ស :ទំព័រទី.១៩៤.. ដល់ទំព័រទី..១៩៩..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-បន្ទាត់ ខ្សែម៉ែត្រ តារាងរូបភាព ស្កុត

IV.<u>ដំណើកនាំមេរៀន</u>

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | <u>ជំហានទី១</u> (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| .គ្រូឲ្យសិស្សឲ្យនិយមន័យអេលីប?<br>.ប្រាប់ធាតុសំខាន់ៗនៃអេលីប? | <u>ជំហានទី២</u> (រំលឹកមេរៀនចាស់) | សិស្សឆ្លើយ<br>អេលីបជាសំណុំចំនុចនៅក្នុងប្លង់ដែលមានផលបូកចម្ងាយពីចំនុចនោះទៅចំនុចនឹងពីរជាចំនួនថេរ។<br>.មាន កំណុំ កំពូល អ័ក្សធំ |

| | | |
|---|---|---|
| | | អ័ក្សតូច ផ្ចិត<br>កន្លះអ័ក្សធំនិងកន្លះអ័ក្សតូច។ |
| .គ្រូធ្វើការស្រាយបញ្ជាក់ពីសមីការអេលីបដោយលើករូបភាពនិងបញ្ជាក់ឧទាហរណ៍។<br>.អេលីបមួយមានផ្ចិតគល់តំរុយកូអរដោនេ $(0;0)$ និងកំណុំទាំងពីរលើអ័ក្សអាប់ស៊ីស<br>តាង $F_1(c;0)$ និង $F_1(-c;0)$<br><br>.គ្រូបញ្ជាក់នេះជាសមីការស្តង់ដានសអេលីបកាត់តាមគល់អ័ក្ស<br><br>.បន្ទាប់មកគ្រូកត់ជាទូទៅទំព័រ១៩៥លើក្តាខៀន | *ជំហានទី៣* (មេរៀនថ្មី)<br>*មេរៀនទី.១.* **អេលីប**<br>៣.<u>សមីការនៃសអេលីប</u><br>៣.១<u>សមីការស្តង់ដានៃអេលីបដែលមានផ្ចិតជាគល់អ័ក្សកូអរដោនេ</u><br><br>គេបាន:<br>$PF_1+PF_2=2a$<br>$\sqrt{(x-c)^2+y^2}+\sqrt{(x+c)^2+y^2}=2a$<br>$\sqrt{(x-c)^2+y^2}=2a-\sqrt{(x+c)^2+y^2}$<br>លើកអង្គទាំងពីរជាការេ<br>$a\sqrt{(x+c)^2+y^2}=a^2+cx$<br>លើកជាការេ<br>$x^2\left(a^2-c^2\right)+a^2y^2=a^2\left(a^2-c^2\right)$<br>ដោយ $b^2=a^2-c^2$<br>$\Rightarrow x^2b^2+a^2y^2=a^2b^2$<br>ចែក $a^2b^2$<br>ដូចនេះ $\frac{x^2}{a^2}+\frac{y^2}{b^2}=1$<br>សមីការស្តង់ដា $\frac{x^2}{a^2}+\frac{y^2}{b^2}=1$ $(a>b>0)$ | សិស្សសង្កេតនិងកត់ត្រា<br><br>សិស្សកាត់ត្រា<br><br>សិស្សស្តាប់និងកត់ត្រា |

| | | |
|---|---|---|
| គ្រូបញ្ជាក់អ័ក្សទាំងពីរ | -អ័ក្សធំ $2a$ ;អ័ក្សតូច $2b$<br>-កំពូល $(a;0)\&(-c;0)$<br>-កំណុំ $(c;0)\&(-c;0)$<br>ដែល $c^2=a^2+b^2$ | |
| គ្រូឲ្យឧទាហរណ៍និងពន្យល់<br>ឧះគេឲ្យសមីការ<br>$\frac{(x-2)^2}{25}+\frac{(y+4)^2}{4}=1$<br>ក.កំនត់ប្រភេទរូធរណី<br>មាត្រ។<br>ខ.សង់រូប រកផ្ចិតកំពូល<br>កំណុំ។ | សមីការស្តង់ដា $\frac{x^2}{a^2}+\frac{y^2}{b^2}=1 \quad (a>b>0)$<br>ហើយកំពូលនិងកំណុំមានអរដោនេផ្ទុយ<br>ពីសមីការលើ<br>៣.២<u>សមីការស្តង់ដានៃអេលីបដែលមាន</u><br><u>ផ្ចិតខុសពីគល់អ័ក្ស</u><br>ក.បើគេជំនួស $x=x-3$ និង $y=y+4$<br>គេបានសមីការស្តង់ដាអេលីបថ្មី<br>$\frac{(x-2)^2}{25}+\frac{(y+4)^2}{4}=1$<br>ដែលបានមកពីការរំកិលអេលីបមុនឲ្យ<br>ស្របនិងអ័ក្សកូអរដោនេទៅខាងស្តាំចំនួ<br>ន<br>៣ឯកតានិងចុះក្រោមចំនួន៤ឯកតា | សិស្សមើលឧទាហណ៍ |
| គ្រូបិទរូបលើក្តាខៀន<br>គ្រូពន្យល់<br>អេលីបតាង<br>$\frac{(x-2)^2}{25}+\frac{(y+4)^2}{4}=1$<br>ប៉ុននិងអេលីបតាង<br>$\frac{x^2}{25}+\frac{y^2}{4}=1$<br>គេបាន $a^2=25\Rightarrow a=5$<br>$b^2=4\Rightarrow b=2$<br>ប្រវែងអ័ក្សធំ $2a=2\times5=10$<br>តូច $2b=2\times2=4$ | រូបធរណីមាត្រះ<br><br> | កត់ត្រាចំលើយ |

| | | |
|---|---|---|
| កំពូល $(8;-4)\&(-2;-4)$<br>កំណុំ $\left(3+\sqrt{21}-4\right)\&\left(3-\sqrt{21};-4\right)$<br>ព្រោះ<br>$c^2=a^2+b^2=25-4=21$<br>$\Rightarrow c=\sqrt{21}$<br><br>.គ្រូជាទូទៅទំព័រ១៩៨ | ខ្លឹមសារជាទូទៅនៅទំព័រ១៩៨ | |
| .គ្រូឲ្យសិស្សធ្វើលំហាត់<br>គំរូទី១◌:<br>រកសមីការស្តង់ដាអេលីប<br>មានកំណុំ $(0;2)$ និង<br>កំពូល $(0;-3)$ និង $(0;3)$<br>រួចសង់អេលីបនោះ។ | <u>ជំហានទី៤</u> (ពង្រឹងចំណេះដឹង)<br> | សិស្សពិភាក្សាជាក្រុម<br>.ដោយកំពូលនៅត្រង់ចំនុច<br>$(0;-3)$ និង $(0;3)$ ហើយផ្ចិត<br>$(0;0)$<br>និងអ័ក្សធំនៅលើអ័ក្សអរដោនេ<br>$c=2\,;\,a=3$<br>$\Rightarrow b^2=a^2-c^2$<br>$=9-4=5$<br>អេលីបមានសមីការស្តង់ដា<br>$\frac{x^2}{a^2}+\frac{y^2}{a^2}=1\Rightarrow\frac{x^2}{5}+\frac{y^2}{9}=1$ |
| ឲ្យសិស្សធ្វើលំហាត់ប្រតិបត្តិនៅទំព័រ១៩៦&១៩៩ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ) | សិស្សប្រគល់កិច្ចការនៅម៉ោងក្រោយ |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៦. *មេរៀនទី...៣....* **អ៊ីពែបូល**

*(១.សេចក្តីផ្តើមអំពីអ៊ីពែបូល ; ២.និយមន័យនៃអ៊ីពែបូល; ៣.សមីការអ៊ីពែបូល;*

*៣.១ សមីការស្តង់ដាអ៊ីពែបូលមានផ្ចិតជាគល់អ័ក្សកូរដោនេ)*

I.<u>វត្ថុបំណងនៃមេរៀន</u>

-ចំណេះដឹង :សិស្សបង្ហាញសេចក្តីផ្តើមអំពីអ៊ីពែបូល និយមន័យនៃអ៊ីពែបូល; សមីការអ៊ីពែបូលនិងបកស្រាយ សមីការស្តង់ដាអ៊ីពែបូលមានផ្ចិតជាគល់អ័ក្សកូរដោនេ តាមរយ:ឧទាហរណ៍បានត្រឹមត្រូវ។

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយ:ឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

II.<u>ពេលវេលា:</u> ...២....ម៉ោង ថ្ងៃ...............ទី...............ខែ.............ឆ្នាំ..........

III.<u>សម្ភារ:ឧទេស</u>

-ស . ស :ទំព័រទី.២០៤.. ដល់ទំព័រទី..២១១..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-បន្ទាត់ ខ្សែម៉ែត្រ

IV.<u>ដំណើកនាំមេរៀន</u>

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | <u>*ជំហានទី១*</u> (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>.ចូរប្អូនគូររូបកោណមួយដែលប្អូនស្គាល់។<br>.ចូរប្អូនគូររូបកំណត់កោណមួយផ្សេងទៀត<br>.គ្រូត្រូវពិនិត្យមើលរូបដែលសិស្សសរសេរនៅលើក្តារ | <u>*ជំហានទី២*</u> (រំលឹកមេរៀនចាស់)<br><br>$V=\frac{1}{3}\pi R^2h$<br>កោន<br><br>កំណាត់កោន | សិស្សឡើងគូររូបកោន |

| | | |
|---|---|---|
| ខៀន | | |
| .គ្រូត្រូវកត់ត្រាឬសរសេរមេរៀនដាក់នៅលើក្តាខៀន<br><br>.គ្រូត្រូវគូរូបអ័ក្សកោនមួយដើម្បីធ្វើការបកស្រាយនិយមន័យអ៊ីពែបូល?<br><br>គ្រូត្រូវសរសេរនិយមន័យអ៊ីពែបូលដាក់នៅលើក្តាខៀន<br>ហើយពន្យល់បកស្រាយអំពីនិយមន័យនោះឲ្យមានភាពទូលំទូលាយ។ | *ជំហានទី៣* (មេរៀនថ្មី)<br>*មេរៀនទី.១.* **អ៊ីពែបូល**<br>១.*សេចក្តីផ្តើមអ៊ីពែបូល*<br>*ប្លង់មួយស្របនិងអ័ក្សនៃផ្ទៃកោនបរិវត្តន៍ប្រសព្វផ្ទៃកោនបានខ្សែកោងដែលមានពីរផ្នែកផ្សេងគ្នាហៅ*<br>*ថា"អ៊ីពែបូល"។*<br>២.*និយមន័យនៃអ៊ីពែបូល*<br><br>*និយមន័យ:*<br>*អ៊ីពែបូលជាសំណុំចំនុច $P$ នៅក្នុងប្លង់ដែលមានផលដករវាងចំងាយពី ចំនុច $P$ ទៅ ចំនុចនឹងពីរគឺ $F_1$ និង $F_2$ ជាកំណុំនៃអ៊ីពែបូល។*<br> | សិស្សស្តាប់និងកត់ត្រាមេរៀន<br><br>សិស្សកត់ត្រា |

-$V_1V_2$ ហៅថាកំពូលអ៊ីពែបូល។

-បន្ទាត់ $F_1F_2$ ហៅថាអ័ក្សទទឹង។

-ចំនុចកណ្តាលនៃអង្កត់ $F_1F_2$ គឺជាផ្ចិត $0$ នៃអ៊ីពែបូល។

-តាង $0F_1 = 0F_2 = c$ និង $0V_1 = 0V_2 = a$
ដែល $c > a > 0$

-មេដ្យាទ័រនៃអង្កត់ $F_1F_2$ ហៅថាអ័ក្សឆ្លាស់

-អ័ក្សទទឹងនិងអ័ក្សឆ្លាស់ជាអ័ក្សឆ្លុះនៃអ៊ីពែបូល។

៣.<u>សមីការនៃអ៊ីពែបូល</u>

៣.១<u>សមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតជាគល់អ័ក្សកូអរដោនេ</u>

ក.ករណីអ័ក្សទទឹងជាអ័ក្សអាប់ស៊ីស

តាមនិយមន័យគេអាចទាញបានសមីការ
ស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិត $(0;0)$ និងកំនុំទាំងពីរស្ថិតនៅលើអ័ក្សអាប់ស៊ីស
។ទាញពិនិយមន័យផលដករវាងចម្ងាយពីចំណុច $P$ ទៅកំនុំទាំងពីរជាចំនួនថេរ
គេបាន

$$|PF_1 - PF_2| = 2a$$

$$PF_1 - PF_2 = \pm 2a$$

$$\sqrt{(x-c)^2 + y^2} - \sqrt{(x+c)^2 + y^2} = \pm 2a$$

$$\sqrt{\left((x-c)^2 + y^2\right)^2} = \left(\pm 2a + \sqrt{(x+c)^2 + y^2}\right)$$

$$(x-c)^2 + y^2 = 4a^2 \pm 4a\sqrt{(x+c)^2 + y^2}$$
$$+(x+c)^2 + y^2$$

| | | |
|---|---|---|
| គ្រូសរសេរលំហាត់គំរូដាក់នៅលើក្តារខៀនហើយដោះស្រាយតាមលំដាប់លំដោយ | $x^2-2cx+c^2+y^2=4a^2\pm4a\sqrt{(x+c)^2+y^2}$<br>$+x^2-2cx+c^2+y^2$<br>$-4a^2-4cx=\pm4a\sqrt{(x+c)^2+y^2}$<br>$-a^2-cx^2=\pm a\sqrt{(x+c)^2+y^2}$<br>$a^4+2a^2cx+c^2x^2=a^2\left(x^2+2cx+c^2+y^2\right)$<br>សមីការនេះសរសេរទៅជា<br>$\left(c^2-a^2\right)x^2-a^2y^2=a^2\left(c^2-a^2\right)$<br>កំណត់យក $b^2=c^2-a^2$<br>សមីការនេះក្លាយទៅជា<br>$b^2x^2-a^2y^2=a^2b^2$ ចែកអង្គទាំងពីរនឹង $a^2b^2$ គេបាន $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ហៅថាសមីការស្តង់ដានៃអ៊ីពែបូលមានផ្ចិតជាគល់កូអរដោនេហើយមានអ័ក្សទទឹងនៅលើអ័ក្សអាប់ស៊ីស។<br><u>ជាទូទៅ:</u> អ៊ីពែបូលដែលមានផ្ចិតជាគល់អ័ក្សកូអរដោនេហើយអ័ក្សទទឹងស្ថិតនៅអ័ក្សអាប់ស៊ីសមានសមីការស្តង់ដា<br>$\frac{x^2}{a^2}-\frac{y^2}{b^2}=1\left(a>0;b>0\right)$<br>-កំពូលទាំងពីរមានកូអរដោនេ $(a;0)$ និង $(-a;0)$<br>-កំណុំទាំងពីរមានកូអរដោនេ $(c;0)$ និង $(-c;0)$ ដែល $c^2=a^2+b^2$<br>-សមីការអាស៊ីមតូតទាំងពីរគឺ $y=\frac{b}{a}x$ និង $y=-\frac{b}{a}x$<br>លំហាត់គំរូ:<br>គេឲ្យសមីការ $9x^2-16y^2=144$<br>ក.បង្ហាញថាសមីការនេះជាសមីការអ៊ីពែបូល។កំណត់កូអរដោនេកំពូលនិង | សិស្សសង្កេតនិងកត់ត្រា |

កូអរដោនេកំណុំ។

ខ.រកសមីការអាស៊ីមតូត

គ.សង់អ៊ីពែបូល

ចំលើយ

ក.កំណត់កូអរដោនេកំពូលនិងកូអរដោនេកំណុំ

គេមានសមីការ $9x^2-16y^2=144$

ចែកអង្គទាំងពីរនិង $144$

គេបាន $\frac{9x^2}{144}-\frac{16y^2}{144}=\frac{144}{144}$

$\frac{x^2}{16}-\frac{y^2}{9}=1$

គេទាញបានកូអរដោនេកំពូលទាំងពីរគឺ $(4;0)$ និង $(-4;0)$ ។

$c^2=a^2+b^2$

តាម $c^2=16+9=25$

$\Rightarrow c=\sqrt{25}=5$

ដូចនេះកូអរដោនេកំណុំទាំងពីរគឺ $(5;0);(-5;0)$ ។

ខ.សមីការអាស៊ីមតូតទាំងពីរគឺ

$y=\frac{b}{a}x \Rightarrow y=\frac{3}{4}x$

$y=-\frac{b}{a}x \Rightarrow y=-\frac{3}{4}x$

គ.សង់អ៊ីពែបូល



ខ.ករណីអ័ក្សទទឹងជាអ័ក្សអរដោនេ

យើងមានសមីការអ៊ីពែបូល $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ដែលមានផ្ចិត $(0;0)$ និងកំនុំ $(0;\pm c)$ ដែលមានអ័ក្សទទឹងចាអ័ក្សអាប់ស៊ីសហើយ $c^2=a^2+b^2$ ។នោះគេប្តូរ $x$ ជា $y$ និង $y$ ជា

$x$

យើងបាន $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ជាសមីការរូបឆ្លុះរបស់អ៊ីពែបូល $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ធៀបនិងបន្ទាត់ $y = x$ ។

ដូចនេះសមីការ $\frac{x^2}{a^2}-\frac{y^2}{b^2}=1$ ជាសមីការអ៊ីពែបូលមានផ្ចិត $(0;0)$ និងកំណុំ $(0;\pm c)$ ហើយអ័ក្សទទឹងស្ថិតនៅលើអ័ក្សអរដោនេដែល $c^2=a^2+b^2$




ជាទូទៅ:អ៊ីពែបូលដែលមានអ័ក្សទទឹង
ជា
អ័ក្សងអរដោនេមានសមីការស្តង់ដា

$\frac{x^2}{a^2}-\frac{y^2}{b^2}=1;(a>o;b>o)$

-កំពូលទាំងពីរមានកូអរដោនេ $(0;\pm a)$

-កំណុំទាំងពីរមានកូអរដោនេ $(0;\pm c)$

| | | |
|---|---|---|
| | ដែល $c^2 = a^2 + b^2$<br>-សមីការអាស៊ីមតូតទាំងពីរគឺ $y = \pm\frac{a}{b}x$ | |
| គ្រូឲ្យធ្វើលំហាត់ប្រតិបត្តិ ទំព័រទី២១១ ត្រង់ចំនុចក;ខ;គ។ | *<u>ជំហានទី៤</u>* (ពង្រឹងចំណេះដឹង) | សិស្សពិភាក្សាជាក្រុម |
| គ្រូឲ្យធ្វើលំហាត់ប្រតិបត្តិ ទំព័រទី២១៧លេខរៀង ១ដល់៣ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ) | សិស្សប្រកល់កិច្ចការ នៅម៉ោងក្រោយ |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៦....

មេរៀនទី...៣.... **អ៊ីពែបូល**

(.*សមីការស្តង់ដានៃអ៊ីពែបូល;សមីការទូទៅនៃអ៊ីពែបូល*)

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង :សិស្សបង្ហាញសមីការស្តង់ដានិងសមីការទូទៅនៃអ៊ីពែបូលតាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

II.ពេលវេលា: ...២....ម៉ោង ថ្ងៃ...............ទី...............ខែ.............ឆ្នាំ..........

III.សម្ភារៈឧទេស

-ស . ស :ទំព័រទី.២១១.. ដល់ទំព័រទី..៥..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-បន្ទាត់ កូនបាល់ ខ្សែម៉ែត្រ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | *ជំហានទី១* (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>.តើសមីការស្តង់ដារបស់អ៊ីពែបូលដែលមានផ្ចិត 0 និងអ័ក្សទទឹងជាអ័ក្សអាប់ស៊ីសមានទំរង់ដូចម្តេច?<br>.តើកំពូលអ៊ីពែបូលស្មើប៉ុន្មាន?<br>.កូអរដោនេនៃកំនុំនិងអាស៊ីម | *ជំហានទី២* (រំលឹកមេរៀនចាស់)<br>ឧ:កំណត់កូរដោនេកំពូល កំនុំ និងសមីការអាស៊ីមតូតនៃសមីការ $\frac{x^2}{9}-\frac{y^2}{16}=1$<br>ចំលើយ<br>យើងមានសមីការ $\frac{x^2}{9}-\frac{y^2}{16}=1$<br>នោះជាសមីការអ៊ីពែបូលដែលមានអ័ក្សទទឹងជាអ័ក្សអាប់ស៊ីសនិង $a=3;b=4$<br>នោះ | សិស្សឆ្លើយ<br>.សមីការស្តង់ដាអ៊ីពែបូលគឺ<br>$\frac{x^2}{a^2}-\frac{y^2}{b^2}=1;(a>0;b>0)$<br>.កំពូលទាំងពីរគឺ $(a;0);(-a;0)$<br>.កូអរដោនេនៃកំនុំគឺ<br>$(c;0);(-c;0)$ ដែល $c^2=a^2+b^2$<br>សមីការអាស៊ីមតូតគឺ $y=\pm\frac{b}{a}x$ |

| | | |
|---|---|---|
| តូតស្មើប៉ុន្មាន? | $c^2=a^2+b^2\Rightarrow c=\sqrt{a^2+b^2}$<br>$c=\sqrt{3^2+4^2}=5$<br><br>កំពូលអ៊ីពែបូលគឺ: $(a;o)=(3;0)$<br>និង $(-a;o)=(-3;0)$ $(3;1)$<br>កំនុំគឺ $(\pm c;0)=(\pm 5;0)$<br>សមីការអាសុីមតូតគឺ $y=\pm\frac{b}{a}x=\pm\frac{4}{3}x$ | |
| គ្រូសរសេរឧទាហរណ៍<br>គេឲ្យសមីការ<br>$\frac{(x-3)^2}{4}-\frac{(y+2)^2}{9}=1$<br>ក/កំណត់ប្រភេទនៃរូបធរណីមាត្រដែលក្រាបតាងសមីការខាងលើ។<br>ខ/រកកូអរដោនេផ្ចិត កំពូល កំណុំនិងសមីការអាសុីមតូត រួចសង់អ៊ីពែបូល។ | *ជំហានទី៣* (មេរៀនថ្មី)<br>*មេរៀនទី.៣.* **អ៊ីពែបូល**<br>ចំលើយ<br>ក/បើជំនួស $x$ ដោយ $x-3$ និង $y$ ដោយ $y+2$ ក្នុងសមីការ $\frac{x^2}{4}-\frac{y^2}{9}=1$ នៃអ៊ីពែបូល $H$ នោះគេបាន $\frac{(x-3)^2}{4}-\frac{(y+2)^2}{9}=1$ ដែលជាសមីការអ៊ីពែបូលថ្មីមួយទៀត $H'$ បានពីការរំកិលអ៊ីពែបូលចាស់ទៅខាងស្តាំ៣ឯកតាហើយស្របនិងអ័ក្សអាប់សុីសនិងចុះក្រោម២ឯកតាហើយស្របនិងអ័ក្សអរដោនេ។<br>ខ/ដោយអ៊ីពែបូលថ្មីបានពីបំលែងកិលអ៊ីពែបូលចាស់នោះ<br>$\frac{(x-3)^2}{4}-\frac{(y+2)^2}{9}=1$<br>ប៉ុនគ្នានិងអ៊ីពែបូល $\frac{x^2}{4}-\frac{y^2}{9}=1$ នោះ:<br>$a^2=4;b^2=9\Rightarrow c=\sqrt{4+9}=\sqrt{13}$<br>+ផ្ចិតមានកូអរដោនេ $(3;-2)$<br>+កំពូលគឺ $(5;-2);(1;-2)$<br>+កំណុំគឺ $(3+\sqrt{13};-2);(3-\sqrt{13};-2)$<br>+សមីការអាសុីមតូតគឺ $y=\pm\frac{3}{2}(x-3)-2$ | សិស្សកត់ត្រា |

| | | |
|---|---|---|
| គ្រូឲ្យជាទូទៅ | <br>ទូទៅ:<br>១/អ៊ីពែបូលដែលមានផ្ចិត $(h;k)$ និងអ័ក្សទទឹងស្របនិងអ័ក្សអាប់ស៊ីសមានសមីការគឺ<br>$\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1;(a>0;b>0)$<br>.កំពូល $(h\pm a;k)$<br>.កំនុំ $(h\pm c;k);c^2=a^2+b^2$<br>.សមីការអាស៊ីមតូតគឺ $y=k\pm\frac{b}{a}(x-h)$<br>២/ អ៊ីពែបូលដែលមានផ្ចិត $(h;k)$ និងអ័ក្សទទឹងស្របនិងអ័ក្សអរដោនេមានសមីការគឺ<br>$\frac{(y-k)^2}{a^2}-\frac{(x-h)^2}{b^2};(a>0;b>0)$<br>.កំពូល $(h;k\pm a)$<br>.កំនុំ $(h;k\pm c);c^2=a^2+b^2$<br>.សមីការអាស៊ីមតូតគឺ $y=k\pm\frac{a}{b}(x-h)$ | សិស្សកត់ត្រា |







៣.៣<u>សមីការទូទៅនៃអ៊ីពែបូល</u>

ជាទូទៅ៖

សមីការដឺក្រេទី២មានរាង

$Ax^2+By^2+Cx+Dy+E=0$ ដែល $AB<0$

ជាសមីការទូទៅនៃអ៊ីពែបូល។

ឧ:អ៊ីពែបូលមួយមានសមីការទូទៅ

$4x^2-9y^2+32x+18y+91=0$ ។

.គ្រូដាក់ឧទាហរណ៍គំរូ

ក/បំលែងសមីការនេះជាសមីការស្តង់ដា

ខ/រកកូអរដោនេនៃផ្ចិត កំពូល កំណុំនិង សមីការអាស៊ីមតូត។រួចសង់អ៊ីពែបលៈ។

<u>ចំលើយ</u>

ក.បំលែងសមីការនេះជាសមីការស្តង់ដា

យើងមានសមីការ

$4x^2-9y^2+32x+18y+91=0$

$(4x^2+32x)-(9y^2-18y)+91=0$

$4(x^2+8x)-9(y^2-2y)+91=0$

$4(x^2+8x+16-16)-9(y^2-2y+1-1)+91=0$

$4(x^2+8x+16)-64-9(y^2-2y+1)+91+9=0$

$4(x+4)^2-9(y-1)^2+36=0$

$4(x+4)^2-9(y-1)^2=-36$

$\frac{(y-1)^2}{4}-\frac{(x+4)^2}{9}=1$

ខ.រកកូអរដោនេផ្ចិត កំពូល កំណុំនិង សមីការអាស៊ីមតូតរួខសង់ក្រាប

យើងមានសមីការ

$\frac{(y-1)^2}{4}-\frac{(x+4)^2}{9}=1$

នោះ $h=-4;k=1;a=2;b=3;c=\sqrt{13}$

អ័ក្សទទឹងស្របនិងអ័ក្សអរដោនេ

+កូអរដោនេផ្ចិតគឺ $(-4;1)$

+កំពូលទាំងពីរគឺ $(-4;3);(-4;-1)$

+កំណុំទាំងពីរគឺ $\left(-4;1\pm\sqrt{13}\right)$

+សមីការអាស៊ីមតូតទាំងពីរគឺ

$y=\frac{2}{3}x+\frac{11}{3};y=-\frac{2}{3}x-\frac{5}{3}$




| | | |
|---|---|---|
| | ជំហានទី៤ (ពង្រឹងចំណេះដឹង) | សិស្សឆ្លើយ |

| | | |
|---|---|---|
| ប្រត្តិបត្តិ:រកសមីការស្តង់ដា នៃអ៊ីពែបូលដែលមានកំណុំ ត្រង់ចំនុច $(6;1)$ និង $(-2;1)$ ហើយអាស៊ីមតូតមានសមីការ $y=\frac{3}{4}x-\frac{1}{2}$ & $y=-\frac{3}{4}x+\frac{5}{2}$ | | យើងបានចំនុចកណ្តាលនៃកំណុំទាំងពីរគឺជាផ្ចិតនៃអ៊ីពែបូលគឺ: $\left(\frac{6-2}{2};\frac{1+1}{2}\right)=(2;1)$ $\Rightarrow h=2;k=1$ <br>យើងមានសមីការអាស៊ីមតូត $\begin{cases} y=\frac{3}{4}x-\frac{1}{2}=1+\frac{3}{4}x-\frac{3}{2} \\ y=-\frac{3}{4}x+\frac{5}{2}=1-\frac{3}{4}x\frac{3}{2} \end{cases}$ $\begin{cases} y=1+\frac{3}{4}(x-2) \\ y=1-\frac{3}{4}(x-2) \end{cases}$ $b=3;a=4$ <br>ដូចនេះ សមីការស្តង់ដាគឺ $\frac{(x-2)^2}{4^2}-\frac{(y-1)^2}{3^2}=1$ |
| គ្រូដាក់លំហាត់ឲ្យសិស្សធ្វើនៅផ្ទះ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ) <br>រកកូអរដោនេផ្ចិត កំណុំ កំពូលនិងសមីការអាស៊ីមតូតនៃអ៊ីពែបូលហើយសង់ក្រាបនីមួយ <br>ក/ $-x^2+4y^2-2x-6y+11=0$ <br>ខ/ $25x^2+16y^2-250x-382y+109=0$ | សិស្សអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

**ជំពូក ទី**...៦....

មេរៀនទី...៣... **អ៊ីពែប៉ូល**

(៤.អ៊ិចសង់ទ្រីស៊ីតេ ; ៥.លក្ខណចំណាំងផ្លាតនៃអ៊ីពែប៉ូល)

I.វត្ថុបំណងនៃមេរៀន

-ចំណេះដឹង :សិស្សស្គាល់អំពីអ៊ិចសង់ទ្រីស៊ីតេនិងចេះរកលក្ខណៈចំណាំងផ្លាតនៃអ៊ីពែបូល តាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-បំណិន :សិស្សដោះស្រាយប្រតិបត្តិនិងលំហាត់តាមរយៈឧទាហរណ៍បានត្រឹមត្រូវ

-ឥរិយាបថ : សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

II.ពេលវេលា: ...២....ម៉ោង ថ្ងៃ................ទី...............ខែ............ឆ្នាំ.........

III.សម្ភារៈឧទេស

-ស . ស :ទំព័រទី.២១៥.. ដល់ទំព័រទី..២១៦..

-ស . គ : ទំព័រទី... ដល់ទំព័រទី....

-បន្ទាត់ ខ្សែម៉ែត្រ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>-គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | តំណាងសិស្សឡើងរាយការណ៍ |
| គ្រូសួរ<br>.តើសមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតខុសពីគល់អ័ក្សកូអរដោនេ អ័ក្សទទឹងស្របនិងអ័ក្សអាប់ស៊ីសមានសមីការស្តង់ដាដូចម្តេច? | ជំហានទី២ (រំលឹកមេរៀនចាស់) | សិស្សឆ្លើយ<br>+មានផ្ចិត $(h;k)$ កំណុំ $(h+c;k);(h-c;k)$ និងកំពូល $(h+a;k);(h-a;k)$<br>សមីការស្តង់ដាគឺ<br>$\frac{(x-h)^2}{a^2}-\frac{(y-k)^2}{b^2}=1$<br>$c^2=a^2+b^2$<br>+ មានផ្ចិត $(h;k)$ កំណុំ |

| | | |
|---|---|---|
| .តើសមីការស្តង់ដានៃអ៊ីពែបូលដែលមានផ្ចិតខុសពីគល់អ័ក្សកូអរដោនេ អ័ក្សទទឹងស្របនិងអ័ក្សអរដោនេមានសមីការស្តង់ដាដូចម្តេច? | | $(h;k+c);(h;k-c)$ និងកំពូល<br>$(h;k+a);(h;k-a)$<br>សមីការស្តង់ដាគឺ<br>$\frac{(y-k)^2}{a^2}-\frac{(x-h)^2}{b^2}=1$<br>$c^2=a^2+b^2$ |
| គ្រូសរសេរមេរៀនថ្មី | *<u>ជំហានទី៣</u>* (មេរៀនថ្មី)<br>*មេរៀនទី.៣.* **អ៊ីពែបូល**<br>៤.<u>អ៊ិចសង់ទ្រីស៊ីតេ</u> $e$<br>និយមន័យ:<br>អ៊ិចសង់ទ្រីស៊ីតេ $e$ នៃអ៊ីពែបូលគឺជាផលធៀបរវាង $c$ ដែលជាចំងាយពីផ្ចិតទៅកំណុំនិង $a$ ដែលជាចំងាយពីផ្ចិតទៅកំពូលនៃអ៊ីពែបូល $e=\frac{c}{a}$<br>សំគាល់: គ្រប់អ៊ីពែបូលមានកំណុំនៅលើអ័ក្សទទឹងនៃអ៊ីពែបូល $c>a>o$<br>នោះ $\frac{c}{a}>1$ ឬ $e>1$<br>៥.<u>លក្ខណ:ចំណាំងផ្លាតនៃអ៊ីពែបូល</u><br>+អ៊ីពែបូលមានលក្ខណ:ចំណាំងផ្លាតដូចគ្នានឹងអេលីបដែរ។<br><br><br>.បើ $l$ ជាបន្ទាត់ប៉ះនៅនឹងអ៊ីពែបូលត្រង់ចំនុច $p$ ដែលមានកំណុំ $F_1$ និង $F_2$ ដូចរូប។<br>.បើ $\alpha$ ជាមុំស្រួចផ្គុំឡើងរវាង $F_2p$ និង $l$ ហើយ $\beta$ ជាមុំផ្គុំរវាង $F_1p$ និង $l$ នោះ $\alpha=\beta$ | សិស្សស្តាប់និងកត់ត្រា |

.បើកាំពន្លឺមានទិសដៅតាមបន្ទាត់ $l_1$ កាត់តាមចំនុច $F_1$ និង $p$ នោះវានឹងចាំងផ្លាតត្រលប់ពីចំនុច $p$ តាមបន្ទាត់ $l_2$ កាត់តាមចំណុច $F_2$ និង $p$ លក្ខណៈនេះគេអាចប្រើក្នុងការកំណត់កែវយឺតប្រភេទ Casse grain ។

គ្រូដាក់ឧទាហរណ៍

កប៉ាល់មួយកំពុងធ្វើដំណើរពីចំនុច $c$ ស្របនិងឆ្នេរសមុទ្រ ហើយមានចំងាយ $160km$ ពីមាត់សមុទ្រ កប៉ាល់នេះបានបង្ហាញនូវសញ្ញាគ្រោះថ្នាក់ដែលត្រូវបានទទួលដោយស្ថានីយពីរ $A$ និង $B$ ហើយមានចំងាយពីគ្នា $320km$ (ដូចរូបខាងក្រោម)។ តាមការវាស់រយះពេលខុសគ្នាដោយមន្ត្រីស្ថានីយក្នុងការចាប់បានសញ្ញាគ្រោះថ្នាក់ កំណត់ឃើញថាកប៉ាលនេះនៅជិតស្ថានីយ $B$ ជាងស្ថានីយ $A$ ចំងាយ $256km$ ។ តើកប៉ាលនេះមានទីតាំងនៅត្រង់ចំនុចណា?




ចំលើយ

តាង $d_1$ ចំងាយពីកប៉ាលទៅស្ថានីយ $A$

$d_2$ ចំងាយពីកប៉ាលទៅស្ថានីយ $B$

យើងបាន

$d_1 - d_2 = 256 = 2a$

$\Rightarrow a = 128$

ដោយ $c = \dfrac{320}{2} = 160$ និង $c^2 = a^2 + b^2$

នោះ $b^2 = c^2 - a^2 \Rightarrow b = \sqrt{160^2 - 128^2} = 96$

សមីការស្តង់ដានៃអ៊ីពែបូលដែលមានកំនុំមួយនៅត្រង់ចំនុច $A$ ហើយកាត់តាមកូអរដោនេនៃកប៉ាលនៅត្រង់ចំនុច $p(x;y)$ គឺ

$$\frac{x^2}{128^2} - \frac{y^2}{96^2} = 1$$

ដោយ $y = 160$ គេបាន $\dfrac{x^2}{128^2} - \dfrac{y^2}{96^2} = 1$

$$x = \sqrt{\left(1 + \frac{160^2}{96^2}\right)128} \approx 128.\sqrt{3.7}$$

កូអរដោនេនៃចំនុចដែលកប៉ាលស្ថិតនៅគឺ $\left(128\sqrt{3.7};160\right)$ ។

| | | |
|---|---|---|
| គ្រូឲ្យសិស្សពិភាក្សាលើ<br>លំហាត់ទី១១ | *ជំហានទី៤* (ពង្រឹងចំណេះដឹង)<br><br> | សិស្សឡើងធ្វើ<br>ចំលើយ<br>តាមគន្លងអ៊ីពែបូលដែលមាន<br>$V(\pm 3;0)$ និង $W\left(0;\pm\frac{3}{2}\right)$<br>យើងបានសមីការស្តង់ដាគឺ<br>$\frac{x^2}{3^2}-\frac{y^2}{\left(\frac{3}{2}\right)^2}=1$<br>នាំឲ្យ $x^2-4y^2=9$<br>បើមានមែកតែម្ខាងនៅខាងស្តាំ<br>នោះ $x=\sqrt{4y^2+9}$ ជាសមីការ<br>គន្លង។ |
| គ្រូឲ្យសិស្សយកលំហាត់<br>ធ្វើនៅផ្ទះទំព័រទី២១៩<br>លំហាត់ទី៩ | <u>ជំហានទី៥</u> (កិច្ចការផ្ទះ) | សិស្សប្រគលកិច្ចការនៅ<br>ម៉ោងក្រោយ |

# កិច្ចតែងការបង្រៀន

## ជំពូកទី ១ លីមីតនៃស៊ីត

## មេរៀនទី ១ លីមីតនៃស៊ីត

I. **ស៊ីតអនន្ត**

**១. និយមន័យ**

**២. ស៊ីតរួម**

**៣. ស៊ីតរីក**

I. **វត្ថុបំណងនៃមេរៀន ៖** ក្រោយពីរៀនចប់សិស្សមាន

- ចំណេះដឹង : កំណត់និយមន័យ ស៊ីតអនន្ត ស៊ីតរួម ស៊ីតរីក បានត្រឹមត្រូវតាមរយរយៈឧទាហរណ៍
- បំនិន : បង្ហាញបាននូវស៊ីតអនន្ត ស៊ីតរួម ស៊ីតរីក បានត្រឹមត្រូវតាមរយៈលំហាត់គំរូ
- ឥរិយាបថ : សហការគ្នាដោះស្រាយលំហាត់ប្រតិបត្តិ

II. **ពេលវេលា** ០២ ម៉ោង ថ្ងៃ... ទី... ខែ... ឆ្នាំ២០១...

III. **សម្ភារៈឧបទេស**

សៀវភៅគ្រូ

សៀវភៅសិស្ស

IV. **ដំណើរការមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យអវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ថ្នាក់រៀន | ជំហានទី ១<br>រដ្ឋបាលថ្នាក់ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| ចូរអោយនិយមន័យស៊ីតនៃចំនួនពិត។ និយមន័យស៊ីតនព្វន្ត។និយមន័យស៊ីតធរណីមាត្រ។ | ជំហានទី ២<br>រំលឹកមេរៀន | -ស៊ីតចំនួនពិតជាអនុគមន៍លេខដែលកំណត់ពី $IN \rightarrow IR$។<br>-ស៊ីតនព្វន្តជាអនុគមន៍លេខបន្តបន្ទាប់គ្នា ដែលកើតឡើងពីផលបូកចំនួនដំបូងមួយនិងចំនួនថេរ។<br>-ស៊ីតធរណីមាត្រជាអនុគមន៍លេខបន្តបន្ទាប់គ្នា ដែលកើតឡើងពីផលគុណចំនួនដំបូង |

| | | |
|---|---|---|
| | | មួយ និងចំនួនថេរ។ |
| ចាប់ផ្តើមមេរៀនចំនុចទី១<br>គ្រូដាក់ឧទាហរណ៍ទី១ឲ្យសិស្សសង្កេត<br>ហេតុអ្វីបានជាស្វ៊ីតមានតួច្រើនអនន្តជាស្វ៊ីតអនន្ត?<br>គ្រូដាក់ឧទហរណ៍ទី២<br>តើស្វ៊ីតនេះមានតួច្រើនអនន្តតួឬទេ?<br>ឲ្យនិយមន័យ ស្វ៊ីតងនន្តដល់សិស្ស<br>ដាក់លំហាត់គំរូឲ្យសិស្សពិភាក្សា និងឲ្យសិស្សម្នាក់ឡើងដោះស្រាយ | ជំហានទី ៣<br>មេរៀនប្រចាំថ្ងៃ<br>**ជំពូកទី ១ លីមីតនៃស្វ៊ីត**<br>**មេរៀនទី ១ លីមីតនៃស្វ៊ីត**<br>**I ស្វ៊ីតអនន្ត**<br>**១. និយមន័យ**<br><u>ឧទាហរណ៍១</u>៖ ស្វ៊ីតនៃចំនួនពិត $1,\frac{1}{2},\frac{1}{3},\frac{1}{4},\frac{1}{5},\dots,\frac{1}{n},\dots$ ដែលមានចំនួនតួច្រើនអនន្តជាស្វ៊ីតអនន្ត។<br>ដែលមានចំនួនតួច្រើនអនន្តជាស្វ៊ីតអនន្ត។<br><u>ឧទាហរណ៍២</u>៖ ស្វ៊ីតនៃចំនួនពិត $1,4,9,16,\dots,n^2,\dots$ ដែលមានចំនួនតួច្រើនអនន្តជាស្វ៊ីតអនន្ត។<br><u>និយមន័យ</u><br>ស្វ៊ីត $a_1,a_2,a_3,\dots,a_n,\dots$ ដែលមានចំនួនតួច្រើនអនន្តហៅថាស្វ៊ីតអនន្ត។<br>លំហាត់គំរូ៖<br>រកតួទូទៅនៃស្វ៊ីតខាងក្រោមរួចបញ្ជាក់ថាស្វ៊ីតទាំងនោះជាស្វ៊ីតអនន្ត $\frac{3}{1},\frac{5}{4},\frac{7}{7},\frac{9}{10},\frac{11}{13},\dots$ ។<br>គេសង្កេតឃើញថាភាគយកនៃតួនីមួយៗជាចំនួនសេស និងភាគបែងនៃតួបន្ទាប់បានដោយយកភាគបែងនៃតួនៅមុខបូកនិង៣។<br>ដូចនេះ | ស្តាប់<br>សង្កេត<br>កត់ត្រា<br>បានជាស្វ៊ីតមានតួច្រើនអនន្តជាស្វ៊ីតអនន្តព្រោះយើងមិនអាចកំណត់ចំនួនតួនៃស្វ៊ីតបាន<br>ស្វ៊ីតនេះមានតួច្រើនអនន្តតួ<br>កត់ត្រានិយមន័យនៃស្វ៊ីតអនន្ត<br>ពិភាក្សាលំហាត់គំរូ<br>សិស្សម្នាក់ឡើងដោះស្រាយ<br>គេសង្កេតឃើញថាភាគយកនៃតួនីមួយៗជាចំនួនសេស និងភាគបែងនៃតួបន្ទាប់បានដោយយកភាគបែងនៃតួនៅមុខបូកនិង៣។<br>ដូចនេះ<br>$\frac{3}{1},\frac{5}{4},\frac{7}{7},\frac{9}{10},\frac{11}{13},\dots,\frac{2n+1}{3n-2}$<br>មានចំនួនតួច្រើនអនន្តជាស្វ៊ីតអនន្ត ហើយមានតួទូទៅ |

| | | |
|---|---|---|
| ចូលចំនុចទី២<br><br>ដាក់ឧទាហរណ៍ និងពន្យល់ពីឧទាហរណ៍។<br><br>ឲ្យសិស្សទាញសន្និដ្ឋាននិយមន័យស្វ៊ីតរួម<br><br>ដាក់លំហាត់គំរូឲ្យសិស្សពិភាក្សា | $\frac{3}{1},\frac{5}{4},\frac{7}{7},\frac{9}{10},\frac{11}{13},\dots,\frac{2n+1}{3n-2}$ មានចំនួនតួច្រើនអនន្តជាស្វ៊ីតអនន្ត ហើយមានតួទូទៅ $a_n=\frac{2n+1}{3n-2},n\in\mathbb{N}$ ។<br><br>**២. ស្វ៊ីតរួម**<br><br><u>ឧទាហរណ៍</u><br>$(b_n):\frac{2}{1},\frac{3}{2},\frac{4}{3},\frac{5}{4},\dots,\frac{n+1}{n},\dots$ ។<br>គេបាន $(b_n)=\frac{n+1}{n}=1+\frac{1}{n}$ ។<br>កាលណា $n$ យកតម្លៃធំឡើងៗ នោះ $\frac{1}{n}$ មានតម្លៃកាន់តែតូចទៅៗ ហើយខិតទៅរកសូន្យ។ ដូចនេះ $b_n$ យកតម្លៃកាន់តែខិតជិត 1 ។<br>គេថាស្វ៊ីត $(b_n)$ មានលីមីត 1 កាលណា $n$ ខិតទៅ $+\infty$ ហើយគេកំណត់សរសេរ $\lim_{n\to+\infty}b_n=1$ ។ ក្នុងករណីនេះគេថាស្វ៊ីត $(b_n)$ រួមទៅរក 1។<br><u>និយមន័យ</u><br>ស្វ៊ីត $(a_n):a_1,a_2,a_3,\dots,a_n,\dots$ ជាស្វ៊ីតរួមខិតទៅរកចំនួនពិត $\lambda$ បើ $\lim_{n\to+\infty}a_n=\lambda$ ។<br><u>លំហាត់គំរូ</u>៖ បង្ហាញថាស្វ៊ីត $1,-\frac{1}{2},\frac{1}{3},-\frac{1}{4},\frac{1}{5},\cdots$ ជាស្វ៊ីតរួម<br>ដំណោះស្រាយ<br>ស្វ៊ីតនេះមានតួទូទៅ $(-1)^{n+1}\frac{1}{n}$ ។ដោយ $\lim_{n\to+\infty}\frac{1}{n}=0$ នោះ<br>គេបាន $\lim_{n\to+\infty}(-1)^{n+1}\frac{1}{n}=0$ | $a_n=\frac{2n+1}{3n-2},n\in\mathbb{N}$ ។<br><br>កត់ត្រា<br><br>ស្តាប់ និង សង្កេត<br><br>ធ្វើការសន្និដ្ឋាន និងកត់ត្រានិយមន័យ<br><br>ពិភាក្សាដោះស្រាយលំហាត់<br>ដំណោះស្រាយ<br>ស្វ៊ីតនេះមានតួទូទៅ $(-1)^{n+1}\frac{1}{n}$ ។ដោយ $\lim_{n\to+\infty}\frac{1}{n}=0$ នោះ<br>គេបាន $\lim_{n\to+\infty}(-1)^{n+1}\frac{1}{n}=0$<br>ដូចនេះស្វ៊ីត |

| | | |
|---|---|---|
| ចូលចំនុចទី ៣<br>ដាក់ឧទាហរណ៍ទី១នឹងពន្យល់ពីឧទាហរណ៍<br><br>ប្រាប់ថា $(a_n)$ រីកទៅរក $+\infty$<br><br>បង្ហាញ នឹងពន្យល់ឧទាហរណ៍ទី ២<br><br>ឲ្យសិស្សទាញសន្និដ្ឋាននិយមន័យនៃស្វ៊ីតរីក | ដូចនេះស្វ៊ីត $1,-\frac{1}{2},\frac{1}{3},-\frac{1}{4},\frac{1}{5},\cdots,(-1)^{n+1}\frac{1}{n}$ ជាស្វ៊ីតរួមទៅរក $0$ ។<br>**៣. ស្វ៊ីតរីក**<br>ឧទាហរណ៍១៖ ស្វ៊ីត $1,4,9,16,\dots,n^2,\dots$ មានតួទូទៅ $a_n=n^2$ ។ កាលណា $n$ កើនធំទៅៗ ហើយខិតទៅជិតអនន្តនោះ $a_n=n^2$ កើនធំទៅៗ ខិតទៅជិតអនន្តដែរ។<br>គេសរសេរ $\lim\limits_{n\to+\infty}(a_n)=+\infty$<br>គេថា $(a_n)$ រីកទៅរក $+\infty$<br>ឧទាហរណ៍២៖ ស្វ៊ីត $1,0,-1,-2,\dots,2-n,\dots$ មានតួទូទៅ $a_n=2-n$ ។កាលណា $n\to+\infty$ គេបាន $(2-n)\to-\infty$ ឬ $\lim\limits_{n\to+\infty}(2-n)=-\infty$ ។គេថាស្វ៊ីត $(a_n)$ ជាស្វ៊ីតរីកទៅរក $-\infty$ ។<br>និយមន័យ<br>ស្វ៊ីត $(a_n):a_1,a_2,a_3,\dots,a_n,\dots$ ជាស្វ៊ីតរីកខិតទៅរក $+\infty$ បើ $a_n$ មានលីមីត $+\infty$ ឬ $\lim\limits_{n\to+\infty}(a_n)=+\infty$ ។<br>ស្វ៊ីត $(a_n):a_1,a_2,a_3,\dots,a_n,\dots$ ជាស្វ៊ីតរីកខិតទៅរក $-\infty$ បើ $a_n$ មានលីមីត $-\infty$ ឬ $\lim\limits_{n\to+\infty}=-\infty$ ។ | $1,-\frac{1}{2},\frac{1}{3},-\frac{1}{4},\frac{1}{5},\cdots,(-1)^{n+1}\frac{1}{n}$ ជាស្វ៊ីតរួមទៅរក $0$ ។<br><br>ស្តាប់<br>សង្កេតលើឧទាហរណ៍<br>កត់ត្រា<br><br>សិស្សសន្និដ្ឋាននិយមន័យនៃស្វ៊ីតរីក នឹង កត់ត្រានិយមន័យ |
| ដាក់លំហាត់គំរូឲ្យសិស្សឡើងដោះស្រាយ | ជំហានទី៤<br>ពង្រឹងពុទ្ធិ<br>លំហាត់គំរូ<br>បង្ហាញថាស្វ៊ីត $(u_n)$ ដែល $u_n=-3n^2-2$ ជាស្វ៊ីតរីក។ | ពិភាក្សា និង ដោះស្រាយ<br>គេបាន<br>$\lim\limits_{n\to+\infty}(-3n^2-2)$<br>$=\lim\limits_{n\to+\infty}(-3n^2)$<br>$=+\infty$ |

| | | |
|---|---|---|
| ចូរឲ្យនិយមន័យស្វីតរីក។ និងស្វីតរួម។ | | ដូចនេះស្វ៊ីត $(u_n)$ ជាស្វ៊ីតរីកទៅរក $-\infty$ ។<br>ស្វ៊ីត $(a_n): a_1, a_2, a_3, \ldots, a_n, \ldots$ ជាស្វ៊ីតរីកខិតទៅរក $+\infty$ បើ $a_n$ មានលីមីត $+\infty$ ឬ $\lim\limits_{n\to+\infty}(a_n) = +\infty$ ។<br>ស្វ៊ីត $(a_n): a_1, a_2, a_3, \ldots, a_n, \ldots$ ជាស្វ៊ីតរីកខិតទៅរក $-\infty$ បើ $a_n$ មានលីមីត $-\infty$ ឬ $\lim\limits_{n\to+\infty} = -\infty$ ។<br>ស្វ៊ីតរួម<br>ស្វ៊ីត $(a_n): a_1, a_2, a_3, \ldots, a_n, \ldots$ ជាស្វ៊ីតរួមខិតទៅរកចំនួនពិត $\lambda$ បើ $\lim\limits_{n\to+\infty} a_n = \lambda$ ។ |
| ពេលត្រលប់ទៅផ្ទះវិញធ្វើលំហាត់ប្រតិបត្តិរបស់ចំនុចទី ៣ ស្វ៊ីតរីក នៅទំព័រទី០៤ (ក និង ខ) | ជំហានទី ៥<br>បណ្តាំផ្ញើ | កត់ត្រា នឹង ធ្វើតាម |

# កិច្ចតែងការបង្រៀន

## ជំពូកទី ១ លីមីតនៃស្វ៊ីត

## មេរៀនទី ១ លីមីតនៃស្វ៊ីត

### II. ប្រមាណវិធីលើលីមីតនៃស្វ៊ីត

**១. ទ្រឹស្តីបទគ្រឹះ**

**២. លក្ខណៈគ្រឹះ**

### III. លីមីតនៃស្វ៊ីតធរណីមាត្រ

**១. សញ្ញាណស្វ៊ីតធរណីមាត្រអនន្ត**

**I. ចំណុចបំណងនៃមេរៀន ៖** ក្រោយពីរៀនចប់សិស្សមាន

- ចំណេះដឹង : ពន្យល់ពីលក្ខណៈគ្រឹះ និងទ្រឹស្តីបទគ្រឹះបានត្រឹមត្រូវ និងកំណត់សញ្ញាណនៃស្វ៊ីតធរណីមាត្របានត្រឹមត្រូវ
- បំនិន : គណនាលីមីតស្វ៊ីតដោយប្រើប្រមាណវិធីបានត្រឹមត្រូវ
- ឥរិយាបថ : សហការគ្នាដោះស្រាយលំហាត់

**II. ពេលវេលា** ០២ ម៉ោង ថ្ងៃ... ទី... ខែ... ឆ្នាំ២០១...

**III. សម្ភារៈឧបទេស**

សៀវភៅគ្រូ

សៀវភៅសិស្ស

**IV. ដំណើរការមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យអវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ថ្នាក់រៀន | ជំហានទី ១<br>រដ្ឋបាលថ្នាក់ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| ចូរឲ្យនិយមន័យស្វ៊ីតរីក។ និង ស្វ៊ីតរួម។ | ជំហានទី ២<br>រំលឹកមេរៀន | ស្វ៊ីត $(a_n): a_1, a_2, a_3, \ldots, a_n, \ldots$ ជាស្វ៊ីតរីកខិតទៅរក $+\infty$ បើ $a_n$ មានលីមីត $+\infty$ ឬ |

| | | |
|---|---|---|
| | | $\lim_{n\to+\infty}(a_n)=+\infty$ ។<br>ស្វ៊ីត $(a_n): a_1, a_2, a_3, \ldots, a_n, \ldots$ ជាស្វ៊ីតរីកខិតទៅរក $-\infty$ បើ $a_n$ មានលីមីត $-\infty$ ឬ $\lim_{n\to+\infty} = -\infty$ ។<br>ស្វ៊ីតរួម<br>ស្វ៊ីត $(a_n): a_1, a_2, a_3, \ldots, a_n, \ldots$ ជាស្វ៊ីតរួមខិតទៅរកចំនួនពិត $\lambda$ បើ $\lim_{n\to+\infty} a_n = \lambda$ ។ |
| សរសេរទ្រឹស្តីបទគ្រឹះ និងពន្យល់<br>ទ្រឹស្តីបទគ្រឹះមានលក្ខណៈដូចនិងលីមីតដែល<br><br>ឲ្យសិស្សពិភាក្សាដោះស្រាយលំហាត់គំរូដោយប្រើទ្រឹស្តីបទគ្រឹះចំនុចថ្មី<br><br>សរសេរ និងពន្យល់ពីលក្ខណៈគ្រឹះ | ជំហានទី ៣<br>មេរៀនប្រចាំថ្ងៃ<br>**ជំពូកទី ១ លីមីតនៃស្វ៊ីត**<br>**មេរៀនទី ១ លីមីតនៃស្វ៊ីត**<br>**IIប្រមាណវិធីលើលីមីតនៃស្វ៊ីត**<br>**១. ទ្រឹស្តីបទគ្រឹះ**<br>គេមានស្វ៊ីត $(a_n)$ និង $(b_n)$ ដែលមាន $\lim_{n\to+\infty} a_n = M$ និង $\lim_{n\to+\infty} b_n = N$ គេបាន៖<br>▪ $\lim_{n\to+\infty} ka_n = kM$ ដែល $k$ ជាចំនួនថេរ<br>▪ $\lim_{n\to+\infty}(a_n+b_n) = M+N$ , $\lim_{n\to+\infty}(a_n-b_n) = M-N$<br>▪ $\lim_{n\to+\infty}(a_n b_{n)} = MN$ ,បើ $N \neq 0$ នោះ $\lim_{n\to+\infty}\frac{a_n}{b_n} = \frac{M}{N}$ ។<br><u>លំហាត់គំរូ</u> គណនាលីមីតនៃស្វ៊ីត<br>ក. $(u_n): u_n = \frac{3n+1}{n} + \frac{5}{n^2}$<br>**២. លក្ខណៈគ្រឹះ**<br>ឧបមាថា $a_n \le b_n$ ចំពោះលំដាប់ទី $n$ ដែលធំបង្គួរ។<br>▪ បើ $\lim_{n\to+\infty} a_n = \alpha$ និង $\lim_{n\to+\infty} b_n = \beta$ នោះ $\alpha \le \beta$ | កត់ត្រា និងស្តាប់<br>ដោះស្រាយលំហាត់គំរូ<br>តាង $v_n = \frac{3n+1}{n}$ និង $w_n = \frac{5}{n^2}$ គេបាន<br>$u_n = v_n + w_n = \frac{3n+1}{n} + \frac{5}{n^2}$<br>$v_n = \frac{3n+1}{n} = 3 + \frac{1}{n}$<br>ដោយ $\Rightarrow \lim_{n\to+\infty}\frac{3n+1}{n}$<br>$= \lim_{n\to+\infty} 3 + \frac{1}{n}$<br>$= 3$<br>និង $\lim_{n\to+\infty} w_n = \lim_{n\to+\infty}\frac{5}{n^2} = 0$<br>នោះ<br>$\lim_{n\to+\infty} u_n = \lim_{n\to+\infty} v_n + \lim_{n\to+\infty} w_n$<br>$= 3+0$<br>$= 3$<br>ដោះស្រាយលំហាត់គំរូ<br>ក.$u_n = \frac{1}{n}\sin\frac{n\pi}{6}$<br>ចំពោះ $\forall n \in \mathbb{N}$ គេមាន<br>$-1 \le \sin\frac{n\pi}{6} \le 1$ ហើយ<br>$-\frac{1}{n} \le \frac{1}{n}\sin\frac{n\pi}{6} \le \frac{1}{n}$<br>ដោយ $\lim_{n\to+\infty} -\frac{1}{n} = 0$ និង |

| | | |
|---|---|---|
| ដាក់លំហាត់គំរូឲ្យសិស្សអនុវត្តតាមលក្ខណៈគ្រឹះ<br><br>ដាក់សំគាល់ និងពន្យល់<br><br>ដាក់ឧទាហរណ៍ឲ្យសិស្សរកតួរបស់ស៊ីតដោយប្រើ $r=2$ និង $r=\frac{1}{3}$<br><br>ពន្យល់ប្រាប់សិស្សថា ស៊ីតធរណីមាត្រដែលមានតួច្រើនអនន្ត ជាស៊ីតអនន្ត។ | ▪ បើ $\lim\limits_{n\to+\infty} a_n=+\infty$ នោះ $\lim\limits_{n\to+\infty} b_n=+\infty$<br>▪ ឧបមាថា $a_n\le b_n\le c_n$ ចំពោះលំដាប់ទី $n$ ដែលធំបង្គួរ បើ $\lim\limits_{n\to+\infty} a_n=\lim\limits_{n\to+\infty} c_n=\alpha$ នោះ $\lim\limits_{n\to+\infty} b_n=\alpha$ ។<br><u>លំហាត់គំរូ</u> គណនាលីមីតនៃស៊ីត $(u_n)$ ដែលកំណត់ដោយ<br>ក. $u_n=\frac{1}{n}\sin\frac{n\pi}{6}$<br>ខ. $u_n=\frac{n+(-1)^n}{2n}$<br><u>សំគាល់</u><br>ក្នុងលក្ខណៈ ១ ខាងលើមិនអាចថា $a_n<b_n$ បានទេទោះ $a_n<b_n$ ពិតគ្រប់ $n$ ក៏ដោយ។<br>**III លីមីតនៃស៊ីតធរណីមាត្រ**<br>**១. សញ្ញាណស៊ីតធរណីមាត្រអនន្ត**<br><u>ឧទាហរណ៍១៖</u><br>គេមានស៊ីត $(r^n)$ ជាស៊ីតធរណីមាត្រអនន្ត ដែលមានតួទីមួយ $r$ និងផលធៀបរួម $r$ ។<br>បើ $r=2$ នោះគេបានស៊ីតធរណីមាត្រអនន្ត $2,4,8,16,\ldots$ ដែលជាស៊ីតរីកទៅរក $+\infty$ ។<br>បើ $r=\frac{1}{3}$ នោះគេបានស៊ីតធរណីមាត្រអនន្ត $\frac{1}{3},\frac{1}{9},\frac{1}{27},\frac{1}{81},\cdots$ ជាស៊ីតរួមទៅរក $0$ ។ | $\lim\limits_{n\to+\infty}\frac{1}{n}=0$<br>គេបាន<br>$\lim\limits_{n\to+\infty}u_n=\lim\limits_{n\to+\infty}\frac{1}{n}\sin\frac{n\pi}{6}=0$<br><br>ខ. $u_n=\frac{n+(-1)^n}{2n}$<br>ចំពោះ $\forall n\in\mathbb{N}$ គេមាន $-1\le(-1)^n\le1$ ហើយ<br>$\frac{n-1}{2n}\le u_n\le\frac{n+1}{2n}$<br>ដោយ $\lim\limits_{n\to+\infty}\frac{n-1}{2n}=\frac{1}{2}$ និង $\lim\limits_{n\to+\infty}\frac{n+1}{2n}=\frac{1}{2}$<br>គេបាន<br>$\lim\limits_{n\to+\infty}u_n=\lim\limits_{n\to+\infty}\frac{n+(-1)^n}{2n}=\frac{1}{2}$<br><br>កត់ត្រា និង ស្តាប់<br>ចំពោះ $r=2$ គេបាន $(r^n)$ គឺ<br>$n=1,r^1=2^1=2$<br>$n=2,r^2=2^2=4$<br>$n=3,r^3=2^3=8$<br>$n=4,r^4=2^4=16$<br>ចំពោះ $r=\frac{1}{3}$ គេបាន $(r^n)$ គឺ<br>$n=1,r^1=(\frac{1}{3})^1=\frac{1}{3}$<br>$n=2,r^2=\frac{1}{9}$<br>$n=3,r^3=\frac{1}{27}$<br>$n=4,r^4=\frac{1}{81}$ |
| ចូរពណ៌នាអំពីលក្ខណៈគ្រឹះនៃប្រមាណវិធីលើលីមីតនៃ | ជំហានទី ៤<br>ពង្រឹងពុទ្ធិ | ពិភាក្សាហើយឆ្លើយនិងសំនួរ<br>ឧបមាថា $a_n\le b_n$<br>ចំពោះលំដាប់ទី $n$ |

| | | |
|---|---|---|
| ស៊ីត។ | | ដែលធំបង្គួរ។<br>▪ បើ $\lim_{n\to+\infty} a_n = \alpha$ និង $\lim_{n\to+\infty} b_n = \beta$ នោះ $\alpha \le \beta$<br>▪ បើ $\lim_{n\to+\infty} a_n = +\infty$ នោះ $\lim_{n\to+\infty} b_n = +\infty$<br>▪ ឧបមាថា $a_n \le b_n \le c_n$ ចំពោះលំដាប់ទី $n$ ដែលធំបង្គួរ បើ $\lim_{n\to+\infty} a_n = \lim_{n\to+\infty} c_n = \alpha$ នោះ $\lim_{n\to+\infty} b_n = \alpha$ ។ |
| ពេលត្រឡប់ទៅផ្ទះវិញ ធ្វើលំហាត់ប្រតិបត្តិនៅទំព័រទី០៥ត្រង់ចំនុចលក្ខណៈគ្រឹះ | ជំហានទី ៥<br>បណ្តាំផ្ញើរ | កត់ត្រា នឹងធ្វើតាម |

# កិច្ចតែងការបង្រៀន

## ជំពូកទី ១ លីមីតនៃស៊ីត

## មេរៀនទី ១ លីមីតនៃស៊ីត

### III. លីមីតនៃស៊ីតធរណីមាត្រ

### ២. លីមីតស៊ីតធរណីមាត្រអនន្ត

### IV. លីមីតនៃស៊េរី

### ១. ស៊េរីអនន្ត

### ២. ស៊េរីរួមនិងស៊េរីរីក

**I. វត្ថុបំណងនៃមេរៀន ៖** ក្រោយពីរៀនចប់សិស្សមាន

- ចំណេះដឹង : កំណត់សញ្ញាណនៃស៊ីតធរណីមាត្រអនន្ត និងស៊េរីអនន្តបានត្រឹមត្រូវតាមរយៈឧទាហរណ៍
- បំនិន : គណនាលីមីតស៊ីតធរណីមាត្រ និងស្រាយបញ្ជាក់ស៊េរីរួម និងស៊េរីរីកបានត្រឹមត្រូវ
- ឥរិយាបថ : សហការគ្នាដោះស្រាយលំហាត់

**II. ពេលវេលា** ០២ ម៉ោង ថ្ងៃ... ទី... ខែ... ឆ្នាំ២០១...

**III. សម្ភារៈឧបទេស**

សៀវភៅគ្រូ

សៀវភៅសិស្ស

**IV. ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យអវត្តមានអនាម័យនិងសណ្តាប់ធ្នាប់ថ្នាក់រៀន | ជំហានទី ១<br>រដ្ឋបាលថ្នាក់ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| ចូរពណ៌នាពីទ្រឹស្តីគ្រឹះលើប្រមាណវិធីនៃលីមីត | ជំហានទី ២<br>រំលឹកមេរៀន | គេមានស៊ីត$(a_n)$ និង $(b_n)$ ដែលមាន $\lim_{n\to+\infty} a_n = M$ និង |

| | | |
|---|---|---|
| ស្វ៊ីត | | $\lim\limits_{n\to+\infty} b_n = N$ គេបាន៖<br>▪ $\lim\limits_{n\to+\infty} ka_n = kM$ ដែល $k$ ជាចំនួនថេរ<br>▪ $\lim\limits_{n\to+\infty}(a_n + b_n) = M + N$ ,<br>$\lim\limits_{n\to+\infty}(a_n - b_n) = M - N$<br>$\lim\limits_{n\to+\infty}(a_n b_n) = MN$ ,បើ $N \neq 0$<br>នោះ $\lim\limits_{n\to+\infty}\dfrac{a_n}{b_n} = \dfrac{M}{N}$ |
| ឲ្យសិស្សសង្កេតលើករណីទាំងបួនរបស់ស្វ៊ីត $(r^n)$<br><br>ឲ្យសិស្សគនទាលីមីតស្វ៊ីត $(r^n)$ តាមករណីនីមួយៗរបស់ $r$ | ជំហានទី ៣<br>មេរៀនប្រចាំថ្ងៃ<br>**ជំពូកទី ១ លីមីតនៃស្វ៊ីត**<br>**មេរៀនទី ១ លីមីតនៃស្វ៊ីត**<br>**III លីមីតនៃស្វ៊ីតធរណីមាត្រ**<br>**២. លីមីតស្វ៊ីតធរណីមាត្រអនន្ត**<br>គេសិក្សាលីមីតនៃស្វ៊ីតធរណីមាត្រអនន្ត $(r^n)$ ទៅតាមករណីដូចខាងក្រោម៖<br>ក. ករណី $r > 1$ កាលណា $n \to +\infty$ គេបាន $\lim\limits_{n\to+\infty} r^n = +\infty$<br>ខ. ករណី $r = 1$, $\lim\limits_{n\to+\infty} r^n = 1$<br>ព្រោះគ្រប់តួនៃស្វ៊ីតស្មើនឹង 1។<br>គ. ករណី $\|r\| < 1$<br>+ បើ $r = 0$ នោះគេបាន $\lim\limits_{n\to+\infty} r^n = 0$ ព្រោះគ្រប់តួនៃស្វ៊ីតសុទ្ធតែស្មើនឹង 0 ។<br>+ បើ $r \neq 0$ នោះគេយក $S = \dfrac{1}{\|r\|}$ ហើយគេទាញបាន $s > 1$ តាមករណី ក. គេបាន $\lim\limits_{n\to+\infty} s^n = +\infty$ ។ ដូចនេះ<br>$\lim\limits_{n\to+\infty}\|r^n\| = \lim\limits_{n\to+\infty}\|r\|^n = \lim\limits_{n\to+\infty}\dfrac{1}{s^n} = 0$ ។ | កត់ត្រា សង្កេត<br><br>ពិភាក្សារកលីមីតនៃស្វ៊ីត<br>ក. ករណី $r > 1$ គេបាន $\lim\limits_{n\to+\infty} r^n = +\infty$<br>ខ. ករណី $r = 1$, $\lim\limits_{n\to+\infty} r^n = 1$<br>ព្រោះគ្រប់តួនៃស្វ៊ីតស្មើនឹង 1។<br>គ. ករណី $\|r\| < 1$<br>បើ $r = 0$ គេបាន $\lim\limits_{n\to+\infty} r^n = 0$ ព្រោះគ្រប់តួនៃស្វ៊ីតសុទ្ធតែស្មើនឹង 0 ។<br>បើ $r \neq 0$ គេយក $S = \dfrac{1}{\|r\|}$ គេទាញបាន $s > 1$ តាមករណី ក. គេបាន $\lim\limits_{n\to+\infty} s^n = +\infty$ ។ ដូចនេះ៖<br>$\lim\limits_{n\to+\infty}\|r^n\| = \lim\limits_{n\to+\infty}\|r\|^n = \lim\limits_{n\to+\infty}\dfrac{1}{s^n} = 0$ ។ $\lim\limits_{n\to+\infty} r^n = 0$ កាលណា $\|r\| < 1$ ។<br>ឃ.ករណី $r \leq -1$ |

| | | |
|---|---|---|
| | $\lim\limits_{n\to+\infty} r^n = 0$ កាលណា $\lvert r\rvert<1$។<br>ឃ.ករណី $r\le -1$<br>កាលណា $r\le -1$ សញ្ញានៃ $r^n$ ផ្លាស់ប្តូរឆ្លាស់គ្នាតាម $n$ ជាចំនួនគូ ឬសេស និងតម្លៃដាច់ខាតវាកើនធំទៅៗ។ដូចនេះស្វ៊ីត $(r^n)$ ជាស្វ៊ីតឆ្លាស់គ្នា។<br>គេបានតារាងសង្ខេបដូចខាងក្រោម៖ | កាលណា $r\le -1$ សញ្ញានៃ $r^n$ ផ្លាស់ប្តូរឆ្លាស់គ្នាតាម $n$ ជាចំនួនគូ ឬសេស។ |
| សង្ខេបករណីទាំងបួនដាក់ក្នុងតារាង | លីមីតនៃស្វ៊ីត $(r^n)$<br>- បើ $r>1$ នោះ $\lim\limits_{n\to+\infty} r^n=+\infty$ ហើយ $(r^n)$ ជាស្វ៊ីតរីកទៅរក $+\infty$ ។<br>- បើ $r=1$ នោះ $(r^n)$ ជាស្វ៊ីតថេរ ហើយ $\lim\limits_{n\to+\infty} r^n=1$។<br>- បើ $r=0$ នោះ $(r^n)$ ជាស្វ៊ីតថេរ ហើយ $\lim\limits_{n\to+\infty} r^n=0$។<br>- បើ $0<\lvert r\rvert<1$ នោះ $\lim\limits_{n\to+\infty} r^n=0$ ហើយ $(r^n)$ ជាស្វ៊ីតរួមទៅរក $0$<br>- បើ $r\le -1$ នោះស្វ៊ីត $(r^n)$ ជាស្វ៊ីតឆ្លាស់ ហើយកាលណា $n\to+\infty$ គេមិនអាចកំណត់លីមីតនៃ $(r^n)$ បានទេ។ | កត់ត្រា និងសង្កេតលើតារាង |
| ចូលចំនុចថ្មី ឲ្យគេពិនិត្យស្វ៊ីតធរណីមាត្រនិងឲ្យរកផលបូកនៃស្វ៊ីតនេះ | **IV លីមីតនៃស៊េរី**<br>**១. ស៊េរីអនន្ត**<br>គេពិនិត្យមើលផលបូកនៃស្វ៊ីតធរណីមាត្រអនន្ត ដែលមានតួទីមួយ $\frac{1}{2}$ និងផលធៀបរួម $\frac{1}{2}$ ។ គេបាន $\frac{1}{2}+\frac{1}{4}+\frac{1}{8}+\frac{1}{16}+\cdots$ ដែលជាផលបូកតួស្វ៊ីតធរណីមាត្រអនន្ត។ ផលបូកតួនៃស្វ៊ីត | ពិនិត្យស្វ៊ីតធរណីមាត្រហើយរកផលបូកនៃស្វ៊ីត |

| | | |
|---|---|---|
| ប្រាប់សិស្សថាស៊េរីជាផលបូកតួនៃស្វ៊ីតអនន្ត។ <br><br> ទាញនិយមន័យឲ្យសិស្ស <br><br> ចំនុចទីពីរ <br> **២. ស៊េរីរួមនិងស៊េរីរីក** <br> ចំនុច(ក) <br> ដាក់ឧទាហរណ៍ឲ្យសិស្សពិភាក្សា <br><br> គេអាចសន្និដ្ឋានថាស៊េរីមួយរួមដោយសិក្សាលើផលបូកដោយផ្នែកនៃស៊េរីនោះ។ | អនន្តនេះហៅថាស៊េរីអនន្ត។គេកំណត់សរសេរ <br> $\sum_{n=1}^{\infty}\left(\frac{1}{2}\right)^n=\frac{1}{2}+\frac{1}{4}+\frac{1}{8}+\frac{1}{16}+\cdots$ <br> <u>និយមន័យ</u> <br> ស៊េរីអនន្ត <br> $\sum_{n=1}^{\infty}a_n=a_1+a_2+a_3+\cdots+a_n+\cdots$ <br> គឺជាផលបូកតួនៃស្វ៊ីតអនន្ត$(a_n)$។ <br> បើគេយក $S_n=a_1+a_2+a_3+\cdots+a_n$ <br> នោះ $S_n$ ហៅថាផលបូកដោយផ្នែកនៃស៊េរី។ <br> **២. ស៊េរីរួមនិងស៊េរីរីក** <br> **ក. ស៊េរីរួម** <br> <u>ឧទាហរណ៍</u>៖ គេមានស៊េរីអនន្តមួយ $S=\sum_{n=1}^{\infty}\left(\frac{1}{2}\right)^{n-1}$ <br> $=1+\frac{1}{2}+\left(\frac{1}{2}\right)^2+\left(\frac{1}{2}\right)^3+\cdots+\left(\frac{1}{2}\right)^{n-1}+\cdots$ <br> មានផលបូកដោយផ្នែក <br> $S_n=1+\frac{1}{2}+\left(\frac{1}{2}\right)^2+\cdots+\left(\frac{1}{2}\right)^{n-1}$ <br> $=2\left(1-\left(\frac{1}{2}\right)^n\right)$ <br> គេបាន $\lim_{n\to+\infty}S_n=2(1-0)=2$ ។ <br> ស្វ៊ីត$(S_n)$រួមទៅរក $2$ ។ <br> ដូចនេះ ផលបូកនៃស៊េរីអនន្ត $S$ ស្មើនិង $2$ ។ <br> ចំពោះស៊េរីអនន្ត $\sum_{n=1}^{\infty}a_n$ មានផលបូកដោយផ្នែកទី $n$ គឺ <br> $(S_n)=a_1+a_2+a_3+\cdots+a_n$ ។ <br> បើស្វ៊ីតនៃផលបូកដោយផ្នែក$(S_n)$ រួមទៅ $S$ គេថាស៊េរី $\sum_{n=1}^{\infty}a_n$ ជាស៊េរី | សង្កេតលើឧទាហរណ៍ <br> ទាញសន្និដ្ឋានពីស៊េរីរួម |

| | | |
|---|---|---|
| | រួម។ លីមីត $S$ ហៅថាផលបូកនៃស៊េរី។<br>**ខ. ស៊េរីរីក**<br>ទ្រឹស្តីបទ៖ ចំពោះស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$<br>- បើស៊េរី $\sum_{n=1}^{\infty} a_n$ ជាស៊េរីរួមនោះ $\lim\limits_{n\to+\infty} a_n = 0$<br>- បើស្វ៊ីត $(a_n)$ មិនរួមរក $0$ នោះ $\sum_{n=1}^{\infty} a_n$ ជាស៊េរីរីក។ | កត់ត្រា និងស្តាប់ |
| ចំនុច(ខ) | | |
| ដាក់ទ្រឹស្តីបទនិងធ្វើសម្រាយបញ្ជាក់ | សម្រាយបញ្ជាក់<br>▪ ឧបមាស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$ រួម។ តាង $S = \sum_{n=1}^{\infty} a_n$ និង $S_n$ ជាផលបូក $n$ តួនៃស៊េរីនេះ។<br>គេបាន<br>$S = \sum_{n=1}^{\infty} a_n = a_1 + a_2 + a_3 + \cdots + a_n$<br>$= S_{n-1} + a_n$<br>ដូចនេះ $a_n = S_n - S_{n-1}$<br>គេបាន $\lim\limits_{n\to+\infty} a_n = \lim\limits_{n\to+\infty}(S_n - S_{n-1})$<br>$= S - S = 0$<br>ដូចនេះបើស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$ រួមនោះ $\lim\limits_{n\to+\infty} a_n = 0$ ។<br>▪ សំណើផ្ទុយពីសំណើទីមួយ គឺ បើ $\lim\limits_{n\to+\infty} a_n \neq 0$ នោះស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$ រីក។<br>ដោយសំណើក្នុងសំនួរទីមួយពិតនាំឲ្យសំណើផ្ទុយរបស់វាក៏ពិតដែរ។ដូច្នេះ គេសន្និដ្ឋានបានថាបើ $a_n$ មិនរួមទៅរក $0$ នោះស៊េរី $\sum_{n-1}^{\infty} a_n$ រីក។ | ពិភាក្សា និងដោះស្រាយស៊េរី $\frac{1}{\sqrt{2}+1}+\frac{1}{\sqrt{3}+\sqrt{2}}+\cdots+\frac{1}{\sqrt{n+1}+\sqrt{n}}$ តួទី $n$ អាចសរសេរ |

| | | |
|---|---|---|
| ដាក់លំហាត់គំរូឲ្យសិស្សពិភាក្សា នឹងដោះស្រាយ | <u>លំហាត់គំរូ</u> ក្នុងស៊េរីមិនកំណត់ $\frac{1}{\sqrt{2}+1}+\frac{1}{\sqrt{3}+\sqrt{2}}+\cdots+\frac{1}{\sqrt{n+1}+\sqrt{n}}$ ។តើស៊េរីនេះជាស៊េរីរួមឬស៊េរីរីក? | $\frac{1}{\sqrt{n+1}+\sqrt{n}}=\sqrt{n+1}-\sqrt{n}$ <br> នោះផលបូក $n$ តួដំបូងគឺ <br> $S_n=(\sqrt{2}-1)+(\sqrt{3}-\sqrt{2})+\cdots+(\sqrt{n+1}-\sqrt{n})$ <br> $=\sqrt{n+1}-1$ <br> គេបាន <br> $\lim_{n\to+\infty} S_n=\lim_{n\to+\infty}\left(\sqrt{n+1}-1\right)=+\infty$ <br> ដូចនេះស៊េរីនេះជាស៊េរីរីក។ |
| ចូរពណ៌នាពីទ្រឹស្តីបទនៃស៊េរីរីក។ | ជំហានទី ៤ <br> ពង្រឹងពុទ្ធិ | <u>ទ្រឹស្តីបទ៖</u> ចំពោះស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$ <br> ✚ បើស៊េរី $\sum_{n=1}^{\infty} a_n$ ជាស៊េរីរួមនោះ $\lim_{n\to+\infty} a_n=0$ <br> ✚ បើស្វ៊ីត $(a_n)$ មិនរួមរក $0$ នោះ $\sum_{n=1}^{\infty} a_n$ ជាស៊េរីរីក។ |
| ពេលទៅផ្ទះធ្វើលំហាត់ទី ០៦ (ក) និង(ឃ)នៅទំព័រទី១៦។ | ជំហានទី ៥ <br> បណ្តាំផ្ញើ | កត់ត្រានិងធ្វើតាម |

# កិច្ចតែងការបង្រៀន

## ជំពូកទី ១ លីមីតនៃស្វ៊ីត

## មេរៀនទី ១ លីមីតនៃស្វ៊ីត

### IV. លីមីតនៃស៊េរី

### ៣. ស៊េរីធរណីមាត្រអនន្ត

### ៤. លក្ខណៈនៃស៊េរីអនន្ត

### V. អនុវត្តន៍

### ១. ចំនួនទសភាគខួប

I. **វត្ថុបំណងនៃមេរៀន ៖** ក្រោយពីរៀនចប់សិស្សមាន

- ចំណេះដឹង : បង្ហាញពីលក្ខណៈនៃស៊េរីអនន្ត និងគណនាលីមីតស៊េរីធរណីមាត្រអនន្ត បានត្រឹមត្រូវ។
- បំនិន : សរសេរពីចំនួនទសភាគទៅជាចំនួនសនិទានបានត្រឹមត្រូវ
- ឥរិយាបថ : សហកាគ្នាដោះស្រាយលំហាត់

II. **ពេលវេលា** ០២ ម៉ោងថ្ងៃ... ទី... ខែ... ឆ្នាំ២០១...

III. **សម្ភារៈឧបទេស**

សៀវភៅគ្រូ

សៀវភៅសិស្ស

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យអវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ថ្នាក់រៀន | ជំហានទី ១ រដ្ឋបាលថ្នាក់ | ប្រធានថ្នាក់ឡើងរាយការណ៍ |
| ចូរពណ៌នាពីទ្រឹស្តីបទនៃស៊េរីរីក។ | ជំហានទី ២ រំលឹកមេរៀន | <u>ទ្រឹស្តីបទ៖</u> ចំពោះស៊េរីអនន្ត $\sum_{n=1}^{\infty} a_n$<br>✚ បើស៊េរី $\sum_{n=1}^{\infty} a_n$ ជាស៊េរីរួមនោះ |

| | | |
|---|---|---|
| | | $\lim_{n\to+\infty} a_n = 0$<br>បើស៊ីត $(a_n)$ មិនរួមរក $0$ នោះ $\sum_{n=1}^{\infty} a_n$ ជាស៊េរីរីក។ |
| -ដាក់និយមន័យនៃស៊េរីធរណីមាត្រអនន្ត | ជំហានទី ៣<br>មេរៀនប្រចាំថ្ងៃ<br>**ជំពូកទី ១ លីមីតនៃស៊ីត**<br>**មេរៀនទី ១ លីមីតនៃស៊ីត**<br>**IV លីមីតនៃស៊េរី**<br>**៣. ស៊េរីធរណីមាត្រអនន្ត**<br>ក. និយមន័យ<br>ស៊េរីធរណីមាត្រអនន្តគឺជាស៊េរីអនន្តដែលកំណត់ដោយ<br>$\sum_{n=1}^{\infty} ar^{n-1} = a + ar + ar^2 + \cdots$<br>ដែលមានតួទីមួយ $a \neq 0$ និងផលធៀបរួម $r$ ។ | -កត់ត្រានិងស្ដាប់<br>ក. និយមន័យ<br>ស៊េរីធរណីមាត្រអនន្តគឺជាស៊េរីអនន្តដែលកំណត់ដោយ<br>$\sum_{n=1}^{\infty} ar^{n-1} = a + ar + ar^2 + \cdots$<br>ដែលមានតួទីមួយ $a \neq 0$ និងផលធៀបរួម $r$ ។ |
| -សិក្សាពីភាពរួមនិងរីកនៃស៊េរីធរណីមាត្រ<br>-គ្រូសិស្សពិភាក្សាលើលក្ខខណ្ឌនីមួយៗរបស់ $a$<br>• $a = 0$<br>• $a \neq 0$<br>-អោយសិស្សពិភាក្សាពីលក្ខខណ្ឌនៃ $r$ និងគណនាលីមីត<br>• $\|r\| < 1$<br>• $\|r\| > 1$<br>• $r = 1$<br>• $r = -1$ | ខ. ភាពរួមនិងរីនៃស៊េរីធរណីមាត្រ<br>គេមានស៊េរីអនន្ត $\sum_{n=1}^{\infty} ar^{n-1}$<br>-បើ $a = 0$ នោះគេបាន<br>$\sum_{n=1}^{\infty} ar^{n-1} = 0$<br>-បើ $a \neq 0$ នោះគេបាន $S_n$ ជាផលបូកដោយផ្នែកទី $n$ នៃស៊េរីធរណីមាត្រនោះករណី $r \neq 0$ គេបាន<br>$S_n = a + ar + \ldots + ar^{n-1}$<br>$= \frac{a(1-r^n)}{1-r}$<br>-បើ $\|r\| < 1$ នោះគេបាន | -ពិភាក្សា<br>-បើ $a = 0$ នោះគេបាន<br>$\sum_{n=1}^{\infty} ar^{n-1} = 0$<br>-បើ $a \neq 0$ នោះគេបាន $S_n$ ជាផលបូកដោយផ្នែកទី $n$ នៃស៊េរីធរណីមាត្រនោះករណី $r \neq 0$ គេបាន<br>$S_n = a + ar + \ldots + ar^{n-1}$<br>$= \frac{a(1-r^n)}{1-r}$<br>-បើ $\|r\| < 1$ នោះគេបាន<br>$\lim_{n\to+\infty} r^n = 0$ ហើយ |

| | | |
|---|---|---|
| -ធ្វើការសង្ខេបលើការសិក្សា | $\lim\limits_{n\to+\infty} r^n = 0$ ហើយ<br>$\lim\limits_{n\to+\infty} S_n = \lim\limits_{n\to+\infty} \frac{a(1-r^n)}{1-r}$<br>$= \frac{a}{1-r}$<br>-បើ $\|r\| > 1$ នោះគេបានស្វ៊ីត $(ar^{n-1})$ រីកហើយស្វ៊ីត $S_n$ ក៏រីកដែរ<br>-បើ $r = 1$ នោះគេបាន:<br>$S_n = a + a + \ldots + a = na$<br>$S_n = na$ និង $a \neq 0$ ហើយស្វ៊ីត $(S_n)$ រីក។<br>-បើ $r = -1$ នោះ $S_n = a$ រឺ $S_n = 0$<br>គេបានតារាងសង្ខេប<br>គ្រប់ស៊េរីធរណីមាត្រអនន្ត<br>$a + ar + ar^2 + \ldots + ar^{n-1} + \ldots$<br>ដែល $(a \neq 0)$ ជាស៊េរីរួមឬរីកទៅតាមករណីដូចខាងក្រោម៖<br>-បើ $\|r\| < 1$ នោះស៊េរីរួមទៅរក $\frac{a}{1-r}$<br>-បើ $\|r\| \geq 1$ នោះស៊េរីរីក។ | $\lim\limits_{n\to+\infty} S_n = \lim\limits_{n\to+\infty} \frac{a(1-r^n)}{1-r}$<br>$= \frac{a}{1-r}$<br>-បើ $\|r\| > 1$ នោះគេបានស្វ៊ីត $(ar^{n-1})$ រីកហើយស្វ៊ីត $S_n$ ក៏រីកដែរ<br>-បើ $r = 1$ នោះគេបាន:<br>$S_n = a + a + \ldots + a = na$<br>$S_n = na$ និង $a \neq 0$ ហើយស្វ៊ីត $(S_n)$ រីក។<br>-បើ $r = -1$ នោះ $S_n = a$ រឺ $S_n = 0$<br>គេបានតារាងសង្ខេប<br>គ្រប់ស៊េរីធរណីមាត្រអនន្ត<br>$a + ar + ar^2 + \ldots + ar^{n-1} + \ldots$<br>ដែល $(a \neq 0)$ ជាស៊េរីរួមឬរីកទៅតាមករណីដូចខាងក្រោម៖<br>-បើ $\|r\| < 1$ នោះស៊េរីរួមទៅរក $\frac{a}{1-r}$<br>-បើ $\|r\| \geq 1$ នោះស៊េរីរីក។ |
| -ប្រាប់សិស្សថាលក្ខណៈនៃស៊េរីមានលក្ខណៈដូចគ្នានិងទ្រឹស្តីបទគ្រឹះនៃស្វ៊ីតអនន្តចំពោះប្រមាណវិធីបូកនិងដក | **៤. លក្ខណៈនៃស៊េរីអនន្ត**<br>បើស៊េរី $\sum\limits_{n=1}^{\infty} a_n = \alpha$ និង $\sum\limits_{n=1}^{\infty} b_n = \beta$ ជាស៊េរីរួម គេបាន៖<br>• $\sum\limits_{n=1}^{\infty} ka_n = k\sum\limits_{n=1}^{\infty} a_n = k\alpha$ , $k$ ជាចំនួនថេរ<br>• $\sum\limits_{n=1}^{\infty}(a_n + b_n) = \sum\limits_{n=1}^{\infty} a_n + \sum\limits_{n=1}^{\infty} b_n$<br>$= \alpha + \beta$<br>• $\sum\limits_{n=1}^{\infty}(a_n + b_n) = \sum\limits_{n=1}^{\infty} a_n - \sum\limits_{n=1}^{\infty} b_n$<br>$= \alpha - \beta$<br>ឧទាហរណ៍៖ រកផលបូកនៃស៊េ | -សិស្សសង្កេត និងកត់ត្រា<br>បើស៊េរី $\sum\limits_{n=1}^{\infty} a_n = \alpha$ និង $\sum\limits_{n=1}^{\infty} b_n = \beta$ ជាស៊េរីរួម គេបាន៖<br>• $\sum\limits_{n=1}^{\infty} ka_n = k\sum\limits_{n=1}^{\infty} a_n = k\alpha$ , $k$ ជាចំនួនថេរ<br>• $\sum\limits_{n=1}^{\infty}(a_n + b_n) = \sum\limits_{n=1}^{\infty} a_n + \sum\limits_{n=1}^{\infty} b_n$<br>$= \alpha + \beta$<br>• $\sum\limits_{n=1}^{\infty}(a_n + b_n) = \sum\limits_{n=1}^{\infty} a_n - \sum\limits_{n=1}^{\infty} b_n$<br>$= \alpha - \beta$ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍អោយសិស្សពិភាក្សា | វិអនន្ត $\sum_{n=1}^{\infty}\left(\frac{3}{2^n}+\frac{2}{3^n}\right)$។ <br> **ចម្លើយ** <br> ដោយ $\sum_{n=1}^{\infty}\frac{3}{2^n}$ ជាស៊េរីធរណីមាត្រអនន្តដែលមានតួទីមួយស្មើនឹង $\frac{3}{2}$ និងផលធៀបរួម $\frac{1}{2}$ និង $\sum_{n=1}^{\infty}\frac{2}{3^n}$ ជាស៊េរីធរណីមាត្រអនន្តដែលមានតួទីមយយស្មើនឹង $\frac{2}{3}$ និងមានផលធៀបរួម $\frac{1}{3}$ និងដោយ $\|r\|<1$ នោះស៊េរីធរណីមាត្រទាំងពីរជាស៊េរីរួម។ <br> គេបាន <br> $S=\sum_{n=1}^{\infty}\left(\frac{3}{2^n}+\frac{2}{3^n}\right)$ <br> $=\sum_{n=1}^{\infty}\frac{3}{2^n}+\sum_{n=1}^{\infty}\frac{2}{3^n}$ <br> $=\frac{\frac{3}{2}}{1-\frac{1}{2}}+\frac{\frac{3}{2}}{1-\frac{1}{3}}$ <br> $=3+1=4$ | -សិស្សពិភាក្សា <br> គេបាន <br> $S=\sum_{n=1}^{\infty}\left(\frac{3}{2^n}+\frac{2}{3^n}\right)$ <br> $=\sum_{n=1}^{\infty}\frac{3}{2^n}+\sum_{n=1}^{\infty}\frac{2}{3^n}$ <br> $=\frac{\frac{3}{2}}{1-\frac{1}{2}}+\frac{\frac{3}{2}}{1-\frac{1}{3}}$ <br> $=3+1=4$ |
| -ប្រាប់សិស្សនូវហេតុផលនៃចំនួនទសភាគខួបនិងភាពខុសគ្នានៃចំនួនទសភាគកំណត់និងចំនួនទសភាគខួប <br> -ដាក់ឧទាហរណ៍ពីចំនួនទសភាគខួបនិងចំនួនទសភាគកំណត់ <br> -ប្រាប់សិស្សថាចំនួនទសភាគ | V. **អនុវត្តន៍** <br> 1. **ចំនួនទសភាគខួប** <br> គ្រប់ចំនួនសនិទានគឺជាចំនួនទសភាគកំណត់ឬជាចំនួនទសភាគខួប។ <br> ឧទាហរណ៍: <br> ចំនួនទសភាគកំណត់ <br> $\frac{1}{4}=0.25$ , $\frac{1}{2}=0.5$ <br> ចំនួនទសភាគខួប <br> $\frac{1}{3}=0.333\ldots$ , $\frac{5}{6}=0.8333\ldots$ <br> គ្រប់ចំនួនទសភាគខួបតាង | -ស្តាប់ សង្កេតនិងកត់ត្រា <br> គ្រប់ចំនួនសនិទានគឺជាចំនួនទសភាគកំណត់ឬជាចំនួនទសភាគខួប។ <br> ឧទាហរណ៍: <br> ចំនួនទសភាគកំណត់ <br> $\frac{1}{4}=0.25$ , $\frac{1}{2}=0.5$ <br> ចំនួនទសភាគខួប <br> $\frac{1}{3}=0.333\ldots$ , $\frac{5}{6}=0.8333\ldots$ <br> គ្រប់ចំនួនទសភាគខួបតាង <br> ដោយចំនួនសនិទានដែលអាច |

| | | |
|---|---|---|
| ខូបបានមកពីផលបូកនៃស៊ីត ធរណីមាត្រអនន្ត។<br><br>-ដាក់ឧទាហរណ៍អោយសិស្ស សរសេរពីចំនួនទសភាគខួបទៅ ជាប្រភាគសនិទានដោយប្រើ ស៊េរីធរណីមាត្រអនន្ត | ដោយចំនួនសនិទានដែលអាច អនុវត្តន៍តាមស៊េរីធរណីមាត្រ អនន្ត។<br>ឧទាហរណ៍:<br>$0.\overline{39} = 0.393939\ldots$<br>$= 0.39 + 0.0039$<br>$+ 0.000039 + \ldots$<br>តាងអង្គទាំងពីរនៃស៊េរីធរណី មាត្រអនន្តមានតួនាទីមួយ $0.39$ និងផលធៀបរួម $0.01$ ។<br>គេបាន<br>$0.\overline{39} = \dfrac{0.39}{1-0.01} = \dfrac{39}{99} = \dfrac{13}{33}$ | អនុវត្តន៍តាមស៊េរីធរណីមាត្រ អនន្ត។<br>-ពិភាក្សាដោះស្រាយ<br>$0.\overline{39} = 0.393939\ldots$<br>$= 0.39 + 0.0039$<br>$+ 0.000039 + \ldots$<br>$= \dfrac{39}{100} + \dfrac{39}{(100)^2}$<br>$+ \dfrac{39}{(100)^3} + \cdots$<br>$= \dfrac{0.39}{1-0.01} = \dfrac{0.39}{0.99}$<br>$= \dfrac{39}{99} = \dfrac{13}{33}$ |
| -កំណត់និយមន័យនៃស៊េរី ធរណីមាត្រអនន្ត។<br><br>-ចូរប្រាប់ពីភាពរួមនិងភាពរីកនៃ ស៊េរីធរណីមាត្រ។ | ជំហានទី៤<br>ពង្រឹងពុទ្ធិ | -ស៊េរីធរណីមាត្រអនន្តគឺជាស៊េរី អនន្តដែលកំណត់ដោយ:<br>$\sum_{n=1}^{\infty} ar^{n-1} = a + ar + ar^2 + \ldots$<br>ដែលមានតួទីមួយ $a \neq 0$ និង ផលធៀបរួម $r$ ។<br>-ភាពរួមនិងភាពរីនៃស៊េរីធរណី មាត្រ៖<br>គ្រប់ស៊េរីធរណីមាត្រអនន្ត<br>$a + ar + ar^2 + \ldots + ar^{n-1} + \ldots$<br>ដែល $(a \neq 0)$ ជាស៊េរីរួមឬរីកទៅ តាមករណីខាងក្រោម៖<br>-បើ $\lvert r\rvert < 1$ នោះស៊េរីរួមទៅរក $\dfrac{a}{1-r}$<br>-បើ $\lvert r\rvert \geq 1$ នោះស៊េរីរីក។ |
| ពេលទៅផ្ទះវិញធ្វើលំហាត់ទី៧ នៅទំព័រទី១៦ | ជំហានទី៥<br>បណ្តាំផ្ញើ | កត់ត្រានិងធ្វើតាម |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី២ ដេរីវេនៃអនុគមន៍

## មេរៀនទី១ អនុវត្តន៍ដេរីវេ

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: ពិពណ៌នាពីឌីផេរ៉ង់ស្យែល វិសមភាពកំណើនមានកំណត់ និងទ្រឹស្តីបទរ៉ូល បានត្រឹមត្រូវតាមរយៈសំណួរបំផុសរបស់គ្រូ។
- បំណិន: សិស្សបកស្រាយនិយមន័យឌីផេរ៉ង់ស្យែល វិសមភាពកំណើនមានកំណត់ និងទ្រឹស្តីបទរ៉ូលបានច្បាស់លាស់តាមរយៈឧទាហរណ៍គំរូរបស់គ្រូ។
- ឥរិយាបថ: សិស្សមានបម្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់ឌីផេរ៉ង់ស្យែល វិសមភាពកំណើនមានកំណត់ និងទ្រឹស្តីបទរ៉ូលក្នុងការប្រលងមានកំរិតខ្ពស់

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២០-២៤
- សៀវភៅគ្រូ: ទំព័រ ២០-២៤

### IV. ខ្លឹមសារមេរៀន

1. **ឌីផេរ៉ង់ស្យែល**
2. **វិសមភាពកំណើនមានកំណត់**
3. **ទ្រឹស្តីបទរ៉ូល**

### V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| -គណនាតំលៃនៃ $y'$ | | -សិស្សពិចារណារួចឡើងធ្វើ |

| | | |
|---|---|---|
| បើ $x=1$<br>$y=3x^2+10x-1$<br>$y=\dfrac{5x^3}{(3x-1)}$ | | • $y=3x^2+10x-1$<br>$y'=6x+10$<br>តែ $x=1$ នោះ $y'=16$<br>• $y=\dfrac{5x^3}{(3x-1)}$<br>$y'=\dfrac{15x(3x-1)-15x^3}{(3x-1)^2}$<br>តែ $x=1$<br>នោះ $y'=\dfrac{45-15-15}{2^2}$<br>$=\dfrac{15}{4}$ |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| -អោយសិស្សមើលមេរៀន ទំព័រទី២០-២១<br>-ចូរកំណត់និយមន័យឌីផេរ៉ង់ស្យែល។<br><br>-គ្រូដាក់ឧទាហរណ៍: គេអោយអនុគមន៍ $f(x)=x^2$ ។ រក $dy$ នៅត្រង់ $x=1$ និង $dx=0.01$ ។ | **អនុវត្តន៍ដេរីវេ**<br>**1. ឌីផេរ៉ង់ស្យែល**<br><br>**និយមន័យ:**<br>-បើអនុគមន៍ $y=f(x)$ មានដេរីវេ នោះឌីផេរ៉ង់ស្យែល $dy$ កំណត់ដោយ $dy=f'(x)dx$<br><br>**2. វិសមភាពកំណើនមានកំណត់** | -សិស្សអានដោយយកចិត្តទុកដាក់<br>-សិស្សអានសៀវភៅពិចារណារួចឆ្លើយ<br>•បើអនុគមន៍ $y=f(x)$ មានដេរីវេនោះឌីផេរ៉ង់ស្យែល $dy$ កំណត់តាងដោយ<br>$dy=f'(x)dx$<br>•សិស្សពិចារណាលើសង្កេតនិយមន័យរួចធ្វើ<br>ដោយ $y=x^2$<br>$y'=2x$<br>$dy=2xdx$<br>តែ $x=1$ ; $dx=0.01$<br>$dy=2\times1\times0.01$<br>$=0.02$ |

| | | |
|---|---|---|
| -ទ្រឹស្តីបទ:<br>គេអោយអនុគមន៍ $f$ កំណត់និងជាប់ហើយមានដេរីវេលើចន្លោះ $I$ ។បើមានពីរចំនួនពិត $m$ និង $M$ ដែលចំពោះគ្រប់ $x\in I$ , $m\le f'(x)\le M$ នោះចំពោះគ្រប់ចំនួនពិត $a;b\in I$ ដែល $a<b$ គេបាន<br>$m(b-a)\le f(b)-f(a)$<br>$\le M(b-a)$ | -ទ្រឹស្តីបទ:<br>គេអោយអនុគមន៍ $f$ កំណត់និងជាប់ហើយមានដេរីវេលើចន្លោះ $I$ ។បើមានពីរចំនួនពិត $m$ និង $M$ ដែលចំពោះគ្រប់ $x\in I$ , $m\le f'(x)\le M$ នោះចំពោះគ្រប់ចំនួនពិត $a;b\in I$ ដែល $a<b$ គេបាន<br>$m(b-a)\le f(b)-f(a)$<br>$\le M(b-a)$ | -សិស្សសង្កេតទាំងយកចិត្តទុកដាក់ |
| ឧទាហរណ៍: គេមានអនុគមន៍ $f$ កំណត់លើ $(-1;+\infty)$ ដែល $f(x)=\sqrt{1+x}$<br>កំណត់តំលៃអមនៃអនុគមន៍ដេរីវេ $f'(x)$ ចំពោះ<br>$\forall x\in\left[0;\frac{1}{2}\right]$ | | -សិស្សសង្កេតនិយមន័យ អានសៀវភៅ ពិចារណារួចធ្វើ:<br>•កំណត់តំលៃអម $f'(x)$ ចំពោះគ្រប់ $x\in\left[0,\frac{1}{2}\right]$<br>$f(x)=\sqrt{1+x}$<br>$f'(x)=\frac{1}{2\sqrt{1+x}}$<br>តាមវិសមភាពកំណើនមានកំណត់<br>$f'(0)\ge f'(x)\ge f\left(\frac{1}{2}\right)$<br>$f'(0)=\frac{1}{2}$<br>$f'\left(\frac{1}{2}\right)=\frac{1}{\sqrt{6}}$<br>ដូចនេះ ចំពោះ $x\in\left[0;\frac{1}{2}\right]$<br>គេបាន $\frac{1}{\sqrt{6}}\le f'(x)\le\frac{1}{2}$ |
| -ទ្រឹស្តីបទ:<br>គេអោយអនុគមន៍ $f$ មានដេរីវេលើចន្លោះ $[a;b]$ ។បើមានចំនួនពិត $M$ ដែល<br>$\lvert f'(x)\rvert\le M$ | **-ទ្រឹស្តីបទ:**<br>គេអោយអនុគមន៍ $f$ មានដេរីវេលើចន្លោះ $[a;b]$ ។បើមានចំនួនពិត $M$ ដែល $\lvert f'(x)\rvert\le M$<br>ចំពោះ $x\in[a;b]$ នោះគេបាន | -សិស្សសង្កេតដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| ចំពោះ $x\in[a;b]$ នោះគេបានវិសមភាព<br>$\lvert f(b)-f(a)\rvert\le(b-a)$<br>ឧទាហរណ៍: គេអោយ $f$ មានដេរីវេលើ $\mathbb{R}$ ដែល<br>$f(t)=\cos t$ ។<br>បង្ហាញថាចំពោះគ្រប់ $x,y\in\mathbb{R}$ គេបាន<br>$\lvert\cos x-\cos y\rvert\le\lvert x-y\rvert$<br><br>+បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $\lvert a;b\rvert$ មានដេរីវេលើចន្លោះ $(a;b)$ និង<br>$f(a)=f(b)$ នោះគេមានចំនួន $c\in(a;b)$ យ៉ាងតិចមួយដែល $f'(c)=0$ | វិសមភាព $\lvert f(b)-f(a)\rvert\le(b-a)$<br><br>**3. ទ្រឹស្តីបទរ៉ូល**<br>-បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $\lvert a;b\rvert$ មានដេរីវេលើចន្លោះ $(a;b)$ និង $f(a)=f(b)$ នោះគេមានចំនួន $c\in(a;b)$ យ៉ាងតិចមួយដែល $f'(c)=0$ | -សិស្សអានសៀវភៅពិចារណារួចធ្វើ:<br>-គេមាន $f(t)=\cos t$<br>$f'(t)=-\sin t$<br>គេបានវិសមភាព $\lvert f'(t)\rvert\le1$ គ្រប់ $t\in\mathbb{R}$<br>ដូចនេះ ចំពោះ $x;y\in\mathbb{R}$ គេបាន<br>$\lvert\cos x-\cos y\rvert\le\lvert x-y\rvert$<br><br>-សិស្សសង្កេតដោយយកចិត្តទុកដាក់ |
| | **ជំហានទី៤** (ពង្រឹងចំណេះដឹង) | |
| -ឧទាហរណ៍: គេអោយ<br>$f(x)=x^2-3x+2$<br>ក. រកអាប់ស៊ីស $x_1$ និង $x_2$ នៃចំនុចប្រសព្វរវាងក្រាបតាងអនុគមន៍និងអ័ក្សអាប់ស៊ីស<br>ខ. បង្ហាញថាមានចំនួនពិត $c$ មួយនៅចន្លោះ $(x_1;x_2)$ ដែល $f'(c)=0$<br>រួចគណនា $c$ ។ | | -សិស្សសង្កេតប្រធានពិចារណារួចធ្វើ<br>ក. រក $x_1;x_2$ ជាចំនុចប្រសព្វរវាងខ្សែកោងនិងអ័ក្សអាប់ស៊ីស $f(x)=x^2-3x+2$<br>$f$ ប្រសព្វនិងអ័ក្សអាប់ស៊ីសកាលណា $f(x)=0$<br>យើងបាន $x^2-3x+2=0$<br>$x_1=1$ ; $x_2=2$<br>ដូចនេះ ក្រាបនៃខ្សែកោងកាត់អ័ក្សអាប់ស៊ីសត្រង់ចំនុច $x_1=1$ ; $x_2=2$ |

| | | |
|---|---|---|
| | | ខ. បង្ហាញថាមានចំនួនពិត $c\in(1;2)$ ដែល $f'(c)=0$<br>+ $f$ ជាអនុគមន៍ពហុធា នោះ $f$ ជាប់លើ $[1;2]$ ហើយ $f(1)=f(2)=0$<br>តាមទ្រឹស្តីបទរ៉ូល<br>គេបាន<br>$c\in(1;2),\ f'(c)=0$<br>$f(x)=x^2-3x+2$<br>$f'(x)=2x-3$<br>$f'(x)=0$ រឺ $x=\frac{3}{2}$<br>ដូចនេះ $c=\frac{3}{2}$ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -គេមាន $f(x)=x^2-2x$<br>រកគ្រប់ $c\in[0;2]$ ដែល $f'(c)=0$ | កិច្ចការផ្ទះ<br>លំហាត់លេខ១២ទំព័រ២១៦ | -សិស្សកត់ត្រាលំហាត់ដាក់ក្នុងសៀវភៅ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី២ ដេរីវេនៃអនុគមន៍

## មេរៀនទី១ អនុវត្តន៍ដេរីវេ (ត)

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សពិពណ៌នាពីទ្រឹស្តីបទតំលៃមធ្យម ប្រាក់ចំណាយបន្ថែម ប្រាក់ចំណូលបន្ថែមតាមរយៈឧទាហរណ៍គំរូរបស់គ្រូបានត្រឹមត្រូវ។
- បំណិន: សិស្សបកស្រាយពីទ្រឹស្តីបទតំលៃមធ្យម ប្រាក់ចំណាយបន្ថែម ប្រាក់ចំណូលបន្ថែមតាមរយៈការពន្យល់របស់គ្រូបានច្បាស់លាស់។
- ឥរិយាបថ: សិស្សមានបម្រុងប្រយ័ត្នក្នុងការអនុវត្តន៍ទ្រឹស្តីបទតំលៃមធ្យម ប្រាក់ចំណាយបន្ថែមនិងប្រាក់ចំណូលបន្ថែមក្នុងការដោះស្រាយលំហាត់។

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២៥-៣១
- សៀវភៅគ្រូ: ទំព័រ ២៥-៣១

### IV. ខ្លឹមសារមេរៀន

4. ទ្រឹស្តីបទតម្លៃមធ្យម
5. អនុវត្តន៍ក្នុងសេដ្ឋកិច្ច
   5.1. ប្រាក់ចំណាយបន្ថែម
   5.2. ប្រាក់ចំណូលបន្ថែម
      ក. ប្រាក់ចំណូលសរុប
      ខ. ប្រាក់ចំណូលបន្ថែម

### V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ | | - តំណាងសិស្សឡើងរាយ |

| សណ្តាប់ធ្នាប់ និងវិន័យ | | ការណ៍ |
|---|---|---|
| | **ជំហានទី២** (រំលឹកមេរៀនចាស់) | |
| -កែកិច្ចការផ្ទះ:<br>$f(x)=x^2-2x$<br>រកគ្រប់ $c\in[0;2]$ ដែល<br>$f'(x)=0$ | | -សិស្សឡើងធ្វើ<br>យើងមាន $f(x)=x^2-2x$<br>$f'(x)=2x-2$<br>$f'(x)=0$ រឺ $2x-2=0$<br>នោះ $x=1$<br>ដូចនេះ $c=1$ |
| | **ជំហានទី៣** (មេរៀនថ្មី) | |
| ទ្រឹស្តីបទ<br>-បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a;b]$ មានដេរីវេលើ $(a;b)$ នោះមាន $c\in(a;b)$ មួយយ៉ាងតិចដែល<br>$f'(c)=\frac{f(b)-f(a)}{b-a}$<br>ឧទាហរណ៍: គេអោយ<br>$f(x)=x^2$ រកគ្រប់ $c\in(-2;1)$<br>ដែល $f'(c)=\frac{f(1)-f(-2)}{1+2}$ | **អនុវត្តន៍ដេរីវេ** (ត)<br>**4. ទ្រឹស្តីបទតម្លៃមធ្យម**<br>-បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a;b]$ មានដេរីវេលើ $(a;b)$ នោះ មាន $c\in(a;b)$ មួយយ៉ាងតិចដែល<br>$f'(c)=\frac{f(b)-f(a)}{b-a}$<br><br>**5. អនុវត្តន៍ក្នុងសេដ្ឋកិច្ច** | -សិស្សសង្កេតនិងស្តាប់គ្រូពន្យល់យ៉ាងយកចិត្តទុកដាក់<br><br>-សិស្សសង្កេតប្រធានពិចារណារួចធ្វើ:<br>យើងមាន $f(x)=x^2$<br>$f'(x)=2x$ ដែល<br>$f'(x)=\frac{f(1)-f(-2)}{1+2}$<br>$=\frac{1-4}{3}$<br>$f'(x)=-1$<br>យើងបាន $2x=-1$<br>$x=-\frac{1}{2}$<br>ដូចនេះ $c=-\frac{1}{2}$ |

| | | |
|---|---|---|
| •**ជាទូទៅ:** $C'(x)$ ជាប្រាក់ចំណាយបន្ថែមដែលមានតម្លៃប្រហែលនឹងទឹកប្រាក់ចំណាយក្នុងការផលិតសម្ភារៈឯកតាទី $x+1$។មានន័យថាប្រាក់ចំណាយបន្ថែមជាអត្រាបម្រែបម្រួលប្រាក់ចំណាយសរុប កាលណាកត្តាផលិតកម្មប្រែប្រួលមួយឯកតា។<br>$C'(x)\approx C(x+1)-C(x)$<br>ឧទាហរណ៍: ក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់មួយប្រភេទបានផលិតសម្ភារៈ $x$ គ្រឿង ដែលតម្លៃចំណាយសរុបកំណត់ដោយអនុគមន៍<br>$C(x)=500+3x$ (ពាន់រៀល)<br>គណនាប្រាក់ចំណាយបន្ថែមក្នុងការផលិតសម្ភារៈទី១០១ | **5.1 ប្រាក់ចំណាយបន្ថែម**<br>**ជាទូទៅ:** $C'(x)$ ជាប្រាក់ចំណាយបន្ថែមដែលមានតម្លៃប្រហែលនឹងទឹកប្រាក់ចំណាយក្នុងការផលិតសម្ភារៈឯកតាទី $x+1$។មានន័យថាប្រាក់ចំណាយបន្ថែមជាអត្រាបម្រែបម្រួលប្រាក់ចំណាយសរុប កាលណាកត្តាផលិតកម្មប្រែប្រួលមួយឯកតា។<br>$C'(x)\approx C(x+1)-C(x)$ | -សិស្សសង្កេតនិងកត់ត្រា<br>-សិស្សសង្កេតប្រធានពិចារណារួចធ្វើ<br>-ប្រាក់ចំណាយបន្ថែមក្នុងការផលិតសម្ភារៈទី101 យើងបាន<br>$C'(101)=C(101)-C(100)$<br>តែ $C(x)=500+3x$ ពាន់រៀល<br>$C(101)=(500+3\times101)$<br>$=803$ ពាន់រៀល<br>$C(100)=(500+3\times100)$<br>$=800$ ពាន់រៀល<br>$C'(101)=(803-800)$<br>$C'(101)=3$ ពាន់រៀល |
| **ជាទូទៅ:** ប្រាក់ចំណូលសរុប =តម្លៃលក់ចេញឯកតា×បរិមាណលក់បាន<br>$R(x)=P\times x$ | **5.2 ប្រាក់ចំណូលបន្ថែម**<br>**ក. ប្រាក់ចំណូលសរុប**<br>**ជាទូទៅ:** ប្រាក់ចំណូលសរុប=តម្លៃលក់ចេញឯកតា×បរិមាណលក់បាន<br>$R(x)=P\times x$ ដែល $P=D(x)$ | -សិស្សសង្កេតនិងកត់ត្រាដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| ដែល $P=D(x)$<br>ឧទាហរណ៍: ក្រុមហ៊ុនលក់គ្រឿងអេឡិចត្រូនិចមួយ បានលក់សម្ភារៈមួយគ្រឿងតម្លៃ $D(x)=100-0.5x$ ពាន់រៀល ។ $x$ ជាបរិមាណលក់ក្នុងមួយខែ។<br>គណនាប្រាក់ចំណូលសរុបក្នុង១ខែ បើក្រុមហ៊ុនលក់បាន ១២៣គ្រឿង។ | | -សិស្សអានប្រធានពិចារណារួចធ្វើ<br>គណនាប្រាក់ចំណូលសរុបក្នុង១ខែ<br>តាមរូបមន្ត<br>$R(x)=P\times x$<br>តែ $P=D(x)=100-0.5x$<br>$R(x)=100x-0.5x^2$<br>តែ $x=123$ គ្រឿង<br>$R(123)=100\times123$<br>$-0.5(123)^2$<br>$=4735.5$ ពាន់រៀល |
| •**ជាទូទៅ:** $R'(x)$ ជាប្រាក់ចំណូលបន្ថែមដែលមានតម្លៃប្រហែលនឹងប្រាក់ចំណូលដែលបានពីការលក់សម្ភារៈឯកត្តាទី $x+1$ មានន័យថាប្រាក់ចំណូលបន្ថែមជាអត្រាបម្រែបម្រួលប្រាក់ចំណូលសរុប កាលណាផលិតផលត្រូវបានលក់ប្រែប្រួលមួយឯកតា។<br>$R'(x)\approx R(x+1)-R(x)$<br>ឧទាហរណ៍: អ្នកគ្រប់គ្រងរោងចក្រផលិតសម្ភារៈមួយអោយដឹងថាគាត់លក់សម្ភារៈមួយគ្រឿងក្នុងតម្លៃ $P=D(x)=46-0.25x$ ពាន់រៀល។ | **ខ. ប្រាក់ចំណូលបន្ថែម**<br>**ជាទូទៅ:** $R'(x)$ ជាប្រាក់ចំណូលបន្ថែមដែលមានតម្លៃប្រហែលនឹងប្រាក់ចំណូលដែលបានពីការលក់សម្ភារៈឯកត្តាទី $x+1$ មានន័យថាប្រាក់ចំណូលបន្ថែមជាអត្រាបម្រែបម្រួលប្រាក់ចំណូលសរុប កាលណាផលិតផលត្រូវបានលក់ប្រែប្រួលមួយឯកតា។<br>$R'(x)\approx R(x+1)-R(x)$ | -សិស្សស្តាប់និងសង្កេតដោយយកចិត្តទុកដាក់<br><br>-សិស្សអានប្រធានពិចារណារួចឡើងធ្វើ<br>ក. ប្រាក់ចំណូលសរុបពីការលក់សម្ភារៈ 31 គ្រឿង<br>តាមរូបមន្ត<br>$R(x)=P\times x$<br>$=46x-0.25x^2$ |

| | | |
|---|---|---|
| ក. គណនាប្រាក់ចំណូលសរុបដែលពីការលក់សម្ភារៈ ៣១គ្រឿង<br>ខ. ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំណូលពីការលក់សម្ភារៈគ្រឿងទី៣១។ | | តែ $x=31$<br>$R(31)=46\times31$<br>$-0.25\times(31)^2$<br>$R(31)=1185.75$<br>ពាន់រៀល<br>ខ. ប្រាក់ចំណូលដែលបានមកពីការលក់សម្ភារៈគ្រឿងទី31<br>$R'(x)=46-0.25\times x$<br>$R(30)=46-0.25\times30$<br>$=31$ ពាន់រៀល |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -ប្រាក់ចំណាយបន្ថែមមានរូបមន្តដូចម្តេច?<br><br>-ប្រាក់ចំណូលសរុបមានរូបមន្តដូចម្តេច? | | ក. សិស្សពិចារណារួចឆ្លើយប្រាក់ចំណាយបន្ថែមមានរូបមន្ត<br>$C'(x)=C(x+1)-C(x)$<br>-សិស្សពិចារណារួចឆ្លើយប្រាក់ចំណូលសរុបមានរូបមន្ត<br>$R(x)=P\times x$<br>ដែល $P=D(x)$ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -ធ្វើលំហាត់ប្រតិបត្តិទំព័រទី31 | កិច្ចការផ្ទះ | -សិស្សកត់ទំព័រលំហាត់ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី២ ដេរីវេនៃអនុគមន៍

## មេរៀនទី១ អនុវត្តន៍ដេរីវេ (តចប់)

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សពណ៌នាពីប្រាក់ចំណេញបន្ថែម ប្រាក់ចំណាយមធ្យមន្ថែមតាមរយៈ ឧទាហរណ៍គំរូរបស់គ្រូបានត្រឹមត្រូវ។
- បំណិន: សិស្សបកស្រាយពីរបៀបរកប្រាក់ចំណេញបន្ថែម និងប្រាក់ចំណេញមធ្យម បន្ថែមតាមរយៈការពន្យល់របស់គ្រូបានច្បាស់លាស់។
- ឥរិយាបថ: សិស្សមានបម្រុងប្រយ័ត្នក្នុងការអនុវត្តន៍អនុវត្តន៍រូបមន្តប្រាក់ចំណេញបន្ថែម និងប្រាក់ចំណាយមធ្យមបន្ថែមតាមរយៈខ្លឹមសារមេរៀនបានកម្រិតខ្ពស់។

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ៣២-៣៧
- សៀវភៅគ្រូ: ទំព័រ ៣២-៣៧

### IV. ខ្លឹមសារមេរៀន

**5.3. ប្រាក់ចំណេញបន្ថែម**

**ក. ប្រាក់ចំណេញសរុប**

**ខ. ប្រាក់ចំណេញបន្ថែម**

**5.4. ប្រាក់ចំណាយមធ្យមបន្ថែម**

### V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |

| | | |
|---|---|---|
| -ហៅសិស្សឡើងកែកិច្ចការផ្ទះ | | -សិស្សឡើងធ្វើ<br>ក. សរសេរអនុគមន៍ប្រាក់ចំណូលសរុប<br>$R(x)=P\times x$<br>តែ $P=D(x)=140-0.5x$<br>$R(x)=140x-0.5x^2$<br>ខ. រកតម្លៃប្រហែលដែលបានមកពីការលក់សម្ភារៈគ្រឿងទី31<br>$R'(x)=140-x$<br>$R'(30)=(140-30)$<br>$=110$ ម៉ឺនរៀល |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| •**ជាទូទៅ**<br>ប្រាក់ចំណេញសរុប =ប្រាក់ចំណូលសរុប –ប្រាក់ចំណាយសរុប<br>$P(x)=R(x)-C(x)$<br>ឧទាហរណ៍: សហគ្រាសមួយបានចំណេញសរុបក្នុងការផលិតសម្ភារៈ $x$ គ្រឿងដែលតាងដោយអនុគមន៍ប្រាក់ចំណេញសរុប<br>$C(x)=0.002x^2+0.72x$<br>$+260$ ពាន់រៀល ហើយសហគ្រាសនោះលក់ចេញវិញសម្ភារៈមួយគ្រឿងតម្លៃ<br>$P=D(x)=3-0.001x$ ពាន់ | **អនុវត្តន៍ដេរីវេ** (**តចប់**)<br>**5.3 ប្រាក់ចំណេញបន្ថែម**<br>**ក. ប្រាក់ចំណេញសរុប**<br>**ជាទូទៅ**<br>ប្រាក់ចំណេញសរុប =ប្រាក់ចំណូលសរុប –ប្រាក់ចំណាយសរុប<br>$P(x)=R(x)-C(x)$ | -សិស្សស្តាប់យ៉ាងយកចិត្តទុកដាក់<br>-សិស្សពិចារណារួចឡើងធ្វើ:<br>ក. ប្រាក់ចំណូលសរុប<br>$R(x)=P\times x$<br>តែ $P=D(x)=3-0.001x$<br>$R(x)=3x-0.001x^2$<br>ខ. សរសេរអនុគមន៍ប្រាក់ចំណេញសរុប<br>$P(x)=R(x)-C(x)$<br>តែ |

| | | |
|---|---|---|
| រៀល។<br>ក. សរសេរអនុគមន៍ប្រាក់ចំណូលសរុប<br>ខ. សរសេរអនុគមន៍ប្រាក់ចំណេញសរុប | | $C(x)=0.002x^2+0.32x$<br>$+260$<br>$P(x)=(3x-0.001x^2)-$<br>$(0.002x^2-0.72x$<br>$+260)$<br>$P(x)=-0.003x^2+2.28x$<br>$-260$ ពាន់រៀល |
| **•ជាទូទៅ**<br>$P'(x)$ ជាប្រាក់ចំណេញបន្ថែមដែលមានតម្លៃប្រហែលនឹងប្រាក់ចំណេញដែលបានពីការលក់សម្ភារៈឯកតាទី $x+1$ ។មានន័យថា ប្រាក់ចំណេញបន្ថែមជាអត្រាបម្រែបម្រួលប្រាក់ចំណេញសរុប កាលណាផលិតផលដែលបានលក់ប្រែប្រួល1ឯកតា<br>$P'(x)\approx P(x+1)-P(x)$ | **ខ. ប្រាក់ចំណេញបន្ថែម**<br>**ជាទូទៅ**<br>$P'(x)$ ជាប្រាក់ចំណេញបន្ថែមដែលមានតម្លៃប្រហែលនឹងប្រាក់ចំណេញដែលបានពីការលក់សម្ភារៈឯកតាទី $x+1$ ។មានន័យថា ប្រាក់ចំណេញបន្ថែមជាអត្រាបម្រែបម្រួលប្រាក់ចំណេញសរុប កាលណាផលិតផលដែលបានលក់ប្រែប្រួល1ឯកតា<br>$P'(x)\approx P(x+1)-P(x)$ | |
| ឧទាហរណ៍: រោងចក្រមួយចំណាយប្រាក់សរុបក្នុងការផលិតសម្ភារៈ $x$ គ្រឿង ដែលអោយតាមអនុគមន៍<br>$C(x)=2070+25x+0.1x^2$ ពាន់រៀល ហើយរោងចក្រលក់ចេញវិញទទួលបានប្រាក់ចំណូលសរុបដែលត្រូវតាមអនុគមន៍<br>$R(x)=100x-0.1x^2$ ពាន់រៀល<br>ក. កំណត់អនុគមន៍ប្រាក់ចំណេញសរុប | | -សិស្សពិចារណារួចឡើងធ្វើ<br>ក. អនុគមន៍ប្រាក់ចំណេញសរុប<br>$P(x)=R(x)-C(x)$<br>តែ $R(x)=100x^2-0.1x^2$<br>$C(x)=2070+25x$<br>$+0.1x^2$<br>$P(x)=(100x^2-0.1x^2)-$<br>$(2070+25x+0.1x^2)$<br>$P(x)=-0.2x^2+75x$<br>$-2070$ ពាន់រៀល<br>ខ. គណនាតម្លៃប្រហែលនៃប្រាក់ចំណេញដែលបានពី |

| | | |
|---|---|---|
| ខ. ប៉ាន់ស្មានតម្លៃប្រហែលនៃប្រាក់ចំណេញដែលបានពីការលក់សម្ភារៈគ្រឿងទី81<br><br>•**ជាទូទៅ**<br>បើ $C(x)$ តាងប្រាក់ចំណេញសរុបក្នុងការផលិតសម្ភារៈ $x$ គ្រឿងនេះ $\overline{C}=\dfrac{C(x)}{x}$ ជាប្រាក់ចំណាយមធ្យមក្នុងការផលិតសម្ភារៈ១គ្រឿងៗ។ $\overline{C}'(x)$ ជាប្រាក់ចំណាយមធ្យមបន្ថែមដែលមានតម្លៃប្រហែលនឹងប្រាក់ចំណាយមធ្យម កាលណាផលិតកើនឡើង១ឯកតា | **5.4 ប្រាក់ចំណាយមធ្យមបន្ថែម**<br>**ជាទូទៅ**<br>បើ $C(x)$ តាងប្រាក់ចំណេញសរុបក្នុងការផលិតសម្ភារៈ $x$ គ្រឿងនេះ $\overline{C}=\dfrac{C(x)}{x}$ ជាប្រាក់ចំណាយមធ្យមក្នុងការផលិតសម្ភារៈ១គ្រឿងៗ។ $\overline{C}'(x)$ ជាប្រាក់ចំណាយមធ្យមបន្ថែមដែលមានតម្លៃប្រហែលនឹងប្រាក់ចំណាយមធ្យម កាលណាផលិតកើនឡើង១ឯកតា | ការលក់សម្ភារៈគ្រឿងទី81<br>$P'(x)=-0.4x+75$<br>$P'(80)=-0.4\times80+75$<br>$=43$ ពាន់រៀល |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -ឧទាហរណ៍: ប្រាក់ចំណាយក្នុង១សប្តាហ៍របស់ក្រុមហ៊ុនមួយគឺ $C(x)=0.125x^2+20x$ $+1000$ ពាន់រៀល។ $x$ ជាបរិមាណសម្ភារៈផលិតបាន<br>ក. គណនាប្រាក់ចំណាយមធ្យម<br>ខ. គណនាប្រាក់ចំណាយមធ្យមបន្ថែម កាលណា $x=100$ ។ | | -សិស្សពិចារណារួចធ្វើ:<br>ក. ប្រាក់ចំណាយមធ្យម<br>$\overline{C}(x)=\dfrac{C(x)}{x}$<br>តែ $C(x)=0.125x^2+20x$ $+1000$<br>$\overline{C}(x)=\dfrac{1}{x}(0.125x^2+20x$ $+1000)$<br>$=0.125x+20+\dfrac{1000}{x}$<br>ខ. ប្រាក់ចំណាយបន្ថែមមធ្យម |

| | | |
|---|---|---|
| | | កាលណា $x=100$<br>$\overline{C}'(x)=0.125-\frac{1000}{x^2}$<br>$\overline{C}'(100)=0.125-\frac{1000}{100}$<br>$=0.025$ ពាន់រៀល |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -ធ្វើលំហាត់ប្រតិបត្តិទំព័រទី37 | កិច្ចការផ្ទះ | -សិស្សរកត់ទំព័រលំហាត់ |

# កិច្ចតែងការបង្រៀន

## ជំពូកទី៣ អថេរភាពនិងក្រាបនៃអនុគមន៍

## មេរៀនទី១ អនុគមន៍អសនិទាន

## I. វត្ថុបំណង

- ចំណេះដឹង: សិស្សប្រាប់រាងទូទៅរបស់អនុគមន៍អសនិទានបាន
- បំនិន: សិស្សចេះសិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $y=\sqrt{ax+b};a\neq 0$
- ឥរិយាបថ: សិស្សមានទំនុកចិត្តក្នុងការដោះស្រាយលំហាត់

## II. រយៈពេល: ២ម៉ោងសិក្សា

## III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្សទំព័រទី៨៤ដល់៨៨
- សៀវភៅគ្រូទំព័រទី៨៤ដល់៨៨
- បន្ទាត់និងឧបករណ៍គូសប៉ារ៉ាបូល

## IV. វិធីសាស្ត្របង្រៀន

- គោលវិធីសិស្សមជ្ឈមណ្ឌល

## V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ (5នាទី) | | |
| -គ្រូតពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ វិន័យ និង បរិស្ថាន | (រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| ជំហានទី២ (១០នាទី) | | |
| -ចូរនិយាយពីរបៀប សិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍ សនិទាន។ | រំលឹកមេរៀនចាស់ | -ដើម្បីសិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍ សនិទានយើងត្រូវះ<br>១/ រកដែនកំណត់<br>២/ ទិសដៅអថេរភាព<br>-រកដេរីវេទី១៎:<br>សិក្សាតម្លៃបរមាធៀប<br>-រកលីមីត<br>-រកអាស៊ីមតូត: អាស៊ីមតូតដេក |

| | | |
|---|---|---|
| | | ឈរ និង អាស៊ីមតូតទ្រេត<br>៣/ តារាងអថេរភាព<br>៤/ សំណង់ក្រាប:<br>រកចំណុចប្រសព្វ<br>រវាងអក្សអដោនេ<br>៥/ រកអក្សឆ្លុះ។ |
| ជំហានទី៣(៨០នាទី) | | |
| -គ្រូសរសេរចំណងជើង<br>មេរៀនថ្មី។<br>ដាក់ឧទាហរណ៍<br>បង្ហាញដល់សិស្ស។ | មេរៀនថ្មី<br>ជំពូកទី៣<br>អថេរភាពនិងក្រាបនៃអនុគមន៍<br>មេរៀនទី១<br>អនុគមន៍អសនិទាន<br>I.អនុគមន៍អសនិទាន<br>រាង $y=\sqrt{ax+b};a\neq 0$<br>1.1សិក្សាអនុគមន៍<br>$y=\sqrt{ax+b};a\neq 0$<br>ឧ.សិក្សាអថេរភាពនិង<br>សង់ក្រាបនៃអនុគមន៍<br>$y=\sqrt{2x-4}$<br>-រកដែនកំណត់<br>អនុគមន៍មានន័យកាលណា<br>$2x-4\geq 0, x\geq 2$<br>ដូចនេះ $D=[2;\infty[$<br>-ទិសដៅអថេរភាព<br>➢ ដេរីវេ<br>$y'=\frac{(2x-4)'}{2\sqrt{2x-4}}=\frac{1}{\sqrt{2x-4}}$<br>ដោយ $y'>0$ ចំពោះគ្រប់ $x>2$ ។<br>➢ លីមីត<br>$\lim_{x\to+\infty}\sqrt{2x-4}=+\infty$<br>-ទិសដៅអថេរភាព | -សិស្សកត់ត្រាមេរៀនថ្មីនិង<br>ស្តាប់គ្រូពន្យល់រួចពិភាក្សា<br>លំហាត់។<br>មេរៀនថ្មី<br>ជំពូកទី៣<br>អថេរភាពនិងក្រាបនៃអនុគមន៍<br>មេរៀនទី១<br>អនុគមន៍អសនិទាន<br>I.អនុគមន៍អសនិទាន<br>រាង $y=\sqrt{ax+b};a\neq 0$<br>1.1សិក្សាអនុគមន៍<br>$y=\sqrt{ax+b};a\neq 0$<br>ឧ.សិក្សាអថេរភាពនិង<br>សង់ក្រាបនៃអនុគមន៍<br>$y=\sqrt{2x-4}$<br>-រកដែនកំណត់<br>អនុគមន៍មានន័យកាលណា<br>$2x-4\geq 0, x\geq 2$<br>ដូចនេះ $D=[2;\infty[$<br>-ទិសដៅអថេរភាព<br>➢ ដេរីវេ<br>$y'=\frac{(2x-4)'}{2\sqrt{2x-4}}=\frac{1}{\sqrt{2x-4}}$<br>ដោយ $y'>0$ ចំពោះគ្រប់ $x>2$ ។<br>➢ លីមីត |

| $x$ | $2$ $\qquad +\infty$ |
|---|---|
| $y'$ | $\Vert$ $+$ |
| $y$ | $0 \nearrow +\infty$ |

-សង់ក្រាប: តារាងតម្លៃលេខ

| $x$ | $2$ | $4$ |
|---|---|---|
| $y$ | $0$ | $2$ |

ក្រាប



ជាទូទៅ:ដើម្បីសិក្សាអនុគមន៍អសនិទានរាង

$y=\sqrt{ax+b};a\neq 0$

យើងត្រូវ:

➢ ដែនកំណត់

អនុគមន៍មានន័យកាលណា៖ $ax+b\geq 0$

- បើ $a>0;x\geq -\frac{b}{a};D=[-\frac{b}{a};+\infty[$
- បើ $a<0;x\leq \frac{-b}{a};D=]-\infty;-\frac{b}{a}]$

➢ ដេរីវេ

$y'=\frac{a}{2\sqrt{ax+b}}$

+ករណី $a>0$

-តារាងអថេរភាព

| $x$ | $-\frac{b}{a}$ $\qquad +\infty$ |
|---|---|
| $y'$ | $\Vert$ $+$ |
| $y$ | $0 \nearrow +\infty$ |

➢ ក្រាប

$\lim\limits_{x\to+\infty}\sqrt{2x-4}=+\infty$

-ទិសដៅអថេរភាព

| $x$ | $2$ $\qquad +\infty$ |
|---|---|
| $y'$ | $\Vert$ $+$ |
| $y$ | $0 \nearrow +\infty$ |

-សង់ក្រាប: តារាងតម្លៃលេខ

| $x$ | $2$ | $4$ |
|---|---|---|
| $y$ | $0$ | $2$ |

ក្រាប



ជាទូទៅ: ដើម្បីសិក្សាអនុគមន៍អសនិទានរាង

$y=\sqrt{ax+b};a\neq 0$

យើងត្រូវ:

➢ ដែនកំណត់

អនុគមន៍មានន័យកាលណា៖ $ax+b\geq 0$

- បើ $a>0;x\geq -\frac{b}{a};D=[-\frac{b}{a};+\infty[$
- បើ $a<0;x\leq \frac{-b}{a};D=]-\infty;-\frac{b}{a}]$

➢ ដេរីវេ

$y'=\frac{a}{2\sqrt{ax+b}}$

+ករណី $a>0$

-តារាងអថេរភាព

| $x$ | $-\frac{b}{a}$ $\qquad +\infty$ |
|---|---|
| $y'$ | $\Vert$ $+$ |
| $y$ | $0 \nearrow +\infty$ |

➢ ក្រាប

លំហាត់គំរូ:
សិក្សាអថេរភាពនិង
សង់ក្រាបនៃអនុគមន៍៖
$y=\sqrt{-3x+5}$
ធ្វើការបកស្រាយ
លំហាត់និងពន្យល់
ដល់សិស្ស។



+ករណី $a<0$

តារាងអថេរភាព

| $x$ | $-\infty$ | $-\frac{b}{a}$ |
|---|---|---|
| $y'$ | $-$ | ‖ |
| $y$ | $+\infty$ ↘ | $0$ |

➢ ក្រាប



លំហាត់គំរូ៖សិក្សាអថេរភាព
និងសង់ក្រាបនៃអនុគមន៍

$y=\sqrt{-3x+5}$

➢ រកដែនកំណត់

អនុគមន៍មានន័យកាលណា:

$-3x+5\geq 0; x\leq \frac{5}{2}$

ដូចនេះ $D=]-\infty;\frac{5}{3}]$

➢ ទិសដៅអថេរភាព

-ដេរីវេ

$y'=\frac{-3}{2\sqrt{-3x+5}}<0;\forall x<\frac{5}{3}$

-លីមីត

$\lim_{x\to-\infty}\sqrt{-3x+5}=+\infty$

-តារាងអថេរភាព

| $x$ | $-\infty$ | $\frac{5}{3}$ |
|---|---|---|
| $y'$ | $-$ | ‖ |
| $y$ | $+\infty$ ↘ | $0$ |



+ករណី $a<0$

តារាងអថេរភាព

| $x$ | $-\infty$ | $-\frac{b}{a}$ |
|---|---|---|
| $y'$ | $-$ | ‖ |
| $y$ | $+\infty$ ↘ | $0$ |

➢ ក្រាប



លំហាត់គំរូ៖សិក្សាអថេរភាព
និងសង់ក្រាបនៃអនុគមន៍

$y=\sqrt{-3x+5}$

➢ រកដែនកំណត់

អនុគមន៍មានន័យកាលណា:

$-3x+5\geq 0; x\leq \frac{5}{2}$

ដូចនេះ $D=]-\infty;\frac{5}{3}]$

➢ ទិសដៅអថេរភាព

-ដេរីវេ

$y'=\frac{-3}{2\sqrt{-3x+5}}<0;\forall x<\frac{5}{3}$

-លីមីត

$\lim_{x\to-\infty}\sqrt{-3x+5}=+\infty$

-តារាងអថេរភាព

| $x$ | $-\infty$ | $\frac{5}{3}$ |
|---|---|---|
| $y'$ | $-$ | ‖ |
| $y$ | $+\infty$ ↘ | $0$ |

<table>
<tr>
<td></td>
<td>➢ ក្រាប<br>តារាងតម្លៃលេខ<br><br>$x$ | $0$ | $1$<br>$y$ | $\sqrt{5}$ | $\sqrt{2}$<br><br></td>
<td>➢ ក្រាប<br>តារាងតម្លៃលេខ<br><br>$x$ | $0$ | $1$<br>$y$ | $\sqrt{5}$ | $\sqrt{2}$<br><br></td>
</tr>
<tr>
<td colspan="3" align="center">ជំហានទី៤(១៥នាទី)</td>
</tr>
<tr>
<td>-គ្រូដាក់លំហាត់ប្រតិបត្តិឲ្យសិស្សអនុវត្តន៍។<br>-គ្រូប្រាប់ឲ្យសិស្សអនុវត្តន៍ម្នាក់មួយចំណុចនៅលើក្តាខៀន។</td>
<td>ពង្រឹងពុទ្ធិ<br>សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍<br>ក- $y=\sqrt{5x-1}$<br>ខ- $y=\sqrt{2-x}$</td>
<td>-សិស្សនាំគ្នាធ្វើលំហាត់ដោយយកចិត្តទុកដាក់<br>សិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍៖<br>ក- $y=\sqrt{5x-1}$<br>➢ រកដែនកំណត់<br>អនុគមន៍មានន័យលុះត្រាតែ៖<br>$5x-1\ge 0; x\ge \frac{1}{5}$<br>ដូចនេះ $D=[\frac{1}{5};+\infty[$<br>➢ ទិសដៅអថេរភាព<br>-ដេរីវេ<br>$y'=\frac{5}{2\sqrt{5x-1}}>0;\forall x>\frac{1}{5}$<br>-លីមីត<br>$\lim_{x\to+\infty}\sqrt{5x-1}=+\infty$<br>-តារាងអថេរភាព<br><br>$x$ | $\frac{1}{5}$    $+\infty$<br>$y'$ | $+$<br>$y$ | $0$ ↗ $+\infty$</td>
</tr>
</table>

➢ ក្រាប

តារាងតម្លៃលេខ

| $x$ | 1 | 2 |
|---|---|---|
| $y$ | 2 | 3 |



ខ- $y=\sqrt{2-x}$

➢ រកដែនកំណត់

អនុគមន៍មានន័យលុះត្រាតែ

$2-x\geq 0; x\leq 2$

$D=]-\infty;2]$

➢ ទិសដៅអថេរភាព

-ដេរីវេ

$y'=-\dfrac{1}{2\sqrt{2-x}}<0;\forall x<2$

-លីមីត

$\lim\limits_{x\to-\infty}\sqrt{2-x}=+\infty$

-តារាងអថេរភាព

| $x$ | $-\infty$ | | 2 |
|---|---|---|---|
| $y'$ | | $-$ | |
| $y$ | $+\infty$ | ↘ | 0 |

➢ ក្រាប

តារាងតម្លៃលេខ

| $x$ | 0 | 1 |
|---|---|---|
| $y$ | $\sqrt{2}$ | 1 |

| | | |
|---|---|---|
| | |  |
| | ជំហានទី៥(៥នាទី) | |
| -សិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍<br>ក- $y=\sqrt{x+5}$<br>ខ- $y=\sqrt{-4x+1}$ | កិច្ចការផ្ទះ | សិស្សកត់ត្រាលំហាត់ដាក់ក្នុងសៀវភៅ។ |

# កិច្ចតែងការបង្រៀន

## ជំពូកទី៣ អថេរភាពនិងក្រាបនៃអនុគមន៍

## មេរៀនទី១ អនុគមន៍អសនិទាន

### I. វត្ថុបំណង

- ចំណេះដឹង: សិស្សបានយល់ដឹងពីសារៈសំខាន់របស់អនុគមន៍អសនិទាន។
- បំនិន: សិស្សចេះប្រើអនុគមន៍ក្នុងជីវភាពប្រចាំថ្ងៃ។
- ឥរិយាបថ: សិស្សមានទំនុកចិត្តក្នុងការអនុវត្តន៍។

### II. រយៈពេល: ២ម៉ោងសិក្សា

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្សទំព័រទី៤៨ដល់៥១
- សៀវភៅគ្រូទំព័រទី៤៨ដល់៥១
- បន្ទាត់ ឧបករណ៍គូសប៉ារ៉ាបូលនិងដៃកឈាន។

### IV. វិធីសាស្ត្របង្រៀន

- គោលវិធីសិស្សមជ្ឈមណ្ឌល

### V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១(៥នាទី) | | |
| -គ្រូតពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ វិន័យ និង បរិស្ថាន។ | (រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| ជំហានទី២(១០នាទី) | | |
| -ចូនិយាយពីរបៀប សិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍ អសនិទាន $y=\sqrt{ax+b}; a\neq 0$ | | -ដើម្បីសិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍សនិទាន យើងត្រូវះ<br>១/ រកដែនកំណត់<br>២/ ទិសដៅអថេរភាព<br>-រកដេរីវេទី១ៈ សិក្សាភាពកើនរឺចុះនៃអនុន៍<br>-រកលីមីត<br>៣/ តារាងអថេរភាព |

| | | |
|---|---|---|
| | | ៨/ សំណង់ក្រាប:<br>រកចំណុចប្រសព្វរវាងអក្ស៍<br>អដោនេរ។ |
| ជំហានទី៣(៨០នាទី) | | |
| -គ្រូសរសេរចំណង់ជើង<br>មេរៀនថ្មី។<br>ដាក់ឧទាហរណ៍បង្ហាញ<br>ដល់សិស្ស។<br>-ណែនាំសិស្សពីរបៀប<br>តាងអញ្ញាតរបៀបសរសេរ<br>សមីការនៃអនុគមន៍តាម<br>សម្មតិកម្មរបស់លំហាត់ដូ<br>ចជា<br>សម្មតិកម្មទាក់ទង់និងចម្ងា<br>យ<br>ចរ រយៈពេល ល្បឿន<br>និងទ្រឹស្តីបទពីតាករ័ក្នុង<br>ត្រីកោណកែង។ | មេរៀនថ្មី<br>ជំពូកទី៣<br>អថេរភាពនិងក្រាបនៃ<br>អនុគមន៍<br>មេរៀនទី១<br>អនុគមន៍អសនិទាន<br>III. អនុវត្តន៍<br>លំហាត់គំរូ:<br>មនុស្សម្នាក់ធ្វើដំណើរពី<br>ចំណុចAកាត់វាលខ្សាច់<br>ទៅកាន់ចំណុចMដែលនៅ<br>លើផ្លូវជាតិដោយ<br>ល្បឿន3Km/hរួចបន្តដំណើរ<br>លើកំណារ់ផ្លូវជាតិដោយ<br>ល្បឿន 5Km/h។<br>ចម្ងាយផ្លូវពី AទៅBស្មើ 2Km<br>ហើយពី BទៅCស្មើ 6Km។<br>រកទីតាំងនៃMដើម្បីឲ្យអ្នក<br>ដំណើរប្រើពេលអស់តិច<br>បំផុតក្នុងការធ្វើដំណើរ<br>ពីAទៅMនិងពីMទៅC។<br>ដំណោះស្រាយ<br><br><br>ដើម្បីឲ្យអ្នកដំណើរប្រើពេល | មេរៀនថ្មី<br>ជំពូកទី៣<br>អថេរភាពនិងក្រាបនៃ<br>អនុគមន៍<br>មេរៀនទី១<br>អនុគមន៍អសនិទាន<br>III. អនុវត្តន៍<br>លំហាត់គំរូ:<br>មនុស្សម្នាក់ធ្វើដំណើរពី<br>ចំណុចAកាត់វាលខ្សាច់<br>ទៅកាន់ចំណុចMដែលនៅ<br>លើផ្លូវជាតិដោយ<br>ល្បឿន3Km/hរួចបន្តដំណើរ<br>លើកំណាត់ផ្លូវជាតិដោយ<br>ល្បឿន5Km/h។<br>ចម្ងាយផ្លូវពី AទៅBស្មើ 2Km<br>ហើយពី BទៅCស្មើ 6Km។<br>រកទីតាំងនៃMដើម្បីឲ្យអ្នក<br>ដំណើរប្រើពេលអស់<br>តិចបំផុតក្នុងការធ្វើដំណើរ<br>ពីAទៅMនិងពីMទៅC។<br>ដំណោះស្រាយ<br><br><br>-ដើម្បីឲ្យអ្នកដំណើរប្រើពេល |

| | | |
|---|---|---|
| | អស់តិចបំផុតលុះត្រាតែចម្ងាយពី<br>AទៅCខ្លីបំផុត។<br>-ចម្ងាយពីAទៅCខ្លីបំផុតលុះត្រាតែអនុគមន៍មានតម្លៃអប្បបរមា។<br>-តាង x ជាចម្ងាយពីBទៅM<br>-តាង6-x<br>ជាចម្ងាយពីMទៅC។<br>+ក្នុងត្រីកោណកែងABMមន<br>$AM^2 = AB^2 + BM^2$<br>$\Leftrightarrow AM = \sqrt{AB^2 + BM^2}$<br>$\Leftrightarrow AM = \sqrt{4+x^2}$<br>-រយៈពេលធ្វើដំណើរ<br>ពីAទៅMគឺ $\frac{\sqrt{4+x^2}}{3}$<br>រយៈពេលធ្វើដំណើរពីAទៅC<br>គឺ $f(x) = \frac{\sqrt{4+x^2}}{3} + \frac{6-x}{5}$<br>-រកដេរីវេ<br>$y' = (\frac{\sqrt{4-x^2}}{3} + \frac{6-x}{5})'$<br>$= \frac{x}{3\sqrt{4+x^2}} - \frac{1}{5}$<br>$= \frac{5x - 3\sqrt{4+x^2}}{15\sqrt{4+x^2}}$<br>$= \frac{16(x+\frac{3}{2})(x-\frac{3}{2})}{15\sqrt{4+x^2}(5x+3\sqrt{4+x^2})}$<br>ដោយ $x > 0$<br>ភាគបែងវិជ្ជមាន<br>ហើយ $16(x+\frac{3}{2}) > 0$<br>ដូចនេះដេរីវេមានសញ្ញាដូច<br>$x - \frac{3}{2} = 0 \Leftrightarrow x = \frac{3}{2}$ | អស់តិចបំផុត<br>លុះត្រាតែចម្ងាយពីAទៅCខ្លីបំផុត។<br>-ចម្ងាយពីAទៅCខ្លីបំផុតលុះត្រាតែអនុគមន៍មានតម្លៃអប្បបរមា។<br>-តាង x ជាចម្ងាយពីBទៅM<br>-តាង6-x<br>ជាចម្ងាយពីMទៅC។<br>+ក្នុងត្រីកោណកែងABMមាន<br>$AM^2 = AB^2 + BM^2$<br>$\Leftrightarrow AM = \sqrt{AB^2 + BM^2}$<br>$\Leftrightarrow AM = \sqrt{4+x^2}$<br>-រយៈពេលធ្វើដំណើរ<br>ពីAទៅMគឺ $\frac{\sqrt{4+x^2}}{3}$<br>រយៈពេលធ្វើដំណើរពីAទៅCគឺ<br>$f(x) = \frac{\sqrt{4+x^2}}{3} + \frac{6-x}{5}$<br>-រកដេរីវេ<br>$y' = (\frac{\sqrt{4-x^2}}{3} + \frac{6-x}{5})'$<br>$= \frac{x}{3\sqrt{4+x^2}} - \frac{1}{5}$<br>$= \frac{5x - 3\sqrt{4+x^2}}{15\sqrt{4+x^2}}$<br>$= \frac{16(x+\frac{3}{2})(x-\frac{3}{2})}{15\sqrt{4+x^2}(5x+3\sqrt{4+x^2})}$<br>ដោយ $x > 0$ ភាគបែងវិជ្ជមាន<br>ហើយ $16(x+\frac{3}{2}) > 0$<br>ដូចនេះដេរីវេមានសញ្ញាដូច<br>$x - \frac{3}{2} = 0 \Leftrightarrow x = \frac{3}{2}$ |

| | | |
|---|---|---|
| -លំហាត់គំរូទី២៖<br>គេចង់បានថាសមួយដល<br>មានកាំRទៅធ្វើជា<br>កោណមួយ។<br>គេត្រូវកាត់ចំរៀកថាស<br>មួយយកចេញពីថាស<br>មូលនោះធ្វើយ៉ាងនេះ<br>គេបានកោណដូច<br>រូបខាងក្រោម៖<br><br>ក/ គណនាមាឌកោណជា<br>អនុគមន៍នៃ x<br>ដែលxជាមនៃចម្រៀក<br>ថាសែដលនៅសល់។<br>ខ/ រកតម្លៃxដើម្បីឲ្យមាឌ<br>កោណធំបំផុត។ | -តារាងអថេរភាព<br>$x$: $0$ … $\frac{3}{2}$ … $6$<br>$f'(x)$: $-$ $0$ $+$<br>$f(x)$: ↘ $f(\frac{3}{2})$ ↗<br>-បើ $x=\frac{3}{2}$ នោះ $f$<br>មានតម្លៃតូចបំផុត។<br><br>ដូចនេះចំណុច $M$ ត្រូវស្ថិត<br>នៅចម្ងាយ $\frac{3}{2}Km$ ពីចំណុច $B$<br>។<br>-លំហាត់គំរូទី២៖<br>គេចង់បានថាសមួយដែល<br>មានកាំRទៅធ្វើជា<br>កោណមួយ។<br>គេត្រូវកាត់ចំរៀកថាសមួយ<br>យកចេញពីថាសមូលនោះ<br>ធ្វើយ៉ាងនេះគេបានកោណ<br>ដូចរូបខាងក្រោម៖<br><br>ក/ គណនាមាឌកោណជា<br>អនុគមន៍នៃ x<br>ដែលxជាមនៃចម្រៀក<br>ថាសែដលនៅសល់។<br>ខ/ រកតម្លៃxដើម្បីឲ្យមាឌ<br>កោណធំបំផុត។<br>ដំណោះស្រាយ<br>ក/ គណនាមាឌកោណជា | -តារាងអថេរភាព<br>$x$: $0$ … $\frac{3}{2}$ … $6$<br>$f'(x)$: $-$ $0$ $+$<br>$f(x)$: ↘ $f(\frac{3}{2})$ ↗<br>-បើ $x=\frac{3}{2}$ នោះ $f$<br>មានតម្លៃតូចបំផុត។<br><br>ដូចនេះចំណុច $M$ ត្រូវស្ថិត<br>នៅចម្ងាយ $\frac{3}{2}Km$ ពីចំណុច $B$<br>។<br>-លំហាត់គំរូទី២៖<br>គេចង់បានថាសមួយដែល<br>មានកាំRទៅធ្វើជា<br>កោណមួយ។<br>គេត្រូវកាត់ចំរៀកថាសមួយ<br>យកចេញពីថាសមូលនោះ<br>ធ្វើយ៉ាងនេះគេបានកោណដូច<br>រូបខាងក្រោម៖<br><br>ក/ គណនាមាឌកោណជា<br>អនុគមន៍នៃ x<br>ដែលxជាមនៃចម្រៀក<br>ថាសែដលនៅសល់។<br>ខ/ រកតម្លៃxដើម្បីឲ្យមាឌ<br>កោណធំបំផុត។<br>-សិស្សស្តាប់គ្រូពន្យល់ដោយ<br>យកចិត្តទិកដាក់និង |

អនុគមន៍នៃ x

ប្រវែងធ្នូ $AB$ គឺ $Rx$ គេបាន៖

$2\pi r = Rx \Rightarrow r = \frac{Rx}{2\pi}$

ដូចនេះកោណមានមាឌ

$V = \frac{1}{3}\pi r^2 h$

$= \frac{1}{3}\pi(\frac{Rx}{2\pi})^2\sqrt{R^2 - (\frac{Rx}{2\pi})^2}$

$= \frac{R^3}{24\pi^2}x^2\sqrt{4\pi^2 - x^2}$

$V$ មានតម្លៃលេខលុះត្រាតែ៖

$4\pi^2 - x^2 > 0 \Leftrightarrow 0 < x < 2\pi$

ខ/ រកតម្លៃxដើម្បីឲ្យមាឌ

កោណធំបំផុត

$V = \frac{R^3}{24\pi^2}x^2\sqrt{4\pi^2 - x^2}$

$V' = \frac{R^3}{24\pi^2}[2x\sqrt{4\pi^2 - x^2}$

$+ x^2\frac{(4\pi^2 - x^2)}{2\sqrt{4\pi^2 - x^2}}$

$= \frac{R^3}{24\pi^2}[\frac{8\pi^2 x - 3x^3}{\sqrt{4\pi^2 - x^2}}]$

$= \frac{R^3 x}{8\pi^2}\frac{(2\pi\sqrt{\frac{2}{3}} + x)}{\sqrt{4\pi^2 - x^2}}(2\pi\sqrt{\frac{2}{3}} - x)$

ដោយ $0 < x < 2\pi$ នោះ

$\frac{R^3 x}{8\pi^2}\left[\frac{2\pi\sqrt{\frac{2}{3}} + x}{\sqrt{4\pi^2 - x^2}}\right] > 0$

ហើយដេរីវេមានសញ្ញាដូច

$\left(2\pi\sqrt{\frac{2}{3}} - x\right)$

គេបានតារាងអថេរភាព

| $x$ | $0$ | | $2\pi\sqrt{\frac{2}{3}}$ | | $2\pi$ |
|---|---|---|---|---|---|
| $V'$ | | $+$ | $0$ | $-$ | |
| $V$ | | ↗ | | ↘ | |

អតិបរមា

នាំគ្នាធ្វើលំហាត់ដាក់ក្នុងសៀវភៅ។

ដំណោះស្រាយ

ក/ គណនាមាឌកោណជា

អនុគមន៍នៃ x

ប្រវែងធ្នូ $AB$ គឺ $Rx$ គេបាន៖

$2\pi r = Rx \Rightarrow r = \frac{Rx}{2\pi}$

ដូចនេះកោណមានមាឌ

$V = \frac{1}{3}\pi r^2 h$

$= \frac{1}{3}\pi(\frac{Rx}{2\pi})^2\sqrt{R^2 - (\frac{Rx}{2\pi})^2}$

$= \frac{R^3}{24\pi^2}x^2\sqrt{4\pi^2 - x^2}$

$V$ មានតម្លៃលេខលុះត្រាតែ៖

$4\pi^2 - x^2 > 0 \Leftrightarrow 0 < x < 2\pi$

ខ/ រកតម្លៃxដើម្បីឲ្យមាឌ

កោណធំបំផុត

$V = \frac{R^3}{24\pi^2}x^2\sqrt{4\pi^2 - x^2}$

$V' = \frac{R^3}{24\pi^2}[2x\sqrt{4\pi^2 - x^2}$

$+ x^2\frac{(4\pi^2 - x^2)}{2\sqrt{4\pi^2 - x^2}}$

$= \frac{R^3}{24\pi^2}[\frac{8\pi^2 x - 3x^3}{\sqrt{4\pi^2 - x^2}}]$

$= \frac{R^3 x}{8\pi^2}\frac{(2\pi\sqrt{\frac{2}{3}} + x)}{\sqrt{4\pi^2 - x^2}}(2\pi\sqrt{\frac{2}{3}} - x)$

ដោយ $0 < x < 2\pi$ នោះ

$\frac{R^3 x}{8\pi^2}\left[\frac{2\pi\sqrt{\frac{2}{3}} + x}{\sqrt{4\pi^2 - x^2}}\right] > 0$

ហើយដេរីវេមានសញ្ញាដូច

<table>
<tr><td></td><td>ដូចនេះកោណមានមាឌធំបំផុតបើ $x=2\pi\sqrt{\frac{2}{3}}$ ។</td><td>$\left(2\pi\sqrt{\frac{2}{3}}-x\right)$<br>គេបានតារាងអថេរភាព<br>$x$ : $0$ , $2\pi\sqrt{\frac{2}{3}}$ , $2\pi$<br>$V'$ : $+$ $0$ $-$<br>$V$ : ↗ អតិបរមា ↘<br>ដូចនេះកោណមានមាឌធំបំផុតបើ $x=2\pi\sqrt{\frac{2}{3}}$ ។</td></tr>
<tr><td colspan="3">ជំហានទី៤(១៥នាទី)</td></tr>
<tr><td>តើគេអនុវត្តន៍អនុគមន៍អសនិទានសំរាប់ធ្វើអ្វី?</td><td>ពង្រឹងពុទ្ធិ</td><td>-អនុវត្តន៍សំរាប់រកតម្លៃធំបំផុតរឺតូចបំផុត។</td></tr>
<tr><td colspan="3">ជំហានទី៥(៥នាទី)</td></tr>
<tr><td>ចូរប្អូនធ្វើលំហាត់ប្រតិបត្តិទំព័រទី៥១។</td><td>កិច្ចការផ្ទះ</td><td>-សិស្សកត់ត្រាកិច្ចការផ្ទះចូលសៀវភៅ។</td></tr>
</table>

# កិច្ចតែងការបង្រៀន

## ជំពូកទី៣ អថេរភាពនិងក្រាបនៃអនុគមន៍

## មេរៀនទី១ អនុគមន៍អសនិទាន

### I. វត្ថុបំណង

- ចំណេះដឹងៈ សិស្សប្រាប់រាងទូទៅរបស់អនុគមន៍អសនិទានបាន
- បំនិនៈ សិស្សចេះសិក្សាអថេរភាពនិងសង់ក្រាបនៃអនុគមន៍ $y=\sqrt{ax^2+bx+c};a\neq 0$
- ឥរិយាបថៈ សិស្សមានទំនុកចិត្តក្នុងការដោះស្រាយលំហាត់

### II. រយៈពេលៈ ២ម៉ោងសិក្សា

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្សទំព័រទី៨៤ដល់៨៨
- សៀវភៅគ្រូទំព័រទី៨៤ដល់៨៨
- បន្ទាត់និងឧបករណ៍គូសប៉ារ៉ាបូល

### IV. វិធីសាស្ត្របង្រៀន

- គោលវិធីសិស្សមជ្ឈមណ្ឌល

### V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | ជំហានទី១(៥នាទី) | |
| -គ្រូតពិនិត្យអវត្តមាន សណ្តាប់ធ្នាប់ វិន័យ និង បរិស្ថាន។ | (រដ្ឋបាលថ្នាក់) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| | ជំហានទី២(១០នាទី) | |
| -ចូនិយាយពីរបៀប សិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍ អសនិទាន $y=\sqrt{ax+b};a\neq 0$ | រំលឹកមេរៀនចាស់ | -ដើម្បីសិក្សាអថេរភាពនិង សង់ក្រាបនៃអនុគមន៍សនិទាន យើងត្រូវៈ<br>១/ រកដែនកំណត់<br>២/ ទិសដៅអថេរភាព<br>-រកដេរីវេទី១ៈ<br>សិក្សាភាពកើនរឺចុះនៃអនុន៍<br>-រកលីមីត<br>៣/ តារាងអថេរភាព |

<table>
<tr><td></td><td></td><td>៤/ សំណង់ក្រាប:<br>រកចំណុចប្រសព្វរវាងអក្ស័<br>អដោនេរ។</td></tr>
<tr><td colspan="3">ជំហានទី៣(៨០នាទី)</td></tr>
<tr><td>-គ្រូសរសេរចំណង់ជើង<br>មេរៀនថ្មី។<br>ដាក់ឧទាហរណ៍បង្ហាញ<br>ដល់សិស្ស។</td><td>មេរៀនថ្មី<br>ជំពូកទី៣<br>អថេរភាពនិងក្រាបនៃអនុគមន៍<br>មេរៀនទី១<br>អនុគមន៍អសនិទាន<br>II.សិក្សាអថេរភាពនៃអនុគន៍<br>$y=\sqrt{ax^2+bx+c};a\neq 0$<br>-សិក្សាអថេរភាពនិងសង់<br>ក្រាបនៃអនុគមន៍<br>$y=\sqrt{x^2-4x+3}$ ។<br>➢ រកដែនកំណត់<br>អនុគមន៍មានន័យកាលណា៖<br>$x^2-4x+3\geq 0$<br>បើ $x^2-4x+3=0$<br>$\Delta=(-4)^2-4.1.3=4$<br>$\Leftrightarrow x_1=1;x_2=3$<br>$\begin{array}{c|ccccc} x & -\infty & 1 & & 3 & +\infty \\ \hline x^2-4x+3 & + & 0 & - & 0 & + \end{array}$<br>គេបាន $x^2-4x+3\geq 0$<br>បើ $x\leq 1;x\geq 3$<br>ដូចនេះ $D=]-\infty;1]\cup[3;+\infty[$<br>➢ ទិសដៅអថេរភាព<br>-ដេរីវេ<br>$y'=\frac{(x^2-4x+3)'}{2\sqrt{x^2-4x+3}}$<br>$=\frac{x-2}{\sqrt{x^2-4x+3}}$<br>ដេរីវេមានសញ្ញាដូច $x-2$<br>ព្រោះ $\sqrt{x^2-4x+3}>0$</td><td>សិស្សកត់ត្រាមេរៀនថ្មី<br>មេរៀនថ្មី<br>ជំពូកទី៣<br>អថេរភាពនិងក្រាបនៃអនុគមន៍<br>មេរៀនទី១<br>អនុគមន៍អសនិទាន<br>II.សិក្សាអថេរភាពនៃអនុគន៍<br>$y=\sqrt{ax^2+bx+c};a\neq 0$<br>-សិក្សាអថេរភាពនិងសង់<br>ក្រាបនៃអនុគមន៍<br>$y=\sqrt{x^2-4x+3}$ ។<br>➢ រកដែនកំណត់<br>អនុគមន៍មានន័យកាលណា៖<br>$x^2-4x+3\geq 0$<br>បើ $x^2-4x+3=0$<br>$\Delta=(-4)^2-4.1.3=4$<br>$\Leftrightarrow x_1=1;x_2=3$<br>$\begin{array}{c|ccccc} x & -\infty & 1 & & 3 & +\infty \\ \hline x^2-4x+3 & + & 0 & - & 0 & + \end{array}$<br>គេបាន $x^2-4x+3\geq 0$<br>បើ $x\leq 1;x\geq 3$<br>ដូចនេះ $D=]-\infty;1]\cup[3;+\infty[$<br>➢ ទិសដៅអថេរភាព<br>-ដេរីវេ<br>$y'=\frac{(x^2-4x+3)'}{2\sqrt{x^2-4x+3}}$<br>$=\frac{x-2}{\sqrt{x^2-4x+3}}$<br>ដេរីវេមានសញ្ញាដូច $x-2$</td></tr>
</table>

ចំពោះ $x<1$ ឬ $x>3$

បើ $x-2=0 \Leftrightarrow x=2$

| $x$ | $-\infty$ | 1 | 2 | 3 | $+\infty$ |
|---|---|---|---|---|---|
| $x-2$ | $-$ | | $-$ 0 $+$ | | $+$ |
| $y'$ | $-$ | | $-$ 0 $+$ | | $+$ |

-លីមីត

$y=\sqrt{x^2-4x+3}$

$=\sqrt{(x-2)^2-1}$

$=|x-2|+\varepsilon(x)$

ដែល $\lim\limits_{x\to+\infty}\varepsilon(x)=0$

គេបាន

$f(x)=x-2+\varepsilon(x); x\geq 3$

$f(x)=-x+2+\varepsilon(x); x\leq 1$

$\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} x-2+\varepsilon(x)$

$=+\infty$

$\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} -x+2+\varepsilon(x)$

$=+\infty$

-អាស៊ីមតូត៖

ដោយ $\lim\limits_{x\to+\infty}\varepsilon(x)=0$

ដូចនេះ៖ $y=x-2$

ជាអាស៊ីមតូតទ្រេតខាង

$x\to+\infty$ ។

- $y=-x+2$

ជាអាស៊ីមតូតទ្រេតខាង

$x\to-\infty$ ។

-តារាងអថេរភាព

| $x$ | $-\infty$ | 1 | | 3 | $+\infty$ |
|---|---|---|---|---|---|
| $y'$ | $-$ | | | | $+$ |
| $y$ | $+\infty$ ↘ | 0 | | 0 | ↗ $+\infty$ |

➢ ក្រាប

តារាងអថេរភាព

| $x$ | 0 | 1 | 3 |
|---|---|---|---|
| $y$ | $\sqrt{3}$ | 0 | 0 |

ព្រោះ $\sqrt{x^2-4x+3}>0$

ចំពោះ $x<1$ ឬ $x>3$

បើ $x-2=0 \Leftrightarrow x=2$

| $x$ | $-\infty$ | 1 | 2 | 3 | $+\infty$ |
|---|---|---|---|---|---|
| $x-2$ | $-$ | | $-$ 0 $+$ | | $+$ |
| $y'$ | $-$ | | $-$ 0 $+$ | | $+$ |

-លីមីត

$y=\sqrt{x^2-4x+3}$

$=\sqrt{(x-2)^2-1}$

$=|x-2|+\varepsilon(x)$

ដែល $\lim\limits_{x\to+\infty}\varepsilon(x)=0$

គេបាន

$f(x)=x-2+\varepsilon(x); x\geq 3$

$f(x)=-x+2+\varepsilon(x); x\leq 1$

$\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} x-2+\varepsilon(x)$

$=+\infty$

$\lim\limits_{x\to+\infty} f(x)=\lim\limits_{x\to+\infty} -x+2+\varepsilon(x)$

$=+\infty$

-អាស៊ីមតូត៖

ដោយ $\lim\limits_{x\to+\infty}\varepsilon(x)=0$

ដូចនេះ៖ $y=x-2$

ជាអាស៊ីមតូតទ្រេតខាង

$x\to+\infty$ ។

- $y=-x+2$

ជាអាស៊ីមតូតទ្រេតខាង

$x\to-\infty$ ។

-តារាងអថេរភាព

| $x$ | $-\infty$ | 1 | | 3 | $+\infty$ |
|---|---|---|---|---|---|
| $y'$ | $-$ | | | | $+$ |
| $y$ | $+\infty$ ↘ | 0 | | 0 | ↗ $+\infty$ |

➢ ក្រាប

តារាងអថេរភាព

| $x$ | 0 | 1 | 3 |
|---|---|---|---|
| $y$ | $\sqrt{3}$ | 0 | 0 |

-គ្រូដាក់លំហាត់គំរូទី២
សិក្សាអថេរភាពនិងសង់ក្រាប
នៃអនុគមន៍៖
$y=\sqrt{-2x^2+10x-8}$



លំហាត់គំរូ២
សិក្សាអថេរភាពនិងសង់ក្រាប
នៃអនុគមន៍៖
$y=\sqrt{-2x^2+10x-8}$

➢ រកដែនកំណត់
អនុគមន៍មានន័យកាលណា៖
$-2x^2+10x-8\ge 0$
បើ $-2x^2+10x-8=0$
$\Leftrightarrow x_1=1; x_2=4$

សញ្ញានៃអនុគមន៍

| $x$ | $-\infty$ | 1 | | 4 | $+\infty$ |
|---|---|---|---|---|---|
| $-2x^2+10x-8$ | $-$ | 0 | $+$ | 0 | $-$ |

គេបាន៖ $-2x^2-10x-8\ge 0$
បើ $1\le x\le 4$
ដូចនេះ $D=[1;4]$ ។

➢ ទិសដៅអថេរភាព
-ដេរីវេ

$$y'=\frac{-4x+10}{2\sqrt{-2x^2+10x-8}}$$
$$=\frac{-2x+5}{\sqrt{-2x^2+10x-8}}$$

ដេរីវេមានសញ្ញាតាម $-2+5$
ព្រោះ
$\sqrt{-2x^2+10x-8}>0; \forall x\in ]1;4[$
ចំពោះ $x=\frac{5}{2}\Rightarrow y'=0$

| $x$ | 1 | | $\frac{5}{2}$ | | 4 |
|---|---|---|---|---|---|
| $y'$ | | $+$ | 0 | $-$ | |



លំហាត់គំរូ២
សិក្សាអថេរភាពនិងសង់ក្រាប
នៃអនុគមន៍៖
$y=\sqrt{-2x^2+10x-8}$

➢ រកដែនកំណត់
អនុគមន៍មានន័យកាលណា៖
$-2x^2+10x-8\ge 0$
បើ $-2x^2+10x-8=0$
$\Leftrightarrow x_1=1; x_2=4$

សញ្ញានៃអនុគមន៍

| $x$ | $-\infty$ | 1 | | 4 | $+\infty$ |
|---|---|---|---|---|---|
| $-2x^2+10x-8$ | $-$ | 0 | $+$ | 0 | $-$ |

គេបាន៖ $-2x^2-10x-8\ge 0$
បើ $1\le x\le 4$
ដូចនេះ $D=[1;4]$ ។

➢ ទិសដៅអថេរភាព
  - o ស្គាល់ច្បាស់អំពី បញ្ញាត្តទូទៅក្នុងការគណនា មាឌនៃសូលីតបរិវត្ត ដែលបានពីរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃដែលខ័ណ្ឌដោយខ្សែកោង $y=(x)$ និង $y=g(x)$ នៅលើចន្លោះ $[a;b]$ ដែល $f(x)\geq g(x)$ កំណត់ដោយ $V=\pi\int_a^b\left[f(x)\right]^2dx-\pi\int_a^b\left[g(x)\right]^2dx$ ។
  - o យល់ពីនិយមន័យ និងរូបមន្ត អាំងតេក្រាលដើម្បីគណនាមាននៃអាំងតេក្រាលបានត្រឹមត្រូវ ។
- **បំណិន:** ចេះប្រើរូបមន្ត និងនិយមន័យដើម្បីដោះស្រាយលំហាត់មានត្រឹមត្រូវ
  - o ចេះសង្ខេបខ្លឹមសាមេរៀន
- **ឥរិយាបទ:** សិស្សមានបម្រុងប្រយ័ត្នខ្ពស់ក្នុងការដោះស្រាយលំហាត់។កែប្រែចំណុចខ្វះខាត និងការយល់ច្រលំមួយចំនួន និងទាញយកប្រយោជន៍ពីគណិតវិទ្យាទៅប្រើប្រាស់ក្នុងស្ថានភាពរស់នៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃ ហើយមានលក្ខណៈតក្កៈ ។

II. **សម្ភារៈឧបទេស:**

- គ្រូបង្រៀនៈ សៀវភៅគ្រូ កិច្ចតែងការបង្រៀន, សៀវភៅសិស្ស,
- សិស្សៈ មានសៀវភៅពុម្ពសិស្ស, សៀវភៅកត់ត្រា

III. **ដំណើរនាំមេរៀន:**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១៖ រដ្ឋបាលថ្នាក់រៀន** | | |
| គ្រូតពិនិត្យសណ្តាប់ធ្នាប់, អណាម័យ និងវត្តមានសិស្សក្នុងថ្នាក់រៀន ។ | | ប្រធានថ្នាក់ឡើងរាយការណ៍ ។ |
| **ជំហានទី២៖ រំឭកមេរៀន** | | |

| | | |
|---|---|---|
| ចូរគណនា $\int_1^2 x^2dx$ ។ | | $=\frac{1}{3}x^3+c$ |
| **ជំហានទី៣៖ ខ្លឹមសារមេរៀន** | | |
| • គ្រូផ្តល់ឧទាហរណ៍គំរូ ដូចជា $y=x^2$ , $g=\sqrt{x}$ ដែលត្រូវនឹងចន្លោះ $[0;1]$ ។ រួចគ្រូត្រូវគណនាមាឌនៃ $y$ គឺ $V_y=\frac{\pi}{5}$ និង មាឌនៃ $g$ គឺ $V_g=\frac{\pi}{2}$ ។<br>យើងយក $V=V_g-V_y$<br>$=\pi\int_0^1[g(x)]^2dx-\pi\int_0^1[f(x)]^2dx$<br>$=\frac{\pi}{2}-\frac{\pi}{5}=\frac{3\pi}{10}$ ឯកតាមាឌ ឲ្យសិស្សសង្កេត ចំពោះចន្លោះ $[0;1]$ គេបាន $x^2\le\sqrt{x}\Leftrightarrow f\le g$ នោះ៖ មាឌនៃសូលីតនៅចន្លោះ $[0;1]$ ខណ្ឌដោយ $f$ និង $g$ គឺស្មើនឹង<br>$V=\int_0^1[g(x)-f(x)]dx$ ។<br>• គ្រូផ្តល់បញ្ញត្តិទូទៅក្នុងការគណនាមាឌសូលីតបរិវត្តកំណត់បានពីការបង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃខណ្ឌដោយខ្សែកោង $y=f(x)$ និង $y=g(x)$ លើចន្លោះ $[a;b]$ ដែល $f(x)\ge g(x)$ ។<br>• គ្រូដាក់ឧទាហរណ៍គំរូ ទីមួយ និងទីពីរ ។ | **1.1. មាឌសូលីតបរិវត្តដែលបានពីរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃខណ្ឌដោយខ្សែកោងនិងអ័ក្សអាប់ស៊ីស(ត)**<br>ជាទូទៅ: មាឌនៃសូលីតបរិវត្តកំណត់បានពីការបង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃខណ្ឌដោយខ្សែកោង $y=f(x)$ និង $y=g(x)$ លើចន្លោះ $[a;b]$ ដែល $f(x)\ge g(x)$ កំណត់ដោយ:<br>$V=\pi\int_a^b\left[f(x)\right]^2dx-\pi\int_a^b\left[g(x)\right]^2dx$ ។<br>**លំហាត់គំរូ១៖** កំណត់មាឌសូលីតបរិវត្តកំណត់បានពីរង្វិលជុំវិញអ័ក្ស $(ox)$ នៃផ្ទៃខណ្ឌដោយក្រាបអនុ. $f(x)=x^2+1$ និង $g(x)=-x+3$ ដែលត្រូវនឹង $0\le x\le1$ ។<br>ចម្លើយ:<br>$V=\pi\int_a^b\left[f(x)\right]^2dx-\pi\int_a^b\left[g(x)\right]^2dx$<br>$=\pi\int_0^1[-x+3]^2dx-\pi\int_0^1\left[x^2+1\right]^2dx$<br>$=\frac{67\pi}{15}$<br>**លំហាត់គំរូទី២៖** គណនាមាឌសូលីតបរិវត្តកំណត់បានពីការរង្វិលជុំវិញអ័ក្សអាប់ស៊ីសនៃផ្ទៃខណ្ឌដោយក្រាបតាងដោយ: $y=\sqrt{x}$ និង $y=x^2$ ; $(0\le x\le1)$ ។<br>**ចម្លើយ:** | សិស្សស្តាប់និងកត់ត្រា<br>ចម្លើយ:<br>ចំពោះ $0\le x\le1$ នោះ $2\le-x+3\le3$ $\Leftrightarrow 2\le g(x)\le3$ និង $0\le x^2+1\le2$ $\Leftrightarrow 0\le f(x)\le1$ នោះ: $g(x)\ge f(x)$ ។ យើងបានមាឌសូលីតដែលបង្កើតបានមកពីការរង្វិលជុំវិញអ័ក្សអាប់ស៊ីសនូវផ្ទៃខណ្ឌដោយក្រាបនៃអនុ. ទាំង២កំណត់ដោយ:<br>$V=\pi\int_a^b\left[f(x)\right]^2dx-\pi\int_a^b\left[g(x)\right]^2dx$<br>$=\pi\int_0^1[-x+3]^2dx-\pi\int_0^1\left[x^2+1\right]^2dx$<br>$=\frac{67\pi}{15}$<br>ចម្លើយ:<br>ចំពោះ $0\le x\le1$ គេបាន:<br>$\sqrt{x}\ge x^2\Leftrightarrow f(x)\ge g(x)$<br>នោះ៖ |

| | | |
|---|---|---|
| | $V=\pi\int_0^1\left(\sqrt{x}\right)^2 dx-\pi\int_0^1\left(x^2\right)^2 dx$<br>$=\pi\int_0^1\left(x-x^4\right)dx=\frac{3\pi}{10}$ | $V=\pi\int_0^1\left(\sqrt{x}\right)^2 dx-\pi\int_0^1\left(x^2\right)^2 dx$<br>$=\pi\int_0^1\left(x-x^4\right)dx=\frac{3\pi}{10}$ |
| គ្រូបញ្ជាក់អំពីនិយមន័យ និងបញ្ញត្តិក្នុងការគណនាមាឌនៃសូលីតបរិវត្តដែលវិលជុំវិញអ័ក្សអរដោនេ ។ | **1.2: មាឌសូលីតបរិវត្តដែលបានពីការរង្វិលជុំវិញអ័ក្សអរដោនេ**<br>ដោយរង្វិលជុំវិញអ័ក្ស $(oy)$ នូវផ្ទៃដែលកំណត់ដោយក្រាប $x=g(y)$ និងបន្ទាត់ដេកy=aនិង y=b បង្កើតបានជាសូលីតមួយដែលមានមាឌកំណត់ដោយ:<br>$V=\pi\int_a^b\left[g(y)\right]^2 dy$ ។ | |
| គ្រូណែនាំពី របៀបដោះស្រាយលំហាត់គំរូ១ ដោយប្រើតាមបញ្ញត្តិ ។ | ឧទាហរណ៍១៖ គណនាមាឌសូលីតបរិវត្តដែលបង្កើតពីការរង្វិលក្រាបតាងដោយ $y=\sqrt{3-x}$ និង $o\le y\le\sqrt{3}$ ។<br>ចម្លើយ: $V=\pi\int_0^{\sqrt{3}}\left(3-y^2\right)dx=\frac{24\sqrt{3}\pi}{5}$ | ចម្លើយ:<br>គេមាន $y=\sqrt{3-x}$ នោះ<br>$y^2=2-x\Leftrightarrow x=3-y^2$<br>នោះ:<br>$V=\pi\int_0^{\sqrt{3}}\left(3-y^2\right)dx=\frac{24\sqrt{3}\pi}{5}$ |
| គ្រូណែនាំពីបញ្ញត្តិទូទៅ និងទ្រឹស្តីបទក្នុងការកំណត់អនុគមន៍តាមអាំងតេក្រាលកំណត់ ។ | **2. កំណត់អនុគមន៍តាមអាំងតេក្រាលកំណត់**<br>**ជាទូទៅ:** $f$ ជាអនុគមន៍កំណត់ និងជាប់លើ $[a;b]$ ។ អនុគមន៍ $F$ ដែលកំណត់និងជាប់លើចន្លោះ $[a;b]$ ដោយ<br>$F(x)=\int_a^x f(t)\,dt$ ហៅថាអនុគមន៍កំណត់តាមអាំងតេក្រាលកំណត់ ។<br>**ទ្រឹស្តីបទ:** បើ $f$ ជាអនុគមន៍ជាប់លើចន្លោះ $[a;b]$ នោះអនុគមន៍ $F$ កំណត់លើចន្លោះ $[a;b]$ ដោយ<br>$F(x)=\int_a^x f(t)\,dt$ ជាប់លើចន្លោះ $[a;b]$ និងមានដេរីវេគ្រប់ចំណុចលើចន្លោះ $[a;b]$ ហើយ<br>$\frac{d}{dx}\left[f(x)\right]=\frac{d}{dx}\left[\int_a^x f(t)\,dt\right]=f(x)$ ។ | |
| គ្រូណែនាំសិស្សអោយធ្វើសម្រាយបញ្ជាក់ទៅលើទ្រឹស្តីបទនេះ ។ | **សម្រាយបញ្ជាក់**<br>$F(t)=$ ជាព្រីមីទីវនៃ $f(t)$<br>$\int_a^x f(t)\,dt=F(x)-F(a)$ នោះ: | |

| | | |
|---|---|---|
| គ្រូណែនាំសិស្សអោយធ្វើលំហាត់ជាក្រុម ឬជាដៃគូរ | $\frac{d}{dx}\int_a^x f(t)\,dt = \frac{d}{dx}\left[F(x)-F(a)\right]$<br>$=\frac{d}{dx}\left[f(x)\right]=f(x)$ ។<br>**លំហាត់គំរូ** គណនា<br>ក. $\frac{d}{dx}\int_0^x \cos t\,dt$ ខ. $\frac{d}{dx}\int_0^x \frac{\sin t}{t^2+1}dt$<br>គ. $\frac{d}{dx}\int_0^x \sqrt{t^2+1}\,dt$ | ចម្លើយ:<br>ក. $\cos x$<br>ខ. $\frac{\sin x}{x^2+1}$ គ. $\sqrt{x^2+1}$ |
| **ជំហានទី ៤៖ ពង្រឹងពុទ្ធិ** | | |
| អោយសិស្សធ្វើលំហាត់ប្រតិបត្តិ | ក. គេអោយ $F(x)=\int_0^x t(t^2-1)\,dt$ ។ គណនា $\frac{d}{dx}\left[F(x)\right]$ ។<br>ខ. $F(x)=\int_0^x t\cos t\,dt$ ។ គណនា $\frac{d}{dx}\left[F\left(\frac{\pi}{3}\right)\right]$ ។ | $\frac{d}{dx}F(x)=\frac{d}{dx}\left[\int_0^x t(t^2-1)\,dt\right]$<br>$=x(x^2-1)$<br>$\frac{d}{dx}F(x)=\frac{d}{dx}\int_0^x t\cos t\,dt$<br>$=x\cos x$<br>នោះ $\frac{d}{dx}F\left(\frac{\pi}{3}\right)=0$ ។ |
| **ជំហានទី៥៖ បណ្តាំផ្ញើ** | | |
| ចូរប្អូនៗយកមេរៀននេះឡើងវិញ ។<br>និងប្អូនៗ ត្រូវមើលមេរៀនបន្ទាប់ ។ | | សិស្សស្តាប់ និងកត់ត្រាដោយយកចិត្តទុកដាក់ ។ |

# កិច្ចតែងការបង្រៀន

## ជំពូកទី ៤ អាំងតេក្រាលកំណត់

## មេរៀនទី២ មាឌសូលីត និងប្រវែងធ្នូ (តចប់)

ម៉ោងទី រយៈពេល ២ ម៉ោង

I. **គោលបំណង:** ក្រោយពេលរៀនចប់សិស្សទទួលបាន:

- **ចំណេះដឹង:** សិស្សនឹង
  - ស្គាល់ច្បាស់អំពី បញ្ញាត្តទូទៅក្នុងការគណនា រកតម្លៃមធ្យមនៃអនុគមន៍, បំណកស្រាយតាមបែបធរណីមាត្រ ។
  - ចេះកំណត់ពីរបៀបគណនាប្រវែងធ្នូនៃក្រាប ។
- **បំណិន:** ចេះប្រើរូបមន្ត និងនិយមន័យដើម្បីដោះស្រាយលំហាត់មានត្រឹមត្រូវ
  - ចេះសង្ខេបខ្លឹមសាមេរៀន
- **ឥរិយាបថ:** សិស្សមានបម្រុងប្រយ័ត្នខ្ពស់ក្នុងការដោះស្រាយលំហាត់។កែប្រែចំណុចខ្វះខាត និងការយល់ច្រលំមួយចំនួន និងទាញយកប្រយោជន៍ពីគណិតវិទ្យាទៅប្រើប្រាស់ក្នុងស្ថានភាពរស់នៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃ ហើយមានលក្ខណៈតក្កៈ ។

II. **សម្ភារៈឧបទេស:**

- គ្រូបង្រៀន: សៀវភៅគ្រូ កិច្ចតែងការបង្រៀន, សៀវភៅសិស្ស,
- សិស្ស: មានសៀវភៅពុម្ពសិស្ស, សៀវភៅកត់ត្រា

III. **បញ្ញាត្តិមេរៀន**

- $f$ ជាប់លើចន្លោះ $[a;b]$ នោះតម្លៃមធ្យមនៃអនុគមន៍ធៀបនឹង $x$ កំណាត់ដោយ $y_m = \dfrac{1}{a-b}\int_a^b f(x)dx$ ។
- ប្រវែងធ្នូនៃក្រាបតាងអនុគមន៍ $f$ នៅចន្លោះបន្ទាត់ឈរ $x=a$ និង $x=b$ កំណត់ដោយរូបមន្ត $L=\int_a^b \sqrt{1+\left[f'(x)\right]^2}dx$

IV. **ដំណើកនាំមេរៀន:**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១៖ រដ្ឋបាលថ្នាក់រៀន | | |

<table>
<tr><td>គ្រូតពិនិត្យសណ្តាប់ធ្នាប់, អវត្តមាន និងវត្តមានសិស្សក្នុងថ្នាក់រៀន ។</td><td></td><td>ប្រធានថ្នាក់ឡើងរាយការណ៍ ។</td></tr>
<tr><td colspan="3" align="center">ជំហានទី២៖ រំឭកមេរៀន</td></tr>
<tr><td>ក.គេអោយ $P(x)=\int_0^x \sin t dt$ ។ គណនា $\frac{d}{dx}P(x)$ ។<br>ខ. $F=\int\limits_0^x \sqrt{t^2-5t+4}$ ។<br>គណនា $\frac{d}{dx}F(x)$</td><td></td><td>ចម្លើយ:<br>ក. $\frac{d}{dx}P(x)$<br>$=\frac{d}{dx}\left[\int_0^x \sin t dt\right]=\sin x$<br>ខ. $\frac{d}{dx}F$<br>$=\frac{d}{dx}\left[\int\limits_0^x \sqrt{t^2-5t+4}\right]$<br>$=\sqrt{x^2-5x+4}$</td></tr>
<tr><td colspan="3" align="center">ជំហានទី៣៖ ខ្លឹមសារមេរៀន</td></tr>
<tr><td>គ្រូណែនាំនិងផ្តល់និយមន័យអោយសិស្សដើម្បីរកតន្លៃនៃអនុគមន៍ ។<br>បន្ទាប់គ្រូស្រាយបញ្ជាក់រូបមន្តនោះអោយសិស្ស ។<br><u>ជាទូទៅ</u>៖បើ $f$ ជាអនុគមន៍កំណត់ និងជាប់លើចន្លោះ $[a;b]$ នោះគេបានតម្លៃមធ្យមនៃតម្លៃ អនុគមន៍លើចន្លោះ $[a;b]$ តាមរបៀបដូចខាងក្រោម:<br>. ចែកចន្លោះ $[a;b]$ ជា $n$ ចំណែកស្មើៗគ្នា ហើយចន្លោះនិមួយៗមានប្រវែង $\Delta x=\frac{b-a}{n}$ ។ យក $x_1;x_2;..;x_n$ ជាតម្លៃនោះចន្លោះតូចៗនិមួយៗរៀងគ្នា។<br>. រកតម្លៃប្រហែលនៃតម្លៃ</td><td>3. តម្លៃមធ្យមនៃអនុគមន៍<br>និយមន័យ: $f$ ជាប់លើចន្លោះ $[a;b]$ នោះតម្លៃមធ្យមនៃអនុគមន៍ធៀបនឹង $x$ កំណត់ដោយ $y_m=\frac{1}{a-b}\int_a^b f(x)dx$<br>បំណកស្រាយតាមបែបធរណីមាត្រ<br>$y_m=\frac{1}{a-b}\int_a^b f(x)dx \qquad (1)$<br>គុណ $(1)$ និង $(b-a)$ គេបាន:<br>$y_m(b-a)=\int_a^b f(x)dx \qquad (2)$ យើងឃើញថា នៅអង្គខាងស្តាំនៃ $(2)$ គឺជាផ្ទៃនៃប្លង់ដែលខណ្ឌដោយក្រាប $y=f(x)$ និង បន្ទាត់ $x=a;x=b$ ។ ហើយអង្គខាងឆ្វេងគឺជាផ្ទៃក្រឡានៃចតុកោណកែងដែលមានទទឹង $f_m$ និងបណ្តោយ $(b-a)$ ។ ដូចនេះ តាម $(2)$ គេអាចអះអាងថា តម្លៃមធ្យមនៃអនុ. លើ $[a;b]$ គឺជាទទឹងនៃចតុកោណកែងដែលមានបណ្តោយ $(b-a)$ និងផ្ទៃក្រឡាស្មើនឹងផ្ទៃក្រឡានៃប្លង់ដែលកំណត់ដោយក្រាបនៃ</td><td>សិស្សស្តាប់និងកត់ត្រា<br><u>ជាទូទៅ</u>៖បើ $f$ ជាអនុគមន៍កំណត់ និងជាប់លើចន្លោះ $[a;b]$ នោះគេបានតម្លៃមធ្យមនៃតម្លៃ អនុគមន៍លើចន្លោះ $[a;b]$ តាមរបៀបដូចខាងក្រោម:<br>. ចែកចន្លោះ $[a;b]$ ជា $n$ ចំណែកស្មើៗគ្នា ហើយចន្លោះនិមួយៗមានប្រវែង $\Delta x=\frac{b-a}{n}$ ។ យក $x_1;x_2;..;x_n$ ជាតម្លៃនោះចន្លោះតូចៗនិមួយៗរៀងគ្នា ។<br>. រកតម្លៃប្រហែលនៃតម្លៃមធ្យមរបស់ $f$ នៅលើ $[a;b]$ ។ នោះ</td></tr>
</table>

មធ្យមរបស់ $f$ នៅលើ $[a;b]$ ។ នោះ:

$$\frac{f(x_1)+..+f(x_n)}{n}$$

$$=\frac{1}{b-a}.\left[f(x_1)\frac{b-a}{n}+...+f(x_n)\frac{b-a}{n}\right]$$

$$=\frac{1}{b-a}\left[f(x_1)\Delta x+...+f(x_n)\Delta x\right]$$

$$=\frac{1}{b-a}\sum_{k=1}^{n} f(x_k)\Delta x$$

បើ $n\to\infty$ នោះ: $\frac{1}{b-a}\sum_{k=1}^{n} f(x_k)\Delta x$ មានតម្លៃកាត់តែជាក់លាក់ ហើយខិតទៅរកតម្លៃមធ្យមមួយដែលតាង $y_m$ គឺ

$$y_m=\frac{1}{b-a}\lim_{n\to\infty} f(x_k)\Delta x$$

$$=\frac{1}{b-a}\int_a^b f(x)dx$$

ដូចនេះ គេបាននិមយន័យដូចខាងលើ ។

អនុ. $y=f(x)$ និងបន្ទាត់ $x=a;x=b$ ។

**លំហាត់គំរូ១៖** គននតម្លៃមធ្យមនៃអនុ. $y=\sqrt{x}$ លើចន្លោះ $[0;4]$ ។

ចម្លើយ: តាមរូបមន្ត:

$$y_m=\frac{1}{b-a}\int_a^b f(x)dx$$

$$=\frac{1}{4-0}\int_0^4\sqrt{x}dx=\frac{4}{3}$$

**លំហាត់គំរូ២៖** ក. គណនាតម្លៃមធ្យមនៃ $y=\sin x$ លើ $\left[0;\frac{\pi}{2}\right]$ ។

ខ. សង់ក្រាប អនុគមន៍ $y=\sin x$ និងចតុកោណកែងដែលមានទទឹងជាតម្លៃធម្យមនៃ $y$ ។

ចម្លើយ: ក. $y=\frac{2}{\pi}$ ។

ខ. សង់ក្រាប:




**4. ប្រវែងធ្នូនៃក្រាប**

$f$ ជាអនុគមន៍ជាប់និងកំណត់ដោយ $y=f(x)$ និងមានក្រាប $C$ ។ គេអាចគណនាប្រវែងធ្នូ $\widehat{AB}$ នៃក្រាប $C$ ដែលនៅចន្លោះបន្ទាត់ $x=a$ និង $x=b$ តាមរបៀបខាងក្រោម:

គេចែកចន្លោះ $[a;b]$ ជា $n$ ចំណែកស្មើនឹង $\Delta x=\frac{b-a}{n}$ ។ គេយកចំណុច $P_0(x;f(x))$ និងចំណុច $P(x+\Delta x;f(x+\Delta x))$ ដែល $a\le x<x+\Delta x\le b$ ។ តាង $\Delta y=f(x+\Delta x)-f(x)$

$$\frac{f(x_1)+..+f(x_n)}{n}$$

$$=\frac{1}{b-a}.\left[f(x_1)\frac{b-a}{n}+...+f(x_n)\frac{b-a}{n}\right]$$

$$=\frac{1}{b-a}\left[f(x_1)\Delta x+...+f(x_n)\Delta x\right]$$

$$=\frac{1}{b-a}\sum_{k=1}^{n} f(x_k)\Delta x$$

បើ $n\to\infty$ នោះ: $\frac{1}{b-a}\sum_{k=1}^{n} f(x_k)\Delta x$ មានតម្លៃកាត់តែជាក់លាក់ហើយខិតទៅរកតម្លៃមធ្យមមួយដែលតាង $y_m$ គឺ

$$y_m=\frac{1}{b-a}\lim_{n\to\infty} f(x_k)\Delta x$$

$$=\frac{1}{b-a}\int_a^b f(x)dx$$

ដូចនេះ **និយមន័យ:** $f$ ជាប់លើចន្លោះ $[a;b]$ នោះតម្លៃមធ្យមនៃអនុគមន៍ធៀបនឹង $x$ កំណត់ដោយ

$$y_m=\frac{1}{a-b}\int_a^b f(x)dx \text{ ។}$$

**4. ប្រវែងធ្នូនៃក្រាប**

**ជាទូទៅ** ប្រវែងនៃខ្សែកោងតាងអនុគមន៍ $f$ នៅចន្លោះ: $[a;b]$ កំណត់ដោយ:

$$L=\int_a^b\sqrt{1+(y')^2}dx \text{ ។}$$

| | | |
|---|---|---|
| | $\Delta L = P_oP \Rightarrow \Delta L = \sqrt{(\Delta x)^2 + (\Delta y)^2}$<br>$= \sqrt{(\Delta x)^2\left[1+\left(\frac{\Delta y}{\Delta x}\right)\right]^2}$<br>$\Rightarrow \Delta L = \sqrt{(\Delta x)^2\left[1+\left(\frac{\Delta y}{\Delta x}\right)\right]^2}\,(\Delta x)$<br>ដូចនេះ ពេល $n \to \infty \Rightarrow \Delta x \to 0$<br>$\Rightarrow dL = \sqrt{1+\left(\frac{dy}{dx}\right)^2}.dx$<br>$= \sqrt{1+(y')^2}dx$<br>$\Rightarrow L = \int_a^b \sqrt{1+(y')^2}dx$<br>ដូចនេះ ជាទូទៅ ប្រវែងនៃខ្សែកោងតាងអនុគមន៍ $f$ នៅចន្លោះ $[a;b]$ កំណត់ដោយៈ $L = \int_a^b \sqrt{1+(y')^2}dx$ ។<br>**លំហាត់គំរូ១៖ គណនាប្រវែងធ្នូនៃក្រាប** តាងអនុគមន៍ $y = f(x) = \frac{4\sqrt{2}}{3}x^{\frac{3}{2}} - 1$ នៅចន្លោះបន្ទាត់ឈរ $x=0$ និង $x=1$ ។<br>**ចម្លើយ:**<br>យើងមាន $y = f(x) = \frac{4\sqrt{2}}{3}x^{\frac{3}{2}} - 1$ នោះ<br>$y' = 2\sqrt{2}\sqrt{x}$<br>$\Rightarrow L = \int_0^1 \sqrt{1+8x}dx = \frac{13}{6}$ | **លំហាត់គំរូ១៖ គណនាប្រវែងធ្នូនៃក្រាបតាងអនុគមន៍** $y = f(x) = \frac{4\sqrt{2}}{3}x^{\frac{3}{2}} - 1$ នៅចន្លោះបន្ទាត់ឈរ $x=0$ និង $x=1$ ។<br>**ចម្លើយ:**<br>យើងមាន<br>$y = f(x) = \frac{4\sqrt{2}}{3}x^{\frac{3}{2}} - 1$<br>នោះ<br>$y' = 2\sqrt{2}\sqrt{x}$<br>$\Rightarrow L = \int_0^1 \sqrt{1+8x}dx = \frac{13}{6}$ |
| **ជំហានទី ៤៖ ពង្រឹងពុទ្ធិ** | | |
| អោយសិស្សធ្វើលំហាត់ប្រតិបត្តិ<br>ក.គណនាប្រវែងធ្នូ $y = \frac{1}{3}(x^2+2)^{\frac{3}{2}}$ នៅចន្លោះ $[0;3]$ ។<br>ខ. គណនាប្រវែងធ្នូ $L(a): y = x^{3/2}\ ;\ a \ge \frac{5}{9}$ | | ក. យើងមាន $y = \frac{1}{3}(x^2+2)^{\frac{3}{2}}$<br>$\Rightarrow y' = \frac{1}{2}(x^2+2)^{\frac{1}{2}}$<br>នោះ $L(a) = \frac{27}{4}$ ។<br>ខ. $a = \frac{32}{9}$ |

| | | |
|---|---|---|
| ។ចូររក $L(a)$ និង តម្លៃ $a$ បើ $L(a)=7$ ។ | | |
| **ជំហានទី៥៖ បណ្តាំផ្ញើ** | | |
| ចូរប្អូនៗយកមេរៀននេះឡើងវិញ និងប្អូនៗ ត្រូវធ្វើលំហាត់ចុងសៀវមេរៀន។ | | សិស្សស្តាប់ និងកត់ត្រាដោយយកចិត្តទុកដាក់ ។ |

# កិច្ចតែងការបង្រៀន

## ❖ ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល

## ❖ មេរៀនទី១ សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១

I. **វត្ថុបំណងមេរៀន:**ក្រោយពីរៀនមេរៀនចប់សិស្សអាចៈ

- ចំណេះដឹង:កំណត់សញ្ញាណនៃសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១បានត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀន។
- ចំណេះធ្វើ:ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១បានត្រឹមត្រូវតាមរយៈឧទាហរណ៍របស់គ្រូ។
- ឥរិយាបថ:មានស្មារតីទទួលខុសត្រូវលើការអនុវត្តន៍លំហាត់បានកំរិតខ្ពស់។

II. **រយៈពេល:** ០១ម៉ោង

III. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រទី៩២ ៩៧ បោះពុម្ពឆ្នាំ២០១០
- ម៉ែតឈើ

IV. **ដំណើរការនៃការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -ពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -អោយសិស្សឡើងធ្វើ លំហាត់<br>-គណនាដេរីវេនៃអនុគមន៍<br>$y=(3x^4+5)^6$<br><br>-គណនាអាំងតេក្រាល<br>$\int(x^7-11x^5+\frac{3}{5}x^2)dx$ | ជំហានទី២<br>(រំលឹកមេរៀនចាស់)<br>$y=(3x^4+5)^6$<br>$\Rightarrow y'=72x^3(3x^4+5)^5$<br><br>$\int(x^7-11x^5+\frac{3}{5}x^2)dx$<br>$=\frac{1}{8}x^8-\frac{11}{6}x^6+\frac{1}{5}x^3+c$ | -ឡើងធ្វើលំហាត់<br>$y=(3x^4+5)^6$<br>$\Rightarrow y'=6(3x^4+5)^5(3x^4+5)'$<br>$=72x^3(3x^4+5)^5$<br><br>$\int(x^7-11x^5+\frac{3}{5}x^2)dx$<br>$=\int x^7dx-11\int x^5dx+\frac{3}{5}\int x^2dx$<br>$=\frac{1}{8}x^8-\frac{11}{6}x^6+\frac{1}{5}x^3+c$ |

| | | |
|---|---|---|
| | ជំហានទី៣<br>(មេរៀនថ្មី) | |
| -បង្ហាញវត្ថុបំណងមេរៀនថ្ងៃនេះ | មេរៀនទី១**សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១**<br>1.**សញ្ញាណនៃសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១** | |
| -ដាក់ឧទាហរណ៍<br>-ចូរគណនា $y'$<br>-ចូរសរសេរទំនាក់ទំនងរវាង $y$ និង $y'$ | ឧទាហរណ៍:គេមានអនុគមន៍ $y=cx-3$ កំណត់លើ $\mathbb{R}$ ចំពោះគ្រប់ចំនួនពិត $c$ ។គណនាដេរីវេទី១ $y'$ រួចសរសេរទំនាក់ទំនងរវាង $y$ និង $y'$ ។ | -ពិនិត្យឧទាហរណ៍<br>-យើងមាន<br>$y=cx-3$<br>$\Rightarrow y'=c$<br>-ទំនាក់ទំនង $y$ និង $y'$ គេបាន<br>$y=xy'-3$<br>$y+3=xy'$<br>$y'=\frac{1}{x}y+\frac{3}{x}$<br>ឬ $y'-\frac{1}{x}y=\frac{3}{x}$ |
| -បញ្ជាក់សមីការពីសញ្ញាណនៃសមីការឌីផេរ៉ង់ស្យែលលំដាប់ទី ១ និងចម្លើយទូទៅ | -សមីការ $y'-\frac{1}{x}y=\frac{3}{x}$ ហៅថាសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ដែលមានអនុគមន៍ $y=cx-3$ ជាចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលនេះ។ | -យកចិត្តទុកដាក់ស្តាប់ការបញ្ជាក់របស់គ្រូ |
| -អោយសិស្សទាញនិយម ន័យ | -និយមន័យសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ | -ទាញនិយមន័យ<br>• សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ជាទំនាក់ទំនងរវាងអនុគមន៍ដេរីវេទី១របស់អនុគមន៍នោះ អថេរនិងចំនួនថេរ។<br>• ចម្លើយនៃសមីការឌីផេរ៉ង់ស្យែលជាអនុគមន៍មួយដែលអនុគមន៍នេះនិងដេរីវេរប |

| | | |
|---|---|---|
| | | ស់វាផ្ទៀងផ្ទាត់សមីការ។<br>• លំដាប់នៃសមីការឌីផេរ៉ង់ស្យែលគឺជាលំដាប់នៃដេរីវេខ្ពស់ជាងគេក្នុង សមីការ។ |
| -បញ្ជាក់ពីលក្ខណ:សំគាល់អនុគមន៍<br>ចម្លើយនៃសមីការឌីផេរ៉ង់ស្យែល<br><br><br><br>-ដាក់ឧទាហរណ៍អោយសិស្សឡើងធ្វើលើក្តារខៀន<br><br><br><br><br><br><br><br>-ដាក់ឧទាហរណ៍<br>-សរសេរសមីការឌីផេរ៉ង់ ស្យែល<br><br><br><br><br><br><br><br><br>-ចូរគណនាចំងាយចរក្នុងរយ:ពេ | -**សំគាល់:**អនុគមន៍ចម្លើយនៃសមីការឌីផេរ៉ង់ស្យែលមានច្រើនរាប់មិនអស់។<br>គ្រប់ខ្សែកោងដែលតាងចម្លើយនីមួយៗនៃសមីការបង្កើតបានជាគ្រួសារនៃខ្សែកោង។<br>ឧទាហរណ៍:គេមានអនុគមន៍ $y = ke^{-3x}$ កំណត់លើ $\mathbb{R}$ ចំពោះគ្រប់ចំនួនពិត $k$ ។សរសេរសមីការឌីផេរ៉ង់ស្យែលដែលមាន $y = ke^{-3x}$ ជាចម្លើយទូទៅ។<br>2.**ដំណោះស្រាយសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១**<br>2.1.**សមីការមានទម្រង់**<br>$\frac{dy}{dx} = f(x)$<br>ឧទាហរណ៍:វត្ថុPមួយផ្លាស់ទីតាមអ័ក្ស $\overrightarrow{ox}$ ដែលមានចំណុច $o$ ជាគល់ដោយល្បឿនថេរ $a$ (គិតជា $m$ ក្នុង1វិនាទី)។តាង $x(t)$ ជាចម្ងាយដែលPផ្លាស់ទីចេញពីចំណុច $o$ នៅលើអ័ក្សអស់រយ:ពេល $t$ ។ | <br><br><br><br>-ឡើងធ្វើឧទាហរណ៍<br>$y = ke^{-3x}$ នាំអោយ<br>$y' = -3ke^{-3x} = -3y$<br>គេបាន $y' + 3y = 0$ ជាសមីការឌីផេ<br>រ៉ង់ស្យែលដែលមានអនុគមន៍ $y = ke^{-3x}$ ជាចម្លើយទូទៅ។<br><br><br><br><br><br>-ពិនិត្យ<br>បើ $x(t)$ ជាចម្ងាយចរដែលPផ្លាស់ទីក្នុងរយ:ពេល $t$<br>នោះល្បឿននៃការផ្លាស់ទីរបស់វត្ថុPគឺ $x'(t)$ ។ដោយល្បឿននេះស្មើ $a$ នោះគេបាន $x'(t) = a$ ដែល $x'(t)$ ជាដេរីវេនៃ $x(t)$ សមីការ $x'(t) = a$ អាចសរសេរជា $\frac{dx}{dt} = a$ ។ |

| | | |
|---|---|---|
| ល $t$<br><br>-បញ្ជាក់ចម្លើយនៃ $\frac{dx}{dt}=a$<br>-គណនាចំងាយចរនៅខណៈ $t=2s$ បើខណៈ $t=0s$ វត្ថុP ផ្លាស់ទីបានចម្ងាយ $3m$ ពី គល់ $o$<br><br>-បញ្ជាក់ពីចម្លើយពិសេស<br><br>-ចូរកំណត់វិធានដើម្បីដោះស្រាយសមីការមានទម្រង់<br>$\frac{dy}{dx}=f(x)$ | $x(t)$ ជាចម្លើយនៃសមីការឌីផេរ៉ង់ស្យែល $\frac{dx}{dt}=a$ ។<br><br>- $x(t)=at+3$ ហៅថាចម្លើយពិសេសនៃសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១តាមលក្ខខ័ណ្ឌ $x(0)=3$<br>-ដើម្បីដោះស្រាយសមីការឌីផេរ៉ង់ស្យែលមានទម្រង់ $\frac{dy}{dx}=f(x)$<br>a).សរសេរ $\frac{dy}{dx}=f(x)$ ជា<br>$dy=f(x)dx$<br>b).រកអាំងតេក្រាលអង្គទាំងពីរ<br>$\int dy=\int f(x)dx$ ឬ<br>$y=\int f(x)dx+c$<br>$c$ ជាចំនួនថេរ | -យើងមាន<br>$\frac{dx}{dt}=a$<br>$\Rightarrow dx=adt \quad (1)$<br>បំពាក់អាំងតេក្រាលលើអង្គទាំងពីរនៃសមីការ(1) គេបាន<br>$\int dx=\int adt$<br>$x(t)=at+c \quad (c\in\mathbb{R})$<br>ជាចម្ងាយចរដែលPផ្លាស់ទីបានក្នុងរយៈពេល $t$<br>-គណនាចម្ងាយចរ<br>គេមាន $x(t)=ax+c$ ;<br>$(t=0;x=3)$គេបាន<br>$x(0)=a(0)+c$ ដោយ<br>$x(0)=3\Rightarrow c=3$ ដូចនេះ<br>$x(t)=at+3$ យើងបាន<br>$x(2)=2a+3$ ។<br><br>--ដើម្បីដោះស្រាយសមីការឌីផេរ៉ង់ស្យែលមានទម្រង់<br>$\frac{dy}{dx}=f(x)$<br>a).សរសេរ $\frac{dy}{dx}=f(x)$ ជា<br>$dy=f(x)dx$<br>b).រកអាំងតេក្រាលអង្គទាំងពីរ<br>$\int dy=\int f(x)dx$ ឬ<br>$y=\int f(x)dx+c$<br>$c$ ជាចំនួនថេរ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍អោយសិស្សពិភាក្សារួចឡើងធ្វើលើក្តា ខៀន | c). $y=\int f(x)dx+c$ ជាចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល $\frac{dy}{dx}=f(x)$<br>d).រកចម្លើយពិសេសតាមលក្ខខណ្ឌដើម $y(x_0)=y_0$ គឺយក $x_0$ និង $y_0$ ទៅជំនួសក្នុងចម្លើយទូទៅរួចទាញយក $c=y_0-F(x_0)$ នោះ $y=\int f(x)dx+y_0-F(x_0)$ ជាចម្លើយពិសេសតាមលក្ខខណ្ឌ $y(x_0)=y_0$ ។<br>ឧទាហរណ៍:ដោះស្រាយសមីការ $y'=\frac{2x}{x^2+1}$ | c). $y=\int f(x)dx+c$ ជាចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល $\frac{dy}{dx}=f(x)$<br>d).រកចម្លើយពិសេសតាមលក្ខខណ្ឌដើម $y(x_0)=y_0$ គឺយក $x_0$ និង $y_0$ ទៅជំនួសក្នុងចម្លើយទូទៅរួចទាញយក $c=y_0-F(x_0)$ នោះ $y=\int f(x)dx+y_0-F(x_0)$ ជាចម្លើយពិសេសតាមលក្ខខណ្ឌ $y(x_0)=y_0$ ។<br>-ពិភាក្សារួចឡើងធ្វើ<br>$y'=\frac{2x}{x^2+1}$ នាំអោយ<br>$\frac{dy}{dx}=\frac{2x}{x^2+1}$<br>$dy=\frac{2x}{x^2+1}dx$<br>$\int dy=\int\frac{2x}{x^2+1}dx$<br>$=\int\frac{d(x^2+1)}{x^2+1}$<br>$=\ln(x^2+1)+c$ ;$c$ ជាចំនួនថេរ<br>ដូចនេះ $y=\ln(x^2+1)+c$ |
| -ហៅសិស្សដោះស្រាយសមីការ<br>ក. $y'=6x^2+4x+5$<br>ខ. $y'=xe^{x^2}$ | ជំហានទី៤<br>(ពង្រឹងពុទ្ធិ)<br>$y'=6x^2+4x+5$<br>$\Rightarrow y=2x^3+2x^2+5x+c$ | -ឡើងធ្វើលំហាត់ |

| | | |
|---|---|---|
| | $y'=xe^{x^2} \Rightarrow y=\frac{1}{2}e^{x^2}+c$ | $y'=6x^2+4x+5$<br>$\Rightarrow \frac{dy}{dx}=6x^2+4x+5$<br>ក. $dy=(6x^2+4x+5)dx$<br>$\int dy=\int(6x^2+4x+5)dx$<br>$y+c_1=2x^3+2x^2+5x+c_2$<br>$y=2x^3+2x^2+5x+c$<br>ដែល $c=c_2-c_1$<br>ខ. $y'=xe^{x^2}$<br>$\Rightarrow \frac{dy}{dx}=xe^{x^2}$<br>$dy=xe^{x^2}dx$<br>$\int dy=\int xe^{x^2}dx$<br>តាង $t=x^2 \Rightarrow dt=2xdx$<br>$\Rightarrow dx=\frac{dt}{2x}$<br>គេបាន $\int xe^{x^2}dx=\int xe^t\frac{dt}{2x}$<br>$=\frac{1}{2}e^{x^2}+c$<br>ដូចនេះ $y=\frac{1}{2}e^{x^2}+c$ |
| -ទៅផ្ទះវិញធ្វើលំហាត់លេខ០១ ទំព័រទី១១០ | ជំហានទី៥<br>បណ្តាំផ្ញើ<br>លំហាត់លេខ០១ទំព័រ១១០ | -កត់ចំណាំយកទៅអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

❖ ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល

❖ មេរៀនទី១ សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១(ត)

## ២.២.សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ដែលអាចញែកអថេរបាន

(រាង $g(y)\frac{dy}{dx}=f(x)$ )

## I. វត្ថុបំណង:

- ចំណេះដឹង:កំណត់និយមន័យសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ដែលអាចញែលអថេរបាន( រាង $g(y)\frac{dy}{dx}=f(x)$)តាមរយ:ខ្លឹមសារមេរៀនបានត្រឹមត្រូវ។
- ចំណេះធ្វើ:ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ដែលអាចញែលអថេរបាន(រាង $g(y)\frac{dy}{dx}=f(x)$)តាមរយ:ឧទាហរណ៍របស់គ្រូបានត្រឹមត្រូវ។
- ឥរិយាបថ:មានបំរុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់បានកម្រិតខ្ពស់។

## II. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ៩៥-៩៧បោះពុម្ពឆ្នាំ២០១១
- សៀវភៅគ្រូទំព័រ៩៥-៩៧បោះពុម្ពឆ្នាំ២០១១

## III. រយៈពេល ០១ម៉ោង

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមានអណាម័យ សណ្តាប់ធ្នាប់ វិន័យ | **ជំហានទី១**<br>រដ្ឋបាលថ្នាក់ | -ប្រធានថ្នាក់ឬតំណាងថ្នាក់ ឡើងរាយការណ៍ |
| -ដោះស្រាយសមីការ<br>ក. $y'=3x^2-2x+1$<br>ខ. $xy'=1$ កំណត់លើ $(0,+\infty)$ | **ជំហានទី២**<br>រំលឹកមេរៀនចាស់<br>ក. $y'=3x^2-2x+1$<br>$\Rightarrow y=x^3-x^2+x+c$<br>ខ. $xy'=1$ កំណត់លើ $(0,+\infty)$<br>$\Rightarrow y=\ln\|x\|+c$ | -ដោះស្រាយសមីការ<br>ក. $y'=3x^2-2x+1$<br>គេបាន $\frac{dy}{dx}=3x^2-2x+1$<br>$dy=(3x^2-2x+1)dx$<br>$\int dy=\int(3x^2-2x+1)dx$ |

| | | |
|---|---|---|
| | | $y = x^3 - x^2 + x + c$<br>ខ. $xy' = 1$<br>$\Rightarrow y' = \frac{1}{x}$ គេបាន<br>$\frac{dy}{dx} = \frac{1}{x} \Leftrightarrow dy = \frac{1}{x}dx$<br>$\int dy = \int \frac{1}{x}dx$<br>$y = \ln\|x\| + c$ |
| -ដាក់ឧទាហរណ៍ឲ្យសិស្សធ្វើ<br><br>-សរសេរជារាងសមីការឌីផេរ៉ង់ស្បែលលំដាប់ទី១ដែលអាចញែកអថេរបាន<br><br>-ឲ្យសិស្សកំណត់និយមន័យឌីផេរ៉ង់ស្បែលលំដាប់ទី១ដែលអាចញែកអថេរបាន | **ជំហានទី៣**<br>មេរៀនប្រចាំថ្ងៃ<br>**សមីការឌីផេរ៉ង់លំដាប់ទី១**(ត)<br>**២.២.សមីការឌីផេរ៉ង់ស្បែលលំដាប់ទី១ដែលអាចញែកអថេរបាន**<br>(**រាង** $g(y)\frac{dy}{dx} = f(x)$ )<br>**ក.និយមន័យ**<br>ឧទាហរណ៍:រកសមីការឌីផេរ៉ង់នៃគ្រួសាររង្វង់ផ្ចិត $O$ ដែល $O$ ជាគល់តម្រុយកូអរដោនេ។<br><br>**-និយមន័យ:**ឌីផេរ៉ង់ស្បែលលំដាប់ទី១ដែលអាចញែកអថេរបានជាសមីការដែលក្រោយពេលសម្រួលរួចមានទម្រង់ទូទៅ<br>$g(y)\frac{dy}{dx} = f(x)$ ។ | -រង្វង់ផ្ចិត $O$ មានសមីការទូទៅ $x^2 + y^2 = c$ ដែល $c$ ជាចំនួនថេរវិជ្ជមាន គេបាន $y^2 = c - x^2$ ធ្វើដេរីវេលើអង្គទាំងពីរ<br>$2yy' = -2x \Rightarrow y' = -\frac{x}{y}$ ជាសមីការឌីផេរ៉ង់ស្បែលនៃគ្រួសាររង្វង់ផ្ចិត $O$ ។<br>-សមីការនេះអាចសរសេរជា $\frac{dy}{dx} = -\frac{x}{y}$ ឬ $y\frac{dy}{dx} = -x$ ជាសមីការឌីផេរ៉ង់ស្បែលលំដាប់ទី១ដែលអាចញែកអថេរបាន<br>-កំណត់បានត្រឹមត្រូវ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍គំរូដោះស្រាយបង្ហាញសិស្ស<br>ឧទាហរណ៍:ដោះស្រាយសមីការ $y'=x^2y^3$<br>គេបាន $y'=x^2y^3$ អាចសរសេរជា $\frac{1}{y^3}\frac{dy}{dx}=x^2$ ជាសមីការដែលអាចញែកអថេរបាន $\frac{1}{y^3}\frac{dy}{dx}=x^2$<br>$\Rightarrow \frac{dy}{y^3}=x^2dx$ បំពាក់អាំងតេក្រាលលើអង្គទាំងពីរ គេបាន<br>$\int\frac{dy}{y^3}=\int x^2dx$<br>$-\frac{1}{2y^2}=\frac{1}{3}x^3+c$<br>$\frac{2}{3}x^3y^2+2cy^2+1=0$ ឬ<br>$2x^3y^2+6cy^2+3=0$ ជាចម្លើយទូទៅនៃសមីការ $y'=x^2y^3$<br>-ឲ្យសិស្សទាញទូទៅ | **ខ.របៀបដោះស្រាយសមីការ**<br>$g(y)\frac{dy}{dx}=f(x)$ | -យកចិត្តទុកដាក់ពិនិត្យការដោះស្រាយបង្ហាញរបស់គ្រូ |
| | **ជាទូទៅ**:ដើម្បីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ ដែលអាចញែកអថេរបាន គេត្រូវ:<br>• សរសេរសមីការឲ្យទៅជារាង $g(y)\frac{dy}{dx}=f(x)$<br>• ធ្វើអាំងតេក្រាលលើអង្គទាំងពីរធៀបនឹងអថេរ $x$<br>$\int g(y)dy=\int f(x)dx$<br>$G(y)=F(x)+c$<br>($c$ ជាចំនួនណាមួយក៏បាន)<br>ដែល $G(y)$ ជាព្រីមីទីវនៃអនុគមន៍ $g(y)$ និង $F(x)$ ជា | -ទាញទូទៅបានត្រឹមត្រូវ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍ឲ្យសិស្សធ្វើ | ព្រីមីទីវនៃអនុគមន៍ $f(x)$ ។<br><br>ឧទាហរណ៍:ដោះស្រាយសមីការ $\frac{dy}{dx}=e^{x+y}$ តាមលក្ខដើម $y(2)=0$ ។ | -គេបាន $e^{-y}dy=e^{x}dx$<br>$\int e^{-y}dy=\int e^{x}dx$<br>$-e^{-y}=e^{x}+c$ ឬ $e^{x}+e^{-y}=c$<br>ជាចម្លើយទូទៅនៃសមីការ។<br>តាមលក្ខខណ្ឌដើម $y(2)=0$ គេបាន $e^{2}+e^{0}=c\Rightarrow c=e^{2}+1$<br>ដូចនេះ $e^{x}+e^{-y}=e^{2}+1$ ជាចម្លើយពិសេសនៃសមីការ។ |
| -ដាក់លំហាត់ប្រតិបត្តិឲ្យសិស្សធ្វើ | **ជំហានទី៤**<br>ពង្រឹងពុទ្ធិ<br>ប្រតិបត្តិ:រកអនុគមន៍ចម្លើយមួយនៃសមីការឌីផេរ៉ង់ស្យែល $x\frac{dy}{dx}-y=2x^{2}y$ ដែលក្រាបនៃអនុគមន៍ចម្លើយនោះកាត់តាមចំណុច $(x=1,y=e)$ ។ | -ឡើងធ្វើលើក្តារខៀន<br>ដោះស្រាយសមីការ<br>$x\frac{dy}{dx}-y=2x^{2}y$ គេបាន<br>$\frac{1}{y}\frac{dy}{dx}=\frac{2x^{2}+1}{x}$<br>$\int\frac{dy}{y}=\int\left(2x+\frac{1}{x}\right)dx$<br>$\ln\lvert y\rvert=x^{2}+\ln\lvert x\rvert+c$<br>តាមលក្ខខណ្ឌ $(x=1,y=e)$<br>$\ln e=1+\ln 1+c\Rightarrow c=0$<br>ដូចនេះ $\ln\lvert y\rvert=x^{2}+\ln\lvert x\rvert$ ឬ $y=\pm e^{x^{2}+\ln\lvert x\rvert}$ ជាចម្លើយពិសេសនៃសមីការ។ |
| -ទៅផ្ទះវិញធ្វើលំហាត់លេខ២ទំព័រ១១០ | **ជំហានទី៥**<br>បណ្តាំផ្ញើ<br>លំហាត់លេខ២ទំព័រ១១០ | -កត់ចំណាំយកទៅអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

- ❖ ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល
- ❖ មេរៀនទី១ សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១

## I. វត្ថុបំណង

- ចំណេះដឹង:កំណត់និយមន័យសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី១មេគុណថេរអូម៉ូសែន(អង្គទី២ស្មើសូន្យ)តាមរយៈខ្លឹមសារមេរៀនបានត្រឹមត្រូវ។
- ចំណេះធ្វើ:ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី១មេគុណថេរអូម៉ូសែន(អង្គទី២ស្មើសូន្យ)តាមរយៈលំហាត់ប្រតិបត្តិបានត្រឹមត្រូវ។
- ឥរិយាបថ:មានស្មារតីចូលចិត្តដោះស្រាយលំហាត់បានកម្រិតខ្ពស់។

## II. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ៩៨-១០០បោះពុម្ព២០១១
- សៀវភៅគ្រូទំព័រ៩៨-១០០បោះពុម្ព២០១១

## III. រយៈពេល ០១ម៉ោង

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមាន វិន័យ អនាម័យ | ជំហានទី១<br>រដ្ឋបាលថ្នាក់ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ដោះស្រាយសមីការ<br>$y'=e^{2x}, y(0)=5$ | ជំហានទី២<br>រំលឹកមេរៀនចាស់ | -ដោះស្រាយសមីការ<br>$y'=e^{2x}, y(0)=5$<br>$\frac{dy}{dx}=e^{2x} \Leftrightarrow dy=e^{2x}dx$<br>$\int dy=\int e^{2x}dx$<br>$\Rightarrow y=\frac{1}{2}e^{2x}+c$<br>ដោយ $y(0)=5$ |

| | | |
|---|---|---|
| | | $\Leftrightarrow 5=\frac{1}{2}e^{2\cdot5}+c \Rightarrow c=5-\frac{1}{2}e^{10}$<br>ដូចនេះ $y=\frac{1}{2}e^{2x}+5-\frac{1}{2}e^{10}$ |
| -ចូរឲ្យនិយមន័យសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី១មេគុណថេរអូម៉ូសែន<br><br>-ប្រាប់ពីរបៀបដោះស្រាយសមីការ $y'+ay=0$ | ជំហានទី៣<br>មេរៀនប្រចាំថ្ងៃ<br>**សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១**<br>**២.៣សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី១មេគុណថេរអូម៉ូសែន(** **អង្គទី២ស្មើសូន្យ)**<br>**ក.និយមន័យ**<br>និយមន័យ:សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី១មេគុណថេរអូម៉ូសែន(អង្គទី២ស្មើសូន្យ)ជាសមីការដែលមានរាងទូទៅ $y'+ay=0$ ($a$ ជាចំនួនថេរ)។ចម្លើយទូទៅនៃសមីការគឺ $y=Ae^{-ax}$ ដែល $A$ ជាចំនួនថេរណាមួយក៏បាន។<br>**ខ.របៀបដោះស្រាយសមីការ**<br>$y'+ay=0$<br>គេសរសេរ $\frac{dy}{dx}=-ay$ តាមវិធីញែកអថេរគេបាន $\frac{dy}{y}=-adx$<br>$\int\frac{dy}{y}=\int -adx$<br>$\ln\|y\|=-ax+c \Rightarrow y=\pm e^{c}e^{-ax}$<br>យក $A=\pm e^{c}$ : $y=Ae^{-ax}$ ជាចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី១មេគុណថេរអូម៉ូសែន។<br>ឧទាហរណ៍:រកចម្លើយទូទៅនៃសមីការ $y'+y=0$ ដែល $y(0)=1$ | -សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី១មេគុណថេរអូម៉ូសែន(អង្គទី២ស្មើសូន្យ)ជាសមីការដែលមានរាងទូទៅ $y'+ay=0$ ($a$ ជាចំនួនថេរ)។ចម្លើយទូទៅនៃសមីការគឺ $y=Ae^{-ax}$ ដែល $A$ ជាចំនួនថេរណាមួយក៏បាន។<br>-យកចិត្តទុកដាក់ស្តាប់ការពន្យល់របស់គ្រូ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍អោយសិស្សធ្វើ | | -រកចម្លើយទូទៅ<br>$y'+y=0 \Leftrightarrow \frac{dy}{dx}=-y$ ឬ<br>$\frac{dy}{y}=-dx \Rightarrow \ln\|y\|=-x+c$<br>ដូចនេះ $y=Ae^{-x}$ ( $A$ ជាចំនួនថេរណាមួយក៏បាន)ជាចម្លើយទូទៅនៃ $y'+y=0$ ។<br>រកចម្លើយពិសេស<br>$y(0)=1 \Leftrightarrow 1=Ae^{0} \Rightarrow A=1$<br>ដូចនេះ $y=e^{-x}$ ជាចម្លើយពិសេស |
| -ដាក់លំហាត់ប្រតិបត្តិឲ្យសិស្សធ្វើ | ជំហានទី៤<br>ពង្រឹងពុទ្ធិ<br>ប្រតិបត្តិ:ដោះស្រាយសមីការ $-y'+2y=0$ តាមលក្ខខណ្ឌ $y(3)=-2$ | -ដោះស្រាយសមីការ $-y'+2y=0$<br>$y'-2y=0 \Rightarrow y=Ae^{2x}$ ជាចម្លើយទូទៅនៃសមីការ<br>ដោយ $y(3)=-2 \Leftrightarrow -2=Ae^{2\times 3}$<br>$\Rightarrow A=-2e^{-6}$<br>ដូចនេះ $y=-2e^{2x-6}$ |
| -ទៅផ្ទះវិញធ្វើលំហាត់លេខ ៣-៤ទំព័រ១១០ | ជំហានទី៥<br>បណ្តាំផ្ញើ<br>លំហាត់លេខ៣-៤ទំព័រ១១០ | -កត់ចំណាំយកទៅអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

- ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល
- មេរៀនទី១ សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១

## ២.៤.សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១មេគុណថេរមិនអូម៉ូសែន( អង្គទី២ខុសពីសូន្យ )

I. **វត្ថុបំណង**

- ចំណេះដឹង:បកស្រាយពីវិធីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១មេគុណថេរមិនអូម៉ូសែនតាមរយ:ខ្លឹមសារមេរៀនបានត្រឹមត្រូវ។
- ចំណេះធ្វើ:ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១មេគុណថេរមិនអូម៉ូសែនតាមរយ:លំហាត់ប្រតិបត្តិបានត្រឹមត្រូវ។
- ឥរិយាបថ:មានបំរុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១ មេគុណមិនអូម៉ូសែនបានកម្រិតខ្ពស់។

II. **រយៈពេល** ០១ម៉ោង

III. **សម្ភារឧបទេស**

- សៀវភៅសិស្ស ទំព័រទី១០០-១០៤ បោះពុម្ភឆ្នាំ២០១១
- សៀវភៅគ្រូ ទំព័រទី១០០-១០៤ បោះពុម្ភឆ្នាំ២០១១

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមានវិន័យ អណាម័យ | ជំហានទី១<br>រដ្ឋបាលថ្នាក់ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ដោះស្រាយសមីការ<br>$2y'-5y=0, y(1)=-3$ | ជំហានទី២<br>រំលឹកមេរៀនចាស់ | -$2y'-5y=0$ គេបាន<br>$\frac{dy}{dx}=\frac{5}{2}y$ ឬ $\frac{dy}{y}=\frac{5dx}{2}$<br>$\ln\lvert y\rvert=\frac{5}{2}x+c \Rightarrow y=Ae^{\frac{5}{2}x}$<br>តាមលក្ខខណ្ឌ $y(1)=-3$<br>$-3=Ae^{\frac{5}{2}\cdot 1} \Rightarrow A=-3e^{-\frac{5}{2}}$<br>ដូចនេះ $y=-3e^{\frac{5x-5}{2}}$ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍បង្ហាញសិស្ស<br>ក.កំណត់រក $a$ និង $b$<br>បើ $g$ ជាចម្លើយនៃ $(E)$ នោះ $g$ និង $g'$ ផ្ទៀងផ្ទាត់សមីការ $(E)$<br>$g(x)=ax+b$ នាំឲ្យ $g'(x)=a$<br>$g'(x)-3g(x)=3x+2$<br>$a-3(ax+b)=3x+2$<br>$-3ax+a-3b=3x+2$<br>ទាញបាន $\begin{cases}-3a=3\\a-3b=2\end{cases}$<br>$\Rightarrow\begin{cases}a=-1\\b=-1\end{cases}$<br>ដូចនេះ $g(x)=-x-1$ ជាចម្លើយពិសេសនៃសមីការ $(E)$ ។<br>ខ.បង្ហាញថា $f=h+g$ ជាចម្លើយទូទៅនៃ $(E)$<br>បើ $h$ ជាចម្លើយនៃសមីការ<br>$y'-3y=0\Rightarrow h'-3h=0$<br>ម្យ៉ាងទៀត $g$ ជាចម្លើយនៃ $(E)$<br>គេបាន $g'-3g=3x+2$<br>បូកសមភាពអង្គនិងអង្គ<br>$h'+g'-3(h+g)=3x+2$ | ជំហានទី៣<br>មេរៀនប្រចាំថ្ងៃ<br>**សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១(ត)**<br>**២.៤.សមីការឌីផេរ៉ង់ស្យែលនៃអ៊ែលំដាប់ទី១មេគុណថេរមិនអូម៉ូសែន(អង្គទី២ខុសពីសូន្យ)**<br>ក.របៀបដោះស្រាយសមីការ<br>$y'+ay=p(x)$<br>ឧទាហរណ៍:គេមានសមីការ<br>$y'-3y=3x+2\,(E)$ ។<br>ក.កំណត់ចំនួនពិត $a$ និង $b$ ដើម្បីឲ្យអនុគមន៍ $g$ កំណត់លើ $\mathbb{R}$ ដោយ $g(x)=ax+b$ ជាចម្លើយពិសេសនៃ $(E)$ ។<br>ខ.បើ $h$ ជាចម្លើយទូទៅនៃសមីការ $y'-3y=0$ បង្ហាញថា $f=h+g$ ជាចម្លើយទូទៅនៃ $(E)$ ។<br>គ.រកចម្លើយ $h$ នៃសមីការ $y'-3y=0$ រួចទាញរកចម្លើយទូទៅ $f$ នៃសមីការ $(E)$ ។ | -ស្តាប់ការបង្ហាញរបស់គ្រូ |

| | | |
|---|---|---|
| $(h+g)'-3(h+g)=3x+2$<br>ដោយ $f=h+g$ នោះ<br>$f'-3f=3x+2$<br>ដូចនេះ $f=h+g$ ជាចម្លើយទូទៅនៃសមីការ $(E)$ ។<br>គ.ដោះស្រាយសមីការ<br>$y'-3y=0$ ឬ $\frac{dy}{dx}=3y$<br>$\frac{dy}{y}=3dx$ ឬ $\ln\|y\|=3x+c$<br>$y=\pm e^{3x+c}=\pm e^{c}\cdot e^{3x}$<br>ដូចនេះ $h(x)=Ae^{3x}$ ដោយ<br>$f=h+g$ នោះ<br>$f(x)=Ae^{3x}-x-1$ ជាចម្លើយទូទៅនៃសមីការ $(E)$ ។<br>-ដើម្បីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១មេគុណថេរមិនអូម៉ូសែន<br>$y'+ax=p(x),p(x)\neq 0$ គេត្រូវធ្វើដូចម្តេច? | -ដើម្បីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១មេគុណថេរមិនអូម៉ូសែន<br>$y'+ax=p(x),p(x)\neq 0$<br>គេត្រូវ:<br>• រកអនុគមន៍ចម្លើយទូទៅនៃសមីការ $y'+ay=0$ តាងដោយ $y_c$<br>• រកអនុគមន៍ចម្លើយពិសេសនៃសមីការ $y'+ay=p(x)$ តាងដោយ $y_p$<br>• ចម្លើយទូទៅនៃសមីការ $y'+ay=p(x)$ គឺអនុគមន៍ $y$ ដែល<br>$y=y_c+y_p$<br>ឧទាហរណ៍:ដោះស្រាយសមី | -ដើម្បីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី១មេគុណថេរមិនអូម៉ូសែន<br>$y'+ax=p(x),p(x)\neq 0$<br>គេត្រូវ:<br>• រកអនុគមន៍ចម្លើយទូទៅនៃសមីការ $y'+ay=0$ តាងដោយ $y_c$<br>• រកអនុគមន៍ចម្លើយពិសេសនៃសមីការ $y'+ay=p(x)$ តាងដោយ $y_p$<br>• ចម្លើយទូទៅនៃសមីការ $y'+ay=p(x)$ គឺអនុគមន៍ $y$ ដែល $y=y_c+y_p$<br><br>-ដោះស្រាយសមីការ |

| | | |
|---|---|---|
| -ដាក់ឧទាហរណ៍ឲ្យសិស្សធ្វើ | ការ $y'-2y=8x^2-8x\ (E)$ | $y'-2y=0$ ឬ $\frac{dy}{dx}=2y$<br>$\frac{dy}{y}=2dx\Rightarrow\ln\lvert y\rvert=2x+c$<br>$y_c=Ae^{2x}\ \ (A=\pm e^c)$<br>-រកចម្លើយពិសេសនៃ $(E)$<br>$y_p=ax^2+bx+c$<br>$y'_p=2ax+b$<br>$(E): 2ax+b-2ax^2-2bx-2c$<br>$=8x^2-8x$<br>$-2ax^2+(2a-2b)x+b-2c$<br>$=8x^2-8x$<br>$\begin{cases}-2a=8\\2a-2b=-8\\b-2c=0\end{cases}$ ឬ $\begin{cases}a=-4\\b=0\\c=0\end{cases}$<br>$y_p=-4x^2$<br>ដូចនេះចម្លើយទូទៅនៃសមីការ $(E)$ គឺ $y=y_c+y_p$<br>$y=Ae^{2x}-4x^2$<br>-ស្តាប់ការបង្ហាញរបស់គ្រូ |
| -ដាក់ឧទាហរណ៍បង្ហាញសិស្ស<br>ក.រកចម្លើយនៃសមីការ<br>$y'+2y=0(E)$ គេបាន<br>$\frac{dy}{dx}=-2y\Rightarrow\frac{dy}{y}=-2dx$<br>$\ln\lvert y\rvert=-2x+c\Rightarrow y=\pm e^{-2x+c}$<br>$y=Ae^{-2x}$ ជាចម្លើយទូទៅនៃសមីការ $(E)$ ។<br>ខ.គណនា $f'(x)$ និង $g'(x)$<br>$f(x)=e^{-2x}g(x)$ | ខ.ដំណោះស្រាយសមីការ<br>$y'+ay=p(x)$ តាមវិធីបម្រែបម្រួលចំនួនថេរ<br>ឧទាហរណ៍:គេមានសមីការឌីផេរ៉ង់ស្យែល<br>$y'+2y=3e^{-3x}\ (E)$<br>ក.រកចម្លើយទូទៅនៃសមីការ<br>$y'+2y=0(E)$<br>ខ.តាងអនុគមន៍ $f$ កំណត់ដោយ $f(x)=e^{-2x}g(x)$ ។<br>គណនា $f'(x)$ ជាអនុគមន៍នៃ | |

| | | |
|---|---|---|
| $f'(x)=-2e^{-2x}g(x)+e^{-2x}g'(x)$<br>បើ $f(x)$ ជាចម្លើយនៃ $(E)$ នោះគេបាន $f'(x)+2f(x)=3e^{-3x}$<br>$-2e^{-2x}g(x)+e^{-2x}g'(x)+2e^{-2x}g(x)$<br>$=3e^{-3x}$<br>$e^{-2x}g'(x)=3e^{-3x}$<br>$g'(x)=\frac{3e^{-3x}}{e^{-2x}}=3e^{-x}$<br>គ.ដោយ $g'(x)=3e^{-x}$ នោះ<br>$g(x)=\int 3e^{-x}dx=-3e^{-x}+c$<br>ដោយ $f(x)$ ជាចម្លើយនៃ $(E)$ កាលណា $g'(x)=3e^{-x}$ នោះ<br>$f(x)=e^{-2x}g(x)$<br>$=e^{-2x}(-3e^{-x}+c)$<br>ដូចនេះ $f(x)=ce^{-2x}-3e^{-3x}$ ជាចម្លើយទូទៅនៃ $(E)$ ។ | $g(x)$ និង $g'(x)$ ។គណនា $g'(x)$ បើ $f(x)$ ជាចម្លើយនៃ $(E)$ ។<br>គ.ទាញរក $g(x)$ រួច $f(x)$ ដើម្បីឲ្យ $f(x)$ ជាចម្លើយនៃ $(E)$ ។ | |
| -ដាក់ប្រតិបត្តិឲ្យសិស្សធ្វើ | ជំហានទី៤<br>ពង្រឹងពុទ្ធិ<br>ប្រតិបត្តិ:ដោះស្រាយសមីការ $y'+2y=x^2$ តាមលក្ខខណ្ឌដើម $y(0)=2$ | -ដោះស្រាយសមីការ $y'+2y=x^2\ (E)$<br>• រកចម្លើយទូទៅនៃសមីការ $y'+2y=0$ គេបាន $y=Ae^{-2x}$ ជាចម្លើយទូទៅនៃ $y'+2y=0$<br>• $y=A(x)e^{-2x}$<br>$\Rightarrow y'=-2e^{-2x}A(x)+e^{-2x}A'(x)$<br>គេបាន<br>$\Rightarrow -2e^{-2x}A(x)+e^{-2x}A'(x)$<br>$+2A(x)e^{-2x}=x^2$<br>$A'(x)=x^2e^{2x}$<br>$A(x)=\int x^2e^{2x}dx$ |

| | | |
|---|---|---|
| | | $\Rightarrow A(x)=\frac{1}{2}e^{2x}\left(x^2-x+\frac{1}{4}\right)$<br>$+c$<br>(ដែល $c$ ជាចំនួនថេរណាក៏បាន)<br>ដូចនេះ $y=\frac{x^2}{2}-\frac{x}{2}+\frac{1}{8}+c$ |
| -ទៅផ្ទះវិញធ្វើលំហាត់លេខ១០ទំព័រទី១១១ | ជំហានទី៥<br>បណ្តាំផ្ញើ<br>លំហាត់លេខ១០ទំព័រទី១១១ | -កត់ចំណាំយកទៅអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

- **ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល**
- **មេរៀនទី១ សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១**

## I. វត្ថុបំណង

- ចំណេះដឹង:បកស្រាយបាតុភូតធម្មជាតិជាសមីការឌីផេរ៉ង់ស្យែលតាមរយៈខ្លឹមសារមេរៀនបានត្រឹមត្រូវ។
- បំណិន:អនុវត្តន៍សមីការឌីផេរ៉ង់ស្យែលក្នុងវិទ្យាសាស្ត្រតាមរយៈខ្លឹមសារមេរៀនបានត្រឹមត្រូវ។
- ឥរិយាបថ:មានស្មារតីចូលចិត្តដោះស្រាយលំហាត់បានកម្រិតខ្ពស់។

## II. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ១០៥-១០៩បោះពុម្ពឆ្នាំ២០១១
- សៀវភៅគ្រូទំព័រ១០៥-១០៩បោះពុម្ពឆ្នាំ២០១១

## III. រយៈពេល ០២ម៉ោង

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអវត្តមានវិន័យអណាម័យ | ជំហានទី១<br>រដ្ឋបាលថ្នាក់ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ដោះស្រាយសមីការ<br>$y'+y=\cos x+\sin x$ | ជំហានទី២<br>រំលឹកមេរៀនចាស់ | -ដោះស្រាយសមីការ<br>$y'+y=\cos x+\sin x$<br>$y'+y=0\Rightarrow y_c=Ae^{-x}$<br>តាង $y_p=a\cos x+b\sin x$<br>$\Rightarrow y'_p=-a\sin x+b\cos x$<br>$-a\sin x+b\cos x+a\cos x$<br>$+b\sin x=\cos x+\sin x$<br>$\begin{cases}-a+b=1\\a+b=1\end{cases}\Rightarrow\begin{cases}a=0\\b=1\end{cases}$<br>គេបាន $y_p=b\cos x$<br>ដូចនេះ $y=y_c+y_p$ |

| | | |
|---|---|---|
| | | $y = Ae^{-x} + b\cos x$ |
| -ដាក់លំហាត់ឲ្យសិស្សធ្វើ | ជំហានទី៣<br>មេរៀនប្រចាំថ្ងៃ<br>**សមីការឌីផេរ៉ង់ស្យែលលំដាប់ទី១**<br>**៣.អនុវត្តន៍សមីការឌីផេរ៉ង់ស្យែលក្នុងវិទ្យាសាស្ត្រ**<br>**៣.១.អនុវត្តន៍ក្នុងគីមីវិទ្យា**<br>ឧទាហរណ៍:អ្នកវិទ្យាសាស្ត្របានសង្កេតឃើញថាចំនួនណ្វៃយ៉ូនៃសារធាតុវិទ្យុសកម្មត្រូវថយចុះទៅតាមរយ:ពេលដែលប្រើប្រាស់។គេដឹងថាល្បឿននៃការបំបែកណ្វៃយ៉ូនេះសមាមាត្រនឹងចំនួនណ្វៃយ៉ូដែលនៅសល់។តាង $N_0$ ជាចំនួនណ្វៃយ៉ូនៃធាតុវិទ្យុសកម្មដែលមាននៅខណ:ពេល $t = 0$ ។រកចំនួនណ្វៃយ៉ូដែលសល់ក្នុងរយ:ពេល $t$ ជាអនុគមន៍នៃ $t$ ។ | -សិស្សឡើងធ្វើ<br>-តាង $k$ ជាមេគុណសមាមាត្រ<br>$N$ ជាចំនួនណ្វៃយ៉ូនៃសារធាតុវិទ្យុសកម្មដែលនៅសល់ក្នុងខណ:ពេល $t$<br>ដោយល្បឿននៃការបំបែកណ្វៃយ៉ូសមាមាត្រនឹងចំនួនណ្វៃយ៉ូដែលនៅសល់នោះគេអាចសរសេរ:<br>$\frac{dN}{dt} = -kN$ ដែលជាសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១<br>$\frac{dN}{dt} = -kN \Rightarrow \frac{dN}{N} = -kdt$<br>$\int \frac{dN}{N} = -k\int dt$<br>$\ln\lvert N\rvert = -kt + c$<br>$\Rightarrow N = Ae^{-kt+c}$ (យក $A = \pm e^c$ )<br>$N(t) = Ae^{-kt}$ តាមលក្ខខណ្ឌដើម $N(0) = N_0$ គេបាន<br>$N_0 = Ae^{-k(0)} \Rightarrow A = N_0$<br>$N(t) = N_0e^{-kt}$ ដូចនេះនៅខណ:ពេល $t$ សារធាតុនៃវិទ្យុសកម្មនៅសល់ណ្វៃយ៉ូចំនួន $N_0e^{-kt}$ ។ |

| | | |
|---|---|---|
| -លោកញ៉ូតុនបានរកឃើញថា<br>អត្រាថយចុះនៃសីតុណ្ហភាព<br>របស់វត្ថុមួយសមាមាត្រទៅនឹង<br>ផលដករវាងសីតុណ្ហភាពវត្ថុនិង<br>សីតុណ្ហភាពមជ្ឈដ្ឋានជុំវិញនោះ<br>ច្បាប់នេះហៅថាច្បាប់ត្រជាក់<br>របស់ញូតុនដែលបកស្រាយ:<br>$\frac{dT}{dt}=-k(T-M)$<br>-ដាក់ឧទាហរណ៍ឲ្យសិស្សធ្វើ | **៣.២.អនុវត្តន៍ក្នុងរូបវិទ្យា**<br>ច្បាប់ត្រជាក់របស់ញ៉ូតុន<br>$\frac{dT}{dt}=-k(T-M)$ ដែល $T$ ជាសី<br>តុណ្ហភាពវត្ថុ, $M$ ជាសីតុណ្ហភាព<br>មជ្ឈដ្ឋានជុំវិញ, $k$ ជាមេគុណសមា<br>មាត្រនិង $t$ ជារយៈពេល។<br><br>ឧទាហរណ៍:នំដុតដែលគេទើប<br>លើកចេញពីចង្រ្កានមានសីតុណ្ហ<br>ភាព $120°C$ ។គេយកនំដុតនេះមក<br>ដាក់ក្នុងបន្ទប់មួយមានសីតុណ្ហ<br>ភាព $28°C$ ។គេឃើញថា៣នាទី<br>ក្រោយមកសីតុណ្ហភាពនំធ្លាក់<br>នៅ $80°C$ ។<br>ក.សរសេរសមីការឌីផេរ៉ង់ស្យែល<br>ដែលទាក់ទងទៅនឹងសីតុណ្ហភាព<br>$T$ របស់នំនៅខណៈពេល $t$ និង<br>លក្ខខណ្ឌដើមនៃចំណោទ។<br>ខ.គណនាសីតុណ្ហភាពនំនៅ<br>ខណៈពេល $t$ ។<br>គ.គណនារយៈពេលដែល<br>សីតុណ្ហភាពនំថយចុះដល់ $30°C$ | <br><br><br><br><br><br><br><br><br>-ក.អត្រាថយចុះនៃសីតុណ្ហ<br>ភាពគឺ $-\frac{dT}{dt}$<br>ដោយអត្រាថយចុះនេះសមា<br>មាត្រនឹងផលដករវាងសីតុណ្ហ<br>ភាពនំនិងសីតុណ្ហភាពបរិយា<br>កាសជុំវិញ<br>នោះគេបានសមីការឌីផេរ៉ង់<br>ស្យែល: $-\frac{dT}{dt}=k(T-M)$<br>តាមលក្ខខណ្ឌដើម<br>$T(0)=T_0=120°C$ ដោយ<br>សីតុណ្ហភាព $M=28°C$ នោះ<br>$\frac{dT}{dt}=-k(T-28), T(0)=120$<br>ខ.សីតុណ្ហភាពនំនៅខណៈ<br>ពេល $t$<br>$\frac{dT}{dt}=-k(T-28)$ ឬ<br>$\frac{dT}{T-28}=-kdt$<br>$\ln\|T-28\|=-kt+c$<br>$T-28=\pm e^{-kt+c}=Ae^{-kt}$ |

| | | |
|---|---|---|
| ឧទាហរណ៍:គេសិក្សាពីកំនើននៃការបណ្តុះបាក់តេរីក្នុងមជ្ឈដ្ឋានមួយ។តាង $N(t)$ ជាអនុគមន៍នៃ $t$ ជាចំនួនបាក់តេរីដែលមាននៅខណៈពេល $t$ ($t$ គិតជាម៉ោង)។គេដឹងថាចំនួនបាក់តេរីកើនឡើង $10\%$ ក្នុងមួយម៉ោង។<br>ក.បង្ហាញថាចំពោះគ្រប់ $t$ ជាចំនួនពិតវិជ្ជមាន $N(t)$ ផ្ទៀងផ្ទាត់ $N(t+1)-N(t)=0.1N(t)$ | **៣.៣.អនុវត្តន៍ក្នុងជីវវិទ្យា**<br>-ក.ដោយចំនួនបាក់តេរីមាន $N(t)$ នៅម៉ោង $t$ ហើយកើនបាន $10\%$ ក្នុងមួយម៉ោងនោះក្រោយមកចំនួនបាក់តេរីមាន<br>$N(t+1)=N(t)+\frac{10}{100}N(t)$<br>$N(t+1)-N(t)=0.1N(t)$<br>ខ. $N'(t)=\lim\limits_{t\to 0}\frac{N(t+1)-N(t)}{t+1-t}$<br>$N'(t)=0.1N(t)$ ជាសមីការឌីផេរ៉ង់ស្យែល | $T(t)=Ae^{-kt}+28$<br>ដោយ $T(0)=120$<br>$\Rightarrow 120=Ae^{-k(0)}+28$<br>$A=92$<br>$T(t)=92e^{-kt}+28$<br>ដោយ៣នាទីក្រោយសីតុណ្ហភាពនំថយចុះពី $120°C$ មក $80°C$ នោះគេបាន:<br>$80=92e^{-k(3)}+28$<br>$e^{-3k}=\frac{52}{92}=\frac{13}{23}$<br>$-3k=\ln\frac{13}{23}$<br>$k=-\frac{1}{3}\ln\frac{13}{23}=0.19$<br>ដូចនេះ $T(t)=92e^{-0.19t}+28$<br>គ.រយៈពេលដែលសីតុណ្ហភាពថយចុះដល់ $30°C$<br>$30=92e^{-0.19t}+28$<br>$-0.19t=\ln(0.02173)$<br>$t=20$ នាទី $9$ វិនាទី។<br>-ក.ដោយចំនួនបាក់តេរីមាន $N(t)$ នៅម៉ោង $t$ ហើយកើនបាន $10\%$ ក្នុងមួយម៉ោងនោះក្រោយមកចំនួនបាក់តេរីមាន<br>$N(t+1)=N(t)+\frac{10}{100}N(t)$<br>$N(t+1)-N(t)=0.1N(t)$<br>ខ. $N'(t)=\lim\limits_{t\to 0}\frac{N(t+1)-N(t)}{t+1-t}$<br>$N'(t)=0.1N(t)$ ជាសមីការឌីផេរ៉ង់ស្យែល |

| | | |
|---|---|---|
| ខ.គេចាត់ទុកថា<br>$N(t+1)-N(t)$<br>ខិតទៅរក $N'(t)$ ដែលជាដេរីវេនៃ $N$ ។គណនាចំនួនបាក់តេរីនៅខណៈពេល $t=3h$ បើគេដឹងថាចំនួនបាក់តេរីនៅពេលចាប់ផ្តើមបណ្តុះមាន $N_0=10^4$ ។<br>-ដាក់ឧទាហរណ៍ឲ្យសិស្សធ្វើ<br>ឧទាហរណ៍:លោកសារីបានសម្រេចចិត្តថានឹងឈប់ជក់បារីដើម្បីថែរក្សាសុខភាព និងធ្វើការសន្សំប្រាក់ឡើងវិញ។គាត់ជក់ក្នុងមួយថ្ងៃ២កញ្ចប់បើគិតជាប្រាក់គាត់ត្រូវចំណាយអស់៣ម៉ឺនរៀលក្នុងមួយសប្តាហ៍។ឧបមាគាត់បញ្ចូលប្រាក់នេះជារៀងរាល់សប្តាហ៍ក្នុងគណនីសន្សំនៃធនាគារនោះគាត់នឹងទទួលបានអត្រាការប្រាក់សមាស10% ក្នុងមួយឆ្នាំ។តើគាត់ទទួលបានប្រាក់ទាំងការទាំងដើមប៉ុន្មាន បើគាត់ព្យាយាមផ្ញើរប្រាក់នេះចូលធានាគារក្នុងរយៈពេល៣០ឆ្នាំ។ | $\frac{dN}{dt}=0.1N$ នាំឲ្យ $\frac{dN}{N}=0.1dt$<br>$\ln\|N\|=0.1t+c$<br>$N(t)=Ae^{0.1t}$ ដោយ<br>$N(0)=N_0=10^4$ នោះ<br>$10^4=Ae^{0.1(0)}\Rightarrow A=10^4$<br>$N(t)=10^4e^{0.1t}$<br>$t=3:N(3)=10^4e^{0.3}=13498$<br>បាក់តេរី។<br>**៣.៤.អនុវត្តន៍ក្នុងសេដ្ឋកិច្ច**<br>-បើ $S$ ជាទឹកប្រាក់ដែលមានក្នុងឆ្នាំ $t$ ហើយអត្រាការប្រាក់ 10% ក្នុង១ឆ្នាំនោះកំណើនទឹកប្រាក់ក្នុងឆ្នាំនោះគឺ<br>$\frac{dS}{dt}=\frac{10}{100}S$ បើនៅពេលនោះគេបន្ថែមទឹកប្រាក់ $d$ ទៀតនោះកំណើនទឹកប្រាក់គឺ<br>$\frac{dS}{dt}=0.1S+d$ ឬ<br>$\frac{dS}{dt}-0.1S=d$ ដោយក្នុង១សប្តាហ៍លោកសារីសន្សំបាន៣ម៉ឺនរៀលនោះក្នុង១ឆ្នាំគាត់សន្សំបាន: $3\times52=156$ ម៉ឺនរៀល គេបាន $\frac{dS}{dt}-0.1S=156$ ម៉ឺនរៀលជាសមីការឌីផេរ៉ង់ស្យែលដែលមានចម្លើយជាអនុគមន៍ $S(t)$ ជាចំនួនទឹកប្រាក់ដែលមានក្នុងធានាគារនៅខណៈពេល $t$ | $\frac{dN}{dt}=0.1N$ នាំឲ្យ $\frac{dN}{N}=0.1dt$<br>$\ln\|N\|=0.1t+c$<br>$N(t)=Ae^{0.1t}$ ដោយ<br>$N(0)=N_0=10^4$ នោះ<br>$10^4=Ae^{0.1(0)}\Rightarrow A=10^4$<br>$N(t)=10^4e^{0.1t}$<br>$t=3:N(3)=10^4e^{0.3}=13498$<br>បាក់តេរី។<br>-បើ $S$ ជាទឹកប្រាក់ដែលមានក្នុងឆ្នាំ $t$ ហើយអត្រាការប្រាក់ 10% ក្នុង១ឆ្នាំនោះកំណើនទឹកប្រាក់ក្នុងឆ្នាំនោះគឺ<br>$\frac{dS}{dt}=\frac{10}{100}S$ បើនៅពេលនោះគេបន្ថែមទឹកប្រាក់ $d$ ទៀតនោះកំណើនទឹកប្រាក់គឺ<br>$\frac{dS}{dt}=0.1S+d$ ឬ<br>$\frac{dS}{dt}-0.1S=d$ ដោយក្នុង១សប្តាហ៍លោកសារីសន្សំបាន៣ម៉ឺនរៀលនោះក្នុង១ឆ្នាំគាត់សន្សំបាន: $3\times52=156$ ម៉ឺនរៀល គេបាន $\frac{dS}{dt}-0.1S=156$ ម៉ឺនរៀលជាសមីការឌីផេរ៉ង់ស្យែលដែលមានចម្លើយជាអនុគមន៍ $S(t)$ ជាចំនួនទឹកប្រាក់ដែលមានក្នុងធានាគារនៅខណៈពេល $t$ |

| | | |
|---|---|---|
| | $\frac{dS}{dt}-0.1S=156(1)$ សមីការ<br>$\frac{dS}{dt}-0.1S=0$ មានចម្លើយ<br>$S'(t)=Ae^{0.1t}$ ធ្វើបម្រែបម្រួលចំនួនថេរ $A$ គេបាន<br>$S'(t)=A'(x)e^{0.1t}+0.1A(x)e^{0.1t}$<br>$(1): A'(x)e^{0.1t}+0.1A(x)$<br>$-0.1A(x)e^{0.1t}=156$<br>$A'(x)=e^{0.1t}\cdot 156$<br>$A(x)=156\int e^{-0.1t}dt$<br>$=-1560e^{-0.1t}+c$<br>ចម្លើយទូទៅនៃសមីការ $(i)$ គឺ<br>$S(t)=-1560+ce^{0.1t}$<br>ដោយនៅឆ្នាំដំបូងប្រាក់ដើមរបស់លោកសារីគ្មាននោះ<br>$S(O)=0$<br>$S(O)=-1560+ce^{0.1(0)}$<br>$0=-1560+c$ នាំឲ្យ $c=1560$<br>ដូចនេះ $S(t)=1560e^{0.1t}-1560$<br>$30$ ឆ្នាំក្រោយមកលោកសារីមានប្រាក់ចំនួន<br>$S(30)=1560e^{0.1(30)}-1560$<br>$=29773.4376$ ម៉ឺនរៀល | $\frac{dS}{dt}-0.1S=156(1)$ សមីការ<br>$\frac{dS}{dt}-0.1S=0$ មានចម្លើយ<br>$S'(t)=Ae^{0.1t}$ ធ្វើបម្រែបម្រួលចំនួនថេរ $A$ គេបាន<br>$S'(t)=A'(x)e^{0.1t}+0.1A(x)e^{0.1t}$<br>$(1): A'(x)e^{0.1t}+0.1A(x)$<br>$-0.1A(x)e^{0.1t}=156$<br>$A'(x)=e^{0.1t}\cdot 156$<br>$A(x)=156\int e^{-0.1t}dt$<br>$=-1560e^{-0.1t}+c$<br>ចម្លើយទូទៅនៃសមីការ $(i)$ គឺ<br>$S(t)=-1560+ce^{0.1t}$<br>ដោយនៅឆ្នាំដំបូងប្រាក់ដើមរបស់លោកសារីគ្មាននោះ<br>$S(O)=0$<br>$S(O)=-1560+ce^{0.1(0)}$<br>$0=-1560+c$ នាំឲ្យ $c=1560$<br>ដូចនេះ $S(t)=1560e^{0.1t}-1560$<br>$30$ ឆ្នាំក្រោយមកលោកសារីមានប្រាក់ចំនួន<br>$S(30)=1560e^{0.1(30)}-1560$<br>$=29773.4376$ ម៉ឺនរៀល |
| -តើសមីការឌីផេរ៉ង់ស្យែលបានអនុវត្តន៍ក្នុងអ្វីខ្លះ? | ជំហានទី៤<br>ពង្រឹងពុទ្ធិ | -សមីការឌីផេរ៉ង់ស្យែលបានអនុវត្តន៍ក្នុងគីមីវិទ្យា រូបវិទ្យា ជីវវិទ្យា សេដ្ឋកិច្ច...។ |

| | | |
|---|---|---|
| -ទៅផ្ទះវិញធ្វើលំហាត់លេខ១១ ទំព័រ១១១ | ជំហានទី៥<br>បណ្តាំផ្ញើ<br>លំហាត់លេខ១១ទំព័រ១១១ | -កត់ចំណាំយកទៅអនុវត្តន៍ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)
## ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល
## មេរៀនទី២ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី២

## I. វត្ថុបំណង

- ចំនេះដឹង : ក្រោយពីរៀនចំមេរៀននេះសិស្សអាចរៀបរាប់ពីបាតុភូតធម្មជាតិ និង វិទ្យាសាស្ត្រខ្លះៗជាសមីការឌីផេរ៉ង់ស្យែលបានត្រឹមត្រូវតាមរយៈឧទាហរណ៍
- ចំនេះធ្វើ : សិស្សដោះស្រាយសមីការឌីផេរ៉ង់ស្យែលបានត្រឹមត្រូវតាមរយៈឧទាហរណ៍
- ឥរិយាបថ : សិស្សមានស្មារតីប្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់

## II. ខ្លឹមសារមេរៀន

### 4. អនុវត្តនៃសមីការឌីផេរ៉ង់ស្យែលក្នុងវិទ្យាសាស្ត្រ

#### ក. ចលនាគ្មានកំលាំងកកិត

#### ខ. ចលនាមានកំលាំងកកិត

## III. សម្ភារៈឧបទេស

- ស.ស ទំព័រ 125 ដល់ 128 បោះពុម្ពឆ្នាំ2010
- ស.គ

## IV. លំនាំនៃការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិ-ស្ស |
|---|---|---|
| គ្រូត្រួតពិនិត្យវត្តមាន និងអនាម័យថ្នាក់រៀន | ជំហ៊ានទី1 : 3នាទី | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូដាក់លំហាត់ឲ្យសិស្សដោះស្រាយ | ជំហ៊ានទី2<br>(រំលឹកមេរៀនចាស់) 10នាទី<br>លំហាត់:<br>ដោះស្រាយសមីការ :<br>$y'''+y''-4y=0$<br>គេបានសមីការសំគាល់<br>$r^3-3r^2-4=0$<br>$(r-1)(r^2+4r+4)$<br>$=(r-1)(r+2)^2$ | សិស្សដោះស្រាយលំហាត់លើក្តារខៀន<br>ចំលើយទូទៅគឺ<br>$y=Ae^x+Be^{-2x}+Cxe^{-2x}$ |

| | | |
|---|---|---|
| | $\Rightarrow r_1=1, r_2=r_3=-2$<br>ចំលើយទូទៅគឺ<br>$y=Ae^{x}+Be^{-2x}+Cxe^{-2x}$ | |
| គ្រូណែនាំឲ្យ សិស្សមើល សៀវភៅពុម្ព ត្រង់ទំព័រ 125 ហើយពន្យល់ណែនាំសិស្ស<br><br>គ្រូដាក់លំហាត់ គំរូណែនាំពន្យល់ សិស្សពីរបៀបដោះស្រាយ | ជំហ៊ានទី3(មេរៀនប្រចាំថ្ងៃ) 70នាទី<br>**4. អនុវត្តនៃសមីការឌីផេរ៉ង់ស្យែលក្នុងវិទ្យាសាស្ត្រ**<br>**ក. ចលនាគ្មានកំលាំងកកិត**<br>បើគេថ្លក់វត្ថុមួយមានម៉ាស m នៅខាងក្នុងរ៉ឺស័រដែលគេចងភ្ជាប់នឹងរបារមួយ (ដូចរូប) នោះគេឃើញរ៉ឺស័រលូតបានប្រវែង S ។<br>តាមកូនលក្ខខណ្ឌលំនឹង mg=ks រឺ<br>mg-ks=0<br>បើម៉ាសត្រូវបានជំនួសដោយ x ចេញ ពីទីតាំងលំនឹង ហើយភ្ជាប់ដោយកំលាំង ថ្មី នោះនៅក្នុងច្បាប់ទី2 ញូតុន F=ma ដែល a ជាសំទុះ<br>$a=\frac{d^2x}{dt^2}$ តាមច្បាប់ហុក :<br>$ma=-k(s+x)+mg$<br>$ma=-ks-ks+mg$ តែ<br>$mg=ks$<br>$\Rightarrow ma=-kx \Leftrightarrow m\frac{d^2x}{dt^2}+ks=0$<br><br>រឺ $\frac{d^2x}{dt^2}+\frac{k}{m}x=0$ តាង $\frac{k}{m}=c^2$<br>គេបាន $\frac{d^2x}{dt^2}+c^2x=0$ | សិស្សមើល សៀវភៅពុម្ព ត្រង់ទំព័រ125 ហើយស្តាប់គ្រូពន្យល់<br><br>សិស្សគិតដោះស្រាយលំហាត់ ដោយមានណែនាំពន្យល់ពីគ្រូ<br><br>សិស្សស្តាប់ គ្រូពន្យល់ និង |

| | | |
|---|---|---|
| គ្រូដាក់ប្រតិបត្តិ ឲ្យសិស្សធ្វើលើ ក្តារខៀន | ជាសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់2 អូម៉ូសែននិងមានមេគុណថេរ រឺ ជាសមីការឌីផេរ៉ង់ស្យែលនៃ ចលនាសេរី ។<br>**លំហាត់:**<br>បើគេព្យួរវត្ថុមានម៉ាស m=1kg នៅចុងនៃរ៉ឺស័រនោះ រ៉ឺស័រលូត បានប្រវែង 0.20m ។ នៅខណ: t=0 គេឲ្យវត្ថុស្ថិតនៅខាងក្រោមទីតាំងលំនឹងចម្ងាយ 0.40m ។ បន្ទាប់មកគេ លែងវត្ថុឲ្យរត់ឡើងលើដោយល្បឿន 0.70m/s ។ រកសមីការនៃចលនាសេរីនេះ ។<br>ដោយ m = 1kg<br>ធ្វើឲ្យរ៉ឺស័រយឺតបាន 0.20m នោះគេបាន<br>$mg = ks$<br>$\Rightarrow k = \frac{mg}{s} = \frac{1\times 9.8}{0.20}$<br>$= 49N.m$<br>ដោយចលនានេះគ្មានកំលាំងកកិត គេបាន<br>$\frac{d^2x}{dt^2}+\frac{k}{m}x=0\Rightarrow\frac{d^2x}{dt^2}+\frac{49}{1}x$<br>រឺ $x''+49x=0$<br>សមីការសំគាល់<br>$r^2+49=0\Rightarrow r=\pm 7i$<br>ចម្លើយទូទៅ<br>$x(t)=A\cos 7t+B\sin 7t$<br>ដោយខណ:<br>$t=0\Rightarrow x(0)=0.40$ | កត់ត្រា<br>សិស្សធ្វើលំហាត់ ប្រតិបត្តិ លើក្តារខៀន<br>$x(t)=-\frac{1}{4}\cos\sqrt{96t}$<br>សិស្សមើល សៀវភៅពុម្ព |

| | | |
|---|---|---|
| គ្រូឲ្យសិស្ស<br>មើលសៀវភៅ<br>ពុម្ពទំព័រ127<br>ហើយពន្យល់<br>ណែនាំសិស្ស | ហើយ $x'(0) = -0.70$<br>យើងបាន<br>$x(0) = 0.40 \Rightarrow A = 0.40$<br>$x'(t) = -7A\sin 7t + 7B\sin 7t$<br>$x'(0) = -0.70 = 7B$<br>$\Rightarrow B = -\frac{1}{10}$<br>ដូចនេះ<br>សមីការនៃចលនាសេរីគឺ<br>$x(t) = \frac{2}{5}\cos 7t - \frac{1}{10}\sin 7t$ | ទំព័រ127 និង<br>ស្តាប់ការពន្យល់ របស់គ្រូ<br><br>សិស្សស្តាប់ និង កត់ត្រា<br><br>សិស្សធ្វើលំហាត់លើ<br>ក្តារខៀនតាម រយៈសៀវភៅ<br>ពុម្ព និង ការ ណែនាំរបស់គ្រូ |
| គ្រូដាក់លំហាត់<br>ឲ្យសិស្សធ្វើលើ ក្តារខៀន | ប្រតិបត្តិ<br>វត្ថុមានម៉ាស m=0.75kg ត្រូវព្យួរនៅ ចុងរ៉ឺស័រក្នុងមជ្ឈដ្ឋានមួយដែលមាន សំទុះទំនាញផែនដី $g = 9.6m/s^2$ ពេលនោះរ៉ឺស័រលូតបានប្រវែង 0.1m ។<br>រកសមីការនៃចលនារបស់វត្ថុ បើវត្ថុនោះត្រូវគេលែងចេញពីទីតាំងមួយនៅខាងលើ ទីតាំងលំនឹងចម្ងាយ 0.25m<br>ដោយ m=0.75kg<br>ធ្វើឲ្យរ៉ឺស័រលូតបាន 0.1m<br>នោះតាមច្បាប់ហុកគេបាន<br>mg=ks<br>$\Rightarrow k = \frac{mg}{s} = \frac{0.75\times 9.6}{0.1}$<br>$= 72N.m$<br>ដោយចលនានេះគ្មានកំលាំងកកិត | សិស្សសរសេរ លំហាត់ចូល<br>សៀវភៅ និង ស្តាប់គ្រូ<br><br>$x(t) = -\frac{9}{10}te^{-4t}$ |

| | | |
|---|---|---|
| | $\Rightarrow \frac{d^2x}{dt^2}+\frac{k}{m}x=0$<br>$\Leftrightarrow x^{''}+\frac{72}{0.75}x=0$<br>$\Rightarrow x^{''}+96x=0$<br>ដោយរ៉ឺស័រលែងចេញខាងលើទីតាំងលំនឹង<br>$0.25m \Rightarrow x(0)=-0.25$<br>$, x^{'}(0)=0$<br>សមីការសំគាល់<br>$r^2+96=0 \Rightarrow r=i\sqrt{96}$<br>ចម្លើយទូទៅ<br>$x(t)=A\cos\sqrt{96t}$<br>$+B\sin\sqrt{96t}$<br>$x(0)=-0.25 \Rightarrow A=0.25$<br>$x^{'}(t)=-A\sqrt{96}\sin\sqrt{96t}$<br>$+B\sqrt{96}\cos\sqrt{96t}$<br>$x^{'}(0)=0 \Rightarrow B=0$<br>គេបាន $x(t)=-\frac{1}{4}\cos\sqrt{96t}$<br>**ខ. ចលនាមានកំលាំងកកិត**<br>បើប្រព័ន្ធចលនានៃវត្ថុស្ថិតនៅមជ្ឈដ្ឋាន ដែលមានកំលាំងកកិតនោះគេដឹងថាកំលាំងកកិតសមាមាត្រនឹងល្បឿននៃចលនា ។<br>កំលាំងកកិតគិតពី $\mu v$ ដែល $\mu$ ជាមេគុណសមាមាត្រនឹង $v$ ជាល្បឿន $v=\frac{dx}{dt}$<br>តាមច្បាប់ទី2ញូតុននិងហុក គេបាន :<br>$m\frac{d^2x}{dt^2}=-kx-\mu v$<br>$\Rightarrow \frac{d^2x}{dt^2}+\frac{\mu}{m}\frac{dx}{dt}+\frac{k}{m}x=0$ | |

| | | |
|---|---|---|
| | **លំហាត់** : បើគេព្យួរម៉ាស m=0.25kg នៅចុងនៃ រ៉ឺស័រ លូតបានប្រវែង 61cm ។ ក្នុងទីតាំងលំនឹងគេប្រើកំលាំងឲ្យម៉ាសរត់ទៅលើ ដោយល្បឿនដើម 0.9m/s គេសន្មត់ថាក្នុងប្រព័ន្ធចលនានេះមាន កំលាំងកកិត 2ដងនៃ $g=9.76m/s^2$ ។ រកសមីការ បំលាស់ទី $x(t)$<br>តាមច្បាប់ហុក<br>$mg=ks\Rightarrow k=\frac{mg}{s}$<br>$k=\frac{0.25\times9.76}{0.61}=4N.m$<br>សមីការឌីផេរ៉ង់ស្យែលនៃចលនានេះគឺ :<br>$0.25\frac{d^2x}{dt^2}=-4x-2\frac{dx}{dt}$<br>$\Leftrightarrow\frac{d^2x}{dt^2}+8\frac{dx}{dt}+16x=0$<br>គេមានលក្ខខណ្ឌដើម<br>$x(0)=0,x'(0)=-0.9$<br>សមីការសំគាល់<br>$r^2+8r+16=0$<br>$\Rightarrow r_1=r_2=-4$<br>ចម្លើយទូទៅ<br>$x(t)=Ae^{-4t}+Bte^{-4t}$<br>$x(0)=0\Rightarrow A=0$<br>$x'(t)=-4Ae^{-4t}+Be^{-4t}-4Bte^{-4t}$<br>$x'(0)=-0.9\Rightarrow-0.9=-4A+B$<br>$\Leftrightarrow B=-0.9$<br>ដូចនេះ $x(t)=-\frac{9}{10}te^{-4t}$ | |
| គ្រូដាក់លំហាត់ ឲ្យសិស្សធ្វើក្នុងសៀវភៅរៀងៗខ្លួន | ជំហានទី4 (ពង្រឹងពុទ្ធិ)7នាទី<br>**លំហាត់** : | សិស្សធ្វើ លំហាត់ក្នុងសៀវភៅរួច ឡើងកែលើ |

| | | |
|---|---|---|
| | ដោះស្រាយសមីការនិង បកស្រាយ បញ្ហាលក្ខខណ្ឌដើមខាងក្រោម : $\frac{d^2x}{dt^2}+16x=0, x(0)=10, x'(0)$ គេបានសមីការសំគាល់ $r^2+16=0 \Rightarrow r=\pm 4i$ ចំលើយទូទៅ $x(t)=A\cos 4t+B\sin 4t$ $x(0)=10 \Rightarrow A=10$ $x'(t)=-4A\sin 4t+4B\cos 4t$ $x'(0)=0 \Rightarrow 4B=0 \Rightarrow B=0$ ដូចនេះ $x(t)=10\cos 4t$ | ក្តារខៀន $x(t)=10\cos 4t$ |
| ពេលប្អូនទៅ ផ្ទះវិញធ្វើ លំហាត់ ប្រតិ-បត្តិទំព័រ128 | ជំហ៊ានទី5 (បណ្តាំផ្ញើរ)3នាទី លំហាត់ប្រតិបត្តិទំព័រទី128 | សិស្សស្តាប់គ្រូ និង កត់ចំណាំ លេខទំព័រ128 |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)
## ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល
## មេរៀនទី២ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី២

I. **វត្ថុបំណង** : ក្រោយពីរៀនចប់សិស្សអាច :

- សិស្សស្គាល់រាងទូទៅនៃសមីការឌីផេរ៉ង់ស្យែលរាង $y''+by'+c=p(x)$
- សិស្សអាចដោះស្រាយសមីការឌីផេរ៉ង់ស្យែលរាង $y''+by'+c=p(x)$ បាន

II. **រយៈពេល** : 2ម៉ោង ថ្ងៃទី.........ខែ......ឆ្នាំ......

III. **សំភារៈឧបទ្ទេស** :

- ស.ស ទំព័រទី .... ដល់..... បោះពុម្ពឆ្នាំ2010
- ស.គ ទំព័រទី.....ដល់......
- បន្ទាត់ឈើ

IV. **សកម្មភាពបង្រៀន** :

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| គ្រូពិនិត្យ អវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | **ជំហ៊ានទី1 (លំនឹងថ្នាក់)** 3នាទី | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូនិយាយ និង សរសេរលើក្តារខៀន ព្រមទាំងសួរ សិស្ស ខ្លះផង | **ជំហ៊ានទី2 (រំលឹកមេរៀនចាស់)** 7នាទី<br>សមីការអូម៉ូសែនរាង $y''+by'+cy=0$<br>នោះសមីការ សំគាល់គឺ : $r^2+br+c=0$<br>- បើ $\Delta>0$: សមីការមានរឹសពីរ គឺ $r_1,r_2$ ផ្សេងគ្នា<br>$\Rightarrow y=Ae^{r_1x}+Be^{r_2x}$<br>- បើ $\Delta=0$:សមីការមានរឹសឌុប គឺ $r_0$<br>$\Rightarrow y=(Ax+B)e^{r_0x}$<br>- $\Delta<0$: សមីការមានរឹសជា | សិស្សពិនិត្យមើលសកម្មភាពបកស្រាយរបស់គ្រូ |

| | | |
|---|---|---|
| | កុំផ្លិចឆ្លាស់គឺ $r=\alpha\pm i\beta$<br>$\Rightarrow y=\left(A\cos\beta x+B\sin\beta x\right)e^{\alpha x}$ | |
| + គ្រូ សរសេរ មេរៀនថ្មី<br><br><br>+យើងពិនិត្យមើល សមីការមិនអូម៉ូសែនគឺមានរាង $y''+by'+cy=p(x)$<br>+តើគេអាចស្រាយសមីការបែបនេះដូចម្ដេច?<br><br><br>+ ចូរពិនិត្យ $Ex$ ដោះស្រាយសមីការ<br>$y''-y=e^{x}\quad(E)$<br>+តាង $Z=y'-y$ គេបាន | ជំហ៊ានទី3(មេរៀនថ្មី)70នាទី<br>**សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរ លំដាប់2(ត)**<br><br>**3. ដំណោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់2 មិនអូម៉ូសែន និងមានមេគុណថេរ**<br>សមីការមានរាងទូទៅគឺ :<br>$y''+by'+cy=p(x)$<br>**3.1 វិធីដោះស្រាយសមីការ ឌីផេរ៉ង់ស្យែលលីនេអ៊ែរ លំដាប់2មិនអូម៉ូសែន**<br>$y''+by'+cy=p(x)$<br>Ex : ដោះស្រាយសមីការ<br>$y''-y=e^{x}\quad(E)$<br>**ចម្លើយ**<br>$(E)\Leftrightarrow(y'-y)'+(y'-y)=e^{x}$<br><br>តាង $Z=(y'-y)\quad(1)$<br>នោះគេបាន<br>• ដោះស្រាយសមីការ(1):<br>$Z'+Z=e^{x}$<br>i. សមីការអូម៉ូសែនគឺ<br>$Z'+Z=e^{x}$<br>$\Rightarrow Z_c=Ke^{-x}\ ,\ K\in\mathbb{R}$<br>ii. ចម្លើយពិសេសរាង<br>$Z_p=e^{-x}K(x)$ | + សិស្ស កត់ត្រា<br><br>+ សិស្ស សង្កេត និង កត់ត្រា<br><br>+ សិស្ស សង្កេត និង កត់ត្រា<br><br>+ សិស្សសង្កេត<br><br>+ សិស្សពិភាក្សា ជា4ក្រុម |

| | | |
|---|---|---|
| $Z=Be^{-x}+\frac{e^x}{2}$ នោះ<br>$y'-y=Be^{-x}+\frac{e^x}{2}$<br><br>តើគេអាចដោះស្រាយសមីការនេះ យ៉ាងដូចម្តេច?<br><br>+ គ្រូសរសេរលំហាត់លើក្តារខៀនរួចឲ្យសិស្សគិតពិភាក្សាជាគូៗរួចគ្រូហៅម្នាក់ឲ្យឡើងក្តារខៀន | $\Rightarrow Z'_p=e^{-x}K'(x)-e^{-x}K(x)$<br>$(1)\Rightarrow e^{-x}K'(x)-e^{-x}K(x)$<br>$+e^{-x}K(x)=e^x$<br>$\Rightarrow K'(x)=e^{2x}$<br>$\Rightarrow K(x)=\frac{1}{2}e^{2x}+c\ ,\ c\in\mathbb{R}$<br>$\Rightarrow Z_p=e^{-x}\left(\frac{1}{2}e^{2x}+c\right)\ ,\ c\in\mathbb{R}$<br>ដូចនេះ<br>$Z=Z_c+Z_p$<br>$=Ke^{-x}+ce^{-x}+\frac{e^x}{2}$<br>$=Be^{-x}+\frac{e^x}{2}\ ,(B=K+c)\in\mathbb{R}$<br>នោះ $y'-y=Be^{-x}+\frac{e^x}{2}\quad(2)$<br>• ដោះស្រាយសមីការ(2):<br>$y'-y=Be^{-x}+\frac{e^x}{2}$<br>$\Rightarrow e^{-x}y'-e^{-x}y=Be^{-2x}+\frac{1}{2}$<br>$\Rightarrow\left(e^{-x}y\right)'=Be^{-2x}+\frac{1}{2}$<br>$\Rightarrow e^{-x}y=-\frac{Be^{-2x}}{2}+\frac{x}{2}+c_1$<br>$\Rightarrow y=-\frac{Be^{-2x}}{2}+\frac{xe^x}{2}+c_1e^x$<br>**លំហាត់**<br>ដោះស្រាយសមីការ<br>$y''-y=xe^x\quad(E)$<br>**ចម្លើយ**<br>$(E)\Leftrightarrow\left(y'-y\right)'+\left(y'-y\right)=xe^x$<br>តាង $Z=\left(y'-y\right)\quad(*)$<br>$\Rightarrow Z'+Z=xe^x$<br>• ដោះស្រាយសមីការ<br>$Z'+Z=xe^x\quad(**)$<br>i. សមីការអូម៉ូសែន<br>$Z'+Z=0$<br>$\Rightarrow Z_c=Ke^{-x}\ ,\ K\in\mathbb{R}$ | + សិស្ស ធ្វើដាក់លើ ក្រដាសព្រៀងរួច ឡើងធ្វើលើក្តារខៀន |

| | | |
|---|---|---|
| + ពីមុនសមីការ $y'+ay=p(x)$ => ចំ.ទូទៅ= ចំ.ពិសេស+ចំ.អូម៉ូសែន<br><br>តើចំពោះសមីការ $y'+ay=p(x)$ ចំ.ទូទៅ=?<br>+ តើគេរកចំលើយពិសេសយ៉ាងដូចម្តេច?<br>+ ទេមិនដូចគ្នាទេ ព្រោះវាមានសមីការសំគាល់ ដែលធ្វើឲ្យ ចំ.អូម៉ូសែន មានរាងតែបីទេ<br><br>+ ឲ្យសិស្សគិត3នាទី រួចហៅឡើងធ្វើលំហាត់ | ii. ចម្លើយពិសេសនៃសមីការ<br>(**)មានរាង $Z_p=e^{-x}g(x)$<br>$\Rightarrow Z'_p=e^{-x}g'(x)-e^{-x}g(x)$<br>គេបាន<br>$(**):e^{-x}g'(x)-e^{-x}g(x)$<br>$+e^{-x}g(x)=xe^{x}$<br>$\Rightarrow g'(x)=xe^{2x}$<br>$\Rightarrow g(x)=\frac{e^{2x}}{2}\left(x-\frac{1}{2}\right)+c_1$ ,<br>$c_1\in\mathbb{R}$<br>$\Rightarrow Z_p=\frac{e^{x}}{2}\left(x-\frac{1}{2}\right)+c_1e^{-x}$ ,<br>$c_1\in\mathbb{R}$<br>ដូចនេះ<br>$Z=Z_c+Z_p$<br>$=Ke^{-x}+c_1e^{-x}+\frac{e^x}{4}(2x-1)$<br>$=ce^{-x}+\frac{e^x}{4}(2x-1)$<br>នោះ<br>$y'-y=ce^{-x}+\frac{e^x}{4}(2x-1)$<br>$\Rightarrow (e^{-x}y)'=ce^{-2x}+\frac{1}{4}(2x-1)$<br>$\Rightarrow e^{-x}y=-ce^{-2x}+\frac{1}{4}(2x-1)$<br>$+A,\ \ A\in\mathbb{R}$<br>$\Rightarrow y=-\frac{c}{2}e^{-x}+\frac{e^x}{4}(x^2-x)$<br>$+Ae^{x}$<br>**3.2 វិធីដោះស្រាយតាមការស្វែងរកចម្លើយពិសេសមិនអូម៉ូសែន**<br>ចំ.ទូទៅ=ចំ.ពិសេស+ចំ.អូម៉ូសែន<br>Ex : ដោះស្រាយសមីការ<br>$y''-y=e^{x}\ (E)$ | + ចំ.ពិ សេស គឺ អាស្រ័យលើ ចំ.អូម៉ូសែន<br>Ex : $y=Ke^{x}$<br>$\Rightarrow y_p=e^{x}g(x)$ ដែលគេត្រូវរក $g(x)$<br>+ ចំពោះ សមីការ $y''+by'+cy=p(x)$ ក៏ដូចគ្នាដែរ<br><br>+ កត់ត្រា និងសួរ |

| | | |
|---|---|---|
| + ចម្លើយពិសេសរាង<br>$y_p = a\sin x + b\cos x$<br>ព្រោះដេរីវេអាចចេញជា $\sin x$ រឺ $\cos x$ ដែលគេទូទាត់នៅសល់ $\sin x$ នោះ ! | + សមីការអូម៉ូសែនរាង<br>$y''-y=0$<br>សមីការសំគាល់គឺ<br>$r^2-1=0 \Rightarrow r=\pm 1$<br>$\Rightarrow y = Ae^{-x}+Be^{x}\ ,(A,B\in\mathbb{R})$<br><br>+ ចំលើយពិសេសរាង<br>$y = axe^x$<br>$\Rightarrow y_p' = ae^x + axe^x$<br>$= ae^x(x+1)$<br>$\Rightarrow y_p'' = ae^x + ae^x(x+1)$<br>$= ae^x(x+2)$<br>$(E) :\Rightarrow ae^x(x+2) - axe^x = e^x$<br>$\Rightarrow ax + 2a - ax = 1$<br>$\Rightarrow a = \frac{1}{2} \Rightarrow y_p = \frac{xe^x}{2}$<br>ដូចនេះ<br>$y = y_c + y_p = Ae^{-x} + Be^x + \frac{xe^x}{2}$<br><br>**លំហាត់**<br>ដោះស្រាយសមីការ<br>$y''-2y'+y=\sin x \qquad (E)$ ។<br>**ចម្លើយ**<br>+ សមីការអូម៉ូសែនគឺ<br>$y''-2y'+y=0$<br>សមីការសំគាល់គឺ<br>$r^2-2r+1=0$<br>$\Rightarrow r_0 = 1 \Rightarrow y_c = (Ax+B)e^x,\ (A$<br>+ ចម្លើយពិសេសរាង<br>$y_p = a\sin x + b\cos x$<br>$\Rightarrow y_p' = a\cos x - b\sin x$<br>$\Rightarrow y_p'' = -a\sin x - b\cos x$<br>នោះគេបាន : | |

| | | |
|---|---|---|
| | $(E)\Rightarrow -a\sin x-b\cos x$<br>$-2\left(a\cos x-b\sin x\right)$<br>$+a\cos x+b\sin x=\sin x$<br>$\Rightarrow 2b\sin x-2a\cos x=\sin x$<br>$\Rightarrow b=\frac{1}{2}\ ,\ a=0$<br>$\Rightarrow y_p=\frac{1}{2}\cos x$<br>ដូចនេះ<br>$y=y_c+y_p$<br>$=(Ax+B)e^x+\frac{1}{2}\cos x$ | |
| + គ្រូសួរ : | **ជំហ៊ានទី4 (ពង្រឹងពុទ្ធិ)**7នាទី<br>+ ប្រើអថេរជំនួយដោយតាងZ<br>+ចំ.ទូទៅ=ចំ.ពិសេស+ចំ.អូម៉ូសែន | + សិស្សឆ្លើយ : |
| + គ្រូដាក់ លំហាត់ឲ្យសិស្សធ្វើនៅ ផ្ទះ | **ជំហ៊ានទី5 (បណ្តាំផ្ញើរ)** 3នាទី<br>ដោះស្រាយសមីការ<br>ក. $y''-\sqrt{3}y'-y=2x+1$<br>ខ. $y''+y'+y=\left(x-1\right)e^x$ | +សិស្សកត់ត្រា លំហាត់ដោយយក ចិត្តទុកដាក់ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)
## ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល
## មេរៀនទី២ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី២

**I.** វត្ថុបំណង : ក្រោយពីរៀនចប់សិស្សអាច :
- កំណត់សញ្ញាណសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2
- កំណត់សមីការសំគាល់នៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2អូម៉ូសែន

**II.** រយះពេល : 2ម៉ោង ថ្ងៃទី.........ខែ......ឆ្នាំ......

**III.** សំភារ:ឧបទ្ទេស :
- ស.ស ទំព័រទី .... ដល់..... បោះពុម្ពឆ្នាំ2010
- ស.គ ទំព័រទី.....ដល់......
- បន្ទាត់ឈើ

**IV.** សកម្មភាពបង្រៀន :

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូពិនិត្យ អវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | **ជំហ៊ានទី1 (លំនឹងថ្នាក់)**<br>3នាទី | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូសួរសំនួរ និង ដាក់លំហាត់<br>1, ដូចម្តេចហៅថា សមីការឌីផេរ៉ង់ស្យែលលំដាប់ទី1?<br>2, បង្ហាញថាអនុគមន៍ $y=\sin x+\cos x$ ជាចំលើយនៃសមីការ $y'+y=2\cos x$ | **ជំហ៊ានទី2**<br>**(រំលឹកមេរៀនចាស់)7នាទី**<br><br>1, សមីការឌីផេរ៉ង់ស្យែលលំដាប់ លំដាប់ទី1 ជាទំនាក់ទំនងរវាង អនុគមន៍ ដេរីវេទី1របស់អនុគមន៍ នេះ អថេរ និង ចំនួនអថេរ ។<br>2, បង្ហាញថា<br>$y=\sin x+\cos x$ ជា<br>**ចម្លើយនៃ** $y'+y=2\cos x$<br>គេមាន $y=\sin x+\cos x$<br>$\Rightarrow y'=\cos x-\sin x$<br>គេបាន | ចម្លើយរបស់សិស្ស |

| | | |
|---|---|---|
| | $y'+y=\cos x-\sin x+\sin x$<br>$+\cos x$<br>$=2\cos x$<br>ដូចនេះ $y=\sin x+\cos x$<br>ជាគូចម្លើយនៃ<br>$y'+y=2\cos x$ | |
| <br>+ គ្រូ សរសេរ មេរៀនថ្មី<br>+ គ្រូឲ្យសិស្សសង្កេត<br>$Ex$ គេមានអនុគមន៍<br>$f_1(x)$ និង $f_2(x)$ ដែល<br>កំណត់លើ $\mathbb{R}$ ដោយ<br>$f_1(x)=e^{-x}$ និង<br>$f_2(x)=e^{3x}$<br>+ឲ្យសិស្សរកចម្លើយ<br>ក, គណនាដេរីវេទី1 និង<br>ដេរីវេទី2 នៃអនុគមន៍ $f_1$<br>និង $f_2$<br>ខ,<br>ផ្ទៀងផ្ទាត់ថាចំពោះគ្រប់<br>ចំនួនពិត $x$<br>$f_1''(x)-2f_1'(x)-3f_1(x)=0$<br>និង<br>$f_2''(x)-2f_2'(x)-3f_2(x)=0$<br>គ, បង្ហាញថាអនុគមន៍<br>$y=c_1f_1(x)+c_2f_2(x)$<br>ផ្ទៀងផ្ទាត់សមីការ<br>$y''-2y'-3y=0$<br>ចំពោះគ្រប់ $c_1$ និង $c_2$<br><br><br><br><br><br>+គ្រូឲ្យសិស្សសាកល្បង | ជំហ៊ានទី3(មេរៀនថ្មី)70នាទី<br>**សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរ លំដាប់**2(**ត**)<br>1. **សមីការ ឌីផេរ៉ង់ស្យែលលំដាប់ទី**2<br>.សមីការ<br>$f_1''(x)-2f_1'(x)-3f_1(x)=0$<br>និង<br>$f_2''(x)-2f_2'(x)-3f_2(x)=0$<br>អាចសរសេរជាសមីការ<br>$y''-2y'-3y=0$<br>ហៅថាសមីការ លីនេអ៊ែ<br>លំដាប់ ទី2អូម៉ូសែន និង<br>មានមេគុណថេរ (1,-2,-3)<br>.ដោយអនុគមន៍<br>$f_1(x),f_2(x)$<br>ដែលមានដេរីវេទី1<br>$f_1'(x),f_2'(x)$ និងដេរីវេទី2<br>$f_1''(x),f_2''(x)$ ផ្ទៀងផ្ទាត់<br>សមីការ $y''-2y'-3y=0$<br>នោះគេថា $f_1(x),f_2(x)$ ជា<br>ចម្លើយគោលនៃសមីការនេះ<br>.ដោយអនុគមន៍<br>$y=c_1f_1+c_2f_2$<br>និងដេរីវេទី1 និង ទី2នៃ<br>អនុគមន៍នេះផ្ទៀងផ្ទាត់សមីការ<br>$y''-2y'-3y=0$ | <br>ចម្លើយ<br>ក,<br>$f_1(x)=e^{-x}$<br>$\Rightarrow f_1'(x)=-e^{-x}$<br>$\Rightarrow f_1''(x)=e^{-x}$<br>$f_2(x)=e^{3x}$<br>$\Rightarrow f_2'(x)=3e^{3x}$<br>$\Rightarrow f_2''(x)=9e^{3x}$<br>ខ,<br>$f_1''(x)-2f_1'(x)-3f_1(x)$<br>$=e^{-x}+2e^{-x}-3e^{-x}=0$<br>$f_2''(x)-2f_2'(x)-3f_2(x)$<br>$=9e^{3x}-6e^{3x}-3e^{3x}=0$<br>គ,<br>$y=c_1f_1(x)+c_2f_2(x)$<br>$\Rightarrow y'=c_1f_1'(x)+c_2f_2'(x)$<br>$\Rightarrow y''=c_1f_1''(x)+c_2f_2''(x)$<br>$\Rightarrow y''-2y'-3y=$<br>$c_1f_1''(x)+c_2f_2''(x)$<br>$-2\left[c_1f_1'(x)+c_2f_2'(x)\right]$<br>$3\left[c_1f_1(x)+c_2f_2(x)\right]$<br>$=c_1\times 0+c_2\times 0=0$<br>ដូចនេះ $y=c_1f_1(x)+c_2f_2(x)$<br>ផ្ទៀងផ្ទាត់សមីការ<br>$y''-2y'-3y=0$<br>+ចំលើយសិស្ស |

| | | |
|---|---|---|
| កំណត់និយមន័យរបស់សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2 អូម៉ូសែន | ចំពោះគ្រប់ចំនួនថេរ $c_1$ និង $c_2$ នោះគេថាអនុគមន៍ $y=c_1f_1+c_2f_2$ ជាចម្លើយទូទៅនៃសមីការនេះ<br><br>**<u>និយមន័យ</u>**<br>សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែ លំដាប់ទី2អូម៉ូសែន និងមានមេ គុណថេរជាសមីការដែលអាច សរសេរជារាងទូទៅ<br>$ay''+by'+cy=0$ ដែល $a,b,c$ ជាចំនួនពិត $a\neq 0$ ។<br>**<u>ចំណាំ</u>**<br>ដើម្បីងាយស្រួលដោះស្រាយ $ay''+by'+cy=0$ ដែល មេគុណ $y''=1$ ។<br>ការដោះស្រាយសមីការនេះគឺ រកគ្រប់អនុគមន៍ដែលផ្ទៀងផ្ទាត់ សមីការ ។ | |
| + គ្រូដាក់លំហាត់ឲ្យសិស្ស ពិភាក្សាជាក្រុមរួចឡើងធ្វើ ចំលើយនៅលើក្ដារខៀន<br>**លំហាត់:**<br>ផ្ទៀងផ្ទាត់ថាអនុគមន៍ $f$ ជាចំលើយនៃសមីការឌីផេរ៉ង់ស្យែលដែលគេឲ្យនៅខាងស្ដាំ<br>ក, $f(x)=(2x+1)e^{-x}$, $y''+2y'+y=0$ | ជំហានទី4 (ពង្រឹងពុទ្ធិ)7នាទី<br><br>ចម្លើយ<br>**ក,** | |

| | | |
|---|---|---|
| ខ, $f(x)=e^{-x}\sin x$ ,<br>$y''+2y'+2y=0$ | $f(x)=(2x+1)e^{-x}$<br>$\Rightarrow f'(x)=-(2x+1)e^{-x}+2e^{-x}$<br>$=(1-2x)e^{-x}$<br>$\Rightarrow f''(x)=-(1-2x)e^{-x}-2e^{-x}$<br>$=(2x-3)e^{-x}$<br>គេបាន<br>$f''(x)+2f'(x)+f(x)$<br>$=\left[(2x-3)e^{-x}+2(1-2x)e^{-x}\right.$<br>$\left.+(2x+1)e^{-x}\right]$<br>$=(2x-3-4x+2+2x+1)e^{-x}$<br>$=0$<br>ខ, គេមាន $f(x)=e^{-x}\sin x$<br>$\Rightarrow f'(x)=-e^{-x}\sin x+e^{-x}\cos x$<br>$\Rightarrow f''(x)=e^{-x}\sin x-e^{-x}\cos x$<br>$-e^{-x}\cos x-e^{-x}\sin x$<br>$=-2e^{-x}\cos x$<br>គេបាន<br>$f''(x)+2f'(x)+f(x)$<br>$=-2e^{-x}\cos x+2\left(-e^{-x}\sin x+e^{-x}\cos x\right)$<br>$+2e^{-x}\sin x$<br>$=-2e^{-x}\cos x-2-e^{-x}\sin x+2e^{-x}\cos x$<br>$+2e^{-x}\sin x$<br>$=0$<br>ដូចនេះ $f(x)=e^{-x}\sin x$ ជាចម្លើយនៃ<br>$y''+2y'+2y=0$ | + ចំលើយសិស្ស : |
| + គ្រូដាក់កិច្ចការផ្ទះឲ្យសិស្សធ្វើ<br>លំហាត់:<br>ក, បង្ហាញថាអនុគមន៍<br>$f(x)=Ae^{x}+Bxe^{x}$<br>ជាចំលើយនៃសមីការ<br>$y''-2y'+y=0$ ដែល | ជំហ៊ានទី5 (បណ្តាំផ្ញើរ)<br>3នាទី | +សិស្សកត់ត្រា លំហាត់ ដោយយក ចិត្តទុកដាក់ |

| | | |
|---|---|---|
| $A, B$ ជាចំនួនថេរណាមួយក៏បាន ។ ខ, សរសេរនិយមន័យសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2 ។ | | |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល

## មេរៀនទី២ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី២

I. **វត្ថុបំណង** : ក្រោយពីរៀនចប់សិស្សអាច :

- ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2ដែលមានសមីការសំគាល់មានរឹសឌុប
- ដោះស្រាយសមីការសំគាល់នៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2ដែលមានសមីការសំគាល់មានរឹសពីរជាចំនួនកុំផ្លិច

II. **រយៈពេល** : 2ម៉ោង ថ្ងៃទី………ខែ……ឆ្នាំ……

III. **សំភារៈឧបទ្ទេស** :

- ស.ស ទំព័រទី …. ដល់….. បោះពុម្ពឆ្នាំ2010
- ស.គ ទំព័រទី…..ដល់……
- បន្ទាត់ឈើ

IV. **សកម្មភាពបង្រៀន** :

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូពិនិត្យ អវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ជំហ៊ានទី1 (លំនឹងថ្នាក់) 3នាទី | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូសួរសួរសិស្សអំពីនិយមន័យសមីការសំគាល់ នៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី2 | ជំហ៊ានទី2 (រំលឹកមេរៀនចាស់)7នាទី<br><br>ចូរឲ្យនិយមន័យនៃសមីការសំគាល់នៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី2 ។ | សិស្សឡើងឆ្លើយ និយមន័យ: សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី2អូម៉ូសែន និងមានមេគុណថេរជាសមីការដែលអាចសរសេរជារាងទូទៅ $ay''+by'+cy=0$ ដែល $a,b,c$ ជាចំនួនពិត និង $a\neq 0$ |
| + គ្រូ សរសេរ មេរៀនថ្មី | ជំហ៊ានទី3(មេរៀនថ្មី)70នាទី<br>**សមីការឌីផេរ៉ង់ស្យែលលី** | |

| | | |
|---|---|---|
| + គ្រូសរសេរ $Ex$ ដាក់លើក្ដារខៀនឲ្យសិស្សសង្កេត | **នេះអើរលំដាប់2(ត)**<br>**ខ. សមីការសំគាល់មានរឹសឌុប**<br>$Ex$ ដោះស្រាយសមីការឌីផេរ៉ង់ស្យែល<br>$y''+4y'+4y=0 \quad (E)$ | សិស្សសរសេរ $Ex$ ដាក់ក្នុងសៀវភៅ |
| +គ្រូហៅសិស្សដោះស្រាយ សមីការដឺក្រេទី2 | ចម្លើយ<br>សមីការសំគាល់នៃ $(E)$ គឺ<br>$\lambda^2+4\lambda+4=0$<br>សមីការសំគាល់មានរឹស<br>$\lambda_1,\lambda_2=-2$<br>$(E)$ អាចសរសេរ<br>$(y'+2y)'+2(y'+2y)=0 \; (i)$<br>តាង $Z=y'+2y$<br>$(i): Z'+2Z=0$<br>$\frac{dz}{dx}=-2z \Rightarrow \frac{dz}{z}=-2dx$<br>$\ln\|z\|=-2x+c$<br>$Z=Ae^{-2x} \; \left(A=\pm e^{c}\right)$ | +សមីការសំគាល់នៃសមីការ $(E)$ គឺ<br>$\lambda^2+4\lambda+4=0$<br>$\Delta'=4-4=0$<br>$\Rightarrow \lambda_1=\lambda_2=-\frac{b'}{a}=-2$ |
| +គ្រូហៅសិស្សឲ្យឡើងធ្វើដេរីវេ<br>+គ្រូហៅសិស្សឲ្យឡើងធ្វើអាំងតេក្រាល | គេបាន: $y'+2y=Ae^{-2x} \; (ii)$<br>$y'+2y=0$ មានចម្លើយ<br>$y=c_1e^{-2x}$<br>(តាមទម្រង់ $Z'+2Z=0$)<br>ធ្វើបំរែបំរួលចំនួនថេរ $c_1$:<br>$y=c_1e^{-2x}, y'=c_1'(x)e^{-2x}-2c_1($ | $y=c_1(x)e^{-2x} \Rightarrow$<br>$y'=c_1'(x)e^{-2x}-c_1(x)e^{-2x}$<br>+<br>$\int c_1'(x)=\int A$<br>$c_1(x)=Ax+B$ |
| +គ្រូណែនាំសិស្សឲ្យញែករកលក្ខណៈទូទៅ | $(ii): c_1'(x)e^{-2x}-2c_1(x)e^{-2x}+2$<br>$c_1'(x)e^{-2x}=Ae^{-2x}\Rightarrow c_1(x)$<br>($B$ ជាចំនួនថេរ)<br>ដូចនេះ $y=(Ax+B)e^{-2x}$<br>គេបានចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល<br>$y''+4y'+4y=0$ គឺ | |
| +គ្រូដាក់ប្រតិបត្តិឲ្យសិស្ស | $y=(Ax+B)e^{-2x}$ ដែល<br>$A\&B$ ជាចំនួនថេរណា | + សិស្សឆ្លើយ ៖ |

| | | |
|---|---|---|
| ឡើងធ្វើលើក្ដារខៀន | មួយក៏បាន<br><u>ជាទូទៅ</u> បើសមីការសំគាល់<br>$\lambda^2+b\lambda+c=0$ នៃ<br>សមីការឌីផេរ៉ង់ស្យែល<br>$y''+by'+c=0$ មានឫស<br>ឌុបជាចំនួនពិតគឺ<br>$\lambda_1=\lambda_2=\alpha$ នោះគេបាន<br>ចម្លើយទូទៅនៃសមីការឌីផេ<br>រ៉ង់ស្យែលនេះគឺ<br>$y=(Ax+B)e^{\alpha x}$ ដែល<br>$A\&B$ ជាចំនួនថេរណា<br>មួយក៏បាន ។ $\lambda_1=xe^{\alpha x}$ និង<br>$\lambda_2=e^{\alpha x}$ ជាចម្លើយ គោល ។<br><u>ប្រតិបត្តិ</u><br>ដោះស្រាយសមីការឌីផេរ៉ង់<br>ស្យែល $4y''-4y'+y=0$<br>តាមលក្ខខណ្ឌដើម<br>$y(0)=-3, y'(0)=2$ | សមីការ $4y''-4y'+y=0$<br>មានសមីការសំគាល់<br>$\lambda^2-4\lambda+1=0$<br>មានឫសឌុបគឺ $\lambda_1=\lambda_2=1$<br>ដូចនេះ ចម្លើយទូទៅនៃ<br>សមីការគឺ $y=(Ax+B)e^{\alpha x}$<br>ដែល $A\&B$<br>ជាចំនួនថេរណា<br>មួយក៏បាន<br>តាមលក្ខខណ្ឌដើម<br>$y(0)=-3$<br>$\Leftrightarrow -3=A\times 0\times e^0+Be^0$<br>$\Rightarrow B=-3 \quad (1)$<br>$y=Axe^x+Be^x$<br>$y'=Axe^x+Ae^x+Be^x$<br>$y'(0)=2$<br>$\Leftrightarrow 2=A+B \ (2)$<br>$(1)\&(2)$ គេបាន<br>$A=-1$<br>ដូចនេះ $y=-xe^x-3e^x$<br>ជាចម្លើយពិសេស<br>តាមលក្ខខណ្ឌ<br>$y(0)=-3\&y'(0)=2$ |
| +គ្រូឲ្យសិស្សសង្កេត $Ex$ | | +សិស្សកត់ត្រា និង សង្កេត |
| +ណែនាំឲ្យសិស្សឲ្យសិស្ស<br>ឲ្យដោះស្រាយសមីការ<br>ឌីផេរ៉ង់ស្យែលលីនេអ៊ែរ<br>លំដាប់2 បើ បើ $\lambda_1$ និង $\lambda_2$<br>ជាឫស2 | | +សិស្សឆ្លើយ |

| | | |
|---|---|---|
| ផ្សេងគ្នានៃសមីការសំគាល់នោះគេទាញបានចម្លើយទូទៅនៃ$(E)$ ដូចម្តេច?<br><br>+ណែនាំសិស្សឲ្យយកតំលៃ<br>$e^{ix}=\cos x+\sin x$<br>$e^{-ix}=\cos x-i\sin x$<br>ជំនួសក្នុងសមីការ<br>$y=Ae^{(\alpha-i\beta)x}+Be^{(\alpha+i\beta)x}$<br><br>+គ្រូណែនាំសិស្សឲ្យទាញរកលក្ខណះទូទៅ<br><br>+<br>គ្រូដាក់ប្រតិបត្តិឲ្យសិស្សឡើងធ្វើលើក្តារខៀន | **គ. សមីការសំគាល់មានរឹសពីរជាចំនួនកុំផ្លិច**<br>$Ex$:គេមានសមីការឌីផេរ៉ង់ស្យែល $(E): y''+by'+cy=0$<br>ដែលសមីការសំគាល់<br>$\lambda^2+b\lambda+c=0$<br>មានរឹស2ជាចំនួនកុំផ្លិច<br>$\lambda_1=\alpha-i\beta$ និង $\lambda_2=\alpha+i\beta$ ។<br>រកចម្លើយទូទៅនៃ $(E)$ ។<br>ចម្លើយ<br>តាមវិធីដោះស្រាយសមីការឌីផេរ៉ង់ស្យែល<br>លីនេអ៊ែរលំដាប់2<br>បើ $\lambda_1$ និង $\lambda_2$<br>ជារឹស2ផ្សេងគ្នានៃសមីការសំគាល់<br>នោះគេបានចម្លើយទូទៅ<br>$(E)$ គឺ $y=Ae^{\lambda_1 x}+Be^{\lambda_1 x}$<br>ដោយ $\lambda_1=\alpha-i\beta$ និង<br>$\lambda_2=\alpha+i\beta$<br>$y=Ae^{(\alpha-i\beta)x}+Be^{(\alpha+i\beta)x}$<br>$=Ae^{\alpha x}.Ae^{-i\beta x}+Be^{\alpha x}+Be^{i\beta x}$<br><br>តាមរូបមន្ត $Euler$<br>$e^{ix}=\cos x+\sin x$<br>$e^{-ix}=\cos x-i\sin x$<br>គេបាន<br>$y=Ae^{ix}(\cos\beta x-i\sin\beta x)$<br>$+Be^{\alpha x}(\cos\beta x+i\sin\beta x)$<br>$y=(A+B)e^{\alpha x}\cos\beta x+i(B-A$<br><br>ជាចម្លើយនៃ $(E)$ | $y=Ae^{\lambda_1 x}+Be^{\lambda_1 x}$<br><br>ចម្លើយ<br>សមីការសំគាល់គឺ<br>$\lambda^2+4\lambda+8=0$<br>$\Delta'=4-8=-4=4i^2$<br>$\Rightarrow\lambda_1=-2-2i$<br>$\Rightarrow\lambda_2=-2+2i$<br>ចម្លើយទូទៅគឺ |

| | | |
|---|---|---|
| | គេអាចបាន: $y_1 = e^{\alpha x}\cos\beta x$ និង $y_2 = e^{\alpha x}\sin\beta x$ ជាចម្លើយគោលនៃ$(E)$ ដូចនេះ ចម្លើយទូទៅនៃ$(E)$ គឺ: $y = k_1(A+B)e^{\alpha x}\cos\beta x + k_2(B-A)e^{\alpha x}\sin\beta x$ ឬ $y = Ce^{\alpha x}\cos\beta x + D\sin\beta x$ [ ដែល $C = k_1(A+B), D = k_2(B-A)$ $y = e^{\alpha x}(C\cos\beta x + D\sin\beta x)$ ដែល$C\&D$ ជា ចំនួនថេរ ។ <u>ជាទូទៅ</u> សមីការសំគាល់ $\lambda^2 + b\lambda + c = 0$ នៃ សមីការឌីផេរ៉ង់ស្យែល $y'' + by' + c = 0$ មានរឹស កុំផ្លិច $\lambda_1 = \alpha - i\beta$ និង $\lambda_2 = \alpha + i\beta$ នោះគេបាន សមីការទូទៅនៃសមីការឌី ផេរ៉ង់ស្យែលនេះគឺ $y = e^{\alpha x}(C\cos\beta x + D\sin\beta x)$ ដែល$C\&D$ ជា ចំនួនថេរ ។ ប្រតិបត្តិ: ដោះស្រាយសមីការ $y'' + 4y' + 8y = 0$ តាមលក្ខខណ្ឌដើម $y(0) = 1 \& y'(0) = 2$ ។ | $y = e^{-2x}(C\cos 2x + D\sin 2x)$ តាមលក្ខខណ្ឌដើម $y(0) = 1$: $1 = e^0(C\cos 2x + D\sin 2x)$ $\Rightarrow C = 1$ $y'(0) = 2$: $2 = 2e^{-2x}(C\cos 2x + D\sin 2x)$ $+ e^{-2x}C(-2x\sin 2x) + D(2\cos 2$ $\Rightarrow D = 2$ ដូចនេះ: $y = e^{-2x}(\cos 2x + 2\sin 2x)$ |
| + គ្រូហៅសិស្សឡើងសួររូបមន្តរបស់សមីការឌីផេរ៉ង់ស្យែលលំដាប់2 | ជំហ៊ានទី4 (ពង្រឹងពុទ្ធិ)7នាទី<br>1. សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់2<br>អូម៉ូសែននិងមានមេគុណថេរមានរាងទូទៅយ៉ាង | |

| | | |
|---|---|---|
| | ដូចម្តេច?<br>2. សមីការ $(E)$<br>មានសមីការសំគាល់ $\lambda^2+b\lambda+c=0$ ដែលមានរឹស $\lambda_1 \& \lambda_2$ ។<br>ក. បើសមីការសំគាល់មានរឹសពីរជាចំនួនពិត ផ្សេងគ្នាគឺ $\lambda_1=\alpha$ និង $\lambda_2=\beta$ នោះចម្លើយទូទៅ នៃ $(E)$ មានរាងដូចម្តេច?<br>ខ. បើសមីការសំគាល់មានរឹសឌុប គឺ $\lambda_1=\lambda_2=\alpha$ នោះចម្លើយទូទៅនៃ $(E)$ មានរាង ដូចម្តេច?<br>គ. បើសមីការសំគាល់មានរឹសពីរជាចំនួនកុំផ្លិច គឺ $\lambda_1=\alpha-i\beta$ និង $\lambda_2=\alpha+i\beta$ នោះចម្លើយទូទៅ នៃ $(E)$ មានរាងដូចម្តេច? | + ចំលើយសិស្ស :<br>1. $y''+by'+c=0 \ \ (E)$ ដែល $b\&c$ ជាចំនួនថេរ<br>2.សមីការ $(E)$ មានសមីការសំគាល់ $\lambda^2+b\lambda+c=0$ ដែលមានរឹស $\lambda_1 \& \lambda_2$<br>ក. ដោយ<br>$\lambda_1=\alpha \& \lambda_2=\beta$<br>$\Rightarrow (E): y=Ae^{\alpha x}+Be^{\beta x}$<br>($A\&B$ ជាចំនួនថេរ)<br>ខ. ដោយ<br>$\lambda_1=\alpha$ និង $\lambda_2=\beta$<br>$\Rightarrow (E): y=Axe^{\alpha x}+Be^{\alpha x}$<br>គ. ដោយ<br>$\lambda_1=\alpha-i\beta$ និង $\lambda_2=\alpha+i\beta$<br>$(E): y=e^{\alpha x}(C\cos\beta x+D\sin\beta$<br>$C\&D$ ជាចំនួនថេរ ។ |
| + គ្រូសរសេរកិច្ចការផ្ទះដាក់លើក្តារខៀន | ជំហានទី5 (បណ្តាំផ្ញើរ) 3នាទី<br>1. ដោះស្រាយសមីការ<br>ក. $y''-y=0, y(0)=1, y'(0)=-2$<br>ខ. $y''-2y'+3y=0,$<br>$y(0)=2, y'(0)=1$ | +សិស្សកត់ត្រា លំហាត់ដោយយក ចិត្តទុកដាក់ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)
## ជំពូកទី៥ សមីការឌីផេរ៉ង់ស្យែល
## មេរៀនទី២ សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់ទី២

**I.** វត្ថុបំណង : ក្រោយពីរៀនចប់សិស្សអាច :
- ចេះរកសំគាល់សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2
- ដោះស្រាយសមីការសំគាល់នៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2ដែលមាន សមីការសំគាល់មានឫសពីរជាចំនួនពិតផ្សេងគ្នា

**II.** រយះពេល : 2ម៉ោង ថ្ងៃទី.........ខែ......ឆ្នាំ......

**III.** សំភារ:ឧបទ្ទេស :
- ស.ស ទំព័រទី .... ដល់..... បោះពុម្ពឆ្នាំ2010
- ស.គ ទំព័រទី.....ដល់......
- បន្ទាត់ឈើ

**IV.** សកម្មភាពបង្រៀន :

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូពិនិត្យ អវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និង វិន័យ | ជំហ៊ានទី1 (លំនឹងថ្នាក់) 3នាទី | ប្រធានថ្នាក់ឡើងរាយការណ៍ |
| គ្រូឲ្យសិស្សធ្វើលំហាត់ $Ex$<br><br>គ្រូសួរសិស្សពីនិយមន័យនៃសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2 | ជំហ៊ានទី2 (រំលឹកមេរៀនចាស់)7នាទី<br>$Ex$ ដោះស្រាយសមីការ<br>$y'-4y=0$ ។<br>$y'-4y=0 \Rightarrow \frac{y'}{y}=3$<br>$\Rightarrow \ln\|y\|=3x+c$<br>$\Rightarrow y=Ae^{3x}\left(A=\pm e^{c}\right)$<br>និយមន័យ:<br>សមីការឌីផេរ៉ង់ស្យែលលំដាប់ទី2 អូម៉ូសែន និង មានមេគុណថេរជាសមីការដែល អាចសរសេរជារាង | សិស្សឡើងធ្វើលំហាត់<br><br>សិស្សឆ្លើយ |

| | | |
|---|---|---|
| | ទូទៅ $ay''+by'+c=0$ ដែល<br>$a,b\&c$ ជាចំនួនពិត និង<br>$a\neq 0$ ។ | |
| + គ្រូ សរសេរ មេរៀនថ្មី<br><br>+ គ្រូឲ្យសិស្សមើល $Ex$<br>ទំព័រទី 114<br><br>+គ្រូឲ្យសិស្សពន្លាត<br>$(y'-\alpha y)'-\beta(y'-\alpha y)$ ហើយ<br>ប្រៀបធៀបវាជាមួយ<br>$y''-5y'+6y$<br><br>+គ្រូឲ្យសិស្សរករឹសនៃ<br>សមីការ $\lambda^2-5\lambda+6=0$<br><br>+គ្រូប្រាប់សិស្សពីសមីការ<br>សំគាល់ | ជំហានទី3(មេរៀនថ្មី)70នាទី<br>**សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់**2(**ត**)<br><br>2. **ដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែរលំដាប់**2**អូម៉ូសែន និងមេគុណថេរ**<br>2.1 **ការបង្កើតសមីការសំគាល់**<br>$Ex$ គេមានសមីការឌីផេរ៉ង់ស្យែល $y''-5y'+6y=0$<br>និងសមីការ $y'-\alpha y=0$ ។<br>កំនត់ចំនួនពិត $\alpha\&\beta$<br>ដើម្បីឲ្យ $y$ ។<br>គេបាន:<br>$(y'-\alpha y)'-\beta(y'-\alpha y)$<br>$=y''-\alpha y'-\beta y'+\alpha\beta y$<br>$=y''-(\alpha+\beta)y'+\alpha\beta y$<br>នោះគេបាន:<br>$y''-(\alpha+\beta)y'+\alpha\beta y=y''-5y'$<br>$\Rightarrow \alpha+\beta=5 \quad \& \quad \alpha\beta=6$<br><br>នោះគេបាន $\alpha\&\beta$<br>ជារឹសនៃសមីការ<br>$\lambda^2-5\lambda+6=0$<br>មានរឹសពីរផ្សេងគ្នាគឺ:<br>$\lambda_1=2 \ \& \ \lambda_2=3$<br>ដូចនេះ $\alpha=2,\beta=3$ ឬ<br>$\alpha=3,\beta=2$<br>គេបាន:<br>$y''-5y'+6y=(y'-2y)'-3(y'-$ | + សិស្សពិនិត្យមើលនិង<br>សង្កេត<br><br>+ សិស្សធ្វើតាមការណែនាំ<br><br>+ សិស្សគណនាហើយឆ្លើយ<br>$\lambda^2-5\lambda+6=0$<br>$(\lambda-2)-(\lambda-3)=0$<br>$\Rightarrow \lambda=2\ ,\ \lambda=3$<br><br>+ |

| | | |
|---|---|---|
| | ឬ $y''-5y'+6y=(y'-3y)'-2(y'-3y)$ | សិស្សសង្កេតមើលនិងស្តាប់ |
| +គ្រូសួរ:តើអ្នកណាអាចឲ្យជាទូទៅបាន? | បើយើងតាង $z=y'-3y$ ឬ $z=y'-2y$ នោះយើងបាន:<br>$y''-5y'+6y=z'-3z$<br>ឬ $y''-5y'+6y=z'-2z$ | +សិស្សឆ្លើយ |
| + គ្រូឲ្យសិស្សគណនា $Ex$ | គេអាចបំលែងអង្គទី1 ដែលសមីការឌីផេរ៉ង់ស្យែលលំដាប់2<br>$y''-5y'+6y=0$ គឺ<br>$\lambda^2-5\lambda+6=0$<br>ទៅជាសមីការឌីផេរ៉ង់ស្យែល លំដាប់1 $z'-3z=0$ ឬ $z'-2z=0$ | |
| | +សមីការសំគាល់នៃសមីការឌីផេរ៉ង់ស្យែល<br>$y''-5y'+6y=0$ គឺ<br>$\lambda^2-5\lambda+6=0$ | + សិស្សសរសេរ និង គិតធ្វើលំហាត់ $Ex$ |
| | + ដើម្បីដោះស្រាយសមីការ<br>$y''-5y'+6y=0$<br>ដំបូងដោះស្រាយសមីការ<br>$z'-3z=0$ ឬ $z'-2z=0$<br>រួចយើងបានសមីការ<br>$y'-3y=z$ ឬ $y'-2y=z$ | +សិស្សឡើងធ្វើ |
| +គ្រូសរសេរចំនងជើងថ្មី | ជាទូទៅ:<br>+<br>សមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2<br>$y''+by'+cy=0$<br>គេអាចសរសេរជាសមីការ<br>$(y'-\alpha y)'-\beta(y'-\alpha y)=0$<br>ដែល $\alpha\ \&\ \beta$<br>ជាឫសរបស់សមីការសំគាល់<br>$\lambda^2+b\lambda+c=0\ (\lambda=\mathbb{C})$ | +សិស្សសរសេរចំណងជើង |

| | | |
|---|---|---|
| +មើល $Ex$ ទំព័រ 115<br><br>+សរសេរសមីការសំគាល់ និង ដោះស្រាយសមីការ<br><br>+បំលែងសមីការនេះទៅជា ទំរង់<br>$(y'-\alpha y)'-\beta(y'+\alpha y)=0$<br>តាង $z=y'+\alpha y$ និង ដោះស្រាយសមីការ<br>$z'-\beta z=0$<br><br>+ ជំហ៊ានបន្ទាប់ដោះស្រាយសមីការ<br>$y'+4y=c_1e^{2x}$<br>ហើយយើង រកចម្លើយនៃសមីការ<br>$y'+4y=0$ | + សមីការសំគាល់<br>$\lambda^2+b\lambda+c=0$ នៃសមីការឌីផេរ៉ង់ស្យែល<br>$y''+by'+cy=0$<br>អាចមានរឹសឌុប ឬ មានរឹស2ជាចំនួនកុំផ្លិច។<br>$Ex$ សរសេរ និង រករឹសនៃសមីការសំគាល់នៃសមីការឌីផេរ៉ង់ស្យែលលំដាប់2ខាងក្រោម:<br>ក. $y''+y'-6y=0$<br>ខ. $y''+4y'+4y=0$<br>គ. $y''-2y'+5y=0$<br>ចម្លើយ<br>ក. $y''+y'-6y=0$<br>មានសមីការសំគាល់<br>$\lambda^2+\lambda-6=0$<br>មានរឹស $1,-3$<br>ខ. $y''+4y'+4y=0$<br>មានសមីការសំគាល់<br>$\lambda^2+4\lambda+4=0$<br>មានរឹស $\lambda=-2$<br>គ. $y''-2y'+5y=0$<br>មានសមីការសំគាល់<br>$\lambda^2-2\lambda+5=0$<br>$\Delta'=1-5=-4=(2i)^2$<br>$\lambda=1\pm 2i$<br>មានរឹសពីរជាចំនួនកុំផ្លិចគឺ<br>$\lambda=1-2i$ និង $\lambda=1+2i$ ។<br>**2.2 វិធីដោះស្រាយសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែលំដាប់ទី2**<br>**ក. ករណីដែលសមីការសំគាល់មានរឹសពីរ ជា** | +សិស្សមើលសៀវភៅទំព័រ115<br><br>+សិស្សរករឹសសមីការសំគាល់<br><br>+សិស្សសរសេរបំលែងសមីការ និង ដោះស្រាយសមីការ<br>$z'-\beta z=0$<br><br>+ សិស្សពិនិត្យ និង សង្កេត |

| | | |
|---|---|---|
| | **ចំនួនពិតផ្សេងគ្នា** | |
| + គ្រូឲ្យលក្ខណៈទូទៅ | $Ex$ គេមានសមីការឌីផេរ៉ង់ស្យែលលីនេអ៊ែ លំដាប់ទី2<br>$y''+2y'-8y=0 \ (E)$<br>មានសមីការសំគាល់<br>$\lambda^2+2\lambda-8=0$ | +សិស្សស្តាប់ និង កត់ត្រា |
| | ដោយ $\Delta'=1-(-8)=9$<br>សមីការសំគាល់មានរឹសពីរជាចំនួនពិតផ្សេងគ្នា គឺ $-4$ & $2$ ។ | +សិស្សមើល និង កត់ត្រា |
| + គ្រូឲ្យ $Ex$ មួយទៀត | សមីការ<br>$y''+2y'-8y=0 \ (E)$<br>អាចសរសេរជា:<br>$(y'+4y)'-2(y'+4y)=0$<br>តាង $z=y'+4y$ | |
| | នោះគេបាន<br>$z'-2z=0$<br>$\Rightarrow z'=2z \Leftrightarrow \frac{dz}{dx}=2z$<br>$\Leftrightarrow \frac{dz}{z}=2dx \Rightarrow \ln\lvert z\rvert=2x+c$<br>$\Rightarrow \lvert z\rvert=e^{2x+c}$<br>$\Rightarrow z=c_1e^{2x} \ (c_1=e^c)$<br>ដោយ $z=y'+4y$<br>នោះគេបាន<br>$y'+4y=c_1e^{2x}$<br>+ ដោះស្រាយសមីការ<br>$y'+4y=c_1e^{2x} \ (*)$<br>រកដោយដោះស្រាយសមីការ $y'+4y=0$ មុន<br>$\Rightarrow y'=-4y \Leftrightarrow \frac{dy}{dx}=-4y \Leftrightarrow \frac{dy}{y}$<br>$\Rightarrow \ln\lvert y\rvert=-4x+c \Rightarrow y=c_2e^{-4x}$ (<br>គេឲ្យ $c_2$ ជាអនុគមន៍នៃ $x$ | +សិស្សសង្កេត និង កត់ត្រា |

គេបាន

$y = c_2(x)e^{-4x}$

$\Rightarrow y' = c_2'(x)e^{-4x} - 4c_2(x)e^{-4x}$

ជំនួសក្នុង$(*)$ គេបាន:

$\left[c_2'(x)e^{-4x} - 4c_2(x)e^{-4x}\right]$

$+4c_2(x)e^{-4x} = c_1e^{2x}$

$\Rightarrow c_2'(x)e^{-4x} = c_1e^{2x}$

$\Rightarrow c_2'(x) = c_1e^{6x}$

$\Rightarrow c_2(x) = \int c_1e^{6x}dx$

$= \frac{1}{6}c_1e^{6x} + A$

$= Be^{6x} + A \quad \left(B = \frac{1}{6}c_1\right)$

ដូចនេះ

$y = \left(Be^{6x} + A\right)e^{-4x}$

$y = Ae^{-4x} + Be^{2x}$

គេបានចំលើយទូទៅនៃសមីការឌីផេរ៉ង់ស្យែល

$y'' + 2y' - 8y = 0 \ (E)$ គឺ

$y = Ae^{-4x} + Be^{2x}$ ដែល

$A \& B$ ជាចំនួនថេរណាមួយក៏បាន ។

ជាទូទៅ:

+ រកសមីការសំគាល់ $\lambda^2 + b\lambda + c = 0$ នៃ សមីការឌីផេរ៉ង់ស្យែល $y'' + by' + cy = 0$

+ បើសមីការសំគាល់មានរឹសពីរជាចំនួនពិត ផ្សេងគ្នា $\lambda_1 = \alpha \quad \& \quad \lambda_2 = \beta$ នោះសមីការ $y'' + by' + cy = 0$ មានចម្លើយទូទៅ $y = Ae^{\alpha x} + Be^{\beta x}$ ដែល $A \& B$ ជាចំនួនពិតណា

| | | |
|---|---|---|
| | មួយក៏បាន $y_1 = e^{\alpha x}, y_2 = e^{\beta x}$ ជាចម្លើយគោល ។ $Ex$ ដោះស្រាយសមីការឌីផេរ៉ង់ស្សែលលំដាប់2 $y''+3y'+2y=0$ ។ មានសមីការសំគាល់ $\lambda^2+3\lambda+2=0$ មានរឹស $\lambda_1=-1$ & $\lambda_2=-2$ គេបានចម្លើយទូទៅនៃសមីការ $y''+3y'+2y=0$ គឺ $y=Ae^{-x}+Be^{-2x}$ (ដែល $A,B$ ថេរ) | |
| + គ្រូឲ្យសិស្សធ្វើលំហាត់ | ជំហ៊ានទី4 (ពង្រឹងពុទ្ធិ)7នាទី លំហាត់: ដោះស្រាយសមីការឌីផេរ៉ង់ស្សែល $y''-3y'+y=0$ ចម្លើយ $y''-3y'+y=0$ មានសមីការសំគាល់ $\lambda^2-3\lambda+1=0$ $\Delta'=9-4.1.1=5$ $\Rightarrow \lambda_1=\frac{3-\sqrt{5}}{2}, \lambda_2=\frac{3+\sqrt{5}}{2}$ ចម្លើយទូទៅនៃសមីការ $y''-3y'+y=0$ គឺ $y=Ae^{\left(\frac{3-\sqrt{5}}{2}\right)x}+Be^{\left(\frac{3+\sqrt{5}}{2}\right)x}$ ដែល $A,B$ ជាចំនួនថេរ | +សិស្សឡើងធ្វើលំហាត់ |
| + គ្រូសរសេរកិច្ចការផ្ទះដាក់លើក្តារខៀន | ជំហ៊ានទី5 (បណ្តាំផ្ញើរ) 3នាទី ដោះស្រាយសមីការ ក. $4y''+7y'+2y=0$ ខ. $y''-2y'=0$ គ. $y''-3y'+3y=0$ | +សិស្សកត់ត្រា លំហាត់ដោយយក ចិត្តទុកដាក់ |

| | | |
|---|---|---|
| | ឃ. $2y''+3y'-2y=0$<br>ង. $y''-3y'+y=0$ | |

# កិច្ចតែងការបង្រៀនគណិតវិទ្យាទី១២

## ១. ជំពូកទី៦ បំណែងចែកប្រូបាប

## ២. មេរៀនទី១ បំណែងចែកប្រូបាប

## ៣. រយៈពេល: ២ម៉ោងសិក្សា

## ៤. វត្ថុបំណង: ក្រោយពេលបង្រៀនមេរៀននេះចប់សិស្សអាចៈ

- ចំណេះដឹង: សិស្សបកស្រាយខ្លឹមសារ អថេរចៃដន្យ បំណែងចែកប្រូបាប និង អនុគមន៍ដង់ស៊ីតេបានត្រឹមត្រូវតាមរយៈការបង្ហាញរបស់គ្រូ។
- បំនិន: សិស្សដោះស្រាយលំហាត់បានត្រឹមត្រូវ តាមរយៈការពិភាក្សាជាក្រុម និងជាបុគ្គលក្រោមការដឹងនាំរបស់គ្រូ។
- ឥរិយាបថ: បណ្ដុះទឹកចិត្តសិស្សឱ្យចូលចិត្តការគិត

## ៥. សកម្មភាពបង្រៀន និងរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| •ពិនិត្យអនាម័យ សណ្ដាប់ធ្នាប់ អវត្តមាន<br>•តើប្រូបាបនៃព្រឹត្តការណ៍A មានតម្លៃដូចម្ដេច?<br>•តើករណីអាចជាអ្វី?<br><br><br><br><br>១.អថេរចៃដន្យនិងបំណែងចែកប្រូបាប<br>១.១ អថេរចៃដន្យ:<br>ផ្ដល់និយមន័យ | <u>ជំហានទី១</u><br>•បានត្រឹមត្រូវ<br><u>ជំហានទី២</u><br>•ជាផលធៀបរវាងចំនួនករណីស្របនៃព្រឹត្តិការណ៍Aនិង ករណីអាចៈ<br>$P(A)=\frac{n(A)}{n(S)}$<br>•ករណីអាចគឺជាករណីសរុបនៃព្រឹត្តិការណ៍ឬលំហរ<br><u>ជំហានទី៣</u><br>មេរៀនទី១ បំណែងចែកប្រូបាប<br>១.អថេរចៃដន្យ និង បំណែងចែកប្រូបាប<br>និយមន័យ: អថេរចៃដន្យគឺជាអថេរដែលភ្ជាប់ចំនួនទៅនឹងធាតុនីមួយៗនៃលំហរសំណាកហើយមានផលបូកប្រូបាបស្មើ 1។<br><u>ចម្លើយ</u><br>លទ្ធផលដែលបោះកាក់ពីរដងគឺ: | • ប្រធានថ្នាក់រាយការណ៍ អង្គុយស្ងៀមស្ងាត់<br>• ឆ្លើយ<br><br>• ឆ្លើយ<br><br><br><br><br><br><br><br>• ស្ដាប់ដោយយកចិត្ត ទុកដាក់<br><br><br><br>• តាមដានស្ដាប់ដោយយក |

Ex: គេបោះកាក់មួយដែលមានមុខH និងTចំនួនពីរដង, តាង $x$ ជាចំនួនមុខHដែលចេញលទ្ធផល។ចូរបង្កើតតាង អថេរ $x$?

* បញ្ជាក់:

$P(TT)+P(TH)+P(HH)$

$=0.25+0.25+0.25+0.25$

$=1$

១.២ បំណែងចែកប្រូបាប

ផ្តល់និយមន័យ និងឧទាហរណ៍ដើម្បីបកស្រាយ

$Ex_1$: ចូរធ្វើតារាងបំណែងចែកនៃ $X$ នៃការបោះកាក់មុខH និងT ចំនួនពីរដង។

ប្រតិបត្តិ: គេបោះគ្រាប់ឡុកឡាក់ 3 ព្រមគ្នា។ តាង $X$ ជាចំនួនលេខ3 ដែលចេញក្នុងលទ្ធផល។ គណនា $P(X=x)$ រួចធ្វើតារាង បំណែងចែកប្រូបាបនៃអថេរ $X$ ។

$TT, TH, HT, HH$ ។

| លទ្ធផលបោះកាក់2ដង | TH | TH | HT | HH |
|---|---|---|---|---|
| តម្លៃ $x$ | 0 | 1 | 1 | 2 |

និយមន័យ: ប្រូបាប $P(X=x)$ ដែលភ្ជាប់ទៅនឹងតម្លៃនីមួយៗនៃអថេរចៃដន្យ $X$ ។

<u>ចម្លើយ</u>

$X$ ជាអថេរចៃដន្យដែលកាក់ចេញមុខ H នោះ $X=0,1,2$ ដែល

$P(X=0)=0.25$

$P(X=1)=0.5$

$P(X=2)=0.5$

| តម្លៃ $X$ | 0 | 1 | 2 |
|---|---|---|---|
| $P(x)$ | 0.25 | 0.5 | 0.5 |

<u>ចម្លើយ</u>

$$P(X=0)=\frac{125}{216}$$

$$P(X=1)=\frac{75}{216}$$

$$P(X=2)=\frac{15}{216}$$

$$P(X=3)=\frac{1}{216}$$

ចិត្តទុកដាក់

- តាមដានសង្កេត ស្តាប់សួរព្រមទាំង កត់ត្រា។

- ពិភាក្សាដោះស្រាយ លទ្ធផលបោះកាក់មាន $aaa, 3aa, a3a, aa3,$ $33a, 3a3, a33, 333$

$X=0,1,2,3$

$p(X=0)=\frac{5}{6}\times\frac{5}{6}\times\frac{5}{6}=\frac{125}{216}$

$P(X=1)=3\left(\frac{1}{6}\times\frac{5}{6}\times\frac{5}{6}\right)=\frac{75}{216}$

$P(X=2)=3\left(\frac{1}{6}\times\frac{1}{6}\times\frac{5}{6}\right)=\frac{15}{216}$

$P(X=3)=\frac{1}{6}\times\frac{1}{6}\times\frac{1}{6}=\frac{1}{216}$

<table>
<tr>
<td></td>
<td></td>
<td>តារាងបំណែងចែក<br>ប្រូបាប:
<table>
<tr><td>$x$</td><td>0</td><td>1</td><td>2</td><td>3</td></tr>
<tr><td>$P(X$</td><td>$\frac{125}{216}$</td><td>$\frac{75}{216}$</td><td>$\frac{15}{216}$</td><td>$\frac{1}{216}$</td></tr>
</table>
</td>
</tr>
<tr>
<td>១.៣អនុគមន៍ដង់ស៊ីតេប្រូបាប<br><br>ឧទាហរណ៍:<br>តាង $X$ ជាផលបូកលទ្ធផលនៃការបោះគ្រាប់ឡុកឡាក់ពីរគ្រាប់ៗរកប្រូបាបនៃលទ្ធផលនីមួយ:</td>
<td>និយមន័យ: អនុគមន៍ដែលអាចគណនាតម្លៃប្រូបាប $P(X=x)$ ចំពោះគ្រប់តម្លៃទាំងអស់ហៅថាអនុដង់ស៊ីតេប្រូបាប។<br>$X=2,3,4,5,6,7,8,9,10,11,12$<br>$P(X=x)=\frac{1}{36},\frac{2}{36},\frac{3}{36},\frac{4}{36},\frac{5}{36},$<br>$\frac{6}{36},\frac{5}{36},\frac{4}{36},\frac{3}{36},\frac{1}{36}$<br>រឺ $P(X=x)=\frac{x-1}{36}, X=2,3,....7$<br>$P(X=x)=\frac{13-x}{36}, x=8,9....,12$<br>ហៅថាអនុគមន៍ដង់ស៊ីតេប្រូបាបនៃអថេរ $x$ ។</td>
<td>• តាមដានសង្កេតស្តាប់និងសួរ<br><br>• តាមដានសង្កេតស្តាប់ដោយយកចិត្តទុកដាក់</td>
</tr>
<tr>
<td>ប្រតិបត្តិ:គេឱ្យអនុគមន៍ដង់ស៊ីតេប្រូបាប $P(Y=y)=cy^2$ ដែលតម្លៃ<br>$y=0,1,2,3,4$<br>ក.គណនា $P(Y=y)$<br>ខ.គណនា $c$</td>
<td>ក. $P(Y=y)=0,C,4C,9C,16C$<br>ចំពោះ $y=0,1,2,3,4$ ។<br>ខ.គណនា C ដោយ<br>$P(Y=y)=1$<br>$30C=1$<br>$\Rightarrow C=\frac{1}{30}$</td>
<td><u>ចម្លើយ</u> (ពិភាក្សា)<br>ក.គណនា $P(Y=y)$<br>$P(y=0)=0$<br>$P(y=1)=C$<br>$P(y=2)=4C$<br>$P(y=3)=9C$<br>$P(y=4)=16C$<br>ខ.គណនា C<br>ដោយ<br>$P(0)+P(1)+P(2)+P(3)+$<br>$P(4)=1$<br>$30C=1 \Rightarrow C=\frac{1}{30}$</td>
</tr>
</table>

| | | |
|---|---|---|
| ១.ដូចម្តេចដែលហៅថាអថេរចៃដន្យ?<br>២.ដូចម្តេចដែលហៅថាអនុគមន៍ដង់ស៊ីតេ ? | <u>ជំហានទី៤</u><br>១.និយមន័យ: (១.១)<br>២.និយមន័យ (១.៣)<br><u>ជំហានទី៥</u><br>បណ្តាំផ្ញើរ | • ឆ្លើយ |

# កិច្ចតែងការបង្រៀនថ្នាក់ទី១២

## ១. ជំពូកទី ៦

## ២. មេរៀនទី១ បំណែងចែកប្រូបាប

## ៣. រយៈពេល: ២ ម៉ោងសិក្សា

## ៤. វត្ថុបំណង:

- ចំណេះដឹង: ពណ៌នាពីសង្ឃឹមគណិតនៃអថេរចៃដន្យ $X$ និងវ៉ារ្យង់នៃអថេរចៃដន្យ $X$ បានត្រឹមត្រូវតាមរយៈការបង្ហាញរបស់គ្រូ។
- បំនិន: ដោះស្រាយលំហាត់បានយ៉ាងស្ទាត់តាមរយៈការពិភាក្សាជាក្រុមនិងបុគ្គល។
- ឥរិយាបថ: បណ្តុះទឹកចិត្តឱ្យមានសកម្មភាពពិភាក្សានិងមានការប្រុងប្រយ័ត្ន លើការដោះស្រាយ ។

## ៥. សកម្មភាពបង្រៀន និងរៀន

<table>
<tr><th>សកម្មភាពគ្រូ</th><th>ខ្លឹមសារមេរៀន</th><th>សកម្មភាពសិស្ស</th></tr>
<tr><td>• ពិនិត្យសណ្តាប់ធ្នាប់ អនាម័យ អវត្តមាន</td><td><u>ជំហានទី១</u><br>• បានត្រឹមត្រូវ</td><td>• ប្រធានរាយការណ៍</td></tr>
<tr><td>• ដូចម្តេចដែលហៅថាអថេរចៃដន្យ?<br>• ដូចម្តេចដែលហៅថាបំណែងចែកប្រូបាប?</td><td><u>ជំហានទី២</u><br>• ជាអថេរដែលភ្ជាប់ចំនួនទៅនឹងធាតុនីមួយៗក្នុងលំហរដែលមានផលបូកប្រូបាបាស្មើ 1។<br>$P(X=x)$ ដែលភ្ជាប់ទៅនឹងអថេរចៃដន្យ $x$ ។</td><td>• ឆ្លើយយ៉ាងយកចិត្តទុកដាក់</td></tr>
<tr><td>• ផ្តល់រូបមន្តតម្លៃមធ្យមតាមពិសោធ<br>• ផ្តល់ឧទាហរណ៍: គណនាតម្លៃមធ្យម $\overline{X}$ តាមតារាង:<br><table><tr><td>X</td><td>1</td><td>2</td><td>3</td><td>4</td><td>4</td><td>6</td></tr><tr><td>f</td><td>15</td><td>22</td><td>23</td><td>19</td><td>23</td><td>18</td></tr></table></td><td><u>ជំហានទី៣</u><br>២.សង្ឃឹមគណិតនៃអថេរ $X$<br>២.១.តម្លៃមធ្យមតាមពិសោធ<br>$\overline{X}=\frac{\sum fX}{\sum f}$<br>• គណិតតម្លៃមធ្យម<br>$\overline{X}=\frac{\sum fX}{\sum f}$</td><td>• តាមដានសង្កេតមើលនិងស្តាប់យ៉ាងយកចិត្តទុកដាក់</td></tr>
</table>

• ឱ្យនិយមន័យនិងរូបមន្ត សង្ឃឹមគណិត

$Ex$: ឆ្នាំនេះផ្ទះឡើងថ្លៃ $20\%$ ស្មើ $0.3$ តម្លៃផ្ទះនឹង $10\%$ ស្មើ $0.5$ តម្លៃផ្ទះចុះថោក $10\%$ ស្មើ $0.1$ ។ តើអ្នកសង្ឃឹមថាផ្ទះឡើងថ្លៃ $\%$ ?

• ផ្តល់រូបមន្ត:

• ឧទាហរណ៍:

| $x$ | 1 | 2 | 3 |
|---|---|---|---|
| $P(X=x)$ | 0.1 | 0.6 | 0.3 |

$$=\frac{15+44+69+115+108}{120}$$
$$=3.558$$

២.២. តម្លៃមធ្យមតាមទ្រឹស្តីបទ ជាបំណែងចែកប្រូបាបហើយ តម្លៃមធម្យមជាតម្លៃសង្ឃឹមទុក ហៅថា សង្ឃឹមគណិត។

និយមន័យ:សង្ឃឹមគណិត នៃអថេរ $X$ កំណត់ដោយ

$$E(X)=\sum X_iP_i \quad i=1,2,3$$

តាមរូបមន្ត:

$$E(x)=\sum x_ip_i$$
$$=\frac{20}{100}\times0.3+\frac{10}{100}\times0.5-\frac{10}{100}\times0.1$$
$$=10\%$$

២.៣.សង្ឃឹមគណិតនៃអនុគមន៍ នៃអថេរចៃដន្យ $X$

$$E(x)=\sum\left[f(x)\times P(X=x)\right]$$

ចម្លើយ: គណនា $E(5x)$

តាមរូបមន្ត:

$$E(5x)=\sum\left[5x\left(P(X=x)\right)\right]$$
$$=5\times2P(X=2)+5\times2P(X=2)$$
$$+5\times3P(X=3)=11$$

៣.វ៉ារ្យង់នៃអថេរ $X$

៣.១.និយមន័យ

•តាមដានសង្កេត

តាង $X$ ជាអថេរ (តម្លៃផ្ទះនឹងឡើងថ្លៃជា $\%$) យើងបានតារាង

| X | $20\%$ | $10\%$ | $-10\%$ |
|---|---|---|---|
| $P(X=x)$ | 0.3 | 0.5 | 0.1 |

តាម $E(x)=\sum x_ip_i$

$$=\frac{20}{100}\times0.3+\frac{10}{100}\times0.5$$
$$-\frac{10}{100}\times0.1$$
$$=10\%$$

•តាមដានមើលស្តាប់ សួរ កត់ត្រា

• ផ្តល់និយមន័យ

$Ex$: គេឱ្យបំណែងនៃ

អថេរចៃដន្យ $X$

| $x$ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| $P(X=x)$ | 0.1 | 0.3 | 0.2 | 0.3 | 0.1 |

ក/.គណនា $Var(x)$

ខ/.គណនាគម្លាតស្តង់ដា

•ផ្តល់លក្ខណៈនៃវ៉ារ្យង់

១.$Var=0$

២.$Var(ax)=a^2Var(x)$

៣.$Var(ax+b)=a^2Var(x)$

•ចូរប្រើរូបមន្ត $Var(x)$

$Var=E(X-\mu)^2$ ដែល

$\mu=E(x)$ គេបាន

$\sigma=\sqrt{Var(x)}$ ហៅថា

គម្លាតស្តង់ដា

រឺ $Var(x)=E(x^2)-E^2(x)$

$Var(x)=E(x-\mu)^2$

$=E(x^2)-E^2(x)$

$=1.4$

$\sigma=\sqrt{1.4} \quad =1.2$

៣.២ លក្ខណៈនៃវ៉ារ្យង់

សម្រាយបញ្ជាក់

១. $Var(a)=0$

យើងមាន

$Var(a)=E(a^2)-E^2(a)$

$=a^2-[E(a)]^2$

$=a^2-a^2$

$=0$

<u>ជំហានទី៤</u>

មានពីរគឺ

១. សង្ឃឹមគណិតនៃអថេរ $X$

$E(x)=\sum X[P(X=x)]$

២. សង្ឃឹមគណិតនៃអនុគមន៍

អថេរ $X$

$E(f(x))=\sum[f(x).(P(X=x))]$

$Var(x)=E(X-\mu)^2$

$=E(x^2)-E^2(x)$

<u>ជំហានទី៥</u>

បណ្តាំផ្ញើរ

•តាមដានសង្កេតនិងស្តាប់

ព្រមទាំងមានសំណួរនិង

កត់ត្រា ។

•រក $\mu=E(x)$

$=\sum x.P(X=x)$

$=3$

$\Rightarrow \; Var=E(x-3)^2$

$=\sum(x-3)^2\times P(X=x)$

$=4\times0.1+1\times0.3+0\times0.2$

$+4\times0.1=1.4$

ខ/.គណនា $\sigma$

តាម $\sigma=\sqrt{Var(x)}$

$=\sqrt{1.4}=1.2$

•តាមដានស្តាប់សង្កេត

•ធ្វើការបកស្រាយលើ

លក្ខណៈ (២ និង៣) ។

•ឆ្លើយ

•ឆ្លើយ

# កិច្ចតែងការបង្រៀន

## - មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)
## - ជំពូកទី៦ : បំណែងចែកប្រូបាប
## - មេរៀនទី២ : បំណែងចែកទ្វេធា

**I.វត្ថុបំណងនៃមេរៀន**

**-ចំណេះដឹង** : សិស្សកំណត់និយមន័យនៃការពិសោធទ្វេធាបានត្រឹមត្រូវតាមរយៈឧទាហរណ៍។

**-បំណិន** : សិស្សគណនាប្រូបាបនៃអថេរទ្វេធាx នៃបំណែងចែកទ្វេធា សង្ឃឹមគណិត និងវ៉ារ្យង់នៃអថេរx តាមរយៈឧទាហរណ៍បានត្រឹមត្រូវ។

**-ឥរិយាបថ** : សិស្សសហការគ្នាដោះស្រាយលំហាត់ដោយស្មារតីប្រុងប្រយ័ត្នខ្ពស់។

**II. ខ្លឹមសារមេរៀន** : ពេលវេលា: ...២...ម៉ោង ថ្ងៃ........ទី...ខែ...............ឆ្នាំ..........

១. បំណែងចែកទ្វេធា

១.១ ការពិសោធទ្វេធា

១.២ ច្បាប់ទ្វេធានៃប្រូបាប

២. សង្ឃឹមគណិតនិងវ៉ារ្យង់នៃអថេរចៃដន្យx

**III.សម្ភារៈឧទេស**

-ស . ស :ទំព័រទី១៥០ ដល់ទំព័រទី១៥៤

-ស . គ : ទំព័រទី១៥០ ដល់ទំព័រទី១៥៤

- សន្លឹកកម្រង់លំហាត់ប្រត្តិបត្តិ និងកម្រងសំណួរតម្រង់ទិសការសង្កេត

**IV.ដំណើកនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ដាក់លំហាត់ឱ្យសិស្សធ្វើលើក្តារខៀន | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី)<br>-គណនា$c(5\,,3)$,$c(8\,,8)$ $c(7,0)$ | -គណនា $c(5\,,3)$ |

| | | |
|---|---|---|
| -គេមានតារាងទិន្នន័យ | | តាមរូបមន្ត $c(n,r)=\frac{n!}{r!(n-r)!}$<br>$c(5,3)=\frac{5!}{3!(5-3)!}$<br>$=\frac{4\times5}{2}=10$<br>$c(8,8)=\frac{8!}{8!(8-8)!}=\frac{8!}{8!0!}$<br>$=1$<br>$c(7,0)=\frac{7!}{0!(7-0)!}=1$<br>$c(6,3)=\frac{6!}{3!(6-3)!}=\frac{6!}{3!3!}$<br>$=\frac{6\times5\times4}{3\times2\times1}=20$ |
| -ដាក់ឧទាហរណ៍ ណែនាំសិស្សសង្កេតលទ្ធផលនៃការបោះកាក់មួយ<br><br>-បញ្ជាក់ប្រាប់សិស្ស<br><br>-ឱ្យសិស្សទាញរកនិយមន័យនៃការពិសោធន៍ទ្វេធា | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី២:**<br>**បំណែងចែកទ្វេធា**<br>**១. បំណែងចែកទ្វេធា**<br>**១.១ ការពិសោធទ្វេធា**<br>-ឧទាហរណ៍ ក្នុងការពិសោធន៍បោះកាក់មួយដែលមានមុខ $H$ និង $T$ លទ្ធផលមានពីរយ៉ាងគត់គឺ ចេញមុខ $H$ ឬចេញមុខ $T$<br>បើគេបោះបានមុខ $H$ ដូចបំណង គេថាពិសោធន៍នេះបានជោគជ័យ ហើយបើផ្ទុយមកវិញគឺបរាជ័យ។<br>-និយមន័យ ការពិសោទ្វេធាគឺជាការពិសាធន៍ដែលមានលក្ខណៈ:<br>១. ការពិសាធន៍ n វិញ្ញាសាដូចគ្នា | -សង្កេត<br><br>-និយមន័យ ការពិសោទ្វេធាគឺជាការពិសាធន៍ដែលមានលក្ខណៈ: |

| | | |
|---|---|---|
| | ហើយវិញ្ញាសានីមួយៗមិនទាក់ទងគ្នា<br>២. វិញ្ញាសានីមួយៗមានលទ្ធផលមួយក្នុងចំនោម"ជោគជ័យ"ឬ "បរាជ័យ"។<br>៣. ប្រូបាប p នៃ"ជោគជ័យ"រក្សាតម្លៃថេរចំពោះគ្រប់វិញ្ញាសា ហើយប្រូបាបនៃ"បរាជ័យ"គឺ $q = 1 - p$<br>៤.អថេរចៃដន្យទ្វេធាx គឺជាចំនួនដងនៃ "ជោគជ័យ" ក្នុង n វិញ្ញាសានៃការពិសោធន៍។<br>៥. បំណែងចែកទ្វេធាគឺជាបំណែងចែកប្រូបាបនៃអថេរចៃដន្យទ្វេធាx។ | ១. ការពិសោធន៍n វិញ្ញាសាដូចគ្នា ហើយវិញ្ញាសានីមួយៗមិនទាក់ទងគ្នា<br>២. វិញ្ញាសានីមួយៗមានលទ្ធផលមួយក្នុងចំនោម "ជោគជ័យ "ឬ "បរាជ័យ"។<br>៣. ប្រូបាប p នៃ"ជោគជ័យ"រក្សាតម្លៃថេរចំពោះគ្រប់វិញ្ញាសា ហើយប្រូបាបនៃ"បរាជ័យ"គឺ - $q = 1 - p$<br>៤.អថេរចៃដន្យទ្វេធាx គឺជាចំនួនដង នៃ "ជោគជ័យ" ក្នុង n វិញ្ញាសានៃការ ពិសោធន៍។<br>៥.បំណែងចែកទ្វេធាគឺជាបំណែងចែកប្រូបាបនៃអថេរចៃដន្យទ្វេធាx។ |
| -ដាក់ឧទាហរណ៍ណែនាំសិស្សគណនា<br><br>-បើការចេញមុខ $H$ "ជោគជ័យ" គេបាន $p(H) = ?$<br>$p(T) = ?$ | ១.២ ច្បាប់ទ្វេធានៃប្រូបាប<br>ឧទាហរណ៍ គេបោះកាក់មួយដែលមិនស្មើសាច់ល្អ កាក់មុខពីរគឺ H និងT ប្រូបាបដែលនិងចេញបានH ស្មើនឹង $\frac{2}{3}$ បើគេបោះកាក់នោះ ៤ដង។ ចូរគណនាប្រូបាបដែលនិងចេញមុខ H ចំនួនពីរដង<br>ចម្លើយ<br>ការចេញមុខ H "ជោគជ័យ" | |

| | | |
|---|---|---|
| -តើប្រូបាបចេញមុខ $H$ ២ដងនិ $T$ ២ដងតាមលំដាប់ស្មើនឹងប៉ុន្មាន?<br><br>-តើការចេញមុខ $H$ ២ដងនិង $T$ ២ដងអាចមានប៉ុន្មានករណី? អ្វីខ្លះ?<br><br>-ចំនួនករណីនេះជាចំនួនបន្សំនៃប៉ន្មាន? អ្វីខ្លះ?<br>-តើករណីនីមួយៗមានប្រូបាបស្មើគ្នាឬទេ?<br>-តើគេបាន $P$ (ចេញមុខ $H$ ២ដង)=?<br><br>-ឱ្យសិស្សទាញជាទូទៅ | គេបាន ៖ $P(H)=\frac{2}{3}$<br>$\Rightarrow P(T)=1-\frac{2}{3}=\frac{1}{3}$<br>ប្រូបាបចេញមុខ $H$ ២ដង និង $T$ ២ដង<br>តាមលំដាប់ស្មើនឹង<br>$P(HHTT)=\left(\frac{2}{3}\right)^2\times\left(\frac{1}{3}\right)^2$<br>(ព្រឹត្តិការណ៍តាមលំដាប់មិនទាក់ទងគ្នា)<br>ប៉ុន្តែការចេញមុខ $H$ ២ដងនិង $T$ ២ដង អាចមាន ៦ករណី<br>$(HHTT),(HTTH),(TTHH),$<br>$(THTH),(HTHT),(THHT)$<br>ចំនួនករណីនេះគឺជាចំនួនបន្សំ<br>$C(4,2)=\frac{4!}{2!(4-2)!}=6$ ករណី<br>ដោយករណីនីមួយៗមានប្រូបាបស្មើគ្នា<br>គេបាន $P$ (ចេញមុខ $H$ ២ដង)<br>$=C(4,2)=\left(\frac{2}{3}\right)^2\times\left(\frac{1}{3}\right)^2$<br>$=6\times\left(\frac{2}{3}\right)^2\times\left(\frac{1}{3}\right)^2=\frac{8}{27}$<br>ដូចនេះ ប្រូបាបដែលនឹងចេញមុខ $H$ ២ដងពេលគេបោះកាក់មួយចំនួន ៤ដងស្មើនឹង $\frac{8}{27}$<br>-ជាទូទៅ ក្នុងការពិសោធន៍ទ្វេធាដែលមាន $n$ វិញ្ញាសា បើប្រូបាបដែលបានជោគជ័យស្មើនឹង $P$ បរូបាបដែលបរាជ័យស្មើនឹង $q$ $q=1-p$ និង $x$ ជាអថេរចៃដន្យទ្វេធា | |

| | | |
|---|---|---|
| -ដាក់លំហាត់គំរូ<br><br>-ចែកក្រដាសលំហាត់ប្រត្តិបត្តិ<br><br>-បង្ហាញពីច្បាប់ទ្វេធានៃប្រូបាប | នោះអនុគមន៍ដង់ស៊ីតេប្រូបាប<br>នៃអថេរ $x$ កំណត់ដោយ<br>$P\left(X=x\right)=C\left(n,x\right)p^{x}\times\left(1-p\right)^{n-x}$<br>ដែល $x=0\ ,1\ ,\ 2,3.......,n$<br>បើ $x$ អថេរចៃដន្យទ្វេធានោះគេអាច<br>សរសេរ $X\ -Bin\left(n,p\right)$<br>ដែល $n,\ p$ ជាប៉ារ៉ាម៉ែតនៃបំណែង<br>ចែក។<br>លំហាត់គំរូ បើ $x$ ជាអថេរនៃ<br>$Bin\left(n,0.6\right)$ ហើយ $P\left(X\prec 1\right)=0.0256$<br>គណនាតម្លៃ $n$<br>ចម្លើយ<br>គណនាតម្លៃ $n$<br>តាមសម្មតិកម្ម $X-Bin\left(n,0.6\right)$<br>ហើយ<br>$P\left(X\prec 1\right)=P\left(X=0\right)=0.0256\left(1\right)$<br>ម្យ៉ាងទៀត<br>$P\left(X=x\right)=C\left(n,x\right)P^{x}\left(1-p\right)^{n-x}$<br>$P\left(X=0\right)=C\left(n,0\right).\left(0.6\right)^{0}.\left(0.4\right)^{n-0}$<br>$=\left(0.4\right)^{n}\ \ \left(2\right)$<br>តាម(១)និង(២) គេបាន<br>$0.0256=\left(0.4\right)^{n}$<br>$\Leftrightarrow \log\left(0.0256\right)=n\log\left(0.4\right)$<br>$\Rightarrow -1.592=n\left(-0.398\right)$<br>$\Rightarrow n=\frac{1.592}{0.398}=4$<br>ដូចនេះ $n=4$<br>២. សង្ឃឹមគណិតនិងវ៉ារ្យង់នៃអថេរ<br>ចៃដន្យ $X$<br>ច្បាប់ទ្វេធានៃប្រូបាប បើ $X$<br>ជាអថេរចៃដន្យនៃ $Bin\left(n\ ,p\right)$ | |

| | | |
|---|---|---|
| | នោះ $E(X)=np$ ហើយវ៉ារ្យង់តាងដោយ $Var(X)=np(1-p)$<br>ឧទាហរណ៍ ឧបមាថាប្រូបាបដែលជាថ្ងៃមានភ្លៀងស្មើនឹង $0.4$ ។គណនាចំនួនថ្ងៃមានភៀងដែលសង្ឃឹមទុកក្នុងមួយសប្តាហ៍ និងគម្លាតស្តង់ដា<br>ចម្លើយ<br>យក "ថ្ងៃមានភៀង"ជាជោគជ័យ គេបាន<br>$P=0.4, q=1-p=1-0.4=0.6$<br>តាង $X$ ជាអថេរចៃដន្យដែលជា"ចំនួនថ្ងៃមានភៀងក្នុងមួយសប្តាហ៍"<br>នោះ $X$ ជាអថេរនៃ $Bin(n, p)$<br>ដែល $n=7$ , $p=0.4$<br>តាមច្បាប់ទ្វេធា<br>$E(X)=np=7\times0.4=2.8$<br>$Var(X)=np(1-p)=2.8\times0.6$<br>$=1.68$<br>-គម្លាតស្តង់ដាមានរូបមន្ត<br>$\sigma=\sqrt{Var(X)}=\sqrt{1.68}=1.30$ ថ្ងៃ<br>ដូចនេះ ចំនួនមានភៀងដែលសង្ឃឹមទុកក្នុងមួយសប្តាហ៍ប្រហែល ៣ថ្ងៃ និងគម្លាតស្តង់ដាប្រហែល១ថ្ងៃ។<br>លំហាត់គំរូ នៅក្នុងថង់មួយមានបាល់ពណ៌ក្រហម៦បាល់ពណ៌លឿង៨និងបាល់ពណ៌ខៀវ៦។គេចាប់យកបាលមួយដោយចៃដន្យចេញពីថង់នោះ ហើយកត់ទុកពណ៌របស់បាល់រួចដាក់ | |

| | | |
|---|---|---|
| -ចែកក្រដាសលំហាត់ប្រត្តិបត្តិ | ក្នុងថង់វិញ។<br>គេចាប់ហើយដាក់ចូលទៅវិញចំនួន ១០ដង។<br>ក. រកចំនួនបាល់ពណ៌ក្រហមដែលសង្ឃឹមទុកនឹងចាប់បានទាំងអស់<br>ខ. រកប្រូបាបដែលចាប់បានបាល់ពណ៌លឿងទាំងអស់មិនលើសពី៤។<br>ចម្លើយ<br>ក. តាង $X$ ជាអថេរចៃដន្យ "ចំនួនបាល់ពណ៌ក្រហម"<br>$X - Bin(n\ ,p)$ ដែល $n=10$ ហើយ<br>$P=\frac{6}{20}=\frac{3}{10}$<br>គេបាន $E(X)=np=10\times\frac{3}{10}=3$<br>ដូចនេះសង្ឃឹមទុកថា គេនឹងចាប់បានពណ៌ក្រហមទាំងអស់ចំនួន៣បាល់<br>ខ. តាងy ជាអថេរចៃដន្យ "ចំនួនបាល់ពណ៌លឿង"<br>$X - Bin(10\ ,p)$ ដែល $P=\frac{8}{20}=\frac{2}{5}$<br>និង<br>$q=1-\frac{2}{5}=\frac{3}{5}$<br>ប្រូបាបដែលចាប់បានបាល់ពណ៌លឿងមិនលើសពី ៤គឺ $P(x\le 4)$<br>គេបាន | ក. តាង $X$ ជាអថេរចៃដន្យ "ចំនួនបាល់ពណ៌ក្រហម"<br>$X - Bin(n\ ,p)$ ដែល $n=10$<br>ហើយ<br>$P=\frac{6}{20}=\frac{3}{10}$<br>គេបាន $E(X)=np=10\times\frac{3}{10}=3$<br>ដូចនេះសង្ឃឹមទុកថា<br>គេនឹងចាប់បាន<br>ពណ៌ក្រហមទាំងអស់ចំនួន ៣បាល់<br>ខ. តាងy ជាអថេរចៃដន្យ "ចំនួនបាល់ពណ៌លឿង"<br>$X - Bin(10\ ,p)$ ដែល<br>$P=\frac{8}{20}=\frac{2}{5}$<br>និង<br>$q=1-\frac{2}{5}=\frac{3}{5}$<br>ប្រូបាបដែលចាប់បានបាល់ពណ៌លឿងមិនលើសពី ៤គឺ<br>$P(x\le 4)$<br>គេបាន |

| | | |
|---|---|---|
| ឱ្យសិស្សធ្វើតាមក្រុម<br><br>-ចែកក្រដាសលំហាត់ប្រត្តិបត្តិឱ្យសិស្សធ្វើតាមក្រុម | $P(x=4)=P(x=0)+P(x=1)+$<br>$P(x=2)+P(x=3)+P(x=4)$<br>$P(x=0)=C(10,0)+\left(\frac{2}{5}\right)^0\left(\frac{3}{5}\right)^{10}$<br>$=0.0060$<br>$P(x=1)=C(10,1)+\left(\frac{2}{5}\right)^1\left(\frac{3}{5}\right)^9$<br>$=0.0403$<br>$P(x=2)=C(10,2).\left(\frac{2}{5}\right)^2\left(\frac{3}{5}\right)^8$<br>$=0.1209$<br>$P(x=3)=C(10,3).\left(\frac{2}{5}\right)^3\left(\frac{3}{5}\right)^7$<br>$=0.2150$<br>$P(x=4)=C(10,4).\left(\frac{2}{5}\right)^4\left(\frac{3}{5}\right)^6$<br>$=0.2508$<br>$P(x\le 4)=0.0060+0.0403+0.1209$<br>$+0.2150+0.2508=0.6330$<br>ដូចនេះប្រូបាបដែលចាប់បានបាល់ពណ៌លឿងមិនលើសពី ៤គឺ 0.6330 | $P(x=4)=P(x=0)+P(x=1)+$<br>$P(x=2)+P(x=3)+P(x=4)$<br>$P(x=0)=C(10,0)+\left(\frac{2}{5}\right)^0\left(\frac{3}{5}\right)^{10}$<br>$=0.0060$<br>$P(x=1)=C(10,1)+\left(\frac{2}{5}\right)^1\left(\frac{3}{5}\right)^9$<br>$=0.0403$<br>$P(x=2)=C(10,2).\left(\frac{2}{5}\right)^2\left(\frac{3}{5}\right)^8$<br>$=0.1209$<br>$P(x=3)=C(10,3).\left(\frac{2}{5}\right)^3\left(\frac{3}{5}\right)^7$<br>$=0.2150$<br>$P(x=4)=C(10,4).\left(\frac{2}{5}\right)^4\left(\frac{3}{5}\right)^6$<br>$=0.2508$<br>$P(x\le 4)=0.0060+0.0403+0.12$<br>$+0.2150+0.2508=0.6330$<br><br>ដូចនេះប្រូបាបដែលចាប់បានបាល់ពណ៌លឿងមិនលើសពី ៤គឺ 0.6330<br>-ដោះស្រាយតាមក្រុម |

| | | |
|---|---|---|
| -ដាក់លំហាត់ឱ្យសិស្សធ្វើលើក្ដារខៀន | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>- $X$ ជាអថេរចៃដន្យដែល<br>$X-Bin(12,0.45)$<br>ក. $P(x=5)$<br>ខ. $P(x\succ 1)$<br>គ. គម្លាតស្តង់ដា | ចម្លើយ<br>តាមរូបមន្តអនុគមន៍ដង់ស៊ីតេប្រូបាប<br>$P(X=x)=C(n,x)P^{x}(1-p)^{n-x}$<br>$x=0,1,2.........$<br>ក.<br>$P(x=5)=C(12,0.45)(0.45)^{5}$<br>$\times(0.55)^{7}=0.2225$<br>ខ.<br>$P(x\succ 1)=1-P(x\le 1)$<br>$P(x\le 1)=P(x=0)+P(x=1)$<br>$P(x\le 1)=0.0008+0.0075$<br>$=0.0083$<br>$\Rightarrow P(x\succ 1)=1-0.0083=09917$<br>គ.<br>$Var(X)=np(1-p)$<br>$=12(o.45)(0.55)=2.97$<br>គម្លាតស្តង់ដា<br>$\sigma=\sqrt{2.97}=1.72$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី) | -សិស្សកត់លំហាត់<br>និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

## - មុខវិជ្ជា : គណិតវិទ្យា ថ្នាក់ទី ១២(កម្រិតមូលដ្ឋាន)
## - ជំពូកទី៦ : បំណែងចែកប្រូបាប
## - មេរៀនទី២ : បំណែងចែកទ្វេធា

I.**វត្ថុបំណងនៃមេរៀន**

-**ចំណេះដឹង** : សិស្សប្រាប់ពីវិធីគណនាតម្លៃនៃអថេរចៃដន្យx ដែលកើតញឹកញាប់ជាងគេ តាមរយៈឧទាហរណ៍បានត្រឹមត្រូវ។

-**បំណិន** : សិស្សគណនាតម្លៃនៃអថេរចៃដន្យ x ដែលកើតញឹកញាប់ជាងគេតាមរយៈ លំហាត់គំរូបានត្រឹមត្រូវ។

-**ឥរិយាបថ** : សិស្សសហការគ្នាដោះស្រាយលំហាត់ដោយស្មារតីប្រុងប្រយ័ត្នខ្ពស់។

II. **ខ្លឹមសារមេរៀន** : ពេលវេលា: …២…ម៉ោង ថ្ងៃ………ទី…ខែ…………..ឆ្នាំ………..

៣. គណនាតម្លៃនៃអថេរចៃដន្យដែលកើតឡើងញឹកញាប់ជាងគេ

III.**សម្ភារៈឧទេស**

-ស . ស :ទំព័រទី១៥០៤ដល់ទំព័រទី១៥៧

-ស . គ : ទំព័រទី១៥៤ ដល់ទំព័រទី១៥៧

- សន្លឹកកម្រង់លំហាត់ប្រត្តិបត្តិ

IV.ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសាមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ ធ្នាប់ក្នុងថ្នាក់ | ជំហានទី១<br>(រដ្ឋបាលថ្នាក់ ៣នាទី) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងដៅចំណុចទិន្នន័យលើក្តារខៀន | ជំហានទី២<br>(រំលឹកមេរៀនចាស់ ៧នាទី)<br>ឧទាហរណ៍<br>គេបោះកាក់មួយដែលស្មើសាច់ល្អ។ កាក់នោះម្ខាងមានរូបក្បាលមនុស្ស និងម្ខាងទៀតគ្មានរូបក្បាលមនុស្ស។ គេបោះកាក់នោះចំនួន១០ដង | -ចម្លើយ<br>សន្មតថា "កាក់ចេញបានរូបក្បាលមនុស្ស" ជាជោគជ័យ គេបាន |

| | | |
|---|---|---|
| | ក.រកប្រូបាបដែលនឹងចេញរូបខាងក្បាលមនុស្សចំនួន ៥ដង<br>ខ. រកប្រូបាបដែលនឹងចេញបានរូបក្បាលមនុស្សតិចជាង ៣ដង<br>តើអ្នកសង្ឃឹងថានឹងដេញបានរូបក្បាលមនុស្សចំនួនប៉ុន្មានដង? | $p=\frac{1}{2}\ ,q=1-p=1-\frac{1}{2}=\frac{1}{2}$<br>តាង $X$ ជាអថេរចៃដន្យ "ចំនួនដងដែលចេញបានរូបខាងក្បាលមនុស្ស"<br>ក.រក $p(x=5)$<br>$p(x=5)=C(10\ ,5)\left(\frac{1}{2}\right)^5\left(\frac{1}{2}\right)^5$<br>$=0.2461$<br>ដូចនេះ $p(x=5)=0.2461$<br>ខ.<br>$p(x\prec 3)$<br>$p(x\prec 3)=p(x=0)+p(x=1)$<br>$+p(x=2)$<br>តែ<br>$p(x=0)=C(10,0)\left(\frac{1}{2}\right)^0\left(\frac{1}{2}\right)^{10}$<br>$=0.0010$<br>$p(x=1)=C(10,1)\left(\frac{1}{2}\right)^1\left(\frac{1}{2}\right)^9$<br>$=0.0098$<br>$p(x=2)=C(10,2)\left(\frac{1}{2}\right)^2\left(\frac{1}{2}\right)^8$<br>$=0.439$<br>$\Rightarrow p(x\prec 3)=0.0011+0.0098$<br>$+0.439=0.0547$<br>ដូចនេះ<br>$p(x\prec 3)=0.0547$<br>គ. ដោយ $X-Bin(10,0.5)$<br>គេបាន $E(x)=10.\frac{1}{2}=5$<br>ដូចនេះ យើងសង្ឃឹមថានឹងចេញរូបខាងក្បាលមនុស្ស ៥ដង។ |

| | | |
|---|---|---|
| -ប្រាប់សិស្សពីតម្លៃប្រូបាបដែលធ្វើឱ្យអថេរ x កើតឡើងញឹកញាប់ជាងគេ<br><br>-ដាក់ឧទាហរណ៍ណែនាំសិស្សគណនា<br><br>-តើអនុគមន៍ដង់ស៊ីតេមានរូបមន្តដូចម្តេច?<br><br>-តើ..........?ត្រូវនិងប្រូបាបធំជាងគេ<br>-តើតម្លៃនៃ....ដែលកើតញឹកញាប់ជាងគេឬម៉ូតស្មើនឹងប៉ុន្មាន?<br>-ឱ្យសិស្សទាញរកវិធានទូទៅ | <u>ជំហានទី៣</u><br>(មេរៀនថ្មី រយៈពេល៦០នាទី)<br>**មេរៀនទី២:**<br>**បំណែងចែកទ្វេធា**<br>**៣.គណនាតម្លៃនៃអថេរចៃដន្យដែលកើតឡើងញឹកញាប់ជាងគេ**<br>-តម្លៃអថេរចៃដន្យ $X$ ដែលកើតឡើងញឹកញាប់ជាងគេគឺតម្លៃx ណាដែលត្រូវនឹងតម្លៃប្រូបាបធំជាងគេ តម្លៃនោះជួនកាលគេហៅថា ម៉ូត។<br>ឧទាហរណ៍បើ x ជាអថេរចៃដន្យនៃ $Bin(10,0.45)$<br>គណនាតម្លៃ x ដែលកើតឡើងញឹកញាប់ជាងគេ។<br>ចម្លើយ<br>$X - Bin(10,0.45)$<br>គេបាន<br>$p(X=x)=C(n,x)p^{x}(1-p)^{n-x}$<br>$x=0,1,2,3...,10$<br>$p(10,0)=C(10,0)(0.45)^{0}(0.55)^{10}$<br>$=0.0025$<br>$p(x=1)=C(10,1).(0.45)^{1}(0.55)^{9}$<br>$=0.0207$<br>$p(x=2)=C(10,2)(0.45)^{2}(0.55)^{8}$<br>$0.0763$<br>$p(x=3)=C(10,3)(0.45)^{3}(0.55)^{7}$<br>$=0.1665$<br>$p(x=4)=C(10,4)(0.45)^{4}(0.55)^{6}$<br>$=0.3484$<br>$p(x=5)=C(10,5)(0.45)^{5}(0.55)^{5}$<br>$=0.2340$<br>$p(x=6)=C(10,6)(0.45)^{6}(0.55)^{4}$<br>$=0.1595$ | $p(X=x)=C(n,x)p^{x}(1-p)^{n-x}$<br>$x=0,1,2,3...,10$<br>$p(10,0)=C(10,0)(0.45)^{0}(0.55)^{10}$<br>$=0.0025$<br>$p(x=1)=C(10,1).(0.45)^{1}(0.55)^{9}$<br>$=0.0207$<br>$p(x=2)=C(10,2)(0.45)^{2}(0.55)^{8}$<br>$0.0763$<br>$p(x=3)=C(10,3)(0.45)^{3}(0.55)^{7}$<br>$=0.1665$<br>$p(x=4)=C(10,4)(0.45)^{4}(0.55)^{6}$<br>$=0.3484$<br>$p(x=5)=C(10,5)(0.45)^{5}(0.55)^{5}$<br>$=0.2340$<br>$p(x=6)=C(10,6)(0.45)^{6}(0.55)^{4}$<br>$=0.1595$<br><br>គេឃើញថាតម្លៃ x =4 នៃ x ត្រូវនឹង<br>ប្រូបាបធំជាងគេ<br>ដូចនេះ តម្លៃនៃ x<br>ដែលកើតញឹកញាប់<br>ជាងគេ ឬម៉ូតស្មើនឹង ៤។ |

| | | |
|---|---|---|
| -ដាក់លំហាត់គំរូណែនាំសិស្ស<br>គណនា | គេឃើញថាតម្លៃ x =4 នៃ x ត្រូវនឹងប្រូបាបធំជាងគេ<br>ដូចនេះ តម្លៃនៃ x ដែលកើតញឹកញាប់ជាងគេ ឬម៉ូតស្មើនឹង ៤។<br>-ជាទូទៅ ដើម្បីរកតម្លៃនៃ x ដែលធ្វើឱ្យតម្លៃប្រូបាបធំជាងគេ គេត្រូវ រកប្រូបាបតម្លៃ x ដែលនៅជិតតម្លៃមធ្យមឬ $E(x)=np$<br>លំហាត់គំរូ x ជាអថេរចៃដន្យទ្វេធានៃបំណែងចែកទ្វេធាដែលមានមធ្យមស្មើនឹង ២ និងវ៉ារ្យង់ស្មើនឹង1.6<br>ក. គណនាតម្លៃ x ដែលកើតឡើងញឹកញាប់ជាងគេ<br>ខ. គណនា $p(x \prec 6)$<br>ចម្លើយ<br>ក. បើ x ជាអថេរនៃ $Bin(n,p)$<br>គេបាន $E(x)=np$ និង $Var(x)=npq$<br>តាង $q=1-p$ តែ<br>$E(x)=2, Var(x)=1.6$<br>ដូចនេះ $np=2,\ npq=1.6$<br>ជំនួស $np=2$ ក្នុងសមីការ $npq=1.6$<br>គេបាន $2q=1.6 \Rightarrow q=0.8$<br>ដោយ $p=1-q=1-0.8=0.2$<br>ហើយ $np=2\ , n=\frac{2}{p}=\frac{2}{0.2}=10$<br>គេត្រូវយកតម្លៃ x នៃX នៅក្បែរៗតម្លៃមធ្យមហេតុនេះ $x=0\ ,1\ ,\ 2\ ,3$<br>x ជាអថេរទ្វេធានៃបំណែងចែកទ្វេធា | -គណនា |

| | | |
|---|---|---|
| -ចែកក្រដាសលំហាត់ប្រត្តិបត្តិឱ្យសិស្សធ្វើ | គេបានអនុគមន៍ដង់ស៊ីតេប្រូបាប<br><br>$p(X=x)=C(n,x)p^x.q^{n-x}$<br>$p(x=1)=C(10,1)(0.2)^1(0.8)^9$<br>$=0.2484$<br>$p(x=2)=C(10,2)(0.2)^2(0.8)^8$<br>$=0.3020$<br>$p(10,3)=C(10,3)(0.2)^3(0.8)^7$<br>$=0.2013$<br>ដូចនេះ តម្លៃ នៃ $x=2$ កើតឡើងញឹកញាប់ជាងគេ។<br>ខ. គណនា $p(x\prec 6)$<br>$p(x\prec 6)=p(x=0)+p(x=1)+p(x=2)$<br>$+p(x=3)+p(x=4)+p(x=5)$<br>$p(x=0)=C(10,0)(0.2)^0(0.8)^{10}$<br>$=0.1074$<br>$p(x=4)=C(10,1).(0.2)^4(0.8)^6$<br>$=0.0881$<br>$p(x=5)C(10,2)(0.2)^5(0.8)^5$<br>$=0.0264$<br>$p(x\prec 6)=0.1074+0.2684+0.3020$<br>$+0.2013+0.0881+0.0264=0.9936$<br><br>ដូចនេះ $p(x\prec 6)=0.9936$ | -ដោះស្រាយតាមក្រុម |
| -ដាក់លំហាត់ឱ្យសិស្សដោះស្រាយ | <u>ជំហានទី៤</u><br>(ពង្រឹងចំណេះដឹង ១៥នាទី)<br>គេដឹងថាអថេរចៃដន្យដែល<br>$X-Bin(8,0.45)$<br>ក. គណនាតម្លៃ x ដែលកើតឡើងញឹកញាប់ជាងគេ<br>ខ. $p(x\prec 4)$ | ក.<br>ដោយ<br>$E(x)=np=8(0.45)3.6$<br>នោះតម្លៃ $x=2,\ 3\ ,4\ ,5$ |

| | | |
|---|---|---|
| | | $p(X=x)=C(n,x)\,p^x(1-p)^{n-x}$<br>$p(x=2)=C(8,2)(0.45)^2(0.55)^6$<br>$=0.1569$<br>$p(x=3)=C(8,3)(0.45)^3(0.55)^5$<br>$=0.2568$<br>$p(x=4)=C(8,4)(0.45)^4(0.55)^4$<br>$=0.2627$<br>$p(x=5)=C(8,5)(0.45)^5(0.55)^3$<br>$=0.1719$<br>ដូចនេះ តម្លៃ $X$ ដែលកើតឡើងញឹកញាប់ជាងគេគឺ<br>$X=4$<br>ខ. $p(x\prec 4)$<br>$p(x\prec 4)=p(x=0)+p(x=1)+$<br>$p(x=2)+p(x=3)$<br>$p(x=0)=C(8,0)(0.45)^0(0.55)^8$<br>$=0.0084$<br>$p(x=1)=C(8,1).(0.45)^1(0.55)^7$<br>$=0.0548$<br>$p(x\prec 4)=0.0084+0.0548+$<br>$0.1569+0.2568=0.4769$<br>ដូចនេះ $p(x\prec 4)=0.4769$ |
| -គ្រូដាក់កិច្ចការឲ្យសិស្សធ្វើ<br>-ប្រាប់សិស្សឲ្យមើលមេរៀនឡើងវិញ និងធ្វើលំហាត់ | <u>ជំហានទី៥</u><br>(កិច្ចការផ្ទះ ៥នាទី) | -សិស្សកត់លំហាត់ និងអនុវត្តតាម |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី៦ បំណែងចែកប្រូបាប

## មេរៀនទី៣ បំណែងចែកណរម៉ាល់

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សអោយនិយមន័យអថេរចៃដន្យជាប់តាមរយៈឧទាហរណ៍និងកំណត់អនុគមន៍ដង់ស៊ីតេប្រូបាបនៃអថេរណរម៉ាល់ $X$ តាមរយៈខ្លឹមសារមេរៀន។
- បំណិន: សិស្សដោះស្រាយលំហាត់បានត្រឹមត្រូវតាមខ្សែកោងណរម៉ាល់
- ឥរិយាបថ: សិស្សចូលរួមដោះស្រាយលំហាត់យ៉ាងសកម្មនិងស្និទ្ធស្នាល

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ១៦០-១៦៤
- សៀវភៅគ្រូ: ទំព័រ ១៦០-១៦៤

### IV. ខ្លឹមសារមេរៀន

1. **អនុគមន៍ដង់ស៊ីតេប្រូបាបនៃអថេរណរម៉ាល់** $X$

   **1.1. អថេរចៃដន្យជាប់**

   **1.2. បំណែងចែកណរម៉ាល់**

### V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| -ក្នុងពិសោធន៍ទ្វេធា $n$ វិញ្ញាសា បើប្រូបាបជោគជ័យ $p$ ប្រូបាបបរាជ័យ $q$ ។តើអនុគមន៍ដង់ស៊ីតេប្រូបាប | | - $P(X=x)=C(n,x)\,p^x q^{n-x}$<br>ដែល $x=0,1,2,\ldots,n$ |

| | | |
|---|---|---|
| $P(X=x)=?$<br>-បើ $X$ ជាអថេរនៃ $Bin(8,0.4)$<br>គណនា $P(X=2)$ | | -យើងមាន $Bin(8,0.4)$<br>នោះ $n=8, p=0.4, q=0.6$<br>$P(X=2)=C(8,2)(0.4)^2$<br>$\times(0.6)^{8-2}$<br>$=\frac{8!}{6!2!}(0.4)^2(0.6)^6$ |
| ជំហានទី៣ (មេរៀនថ្មី) | | |
| -គ្រូដាក់ឧទាហរណ៍: បុរសម្នាក់មានម៉ាសនៅចន្លោះ 82.5$kg$ និង 83.5$kg$ ។ បើអថេរ $X$ ជាម៉ាសរបស់បុរសនោះតើគេអាចស្គាល់តម្លៃពិតប្រាកដរបស់ $X$ បានដែរឬទេ?<br>-គ្រូប្រាប់ថា $X$ ហៅថាអថេរចៃដន្យជាប់<br>-ចូរអោយនិយមន័យអថេរចៃដន្យជាប់<br><br>-អោយសិស្សមើលនិយមន័យក្នុងសៀវភៅទំព័រ១៦១ | **បំណែងចែកណរម៉ាល់**<br>**1. អនុគមន៍ដង់ស៊ីតេប្រូបាបនៃអថេរណរម៉ាល់** $X$<br>**1.1.អថេរចៃដន្យជាប់**<br>និយមន័យ: អថេរចៃដន្យជាប់គឺជាអថេរចៃដន្យដែលយកតម្លៃណាមួយក៏បាននៅក្នុងចន្លោះនៃចំនួនពិតមួយ។<br><br>**1.2.បំណែងចែកណរម៉ាល់**<br>**និយមន័យ:** បើអថេរចៃដន្យ $X$ មានអនុគមន៍ដង់ស៊ីតេប្រូបាប $f(x)$ ដែល $f(x)=\frac{e^{\frac{-(x-\mu)^2}{2\sigma}}}{\sigma\sqrt{2\pi}}$ ហើយ $x\in(-\infty,+\infty)$ នោះគេថាអថេរ $X$ ជាអថេរចៃដន្យនៃបំណែកចែកណរម៉ាល់ដែលមានមធ្យមស្មើ $\mu$ និងវ៉ារ្យង់ស្មើនឹង $\sigma^2$ ។ | -សិស្សសង្កេតឧទាហរណ៍ និងឆ្លើយសំនួរ<br>-គេមិនអាចស្គាល់តម្លៃពិតរបស់ $X$ បានទេ គ្រាន់តែដឹងថា $X$ អាចយកតម្លៃណាមួយក៏បានអោយស្ថិតក្នុងចន្លោះ 82.5$kg$ និង 83.5$kg$ ។<br>និយមន័យ: អថេរចៃដន្យជាប់គឺជាអថេរចៃដន្យដែលយកតម្លៃណាមួយក៏បាននៅក្នុងចន្លោះនៃចំនួនពិតមួយ។<br><br>-ធ្វើតាមការណែនាំរបស់គ្រូ<br>**និយមន័យ:** បើអថេរចៃដន្យ $X$ មានអនុគមន៍ដង់ស៊ីតេប្រូបាប $f(x)$ ដែល $f(x)=\frac{e^{\frac{-(x-\mu)^2}{2\sigma}}}{\sigma\sqrt{2\pi}}$ ហើយ $x\in(-\infty,+\infty)$ នោះគេថាអថេរ $X$ ជាអថេរចៃដន្យនៃ |

| | | |
|---|---|---|
| -គ្រូអោយសិស្សសង្កេតនិងណែនាំពីលក្ខណ:ពិសេសនៃខ្សែកោង $f(x)$ | បំណែងចែកណរម៉ាល់ដែលមានមធ្យម $\mu$ និងវ៉ារ្យង់ $\sigma^2$ កំណត់ដោយ $N(\mu,\sigma^2)$<br>**✶លក្ខណ:ពិសេសនៃខ្សែកោង** $f(x)$<br>①មានរាងដូចជួងនិងមានលក្ខណ:ឆ្លុះធៀបនឹងម៉ូត<br>②ផ្ទៃផ្នែកឆូតប្រហែល 68% នៃផ្ទៃទាំងអស់ដែលនៅចន្លោះ $\pm\sigma$ ពីមធ្យម<br>គេអាចសរសេរ<br>$\mu\pm\sigma=(\mu-\sigma,\mu+\sigma)$<br><br>-ក្នុងចន្លោះ<br>$\mu\pm2\sigma=(\mu-2\sigma,\mu+2\sigma)$ ផ្ទៃប្រហែល 95%<br><br>-ក្នុងចន្លោះ<br>$\mu\pm3\sigma=(\mu-3\sigma,\mu+3\sigma)$ ផ្ទៃប្រហែល 99.73%<br> | បំណែកចែកណរម៉ាល់ដែលមានមធ្យមស្មើ $\mu$ និងវ៉ារ្យង់ស្មើនឹង $\sigma^2$ ។បំណែងចែកណរម៉ាល់ដែលមានមធ្យម $\mu$ និងវ៉ារ្យង់ $\sigma^2$ កំណត់ដោយ $N(\mu,\sigma^2)$<br>**✶លក្ខណ:ពិសេសនៃខ្សែកោង** $f(x)$<br>①មានរាងដូចជួងនិងមានលក្ខណ:ឆ្លុះធៀបនឹងម៉ូត<br>②ផ្ទៃផ្នែកឆូតប្រហែល 68% នៃផ្ទៃទាំងអស់ដែលនៅចន្លោះ $\pm\sigma$ ពីមធ្យម<br>គេអាចសរសេរ<br>$\mu\pm\sigma=(\mu-\sigma,\mu+\sigma)$<br><br>-ក្នុងចន្លោះ<br>$\mu\pm2\sigma=(\mu-2\sigma,\mu+2\sigma)$<br>ផ្ទៃប្រហែល 95%<br><br>-ក្នុងចន្លោះ<br>$\mu\pm3\sigma=(\mu-3\sigma,\mu+3\sigma)$<br>ផ្ទៃប្រហែល 99.73%<br><br>-សិស្សកត់ឧទាហរណ៍នៅធ្វើតាមការណែនាំរបស់គ្រូ |

| | | |
|---|---|---|
| -គ្រូដាក់ឧទាហរណ៍ណែនាំសិស្សអោយដោះស្រាយដោយប្រើលក្ខណៈពិសេស | ឧទាហរណ៍:បំណែងចែកប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមវិនិយោគមួយក្រុមប្រហាក់ប្រហែលនិងបំណែងចែកណរម៉ាល់ដែលមានមធ្យមស្មើនឹង៣៧២០០ដុល្លានិងមានគំលាតស្តង់ដាស្មើនឹង៨០០ដុល្លា។<br>ក. តើប្រាក់ចំណូលប្រហែល 68% ស្ថិតនៅចន្លោះចំនួនប៉ុន្មានដុល្លា?<br>ខ. តើប្រាក់ចំណូលប្រហែល 95% ស្ថិតនៅចន្លោះចំនួនប៉ុន្មានដុល្លា?<br>គ. តើប្រាក់ចំណូលប្រហែល 99.73% ស្ថិតនៅចន្លោះចំនួនប៉ុន្មានដុល្លា?<br>ឃ. រកមេដ្យាននិងម៉ូតនៃបំណែងចែក។<br><u>ចំលើយ</u><br>ក. តាមខ្សែកោងណរម៉ាល់ប្រហែល 68% នៃផ្ទៃទាំងអស់គឺនៅចន្លោះ $\mu\pm\sigma=(\mu-\sigma,\mu+\sigma)$<br>ដោយ $\mu=37200,\sigma=800$<br>$\mu\pm\sigma=(37200-800,$<br>$37200+800)$<br>$=(36400,38000)$<br>ដូចនេះ ប្រហែលជា 68% នៃប្រាក់ចំណូលប្រចាំឆ្នាំនៅចន្លោះពី 36400 ដុល្លានិង 38000 ដុល្លា។<br>ខ. ប្រាក់ចំណូលប្រហែល 95% នៅក្នុងចន្លោះ<br>$\mu\pm2\sigma=(\mu-2\sigma,\mu+2\sigma)$<br>$=(37200-2\times800,$<br>$37200+2\times800)$<br>$=(35600,38800)$ | <u>ចំលើយ</u><br>ក. តាមខ្សែកោងណរម៉ាល់ប្រហែល 68% នៃផ្ទៃទាំងអស់គឺនៅចន្លោះ<br>$\mu\pm\sigma=(\mu-\sigma,\mu+\sigma)$<br>ដោយ $\mu=37200,\sigma=800$<br>$\mu\pm\sigma=(37200-800,$<br>$37200+800)$<br>$=(36400,38000)$<br>ដូចនេះ ប្រហែលជា 68% នៃប្រាក់ចំណូលប្រចាំឆ្នាំនៅចន្លោះពី 36400 ដុល្លានិង 38000 ដុល្លា។<br>ខ. ប្រាក់ចំណូលប្រហែល 95% នៅក្នុងចន្លោះ<br>$\mu\pm2\sigma=(\mu-2\sigma,\mu+2\sigma)$<br>$=(37200-2\times800,$<br>$37200+2\times800)$<br>$=(35600,38800)$<br>គ. ប្រាក់ចំណូលប្រហែល 99.73% ស្ថិតក្នុងចន្លោះ<br>$\mu\pm3\sigma=(\mu-3\sigma,\mu+3\sigma)$ |

| | | |
|---|---|---|
| | គ. ប្រាក់ចំណូលប្រហែល 99.73% ស្ថិតក្នុងចន្លោះ<br>$\mu \pm 3\sigma = (\mu - 3\sigma, \mu + 3\sigma)$<br>$= (37200 - 2\times 800,$<br>$37200 + 2\times 800)$<br>$= (35600, 38800)$<br>ឃ. ដោយប្រាក់ចំណូលប្រចាំឆ្នាំប្រហាក់ប្រហែលបំណែងចែកណរម៉ាល់នោះមធ្យម ម៉ូត និង មេដ្យាន ស្មើគ្នាគឺ 37200 ដុល្លា | $= (37200 - 2\times 800,$<br>$37200 + 2\times 800)$<br>$= (35600, 38800)$<br>ឃ. ដោយប្រាក់ចំណូលប្រចាំឆ្នាំប្រហាក់ប្រហែលបំណែងចែកណរម៉ាល់នោះមធ្យម ម៉ូត និងមេដ្យាន ស្មើគ្នាគឺ 37200 ដុល្លា |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -ក្នុងបំណែងចែកណរម៉ាល់<br>+ផ្ទៃប្រហែល 68% ស្ថិតក្នុងចន្លោះណាំ?<br>+ផ្ទៃប្រហែល 95% ស្ថិតនៅចន្លោះណា?<br>+ផ្ទៃប្រហែល 99.73% ស្ថិតនៅចន្លោះណា? | | +ផ្ទៃប្រហែល 68% ក្នុងចន្លោះ<br>$\mu \pm \sigma = (\mu - \sigma, \mu + \sigma)$<br>+ក្នុងចន្លោះ<br>$\mu \pm 2\sigma = (\mu - 2\sigma, \mu + 2\sigma)$<br>+ក្នុងចន្លោះ<br>$\mu \pm 3\sigma = (\mu - 3\sigma, \mu + 3\sigma)$ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -សូមប្អូនធ្វើលំហាត់ទំព័រទី ១៧០ លំហាត់លេខ១និង២ | | -សិស្សកត់ត្រាលេខទំព័រនិងលេខលំហាត់ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី៦ បំណែងចែកប្រូបាប

## មេរៀនទី៣ បំណែងចែកណរម៉ាល់ (តចប់)

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សកំណត់បានពីរបៀបរកប្រូបាបដែលស្ថិតនៅក្រោមខ្សែកោងណរម៉ាល់ តាមរយៈខ្លឹមសារមេរៀន។
- បំណិន: សិស្សគណនាប្រូបាបបានត្រឹមត្រូវដោយប្រើខ្សែកោងណរម៉ាល់។
- ឥរិយាបថ: សិស្សចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយនិងយកទៅអនុវត្តក្នុងជីវភាព

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទេ្ទស

- សៀវភៅសិស្ស: ទំព័រ ១៦៤-១៦៧
- សៀវភៅគ្រូ: ទំព័រ ១៦៤-១៦៧

### IV. ខ្លឹមសារមេរៀន

2. ប្រូបាបដែលស្ថិតនៅក្រោមខ្សែកោងណរម៉ាល់

### V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| -តើផ្ទៃក្រឡាប្រហែល 68% នៃផ្ទៃសរុបស្ថិតក្នុងចន្លោះណា? <br> -ផ្ទៃប្រហែល 95% ស្ថិតក្នុងចន្លោះណា? | | -ស្ថិតក្នុងចន្លោះ $\mu\pm\sigma=(\mu-\sigma,\mu+\sigma)$ <br> -ស្ថិតក្នុងចន្លោះ $\mu\pm 2\sigma=(\mu-2\sigma,\mu+2\sigma)$ |

| | | |
|---|---|---|
| -ផ្ទៃប្រហែល 99.73% ស្ថិតក្នុងចន្លោះណា? | | -ស្ថិតក្នុងចន្លោះ<br>$\mu\pm3\sigma=(\mu-3\sigma,\mu+3\sigma)$ |
| | **ជំហានទី៣** (មេរៀនថ្មី) | |
| -អោយសិស្សសង្កេតខ្សែកោងណរម៉ាល់ដែលគ្រូគូសលើក្តារខៀន<br>-តើផ្ទៃក្រឡាដែលស្ថិតនៅខាងក្រោមខ្សែកោងណរម៉ាល់ដែល $X>\mu$ ស្មើប៉ុន្មានភាគរយ?ចុះ $X<\mu$?<br>-គ្រូប្រាប់ថា"ឬមានប្រូបាបស្មើ0.5 ដូចគ្នា<br>-គ្រូប្រាប់ថាដើម្បីងាយស្រួលគណនាប្រូបាប គេត្រូវបង្កើតអ័ក្សថ្មីមានអថេរហៅថាអថេរណរម៉ាល់ស្តង់ដា $Z$ ដោយយក 0 នៅចំតម្លៃ $\mu$ ហើយមួយឯកតាស្មើនឹង $\sigma$ | **បំណែងចែកណរម៉ាល់**<br>**2. ប្រូបាបដែលស្ថិតនៅក្រោមខ្សែកោងណរម៉ាល់**<br><br>$P(X>\mu)=P(X<\mu)=0.5$<br><br><br>**ជាទូទៅ:** បើស្គាល់តម្លៃនៃអថេរ $X$ នោះគេអាចរកតម្លៃនៃអថេរណរម៉ាល់ស្តង់ដា $Z$ បានតាមរូបមន្តបំលែង $Z=\frac{X-\mu}{\sigma}$ ដែល $\mu$ ជាមធ្យមនៃបំណែងចែក ហើយ $\sigma$ ជាគំលាតស្តង់ដា។ | -ស្មើនឹង 50% នៃផ្ទៃសរុប<br>-ស្មើនឹង 50% នៃផ្ទៃសរុប<br>-សិស្សស្តាប់ការណែនាំរបស់គ្រូ រួចកត់ត្រា<br>**ជាទូទៅ:** បើស្គាល់តម្លៃនៃអថេរ $X$ នោះគេអាចរកតម្លៃនៃអថេរណរម៉ាល់ស្តង់ដា $Z$ បានតាមរូបមន្តបំលែង<br>$Z=\frac{X-\mu}{\sigma}$ ដែល $\mu$ ជាមធ្យមនៃបំណែងចែក ហើយ $\sigma$ ជាគំលាតស្តង់ដា។ |

| | | |
|---|---|---|
| -ប្រាប់សិស្សបើ $Z$ ជាអថេរណរម៉ាល់ស្តង់ដានោះគេសរសេរ $N(0,1)$ ដែល O ជាមធ្យមនិងណែនាំសិស្សពីរបៀបមើលតារាងប្រូបាប<br>-គ្រូដាក់ឧទាហរណ៍ទំព័រ ១៦៦<br>ឧទាហរណ៍:បើ $z$ ជាអថេរនៃ $N(0,1)$ ។គណនា<br>ក. $P(\|z\|<1.43)$<br>ខ. $P(\|z\|>1.43)$<br>ណែនាំនិងរួមគណនាជាមួយសិស្ស | ចម្លើយ<br>ក. $P(\|z\|<1.43)$<br>$=P(-1.43<z<1.43)$<br>$=0.4236+0.4236$ (មើលតារាង)<br>$=0.8472$<br>ខ. $P(\|z\|>1.43)$<br>ដោយ $\|z\|>1.43$ នោះ<br>$z>1.43$ ឬ $z<-1.43$<br>គេបាន<br>$P(\|z\|>1.43)=P(z>1.43)$<br>$+P(z<-1.43)$<br>$=(0.5-0.4236)$<br>$+(0.5-0.4236)$<br>$=0.1528$ | -សិស្សស្តាប់និងរៀនមើលតារាងប្រូបាបដោយយកចិត្តទុកដាក់<br>ចម្លើយ<br>ក. $P(\|z\|<1.43)$<br>$=P(-1.43<z<1.43)$<br>$=0.4236+0.4236$ (មើលតារាង)<br>$=0.8472$<br>ខ. $P(\|z\|>1.43)$<br>ដោយ $\|z\|>1.43$ នោះ<br>$z>1.43$ ឬ $z<-1.43$<br>គេបាន<br>$P(\|z\|>1.43)=P(z>1.43)$<br>$+P(z<-1.43)$<br>$=(0.5-0.4236)$<br>$+(0.5-0.4236)$<br>$=0.1528$ |
| -គ្រូដាក់លំហាត់គំរូអោយសិស្សធ្វើ<br>លំហាត់គំរូ: បើ $X$ ជាអថេរនៃ $N(10,25)$ ។គណនាប្រូបាប<br>ក. $P(X>12)$<br>ខ. $P(X<6)$<br>គ. $P(6<X<12)$<br>-ណែនាំអោយសិស្សប្តូរពីអថេរ $X$ ទៅជាអថេរណរម៉ាល់ $Z$ ដោយប្រើរូបមន្ត | លំហាត់គំរូ: បើ $X$ ជាអថេរនៃ $N(10,25)$ ។គណនាប្រូបាប<br>ក. $P(X>12)$<br>ខ. $P(X<6)$<br>គ. $P(6<X<12)$<br>ចម្លើយ<br>ក. គណនា $P(X>12)$<br>បើ $X$ ជាអថេរនៃ $N(10,25)$ ដែល<br>$\mu=10,\sigma^2=25\Rightarrow\sigma=5$ | -សិស្សរួមជាមួយគ្រូគណនាលំហាត់គំរូនិងកត់ត្រា<br>-សិស្សធ្វើតាមការណែនាំ<br>ចម្លើយ<br>ក. គណនា $P(X>12)$<br>បើ $X$ ជាអថេរនៃ $N(10,25)$ ដែល |

| | | |
|---|---|---|
| | គេបាន $Z=\frac{X-10}{5}$<br>$P(X>12)=P\left(\frac{X-10}{5}>\frac{12-10}{5}\right)$<br>$=P(Z<-0.8)$<br>$=0.5-0.2881$<br>$=0.2119$<br>គេបាន $P(X<6)=0.2119$<br>គ. គណនា $P(6<X<12)$<br>$P(6<X<12)=P\left(\frac{6-10}{5}<\frac{X-10}{5}<\frac{12-1}{5}\right)$<br>$=P(-0.8<Z<0.1554)$<br>$=0.2881+0.1554$<br>$=0.4435$<br>ដូចនេះ $P(6<X<12)=0.4435$ | $\mu=10,\sigma^2=25\Rightarrow\sigma=5$<br>គេបាន $Z=\frac{X-10}{5}$<br>$P(X>12)=P\left(\frac{X-10}{5}>\frac{12-10}{5}\right)$<br>$=P(Z<-0.8)$<br>$=0.5-0.2881$<br>$=0.2119$<br>គេបាន $P(X<6)=0.2119$<br>គ. គណនា $P(6<X<12)$<br>$P(6<X<12)=P\left(\frac{6-10}{5}<\frac{X-10}{5}<\frac{12-1}{5}\right)$<br>$=P(-0.8<Z<0.1554)$<br>$=0.2881+0.1554$<br>$=0.4435$<br>ដូចនេះ<br>$P(6<X<12)=0.4435$ |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -លំហាត់: បើ $Z$ ជាអថេរនៃ $N(0,1)$ ។គណនា<br>ក. $P(Z<1.54)$<br>ខ. $P(Z>0.23)$ | | ក. $P(Z<1.54)$<br>តាមតារាងយើងបាន<br>$P(Z<1.54)=0.5+0.4382$<br>$=0.9382$<br>ខ. $P(Z>0.23)$<br>$=0.5-0.0910$<br>$=0.409$ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -ចូរប្អូនដោះស្រាយលំហាត់លេខ៣,៤,៥ទំព័រ១៧០និង ១៧១នៅផ្ទះ។ | កិច្ចការផ្ទះ | -សិស្សស្តាប់ការណែនាំរបស់គ្រូ |

# កិច្ចតែងការបង្រៀន

# ជំពូកទី៧៖ វ៉ិចទ័រក្នុងលំហ

# មេរៀនទី១៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ

## I. វត្ថុបំណងនៃមេរៀន

- ចំនេះដឹង: ពិពណ៌នា ពីនិយមន័យផលគុណនៃពីរវ៉ិចទ័រក្នុងលំហ
- បំនិន: បង្ហាញពីផលគុណវ៉ិចទ័រក្នុងលំហ
- ឥរិយាបថ: មានស្មារតីប្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់

## II. រយៈពេល ២ ម៉ោង

## III. ខ្លឹមសារមេរៀន

១. និយមន័យផលគុណនៃពីរវ៉ិចទ័រ

១.១.និយមន័យ

## IV. សម្ភារៈឧបទ្ទេស

- បន្ទាត់ សន្លឹកកម្រងសំណួរតម្រង់ទិសការពិភាក្សានិងលំហាត់ប្រតិបត្តិ
- សៀវភៅគ្រូទំព័រ ១៧៤-១៧៥
- សៀវភៅសិស្សទំព័រ ១៧៤-១៧៥

## V. ដំណើរការនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យថ្នាក់រៀន អនាម័យ វិន័យ សណ្តាប់ធ្នាប់ និង អវត្តមាន | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | -សិស្សក្រោកឈរ ប្រធានថ្នាក់ឡើងរាយការណ៍ |
| -គ្រូសួរសិស្សឲ្យរំលឹក និយមន័យផលគុណស្កាលែនៃពីរវ៉ិចទ័រក្នុងប្លង់ដែលមានពីរ វ៉ិ | ជំហានទី២<br>(រំលឹកមេរៀន) | -សិស្សឆ្លើយផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ គឺ |

| | | |
|---|---|---|
| ចទ័រ $\vec{a}$ និង $\vec{b}$ | | $\vec{a}.\vec{b}=\left\|\vec{a}\right\|\left\|\vec{b}\right\|\cos\alpha$ ដែល $\alpha$ ជា មុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ |
| -ណែនាំសិស្សឲ្យសង្កេតឧទាហរណ៍រួចតម្រូវឲ្យសិស្សទាញរកនិយមន័យវ៉ិចទ័រក្នុងលំហដូចខាងក្រោម៖ <br> $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$ និង <br> $\vec{V}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ ជាវ៉ិចទ័រ ក្នុងលំហ។ <br> ផលគុណនៃវ៉ិចទ័រ $\vec{U}$ និង $\vec{V}$ គឺជាវ៉ិចទ័រកំណត់ដោយ <br> $\vec{U}\times\vec{V}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$ <br><br> -បញ្ជាក់ប្រាប់សិស្សថាដើម្បីងាយស្រួលក្នុងការគណនាផលគុណនៃពីរវ៉ិចទ័រគេប្រើដេទែមីណង់លំដាប់បីដូចខាងក្រោម៖ <br> $\vec{U}\times\vec{V}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}$ <br> ដាក់កូអរដោនេវ៉ិចទ័រ $\vec{U}$ ក្នុងជួរដេកទីពីរនិងដាក់កូអរដោ-នេវ៉ិ | ជំហានទី៣ <br> (មេរៀនថ្មី) <br> ជំពូកទី៧៖ វ៉ិចទ័រក្នុងលំហ <br> មេរៀនទី១៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ <br> ១. និយមន័យផលគុណនៃពីរវ៉ិចទ័រ <br> ១.១ និយមន័យ | -សិស្សស្តាប់និងពិចារណា <br><br> -សិស្សស្តាប់ ពិចារណានិង កត់ត្រា |

| | | |
|---|---|---|
| ចទ័រ $\vec{V}$ ក្នុងជួរដេកទីបីនោះ គេបាន៖<br>$\vec{U}\times\vec{V}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}$<br>$=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}$<br>$+(u_1v_2-u_2v_1)\vec{k}$<br><br>$*$ សំគាល់: ដើម្បីងាយស្រួលក្នុងការគណនាផលគុណនៃពីរ វ៉ិចទ័រគេសន្មតប្រើដេទែមីណង់លំដាប់បីដូចខាងក្រោម៖<br>$\vec{U}\times\vec{V}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}$<br>ដាក់កូអរដោនេវ៉ិចទ័រ $\vec{U}$ ក្នុងជួរដេកទីពីរនិងដាក់កូអរដោនេ វ៉ិចទ័រ $\vec{V}$ ក្នុងជួរដេកទីបីនោះ គេបាន៖<br>$\vec{U}\times\vec{V}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}$<br>$=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}-\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}$<br>$+\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\u_1&u_2&u_3\\v_1&v_2&v_3\end{vmatrix}$<br>$=\begin{vmatrix}u_2&u_3\\v_2&v_3\end{vmatrix}\vec{i}-\begin{vmatrix}u_1&u_3\\v_1&v_3\end{vmatrix}\vec{j}$<br>$+\begin{vmatrix}u_1&u_2\\v_1&v_2\end{vmatrix}\vec{k}$<br>$=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}$<br>$+(u_1v_2-u_2v_1)\vec{k}$<br>-ណែនាំសិស្សអោយធ្វើលំហាត់ | | -សិស្សស្តាប់និងពិចារណាយ៉ាងយកចិត្តទុកដាក់ |

<table>
<tr>
<td>គំរូជាបុគ្គល<br>+លំហាត់គំរូ៖ គេឲ្យ<br>$\overrightarrow{U}=\vec{i}-2\vec{j}+\vec{k}$ និង<br>$\overrightarrow{V}=3\vec{i}+\vec{j}-2\vec{k}$ ។រកវ៉ិចទ័រ<br>ក.$\overrightarrow{U}\times\overrightarrow{V}$ ខ.$\overrightarrow{V}\times\overrightarrow{U}$ គ.$\overrightarrow{V}\times\overrightarrow{V}$</td>
<td>-គេឲ្យ<br>$\overrightarrow{U}=\vec{i}-2\vec{j}+\vec{k}$ និង<br>$\overrightarrow{V}=3\vec{i}+\vec{j}-2\vec{k}$ ។រកវ៉ិចទ័រ<br>ក.$\overrightarrow{U}\times\overrightarrow{V}$ ខ.$\overrightarrow{V}\times\overrightarrow{U}$<br>គ.$\overrightarrow{V}\times\overrightarrow{V}$<br>ចម្លើយ<br>ក.$\overrightarrow{U}\times\overrightarrow{V}=3\vec{i}+5\vec{j}+7\vec{k}$<br>ខ.$\overrightarrow{V}\times\overrightarrow{U}=-3\vec{i}-5\vec{j}-7\vec{k}$<br>គ.$\overrightarrow{V}\times\overrightarrow{V}=\vec{0}$</td>
<td>-សិស្សដោះស្រាយលំហាត់ជាបុគ្គល<br>ក. $\overrightarrow{U}\times\overrightarrow{V}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\1&-2&1\\3&1&-2\end{vmatrix}$<br>$=\begin{vmatrix}-2&1\\1&-2\end{vmatrix}\vec{i}-\begin{vmatrix}1&1\\3&-2\end{vmatrix}\vec{j}$<br>$+\begin{vmatrix}1&-2\\3&1\end{vmatrix}\vec{k}$<br>$=(4-1)\vec{i}-(-2-3)\vec{j}$<br>$+(1+6)\vec{k}$<br>$=3\vec{i}+5\vec{j}+7\vec{k}$<br>ខ.$\overrightarrow{V}\times\overrightarrow{U}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\3&1&-2\\1&-2&1\end{vmatrix}$<br>$=\begin{vmatrix}1&-2\\-2&1\end{vmatrix}\vec{i}-\begin{vmatrix}3&-2\\1&1\end{vmatrix}\vec{j}$<br>$+\begin{vmatrix}3&1\\1&-2\end{vmatrix}\vec{k}$<br>$=(1-4)\vec{i}-(3+2)\vec{j}$<br>$+(-6-1)\vec{k}$<br>$=-3\vec{i}-5\vec{j}-7\vec{k}$<br>គ.$\overrightarrow{V}\times\overrightarrow{V}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\3&1&-2\\3&1&-2\end{vmatrix}$<br>$=\begin{vmatrix}1&-2\\1&-2\end{vmatrix}\vec{i}-\begin{vmatrix}3&-2\\3&-2\end{vmatrix}\vec{j}$<br>$+\begin{vmatrix}3&1\\3&1\end{vmatrix}\vec{k}=\vec{0}$</td>
</tr>
<tr>
<td>-គ្រូដាក់លំហាត់ប្រតិបត្តិឲ្យសិស្សធ្វើជាក្រុមនៅលើក្តារខៀន</td>
<td>-ប្រតិបត្តិ: គេឲ្យ<br>$\overrightarrow{U}=\sqrt{2}\vec{i}+\sqrt{3}\vec{j}+2\vec{k}$ និង<br>$\overrightarrow{V}=-\vec{i}+\vec{j}$ ។<br>ចូរប្រៀបធៀប<br>$\left|\overrightarrow{U}\times\overrightarrow{V}\right|$ និង $\left|\overrightarrow{V}\times\overrightarrow{U}\right|$</td>
<td>-សិស្សដោះស្រាយលំហាត់ជាក្រុមហើយឡើងកែលើ ក្តារខៀន<br>ចម្លើយ<br>ប្រៀបធៀប</td>
</tr>
</table>

| | | |
|---|---|---|
| | | $\left\|\vec{U}\times\vec{V}\right\|$ និង $\left\|\vec{V}\times\vec{U}\right\|$<br>ដោយ $\vec{U}=\sqrt{2}\vec{i}+\sqrt{3}\vec{j}+2\vec{k}$<br>និង $\vec{V}=-\vec{i}+\vec{j}$ នោះ<br>$\vec{U}\times\vec{V}=-2\vec{i}-2\vec{j}$<br>$-\left(\sqrt{2}+\sqrt{3}\right)\vec{k}$<br>នាំឲ្យ<br>$\left\|\vec{U}\times\vec{V}\right\|=$<br>$\sqrt{(-2)^2+(-2)^2+\left(\sqrt{2}+\sqrt{3}\right)^2}$<br>$=\sqrt{13+2\sqrt{6}}$<br><br>តែ $\vec{V}\times\vec{U}=-\left(\vec{U}\times\vec{V}\right)$<br>នោះគេបាន<br>$\vec{V}\times\vec{U}=2\vec{i}+2\vec{j}+\left(\sqrt{2}+\sqrt{3}\right)\vec{k}$<br>នាំឲ្យ $\left\|\vec{V}\times\vec{U}\right\|=\sqrt{13+2\sqrt{6}}$<br>ដូចនេះ $\left\|\vec{U}\times\vec{V}\right\|=\left\|\vec{V}\times\vec{U}\right\|$ |
| -គ្រូដាក់លំហាត់ឲ្យសិស្សធ្វើតាមបុគ្គល | ជំហានទី៤<br>(ពង្រឹងចំនេះដឹង)<br>-គេឲ្យវ៉ិចទ័រ<br>$\vec{a}=-\vec{i}-\vec{j}+3\vec{k}$ និង<br>$\vec{b}=-5\vec{i}+5\vec{j}-4\vec{k}$ ។<br>ចូរប្រៀបធៀប $\left\|\vec{a}\times\vec{b}\right\|$ និង<br>$\left\|\vec{b}\times\vec{a}\right\|$ | -សិស្សដោះស្រាយតាមបុគ្គល<br>ចម្លើយ<br>ដោយ $\vec{a}\times\vec{b}=-11\vec{i}+11\vec{j}$<br>នាំឲ្យ $\left\|\vec{a}\times\vec{b}\right\|=\sqrt{(-11)^2+(11)^2}$<br>$=11\sqrt{2}$<br>ហើយ $\vec{b}\times\vec{a}=-\left(\vec{a}\times\vec{b}\right)$<br>$=11\vec{i}-11\vec{j}$<br>នាំឲ្យ $\left\|\vec{b}\times\vec{a}\right\|=\sqrt{(11)^2+(-11)^2}$<br>$=11\sqrt{2}$<br>ដូចនេះ $\left\|\vec{a}\times\vec{b}\right\|=\left\|\vec{b}\times\vec{a}\right\|$ |
| -ដាក់លំហាត់កិច្ចការផ្ទះឲ្យសិស្សយកទៅអនុវត្តន៍តាមផ្ទះ | ជំហានទី៥<br>(កិច្ចការផ្ទះ) | -សិស្សយកទៅអនុវត្តន៍តាមផ្ទះ |

| | | |
|---|---|---|
| | -គេឲ្យវ៉ិចទ័រ<br>$\vec{u}=2\vec{i}-3\vec{j}+\vec{k}$ និង<br>$\vec{v}=\vec{i}-2\vec{j}+\vec{k}$<br>ចូរប្រៀបធៀប $\left\|\vec{u}\times\vec{v}\right\|$ និង<br>$\left\|\vec{v}\times\vec{u}\right\|$ | |

# កិច្ចតែងការបង្រៀន

# ជំពូកទី៧៖ វ៉ិចទ័រក្នុងលំហ

## មេរៀនទី១៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ

## I. វត្ថុបំណងនៃមេរៀន

- ចំនេះដឹង: បង្ហាញពីលក្ខណៈផលគុណនៃពីរវ៉ិចទ័រ
- បំនិន: ពិពណ៌នាអំពីលក្ខណៈផលគុណវ៉ិចទ័រ
- ឥរិយាបថ: មានស្មារតីប្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់

## II. រយៈពេល ២ ម៉ោង

## III. ខ្លឹមសារមេរៀន

២. លក្ខណៈផលគុណនៃពីរវ៉ិចទ័រ

៣.បំណកស្រាយផលគុណនៃពីរវ៉ិចទ័រតាមបែបធរណីមាត្រ

## IV. សម្ភារៈឧបទ្ទេស

- បន្ទាត់
- សៀវភៅគ្រូទំព័រ ១៧៦-១៧៧
- សៀវភៅសិស្សទំព័រ ១៧៦-១៧៧

## V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យថ្នាក់រៀន អនាម័យ វិន័យ សណ្តាប់ធ្នាប់ និង អវត្តមាន | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | -សិស្សក្រោកឈរ ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ឲ្យសិស្សឡើងកែលំហាត់កិច្ចការផ្ទះ | ជំហានទី២<br>(រំលឹកមេរៀន)<br>-គេឲ្យវ៉ិចទ័រ<br>$\vec{u}=2\vec{i}-3\vec{j}+\vec{k}$ និង<br>$\vec{v}=\vec{i}-2\vec{j}+\vec{k}$<br>ចូរប្រៀបធៀប $\left\|\vec{u}\times\vec{v}\right\|$ និង | -សិស្សឡើងកែលំហាត់កិច្ចការផ្ទះ<br><br>ចម្លើយ<br>ចូរប្រៀបធៀប $\left\|\vec{u}\times\vec{v}\right\|$ និង |

| | | |
|---|---|---|
| | $\left\|\vec{v}\times\vec{u}\right\|$<br>**ចម្លើយ**<br>$\left\|\vec{u}\times\vec{v}\right\| = \left\|\vec{v}\times\vec{u}\right\|$ | $\left\|\vec{v}\times\vec{u}\right\|$<br>**ដោយ** $\vec{u}=2\vec{i}-3\vec{j}+\vec{k}$ **និង**<br>$\vec{v}=\vec{i}-2\vec{j}+\vec{k}$<br>**យើងបាន**<br>$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & -3 & 1\\ 1 & -2 & 1\end{vmatrix}$<br>$=\begin{vmatrix}-3 & 1\\ -2 & 1\end{vmatrix}\vec{i}-\begin{vmatrix}2 & 1\\ 1 & 1\end{vmatrix}\vec{j}$<br>$+\begin{vmatrix}2 & -3\\ 1 & -2\end{vmatrix}\vec{k}$<br>$=(-3+2)\vec{i}-(2-1)\vec{j}$<br>$+(-4+3)\vec{k}$<br>$=-\vec{i}-\vec{j}-\vec{k}$<br>$\vec{v}\times\vec{u}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -2 & 1\\ 2 & -3 & 1\end{vmatrix}$<br>$=\begin{vmatrix}-2 & 1\\ -3 & 1\end{vmatrix}\vec{i}-\begin{vmatrix}1 & 1\\ 2 & 1\end{vmatrix}\vec{j}$<br>$+\begin{vmatrix}1 & -2\\ 2 & -3\end{vmatrix}\vec{k}$<br>$=(-2+3)\vec{i}-(1-2)\vec{j}$<br>$+(-3+4)\vec{k}$<br>$=\vec{i}+\vec{j}+\vec{k}$<br>**នាំឲ្យ** $\left\|\vec{u}\times\vec{v}\right\|=\sqrt{(-1)^2+(-1)^2+(-1)^2}$<br>$=\sqrt{3}$<br>$\left\|\vec{v}\times\vec{u}\right\|=\sqrt{1^2+1^2+1^2}$<br>$=\sqrt{3}$<br>**ដូចនេះ** $\left\|\vec{u}\times\vec{v}\right\| = \left\|\vec{v}\times\vec{u}\right\|$ |

| | | |
|---|---|---|
| | ជំហានទី៣<br>(មេរៀនថ្មី)<br>ជំពូកទី៧៖ វ៉ិចទ័រក្នុងលំហ<br>មេរៀនទី១៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ<br>២. លក្ខណៈផលគុណនៃពីរវ៉ិចទ័រ | |
| -គ្រូកត់លក្ខណៈផលគុណនៃពីរវ៉ិចទ័រលើក្តារខៀន | -លក្ខណៈផលគុណនៃពីរវ៉ិចទ័រ<br>បើ $\vec{U}$ ,$\vec{V}$ និង$\vec{W}$ ជាវ៉ិចទ័រនៅក្នុងលំហនិង $c$ ជាចំនួនពិតនោះគេបាន:<br>ក. $\vec{U}\times\vec{V}=-\left(\vec{V}\times\vec{U}\right)$<br>ខ. $\vec{U}\times\left(\vec{V}+\vec{W}\right)=\vec{U}\times\vec{V}+\vec{U}\times\vec{W}$<br>គ. $C\left(\vec{U}\times\vec{V}\right)=\left(C\vec{U}\right)\times\vec{V}$<br>$=\vec{U}\times\left(C\vec{V}\right)$<br>ឃ. $\vec{U}\times\vec{0}=\vec{0}\times\vec{U}=\vec{0}$<br>ង. $\vec{U}\times\vec{U}=\vec{0}$<br>ច.$\vec{U}.\left(\vec{V}\times\vec{W}\right)=\left(\vec{U}\times\vec{V}\right).\vec{W}$ | -សិស្សស្តាប់ ពិចារណានិងកត់ត្រាទុក<br><br>-សិស្សសង្កេតនិងពិចារណាយ៉ាងយកចិត្តទុកដាក់ |
| -គ្រូឲ្យសិស្សសង្កេតលក្ខណៈនិងពីការបកស្រាយលក្ខណៈ ក.<br>សម្រាយបញ្ជាក់<br>ក. តាង $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$<br>និង $\vec{V}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$<br>គេបាន:<br>$\vec{U}\times\vec{V}=\left(u_2v_3-u_3v_2\right)\vec{i}-$<br>$\left(u_1v_3-u_3v_1\right)\vec{j}+\left(u_1v_2-u_2v_1\right)\vec{k}$<br>និង | | |

<table>
<tr>
<td>$\vec{V}\times\vec{U}=(v_2u_3-v_3u_2)\vec{i}-$<br>$(v_1u_3-v_3u_1)\vec{j}+(v_1u_2-v_2u_1)\vec{k}$<br>នាំឲ្យ $\vec{U}\times\vec{V}=-(\vec{V}\times\vec{U})$<br>-គ្រូឲ្យសិស្សបកស្រាយ<br>លក្ខណៈបន្តតាមបុគ្គល<br>ខ. $\vec{U}\times(\vec{V}+\vec{W})=\vec{U}\times\vec{V}+\vec{U}\times\vec{W}$<br>គ. $c(\vec{U}\times\vec{V})=(c\vec{U})\times\vec{V}$<br>$=\vec{U}\times(c\vec{V})$<br>ឃ. $\vec{U}\times\vec{0}=\vec{0}\times\vec{U}=\vec{0}$<br>ង. $\vec{U}\times\vec{U}=\vec{0}$<br>ច. $\vec{U}.(\vec{V}\times\vec{W})=(\vec{U}\times\vec{V}).\vec{W}$</td>
<td></td>
<td>-សិស្សបកស្រាយលំហាត់លើ<br>ក្ដារខៀន<br>ចម្លើយ<br>ខ. តាង $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$<br>, $\vec{V}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ និង<br>$\vec{W}=w_1\vec{i}+w_2\vec{j}+w_3\vec{k}$<br>នោះគេបាន:<br>$\vec{V}+\vec{W}=(v_1+w_1)\vec{i}+$<br>$(v_2+w_2)\vec{j}+(v_3+w_3)\vec{k}$<br>នាំឲ្យ<br>$\vec{U}\times(\vec{V}+\vec{W})=\left[u_2(v_3+w_3)-u_3(v_2+w_2)\right]\vec{i}$<br>$-\left[u_1(v_3+w_3)-u_3(v_1+w_1)\right]\vec{j}+$<br>$\left[u_1(v_2+w_2)-u_2(v_1+w_1)\right]\vec{k}$<br>$=[(u_2v_3-u_3v_2)\vec{i}-$<br>$(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}]$<br>$+[(u_2w_3-u_3w_2)\vec{i}-$<br>$(u_1w_3-u_3w_1)\vec{j}+(u_1w_2-u_2w_1)\vec{k}]$<br>$=\vec{U}\times\vec{V}+\vec{U}\times\vec{W}$ ។<br>គ. តាង $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$<br>$\vec{V}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ និង $c$ ជាចំនួនថេរ<br>គេបាន:<br>$c(\vec{U}\times\vec{V})=c(u_2v_3-u_3v_2)\vec{i}-$<br>$c(u_1v_3-u_3v_1)\vec{j}+c(u_1v_2-u_2v_1)\vec{k}$<br>$=(cu_2v_3-cu_3v_2)\vec{i}-$<br>$(cu_1v_3-cu_3v_1)\vec{j}+(cu_1v_2-cu_2v_1)\vec{k}$<br>$=(c\vec{U})\times\vec{V}$<br>ឃ. តាង $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$ និង<br>$\vec{0}=0\vec{i}+0\vec{j}+0\vec{k}$<br>គេបាន<br>$\vec{U}\times\vec{0}=(u_2 0-u_3 0)\vec{i}-$<br>$(u_1 0-u_3 0)\vec{j}+(u_1 0-u_2 0)\vec{k}=\vec{0}$<br>និង</td>
</tr>
</table>

| | | |
|---|---|---|
| | | $\vec{0}\times\vec{U}=(0u_2-0u_3)\vec{i}-$<br>$(0u_1-0u_3)\vec{j}+(0u_1-0u_2)\vec{k}=\vec{0}$<br>នាំឲ្យ $\vec{U}\times\vec{0}=\vec{0}\times\vec{U}=\vec{0}$ ។<br>ង. តាង $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$<br>គេបាន<br>$\vec{U}\times\vec{U}=(u_2u_3-u_3u_2)\vec{i}-$<br>$(u_1u_3-u_3u_1)\vec{j}+(u_1u_2-u_2u_1)\vec{k}=\vec{0}$<br>ដូចនេះ $\vec{U}\times\vec{U}=\vec{0}$ ។<br>ច. តាង $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$<br>, $\vec{V}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ និង<br>$\vec{W}=w_1\vec{i}+w_2\vec{j}+w_3\vec{k}$<br>នោះគេបាន:<br>$\vec{V}\times\vec{W}=(v_2w_3-v_3w_2)\vec{i}-$<br>$(v_1w_3-v_3w_1)\vec{j}+(v_1w_2-v_2w_1)\vec{k}$<br>នាំឲ្យ<br>$\vec{U}.(\vec{V}\times\vec{W})=u_1(v_2w_3-v_3w_2)-$<br>$u_2(v_1w_3-v_3w_1)+u_3(v_1w_2-v_2w_1)$<br>$=u_1v_2w_3-u_1v_3w_2-u_2v_1w_3$<br>$+u_2v_3w_1+u_3v_1w_2-u_3v_2w_1 \quad (1)$<br>ហើយ<br>$\vec{U}\times\vec{V}=(u_2v_3-u_3v_2)\vec{i}-$<br>$(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$<br>នាំឲ្យ<br>$(\vec{U}\times\vec{V}).\vec{W}=(u_2v_3-u_3v_2)w_1-$<br>$(u_1v_3-u_3v_1)w_2+(u_1v_2-u_2v_1)w_3$<br>$=u_2v_3w_1-u_3v_2w_1-u_1v_3w_2$<br>$+u_3v_1w_2+u_1v_2w_3-u_2v_1w_3 \quad (2)$<br>តាម $(1)$ និង $(2)$ គេបាន:<br>$\vec{U}.(\vec{V}\times\vec{W})=(\vec{U}\times\vec{V}).\vec{W}$ ។ |
| | ៣.បំណកស្រាយផលគុណនៃពីរវ៉ិចទ័រ | |

| | | |
|---|---|---|
| -គ្រូគូររូបលើក្ដារខៀនហើយប្រាប់សិស្សឲ្យសង្កេតរួចទាញរកផលគុណនីមួយៗតាមបែបធរណីមាត្រ | តាមបែបធរណីមាត្រ | -សិស្សសង្កេតមើលហើយទាញតាមគ្រូពន្យល់ |
| -គ្រូដាក់លំហាត់ឲ្យសិស្ស អនុវត្តន៍ | ជំហានទី៤<br>(ពង្រឹងចំនេះដឹង)<br>-លំហាត់:<br>គេឲ្យវ៉ិចទ័រ<br>$\vec{p}=(3,1,-2)$<br>; $\vec{q}=(-4,0,3)$<br>; $\vec{a}=(1,-3,1)$ និង<br>$\vec{b}=(-3,-2,-3)$ ។<br>ចូររក $\lvert\vec{a}\times\vec{b}\rvert$ និង<br>$\lvert\vec{p}\times\vec{q}\rvert$<br>ចម្លើយ<br>$\lvert\vec{a}\times\vec{b}\rvert=11\sqrt{2}$<br>$\lvert\vec{p}\times\vec{q}\rvert=\sqrt{26}$ | -សិស្សឡើងដោះស្រាយលំហាត់លើក្ដារខៀន<br>ចម្លើយ<br>ដោយ $\vec{a}\times\vec{b}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -3 & 1\\ -3 & -2 & -3\end{vmatrix}$<br>$=-11\vec{i}+11\vec{k}$<br>នាំឲ្យ $\lvert\vec{a}\times\vec{b}\rvert=\sqrt{(-11)^2+(11)^2}$<br>$=11\sqrt{2}$<br>ហើយ $\vec{p}\times\vec{q}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 3 & 1 & -2\\ -4 & 0 & 3\end{vmatrix}$<br>$=3\vec{i}-\vec{j}+4\vec{k}$<br>នាំឲ្យ $\lvert\vec{p}\times\vec{q}\rvert=\sqrt{3^2+(-1)^2+4^2}$<br>$=\sqrt{26}$ |
| | ជំហានទី៥ | |

| | | |
|---|---|---|
| -ពេលទៅដល់ផ្ទះវិញចូរប្អូនមើលមេរៀនឡើងវិញនិងរំលឹកពីរបៀបគណនាផ្ទៃក្រលានៃត្រីកោណដោយស្គាល់កូអរដោនេនៃកំពូលទាំងបី | (កិច្ចការផ្ទះ) | -សិស្សស្តាប់និងកត់ត្រាទុក |

# កិច្ចតែងការបង្រៀន

# ជំពូកទី៧៖ វ៉ិចទ័រក្នុងលំហ

# មេរៀនទី១៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ

## I. វត្ថុបំណងនៃមេរៀន

- ចំនេះដឹង: បង្ហាញពីលក្ខណ:ផលគុណនៃពីរវ៉ិចទ័រតាមបែបធរណីមាត្រ
- បំនិន: ពិពណ៌នាពីផលគុណនៃពីរវ៉ិចទ័របែបធរណីមាត្រ
- ឥរិយាបថ: មានស្មារតីប្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់

## II. រយៈពេល ២ ម៉ោង

## III. ខ្លឹមសារមេរៀន

៣.បំណកស្រាយផលគុណនៃពីរវ៉ិចទ័រតាមបែបធរណីមាត្រ

ក. $\vec{u}\times\vec{v}$ អរតូកូណាល់ទៅនិង $\vec{u}$ ផងនិង $\vec{v}$ ផង

ខ. $\left|\vec{u}\times\vec{v}\right| = \left|\vec{u}\right|.\left|\vec{v}\right|\sin\theta$

គ. ដោយប្រលេឡូក្រាមសង់លើវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ហើយ $\theta$ ជាមុំដែលផ្គុំឡើងរវាង $\vec{u}$ និង $\vec{v}$

## IV. សម្ភារៈឧបទេ្ទសៀ

- បន្ទាត់ សន្លឹកកម្រងសំនួរពិភាក្សានិងលំហាត់ប្រតិបត្តិ
- សៀវភៅគ្រូទំព័រ ១៧៨-១៨០
- សៀវភៅសិស្សទំព័រ ១៧៨-១៨០

## V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យថ្នាក់រៀន អនាម័យ វិន័យ សណ្តាប់ធ្នាប់ និង អវត្តមាន | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | -សិស្សក្រោកឈរ ប្រធានថ្នាក់ឡើងរាយការណ៍ |
| | ជំហានទី២ | |

| | | |
|---|---|---|
| -គ្រូសួរសិស្សឲ្យគណនាផ្ទៃក្រឡានៃត្រីកោណ $ABC$ និងកត់ត្រាលំហាត់លើក្តារខៀន | (រំលឹកមេរៀន)<br>-លំហាត់<br>ចូរគណនាផ្ទៃក្រឡាត្រីកោណ $ABC$ ដោយដឹងថា $A(0,0,2)$ ; $B(1,2,4)$ និង $C(1,-2,0)$<br>ចម្លើយ<br>$S_{ABC}=2\sqrt{2}$ ឯកតាផ្ទៃ | -សិស្សឡើងឡើងដោះស្រាយលើក្តារខៀន<br>ចម្លើយ<br>ដោយ $\overrightarrow{AB}=(1,2,2)$<br>; $\overrightarrow{AC}=(1,-2,-2)$<br>យើងបាន<br>$\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 1 & 2 & 2 \\ 1 & -2 & -2 \end{vmatrix}$<br>$=4\vec{j}-4\vec{k}$<br>នាំឲ្យ $\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|=\sqrt{4^2+(-4)^2}$<br>$=4\sqrt{2}$<br>ដូចនេះ $S_{\Delta ABC}=\frac{1}{2}\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|$<br>$=\frac{1}{2}(4\sqrt{2})$<br>$=2\sqrt{2}$ ឯកតាផ្ទៃ |
| -គ្រូគូររូបង្ហាញ<br><br><br>-ណែនាំសិស្សឲ្យស្រាយបញ្ជាក់ផលគុណនៃពីរ | ជំហានទី៣<br>(មេរៀនថ្មី)<br>ជំពូកទី៧៖ វ៉ិចទ័រក្នុងលំហ<br>មេរៀនទី១៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ<br>៣. លក្ខណៈផលគុណនៃពីរវ៉ិចទ័រតាមបែបធរណីមាត្រ | |

| | | |
|---|---|---|
| វ៉ិចទ័រតាមបែបធរណីមាត្រ ដូចខាងក្រោម៖<br>$*$ បើ $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រក្នុងលំហ និង $\theta$ ជាមុំដែលផ្គុំឡើង រវាង $\vec{u}$ និង $\vec{v}$ នោះគេបាន:<br>ក. $\vec{u}\times\vec{v}$ អរតូកូណាល់ទៅនិង $\vec{u}$ ផងនិង $\vec{v}$ ផង<br>- បង្ហាញថា $\vec{w}=\vec{u}\times\vec{v}$ កែងនិង $\vec{u}$ និង $\vec{v}$<br>-តាង $\vec{w}=\vec{u}\times\vec{v}$ ដែល $\vec{u}=(x,y,z)$ និង $\vec{v}=(x',y',z')$<br>នាំឲ្យ<br>$\vec{w}=\vec{u}\times\vec{v}$<br>$=(yz'-zy')\vec{i}-$<br>$(xz'-zx')\vec{j}+(xy'-yx')\vec{k}$<br>គេបាន<br>$\vec{w}.\vec{u}=(yz'-zy')x-$<br>$(xz'-zx')y+(xy'-yx')z$<br>$=yz'x-zy'x-xz'y$<br>$+zx'y+xy'z-yx'z$<br>$=0$<br>ដូចនេះ $\vec{w}\perp\vec{u}$ ។<br>ម្យ៉ាងទៀត<br>$\vec{w}.\vec{v}=(yz'-zy')x'-$<br>$(xz'-zx')y'+(xy'-yx')z'$<br>$=yz'x'-zy'x'-xz'y'$<br>$+zx'y'+xy'z'-yx'z'$<br>$=0$<br>ដូចនេះ $\vec{w}\perp\vec{v}$ ។<br>ខ. $\left\|\vec{u}\times\vec{v}\right\|=\left\|\vec{u}\right\|\left\|\vec{v}\right\|\sin\theta$<br>- បង្ហាញថា $\left\|\vec{u}\times\vec{v}\right\|=\left\|\vec{u}\right\|\left\|\vec{v}\right\|\sin\theta$<br>-យក $\vec{u}=(u_1,u_2,u_3)$ និង $\vec{v}=(v_1,v_2,v_3)$<br>យើងមាន | | -សិស្សស្តាប់ ពិចារណានិងកត់ត្រាទុក |

| | | |
|---|---|---|
| $\|\vec{u}\|\|\vec{v}\|\sin\theta = \|\vec{u}\|\|\vec{v}\|\sqrt{1-\cos^2\theta}$<br>$=\|\vec{u}\|\|\vec{v}\|\sqrt{1-\dfrac{\left(\vec{u}.\vec{v}\right)^2}{\|\vec{u}\|^2\|\vec{v}\|^2}}$<br>(ព្រោះ $\vec{u}.\vec{v}=\|\vec{u}\|\|\vec{v}\|\cos\theta$)<br>$=\sqrt{\|\vec{u}\|^2\|\vec{v}\|^2-\left(\vec{u}.\vec{v}\right)^2}$<br>$=\sqrt{\left(u_1^2+u_2^2+u_3^2\right)\left(v_1^2+v_2^2+v_3^2\right)}$<br>$\overline{-\left(u_1v_1+u_2v_2+u_3v_3\right)^2}$<br>$=\sqrt{(u_2v_3-u_3v_2)^2+}$<br>$\overline{+(u_1v_3-u_3v_1)^2+(u_1v_2-u_2v_1)^2}$<br>$=\|\vec{u}\times\vec{v}\|$<br>ដូចនេះ $\|\vec{u}\times\vec{v}\|=\|\vec{u}\|\|\vec{v}\|\sin\theta$ ។<br>-ណែនាំសិស្សស្រាយ គ. ឃ. និង ង. តាមបុគ្គល<br>-ណែនាំសិស្សពឲ្យសង្កេតពីវិបាកបើ $\vec{n}$ ជាវ៉ិចទ័រឯកតាហើយអរតូកូណាល់ទៅនិង $\vec{u}$ ផងនិង $\vec{v}$ ផងនោះ $\vec{u}\times\vec{v}=\pm\left(\|\vec{u}\times\vec{v}\|\vec{n}\right)$<br>ឬ $\vec{u}\times\vec{v}=\pm\left(\|\vec{u}\|\|\vec{v}\|\sin\theta\right)\vec{n}$<br>-ណែនាំសិស្សធ្វើលំហាត់គំរូទី១ ទីនិង ទី៣ ជាដៃគូ | | -សិស្សស្តាប់និងពិចារណាយ៉ាងយកចិត្តទុកដាក់ |
| -គ្រូដាក់លំហាត់ប្រតិបត្តិឲ្យសិស្សធ្វើតាមក្រុម<br>ប្រតិបត្តិ<br>ក. គេឲ្យបីចំនុច $A(1,1,1)$ ;$B(2,0,3)$ និង $C(-1,2,0)$ នៅក្នុងលំហ។រកផ្ទៃក្រឡាត្រីកោណ $ABC$ ។<br>ខ. បង្ហាញថាចតុកោណដែល | ជំហានទី៤<br>(ពង្រឹងពុទ្ធិ)<br>ចម្លើយ<br>ក. $S_{\Delta ABC}=\dfrac{\sqrt{3}}{2}$ ឯកតាផ្ទៃ<br>ខ. $S_{ABCD}=2\sqrt{259}$ ឯកតាផ្ទៃ | -តំណាងក្រុមឡើងដោះស្រាយលំហាត់លើក្តារខៀន<br>ចម្លើយ<br>ក. រកផ្ទៃក្រឡាត្រីកោណ $ABC$<br>ដោយ $\overrightarrow{AB}=(1,-1,2)$ និង $\overrightarrow{AC}=(-2,1,-1)$<br>គេបាន |

| | | |
|---|---|---|
| មានកំពូលត្រង់ចំណុច $A(5,2,0)$ ; $B(2,6,1)$; $C(2,4,7)$ និង $D(5,0,6)$ ជាប្រលេឡូក្រាម រួចរកផ្ទៃក្រឡានៃប្រលេឡូក្រាមនោះ។ | | $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -1 & 2\\ -2 & 1 & -1\end{vmatrix}$ <br> $=\begin{vmatrix}-1 & 2\\ 1 & -1\end{vmatrix}\vec{i}-\begin{vmatrix}1 & 2\\ -2 & -1\end{vmatrix}\vec{j}$ <br> $+\begin{vmatrix}1 & -1\\ -2 & 1\end{vmatrix}\vec{k}$ <br> $=-\vec{i}-3\vec{j}-\vec{k}$ <br> នាំឲ្យ <br> $\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|=\sqrt{(-1)^2+(-3)^2+(-1)^2}$ <br> $=\sqrt{11}$ <br> ដូចនេះ $S_{\Delta ABC}=\frac{1}{2}\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|$ <br> $=\frac{1}{2}\sqrt{11}$ ឯកតាផ្ទៃ។ <br> ខ. បង្ហាញថា $ABCD$ ជាប្រលេឡូក្រាម រួចរកផ្ទៃក្រឡានៃប្រលេឡូក្រាមនេះ <br> ដោយ $\overrightarrow{AB}=(-3,4,1)$ និង $\overrightarrow{DC}=(-3,4,1)$ គេបាន: <br> $\overrightarrow{AB}=\overrightarrow{DC}$ នោះ $ABCD$ ជាប្រលេឡូក្រាមដែលសង់លើវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AD}$ <br> ម្យ៉ាងទៀត $\overrightarrow{AD}=(0,-2,6)$ <br> យើងបាន $\overrightarrow{AB}\times\overrightarrow{AD}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -3 & 4 & 1\\ 0 & -2 & 6\end{vmatrix}$ <br> $=\begin{vmatrix}4 & 1\\ -2 & 6\end{vmatrix}\vec{i}-\begin{vmatrix}-3 & 1\\ 0 & 6\end{vmatrix}\vec{j}+\begin{vmatrix}-3 & 4\\ 0 & -2\end{vmatrix}\vec{k}$ <br> $=26\vec{i}+18\vec{j}+6\vec{k}$ <br> គេបាន <br> $\left\|\overrightarrow{AB}\times\overrightarrow{AD}\right\|=\sqrt{26^2+18^2+6^2}$ <br> $=\sqrt{1036}=2\sqrt{259}$ <br> ដូចនេះ ផ្ទៃក្រលារបស់ប្រលេឡូក្រាម $ABCD$ គឺ $S_{ABCD}=2\sqrt{259}$ ឯកតាផ្ទៃ។ |

| | | |
|---|---|---|
| -គណនាផ្ទៃក្រលាត្រីកោណ $ABC$ ដែល $A(0,0,2)$ ; $B(1,2,4)$ និង $C(1,-2,0)$ ចូរប្អូនដល់ផ្ទះមើលមេរៀនឡើងវិញហើយធ្វើលំហាត់នេះផង | ជំហានទី៥ (កិច្ចការផ្ទះ) | -សិស្សកត់ត្រាទុក និងស្តាប់ដំបូន្មានគ្រូ |

# កិច្ចតែងការបង្រៀន

# ជំពូកទី៧៖ វិចទ័រក្នុងលំហ

# មេរៀនទី១៖ ផលគុណនៃពីរវិចទ័រក្នុងលំហ

## I. វត្ថុបំណងនៃមេរៀន

- ចំនេះដឹង: ពិពណ៌នាពីផលគុណនៃពីរវិចទ័រក្នុងរូបវិទ្យា
- បំនិន: បង្ហាញពីផលគុណចម្រុះនៃបីវិចទ័រក្នុងលំហ
- ឥរិយាបថ: មានស្មារតីប្រុងប្រយ័ត្នក្នុងការដោះស្រាយលំហាត់

## II. រយៈពេល ២ ម៉ោង

## III. ខ្លឹមសារមេរៀន

៤. អនុវត្តន៍ផលគុណនៃពីរវិចទ័រក្នុងរូបវិទ្យា

៥. ផលគុណចម្រុះនៃបីវិចទ័រក្នុងលំហ

៥.១ និយមន័យ

៥.២ ទ្រឹស្តីបទទី១

៥.៣ ទ្រឹស្តីបទទី២

## IV. សម្ភារៈឧបទ្ទេស

- បន្ទាត់ សន្លឹកកម្រងសំណួរតម្រង់ទិស ការពិភាក្សានិងសង្កេត
- សៀវភៅគ្រូទំព័រ ១៨០-១៨២
- សៀវភៅសិស្សទំព័រ ១៨០-១៨២

## V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យថ្នាក់រៀន អនាម័យ វិន័យ សណ្តាប់ធ្នាប់ និង អវត្តមាន | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | -សិស្សក្រោកឈរ ប្រធានថ្នាក់ឡើងរាយការណ៍ |

| | | |
|---|---|---|
| គ្រូកត់លំហាត់កិច្ចការផ្ទះលើក្ដារខៀន<br>-គណនាផ្ទៃក្រលាត្រីកោណ $ABC$ ដែល $A(0,0,2)$<br>;$B(1,2,4)$ និង $C(1,-2,0)$ | ជំហានទី២<br>(រំលឹកមេរៀន) | -សិស្សឡើងឡើងដោះស្រាយលើក្ដារខៀន<br>ចម្លើយ<br>ដោយ $\overrightarrow{AB}=(1,2,2)$<br>;$\overrightarrow{AC}=(1,-2,-2)$<br>យើងបាន<br>$\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 2 & 2\\ 1 & -2 & -2\end{vmatrix}$<br>$=4\vec{j}-4\vec{k}$<br>នាំឲ្យ $\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|=\sqrt{4^2+(-4)^2}$<br>$=4\sqrt{2}$<br>ដូចនេះ $S_{\Delta ABC}=\frac{1}{2}\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|$<br>$=\frac{1}{2}\left(4\sqrt{2}\right)$<br>$=2\sqrt{2}$ ឯកតាផ្ទៃ |
| -គ្រូគូររូបលើក្ដារខៀន<br><br><br>-ណែនាំសិស្សឲ្យសង្កេតរូបរួច | ជំហានទី៣<br>(មេរៀនថ្មី)<br>ជំពូកទី៧៖ វ៉ិចទ័រក្នុងលំហ<br>មេរៀនទី១៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ<br>៩. អនុវត្តន៍ផលគុណនៃពីរវ៉ិចទ័រក្នុងរូបវិទ្យា | -សិស្សសង្កេតនិងពិចារណាយ៉ាងយក |

| | | |
|---|---|---|
| តម្រូវឲ្យសិស្សទាញថាបើ $Q$ ជាចំណុចចាប់នៃកម្លាំង $\vec{F}$ នោះ ម៉ូម៉ង់នៃកម្លាំង $\vec{F}$ ត្រង់ $P$ គឺ $\left\|\vec{M}\right\|=\left\|\overrightarrow{PQ}\times\vec{F}\right\|$<br>-ណែនាំសិស្សឲ្យធ្វើលំហាត់គំរូ ១ តាមបុគ្គល | | ចិត្តទុកដាក់<br>-សិស្សដោះស្រាយលំហាត់រៀងៗខ្លួន |
| -ណែនាំសិស្សឲ្យទាញរកនិយមន័យថាបើមានវ៉ិចទ័រ $\vec{u};\vec{v}$ និង $\vec{w}$ នៅក្នុងលំហនោះ ផលគុណចម្រុះនៃ $\vec{u};\vec{v}$ និង $\vec{w}$ តាមលំដាប់គឺជាចំនួនពិតដែលកំណត់ដោយ $\vec{u}.\left(\vec{v}\times\vec{w}\right)$ ។ | ៥. ផលគុណចម្រុះនៃបីវ៉ិចទ័រក្នុងលំហ<br>៥.១ និយមន័យ | -សិស្សសង្កេតមើលនិងពិចារណារ |
| -ណែនាំសិស្សឲ្យទាញរកទ្រឹស្តីបទថា បើគេមានវ៉ិចទ័រ $\vec{U}=u_1\vec{i}+u_2\vec{j}+u_3\vec{k}$ , $\vec{V}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ និង $\vec{W}=w_1\vec{i}+w_2\vec{j}+w_3\vec{k}$ នោះ $\vec{u}.\left(\vec{v}\times\vec{w}\right)=\begin{vmatrix}u_1&u_2&u_3\\v_1&v_2&v_3\\w_1&w_2&w_3\end{vmatrix}$<br>-ប្រាប់សិស្សបើវ៉ិចទ័រ $\vec{u};\vec{v}$ និង $\vec{w}$ មិននៅក្នុងប្លង់តែមួយនោះ ផលគុណចម្រុះនៃបីវ៉ិចទ័រ $\vec{u};\vec{v}$ និង $\vec{w}$ តាមលំដាប់គឺជាមាឌរបស់ប្រលេពីប៉ែតដែលសង់លើ $\vec{u};\vec{v}$ និង $\vec{w}$ ។ | ៥.២ ទ្រឹស្តីបទទី១ | -សិស្សមើលសៀវភៅទំព័រ ១៨១<br>-សិស្សស្តាប់ សង្កេតនិងពិចារណាឮ |
| | ៥.៣ ទ្រឹស្តីបទទី២ (បំណាកស្រាយតាមផល | |

| | | |
|---|---|---|
| -ណែនាំសិស្សឲ្យទាញរកទ្រឹស្តីបទថាមាឌ $V$ របស់ប្រលេពីប៉ែតដែលសង់លើវ៉ិចទ័រ $\vec{u};\vec{v}$ និង $\vec{w}$ គឺ $V=\left\|\vec{u}.\left(\vec{v}\times\vec{w}\right)\right\|$ និងមាឌ $W$ របស់តេត្រាអែតគឺ $W=\frac{\left\|\vec{u}.\left(\vec{v}\times\vec{w}\right)\right\|}{6}$ ។<br>-ប្រាប់សិស្សឲ្យពិនិត្យមើលលំហាត់គំរូ<br>-គ្រូដាក់លំហាត់ប្រតិបត្តិឲ្យសិស្សធ្វើតាមក្រុម<br>ប្រតិបត្តិ<br>រកមាឌប្រលេពីប៉ែតដែលមានជ្រុងជាប់ $\vec{u};\vec{v}$ និង $\vec{w}$ ដូចខាងក្រោម៖<br>ក. $\vec{u}=\vec{i}+\vec{j}\ ,\vec{v}=\vec{j}+\vec{k}$<br>ខ. $\vec{u}=(1,3,1);\vec{v}=(0,5,5)$ និង $\vec{w}=(4,0,4)$ | គុណចម្រុះនៃបីវ៉ិចទ័រ)<br>ចម្លើយ<br>ក. ដោយ $\vec{u}.\left(\vec{v}\times\vec{w}\right)=2$ នាំឲ្យមាឌប្រលេពីប៉ែតគឺ $V=2$ ឯកតាមាឌ<br>ខ. $V=60$ ឯកតាមាឌ | ចម្លើយ<br>ក. ដោយ $\vec{u}.\left(\vec{v}\times\vec{w}\right)=2$ នាំឲ្យមាឌប្រលេពីប៉ែតគឺ $V=2$ ឯកតាមាឌ<br>ខ. $V=60$ ឯកតាមាឌ |
| -គ្រូដាក់លំហាត់ឲ្យសិស្សធ្វើតាមបុគ្គល<br>លំហាត់<br>បង្ហាញថា $\vec{a};\vec{b}$ និង $\vec{c}$ ស្ថិតក្នុងប្លង់តែមួយដែល $\vec{a}=(2,3,-1)$ ; $\vec{b}=(1,-1,3)$ និង $\vec{c}=(1,9,-11)$ | ជំហានទី៤<br>(ពង្រឹងចំនេះដឹង) | -សិស្សម្នាក់ឡើងដោះស្រាយលំហាត់លើក្តារខៀន<br>ចម្លើយ<br>ដោយ $\vec{c}.\left(\vec{a}\times\vec{b}\right)=\begin{vmatrix}1&9&-11\\2&3&-1\\1&-1&3\end{vmatrix}$<br>$=\begin{vmatrix}3&-1\\-1&3\end{vmatrix}-9\begin{vmatrix}2&-1\\1&3\end{vmatrix}$<br>$-11\begin{vmatrix}2&3\\1&-1\end{vmatrix}$<br>$=8-63+55=0$<br>ដូចនេះវ៉ិចទ័រ $\vec{a};\vec{b}$ និង $\vec{c}$ ស្ថិតក្នុងប្លង់តែមួយ។ |
| | ជំហានទី៥ | |

| | | |
|---|---|---|
| - ចូរប្អូនទៅដល់ផ្ទះធ្វើលំហាត់ក្នុងសៀវភៅពុម្ពទំព័រ ១៨៥ លំហាត់លេខ ៧ | (កិច្ចការផ្ទះ) | -សិស្សស្តាប់និងកត់ត្រាទុក |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី៧ វិចទ័រក្នុងលំហ

## មេរៀនទី២អនុវត្តន៍នៃផលគុណវិចទ័រ

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សសរសេរសមីការប៉ារ៉ាម៉ែត សមីការឆ្លុះនៃបន្ទាត់ និងសមីការស្វ៊ែរ តាមរយៈឧទាហរណ៍បានត្រឹមត្រូវ។
- បំណិន: សិស្សសរសេរបានសមីការប៉ារ៉ាម៉ែត សមីការប្លង់ និងសមីការស្វ៊ែរបាន
- ឥរិយាបថ: សិស្សសហការដោះស្រាយដោយស្មារតីយោគយល់។

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- មានបន្ទាត់ ហ្វឺត សៀវភៅ សិស្សនិងសៀវភៅគ្រូ

### IV. ខ្លឹមសារមេរៀន

1. **បន្ទាត់និងប្លង់ក្នុងលំហ**
   1.1. **បន្ទាត់ក្នុងប្លង់**
   1.2. **ប្លង់ក្នុងលំហ**
2. **សមីការស្វ៊ែរ**

### V. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ជំហានទី១ (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| ជំហានទី២ (រំលឹកមេរៀនចាស់) | | |
| -គ្រូសួរសិស្សអោយរំលឹកពីសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ដែលកាត់ឯតាមចំណុច | សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ដែលកាត់តាមចំណុច $P(x_0, y_0)$ ហើយស្របនឹង $\vec{V} = (a,b)$ ។ | សិស្សស្តាប់គ្រូពន្យល់មេរៀន ហើយកត់ត្រាសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ដែលកាត់ |

| | | |
|---|---|---|
| $P(x_0,y_0)$ ហើយស្រប $\vec{V}=(a,b)$ ។ | ចម្លើយ<br>សមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $L$ គឺ<br>$\begin{cases}x=x_0+at\\y=y_0+bt\end{cases}\ (t\in\mathbb{R})$ | តាមចំនុច $P(x_0,y_0)$ ហើយស្រប $\vec{V}=(a,b)$ ។<br>ចម្លើយ<br>សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L$ គឺ:<br>$\begin{cases}x=x_0+at\\y=y_0+bt\end{cases}$ |
| ជំហានទី៣ (មេរៀនថ្មី) | | |
| -គ្រូសរសេរមេរៀនថ្មី<br><br>-គ្រូណែនាំសិស្សអោយសង្កេតរូបរួចគ្រូបង្ហាញរូបមន្តរកសមីការប៉ារ៉ាម៉ែតនិងសមីការឆ្លុះក្នុងលំហ<br><br>-គ្រូដាក់លំហាត់គំរូអោយសិស្សសង្កេតមើល | **អនុវត្តន៍ផលគុណវិចទ័រ**<br>**1. បន្ទាត់និងប្លង់ក្នុងលំហ**<br>**1.1. បន្ទាត់ក្នុងប្លង់**<br><br>គេមានបន្ទាត់ $L$ មួយស្របទៅនឹងវិចទ័រ $\vec{V}=(a,b,c)$ ហើយកាត់តាមចំនុច $P(x_0,y_0,z_0)$ សមីការប៉ារ៉ាម៉ែតបន្ទាត់ $L$ គឺ: $\begin{cases}x=x_0+at\\y=y_0+bt\\z=z_0+ct\end{cases}$<br>លំហាត់: រកសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $L$ ដែលកាត់តាមចំនុច $(1;-2;4)$ ហើយស្របទៅនឹងវិចទ័រ $\vec{V}=(2;4;-4)$ ។<br>ចម្លើយ<br>រកសមីការនៃបន្ទាត់ $L$ កាត់តាមចំនុច $(1;-2;4)$ ហើយស្របនឹង | <br>គេមានបន្ទាត់ $L$ មួយស្របទៅនឹងវិចទ័រ $\vec{V}=(a,b,c)$ ហើយកាត់តាមចំនុច $P(x_0,y_0,z_0)$ សមីការប៉ារ៉ាម៉ែតបន្ទាត់ $L$ គឺ:<br>$\begin{cases}x=x_0+at\\y=y_0+bt\\z=z_0+ct\end{cases}$<br>លំហាត់: រកសមីការប៉ារ៉ាម៉ែតនៃបន្ទាត់ $L$ ដែលកាត់តាមចំនុច $(1;-2;4)$ ហើយស្របទៅនឹងវិចទ័រ $\vec{V}=(2;4;-4)$ ។<br>ចម្លើយ<br>រកសមីការនៃបន្ទាត់ $L$ កាត់ |

| | | |
|---|---|---|
| -គ្រូបង្ហាញរូបមន្តសមីការឆ្លុះនៃបន្ទាត់ទៅអោយសិស្ស។ ហើយគ្រូដាក់លំហាត់គំរូអោយសិស្ស។ | $\vec{V}=(2;4;-4)$ គេបាន: $\begin{cases}x=1+2t\\y=-2+4t\\z=4-4t\end{cases}$ ដែល $t\in\mathbb{R}$<br>គេមានបន្ទាត់ $L$ មួយស្របទៅនឹងវ៉ិចទ័រ $\vec{V}=(a;b;c)$ ហើយកាត់តាមចំនុច $P(x_0;y_0;z_0)$ នោះសមីការឆ្លុះនៃបន្ទាត់ $L$ គឺ<br>$\frac{x-x_0}{a}=\frac{y-y_0}{b}=\frac{z-z_0}{c}$ | តាមចំនុច $(1;-2;4)$ ហើយស្របនឹង $\vec{V}=(2;4;-4)$<br>គេបាន: $\begin{cases}x=1+2t\\y=-2+4t\\z=4-4t\end{cases}$ ដែល $t\in\mathbb{R}$<br>គេមានបន្ទាត់ $L$ មួយស្របទៅនឹងវ៉ិចទ័រ $\vec{V}=(a;b;c)$ ហើយកាត់តាមចំនុច $P(x_0;y_0;z_0)$ នោះសមីការឆ្លុះនៃបន្ទាត់ $L$ គឺ<br>$\frac{x-x_0}{a}=\frac{y-y_0}{b}=\frac{z-z_0}{c}$ |
| | លំហាត់: រកសមីការឆ្លុះបន្ទាត់ $(D)$ កាត់តាមចំនុច $A(0,0,0)$ ហើយស្របនឹងវ៉ិចទ័រ $\vec{u}=(1;2;3)$<br>ចម្លើយ<br>រកសមីការឆ្លុះ<br>គេមានបន្ទាត់ $(D)$ កាត់តាម $A(0,0,0)$ ហើយស្របនឹងវ៉ិចទ័រ $\vec{u}=(1,2,3)$ នោះសមីការឆ្លុះ<br>$\frac{x-x_0}{a}=\frac{y-y_0}{b}=\frac{z-z_0}{c}$ រឺ<br>$\frac{x-0}{1}=\frac{y-0}{2}=\frac{z-0}{3}$ រឺ $x=\frac{y}{2}=\frac{z}{3}$<br>ដូចនេះ $(D)$ គឺ $x=\frac{y}{2}=\frac{z}{3}$ | លំហាត់: រកសមីការឆ្លុះបន្ទាត់ $(D)$ កាត់តាមចំនុច $A(0,0,0)$ ហើយស្របនឹងវ៉ិចទ័រ $\vec{u}=(1;2;3)$<br>ចម្លើយ<br>រកសមីការឆ្លុះ<br>គេមានបន្ទាត់ $(D)$ កាត់តាម $A(0,0,0)$ ហើយស្របនឹងវ៉ិចទ័រ $\vec{u}=(1,2,3)$ នោះសមីការឆ្លុះ<br>$\frac{x-x_0}{a}=\frac{y-y_0}{b}=\frac{z-z_0}{c}$ រឺ<br>$\frac{x-0}{1}=\frac{y-0}{2}=\frac{z-0}{3}$ រឺ<br>$x=\frac{y}{2}=\frac{z}{3}$<br>ដូចនេះ $(D)$ គឺ $x=\frac{y}{2}=\frac{z}{3}$ |
| -គ្រូណែនាំសិស្សអោយសង្កេតពីរូបមន្តសមីការប្លង់ ហើយបញ្ជាក់ប្រាប់វ៉ិចទ័រ | 1.2 **ប្លង់ក្នុងលំហ**<br>បើប្លង់មួយកាត់តាមចំណុច $P(x_0,y_0,z_0)$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(a,b,c)$ នោះសមីការប្លង់គឺ | -សិស្សស្តាប់ហើយកត់ត្រា<br>បើប្លង់មួយកាត់តាមចំណុច $P(x_0,y_0,z_0)$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(a,b,c)$ នោះសមីការប្លង់គឺ |

| | | |
|---|---|---|
| $\vec{n}=(a,b,c)$ កែងនឹងប្លង់ ហៅថាវ៉ិចទ័រណរម៉ាល់នៃប្លង់ ។<br>-គ្រូដាក់លំហាត់គំរូអោយសិស្សសង្កេតតាម។ | $a(x-x_0)+b(y-y_0)$<br>$+c(z-z_0)=0$<br>លំហាត់: រកសមីការទូទៅនៃប្លង់ដែលកំណត់ដោយចំនុច $A(2,1,1)$ ហើយវ៉ិចទ័រណរម៉ាល់ $\vec{n}=(3,4,2)$ ។<br>**ចម្លើយ**<br>រកសមីការប្លង់<br>គេមានប្លង់កំណត់ដោយចំណុច $A(2,1,1)$ ហើយមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(3,4,2)$ គេបានសមីការប្លង់គឺ<br>$a(x-x_0)+b(y-y_0)$<br>$+c(z-z_0)=0$<br>$\Leftrightarrow 3(x-2)+4(y-1)$<br>$+2(z-1)=0$<br>$\Leftrightarrow 3x-6+4y-4+2z-z=0$<br>$\Leftrightarrow 3x+4y+2z-8=0$<br>ដូចនេះ សមីការប្លង់គឺ<br>$3x+4y+2z-8=0$ | $a(x-x_0)+b(y-y_0)$<br>$+c(z-z_0)=0$<br>លំហាត់: រកសមីការទូទៅនៃប្លង់ដែលកំណត់ដោយចំនុច $A(2,1,1)$ ហើយវ៉ិចទ័រណរម៉ាល់ $\vec{n}=(3,4,2)$ ។<br>**ចម្លើយ**<br>រកសមីការប្លង់<br>គេមានប្លង់កំណត់ដោយចំណុច $A(2,1,1)$ ហើយមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(3,4,2)$<br>គេបានសមីការប្លង់គឺ<br>$a(x-x_0)+b(y-y_0)$<br>$+c(z-z_0)=0$<br>$\Leftrightarrow 3(x-2)+4(y-1)$<br>$+2(z-1)=0$<br>$\Leftrightarrow 3x-6+4y-4+2z$<br>$-z=0$<br>$\Leftrightarrow 3x+4y+2z-8=0$<br>ដូចនេះ សមីការប្លង់គឺ<br>$3x+4y+2z-8=0$ |
| -ណែនាំសិស្សអោយសង្កេតរូបអោយស្គាល់ពីផ្ចិតនិងកាំរបស់ស្វ៊ែរហើយបង្ហាញរូបមន្តសមីការស្វ៊ែរ។ | **2. សមីការស្វ៊ែរ**<br>បើគេមានស្វ៊ែរ $(S)$ មួយដែលមានផ្ចិត $c(x_0,y_0,z_0)$ និងកាំ $r$ នោះសមីការស្វ៊ែរ $(S)$ គឺ<br>$(S):(x-a)^2+(y-b)^2$<br>$+(z-c)^2=r^2$ | -សិស្សកត់ត្រាតាមគ្រូបង្ហាញ:<br>បើគេមានស្វ៊ែរ $(S)$ មួយដែលមានផ្ចិត $c(x_0,y_0,z_0)$ និងកាំ $r$ នោះសមីការស្វ៊ែរ $(S)$ គឺ<br>$(S):(x-a)^2+(y-b)^2$<br>$+(z-c)^2=r^2$ |

| | | |
|---|---|---|
| -គ្រូដាក់លំហាត់គំរូអោយសិស្សសង្កេត | <br>លំហាត់:<br>រកសមីការស្វ៊ែរដែលមានផ្ចិត $(2;2;0)$ និងកាំរបស់ស្វ៊ែរស្មើ $3cm$<br>ចម្លើយ<br>រកសមីការផ្ចិត $(2;2;0)$ និងកាំស្មើ $3cm$ នោះសមីការស្វ៊ែរគឺ<br>$(x-a)^2+(y-b)^2+(z-c)^2=r^2$<br>$(x-2)^2+(y-2)^2+(z-0)^2=3^2$<br>ដូចនេះ សមីការស្វ៊ែរកំណត់ដោយ<br>$(x-2)^2+(y-2)^2+z^2=9$ | <br>លំហាត់:<br>រកសមីការស្វ៊ែរដែលមានផ្ចិត $(2;2;0)$ និងកាំរបស់ស្វ៊ែរស្មើ $3cm$<br>ចម្លើយ<br>រកសមីការផ្ចិត $(2;2;0)$ និងកាំស្មើ $3cm$ នោះសមីការស្វ៊ែរគឺ<br>$(x-a)^2+(y-b)^2$<br>$+(z-c)^2=r^2$<br>$(x-2)^2+(y-2)^2$<br>$+(z-0)^2=3^2$<br>ដូចនេះ សមីការស្វ៊ែរកំណត់ដោយ<br>$(x-2)^2+(y-2)^2+z^2=9$ |
| ជំហានទី៤ (ពង្រឹងចំណេះដឹង) | | |
| -រកសមីការស្តង់ដារនៃស្វ៊ែរដែលមានចំនុច $A(2,2,0)$ និង $B(0,0,2)$ ជាចំនុចចុងសងខាងនៃអង្កត់ផ្ចិត។ | រកសមីការស្តង់ដារនៃស្វ៊ែរដែលមានចំនុច $A(2,2,0)$ និង $B(0,0,2)$ ជាចំនុចចុងសងខាងនៃអង្កត់ផ្ចិត។ | -សិស្សពិចារណារួចឆ្លើយដោយចំនុច $A(2,2,0)$ និង $B(0,0,2)$ ជាចំនុចចុងសងខាងនៃអង្កត់ផ្ចិតនោះ គេបានផ្ចិតស្វ៊ែរគឺ<br>$\left(\frac{2+0}{2},\frac{2+0}{2},\frac{0+2}{2}\right)$<br>$=(1,1,1)$<br>កាំស្វ៊ែរ |

| | | |
|---|---|---|
| | | $r=\sqrt{(2-1)^2+(2-1)^2+(0-1)^2}=\sqrt{3}$<br>ដូចនេះ សមីការស្វ៊ែរកំណត់ដោយ<br>$S:(x-1)^2+(y-1)^2+(z-1)^2=3$ |
| ជំហានទី៥ (បណ្ដាំផ្ញើ) | | |
| -ណែនាំសិស្សធ្វើលំហាត់លេខ៧ទំព័រ១៩៩និងមើលមេរៀននៅផ្ទះបន្ថែម។ | កិច្ចការផ្ទះ<br>លំហាត់លេខ៧ទំព័រ១៩៩ | -សិស្សស្ដាប់ការណែនាំរបស់គ្រូ |

# កិច្ចតែងការបង្រៀន

## I មុខវិជ្ជា: គណិតវិទ្យាថ្នាក់ទី១២ (កម្រិតខ្ពស់)

## II ចំណងជើងមេរៀន:

## ជំពូកទី៨ ភាពចែកដាច់និងវិធីចែកអឺគ្លីត

## មេរៀនទី១ ភាពចែកដាច់និងវិធីចែកអឺគ្លីត

**១ ភាពចែកដាច់ក្នុង$\mathbb{Z}$**

**១.១ តួចែកដាច់និង ពហុគុណនៃចំនួនគត់រ៉ឺទ្បាទីប**

**១.២ លក្ខណៈចែកដាច់នៃផលបូកនិងផលដក**

**១.៣ លក្ខណៈចែកដាច់នឹងមួយចំនួន**

III **ទស្សចំណង:** ក្រោយពីរៀនចប់សិស្សអាច:

កំណត់ភាពចែកដាច់ក្នុង$\mathbb{Z}$

IV **រយៈពេល: ២ម៉ោង ថ្ងៃ.........ទី.........ខែ............ឆ្នាំ...............**

V **សម្ភារៈឧបទ្ទេស:**

- ស.សទំព័រទី 202 ដល់ 209 បោះពុម្ពឆ្នាំ 2010
- ស.គ ទំព័រទី..........ដល់............
- បន្ទាត់ឈើ + បន្ទាត់ជ័រ

VI **សកម្មភាពបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពបង្រៀន** |
|---|---|---|
| គ្រូគពិនិត្យ អវត្តមាន អនាម័យសណ្តាប់ធ្នាប់និងវិន័យ | <u>ជំហានទី១</u><br>(លំនឹងថ្នាក់ 3 នាទី) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| ហៅសិស្ស២ នាក់ឬ ៣នាក់ ឆ្លើយសំណួរនិង ធ្វើលំហាត់ មេរៀនចាស់ | <u>ជំហានទី២</u>(រំលឹកមេរៀនចាស់៧នាទី)<br>លំហាត់:បង្ហាញថា $10^{2009}-1$និង $10^{2010}-1$ចែកដាច់នឹង9។ | ឡើងធ្វើលំហាត់លើ ក្តារខៀន |

| | | |
|---|---|---|
| • គ្រូសរសេរមេរៀនថ្មី<br>• កែឧទាហរណ៍ឱ្យសិស្សមើល<br>• កែលំហាត់គំរូ<br>បង្ហាញថា $10^{2009}-1$ នឹង $10^{2010}-1$ចែកដាច់នឹង9 ។<br><u>ចម្លើយ</u><br>$10^{2009}-1=(10-1)(10^{2008}+10^{2007}+10^{2006}\ldots\ldots+1)$<br>$=9(10^{2008}+10^{2007}+10^{2006}+\ldots+1)$<br>ដូចនេះ$10^{2009}-1$ចែកដាច់នឹង9<br>• ទុកពេលឱ្យសិស្សចំលងមេរៀន<br>• ណែនាំសិស្សពន្យល់ពីរបៀប ចែកអឺគ្លីត<br>• ប្រាប់ពីរបៀបដោះស្រាយ របៀបវិធីចែកអឺគ្លីត | <u>ជំហានទី៣</u>(មេរៀនថ្មី) 70 នាទី<br><br><u>មេរៀនទី១</u>ភាពចែកដាច់និងវិធីចែកអឺគ្លីត<br>Ex: 24ចែកដាច់នឹង 3<br>បង្ហាញថា $10^{2010}-1$ចែកដាច់នឹង 9<br><u>ចម្លើយ</u><br>$10^{2010}-1=(10-1)(10^{2009}+10^{2008}+10^{2007}+\ldots\ldots+1)$<br>$=9(10^{2008}+10^{2007}+10^{2006}+\ldots+1)$<br>ដូចនេះ$10^{2010}-1$ចែកដាច់នឹង9។<br>+និយមន័យ<br>១.២លក្ខណៈចែកដាច់នៃផលបូកឬផលដក<br>+លំហាត់Ex ទី2<br>1.៣លក្ខណៈចែកដាច់និងមួយចំនួន<br>+លំហាត់ទី1.<br>គេមានចំនួន $n=abcd_{10}$<br>(របាបគោល10)។<br>ក/.បង្ហាញថា n ចែកដាច់និង3(នឹង9) កាលណា a+b+c+d ចែកដាច់នឹង 3(នឹង9)។<br>ខ/.បង្ហាញថា n ចែកដាច់នឹង11កាលណា(b+d)−(a+c) ចែកដាច់នឹង11។<br><u>ចម្លើយ</u><br>ក/. $n=1000a+100b+10c+d$<br>$=(999+1)a+(99+1)b+(9+1)c+d$<br>$=9(111a+11b+c)+(a+b+c+d)$<br>ដូចនេះ n ចែកដាច់នឹង3(នឹង9) កាល | +សិស្សសរសេរមេរៀនថ្មី<br>+សិស្សឆ្លល់លើកដៃសួរគ្រូ<br>+សិស្សចំលងមេរៀនចូលក្នុងសៀវភៅ.......<br><br>+សិស្សកត់មេរៀន<br><br><br>+សិស្សមើលកត់ត្រា |

| | | |
|---|---|---|
| • គ្រូពន្យល់ឱ្យសិស្សធ្វើលំហាត់ | ណាa+b+c+dចែកដាច់នឹង3 (នឹង9)។<br><br>ខ/. n=1000a+100b+10c+d<br><br>=( 1100 − 110+ 11 − 1 )a +(110 − 11+1)b +(11 − 1 )c+(b+d) − (a+c)<br><br>ដូចនេះ n ចែកដាច់នឹង11កាលណា (b+d)−(a+c) ចែកដាច់នឹង11។<br><br>$Ex_1$: ដោយមិនចាំបាច់គណនាផលបូកនិងផលដកបង្ហាញថា:<br><br>ក.777777+4136 និង777777 − 4136 ចែកដាច់នឹង11។<br><br>ខ.បង្ហាញថា$8^{2007}$−1 និង$8^{2008}$−1 ចែកដាច់នឹង7 ។ | +សិស្សឡើងធ្វើលំហាត់លើក្ដារខៀន |
| • គ្រូពន្យល់មេរៀនសារឡើងវិញ ដាក់លំហាត់ប្រតិបត្តិឱ្យសិស្សធ្វើ | ជំហានទី៤(ពង្រឹងពិន្ទុ) 7 នាទី<br>+លំហាត់ប្រតិបត្តិ<br>1. គេមានចំនួន n=8$x$6$y_{10}$(របាប់គោល10)។បើផលគុណលេខពីខ្ទង់ $x$y=12 ។ចូរកំនត់ដើម្បីឱ្យវាចែកដាច់នឹង3 ។ | +សិស្សឡើងធ្វើលំហាត់ចម្លើយ |
| • ធ្វើលំហាត់លេខ 12 ទំព័រលេខ 209 | ជំហានទី៥ (បណ្ដាំផ្ញើរ) 3 នាទី | +សិស្សកត់ត្រាដោយយកចិត្តទុកដាក់ |

# កិច្ចតែងការបង្រៀន

I **មុខវិជ្ជា: គណិតវិទ្យាថ្នាក់ទី១២ (កម្រិតខ្ពស់)**

II **ចំណងជើងមេរៀន:**

**ជំពូកទី៨ ភាពចែកដាច់និងវិធីចែកអឺគ្លីត (ត)**

**២.វិធីចែកបែបអឺគ្លីត**
**២.១ និយមន័យ**
**២.២ ទ្រឹស្តីបទ**

III **វត្ថុបំណង:** ក្រោយពីរៀនចប់សិស្សអាច:

កំណត់វិធីចែកបែបអឺគ្លីត

IV **រយៈពេល: ២ម៉ោង ថ្ងៃ.........ទី.........ខែ.............ឆ្នាំ...............**

V **សម្ភារៈឧបទ្ទេស:**

- ស.សទំព័រទី202 ដល់ 209 បោះពុម្ពឆ្នាំ 2010
- ស.គ ទំព័រទី..........ដល់ទំព័រទី............
- បន្ទាត់ឈើ + បន្ទាត់ជ័រ

VI **<u>សកម្មភាពបង្រៀន</u>**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| គ្រូតពិនិត្យ អវត្តមានសិស្ស អនាម័យសណ្តាប់ធ្នាប់និងវិន័យ | <u>ជំហានទី១</u><br>(លំនឹងថ្នាក់3 នាទី) | ប្រធានថ្នាក់ឡើងរាយការណ៍ |
| ហៅសិស្ស២នាក់ឬ ៣នាក់ ឆ្លើយសំនួរនិងធ្វើលំហាត់មេរៀនដែលរៀនរួច | <u>ជំហានទី២</u><br>(រំលឹកមេរៀនចាស់7 នាទី)<br>លំហាត់: បង្ហាញថា $13^{1985}+13^{1986}+13^{1992}$ ចែកដាច់នឹង170។ | ឡើងធ្វើលំហាត់នៅលើ ក្តារខៀន |
| • គ្រូសរសេរមេរៀនថ្មី<br>• កែឧទាហរណ៍ឱ្យសិស្សមើល<br>• កែលំហាត់គំរូ | <u>ជំហានទី៣</u><br>(មេរៀនថ្មី) 70 នាទី | +សិស្សសរសេរមេរៀនថ្មី |

| | | |
|---|---|---|
| រកផលចែក q និងសំណល់ r ក្នុងវិធីចែកបែបអឺគ្លីតនៃa និងb ដូចខាងក្រោម:<br>ក. a=194 , b=7<br>ខ. −1317, b=21<br>ចម្លើយ<br>ក.ដោយ194=7x27+5 នាំឱ្យ9=27និងr=5<br>ខ. ដោយ − 1317=21x( −16) នាំឱ្យ9=−15 និង r=19 | មេរៀនទី១. ភាពចែកដាច់និង វិធីចែកដាច់បែបអឺគ្លីត<br>Ex: បង្ហាញថាអត្ថិភាពនៃ q នឹង r<br>_បើa ជាពហុគុណនៃក្នុង ℤ នោះគេបាន a=bq +0 , r=0<br>_បើa មិនមែនជាពហុគុណនៃ b ក្នុងℤ នោះមានពហុគុណនៃ bដែលតូចជាង aនិងពហុគុណផ្សេងទៀតនៃ b ដែលមានធំជាងa ។<br>បើbqនិងb(q+1) ជាពហុគុណនៃbដែលតូចជាងនឹងធំជាងa នោះគេបាន<br>bq<a<b(q+1)ឬ 0≤a−bq<b<br>តាង r=a−bq គេបាន<br>a=bq +r ដែល 0≤r<b ។<br>+និយមន័យ<br><br><br>២.២ ទ្រឹស្តីបទ<br>លំហាត់គំរូ: គេនឹងថាចំនួន m ចែកនឹង 17 បានសំណល់ 8 ហើយ n ចែកនឹង 17 បានសំណល់12 ។កំនត់សំណល់នៃវិធីចែកបែបអឺគ្លីតនៃ m+n; mn និង $m^2$ និង17 ។<br>ចម្លើយ<br>គេមានចំនួនគត់ធម្មជាតិ qនិងq′ដែល<br>m=17q +8 (1) និង n=17q′′+12 (2)<br>យក(1)+(2)គេបាន៖ | +សិស្សឆ្លល់លើកដៃសួរគ្រូ<br><br>+សិស្សចំលងមេរៀនចូលក្នុងសៀវភៅ<br><br><br>+សិស្សកត់មេរៀន |

| | | |
|---|---|---|
| | $m+n(17q+8)+(17q'+12)$<br>$=17q+17q'+20$<br>$=17(q+q')+17x1+3$<br>$=17(q+q'+1)+3$<br>ដូចនេះសំណល់នៃវិធីចែកបែបអឺគ្លីត នៃ m+n និង 17 គឺ 3 ។<br>$mn=(17q+8)x(17q'+12)$<br>$=17^2qq'+17x12q+17x8q'+17$ $x5+11$<br>$=17(17qq'+12q+8q'+5)+11$<br>ដូចនេះសំណល់នៃវិធីចែកបែបអឺគ្លីត នៃmn និង17គឺ11 ។<br>$m^2=(17q+8)^2$<br>$=17^2q^2+2x17x89+64$<br>$=17(17q^2+16q+3)+13$<br>ដូចនេះសំណល់នៃវិធីចែកបែបអឺគ្លីត នៃ$m^2$ និង17គឺ13 ។<br>Ex1:រកផលចែកqនិងសំណល់r ក្នុងវិធីចែកបែបអឺគ្លីតនៃ aនិងb ដូចខាងក្រោម៖<br>ក. a=−734 ; b=5<br>ខ. a=−849 ; b=13 | +សិស្សឡើងធ្វើលំហាត់ លើក្ដារខៀន |
| គ្រូពន្យល់មេរៀនសារឡើងវិញ ដាក់លំហាត់ប្រតិបត្តិឱ្យសិស្សធ្វើ | <u>ជំហានទី៤</u><br>(ពង្រឹងពុទ្ធិ) 7 នាទី<br>+លំហាត់<br>១.រកផលចែកqនិងសំណល់rក្នុងវិធីចែកបែបអឺគ្លីតនៃaនិងbដូចខាងក្រោម៖<br>ក. a=569 ; b=7 | +សិស្សឡើងធ្វើលំហាត់:<br><u>ចម្លើយ</u><br>ក.569=7x81+2<br>ខ.−671=6x−111+5<br>(q=111; r=5) |

| | | |
|---|---|---|
| | ខ. a=−671 ; b=6<br>២. រកគ្រប់គូចំនួនគត់វិជ្ជមាន (x,y) ដែល 7$x$+y=37 | <u>ចម្លើយ</u><br>37=7x5+2<br>37=7$x$+y |
| ធ្វើលំហាត់លេខ 13 ដល់លេខ 15 ទំព័រលេខ 209 | <u>ជំហានទី៥</u><br>(បណ្តាំផ្ញើរ)3 នាទី | សិស្សរកត់លំហាត់យកទុក្ខធ្វើនៅគេហដ្ឋាន ។ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី៨ ភាពចែកដាច់និងវិធីចែកអឺគ្លីត

## មេរៀនទី២ ចំនួនបឋម

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សប្រាប់បានពីនិយមន័យចំនួនបឋមតាមរយៈខ្លឹមសារមេរៀនយ៉ាងត្រឹមត្រូវ។
- បំណិន: សិស្សបកស្រាយទ្រឹស្តីបទនៃចំនួនបឋមនិងរបៀបកំណត់ចំនួនបឋមតាមការដោះស្រាយលំហាត់ត្រឹមត្រូវ។
- ឥរិយាបថ: សិស្សមានបម្រុងប្រយ័ត្នពេលធ្វើកិច្ចការផ្សេងៗ។

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២១០-២១៥
- សៀវភៅគ្រូ: ទំព័រ

### IV. ខ្លឹមសារមេរៀន

1. **អនន្តភាពនៃចំនួនបឋម**

   1.1. **ចំនួនបឋម**

### V. ដំណើរការមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| -អោយសិស្សឡើងធ្វើលំហាត់ | លំហាត់: រកផលចែក $q$ និងសំណល់ $r$ ក្នុងវិធីចែកបែបអឺគ្លីត $a$ និង $b$ ដូចខាងក្រោម | -ដោះស្រាយលំហាត់<br>$a=b\times q+r$<br>$194=7\times 27+5$<br>នាំអោយ $q=27$ ; $r=5$ |

| | | |
|---|---|---|
| | $a=194$ ; $b=7$ | |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| -ប្រាប់និយមន័យចំនួនបឋម<br><br>-បង្ហាញទ្រឹស្តីបទនិងអោយសិស្សស្រាយបញ្ជាក់<br><br>-ស្រាយបញ្ជាក់: តាង $n$ ជាចំនួនគត់ធម្មជាតិមិនបឋម តាមទ្រឹស្តីបទខាងលើ $n$ មានតួចែកជាចំនួនបឋមតូចបំផុតមួយតាងដោយ $b$ | **ចំនួនបឋម**<br>**1. អនន្តភាពនៃចំនួនបឋម**<br>**1.1. ចំនួនបឋម**<br>និយមន័យ: ចំនួនគត់ធម្មជាតិ $n$ ជាចំនួនបឋម លុះត្រាតែ $n>1$ ហើយ $n$ មានតួចែកតែពីរគត់គឺ1និង $n$ ខ្លួនឯង។<br>**-ទ្រឹស្តីបទ:** គ្រប់ចំនួនគត់ធម្មជាតិ $n$ ធំជាង1មានតួចែកជាចំនួនបឋមមួយដែលជាតួចែកតូចបំផុតក្រៅពី1។<br><br>**ទ្រឹស្តីបទ:** បើ $n\in\mathbb{N}$ ហើយ $n$ ជាចំនួនបឋម នោះមានចំនួនគត់ធម្មជាតិបឋម $b$ ដែល $b/n$ និង $b^2/n$ ។ | -ស្តាប់<br><br>-ពិនិត្យទ្រឹស្តីបទនិងស្រាយបញ្ជាក់<br>-បើ $n$ ជាចំនួនបឋមនោះ $n$ ជាតួចែកបឋមតូចបំផុតនៃចំនួន $n$ ខ្លួនឯង។<br>-បើ $n$ មិនបឋម<br>តាង $d$ ជាតួចែកតូចបំផុតនៃ $n$<br>ឧបមាថា $d$ មិនបឋមមានតួចែក $b$ មួយទៀតដែល $b<d$ ដូចនេះ $b$ ក៏ជាតួចែកនៃ $n$ ដែរ<br>$\Rightarrow b/n$ និង $b<d$ ដែលផ្ទុយពី $d$ ជាតួចែកតូចបំផុតនៃ $n$ ដូចនេះ $d$ មិនអាចមានតួចែក $b$ បានទេ មានន័យថា $d$ ជាតួចែកបឋមតូចបំផុតនៃ $n$ ។<br>-សង្កេតដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| គេបាន $n = bq$ ហើយ $b$ ជាតួចែកតូចបំផុតនៃ $n$ និង $b \le n$ ។ ដូចនេះ $b^2 \le n$ មានន័យថា $n$ ចែកដាច់នឹងចំនួនបឋមណាមួយដែលការេរបស់វាតូចជាងឬស្មើ $n$ ។ | **ទ្រឹស្តីបទ:** បើ $n \in \mathbb{N}; n$ ចែកមិនដាច់នឹងចំនួនមិនបឋមដែលមានការេតូចជាងឬស្មើ $n$ នោះ $n$ ជាចំនួនបឋម។ | -មើលសម្រាយបញ្ជាក់ |
| -អោយសិស្សធ្វើលំហាត់ | លំហាត់: បង្ហាញថា173 ជាចំនួនបឋម។ | -ដោះស្រាយលំហាត់<br>173 ចែកមិនដាច់នឹងចំនួនបឋម $2;3;5;7;11$ និង13 ទេ<br>ហើយ $13^2 = 169 \le 173$<br>ដូចនេះ 173 ជាចំនួនបឋម |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -អោយសិស្សធ្វើលំហាត់ប្រតិបត្តិ | លំហាត់: បង្ហាញថាចំនួន 997 ជាចំនួនបឋម។ | -ឆ្លោះ 997 ចែកមិនដាច់នឹងចំនួនបឋម $2;3;5;7;11;$<br>$13;17;19;23;29;31$ ហើយ<br>$31^2 \le 997$<br>ដូចនេះ 997 ជាចំនួនបឋម |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -អោយសិស្សធ្វើលំហាត់នៅផ្ទះ | កិច្ចការផ្ទះ<br>លំហាត់លេខ១២ទំព័រ២១៦ | -សិស្សស្តាប់ការណែនាំរបស់គ្រូ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតខ្ពស់)

## ជំពូកទី៨ ភាពចែកដាច់និងវិធីចែកអឺគ្លីត

## មេរៀនទី២ ចំនួនបឋម (តចប់)

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សប្រាប់ពីការបំបែកមួយចំនួនជាផលគុណកត្តាបឋមបានតាមរយៈ មេរៀនមេរៀនយ៉ាងត្រឹមត្រូវ។
- បំណិន: សិស្សបំបែកមួយចំនួនជាផលគុណកត្តាបឋមបានតាមរយៈការធ្វើលំហាត់ យ៉ាងត្រឹមត្រូវ។
- ឥរិយាបថ: បណ្តុះគំនិតសិស្សអោយចេះវិភាគពីបញ្ហាផ្សេងៗ។

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២១២-២១៥
- សៀវភៅគ្រូ: ទំព័រ
- បន្ទាត់

### IV. ខ្លឹមសារមេរៀន

2. **ការបំបែកមួយចំនួនជាផលគុណកត្តាបឋម**

 2.1. **អត្ថិភាពនិងភាពតែមួយគត់នៃការបំបែក**

 2.2. **លក្ខខណ្ឌចែកដាច់**

### V. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| -អោយសិស្សឡើងធ្វើលំហាត់ | លំហាត់: បញ្ជាក់ថាចំនួន 937 និង | -ដោយចំនួន 937 ចែកមិន |

| | | |
|---|---|---|
| | 1933 ជាចំនួនបឋម។ | ដាច់ 2;3;5;7;11;13;17;<br>19;23;29 ទេ<br>ដូចនេះ 937 ជាចំនួនបឋម |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| -បង្ហាញទ្រឹស្តីបទដល់សិស្សរួចអោយសិស្សស្រាយបញ្ជាក់<br><br>-គ្រូបង្ហាញទ្រឹស្តីបទដល់សិស្សរួចអោយសិស្សស្រាយបញ្ជាក់ | **ចំនួនបឋម**<br>**2. ការបំបែកមួយចំនួនជាផលគុណកត្តាបឋម**<br>**2.1 អត្ថិភាពនិងភាពតែមួយគត់នៃការបំបែក**<br>**ទ្រឹស្តីបទ:** គ្រប់ចំនួនគត់មិនបឋមហើយធំជាងមួយអាចបំបែកជាផលគុណកត្តាបឋមបានហើយបានតែមួយបែបគត់។<br>សន្និដ្ឋាន: គ្រប់ចំនួនមិនបឋមអាចសរសេរជាផលគុណនៃកត្តាបឋមបាន។<br><br>**2.2 លក្ខខណ្ឌចែកដាច់**<br>**ទ្រឹស្តីបទ:** តាង $n$ និង $p$ ជាចំនួនគត់ធម្មជាតិធំជាង1ដើម្បីអោយ $p$ ជាតួចែកមួយនៃ $n$ លុះត្រាតែគ្រប់តួចែកបឋមនៃ $p$ ជាតួចែកនៃ $n$ ហើយនិទស្សន្តនៃតួចែកនៃ $p$ មិនធំជាងនិទស្សន្តនៃតួចែកដែលដូចគ្នារៀងគ្នានៃ $n$។ | -សង្កេតមើលទ្រឹស្តីបទ<br>ស្រាយបញ្ជាក់<br>តាង $n$ ជាចំនួនគត់ធម្មជាតិមិនបឋម នោះ $n$ អាចមានតួចែកបឋមមួយតាងដោយ $a$ ហើយ $n=aq$<br>-បើ $q$ ចំនួនបឋមនោះ $n$ អាចសរសេរជាផលគុណពីរកត្តាបឋមបាន។<br>-បើ $q$ មិនមែនជាចំនួនបឋម នោះ $q=b\cdot q'$ ដែល $q'<q$<br>បើ $q'$ បឋមនោះ $n=abq'$<br>-ស្រាយបញ្ជាក់:<br>ឧបមាថា $n=a^{\alpha}\times b^{\beta}\times c^{\gamma}$ ដែល $a;b;c$ ជាចំនួនគត់ធម្មជាតិ។<br>បើ $p$ ជាតួចែកមួយនៃ $n$ នោះ $n=p\cdot q$ ហើយការបំបែក $p\cdot q$ ជាផលគុណនៃកត្តាបឋម |

| | | |
|---|---|---|
| -អោយសិស្សធ្វើលំហាត់គំរូ | លំហាត់គំរូ:<br>ក. រកសំណុំតួចែកនៃ150<br>ខ. បើ $n=a^{\alpha}\times b^{\beta}\times c^{\gamma}$ ដែល $a;b;c$ ជាចំនួនបឋមហើយ $\alpha;\beta;\gamma$ ជាចំនួនគត់ធម្មជាតិ បង្ហាញថាចំនួនតួចែកទាំងអស់នៃ $n$ គឺ $(\alpha+1)(\beta+1)(\gamma+1)$<br><br>ដូចនេះ សំណុំតួចែកនៃ150 គឺ $\{1;2;3;5;10;15;25;$<br>$30;50;75;150\}$ | -ធ្វើលំហាត់<br>$150=2\times3\times5^2$ មានបីក្រុម<br>ក្រុមទី១គឺ1;2<br>ក្រុមទី២គឺ 2;1;3<br>ក្រុមទី៣គឺ$1;5;5^2$<br> |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -អោយសិស្សធ្វើលំហាត់ប្រតិបត្តិ | ប្រតិបត្តិ:<br>ក. រកសំណុំតួចែកនៃ 4258<br>ខ. រកតម្លៃអប្បបរមានៃ $m$ ដែលធ្វើអោយ $20m$ ជាការេនៃចំនួនគត់វ៉ុឡាទីប។ | ក. រកសំណុំតួចែក<br>$4258=2\times2129$<br>មានពីរក្រុមគឺ1;2 និង<br>1;2129<br>ដូចនេះ $\{1;2;2129;4258\}$<br>ខ. ដើម្បីអោយ<br>$20m=2^2\times5m$ ជាការេប្រាកដគ្រាន់តែអោយ $5m$ ជាការេប្រាកដ<br>$5m=a^2;a$ ជាចំនួនគត់វិជ្ជមាន $m=\frac{a^2}{5}$<br>$20m=20\times5=100$<br>ដូចនេះ $m=5$ |

| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
|---|---|---|
| -អោយសិស្សធ្វើលំហាត់នៅផ្ទះ | កិច្ចការផ្ទះ<br>លំហាត់ទំព័រ ២១៦ដល់២១៧ | -សិស្សស្តាប់ការណែនាំរបស់គ្រូ |

# កិច្ចតែងការបង្រៀន

## ជំពូកទី៨ ៖ ភាពចែកដាច់ និងវិធីចែកអឺគ្លីត

## មេរៀនទី៣ ៖ តួចែករួម និងពហុគុណរួម

I. **វត្ថុបំណងនៃមេរៀន** ៖ ក្រោយពីរៀនមេរៀននេះចប់សិស្សអាច ៖

- បំនេះដឹង ៖ ប្រាប់ពីរបៀបរកតួចែករួម និងពហុគុណរួម បានត្រឹមត្រូវតាមរយៈឧទាហរណ៍ ។
- បំនិន ៖ រកតួចែករួម និងពហុគុណរួម បានត្រឹមត្រូវតាមរយៈលំហាត់គំរូ ។
- ឥរិយាបថ ៖ មានស្មារតីប្រុងប្រយ័ត្ន និងចេះធ្វើការងារជាក្រុម ។

II. **រយៈពេលបង្រៀន** ៖ កិច្ចតែងការនេះសម្រាប់រយៈពេល ២ម៉ោងសិក្សា ។

III. **សម្ភារៈឧបទេ្ទស**

- សៀវភៅគ្រូ និង សៀវភៅសិស្ស
- ទ្រឹស្តីចំនួន

IV. **វិធីសាស្ត្របង្រៀន** ៖ ប្រើប្រាស់វិធីសាស្ត្រចម្រុះ "ចោទឆ្លើយ , សង្កេត , រិះរក , ..."

V. **ដំណើរនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអនាម័យ វិន័យ សណ្តាប់ធ្នាប់ និង អវត្តមាន ។ | ជំហានទី១<br>(រដ្ឋបាលថ្នាក់) | -សិស្សក្រោកឈរ ប្រធានថ្នាក់ឡើងរាយការណ៍ ។ |
| -ដូចម្តេចដែលហៅថាចំនួនបឋម?<br>-តើ 2013 ជាចំនួនបឋម ឬទេ? | ជំហានទី២<br>(រំលឹកមេរៀន) | -គឺជាចំនួនដែលមានតួចែកតែ៤គត់គឺ $\pm 1$ និង $\pm$ ខ្លួនឯង ។<br>-មិនមែនទេ ព្រោះ $2013 \vdots 3$ ។ |
| | ជំហានទី៣<br>១. តួចែករួមធំបំផុត | |

| | | |
|---|---|---|
| | ១.១ តួចែករួមនៃពីរចំនួនគត់ធម្មជាតិ | |
| -ចូររកគ្រប់តួចែកវិជ្ជមាននៃ 30 និង 45 ។ | - តួចែកវិជ្ជមាននៃ ៖<br>30 មាន $\{1,2,3,5,10,15,30\}$<br>45 មាន $\{1,3,5,9,15,45\}$ | - តួចែកវិជ្ជមាននៃ ៖<br>30 មាន $\{1,2,3,5,10,15,30\}$<br>45 មាន $\{1,3,5,9,15,45\}$ |
| -តើតួចែករួមនៃ 30 និង 45 មានអ្វីខ្លះ ? | - មាន ៖$\{1,3,5,15\}$ | - មាន ៖$\{1,3,5,15\}$ |
| - ចូរឲ្យនិយមន័យតួចែករួម $d$ នៃពីរចំនួនគត់ធម្មជាតិ $a$ និង $b$ ។ | - និយមន័យ ៖<br>$a$ និង $b$ ជាចំនួនគត់ធម្មជាតិ, គ្រប់ចំនួនគត់ធម្មជាតិ $d$ ជាតួចែករួមនៃ $a$ និង $b$ កាលណា $d$ ជាតួចែកនៃ $a$ ផងនិងជាតួចែកនៃ $b$ ផង។ | - និយមន័យ ៖<br>$a$ និង $b$ ជាចំនួនគត់ធម្មជាតិ, គ្រប់ចំនួនគត់ធម្មជាតិ $d$ ជាតួចែករួមនៃ $a$ និង $b$ កាលណា $d$ ជាតួចែករួមនៃ $a$ និង $b$ ហើយតាងដោយ $\delta=\gcd(a,b)$ ។ |
| - តើតួចែករួមធំបំផុតនៃ 30 និង 45 គឺប៉ុន្មាន ? | - គឺ 15 ។ | - គឺ 15 ។ |
| - ចូរឲ្យនិយមន័យតួចែករួមធំបំផុតនៃចំនួនគត់ធម្មជាតិ $a$ និង $b$ ។ | - និយមន័យ ៖<br>តួចែករួមធំបំផុតនៃចំនួនគត់ធម្មជាតិ $a$ និង $b$ ជាចំនួនគត់ធម្មជាតិដែលធំជាងគេក្នុងចំណោមតួចែករួមនៃ $a$ និង $b$ ហើយតាងដោយ $\delta=\gcd(a,b)$ ។ | - និយមន័យ ៖<br>តួចែករួមធំបំផុតនៃចំនួនគត់ធម្មជាតិ $a$ និង $b$ ជាចំនួនគត់ធម្មជាតិដែលធំជាងគេក្នុងចំណោមតួចែករួមនៃ $a$ និង $b$ ហើយតាងដោយ $\delta=\gcd(a,b)$ ។ |
| - រក $\gcd(6,12)$ | - តួចែកនៃ 6 មាន $\{1,2,3,6\}$<br>និង 12 មាន $\{1,2,3,6,12\}$<br>គេបាន $\gcd(6,12)=6$ | - តួចែកនៃ 6 មាន $\{1,2,3,6\}$<br>និង 12 មាន $\{1,2,3,6,12\}$<br>គេបាន $\gcd(6,12)=6$ |
| - បើ $a$ ជាតួចែកនៃ $b$ តើ | | |

| | | |
|---|---|---|
| $\gcd(a,b)=?$<br>- ចូររៀបរាប់ពីរបៀបនៃការរក $\gcd(a,b)$ ។ | - នោះ $\gcd(a,b)=a$<br>- ដើម្បីរក $\gcd(a,b)$ គេត្រូវបំបែក $a\&b$ ជាកត្តាបឋម ។ $\gcd(a,b)$ ជាផលគុណកត្តាបឋមដែលដូចគ្នានិងមាននិទស្សន្តតូចនៃ $a\&b$ ។ | - នោះ $\gcd(a,b)=a$<br>- ដើម្បីរក $\gcd(a,b)$ គេត្រូវបំបែក $a\&b$ ជាកត្តាបឋម ។ $\gcd(a,b)$ ជាផលគុណកត្តាបឋមដែលដូចគ្នានិងមាននិទស្សន្តតូចនៃ $a\&b$ ។ |
| -រក $\gcd(60,90)$ , $\gcd(56,84)$ និង $\gcd(16,15)$ ។ | - $60=2^2\cdot3\cdot5$<br>និង $90=2\cdot3^2\cdot5$<br>នោះ $\gcd(60,90)=30$<br>$56=2^3\cdot7$<br>និង $84=2\cdot3\cdot7$<br>នោះ $\gcd(56,84)=28$<br>$16=2^4$<br>និង $15=3\cdot5$<br>នោះ $\gcd(56,84)=1$ | - $60=2^2\cdot3\cdot5$<br>និង $90=2\cdot3^2\cdot5$<br>នោះ $\gcd(60,90)=30$<br>$56=2^3\cdot7$<br>និង $84=2\cdot3\cdot7$<br>នោះ $\gcd(56,84)=28$<br>$16=2^4$<br>និង $15=3\cdot5$<br>នោះ $\gcd(56,84)=1$ |
| -តើប្រភាគ $\frac{15}{16}$ សម្រួលបានឬទេ? ព្រោះអ្វី ? | -មិនបានទេ ព្រោះ $\gcd(56,84)=1$ | -មិនបានទេ ព្រោះ $\gcd(56,84)=1$ |
| -បើ $\gcd(a,b)=1$ តើ $a$ និង $b$ ហៅថាអ្វី ? ប្រភាគ $\frac{a}{b}$ ហៅថាអ្វី ? | -ហៅថាចំនួនបឋមនឹងគ្នា ។ ប្រភាគសម្រួលមិនបាន ។ | -ហៅថាចំនួនបឋមនឹងគ្នា ។ ប្រភាគសម្រួលមិនបាន ។ |
| -ចូរសម្រួលប្រភាគ $\frac{168}{441}$ | មាន $168=2^3\cdot3\cdot7$ និង $441=3^2\cdot7^2$ គេបាន ៖<br>$\gcd(168,441)=21$<br>នោះ $\frac{168}{441}=\frac{21\cdot8}{21\cdot21}=\frac{8}{21}$ | មាន $168=2^3\cdot3\cdot7$ និង $441=3^2\cdot7^2$ គេបាន ៖<br>$\gcd(168,441)=21$<br>នោះ $\frac{168}{441}=\frac{21\cdot8}{21\cdot21}=\frac{8}{21}$ |

| | | |
|---|---|---|
| -ស្រាយទ្រឹស្តីបទឲ្យសិស្ស<br><br>-លំហាត់គំរូ ៖ រក $\gcd(75,25)$ និង $\gcd(213,63)$ ។<br><br>-ស្រាយទ្រឹស្តីបទ និងអាល់កូរីតអឺគ្លីតឲ្យសិស្ស | ១.២ លក្ខណៈនៃតួចែករួមធំបំផុតនៃពីរចំនួន<br>-ទ្រឹស្តីបទ ៖បើ $a \& b$ ជាចំនួនគត់ធម្មជាតិ ដែល $a=bq+r$ ដោយ $0<r<b$ នោះ $\gcd(a,b)=\gcd(b,r)$ ។<br>សម្រាយ(មើលទំព័រ២២០)<br><br>១.៣ អាល់កូរីតអឺគ្លីត<br>-ទ្រឹស្តីបទ ៖gcd នៃ $a \& b$ គឺជាសំណល់ចុងក្រោយបំផុតខុសពីសូន្យ ក្នុងវិធីចែកបន្តបន្ទាប់គ្នា ឬអាល់កូរីតអឺគ្លីត។<br>សម្រាយ(មើលទំព័រ២២០)<br>សំគាល់ ៖ បើ $r_n=1$ នោះ $a \& b$ ជាចំនួនបឋមរវាងគ្នា។ | -សង្កេត<br><br>- $\gcd(75,25)=25$<br>ព្រោះ $75 \vdots 25$<br>$\gcd(213,63)=\gcd(63,24)$<br>$=\gcd(24,15)=3$<br><br>-សង្កេត |
| - រក $\gcd(90,45)$ និង $\gcd(125,95)$<br><br>- សម្រួលប្រភាគ $\frac{234}{2009}$ | ជំហានទី៤<br>(ពង្រឹងចំនេះដឹង) | - $\gcd(90,45)=45$ និង<br>$\gcd(125,95)=\gcd(95,30)$<br>$=\gcd(30,5)=5$<br>$\gcd(234,2009)=\gcd(137,97)$<br>$=\gcd(97,40)=\gcd(40,17)=1$<br>នោះប្រភាគ $\frac{234}{2009}$ សម្រួលមិនបាន ។ |

| | | |
|---|---|---|
| -ដាក់លំហាត់កិច្ចការផ្ទះឲ្យសិស្ស(លំហាត់១ដល់៥ទំព័រ ២៣២) | ជំហានទី៥ (កិច្ចការផ្ទះ) | -សិស្សកត់ត្រា និងស្តាប់ |

# កិច្ចតែងការបង្រៀន

## ជំពូកទី៨ ៖ភាពចែកដាច់ និងវិធីចែកអឺគ្លីត

## មេរៀនទី៣ ៖ តួចែករួម និងពហុគុណរួម

I. **វត្ថុបំណងនៃមេរៀន ៖** ក្រោយពីរៀនមេរៀននេះចប់សិស្សអាច ៖

- បំនេះដឹង ៖ ប្រាប់ពីរបៀបរក gcd តាមអាល់កូរីតអឺគ្លីតបានត្រឹមត្រូវតាមរយៈឧទាហរណ៍ ។
- បំនិន ៖ រក gcd តាមអាល់កូរីតអឺគ្លីតបានត្រឹមត្រូវតាមរយៈលំហាត់គំរូ ។
- ឥរិយាបថ ៖ មានស្មារតីប្រុងប្រយ័ត្ន និងចេះធ្វើការងារជាក្រុមដល់សិស្ស ។

II. **រយៈពេលបង្រៀន ៖** កិច្ចតែងការនេះសម្រាប់រយៈពេល ២ម៉ោងសិក្សា ។

III. **សម្ភារៈឧបទ្ទេស**

- សៀវភៅគ្រូ និង សៀវភៅសិស្ស
- ទ្រឹស្តីចំនួន

IV. **វិធីសាស្ត្របង្រៀន ៖** ប្រើប្រាស់វិធីសាស្រ្តចម្រុះ "ចោទឆ្លើយ , សង្កេត , រិះរក , ..."

V. **ដំណើរនាំមេរៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យអនាម័យ វិន័យ សណ្តាប់ធ្នាប់ និង អវត្តមាន ។ | ជំហានទី១(រដ្ឋបាលថ្នាក់) | -សិស្សក្រោកឈរ ប្រធានថ្នាក់ឡើងរាយការណ៍ ។ |
| -រក $\gcd(90,45)$ | ជំហានទី២(រំលឹកមេរៀន) | -ដោយ $90 = 45\cdot 2+0$<br>នោះ $\gcd(90,45)=45$ |
| - រក $\gcd(5664,984)$ ។ | ជំហានទី៣<br>១.៤ របៀបរក gcd តាមអាល់កូរីតអឺគ្លីត | - រក $\gcd(5664,984)$ |

| | | | | | |
|---|---|---|---|---|---|
| | 5 | 1 | 3 | 10 | ផលចែក |
| 5664 | 987 | 744 | 240 | 24 | |
| 744 | 240 | 24 | 0 | | សំណល់ |
| $r_1$ | $r_2$ | $r_3$ | | | |

តាមតារាងគេបាន ,

$\gcd(5664,984)=24$

-ណែនាំសិស្សឲ្យទាញជាទ្រឹស្តីបទ ។ ណែនាំសិស្សឲ្យធ្វើសម្រាយបញ្ជាក់ ។

-ទ្រឹស្តីបទ ៖ $a\&b$ ជាពីរចំនួនគត់ធម្មជាតិ។សំណុំតួចែករួមនៃ $a\&b$ ស្មើនឹងសំណុំតួចែករួមធំបំផុតរបស់វា ។

-ទ្រឹស្តីបទ ៖គ្រប់ចំនួនគត់ធម្មជាតិ $a,b,n$ និងគ្រប់តួចែករួម $d$ នៃ $a\&b$ គេបាន ៖

$\gcd(na,nb)=n\gcd(a,b)$

និង $\gcd\left(\frac{a}{d},\frac{b}{d}\right)=\frac{\gcd(a,b)}{d}$

-ទ្រឹស្តីបទ ៖$a\&b$ ជាពីរចំនួនគត់ធម្មជាតិហើយ $\delta$ ជាតួចែករួមនៃ $a\&b$ ។ $\delta$ ជាតួចែករួមធំបំផុតនៃ $a\&b$ លុះត្រាតែ $\frac{a}{\delta}\&\frac{b}{\delta}$ បឋមរវាងគ្នា

(សម្រាយទំព័រទី២២២,២២៣)

| | | |
|---|---|---|
| -ណែនាំសិស្សឲ្យទាញនិយមន័យ | ១.៥ តួចែករួមធំបំផុតនៃច្រើនចំនួនគត់<br>ក. និយមន័យ | -និយមន័យ ៖ $a_1, a_2, ..., a_n$ ជា $n$ ចំនួនគត់ធម្មជាតិ។តួចែករួមធំបំផុតនៃ $a_1, a_2, ..., a_n$ ជាចំនួនគត់ធម្មជាតិធំជាងគេបណ្ដាតួចែករួមនៃ $a_1, a_2, ..., a_n$ ។និមិត្តសញ្ញា $\delta = \gcd(a_1, a_2, ..., a_n)$ ។ |
| -ណែនាំសិស្សឲ្យទាញលក្ខណៈ | ខ. លក្ខណៈ | -លក្ខណៈទូទៅ<br>$i$ .ដើម្បីរក $\gcd(a_1, a_2, ..., a_n)$ គេរក $\gcd(a_1, a_2) = \delta_1$ រួចរក $\gcd(\delta_1, a_3) = \delta_2, ...$ ហើយធ្វើបែបនេះរហូតដល់ $a_n$ ។<br>$\gcd(a_1, a_2, ..., a_n)$<br>$= \gcd(((a_1, a_2), a_3), ..., a_n)$<br>$ii$ .សំណុំតួចែករួមនៃ $a_1, ..., a_n$ ស្មើសំណុំតួចែកនៃ gcd របស់វា |
| -រក $\gcd(315, 225, 525)$ | | -យើងមាន<br>$\gcd(315, 225) = 45$<br>$\gcd(45, 525) = 15$<br>នោះ $\gcd(315, 225, 525) = 15$ |
| -ណែនាំសិស្សឲ្យធ្វើសម្រាយបញ្ជាក់ទ្រឹស្ដីបទបឺស៊ូ | ១.៦ ទ្រឹស្ដីបទបឺស៊ូ និងទ្រឹស្ដីបទហ្គោស<br>ក. ទ្រឹស្ដីបទបឺស៊ូ | -ទ្រឹស្ដីបទបឺស៊ូ ៖ $a \& b$ ជាចំនួនគត់ធម្មជាតិបឋមរវាងគ្នា លុះត្រាតែមានចំនួនគត់រ៉ឺឡាទីប $u \& v$ ដែល $au + bv = 1$ ។ |

| | | |
|---|---|---|
| -រក $\gcd(12,18)$ និង $\gcd(12,18\cdot5)$ រួចសន្និដ្ឋាន $\gcd(12,18)$ & $\gcd(12,18\cdot5)$<br><br>-ណែនាំសិស្សធ្វើសម្រាយបញ្ជាក់លើទ្រឹស្តីបទហ្គោស<br><br>-ណែនាំសិស្សធ្វើការទាញវិបាក និងស្រាយបញ្ជាក់ | ខ. ទ្រឹស្តីបទហ្គោស | (សម្រាយទំព័រ២២៤)<br>-គេបាន $\gcd(12,18)=6$ និង $\gcd(12,18\cdot5)=6$<br>គេសន្និដ្ឋានបានថា $\gcd(12,18)=\gcd(12,18\cdot5)$<br><br>-ទ្រឹស្តីបទហ្គោស ៖បើផលគុណ $ab$ ចែកដាច់នឹង $c$ ហើយ $c$ & $a$ បឋមរវាងគ្នា នោះ $b$ ចែកដាច់នឹង $c$ ។ មានន័យថា ៖<br>$c\mid ab$ & $\gcd(a,c)=1\Rightarrow c\mid b$<br>(សម្រាយទំព័រ២២៥)<br>-វិបាក ៖បើមួយចំនួនគត់ $n$ ចែកដាច់នឹង $a$ ផង,ចែកដាច់នឹង $b$ ផង ហើយ $a$ & $b$ បឋមរវាងគ្នា នោះ $n$ ចែកដាច់នឹងផលគុណ $ab$ ។ បានន័យថា ៖<br>$a\mid n, b\mid n$ & $\gcd(a,b)=1$<br>$\Rightarrow ab\mid n$<br>(សម្រាយទំព័រ២២៦) |
| - ដោះស្រាយសមីការ $75x+125y=5$ ដែល $x,y\in\mathbb{Z}$ ។ | ជំហានទី៤<br>(ពង្រឹងចំនេះដឹង) | - ដោះស្រាយសមីការ<br>$75x+125y=5$<br>$15x+25y=1$<br>ដោយ $\gcd(15,25)=5\neq1$<br>ដូចនេះសមីការគ្មានឫសក្នុង $\mathbb{Z}$ ទេ ។ |

| | | |
|---|---|---|
| -ដាក់លំហាត់កិច្ចការផ្ទះឲ្យសិស្ស(ដោះស្រាយក្នុង $\mathbb{Z}$ សមីការ $40x+80y=4$) | ជំហានទី៥ (កិច្ចការផ្ទះ) | -សិស្សកត់ត្រា និងស្តាប់ |

# កិច្ចតែងការបង្រៀន

## ជំពូកទី៨ ៖ ភាពចែកដាច់ និងវិធីចែកអឺគ្លីត

## មេរៀនទី៣ ៖ តួចែករួម និងពហុគុណរួម

I. **វត្ថុបំណងនៃមេរៀន ៖** ក្រោយពីរៀនមេរៀននេះចប់សិស្សអាច ៖

- បំនេះដឹង ៖ ប្រាប់ពីលក្ខណៈ និងរបៀបរកពហុគុណរួមតូចបំផុតបានត្រឹមត្រូវតាមរយៈ ឧ. ។
- បំនិន ៖ កំណត់លក្ខណៈ និងរកពហុគុណរួមតូចបំផុតបានត្រឹមត្រូវតាមរយៈលំហាត់គំរូ ។
- ឥរិយាបថ ៖ មានស្មារតីប្រុងប្រយ័ត្ន និងចេះធ្វើការងារជាក្រុម ។

II. **រយៈពេលបង្រៀន ៖** កិច្ចតែងការនេះសម្រាប់រយៈពេល ២ម៉ោងសិក្សា ។

III. **សម្ភារៈឧបទ្ទេស**

- សៀវភៅគ្រូ និង សៀវភៅសិស្ស
- ទ្រឹស្តីចំនួន

IV. **វិធីសាស្ត្របង្រៀន ៖** ប្រើប្រាស់វិធីសាស្ត្រចម្រុះ "ចោទឆ្លើយ , សង្កេត , រិះរក , ..."

V. **ដំណើរនាំមេរៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| -ត្រួតពិនិត្យសណ្តាប់ធ្នាប់ | **ជំហានទី១** | -ប្រធានថ្នាក់រាយការណ៍ |
| -ឲ្យសិស្សឡើងកែកិច្ចការ | **ជំហានទី២** | -ដោះស្រាយសមីការក្នុង $\mathbb{Z}$<br>$40x+80y=4$<br>$10x+20y=1$<br>ដោយ $\gcd(10,20)=10\neq 1$<br>ដូចនេះសមីការគ្មានឫសក្នុង $\mathbb{Z}$ ទេ ។ |
| | **ជំហានទី៣**<br>**២. ពហុគុណរួមតូចបំផុត**<br>**២.១ ពហុគុណរួមតូចបំផុត** | |

| | | |
|---|---|---|
| -ណែនាំសិស្សទាញនិយមន័យ<br><br>-រក $lcm(168,180)$<br><br>-ណែនាំសិស្សទាញជាលក្ខណៈទូទៅក្នុងការរក $lcm(a,b)$<br><br>-គណនា $\frac{1581}{306}-\frac{912}{12312}$ | **ក. និយមន័យ** | -និយមន័យ ៖ ពហុគុណរួមតូចបំផុតនៃពីរចំនួនគត់ធម្មជាតិ $a\&b$ គឺជាចំនួនគត់ធម្មជាតិដែលជាពហុគុណរួមវិជ្ជមាន ហើយតូចជាងគេនៃ $a\&b$ ។<br>-មាន $168=2^3\cdot3\cdot7$ និង $180=2^2\cdot3^2\cdot5$ នោះ:<br>$lcm(168,180)=2^3\cdot3^2\cdot5\cdot7$<br>$=2520$<br>-ជាទូទៅ ៖ ដើម្បីរក $lcm(a,b)$ គេត្រូវ ,<br>១. បំបែក $a\&b$ ជាផលគុណកត្តាបឋម ។<br>២. គណនាផលគុណនៃកត្តាបឋមទាំងអស់ ដោយយកកត្តាដែលមាននិទស្សន្តធំចំពោះកត្តាណាដែលដូចគ្នា ។ ផលគុណនេះជា $lcm(a,b)$ ។<br>-ដោយ $\gcd(1581,306)=51$ និង $\gcd(912,12312)=456$ គេបាន ,<br>$\frac{1581}{306}-\frac{912}{12312}=\frac{31}{6}-\frac{2}{27}$<br>ហើយ $lcm(6,27)=54$<br>គេបាន ,<br>$\frac{31}{6}-\frac{2}{27}=\frac{31\cdot9-2\cdot2}{54}$<br>$=\frac{275}{54}$ |

| | | |
|---|---|---|
| -ណែនាំសិស្សទាញជាទ្រឹស្តីបទ និងធ្វើការស្រាយបញ្ជាក់ | **ខ. ទ្រឹស្តីបទ** | -ទ្រឹស្តីបទ ៖ គ្រប់ពហុគុណនៃ $lcm(a,b)$ គឺជាពហុគុណរួមនៃ $a$ និង $b$ ។ (សម្រាយទំព័រទី ២២៨) |
| -ណែនាំសិស្ស ធ្វើការស្រាយបញ្ជាក់លក្ខណៈ | **២.២ លក្ខណៈនៃពហុគុណរួមតូចបំផុត** | - លក្ខណៈ ៖ គ្រប់ $a,b$ និង $n$ ជាចំនួនគត់ធម្មជាតិ និងគ្រប់តួចែករួម $d$ នៃ $a\&b$ គេបាន ៖<br>១. $lcm(a,b)=lcm(b,a)$<br>២. $lcm(a,a)=a$<br>៣. $lcm(1,a)=a$<br>៤. $lcm(a,na)=na$<br>៥. $lcm(na,nb)=n\cdot lcm(a,b)$<br>៦. $lcm\left(\frac{a}{d},\frac{b}{d}\right)=\frac{lcm(a,b)}{d}$<br>(សម្រាយទំព័រ ២២៩) |
| -រក $lcm(25,15)$ | | -បាន<br>$lcm(25,15)=5\cdot lcm(5,3)$<br>$=5\cdot 15=75$ |
| -ណែនាំសិស្សធ្វើការស្រាយបញ្ជាក់ទ្រឹស្តីបទ | **២.៣ ទំនាក់ទំនងរវាង lcm និង gcd**<br>**ក. ពហុគុណរួមតូចបំផុតនៃពីរចំនួនបឋមរវាងគ្នា** | -ទ្រឹស្តីបទ ៖ បើ $a\&b$ ជាពីរចំនួនគត់ធម្មជាតិបឋមរវាងគ្នានោះ $lcm(a,b)=ab$ ។<br>-ទ្រឹស្តីបទ ៖ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $a\&b$ គេបាន ៖<br>$\gcd(a,b)\cdot lcm(a,b)=ab$<br>ឬ $\delta\mu=ab$ ។ |

| | | |
|---|---|---|
| -រក $lcm(1176,252)$<br><br>-សួរសិស្ស, រកពហុគុណនៃ $5,10,15$ រួចរក $lcm(5,10,15)$<br><br>-ណែនាំឲ្យទាញនិយមន័យ | **ខ. ពហុគុណរួមតូចបំផុតនៃច្រើនចំនួនគត់** | (សម្រាយទំព័រទី ២២៩,២៣០)<br>-មាន $\gcd(1176,252)=84$ (តាមអាល់កូរីតអឺគ្លីត)<br>គេបាន,<br>$lcm(1176,252)=\frac{1176\cdot 252}{\gcd(1176,252)}$<br>$=3528$<br><br>- ពហុគុណនៃ<br>$5$ មាន $5,10,15,20,25,30,...$<br>$10$ មាន $10,20,30,40,...$<br>$15$ មាន $15,30,45,60,75,...$<br>គេបាន , $lcm(5,10,15)=30$<br>-និយមន័យ ៖ ពហុគុណរួមតូចបំផុតនៃ $n$ ចំនួនគត់ធម្មជាតិ $a_1,a_2,...,a_n$ គឺជាចំនួនគត់ធម្មជាតិដែលតូចជាងគេបណ្ដាពហុគុណរួមវិជ្ជមាននៃ $a_1,...,a_n$ ដែលកំណត់សរសេរដោយ, $\mu=lcm(a_1,...,a_n)$ ។<br>១. សំណុំពហុគុណរួមនៃ $a_1,...,a_n$ ស្មើនឹងពហុគុណនៃ $lcm$ របស់វា ។<br>២. ដើម្បីរក $lcm(a_1,...,a_n)$ គេរក $lcm(a_1,a_2)=\mu_1$ រួច $lcm(\mu_1,a_3)$,... ហើយធ្វើបែបនេះរហូតដល់ $a_n$ ។ |
| | | |

| | | |
|---|---|---|
| | **ជំហានទី៤** | |
| -រក $lcm(45,65,85)$ | | -បាន<br>$lcm(45,65)=5\cdot lcm(9,13)$<br>$=5\cdot 9\cdot 13=585$<br>$lcm(585,85)=5\cdot lcm(117,17)$<br>$=5\cdot 117\cdot 17=9945$<br>នោះ $lcm(45,65,85)=9945$ |
| | **ជំហានទី៥** | |
| -កិច្ចការផ្ទះ<br>បើ $lcm(126,70\cdot a)=42$ ចូររកតម្លៃអប្បបរមានៃ $a$ ។ | | -ចម្លងកិច្ចការ និងស្តាប់ ។ |

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ គណិតវិទ្យាថ្នាក់ទី១២
- ជំពូកទី៩ ៖ សមីការប៉ារ៉ាម៉ែត និង កូអរដោនេប៉ូលែ
- មេរៀនទី១ ៖ សមីការប៉ារ៉ាម៉ែត និង កូអរដោនេប៉ូលែ
- រយៈពេល ២ ម៉ោង

## I. វត្ថុបំណងមេរៀន

-ចំណេះដឹង ៖ សិស្សប្រាប់ពីនិយមន័យនៃខ្សែកោងរាប និងសមីការប៉ារ៉ាម៉ែតបាន ត្រឹមត្រូវតាមរយៈឧទាហរណ៍។

-បំនិន ៖ សិស្សកំណត់ សិស្សប្រាប់ពីនិយមន័យនៃខ្សែកោងរាប និងសមីការប៉ារ៉ាម៉ែត និងសង់ក្រាបតាងសមីការប៉ារ៉ាម៉ែតបានត្រឹមត្រូវតាមរយៈលំហាត់គំរូ ។

-ឥរិយាបថ ៖ បណ្តុះស្មារតីរាងវៃប្រុងប្រយ័ត្នក្នុងការសង់ក្រាប ។

## II. សំភារឧបទេស

-សៀវភៅសិស្សទំព័រ ២៣៦

-សៀវភៅគ្រូទំព័រ ២៣៦

-បន្ទាត់ និងប៉ារ៉ាបូល

## III. ដំណើរការនៃមេរៀន

<table>
<tr><th>សកម្មភាពគ្រូ</th><th>ខ្លឹមសារមេរៀន</th><th>សកម្មភាពសិស្ស</th></tr>
<tr><td>-ត្រួតពិនិត្យ</td><td>ជំហានទី១ (រដ្ឋបាលថ្នាក់)<br>អនាម័យ-វិន័យ អវត្តមាន</td><td>-ប្រធានថ្នាក់រាយការណ៍</td></tr>
<tr><td>-ឲ្យសិស្សឡើងកែកិច្ចការ<br>លំហាត់<br>រកGCDតាមអាល់កូរីតអឺគ្លីត<br>នៃ 2468 និង 442។</td><td>ជំហានទី២ (កែកិច្ចការចាស់)<br><br>ចំលើយ<br>រកGCDនៃ2468 និង 442<br>តាមអាល់កូរីតអឺគ្លីត<br>គេបានតារាង
<table>
<tr><td></td><td>5</td><td>1</td><td>1</td><td>2</td><td>2</td><td>18</td></tr>
<tr><td>2468</td><td>442</td><td>258</td><td>184</td><td>74</td><td>36</td><td>2</td></tr>
<tr><td>258</td><td>184</td><td>74</td><td>36</td><td>2</td><td>0</td><td></td></tr>
</table>
តាមតារាងគេបាន<br>GCD(2468,442)=2</td><td>-អនុវត្តន៍ដោះស្រាយលំហាត់<br><br>ចំលើយ<br>រកGCDនៃ2468 និង 442<br>តាមអាល់កូរីតអឺគ្លីត<br>គេបានតារាង
<table>
<tr><td></td><td>5</td><td>1</td><td>1</td><td>2</td><td>2</td><td>18</td></tr>
<tr><td>2468</td><td>442</td><td>258</td><td>184</td><td>74</td><td>36</td><td>2</td></tr>
<tr><td>258</td><td>184</td><td>74</td><td>36</td><td>2</td><td>0</td><td></td></tr>
</table>
តាមតារាងគេបាន<br>GCD(2468,442)=2</td></tr>
<tr><td></td><td>ជំហានទី៣<br>មេរៀនទី១ ៖ សមីការប៉ារ៉ាមែត<br>និង កូអរដោនេប៉ូលែ</td><td></td></tr>
</table>

| | | |
|---|---|---|
| ណែនាំសិស្សពិនិត្យមើលក្រាប-នៃចលនាវត្ថុមួយផ្លាស់ទីក្នុងលំហអាកាសត្រង់មុំ45°។វត្ថុនោមានល្បឿនដើម48cm/sហើយមានគន្លងជាប៉ារ៉ាបូលដែលកំណត់ដោយសមីការ<br>$y=-\frac{x^2}{72}+x$<br>តើវាជាសមីការអ្វី?<br>ដើម្បីកំណត់រយពេលចរតើគេត្រូវធ្វើដូចម្តេច?<br>ណែនាំសិស្សទាញរក x និង y ជាអនុគមន៍នៃ t<br><br>ណែនាំសិស្សអោយធ្វើការសន្និដ្ឋាន<br><br>តើគន្លងនៃចលនាមានឈ្មោះដូចម្តេច?<br><br>ណែនាំសិស្សទាញជានិយមន័យ<br><br>ណែនាំសិស្សនោះស្រាយលំហាត់ Ex គូសខ្សែកោងដែលកំណត់ដោយសមីការប៉ារ៉ាម៉ែត្រ<br>$x=t^2-4$ និង $y=\frac{t}{2}$<br>$-2\le t\le 3$ | 1 ខ្សែកោងរាប និង សមីការប៉ារ៉ាម៉ែត<br>$y=-\frac{x^2}{72}+x$<br><br>សមីការប៉ារ៉ាម៉ែត<br>$x=24\sqrt{2}t$ ;<br>$y=-16t^2+24\sqrt{2}t$ | $y=-\frac{x^2}{72}+x$<br><br>សមីការប៉ារ៉ាម៉ែត<br>$x=24\sqrt{2}t$ ;<br>$y=-16t^2+24\sqrt{2}t$<br>$y=-\frac{x^2}{72}+x$ ជាសមីការដេកាត ដើម្បីកំណត់រយពេលចរគេអាចប្រើអថេរទី៣ ថ្មីមួយទៀតដែលហៅថាប៉ារ៉ាម៉ែត្រ។<br>កូអរដោនេនៃចំនុចមួយនៅរយពេល t គឺ<br>$x=(Vo\cos\theta)t=48cos45^\circ\times t$<br>$=24\sqrt{2}\times t$<br>$y=-\frac{x^2}{72}+x=\frac{(24t\sqrt{2})^2}{72}+24\sqrt{2}\,t$<br>$=-16t^2+24\sqrt{2}\,t$<br>ដោយ x និង y ជាអនុគមន៍នៃ t គេថា $x=24\sqrt{2}\,t$<br>និង $y=-16t^2+24\sqrt{2}\,t$<br>ជាសមីការប៉ារ៉ាម៉ែត្រ ។<br>ចំពោះចលនាពិសេសនេះ $x$ និង $y$ ជាអនុគមន៍នៃ t ហើយគន្លងដែលបាន ហៅថា ខ្សែកោងរាប។<br>និយមន័យ<br>បើ f និង g ជាអនុគមន៍ជាប់នៃអថេរ t នៅលើចន្លោះ I ។ នោះសមីការ $x=f(t)$ និង<br>$y=g(t)$ ហៅថា សមីការប៉ារ៉ាម៉ែត្រនៃ $t$ និង $t$ ហៅថាប៉ារ៉ាម៉ែត្រ។ |

កាលណា t ប្រែប្រួលនៅលើចន្លោះ I សំនុំចំនុចនៃចំនុច (x;y) ដែលហៅថា ក្រាបនៃសមីការប៉ារ៉ាម៉ែត្រ ។ ខ្សែកោងតាងអោយ x=f(t) និង y=g(t) នៅលើចន្លោះI ហៅថាខ្សែកោងរាប។

ដោះស្រាយលំហាត់

ចំពោះ t នៅលើចន្លោះ[-2;3 ] គេបានចំនុច (x;y) ដូចក្នុងតារាង

| t | -2 | -1 | 0 | 1 | 2 | 3 |
|---|---|---|---|---|---|---|
| x | 0 | -3 | -4 | -3 | 0 | 5 |
| y | -1 | -0.5 | 0 | 0.5 | 1 | 1.5 |




ការបំលែងសមីការប៉ារ៉ាម៉ាត្រទៅជាសមីការដេកាត

សមីការប៉ារ៉ាម៉ែត្រ

=>

ដោះស្រាយរក t ក្នុងសមីការមួយ

=>

ជំនួសក្នុងសមីការពីរ

=>

សមីការដេកាត

អនុវត្តន៍ ៖ ដោះស្រាយតាមការណែនាំបំលែងជាសមីការដេកាត

$x = 3\cos\theta \Rightarrow \cos\theta = \frac{x}{3}$

$y = 4\sin\theta \Rightarrow \sin\theta = \frac{y}{4}$

តាមរូបមន្ត ៖

$(\sin\theta)^2 + (\cos\theta)^2 = 1$

គេបាន $\frac{x^2}{9} + \frac{y^2}{16} = 1$

<table>
<tr>
<td></td>
<td></td>
<td>តាមសមីការដេកាតគេឃើញខ្សែកោងនេះជាអេលីបមានផ្ចិតត្រង់(0;0) និងកំពូល(0;4) និង(0;-4) កាត់អ័ក្សតូចត្រង់(-3;0) និង(0;3)។<br>


អនុវត្តន៍តាមការណែនាំជាទូទៅ<br>
ក្រាបនៃសមីការប៉ារ៉ាម៉ែត្រ<br>
$\mathbf{x=h+a\sin\theta}$ និង<br>
$\boldsymbol{y=k+bcos\theta}$ , $\boldsymbol{0\le\theta\le 2\pi}$<br>
ជាអេលីប។គូសផ្ទុយនិងទិសដៅនៃដំនើរនាឡិកាដែលមានសមីការ ៖<br>
$$\frac{(x-h)^2}{a^2}+\frac{(y-k)^2}{b^2}=1$$</td>
</tr>
<tr>
<td>ណែនាំសិស្សបង្កើតគំនូសបំព្រួញបំលែងសមីការប៉ារ៉ាម៉ែត្រទៅជាសមីការដេកាត<br><br>
ណែនាំសិស្សធ្វើលំហាត់ឧទាហរណ៍<br>
គូសខ្សែកោងតាងសមីការប៉ារ៉ាម៉ែត្រ<br>
$x=3\cos\theta$ និង $\mathrm{y}=4\sin\theta$</td>
<td>ជំហានទី៤<br>(ពង្រឹងចំនេះដឹង)</td>
<td>អនុវត្តន៍ដោះស្រាយលំហាត់គំរូ<br>
ចំលើយ<br>
តាងប៉ារ៉ាម៉ែត្រ θ ជារង្វង់មុំដែលជាមុំរង្វិលរបស់ចំនុចP(x;y)ផ្តើមចេញពីគល់តំរុយកូអរដោនេ។<br>
បើ$\theta=0$ នោះ$P(0;0)$<br>
បើ$\theta=\pi$ នោះ $P(\pi a;2a)$<br>
បើ$\theta=2\pi$ នោះ $\mathrm{P}(2\pi a;0)$<br>
តាមរូបគេឃើញថាមុំ<br>
APC=180° $-\,\theta$</td>
</tr>
</table>

| | | |
|---|---|---|
| $0 \le \theta \le 2\pi$<br><br>ណែនាំសិស្សទាញលក្ខណទូទៅ<br><br>ណែនាំសិស្សអោយដោះស្រាយលំហាត់គំរូ<br>កំណត់ខ្សែកោងដែលបានគូសដោយចំនុច P<br>មួយដែលស្ថិតនៅលើរង្វង់មានកាំ a<br>ហើយរមៀលដោយឥតរអិលតាមបន្ទាត់មួយនៅក្នុងប្លង់។ខ្សែកោងនេះហៅថា ស៊ីក្លូអ៊ីត។ |  | ដូចនេះ<br>$sin\theta = \sin(180° - \theta)$<br>$= sinAPC$<br>$= \frac{AC}{a} = \frac{BD}{a}$<br>$cos\theta = -\cos(180° - \theta)$<br>$= sinAPC = -\frac{AP}{a}$<br>$=> AP = -acos\theta$ និង<br>$BC = asin\theta$<br>ដោយរង្វង់នេះរមៀលតាមអ័ក្សអាប់ស៊ីសគេដឹងថា<br>$OD = \widehat{PD} = a\theta$<br>ម្យ៉ាងទៀត$\mathrm{BA} = \mathrm{DC} = \mathrm{a}$<br>គេបាន<br>$x = OD - BD = a\theta - asin\theta$<br>$y = BA + AB = a - acos\theta$<br>ដូចនេះសមីការប៉ារ៉ាម៉ែត្រគឺ<br>$x = a(\theta - sin\theta)$និង<br>$\mathrm{y = a(1 - cos\theta)}$ |
| ដាក់លំហាត់កិច្ចការផ្ទះ<br>លំហាត់<br>គូសខ្សែកោងតាងសមីការប៉ារ៉ាម៉ែត្រ<br>$\begin{cases} x = 4 + 2cos\theta \\ y = -1 + 4sin\theta \end{cases}$ | ជំហានទី៥<br>កិច្ចការផ្ទះ+បណ្ដាំផ្ញើ | ចំលងលំហាត់ទុកធ្វើផ្ទះ |

# កិច្ចតែងការបង្រៀន

- មុខវិជ្ជា : គណិតវិទ្យាថ្នាក់ទី១២
- ជំពូកទី៩ : សមីការប៉ារ៉ាម៉ែត និង កូអរដោនេប៉ូលែ
- មេរៀនទី១ : សមីការប៉ារ៉ាម៉ែត និង កូអរដោនេប៉ូលែ

  ២ ៖ កូអរដោនេប៉ូលែ

  ២.១ ៖ កូអរដោនេប៉ូលែ

  ២.២ ៖ ទំនាក់ទំនងរវាងកូអរដេកាត និងកូអរដោនេប៉ូលែ
- រយៈពេល ២ ម៉ោង

## I. វត្ថុបំណងមេរៀន

-ចំណេះដឹង ៖សិស្សបង្ហាញពីកូអរដោនេប៉ូលែ និង ទំនាក់ទំនងរវាងកូអរដោនេដេកាត និងកូអរដោនេប៉ូលែបានត្រឹមត្រូវ តាមរយៈឧទាហរណ៍។

-បំនិន ៖ សិស្សសង់ក្រាបនៃអនុគមន៍ប៉ូលែបានត្រឹមត្រូវតាមរយៈ លំហាត់គំរូ។

-ឥរិយាបថ ៖ បណ្តុះស្មារតីវាងវៃ និង ស្រលាញ់ការសិក្សាវិទ្យាសាស្រ្តគណិតវិទ្យា។

## II. សំភារឧបទេស

-សៀវភៅសិស្សទំព័រ ២៤១

-សៀវភៅគ្រូទំព័រ ២៤១

## III . ដំណើរការមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យ | ជំហានទី១ (រដ្ឋបាលថ្នាក់)<br>-អនាម័យ វិន័យ អវត្តមាន | -ប្រធានថ្នាក់រាយការណ៍ |
| លំហាត់<br>គូសខ្សែកោងតាងសមីការប៉ារ៉ាម៉ែត្រ<br>$\begin{cases} x = 4 + 2cos\theta \\ y = -1 + 4sin\theta \end{cases}$ | ជំហានទី២<br>(កែកិច្ចការចាស់) | ចំលើយ<br>បំលែងជាសមីការដេកាត<br>$x = 4 + 2cos\theta \Rightarrow cos\theta = \frac{x-4}{2}$<br>$y = -1 + 4sin\theta \Rightarrow sin\theta = \frac{y+1}{4}$<br>តាមរូបមន្ត $cos^2\theta + sin^2\theta = 1$<br>គេបាន $\frac{(x-4)^2}{2^2} + \frac{(y+1)^2}{4^2} = 1$<br>មានក្រាបជាអេលីបដែលមាន<br>$C(4;-1)$ , $S_1(4;3)$ , $S_2(4;5)$ ,<br>$F_1(4;2\sqrt{3}-1)$ , $F_2(4;-2\sqrt{3}-1)$ |

| | | |
|---|---|---|
| | | <br> |
| <br>តើតំរុយកូអរដោនេប៉ូលែ<br>មានលក្ខណដូចម្ដេច?<br><br><br><br><br><br>ណែនាំសិស្សធ្វើលក្ខណ<br>សំគាល់<br><br><br><br><br>ណែនាំសិស្សទាញជា<br>លក្ខណទូទៅ<br><br><br>ណែនាំសិស្សដោះស្រាយ<br>លំហាត់គំរូ<br>រកអរដោនេប៉ូលែផ្សេង<br>ទៀតនៃ ចំនុច $(2;\frac{\pi}{6})$ | ជំហានទី៣<br>មេរៀនទី១<br>សមីការប៉ារ៉ាម៉ែត្រ និង<br>កូអរដោនេប៉ូលែ<br>២. កូអរដោនេប៉ូលែ<br><br> | <br>លក្ខណតំរុយកូអរដោនេប៉ូលែ<br>ចំនុចនឹងOមួយហៅថាប៉ូលែ<br>កន្លះបន្ទាត់ដើមមួយហៅថាអ័ក្ស<br>ប៉ូលែ OP= $\theta$ជារង្វាស់មុំមានទិស<br>ដៅ ផ្គុំដោយអ័ក្សប៉ូលែ និង អង្កត់<br>OP បើ$0 \le \theta \le 2\pi$នោះចំនុចនី<br>មួយៗនៃប្លង់កំណត់ដោយគូ)r; $\theta$)<br>តែមួយគត់លើកលែងតែគល់)<br>O( បើ$\theta$យកតំលៃក្នុង IRនោះចំនុច<br>មួយនៃប្លង់កំណត់ដោយគូ)r; $\theta$)<br>ច្រើនដែលតាងដោយ$(r;\theta+2\pi n)$<br>ជាទូទៅ ៖ចំនុចមួយនៅក្នុងប្លង់<br>មានកូអរដោនេប៉ូលែ$(r;\theta)$ ឬ<br>$(r;\theta+2\pi n)$ដែលមាន n ជាចំនួន<br>គត់រ៉ឺឡាទីប។<br>ចំលើយ ៖ រកអរដោនេប៉ូលែនៃ<br>$(2;\frac{\pi}{6})$មានច្រើន ដូចជា<br>$n=1$ គេបាន $(2;\frac{12\pi}{6})$<br>$n=2$ គេបាន $(2;\frac{25\pi}{6})$<br>- - - - - - - - - - - - - - |

<table>
<tr>
<td>ណែនាំសិស្សឲ្យសង់រូប<br>ដោយយកអ័ក្សប៉ូលែឲ្យ<br>ត្រួតស៊ីគ្នាជាមួយនឹង<br>ប៉ូលែឲ្យត្រួតស៊ីជាមួយ<br>នឹងគល់តំរុយ<br>ចូរទាញរក x & y ជា<br>អនុគមន៍នៃr និង $\theta$</td>
<td>២.ទំនាក់ទំនងរវាងកូអរដោនេ<br>ដេកាតនិង អរដោនេប៉ូលែ</td>
<td>
<br>$cos\theta = \frac{x}{r} \Rightarrow x = rcos\theta$<br>$sin\theta = \frac{y}{r} \Rightarrow y = rsin\theta$</td>
</tr>
<tr>
<td>ណែនាំសិស្សទាញជា<br>លក្ខណទូទៅ</td>
<td></td>
<td>ម្យ៉ាងទៀត $cos^2\theta + sin^2\theta = 1$<br>នាំឲ្យ $x^2 + y^2 = r^2$ ហើយ $\tan\theta = \frac{y}{x}$<br>ជាទូទៅ<br>កូអរដោនៃប៉ូលែ$(r;\theta)$និងកូអរដោនេ<br>ដេកាត)x;y) នៃចំនុចមួយមានទំនាក់<br>ទំនងគ្នាដូចខាងក្រោម<br>$x = rcos\theta \ ; y = rsin\theta$<br>$r^2 = x^2 + y^2 \ ; tan\theta = \frac{y}{x}$ បើ $x \neq 0$</td>
</tr>
<tr>
<td>ណែនាំសិស្សដោះ<br>ស្រាយលំហាត់គំរូ<br>បំលែងកូអរដោនេប៉ូលែ<br>ទៅជាកូអរដោនេដេកាត<br>រួចដៅនៅក្នុងតំរុយកូអរ<br>ដោនេដេកាត$(2;\pi)$</td>
<td></td>
<td>អនុវត្តន៍ដោះស្រាយ<br>ចំលើយ<br>គេមាន $(r;\theta) = (2;\pi)$<br>គេបាន $x = rcos\theta = 2cos\pi = -2$<br>$y = rsin\theta = 2sin\pi = 0$</td>
</tr>
<tr>
<td>ណែនាំសិស្សដោះស្រាយ<br>ឧទាហរណ៍<br>គូសក្រាបនៃសមីការប៉ូលែ<br>$r = 2 + 2cos\theta$<br>តើr ប្រែប្រួលដូចម្ដេច?<br>ចូរបង្កើតតារាងតំលៃនៃ<br>សមីការប៉ូលែ</td>
<td>២.៣ ក្រាបនៃសមីការប៉ូលែ</td>
<td>អនុវត្តន៍<br>ដោយអនុគមន៍កូស៊ីនុសចុះពី 1 ទៅ -1<br>កាលណា$\theta$ប្រែប្រួលពី0 ទៅ $\pi$<br>នាំឲ្យr ចុះពី4 ទៅ 0។<br>តារាងសមីការប៉ូលែ<br>
<table>
<tr><td>θ</td><td>0</td><td>$\frac{\pi}{6}$</td><td>$\frac{\pi}{4}$</td><td>$\frac{\pi}{3}$</td><td>$\frac{\pi}{2}$</td><td>$\frac{2\pi}{3}$</td><td>$\frac{3\pi}{4}$</td><td>$\frac{5\pi}{6}$</td><td>$\pi$</td></tr>
<tr><td>$r$</td><td>4</td><td>$2+\sqrt{3}$</td><td>$2+\sqrt{2}$</td><td>3</td><td>2</td><td>1</td><td>$2-\sqrt{2}$</td><td>$2-\sqrt{3}$</td><td>0</td></tr>
</table>
បើθកើនឡើង $\pi$ ទៅ $2\pi$ នោះ $cos\theta$<br>កើនពី-1 ទៅ 1 គេបាន r ពី 0 ទៅ<br>4។គេដៅចំនុចចំពោះ$\pi \leq \theta \leq 2\pi$</td>
</tr>
</table>

<table>
<tr>
<td></td>
<td></td>
<td>នៅពាក់កណ្តាលផ្នែកខាងក្រោមនៃក្រាប<br><br><br>$r = 2 + 2cos\theta$<br>ជាទូទៅ<br>ចំពោះគ្រប់ចំនួនពិត $a \neq 0$<br>សមីការប៉ូលែដែលមានទំរង់ណាមួយខាងក្រោម<br>$r = a(1 + cos\theta)\ ; r = a(1 + sin\theta)$<br>$r = a(1 - cos\theta)\ ; r = a(1 - sin\theta)$<br>មានក្រាបជាកាដ្យូអ៊ីត Cardioid ។<br>សមីការប៉ូលែដែលមានទំរង់ណាមួយខាងក្រោម $r = a + bcos\theta$<br>ឬ $r = a + bsin\theta$<br>មានក្រាបជាលីម៉ាសុន ។</td>
</tr>
<tr>
<td>ដាក់លំហាត់ឲ្យសិស្សដោះស្រាយលំហាត់គូសក្រាបនៃសមីការប៉ូលែ<br>$r = 2 + 4cos\theta$</td>
<td>ជំហានទី៤<br>(ពង្រឹងចំនេះដឹង)<br>
<table>
<tr><td>$\theta$</td><td>0</td><td>$\frac{\pi}{6}$</td><td>$\frac{\pi}{4}$</td><td>$\frac{\pi}{3}$</td><td>$\frac{\pi}{2}$</td><td>$\frac{2\pi}{3}$</td><td>$\frac{3\pi}{4}$</td><td>$\frac{5\pi}{6}$</td><td>$\pi$</td></tr>
<tr><td>$r$</td><td>4</td><td>$2+2\sqrt{3}$</td><td>$2+2\sqrt{2}$</td><td>4</td><td>2</td><td>0</td><td>$2-2\sqrt{2}$</td><td>$2-2\sqrt{3}$</td><td>-2</td></tr>
</table>
</td>
<td>អនុវត្តន៍ដោះស្រាយ<br>ចំលើយ ៖ គូអរដោនេនៃចំនុចខ្លះៗត្រូវនឹង $0 \leq \theta \leq \pi$<br>មានដូចតារាងខាងឆ្វេង<br><br>គេកត់សំគាល់ឃើញថា r=0ត្រង់ $\theta = \frac{2\pi}{3}$<br>តម្លៃ $r < 0$ បើ $\frac{2\pi}{3} \leq \theta \leq \pi$<br>នោះគេបានពាក់កណ្តាលផ្នែកខាងក្រោមនៃគំនូចតូច និង ពាក់កណ្តាលផ្នែកខាងក្រោមនៃគំនូចធំ។យក $\theta$នៅចន្លោះពី $\pi$ ទៅ $2\pi$ នាំឲ្យគេបានពាក់កណ្តាលផ្នែកខាងលើនៃគំនូចតូច និង ពាក់កណ្តាលផ្នែកខាងលើនៃគំនូចធំ។</td>
</tr>
</table>

| | | |
|---|---|---|
| | |  $r = 2 + 4cos\theta$ |
| ដាក់លំហាត់ឲ្យសិស្ស + លំហាត់ គូសក្រាបនៃសមីការប៉ូលែ $r = 2cos3\theta$ | ជំហានទី៥ (កិច្ចការផ្ទះ+បណ្តាំផ្ញើ) | ចំលងលំហាត់ទុកធ្វើនៅផ្ទះ។ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតមូលដ្ឋាន)

## ជំពូកទី៦ ប្រូបាប

## មេរៀនទី១ ប្រូបាប

### 1. លំហសំណាក និងព្រឹត្តិការណ៍

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សបានកំណត់និយមន័យនៃពាក្យ ពិសោធន៍ចៃដន្យវិញ្ញាសាលំហសំណាក
- បំណិន: សិស្សដោះស្រាយលំហាត់គម្រូបានត្រឹមត្រូវ
- ឥរិយាបថ: សិស្សចូលរួមដោះស្រាយដោយយកចិត្តទុកដាក់

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ១៩៨-១៩៩
- សៀវភៅគ្រូ: ទំព័រ
- កាក់ គ្រាប់ឡុកឡាក់

### IV. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - គ្រូតពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| - គ្រូសួរ: ថង់មួយមានឃ្លី៤ ពណ៌ខៀវ ក្រហម ខ្មៅ និងស<br>+បើប្អូនលូកដៃចាប់យកឃ្លី១ពីថង់។តើប្អូនដឹងថាបានឃ្លីពណ៌អ្វី?<br>+តើមានប៉ុន្មានករណីផ្សេងគ្នា | ការចាប់យកឃ្លី១ពីថង់ដែលមានពណ៌ខៀវ ក្រហម ខ្មៅ និងស | -សិស្សឆ្លើយ<br>+គេមិនអាចដឹងបានឃ្លីពណ៌អ្វីមួយប្រាកដនោះទេ<br>+មាន៤ករណីផ្សេងគ្នា |

| | | |
|---|---|---|
| ដែលអ្នកអាចចាប់បាន? | | |
| **ជំហានទី៣** (មេរៀនប្រចាំថ្ងៃ) | | |
| -គ្រូសរសេរមេរៀនថ្មី<br>1. "ប្រូបាប" និងចំណាងជើងរង<br>-គ្រូអោយសិស្សអានឧទាហរណ៍<br>រួចបញ្ជាក់ថានេះជាពិសោធន៍ចៃដន្យ។<br>-គ្រូអោយសិស្សកំណត់ន័យរបស់ពាក្យ "ពិសោធន៍ចៃដន្យ<br>-គ្រូអោយសិស្សអានឧទាហរណ៍២និង៣រួចបញ្ជាក់ថាក្នុងការកំណត់បោះកាក់១ដងឬ២ដង...ឬការចាប់យកបណ្ណម្តងមួយៗចំនួន២លើកចេញពីថង់ដោយមិនដាក់វិញថាជា"វិញ្ញាសា"។<br>-គ្រូអោយសិស្សកំណត់ន័យរបស់ពាក្យវិញ្ញាសា<br>-គ្រូអោយសិស្សពិនិត្យឧទាហរណ៍និងឆ្លើយសំណួរ | មេរៀនទី១ **ប្រូបាប**<br>**1.លំហសំណាកនិងព្រឹត្តិការណ៍**<br>**1.1.ពិសោធន៍ចៃដន្យវិញ្ញាសា**<br>ឧ១.នៅពេលដែលគេបោះកាក់១គេមិនអាចដឹងច្បាស់ជាមុនថាកាក់នោះផ្ងារឡើងខាងរូបឬមួយខាងលេខនោះទេ។<br>-ពិសោធន៍ចៃដន្យគឺជាពិសោធន៍មួយដែលគេធ្វើដោយមិនបានដឹងជាមុនថាមានលទ្ធផលអ្វីមួយប្រាកដកើតឡើងនោះទេ។<br>ឧ២,៣.បើគេយកកាក់មួយមកពិសោធន៍ដោយកំណត់ជាក់លាក់ថា គេបោះកាក់១ដងឬ២ដងឬ៣ដង...ឬបើគេយកសន្លឹកបណ្ណម្តងមួយៗចំនួន២លើកចេញពីថង់ដោយចៃដន្យហើយមិនដាក់ចូលថង់វិញ (ថង់មានសន្លឹកបណ្ណ៤ចុះលេខ១,២,៣និង៤)។<br>-វិញ្ញាសាគឺជាពិសោធន៍មួយដែលគេកំណត់ធ្វើដោយជាក់លាក់ក្នុងពិសោធន៍ចៃដន្យមួយ។<br>**1.2.លំហសំណាក**<br>ឧ: គេបោះកាក់មួយដែលមានមុខ HនិងTចំនួនពីរដង។តើមានលទ្ធផលប៉ុន្មានរបៀបកើតឡើង? | -សិស្សកត់ត្រា<br>-សិស្សស្តាប់ដោយយកចិត្តទុកដាក់<br>-សិស្សឡើងឆ្លើយ: ពិសោធន៍ចៃដន្យជាពិសោធន៍មួយដែលគេធ្វើដោយមិនបានដឹងជាមុនថាមានលទ្ធផលអ្វីមួយប្រាកដកើតឡើងនោះទេ។<br>-សិស្សអាននិងស្តាប់ដោយយកចិត្តទុកដាក់<br>-សិស្សឆ្លើយ: វិញ្ញាសាគឺជាពិសោធន៍មួយដែលគេកំណត់ធ្វើដោយជាក់លាក់ក្នុងពិសោធន៍ចៃដន្យមួយ<br>-ក្រោយពីពិភាក្សាគ្នារួចសិស្សឡើងបកស្រាយ: ៤របៀប(TT),(TH),(HT),និង |

| | | |
|---|---|---|
| -គ្រូបញ្ជាក់ថាសំណុំលទ្ធផលដែលអាចកើតឡើងទាំងអស់ក្នុងវិញ្ញាសានេះហៅថា"សំណុំសំណាកឬលំហសំណាក" -គ្រូអោយសិស្សកំណត់ន័យរបស់ពាក្យលំហសំណាក<br><br>-គ្រូអោយសិស្សកត់លំហាត់គម្រូរួចពិភាក្សារកចម្លើយ | -លំហសំណាកឬសំណុំសំណាកគឺជាសំណុំលទ្ធផលទាំងអស់ដែលអាចកើតឡើងក្នុងវិញ្ញាសាមួយនៃពិសោធន៍ចៃដន្យ។<br>-លំហាត់គម្រូ:<br>គេបោះគ្រាប់ឡុកឡាក់មួយចំនួន ២ដង។<br>ក.តើសកម្មភាពណាជាពិសោធន៍ចៃដន្យ?ជាវិញ្ញាសា?<br>ខ.ចូរសរសេរលំហសំណាក<br><u>ចម្លើយ</u><br>ក.ពិសោធន៍ចៃដន្យគឺជាសកម្មភាពបោះគ្រាប់ឡុកឡាក់។វិញ្ញាសាគឺជាសកម្មភាពបោះគ្រាប់ឡុកឡាក់មួយចំនួន២ដង។<br>ខ.លំហសំណាក<br>$S=\{(1,1),(1,2),\ldots,(6,1),(6,2),(6,3),(6,4),(6,5),(6,6)\}$<br>មាន៣៦ករណីផ្សេងគ្នា។ | (HH)។<br><br>-សិស្សគិតរួចឆ្លើយថាលំហសំណាកគឺជាសំណុំលទ្ធផលទាំងអស់ដែលអាចកើតឡើងក្នុងវិញ្ញាសាមួយនៃពិសោធន៍ចៃដន្យ។<br><br>-សិស្សពិភាក្សារួចឆ្លើយ<br>ក.ពិសោធន៍ចៃដន្យគឺជាសកម្មភាពបោះគ្រាប់ឡុកឡាក់។វិញ្ញាសាគឺជាសកម្មភាពបោះគ្រាប់ឡុកឡាក់មួយចំនួន២ដង។<br>ខ.លំហសំណាក់<br>$S=\{(1,1),(1,2),\ldots,(6,1),\ldots,(6,6)\}$<br>សរុបមាន៣៦ករណីផ្សេងគ្នា។ |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -អោយសិស្សពិភាក្សាប្រតិបត្តិរួចឆ្លើយនឹងសំណួរ | **ប្រតិបត្តិ:**គេចាប់យកឃ្លីម្តង២គ្រាប់ចេញពីថង់មួយដោយចៃដន្យដែលក្នុងនោះមានឃ្លីក្រហម២ លឿង២ និងខៀវ១។<br>ក.តើសកម្មភាពណាជាពិសោធន៍ | -សិស្សពិភាក្សាលើលំហាត់ប្រតិបត្តិរួចឡើងឆ្លើយ |

| | | |
|---|---|---|
| | ចៃដន្យ?ជាវិញ្ញាសា?<br>ខ.ចូរសរសេរលំហសំណាក<br>ចម្លើយ<br>ក.ពិសោធន៍ចៃដន្យជាសកម្មភាពយកឃ្លីពីថង់។វិញ្ញាសាជាសកម្មភាពចាប់យកឃ្លីម្តង២ចេញពីថង់។<br>ខ.លំហសំណាក់<br>$S=\{\{R_1R_2\},\{R_1Y_1\},\{R_1Y_2\},$ $\{R_1B\},\{R_2Y_1\},\{R_2Y_2\},$ $\{R_2B\},\{Y_1Y_2\},\{Y_1B\},\{Y_2B\}\}$<br>ដែល $R=$ក្រហម, $Y=$លឿង<br>$B=$ខៀវ | ក.ពិសោធន៍ចៃដន្យគឺជាសកម្មភាពចាប់យកឃ្លីចេញពីថង់។វិញ្ញាសាជាសកម្មភាពចាប់យកឃ្លីម្តង២ចេញពីថង់។<br>ខ.លំហសំណាក់<br>$S=\{\{R_1R_2\},\{R_1Y_1\},\{R_1Y_2\},$ $\{R_1B\},\{R_2Y_1\},\{R_2Y_2\},$ $\{R_2B\},\{Y_1Y_2\},\{Y_1B\},$ $\{Y_2B\}\}$<br>ដែល $R=$ក្រហម,<br>$Y=$លឿង, $B=$ខៀវ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -ចូរប្អូនបង្កើតពិសោធន៍ដោយខ្លួនឯងហើយកំណត់ថាតើសកម្មភាពមួយណាជាពិសោធន៍ចៃដន្យ ណាមួយជាវិញ្ញាសា ហើយមានអ្វីជាលំហសំណាក់។ | | -សិស្សស្តាប់និងសន្យាធ្វើដោយខ្លួនឯង |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតមូលដ្ឋាន)

## ជំពូកទី៦ ប្រូបាប

## មេរៀនទី១ ប្រូបាប

1. លំហសំណាក និងព្រឹត្តិការណ៍

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សបានកំណត់ន័យនៃពាក្យ ព្រឹត្តិការណ៍ ព្រឹត្តិការណ៍សមាស បានត្រឹមត្រូវតាមរយៈឧទាហរណ៍
- បំណិន: សិស្សដោះស្រាយលំហាត់គម្រូបានត្រឹមត្រូវ
- ឥរិយាបថ: សិស្សសហការដោះស្រាយលំហាត់ដោយយកចិត្តទុកដាក់

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២០០-២០៤
- សៀវភៅគ្រូ: ទំព័រ
- កាក់ ឃ្លី គ្រាប់ឡុកឡាក់

### IV. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| - គេបោះគ្រាប់ឡុកឡាក់២ព្រមគ្នា។<br>ក.តើសកម្មភាពណាជាពិសោធន៍ចៃដន្យ?ជាវិញ្ញាសា?<br>ខ.ចូរសរសេរលំហសំណាក់ | ក.ពិសោធន៍ចៃដន្យជាសកម្មភាពបោះគ្រាប់ឡុកឡាក់។វិញ្ញាសាជាសកម្មភាពបោះគ្រាប់ឡុកឡាក់២ព្រមគ្នា។<br>ខ.លំហសំណាក់ | ក.ពិសោធន៍ចៃដន្យគឺជាសកម្មភាពបោះគ្រាប់ឡុកឡាក់។វិញ្ញាសាគឺជាសកម្មភាពបោះគ្រាប់ឡុកឡាក់មួយចំនួន២ដង។ |

| | | |
|---|---|---|
| | $S=\{(1,1),(1,2),\ldots,(6,1),(6,2),$ $(6,3),(6,4),(6,5),(6,6)\}$<br>ស្មើនឹង៣៦ករណី | ខ.លំហសំណាក់<br>$S=\{(1,1),(1,2),\ldots,$ $(6,1),\ldots,(6,6)\}$<br>សរុបមាន៣៦ករណីផ្សេងគ្នា។ |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| -គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន | មេរៀនទី១ **ប្រូបាប** (**ត**)<br>**1.3 ព្រឹត្តិការណ៍**<br>**ក. ព្រឹត្តិការណ៍** | -សិស្សកំណត់ចំណងជើងមេរៀនថ្មី |
| -គ្រូអោយឧទាហរណ៍១: ក្នុងវិញ្ញាសាបោះកាក់មួយចំនួន២ដង តើមានករណីដែលមុខខាងរូបHកើតឡើងតែ១ដងគត់? | -មានពីរករណីគឺ(HT),(TH) | -មានពីរករណីគឺ<br>$\{(TH),(HT)\}$ |
| -គ្រូបញ្ជាក់ថាលទ្ធផលដែលកើតឡើងស្របតាមបំណងប្រាថ្នានេះហៅថាព្រឹត្តិការណ៍ រួចអោយសិស្សកំណត់ន័យនៃពាក្យព្រឹត្តិការណ៍។<br>-អោយឧទាហរណ៍២: ក្នុងថង់មួយមានឃ្លីក្រហម១ ខៀវ១ និងលឿង១។គេចាប់យកឃ្លីម្តងមួយដោយចៃដន្យចេញពីថង់រួចដាក់ចូលថង់វិញចំនួន២ដង។តាមរយៈពិសោធន៍នេះគ្រូវណែនាំអោយសិស្សយ៉ាងច្បាស់ ថាតើអ្វីជាព្រឹត្តិការណ៍ឯកធាតុព្រឹត្តិការណ៍មិនអាចមានព្រឹត្តិការណ៍ប្រាកដ។ | -ព្រឹត្តិការណ៍ជាសំណុំរងនៃលំហសំណាក់។<br>+ព្រឹត្តិការណ៍ដែលលទ្ធផលកើតឡើងមានតែមួយករណីគត់ហៅថា "ព្រឹត្តិការណ៍ឯកធាតុ"។<br>+ព្រឹត្តិការណ៍ដែលគ្មានលទ្ធផលណាមួយកើតឡើងនៅក្នុងលំហសំណាក់ហៅថា "ព្រឹត្តិការណ៍មិនអាចមាន"។<br>+ព្រឹត្តិការណ៍ដែលគ្រប់លទ្ធផលទាំងអស់ដូចក្នុងលំហសំណាក់ហៅថា "ព្រឹត្តិការណ៍ប្រាកដ"។ | -សិស្សស្តាប់យ៉ាងយកចិត្តទុកដាក់រួចបានកំណត់ថាព្រឹត្តិការណ៍ជាសំណុំរងនៃលំហសំណាក់។<br>+ព្រឹត្តិការណ៍ដែលលទ្ធផលកើតឡើងមានតែមួយករណីគត់ហៅថា "ព្រឹត្តិការណ៍ឯកធាតុ"។<br>+ព្រឹត្តិការណ៍ដែលគ្មានលទ្ធផលណាមួយកើតឡើងនៅក្នុងលំហសំណាក់ហៅថា "ព្រឹត្តិការណ៍មិនអាចមាន"។<br>+ព្រឹត្តិការណ៍ដែលគ្រប់លទ្ធផលទាំងអស់ដូចក្នុងលំហសំណាក់ហៅថា "ព្រឹត្តិការណ៍ប្រាកដ"។ |

| | | |
|---|---|---|
| -លំហាត់គំរូ:<br>គេធ្វើវិញ្ញាសាបោះគ្រាប់ឡុកឡាក់២គ្រាប់មួយតូចមួយធំ។<br>ក.ចូរកំណត់ព្រឹត្តិការណ៍<br>$B_1$ : "គ្រាប់ឡុកឡាក់ធំចេញលេខ៤"<br>$B_2$ : "គ្រាប់ឡុកឡាក់ធំចេញលេខសេស"<br>$B_3$ : "គ្រាប់ឡុកឡាក់តូចចេញលេខ៣ គ្រាប់ឡុកឡាក់ធំចេញលេខ៥"<br>$B_4$ : "គ្រាប់ឡុកឡាក់តូចចេញលេខ១ គ្រាប់ធំចេញលេខ៧"<br>ខ.តើព្រឹត្តិការណ៍ណាជាព្រឹត្តិការណ៍ឯកធាតុ? | $B_1=\{(4,1),(4,1),(4,3),$<br>$(4,4),(4,5),(4,6)\}$<br>$B_2=\{(1,1),(1,2),\ldots,(3,1),$<br>$(3,2),\ldots,(5,5),(5,6)\}$<br>$B_3=\{(3,5)\}$<br>$B_4$ ជាព្រឹត្តិការណ៍មិនអាចមាន<br>ខ.ព្រឹត្តិការណ៍ $B_3$ ជាព្រឹត្តិការណ៍ឯកធាតុ។ | $B_1=\{(4,1),(4,1),(4,3),$<br>$(4,4),(4,5),(4,6)\}$<br>$B_2=\{(1,1),(1,2),\ldots,(3,1),$<br>$(3,2),\ldots,(5,6)\}$<br>$B_3=\{(3,5)\}$<br>$B_4$ ជាព្រឹត្តិការណ៍មិនអាចមាន<br>ខ.ព្រឹត្តិការណ៍ $B_3$ ជាព្រឹត្តិការណ៍ឯកធាតុ។ |
| -គ្រូដាក់ឧទាហរណ៍រួចណែនាំអោយសិស្សកំណត់និយមន័យនៃព្រឹត្តិការណ៍សមាសនីមួយៗ។ | **ខ.ព្រឹត្តិការណ៍សមាស**<br>+ព្រឹត្តិការណ៍ផលគុណនៃAនិងB ជាប្រសព្វនៃព្រឹត្តិការណ៍Aនិងព្រឹត្តិការណ៍B។<br>+ព្រឹត្តិការណ៍ផលបូកនៃAនិងBជាប្រជុំនៃព្រឹត្តិការណ៍AនិងB។<br>+ព្រឹត្តិការណ៍Bនិងព្រឹត្តិការណ៍Dជាព្រឹត្តិការណ៍មិនចុះសម្រុងគ្នា កាលណាព្រឹត្តិការណ៍ផលគុណនៃBនិងDជាព្រឹត្តិការណ៍មិនអាចមាន:<br>$B\cap D=\varnothing$ ។<br>+ព្រឹត្តិការណ៍២ជាព្រឹត្តិការណ៍ផ្ទុយគ្នាឬជាព្រឹត្តិការណ៍បំពេញគ្នា កាលណាព្រឹត្តិការណ៍ផលគុណនៃ | +ព្រឹត្តិការណ៍ផលគុណនៃAនិងBជាប្រសព្វនៃព្រឹត្តិការណ៍Aនិងព្រឹត្តិការណ៍B។<br>+ព្រឹត្តិការណ៍ផលបូកនៃAនិងBជាប្រជុំនៃព្រឹត្តិការណ៍AនិងB។<br>+ព្រឹត្តិការណ៍Bនិងព្រឹត្តិការណ៍Dជាព្រឹត្តិការណ៍មិនចុះសម្រុងគ្នា កាលណាព្រឹត្តិការណ៍ផលគុណនៃBនិងDជាព្រឹត្តិការណ៍មិនអាចមាន<br>$B\cap D=\varnothing$ ។ |

| | | |
|---|---|---|
| -គ្រូដាក់លំហាត់គំរូអោយសិស្សពិភាក្សាតាមក្រុមដើម្បីរកចម្លើយ។<br>គេបោះគ្រាប់ឡុកឡាក់មួយគ្រាប់។គេតាង $A$ ជាព្រឹត្តិការណ៍ដែលគ្រាប់ឡុកឡាក់ចេញលេខគូ $B$ ជាព្រឹត្តិការណ៍ដែលគ្រាប់ឡុកឡាក់ចេញលេខជាពហុគុណនៃ៣និង $C$ ជាព្រឹត្តិការណ៍ដែលគ្រាប់ឡុកឡាក់ចេញលេខតូចជាងឬស្មើនឹង២។ចូរកំណត់:<br>ក.លំហាសំណាក់និងព្រឹត្តិការណ៍ $A,B,C$<br>ខ.ព្រឹត្តិការណ៍ផលគុណ<br>$A\cap B, A\cap C, B\cap C$<br>គ.ព្រឹត្តិការណ៍ផលបូក<br>$A\cup B,\ B\cup C$<br>ឃ.ព្រឹត្តិការណ៍ផ្ទុយនឹងព្រឹត្តិ | ព្រឹត្តិការណ៍ទាំង២ជាព្រឹត្តិការណ៍មិនអាចមាននិងព្រឹត្តិការណ៍ផលបូកនៃព្រឹត្តិកាណ៍ទាំងពីរជាព្រឹត្តិការណ៍ប្រាកដ:<br>$A\cap\overline{A}=\varnothing$ , $A\cup\overline{A}=S$<br>គេបានព្រឹត្តិការណ៍២ផ្ទុយគ្នាជាព្រឹត្តិការណ៍មិនចុះចម្រុង។<br><br><u>ចម្លើយ</u><br>ក.លំហសំណាក់<br>$S=\{1,2,3,4,5,6\}$<br>$A=\{2,4,6\}$<br>$B=\{3,6\}$<br>$C=\{1,2\}$<br>ខ.ព្រឹត្តិការណ៍ផលគុណ<br>$A\cap B=\{6\}$<br>$A\cap C=\{2\}$<br>$B\cap C=\varnothing$<br>គ.ព្រឹត្តិការណ៍ផលបូក<br>$A\cup B=\{2,3,4,6\}$<br>$B\cup C=\{1,2,3,6\}$<br>ឃ.ព្រឹត្តិការណ៍ផ្ទុយនឹងព្រឹត្តិការណ៍ $A,B,C$ គឺ<br>$\overline{A}=\{1,3,5\}$<br>$\overline{B}=\{1,2,4,5\}$<br>$\overline{C}=\{3,4,5,6\}$<br>ង.ដោយ $B\cap C=\varnothing$ នោះ $B$ និង $C$ ជាព្រឹត្តិការណ៍មិនចុះសម្រុង។ | +ព្រឹត្តិការណ៍២ជាព្រឹត្តិការណ៍ផ្ទុយគ្នាឬជាព្រឹត្តិការណ៍បំពេញគ្នា កាលណាព្រឹត្តិការណ៍ផលគុណនៃព្រឹត្តិការណ៍ទាំង២ជាព្រឹត្តិការណ៍មិនអាចមាននិងព្រឹត្តិការណ៍ផលបូកនៃព្រឹត្តិការណ៍ទាំងពីរជាព្រឹត្តិការណ៍ប្រាកដ:<br>$A\cap\overline{A}=\varnothing$ , $A\cup\overline{A}=S$<br>គេបានព្រឹត្តិការណ៍២ផ្ទុយគ្នាជាព្រឹត្តិការណ៍មិនចុះសម្រុង។<br>-សិស្សពិភាក្សារួចផ្តល់<br>ចម្លើយ<br>ក.លំហសំណាក់<br>$S=\{1,2,3,4,5,6\}$<br>$A=\{2,4,6\}$<br>$B=\{3,6\}$<br>$C=\{1,2\}$<br>ខ.ព្រឹត្តិការណ៍ផលគុណ<br>$A\cap B=\{6\}$<br>$A\cap C=\{2\}$<br>$B\cap C=\varnothing$<br>គ.ព្រឹត្តិការណ៍ផលបូក<br>$A\cup B=\{2,3,4,6\}$<br>$B\cup C=\{1,2,3,6\}$<br>ឃ.ព្រឹត្តិការណ៍ផ្ទុយនឹងព្រឹត្តិការណ៍ $A,B,C$ គឺ |

| | | |
|---|---|---|
| ការណ៍ $A,B,C$<br>ង.តើព្រឹត្តិការណ៍ណាជាព្រឹត្តិការណ៍មិនចុះសម្រុង? | | $\overline{A}=\{1,3,5\}$<br>$\overline{B}=\{1,2,4,5\}$<br>$\overline{C}=\{3,4,5,6\}$<br>ង.ដោយ $B\cap C=\varnothing$ នោះ $B$ និង $C$ ជាព្រឹត្តិការណ៍មិនចុះសម្រុង។ |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -ដូចម្តេចដែលហៅថាព្រឹត្តិការណ៍?<br>-ដូចម្តេចដែលហៅថាព្រឹត្តិការណ៍ឯកធាតុមិនចុះសម្រុងប្រាកដ? | -ជាសំណុំរងនៃលំហសំណាក<br>+ព្រឹត្តិការណ៍ឯកធាតុជាព្រឹត្តិការណ៍ដែលមានលទ្ធផលកើតឡើងតែមួយគត់។<br>+ព្រឹត្តិការណ៍មិនចុះសម្រុងជាពីរព្រឹត្តិការណ៍ដែលផលគុណនៃព្រឹត្តិការណ៍ទាំងពីរមិនអាចមាន។<br>+ព្រឹត្តិការណ៍ប្រាកដជាព្រឹត្តិការណ៍ដែលមានគ្រប់លទ្ធផលទាំងអស់ដែលកើតឡើងដូចក្នុងលំហសំណាក់។ | -ជាសំណុំរងនៃលំហសំណាក<br>+ព្រឹត្តិការណ៍ឯកធាតុជាព្រឹត្តិការណ៍ដែលមានលទ្ធផលកើតឡើងតែមួយគត់។<br>+ព្រឹត្តិការណ៍មិនចុះសម្រុងជាពីរព្រឹត្តិការណ៍ដែលផលគុណនៃព្រឹត្តិការណ៍ទាំងពីរមិនអាចមាន។<br>+ព្រឹត្តិការណ៍ប្រាកដជាព្រឹត្តិការណ៍ដែលមានគ្រប់លទ្ធផលទាំងអស់ដែលកើតឡើងដូចក្នុងលំហសំណាក់ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -អោយសិស្សធ្វើលំហាត់លេខ ១ទំព័រ២១៨ | កិច្ចការផ្ទះ | -សិស្សកត់ត្រាលេខរៀង និងលេខទំព័រនៃលំហាត់ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតមូលដ្ឋាន)

## ជំពូកទី៦ ប្រូបាប

## មេរៀនទី១ ប្រូបាប

2. **ប្រូបាប**

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សកំណត់និយមន័យប្រូបាបនិងលក្ខណៈនៃប្រូបាបតាមរយៈឧទាហរណ៍បានត្រឹមត្រូវ
- បំណិន: សិស្សដោះស្រាយលំហាត់គំរូនិងលំហាត់ប្រតិបត្តិបានត្រឹមត្រូវដោយប្រើនិយមន័យប្រូបាបនិងលក្ខណៈនៃប្រូបាប។
- ឥរិយាបថ: សិស្សសហការដោះស្រាយលំហាត់ដោយយកចិត្តទុកដាក់

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III.សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២០៥-២០៧
- សៀវភៅគ្រូ: ទំព័រ
- គ្រាប់ឡុកឡាក់ សន្លឹកប័ណ្ណដែលមានចុះលេខ

### IV. ដំណើរការនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |

| | | |
|---|---|---|
| -គេអោយសំណុំ:<br>$A=\{0,1,2,3,4,5\}$<br>$B=\{1,3,5\}$<br>$C=\{2,4,6\}$<br>ចូរកំណត់: $A\cap B, A\cap C$<br>$B\cap C, A\cup B, A\cup C, B\cup C$ | $A\cap B=\{1,3,5\}$<br>$A\cap C=\{2,4\}$<br>$B\cap C=\varnothing$<br>$A\cup B=\{0,1,2,3,4,5\}$<br>$A\cup C=\{0,1,2,3,4,5,6\}$<br>$B\cup C=\{1,2,3,4,5,6\}$ | $A\cap B=\{1,3,5\}$<br>$A\cap C=\{2,4\}$<br>$B\cap C=\varnothing$<br>$A\cup B=\{0,1,2,3,4,5\}$<br>$A\cup C=\{0,1,2,3,4,5,6\}$<br>$B\cup C=\{1,2,3,4,5,6\}$ |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| -គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន<br><br>-គ្រូអោយឧទាហរណ៍១និងឧទាហរណ៍២ដូចមានក្នុងសៀវភៅសិស្សរួចអោយសិស្សកំណត់និយមន័យប្រូបាប។<br><br>-គ្រូដាក់លំហាត់គម្រូអោយសិស្សពិភាក្សារកចម្លើយ | មេរៀនទី១ **ប្រូបាប** (ត)<br>**2. ប្រូបាប**<br>**2.1. និយមន័យ**<br>-ប្រូបាបនៃព្រឹត្តិការណ៍មួយជាផលធៀបនៃចំនួនករណីស្របនឹងចំនួនករណីអាច<br>$P(A)=\frac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}}=\frac{n(A)}{n(S)}$<br>-លំហាត់គំរូ: គេរើសសិស្សម្នាក់អោយធ្វើជាប្រធានក្រុមក្នុងចំណោមសិស្សស្រី៥នាក់និងសិស្សប្រុស៣នាក់។រកប្រូបាបដែលប្រធានក្រុមជាសិស្សស្រីនិងរកប្រូបាបសិស្សប្រុសជាប្រធានក្រុម។<br>$A$ ជាសិស្សប្រុសជាប្រធាន<br>$B$ ជាសិស្សស្រីជាប្រធាន<br>សិស្សសរុប $5+3=8$ នាក់<br>នោះ $n(S)=8$ , $n(A)=3,$<br>$n(B)=5$ ។<br>ដូច្នេះ $P(A)=\frac{3}{8}$ , $P(B)=\frac{5}{8}$ ។ | -សិស្សកត់ត្រាចំណងជើងមេរៀនថ្មី<br><br>-ប្រូបាបនៃព្រឹត្តិការណ៍មួយជាផលធៀបនៃចំនួនករណីស្របនឹងចំនួនករណីអាច<br>$P(A)=\frac{\text{ចំនួនករណីស្រប}}{\text{ចំនួនករណីអាច}}$<br>$=\frac{n(A)}{n(S)}$<br>-ចម្លើយ<br>តាង $A$ ជាព្រឹត្តិការណ៍ដែលសិស្សប្រុសធ្វើជាប្រធានក្រុមហើយ $B$ ជាព្រឹត្តិការណ៍ដែលសិស្សស្រីធ្វើជាប្រធានក្រុម។<br>សិស្សសរុប $5+3=8$ នាក់<br>$n(S)=8$ , $n(A)=3,$<br>$n(B)=5$ ។គេបាន<br>ប្រូបាបដែលសិស្សប្រុសជាប្រធាន $P(A)=\frac{3}{8}$<br>ប្រូបាបដែលសិស្សស្រីជា |

| | | |
|---|---|---|
| -អោយសិស្សគណនាប្រតិបត្តិនៅលើក្តារខៀន | **ប្រតិបត្តិ:** គេធ្វើវិញ្ញាសាហូតប័ណ្ណម្តងមួយសន្លឹកចំនួន២ដងចេញពីថង់មួយដែលមានប័ណ្ណលេខ១ លេខ២ លេខ៣ ដោយហូតហើយដាក់វិញ។<br>ក.ចូរសរសេរលំហសំណាក់ $S$ ព្រឹត្តិការណ៍ $A$ ដែលហូតលើកទី១បានលេខគូនិងព្រឹត្តិការណ៍ $B$ ដែលហូតទាំងពីរលើកបានប័ណ្ណមានផលបូកលេខស្មើនឹង៥។<br>ខ.រកប្រូបាបនៃព្រឹត្តិការណ៍ $A$ និងប្រូបាបនៃព្រឹត្តិការណ៍ $B$<br><u>ចម្លើយ</u><br>ក.<br>$S=\{(1,1),(1,2),(1,3),(2,1),(2,2),(2,3),(3,1),(3,2),(3,4)\}$<br>$A=\{(2,2),(2,1),(2,3)\}$<br>$B=\{(2,3),(3,2)\}$<br>ខ. $n(S)=9$<br>$n(A)=3$<br>$n(B)=2$<br>គេបាន $P(A)=\frac{3}{9}=\frac{1}{3}$<br>$P(B)=\frac{2}{9}$ | ប្រធាន $P(B)=\frac{5}{8}$<br>-ចម្លើយ:<br>ក.<br>$S=\{(1,1),(1,2),(1,3),(2,1),(2,2),(2,3),(3,1),(3,2),(3,3)\}$<br>$A=\{(2,1),(2,2),(2,3)\}$<br>$B=\{(2,3),(3,2)\}$<br>ខ. $n(S)=9$<br>$n(A)=3$<br>$n(B)=2$<br>គេបាន:<br>$P(A)=\frac{3}{9}=\frac{1}{3}$<br>$P(B)=\frac{2}{9}$ |
| -គ្រូបញ្ជាក់ថាក្នុងវិញ្ញាសាបោះគ្រាប់ឡុកឡាក់មួយគ្រាប់លទ្ធផលទាំងអស់កើតឡើងក្នុងលំហសំណាកគឺ | **2.2.លក្ខណៈនៃប្រូបាប**<br>មានន័យថា<br>$P(\{1\})=P(\{2\})=P(\{3\})=P(\{4\})=P(\{5\})=P(\{6\})=\frac{1}{6}$<br>ផលបូកប្រូបាបនៃព្រឹត្តិការណ៍ឯក | -សិស្សស្តាប់ដោយយកចិត្តទុកដាក់រួចកត់ត្រា។ |

| | | |
|---|---|---|
| លទ្ធផលបោះបានលេខ១ លេខ២ លេខ៣ លេខ៤ លេខ ៥ និងលេខ៦ មានប្រូបាបស្មើនឹង $\frac{1}{6}$ ដូចគ្នា។ | ធាតុទាំងអស់ដែលអាចកើតឡើងក្នុងលំហសំណាក $S$ ស្មើនឹង1គឺ $\frac{1}{6}+\frac{1}{6}+\frac{1}{6}+\frac{1}{6}+\frac{1}{6}+\frac{1}{6}=1$។<br>គេបាន: $P(S)=1$។<br>**ជាទូទៅ:**<br>+បើគេតាង $e_i$ ជាព្រឹត្តិការណ៍ឯកធាតុនៃលំហសំណាក $S$ នោះ<br>គេបាន:<br>$P(e_1)+P(e_2)+\ldots+P(e_n)$<br>$=\sum_{i=1}^{n}P(e_i)=P(S)=1$<br>+បើ $A$ ជាព្រឹត្តិការណ៍មិនអាចកើតឡើងគឺ $A=\varnothing$ នោះ $n(A)=0$ ហើយ $P(A)=0$<br>+បើ $A$ ជាព្រឹត្តិការណ៍មួយនៃលំហសំណាក $S$ នោះ $n(A)\le n(S)$ ហើយ $P(A)\le P(S)$ | |
| -គ្រូអោយសិស្សទាញជាសន្និដ្ឋានរួម | **សន្និដ្ឋាន:**<br>-ប្រូបាបនៃលំហសំណាក $S$ ស្មើនឹង1 : $P(S)=1$<br>-ប្រូបាបនៃព្រឹត្តិការណ៍មិនអាចមានស្មើនឹង $0$: $P(\varnothing)=0$<br>-ប្រូបាបនៃព្រឹត្តិការណ៍មួយក្នុងលំហសំណាកជាចំនួនដែលនៅចន្លោះ $[0,1], 0\le P(A)\le P(S)$<br>-ប្រូបាបជាអនុគមន៍ដែលកំណត់ពីលំហសំណាក $S$ ទៅចន្លោះ $[0,1], P:S\to[0,1]$ ។ | **សន្និដ្ឋាន:**<br>-ប្រូបាបនៃលំហសំណាក $S$ ស្មើនឹង1 : $P(S)=1$<br>-ប្រូបាបនៃព្រឹត្តិការណ៍មិនអាចមានស្មើនឹង $0$:<br>$P(\varnothing)=0$<br>-ប្រូបាបនៃព្រឹត្តិការណ៍មួយក្នុងលំហសំណាកជាចំនួនដែលនៅចន្លោះ:<br>$[0,1], 0\le P(A)\le P(S)$<br>-ប្រូបាបជាអនុគមន៍ដែលកំណត់ពីលំហសំណាក $S$ ទៅចន្លោះ $[0,1], P:S\to[0,1]$ ។ |

| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
|---|---|---|
| -ចូរអោយនិយមន័យប្រូបាបនៃព្រឹត្តិការណ៍ $A$ មួយ<br>-$B$ ជាព្រឹត្តិការណ៍នៃការបោះគ្រាប់ឡុកឡាក់មួយគ្រាប់ចេញលេខ។ចូររក $P(B)$ ។ | -$P(A)=\dfrac{n(A)}{n(S)}$<br>-$n(B)=\varnothing$ នោះ $P(B)=0$ | -សិស្សឆ្លើយ $P(A)=\dfrac{n(A)}{n(S)}$<br>-$n(B)=\varnothing$ នោះ $P(B)=0$ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -អោយសិស្សធ្វើលំហាត់លេខ ២និងលេខទំព័រ២១៨ | កិច្ចការផ្ទះ | -សិស្សស្តាប់ការណែនាំនិងកត់ត្រាលេខលំហាត់និងលេខទំព័រ |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតមូលដ្ឋាន)

## ជំពូកទី៦ ប្រូបាប

## មេរៀនទី១ ប្រូបាប

(ប្រូបាបនៃព្រឹត្តិការណ៍សមាស)

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សស្គាល់ច្បាស់អំពីលក្ខណៈនៃព្រឹត្តិការណ៍សមាស
- បំណិន: សិស្សប្រើលក្ខណៈព្រឹត្តិការណ៍សមាសក្នុងការដោះស្រាយលំហាត់បាន ត្រឹមត្រូវតាមរយៈឧទាហរណ៍
- ឥរិយាបថ: សិស្សសហការដោះស្រាយដោយស្មារតីយោគយល់

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២០៨-២១២
- សៀវភៅគ្រូ: ទំព័រ
- គ្រាប់ឡុកឡាក់ ឃ្លី ក្រដាស(សន្លឹកកាត)ដែលមានតួអក្សរ ALGEBRA

### IV. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | **ជំហានទី១** (រដ្ឋបាលថ្នាក់) | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| | **ជំហានទី២** (រំលឹកមេរៀនចាស់) | |
| -គេបោះគ្រាប់ឡុកឡាក់មួយគ្រាប់។តាង $A$ ជាព្រឹត្តិការណ៍ដែលគ្រាប់ឡុកឡាក់ចេញលេខសេស។ $B$ ជាព្រឹត្តិការណ៍ដែលគ្រាប់ឡុកឡាក់ចេញ | ក. $A=\{1,3,5\}$<br>$B=\{3,6\}$<br>$C=\{1,2,3\}$<br>ខ. $A\cup B=\{1,3,5,6\}$<br>$B\cap C=\{3\}$ | ក. $A=\{1,3,5\}$<br>$B=\{3,6\}$<br>$C=\{1,2,3\}$<br>ខ. $A\cup B=\{1,3,5,6\}$<br>$B\cap C=\{3\}$ |

| | | |
|---|---|---|
| លេខជាពហុគុណនៃ $3$ និង $C$ ជាព្រឹត្តិការណ៍ដែលគ្រាប់ឡុកឡាក់ចេញលេខតូចជាងឬស្មើ $3$ ។ចូរកំណត់<br>ក.ព្រឹត្តិការណ៍ $A,B,C$<br>ខ.ព្រឹត្តិការណ៍ $A\cup B, B\cap C$ | | |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| ឧ១. គេធ្វើវិញ្ញាសាបោះគ្រាប់ឡុកឡាក់មួយគ្រាប់។តាង $A$ ជាព្រឹត្តិការណ៍បោះបានលេខគូនិង $B$ ជាព្រឹត្តិការណ៍បោះបានលេខជាពហុគុណនៃ $3$<br>គ្រូណែនាំអោយសិស្សកំណត់លំហសំណាក ប្រូបាបនៃផលបូកប្រូបាបនៃព្រឹត្តិការណ៍ផលគុណនិងប្រូបាបនៃព្រឹត្តិការណ៍ផ្ទុយ។ | មេរៀនទី១ **ប្រូបាប** (**ត**)<br>**ប្រូបាបនៃព្រឹត្តិការណ៍សមាស**<br>គេបាន: លំហសំណាក<br>$S\{1,2,3,4,5,6\}$<br>$A=\{2,4,6\}$<br>$B=\{3,6\}$<br>ក. $A\cap B=\{6\}$ នោះ<br>$n(A\cap B)=1\Rightarrow P(A\cap B)=\frac{1}{6}$<br>តែ $P(A)=\frac{3}{6}$ , $P(B)=\frac{2}{6}$<br>ដូចនេះ<br>$P(A\cap B)=P(A)\times P(B)$<br>ខ. $A\cup B=\{2,3,4,6\}$<br>នោះ $P(A\cup B)=\frac{4}{6}$<br>គេដឹងថាបើ $A\cap B\neq\emptyset$ នោះ<br>$n(A\cup B)=n(A)+n(B)$<br>$-n(A\cap B)$ | -សិស្សកត់ចំណងជើងមេរៀនរួចឡើងដោះស្រាយ<br>គេបាន: លំហសំណាក<br>$S\{1,2,3,4,5,6\}$<br>$A=\{2,4,6\}$<br>$B=\{3,6\}$<br>ក. $A\cap B=\{6\}$ នោះ<br>$n(A\cap B)=1$<br>$\Rightarrow P(A\cap B)=\frac{1}{6}$<br>តែ $P(A)=\frac{3}{6}$ , $P(B)=\frac{2}{6}$<br>ដូចនេះ<br>$P(A\cap B)=P(A)\times P(B)$<br>ខ. $A\cup B=\{2,3,4,6\}$<br>នោះ $P(A\cup B)=\frac{4}{6}$<br>គេដឹងថាបើ $A\cap B\neq\emptyset$<br>នោះ<br>$n(A\cup B)=n(A)+n(B)$<br>$-n(A\cap B)$<br>$P(A\cup B)=\frac{n(A)+n(B)}{n(S)}$<br>$-\frac{-n(A\cap B)}{n(S)}$ |

| | | |
|---|---|---|
| ឧទាហរណ៍២: ក្នុងថង់មួយមានឃ្លីក្រហម២និងឃ្លីខៀវ៣ គេចាប់យកឃ្លី២ចេញពីថង់ម្តងមួយៗដោយចៃដន្យ។<br>ក. ក្នុងករណីយកហើយដាក់វិញ ចូររកប្រូបាបដែលចាប់បាន<br>-ឃ្លីក្រហមមុននិងខៀវក្រោយ<br>-ឃ្លីក្រហមមុនឬខៀវក្រោយ | $P(A\cup B)=\frac{n(A)+n(B)}{n(S)}$<br>$-\frac{-n(A\cap B)}{n(S)}$<br>$=\frac{n(A)}{n(S)}+\frac{n(B)}{n(S)}-\frac{n(A\cap B)}{n(S)}$<br>$=\frac{3}{6}+\frac{2}{6}-\frac{1}{6}=\frac{4}{6}$<br>ដូចនេះ<br>$P(A\cup B)=P(A)+P(B)$<br>$-P(A\cap B)$<br>បើ $A\cap B=\varnothing$ នោះ<br>$P(A\cup B)=P(A)+P(B)$<br>គ.ព្រឹត្តិការណ៍ផ្ទុយនឹងព្រឹត្តិការណ៍ $A$ គឺ $\overline{A}$<br>គេបាន $\overline{A}=\{1,3,5\}$, $P(\overline{A})=\frac{3}{6}$,<br>$A\cap\overline{A}=\varnothing$, $A\cup\overline{A}=S$ នោះ<br>$P(A\cup\overline{A})=P(A)+P(\overline{A})=1$<br>ដូចនេះ $P(\overline{A})=1-P(A)$<br>**<u>ចម្លើយ</u>**<br>តាងព្រឹត្តិការណ៍<br>$A$: "ចាប់បានឃ្លីក្រហមមុន"<br>$B$: "ចាប់បានឃ្លីខៀវក្រោយ"<br>ក.ករណីចាប់ហើយដាក់វិញ<br>ការចាប់ឃ្លីលើកទី១និងទី២ជាព្រឹត្តិការណ៍២មិនទាក់ទងគ្នាទេ | $=\frac{n(A)}{n(S)}+\frac{n(B)}{n(S)}$<br>$-\frac{n(A\cap B)}{n(S)}$<br>$=\frac{3}{6}+\frac{2}{6}-\frac{1}{6}=\frac{4}{6}$<br>ដូចនេះ<br>$P(A\cup B)=P(A)+P(B)$<br>$-P(A\cap B)$<br>បើ $A\cap B=\varnothing$ នោះ<br>$P(A\cup B)=P(A)+P(B)$<br>គ.ព្រឹត្តិការណ៍ផ្ទុយនឹងព្រឹត្តិការណ៍ $A$ គឺ $\overline{A}$<br>គេបាន $\overline{A}=\{1,3,5\}$,<br>$P(\overline{A})=\frac{3}{6}$,<br>$A\cap\overline{A}=\varnothing$, $A\cup\overline{A}=S$<br>នោះ<br>$P(A\cup\overline{A})=P(A)+P(\overline{A})$<br>$=1$<br>ដូចនេះ $P(\overline{A})=1-P(A)$<br>សិស្សឡើងគណនា<br>តាងព្រឹត្តិការណ៍<br>$A$:"ចាប់បានឃ្លីក្រហមមុន"<br>$B$:"ចាប់បានឃ្លីខៀវក្រោយ"<br>ក.ករណីចាប់ហើយដាក់វិញ<br>ការចាប់ឃ្លីលើកទី១និងទី២ជាព្រឹត្តិការណ៍២មិនទាក់ទងគ្នាទេ<br>គេបាន |

| | | |
|---|---|---|
| ខ. ក្នុងករណីយកហើយមិនដាក់វិញ ចូររកប្រូបាបដែលចាប់បាន<br>-ឃ្លីក្រហមមុននិងខៀវក្រោយ<br>-ឃ្លីក្រហមមុនឬខៀវក្រោយ | គេបាន $P(A)=\frac{2}{5},P(B)=\frac{3}{5}$<br>-នោះប្រូបាបនៃព្រឹត្តិការណ៍ចាប់បានឃ្លីក្រហមមុននិងខៀវក្រោយ<br>$P(A\cap B)=P(A)\times P(B)$<br>$=\frac{2}{5}\times\frac{3}{5}=\frac{6}{25}$<br>-ព្រឹត្តិការណ៍ចាប់បានឃ្លីក្រហមមុនឬខៀវក្រោយជាព្រឹត្តិការណ៍ផលបូក $A$ និង $B:A\cup B$<br>$A=\{(កក),(កខ)\}$<br>$B=\{(ខខ),(កខ)\}$<br>ដោយ $A\cap B=\{(កខ)\}$<br>គេបាន:<br>$P(A\cup B)=P(A)+P(B)$<br>$-P(A\cap B)$<br>$=\frac{2}{5}+\frac{3}{5}-\frac{6}{25}$<br>$=\frac{19}{25}$<br>ខ. ក្នុងវិញ្ញាសាយកហើយមិនដាក់វិញ:<br>ចំនួនឃ្លីដែលត្រូវចាប់លើកទី១ វាប៉ះពាល់ដល់ការចាប់ឃ្លីលើកទី២ ។គេថាព្រឹត្តិការណ៍ដែលកើតលើកទី២ទាក់ទងនឹងព្រឹត្តិការណ៍លើកទី១។<br>-បើលើកទី១ចាប់បានឃ្លីក្រហម | $P(A)=\frac{2}{5},P(B)=\frac{3}{5}$<br>-នោះប្រូបាបនៃព្រឹត្តិការណ៍ចាប់បានឃ្លីក្រហមមុននិងខៀវក្រោយ<br>$P(A\cap B)=P(A)\times P(B)$<br>$=\frac{2}{5}\times\frac{3}{5}=\frac{6}{25}$<br>-ព្រឹត្តិការណ៍ចាប់បានឃ្លីក្រហមមុនឬខៀវក្រោយជាព្រឹត្តិការណ៍ផលបូក $A$ និង $B:A\cup B$<br>$A=\{(កក),(កខ)\}$<br>$B=\{(ខខ),(កខ)\}$<br>ដោយ $A\cap B=\{(កខ)\}$<br>គេបាន:<br>$P(A\cup B)=P(A)+P(B)$<br>$-P(A\cap B)$<br>$=\frac{2}{5}+\frac{3}{5}-\frac{6}{25}$<br>$=\frac{19}{25}$<br>ខ. ក្នុងវិញ្ញាសាយកហើយមិនដាក់វិញ:<br>ចំនួនឃ្លីដែលត្រូវចាប់លើកទី១ វាប៉ះពាល់ដល់ការចាប់ឃ្លីលើកទី២។ គេថាព្រឹត្តិការណ៍ដែលកើតលើកទី២ទាក់ទងនឹងព្រឹត្តិការណ៍លើកទី១។<br>-បើលើកទី១ចាប់បានឃ្លីក្រហមនិងលើកទី២ចាប់បានឃ្លីខៀវ នោះប្រូបាប |

| | | |
|---|---|---|
| | និងលើកទី២ចាប់បានឃ្លីខៀវ នោះប្រូបាបដែលចាប់បានឃ្លីក្រហមមុនគឺ $\frac{2}{5}$ និងប្រូបាបចាប់បានឃ្លីខៀវក្រោយគឺ $\frac{3}{4}$<br>គេកំណត់សរសេរ: $P(A)=\frac{2}{5}$<br>និង $P\left(B\text{ដែល}A\text{កើតមុន}\right)=\frac{3}{4}$<br>ដូចនេះ ប្រូបាបផលគុណនៃព្រឹត្តិការណ៍ $A$ និង $B$:<br>$P(A\cap B)=P\left(B\text{ដែល}A\text{កើតមុន}\right)+P(A)-P(A\cap B)$<br>$=\frac{2}{5}+\frac{3}{4}-\frac{3}{10}=\frac{17}{20}$ | ដែលចាប់បានឃ្លីក្រហមមុនគឺ $\frac{2}{5}$ និងប្រូបាបចាប់បានឃ្លីខៀវក្រោយគឺ $\frac{3}{4}$<br>គេកំណត់សរសេរ:<br>$P(A)=\frac{2}{5}$ និង<br>$P\left(B\text{ដែល}A\text{កើតមុន}\right)=\frac{3}{4}$<br>ដូចនេះ ប្រូបាបផលគុណនៃព្រឹត្តិការណ៍ $A$ និង $B$:<br>$P(A\cap B)=P(B\text{ដែល}A$ $\text{កើតមុន})+P(A)$ $-P(A\cap B)$<br>$=\frac{2}{5}+\frac{3}{4}-\frac{3}{10}=\frac{17}{20}$ |
| -គ្រូអោយសិស្សទាញសេចក្តីសន្និដ្ឋាន | -សន្និដ្ឋាន:<br>+ប្រូបាបនៃព្រឹត្តិការណ៍ផលគុណ $A$ និង $B$ គឺ<br>$P(A\cap B)=P(A)\times P(B)$ បើ $A$ និង $B$ មិនទាក់ទងគ្នា<br>$P(A\cap)B=P(A)+P\left(B\text{ដែល}A\text{កើតមុន}\right)$<br>+ប្រូបាបនៃព្រឹត្តិការណ៍ផលបូក $A$ និង $B$ គឺ<br>$P(A\cup B)=P(A)+P(B)-P(A\cap B)$<br>$P(A\cup B)=P(A)+P(B)$ បើ $A$ និង $B$ ជាព្រឹត្តិការណ៍មិនចុះសម្រុងគ្នា | -សន្និដ្ឋាន:<br>+ប្រូបាបនៃព្រឹត្តិការណ៍ផលគុណ $A$ និង $B$ គឺ<br>$P(A\cap B)=P(A)\times P(B)$<br>បើ $A$ និង $B$ មិនទាក់ទងគ្នា<br>$P(A\cap)B=P(A)+P\left(B\text{ដែល}A\text{កើតមុន}\right)$<br>+ប្រូបាបនៃព្រឹត្តិការណ៍ផលបូក $A$ និង $B$ គឺ<br>$P(A\cup B)=P(A)+P(B)-P(A\cap B)$<br>$P(A\cup B)=P(A)+P(B)$<br>បើ $A$ និង $B$ ជាព្រឹត្តិការណ៍មិនចុះសម្រុងគ្នា<br>+ប្រូបាបនៃព្រឹត្តិការណ៍ផ្ទុយនឹង $A$ គឺ<br>$P(\overline{A})=1-P(A)$ |

| | | |
|---|---|---|
| | +ប្រូបាបនៃព្រឹត្តិការណ៍ផ្ទុយនឹង $A$ គឺ $P\left(\overline{A}\right)=1-P(A)$ | |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -គេសរសេរតួអក្សរមួយដាក់លើសន្លឹកកាតមួយក្នុងចំនោមតួអក្សរនៃពាក្យ ALGEBRA រួចដាក់ចូលក្នុងថង់។គេចាប់យកសន្លឹកកាតម្ដងមួយចេញពីថង់២ដងដោយចៃដន្យដោយយកហើយដាក់វិញ។ $A$ ជាព្រឹត្តិការណ៍ចាប់បានស្រៈលើកទី១ $B$ ចាប់បានព្យញ្ជនៈលើកទី១និង $C$ ចាប់បានព្យញ្ជនៈលើកទី២។តើព្រឹត្តិការណ៍ណាជាព្រឹត្តិការណ៍ផ្ទុយគ្នា។ | -ចម្លើយៈ<br>ព្រឹត្តិការណ៍ $A=\{(សព),(សស)\}$<br>ដែល(ស=ស្រៈ និង ព=ព្យញ្ជនៈ)<br>$B=\{(ពព),(ពស)\}$<br>$C=\{(ពព),(សព)\}$<br>-ព្រឹត្តិការណ៍ $A$ និង $B$ ជាព្រឹត្តិការណ៍ផ្ទុយគ្នា ព្រោះ<br>$A\cap B=\varnothing$ និង $A\cup B=S$ | -ចម្លើយៈ<br>ព្រឹត្តិការណ៍<br>$A=\{(សព),(សស)\}$<br>ដែល(ស=ស្រៈ និង ព=ព្យញ្ជនៈ)<br>$B=\{(ពព),(ពស)\}$<br>$C=\{(ពព),(សព)\}$<br>-ព្រឹត្តិការណ៍ $A$ និង $B$ ជាព្រឹត្តិការណ៍ផ្ទុយគ្នា ព្រោះ<br>$A\cap B=\varnothing$ និង $A\cup B=S$ |
| **ជំហានទី៥** (បណ្ដាំផ្ញើ) | | |
| -អោយសិស្សធ្វើលំហាត់លេខ៣ទំព័រ២១៨ | កិច្ចការផ្ទះ | -សិស្សស្ដាប់និងកត់ត្រា |

# កិច្ចតែងការបង្រៀន

## មុខវិជ្ជា គណិតវិទ្យា ថ្នាក់ទី១២ (កំរិតមូលដ្ឋាន)

## ជំពូកទី៦ ប្រូបាប

## មេរៀនទី១ ប្រូបាប

### 3. គណនាប្រូបាបដោយប្រើចម្លាស់និងបន្សំ

### I. វត្ថុបំណងនៃមេរៀន

- ចំណេះដឹង: សិស្សគណនាចំនួនករណីអាចក៏ដូចជាចំនួនករណីស្របក្នុងលំហាសំណាក ដោយប្រើចម្លាស់និងបន្សំបានត្រឹមត្រូវ។
- បំណិន: សិស្សដោះស្រាយលំហាត់ក្នុងឧទាហរណ៍ដោយប្រើចម្លាស់បិងបន្សំបាន ត្រឹមត្រូវ។
- ឥរិយាបថ: សិស្សសហការដោះស្រាយលំហាត់ដោយស្មារតីយោគយល់

### II. ពេលវេលា

២ម៉ោង ថ្ងៃ..........ទី.......ខែ...........ឆ្នាំ..........

### III. សម្ភារៈឧបទ្ទេស

- សៀវភៅសិស្ស: ទំព័រ ២១៣-២១៦
- សៀវភៅគ្រូ: ទំព័រ
- គ្រាប់ឡុកឡាក់១គ្រាប់ កាស៩

### IV. ដំណើកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១** (រដ្ឋបាលថ្នាក់) | | |
| - គ្រូពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ និងវិន័យ | - លំនឹងថ្នាក់ | - តំណាងសិស្សឡើងរាយការណ៍ |
| **ជំហានទី២** (រំលឹកមេរៀនចាស់) | | |
| -ចូរកំណត់<br>១.ប្រូបាបនៃព្រឹត្តិការណ៍ផលគុណ $A$ និង $B$ បើ | | -សិស្សឆ្លើយ<br>១. ក.<br>$P(A\cap B)=P(A)\times P(B)$ |

| | | |
|---|---|---|
| ក. $A$ និង $B$ មិនទាក់ទងគ្នា<br>ខ. $A$ និង $B$ ទាក់ទងគ្នា<br>២.ប្រូបាបនៃព្រឹត្តិការណ៍ផលបូក $A$ និង $B$ បើ<br>គ. $A$ និង $B$ ជាព្រឹត្តិការណ៍ចុះសម្រុង<br>ឃ. $A$ និង $B$ ជាព្រឹត្តិការណ៍មិនចុះសម្រុង | | ខ.<br>$P(A\cap B)=P(A)\times P(B/A)$<br>២. ក.<br>$P(A\cup B)=P(A)+P(B)-P(A\cap B)$<br>ខ.<br>$P(A\cup B)=P(A)+P(B)$ |
| **ជំហានទី៣** (មេរៀនថ្មី) | | |
| -គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន<br><br>-គ្រូណែនាំអោយសិស្សនោះស្រាយលំហាត់ក្នុងឧទាហរណ៍<br><br>-គ្រូសួរ: តើគេធ្វើដូចម្តេចដើម្បីកំណត់ចំនួនករណីអាច ?<br>-គ្រូបំផុសគំនិតអោយសិស្សរកប្រូបាបចំណុច ក ខ និងគ ដោយខ្លួនឯង។ | មេរៀនទី១ **ប្រូបាប** (**តចប់**)<br>**3. គណនាប្រូបាបដោយប្រើចម្លាស់និងបន្សំ**<br>**3.1.គណនាប្រូបាបដោយប្រើចម្លាស់**<br>-ឧទាហរណ៍១. គេបោះគ្រាប់ឡុកឡាក់មួយគ្រាប់២ដង។<br>ក.រកប្រូបាបដែលបោះបានលេខទាំងពីរលើកខុសគ្នា។<br>ខ.រកប្រូបាបដែលបោះបានលេខទាំងពីរលើកជាលេខគូ។<br>គ.រកប្រូបាបដែលបោះបានលេខទាំងពីរលើកខុសគ្នានិងជាលេខគូ<br>ចម្លើយ<br>ចម្លាស់ច្រំដែលនៃ២ធាតុយកពី៦ធាតុ។នោះចំនួនករណីអាចគឺ $6^2=36$ ករណី<br>ក.តាង $A$ ជាព្រឹត្តិការណ៍ដែលបោះបានលេខខុសគ្នាទាំង២លើក។ $A$ ជាចម្លាស់នៃ២ធាតុយកពី៦ធាតុ។ គេបាន: | -សិស្សកត់ចំណងជើងមេរៀនថ្មី<br><br>ចម្លាស់ច្រំដែលនៃ២ធាតុយកពី៦ធាតុ។នោះចំនួនករណីអាចគឺ $6^2=36$ ករណី<br>ក.តាង $A$ ជាព្រឹត្តិការណ៍ដែលបោះបានលេខខុសគ្នាទាំង២លើក។ $A$ ជាចម្លាស់នៃ២ធាតុយកពី៦ធាតុ។ |

| | | |
|---|---|---|
| | $A = P(6,2) = 30$<br>ដូចនេះ $P(A) = \frac{30}{36} = \frac{5}{6}$<br>ខ.តាង $B$ ជាព្រឹត្តិការណ៍បោះបានលេខទាំង២ជាលេខគូ។ $B$ ជាចម្លាស់ច្រំដែលជាលេខ $2, 4, 6$<br>នោះ $n(B) = 3^2 = 9$ ។<br>គេបាន: $P(B) = \frac{9}{36} = 0.25$<br>គ.ព្រឹត្តិការណ៍ដែលបោះបានលេខទាំង២ខុសគ្នានិងជាលេខគូជាព្រឹត្តិការណ៍ $A \cap B$<br>$A \cap B = \{(2,4),(2,6),(4,2),(4,6),(6,2),(6,4)\}$<br>$n(A \cap B) = 6$ ជាចំនួនករណីស្រប<br>ដូចនេះ $P(A \cap B) = \frac{6}{36} = 0.166$ | គេបាន:<br>$A = P(6,2) = 30$<br>ដូចនេះ $P(A) = \frac{30}{36} = \frac{5}{6}$<br>ខ.តាង $B$ ជាព្រឹត្តិការណ៍បោះបានលេខទាំង២ជាលេខគូ។ $B$ ជាចម្លាស់ច្រំដែលជាលេខ $2, 4, 6$<br>នោះ $n(B) = 3^2 = 9$ ។<br>គេបាន: $P(B) = \frac{9}{36} = 0.25$<br>គ.ព្រឹត្តិការណ៍ដែលបោះបានលេខទាំង២ខុសគ្នានិងជាលេខគូជាព្រឹត្តិការណ៍ $A \cap B$<br>$A \cap B = \{(2,4),(2,6),(4,2),(4,6),(6,2),(6,4)\}$<br>$n(A \cap B) = 6$ ជាចំនួនករណីស្រប<br>ដូចនេះ<br>$P(A \cap B) = \frac{6}{36} = 0.166$ |
| -គ្រូដាក់ឧទាហរណ៍១អោយសិស្សពិភាក្សារកដំណោះស្រាយ។ | **3.2. គណនាប្រូបាបដោយប្រើបន្សំ**<br>-ឧទាហរណ៍១. គេរើសសិស្ស៨នាក់ដោយចៃដន្យក្នុងចំណោមសិស្សប្រុស៩នាក់និងសិស្សស្រី១១នាក់ទៅសម្ភាសន៍។<br>ក.តើគេអាចរៀបសិស្សបានប៉ុន្មានរបៀបខុសៗគ្នា?<br>ខ.រកប្រូបាបនៃព្រឹត្តិការណ៍ $A$:"តើគេអាចរៀបសិស្សបាន | -សិស្សរកត់ឧទាហរណ៍១និងពិភាក្សាគ្នារកចម្លើយ។ |

| | | |
|---|---|---|
| | ប៉ុន្មានរបៀបខុសៗគ្នា?″<br>$B$:"ក្នុងក្រុមមានសិស្សស្រី៥នាក់និងសិស្សប្រុស៣នាក់″<br>ចម្លើយ<br>ក.ចំនួនករណីអាចជាបន្សំ៨ធាតុយកពី២០ធាតុគឺ<br>$C(20,8)=\frac{20!}{12!\cdot 8!}=125970$<br>ខ.គេរើសសិស្សដោយចៃដន្យដូចនេះធាតុនីមួយៗមានសមប្រូបាប<br>+សិស្ស៨នាក់ដែលត្រូវជ្រើសរើសមានសុទ្ធតែស្រីគឺគេរើស៨នាក់ក្នុងចំណោម១១នាក់។ចំនួនករណីស្របជាបន្សំ $C(11,8)=165$<br>ប្រូបាបនៃព្រឹត្តិការណ៍ $A$ គឺ<br>$P(A)=\frac{165}{125970}=0.0013$<br>+គេរើសសិស្សស្រី៥នាក់និងសិស្សប្រុស៣នាក់ចេញពីសិស្សស្រី១១នាក់និងសិស្សប្រុស៩នាក់ ចំនួនរបៀបដែលរើសសិស្សស្រី៥នាក់គឺ $C(11,5)$ និងចំនួនរបៀបដែលរើសសិស្សប្រុស៣នាក់គឺ $C(9,3)$ ។<br>ដូចនេះចំនួនករណីស្របនៃព្រឹត្តិការណ៍ $B$ គឺ<br>$C(11,5)\times C(9,3)$ ។គេបាន<br>$P(B)=\frac{C(11,5)\times C(9,3)}{C(20,8)}$<br>$=0.308$ | -សិស្សឡើងគណនាលើក្តារខៀន<br>ក.ចំនួនករណីអាចជាបន្សំ៨ធាតុយកពី២០ធាតុគឺ<br>$C(20,8)=\frac{20!}{12!\cdot 8!}=125970$<br>ខ.គេរើសសិស្សដោយចៃដន្យដូចនេះធាតុនីមួយៗមានសមប្រូបាប<br>+សិស្ស៨នាក់ដែលត្រូវជ្រើសរើសមានសុទ្ធតែស្រីគឺគេរើស៨នាក់ក្នុងចំណោម១១នាក់។ចំនួនករណីស្របជាបន្សំ<br>$C(11,8)=165$<br>ប្រូបាបនៃព្រឹត្តិការណ៍ $A$ គឺ<br>$P(A)=\frac{165}{125970}=0.0013$<br>+គេរើសសិស្សស្រី៥នាក់និងសិស្សប្រុស៣នាក់ចេញពីសិស្សស្រី១១នាក់និងសិស្សប្រុស៩នាក់<br>ចំនួនរបៀបដែលរើសសិស្សស្រី៥នាក់គឺ $C(11,5)$ និងចំនួនរបៀបដែលរើសសិស្សប្រុស៣នាក់គឺ<br>$C(9,3)$ ។<br>ដូចនេះចំនួនករណីស្របនៃព្រឹត្តិការណ៍ $B$ គឺ<br>$C(11,5)\times C(9,3)$ ។គេបាន |

| | | |
|---|---|---|
| | | $P(B)=\frac{C(11,5)\times C(9,3)}{C(20,8)}$ $=0.308$ |
| **ជំហានទី៤** (ពង្រឹងចំណេះដឹង) | | |
| -គេបង្កើតលេខសម្ងាត់របស់សោដោយចំនួនដែលមានលេខ៤ខ្ទង់ខុសពីលេខសូន្យ ក.តើគេប្រើចម្លាស់ឬបន្សំដើម្បីកំណត់លេខសម្ងាត់ទាំងនេះ? ខ.គណនាចំនួនលេខសម្ងាត់ដែលអាចបង្កើតបានទាំងអស់ | | -ក. គេប្រើចម្លាស់ច្រាំដែលនៃ៤ធាតុយកពី៩ធាតុ។ ខ. ចំនួនលេខសម្ងាត់ទាំងអស់គឺ $9^4=6561$ |
| **ជំហានទី៥** (បណ្តាំផ្ញើ) | | |
| -អោយសិស្សមើលមេរៀនឡើងវិញនិងធ្វើលំហាត់នៅទំព័រ២១៨ | កិច្ចការផ្ទះ | -សិស្សស្តាប់ការណែនាំរបស់គ្រូ |

# កិច្ចតែងការបង្រៀន
# ជំពូកទី៦
# មេរៀនទី១

I. **វត្ថុបំណង៖**

- ចំណេះដឹង: ចេះនិយមនយ័ប្រូបាបមានលក្ខណ្ឌ័និងរូបមន្តប្រូបាបមានលក្ខខណ្ឌ័
- ចំណេះធ្វើ: ចេះដោះស្រាយលំហាត់ប្រូបាបមានលក្ខណ្ឌ័បានត្រឹមត្រូវ
- ឥរិយាបទ: ចេះយករូបមន្តប្រូបាបមានលក្ខខណ្ឌ័ទៅអនុវត្តបានត្រឹមត្រូវ

II. **ខ្លឹមសារមេរៀន៖**

១.ប្រូបាបមានលក្ខណ្ឌ័

III. **សម្ភារៈឧបទេសៈ** ស.សទំព័១១៨-១២២ និងបន្ទាត់

IV. **វិធីសាស្ត្របង្រៀន៖** សិស្សមជ្ឈមណ្ឌល

V. **ដំណើកនាំមេរៀន៖**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| – ត្រួតពិនិត្យអវត្តមានអនាមយ័ និងសណ្តាបធ្នាប់ | **១. លំនឹងថ្នាក់** | – តំណាងសិស្សរាយការណ៍ ពីចំនួនអវត្តមាន |
| – សួរសិស្ស រូបមន្ត៖ $P(A)=?$ $C(p,n)=?$ $A(m,n)=?$ | **២. រំលឹក** $P(A)=\dfrac{n(A)}{n(S)}$ $C(p,n)=\dfrac{n!}{(m-p)!p!}$ $A(m,n)=\dfrac{n!}{(n-m)!}$ | សិស្សឆ្លើយ $P(A)=\dfrac{n(A)}{n(S)}$ $A(m,n)=\dfrac{n!}{(n-m)!}$ $C(p,n)=\dfrac{n!}{(m-p)!p!}$ |
| – កត់ចំណងជើងមេរៀន រួចដាក់ឧទាហរណ៍ | **៣.មេរៀនប្រចាំថ្ងៃ៖** «**ប្រូបាបមានលក្ខណ្ឌ័**» **១.ប្រូបាបមានលក្ខណ៍៖** ឧទាហរណ៍៖ ក្នុងចំណោមសិស្ស២០០នាក់ ដែល រៀនចប់វិទ្យាល័យមួយមានស្រី ៩០ នាក់ និងប្រុស ១១០នាក់ ក្នុងនោះមានស្រី ២៧នាក់ប៉ុណ្ណោះ បន្តការសិក្សា។ ឯសិស្សប្រុសមានតែ ៦៦នាក់ ដែលបន្តការសិក្សា។ គេចង់រើសសិស្សម្នាក់។ រកប្រូបាប | – សិស្សកត់ |

ក. ជួបសិស្សស្រី

គ. ជួបសិស្សស្រីដែលបន្តការសិក្សា

ឃ.ជួបសិស្សប្រុសដែលបន្តការ
សិក្សា

ង. ជួបសិស្សបន្តការសិស្សា

ច. ជួបសិស្សបន្តការសិស្សាដោយដឹង
មុនថាជាសិស្សស្រី

ឆ. ជួបសិស្សបន្តការសិស្សាដោយដឹង
មុនថាជាសិស្សបន្តការសិក្សា

តារាងទិន្នន័យ

| ភេទ / ការសិក្សា | ស្រី | ប្រុស | សរុប |
|---|---|---|---|
| បន្តការសិក្សា | ២៧ | ៦៦ | ៩៣ |
| មិនសិក្សា | ៦៣ | ៤៤ | ១០៧ |
| សរុប | ៩០ | ១១០ | ២០០ |

– អោយសិស្សតាងលំហសំណាកនិងព្រឹត្តិការណ៍ផ្សេងៗ

– អោយសិស្សគណនាប្រូបាបពី ក ទៅ ង

តាង $s$ លំហាសំណាក $n(s)=200$

តាងព្រឹតិការណ៍៖

$G$ ជួបសិស្សស្រី $\Rightarrow P(G)=90$

$B$ ជួបសិស្សប្រុស $\Rightarrow n(B)=110$

$C$ ជួបសិស្សបន្តការសិក្សា $\Rightarrow n(C)=93$

$\overline{C}$ ជួបសិស្សមិនសិក្សា $\Rightarrow n(\overline{C})=107$

ក. ប្រូបាបព្រឹត្តិការណ៍ជួបសិស្សស្រី

$$P(B)=\frac{n(G)}{n(s)}=\frac{90}{200}=0.45$$

ខ. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សប្រុស

$$P(B)=\frac{n(B)}{n(s)}=\frac{110}{200}=0.55$$

គ. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សស្រីដែលបន្តការសិក្សា

$$P(G\cap C)=\frac{n(G\cap C)}{n(s)}=\frac{27}{200}=0.135$$

ឃ. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សប្រុសដែលបន្តការសិក្សា

– សិស្សតាងលំហសំណាកដោយ $s$ និងព្រឹត្តិការណ៍ផ្សេងៗ ដោយអក្សរធំ និងទាញរកចំនួនធាតុវា

– សិស្សគណនាប្រូបាប ពី ក ទៅ ង

| | | |
|---|---|---|
| | $P(B\cap C)=\frac{n(B\cap C)}{n(s)}=\frac{66}{200}=0.33$<br>ង. ប្រូបាបនៃព្រឹត្តិការណ៍ជួបសិស្សបន្តការសិក្សា<br>$P(C)=\frac{n(C)}{n(s)}=\frac{93}{200}=0.465$ | |
| – ចំពោះសំណួរ (ច) គ្រូណែនាំសិស្សគណនា រួចបំផុសសំណួរទាញនិយមន័យប្រូបាបមានលក្ខខណ្ឌ និងណែនាំសិស្សអោយទាញជារូបមន្ត | ច. ប្រូបាបនៃព្រឹត្តិការណ៍បន្តការសិក្សា ដោយដឹងមុនថាជាសិស្សស្រី:<br>បានន័យថាសិស្សបន្តការសិក្សារើសចេញពីចំណោមសិស្សស្រី<br>ប្រូបាបវាគឺ $\frac{n(G\cap C)}{n(G)}=\frac{27}{90}=0.30$<br><u>ចំពោះ</u><br>$\frac{n(G\cap C)}{n(G)}=\frac{\frac{n(G\cap C)}{n(s)}}{\frac{n(G)}{n(s)}}=\frac{P(G\cap C)}{P(G)}$<br>$=\frac{0.135}{0.45}=0.3$<br>ប្រូបាបនេះហៅថាប្រូបាបមានលក្ខខណ្ឌនៃព្រឹត្តិការណ៍Gដោយដឹងព្រឹត្តិការណ៍G | – សិស្សសង្កេត រួចទាញរូបមន្ត<br>$P(C/G)=\frac{P(C\cap G)}{P(G)}$ |
| – អោយសិស្សប្រើរូបមន្តនេះក្នុងកការគណនាសំណួរ (ឆ)<br>- ណែនាំសិស្សអោយទាញរូបមន្តប្រូបាបមានលក្ខខណ្ឌនៃព្រឹត្តិការណ៍ $A$ ដោយដឹង $B$<br>- ដូចគ្នាដែរ<br>តើ $P(B/A)=?$ | គេសរសេរ<br>$P(C/G)$ ឬ $P_G(C)=\frac{n(G\cap C)}{n(G)}$<br>ឆ. ប្រូបាបជួបសិស្សស្រីដោយដឹងមុនថាបន្តការសិក្សា<br>$P(G/C)=\frac{p(G\cap C)}{P(C)}=\frac{0.135}{o.465}=0.29$<br>**<u>និយមន័យ</u>**<br>- ប្រូបាបមានលក្ខខណ្ឌនៃព្រឹត្តិការណ៍ $A$ ដោយដឹង $B$ គឺ<br>$P(A/B)=\frac{P(A\cap B)}{P(B)}$<br>- ដូចគ្នាដែរ $P(B/A)=\frac{P(A\cap B)}{P(B)}$<br>- យើងបាន | ឆ. ប្រូបាបជួបសិស្សស្រីដោយដឹងមុនថាបន្តការសិក្សា<br>$P(G/C)=\frac{P(G\cap C)}{P(C)}$<br>$=\frac{0.135}{0.465}$<br>$=0.29$<br>$P(A/B)=\frac{P(A\cap B)}{P(B)}$<br>$P(B/A)=\frac{P(A\cap B)}{P(A)}$<br>$P(A\cap B)$<br>$=P(A).P(B/A)$<br>$=P(B).P(A/B)$ |
| – ដាក់លំហាត់ប្រតិបត្តិអោយសិស្សធ្វើ។ | $P(A\cap B)=P(A)\times P(B/A)=P(B)\times P(A/B)$ | |

| | | |
|---|---|---|
| | **<u>ប្រតិបត្តិ</u>**<br>សិប្បកម្មមួយមានម៉ាសស៊ីន២ផលិតវត្ថុដូចគ្នា។<br>គេដឹងថាម៉ាស៊ីនទី១ផលិតបាន៤៥%ក្នុងនោះខូច៣% និងម៉ាស៊ីនទី២ផលិតបាន៥៥% ដែលក្នុងនោះខូច២%។<br>ក. តើប្រូបាបដែលមានវត្ថុខូច ដោយដឹងថាផលិតដោយម៉ាស៊ីនទី១ស្មើប៉ុន្មាន?<br>ខ. រកប្រូបាបដែលមានវត្ថុខូចក្នុងម៉ាស៊ីនទី១<br>គ. រកប្រូបាបដែលមានវត្ថុខូចក្នុងម៉ាស៊ីនទី២<br>ឃ. បើម៉ាស៊ីនទាំងពីរផលិតបានវត្ថុ១០០០ តើម៉ាស៊ីនទី១ធ្វើអោយខូចអស់ប៉ុន្មាន? ម៉ាស៊ីនទី២ធ្វើអោយខូចអស់ប៉ុន្មាន? | - តាងា $A$ ព្រឹត្តិការណ៍ជួបវត្ថុផលិតដោយម៉ាស៊ីនទី១<br>- $A'$ ព្រឹត្តិការណ៍ជួបវត្ថុផលិតដោយម៉ាស៊ីនទី២<br>- $B$ វត្ថុខូច<br>ក. $P(B/A)$<br>$=3\%=0.03$<br>ខ. $P(B/A)$<br>$=P(A)\times P(B/A)$<br>$=0.45\times 0.03$<br>$=0.0135$ |
| - សួររូបមន្ត<br>$P(A/B)=?$<br>$P(B/A)=?$<br>$P(A\cap B)=?$ | **ជំហានទី៤ ពង្រឹងពុទ្ធិ** | $P(A/B)=\dfrac{P(A\cap B)}{P(B)}$<br>$P(B/A)=\dfrac{P(B\cap A)}{P(A)}$<br>$P(A\cap B)$<br>$=P(A)\times P(B/A)$<br>$=P(A)\times P(A/B)$ |
| - អោយសិស្សកត់លេកលំហាត់ និងទំព័រ ដើម្បីធ្វើនៅផ្ទះ | **ជំហានទី៥ បណ្តាំផ្ញើ**<br>លំហាត់ ទី២ ទំព័រទី១៣១ | - សិស្សយកលំហាត់ |

# កិច្ចតែងការបង្រៀន
# ជំពូកទី៦
# មេរៀនទី១

## I. **វត្ថុបំណង៖** អោយសិស្ស

- អោយនិយមន័យព្រឹត្តិការណ៍ទាក់ទងគ្នា និងមិនទាក់ទងគ្នា ចេះរូបមន្តប្រូបាបសរុប និងប្រូបាបទ្រឹស្តីបទបៃយេសបានត្រឹមត្រូវ
- ចេះដោះស្រាយលំហាត់ដោយប្រើរូបមន្តប្រូបាបសរុប និងទ្រឹស្តីបទបៃយេស
- មានចំណូលចិត្តសិក្សាមេរៀនគណិតវិទ្យា

## II. **ខ្លឹមសារមេរៀន៖**

២. ព្រឹត្តិការណ៍ទាក់ទងគ្នា និងមិនទាក់ទងគ្នា

៣. រូបមន្តប្រូបាបសរុប

## III. **សម្ភារៈឧបទេស៖**

- ស.សទំព័រទី១២៣→១២៩ និងសៀវភៅគ្រូទំព័រ
- បន្ទាត់

## V. **ដំណើរនាំមេរៀន៖**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| - គ្រូតពិនិត្យ អវត្តមាន អនាម័យ និងសណ្តាប់ធ្នាប់ | ជំហានទី១ លំនឹងថ្នាក់ | - ប្រធានថ្នាក់រាយការណ៍ពីចំនួនអវត្តមាន |
| - សួររូបមន្តប្រូបាបមានលក្ខខណ្ឌ | ជំហានទី២ រំលឹក<br>$P(A/B)=\dfrac{P(A\cap B)}{P(B)}$<br>$P(B/A)=\dfrac{P(A\cap B)}{P(A)}$<br>$P(A\cap B)=P(A)\times P(B/A)$<br>$=P(B)\times P(A/B)$ | - សិស្សឆ្លើយ |
| - គ្រូណែនាំប្រាប់សិស្សពីព្រឹត្តិការណ៍ទាក់ទងគ្នានិងមិនទាក់ទងគ្នា | ជំហានទី៣ មេរៀនថ្មី<br><u>មេរៀនទី១</u> « <u>**ប្រូបាបមានលក្ខខណ្ឌ**</u>»<br>ខ. <u>ព្រឹត្តិការណ៍ទាក់ទងគ្នា និងមិនទាក់ទងគ្នា</u><br>**ជាទូទៅ**<br>– $A$ និង $B$ ជាព្រឹត្តិការណ៍មិនទាក់ទងគ្នាកាលណា<br>$P(A/B)=P(A)\times P(B)$ | - សិស្សសង្កេត និងកត់ត្រា |

| | | |
|---|---|---|
| | ឬ $P(A/B)=P(A)$<br>ឬ $P(B/A)=P(B)$<br>- ទាក់ទងគ្នាកាលណា<br>$P(A\cap B)\neq P(A)\times P(B)$ | |
| - ដាក់ឧទាហរណ៍អោយសិស្សពិនិត្យដោយយកចិត្តទុកដាក់ រួចណែនាំសិស្សទាញរកចម្លើយ<br><br>– តើចំនួនករណីអាចមានប៉ុន្មាន? | ឧទាហរណ៍: ថងមួយមានប៊ូលស៣ មានលេខខុសគ្នា និងប៊ូលខ្មៅពីរមានលេខខុសគ្នា។ គេចាប់យកប៊ូលម្តងមួយៗចំនួនពីរដងដោយចៃដន្យចេញពីរថងដោយដាក់វិញ។ តាងព្រឹត្តិការណ៍<br>$A$ «ចាប់លើទី១បានប៊ូលស»<br>$B$ «ចាប់លើកទី២បានប៊ូលខ្មៅ»<br>ក. រកប្រូបាបនៃព្រឹត្តិការណ៍ $A;B$ និង $A\cap B$<br>ខ. តើព្រឹត្តិការណ៍ $A$ និង $B$ អាស្រ័យគ្នាឬទេ?<br>គ. គណនា $P(B/A)$ និង $P(A/B)$ | - សិស្សអានប្រធានលំហាត់និងសង្ខេប<br><br>- ករណីអាច $n(s)=5^2$<br><br>- ចាប់បានប៊ូលសលើទី១មាន៣របៀប |
| – ក្នុងការចាប់ប៊ូលលើកទី១បាន សមានប៉ុន្មានរបៀប? ដោយចាប់ហើយដាក់វិញនោះលើកទី២អាចចាប់បានប៉ុន្មានរបៀប?<br>តើ $n(A)=?$<br><br>- ដូចគ្នាដែរតើ $n(B)=?$<br>$n(A\cap B)=?$<br>- ដោយសិស្សរកប្រូបាបចំនុច(ក)<br><br>- អោយសិស្សគណនា $P(A)\times P(B)$ រួចប្រៀបធៀប $P(A\cap B)$ | <u>ចម្លើយ</u><br>ដោយវិញ្ញាសារចាប់ហើយដាក់វិញនោះករណីអាចជាចម្លាស់ច្រំដែលនៃ២ធាតុយកចេញពី៥ធាតុ<br>$n(s)=5^2=25$<br>$n(A)=3\times5=15$<br>$n(B)=5\times2=10$<br>$n(A\cap B)=3\times2=6$<br>ក. $P(A)=\dfrac{n(A)}{n(s)}=\dfrac{15}{25}=\dfrac{3}{5}$<br>$P(B)=\dfrac{n(B)}{n(s)}=\dfrac{10}{25}=\dfrac{2}{5}$<br>$P(A\cap B)=\dfrac{n(A\cap B)}{n(s)}=\dfrac{6}{25}$<br>ខ. តើ $A$ និង $B$ អាស្រ័យគ្នាឬទេ<br>$P(A)\times P(B)=\dfrac{3}{5}\times\dfrac{2}{5}=\dfrac{6}{25}=P(A\cap B)$<br>$\Rightarrow A$ និង $B$ ជាព្រឹត្តិការណ៍មិនអាស្រ័យគ្នាទេ | - ដោយចាប់ហើយដាក់វិញនោះលើកទី២មាន៥របៀប។<br>$\Rightarrow n(A)=3\times5$<br>(តាមគោលការណ៍ផលគុណ)<br>- $n(B)=5\times2$<br>- $n(A\cap B)=3\times2$<br>– $p(A)=\dfrac{n(A)}{n(s)}=\dfrac{15}{25}$<br>$=\dfrac{3}{5}$<br>- $P(B)=\dfrac{n(B)}{n(s)}=\dfrac{10}{25}$<br>$=\dfrac{2}{5}$<br>$-P(A\cap B)=\dfrac{n(A\cap B)}{n(s)}$<br>$=\dfrac{6}{25}$<br><br>- $P(A)\times P(B)$<br>$=P(A\cap B)$<br>$\Rightarrow A$ និង $B$ |

<table>
<tr>
<td>
- អោយសិស្សពិនិត្យមើលលក្ខខណ្ឌទី២ និងទី៣នៃព្រឹត្តិការណ៍មិនទាក់ទងគ្នា<br><br>
– ពន្យល់ណែនាំសិស្សរហូតទាញបានរូបមន្តប្រូបាបសរុប និងទ្រឹស្តីបទបៃយេស
</td>
<td>
គ. ដោយ $A$ និង $B$ មិនទាក់ទងគ្នានោះ<br>
$P(A/B)=P(A)=\frac{3}{5}$<br>
$P(B/A)=P(B)=\frac{2}{5}$<br>
៣. រូបមន្តប្រូបាបសរុប<br>

<br>
– បើ $A_1;A_2;......;A_n$ ជាព្រឹត្តិការណ៍មិនចុះសម្រុងគ្នាពីរពីក្នុងលំហសំណាកមួយ ហើយ $B$ កើតឡើងក្នុងព្រឹត្តិការណ៍ $A_1;A_2;......;A_n$ នោះ<br>
$\mathbf{B}=(B\cap A_1)\cup(B\cap A_2)\cup.....\cup(B\cap A_n)$<br>
$\Rightarrow P(B)=P(B\cap A_1)+P(B\cap A_2)+..........$<br>
$.....+P(B\cap A_n)$<br>
$=P(A_1)\times P(B/A_1)+P(A_2)\times P(B\cap A_2)+..$<br>
$....+p(A_n)\times P(B/A_n)$<br>
$P(B)=\sum_{i=1}^{n}P(A_i)\times P(B/A_i)$<br>
(ប្រូបាបសរុប)<br><br>
$P(A_k/B)=\frac{P(A_k\cap B)}{P(B)}$<br>
$=\frac{P(B/A_k)\times P(A_k)}{\sum_{i=1}^{n}P(A_i)\times P(B/A_i)}$<br>
(ទ្រឹស្តីបទបៃយេស)<br><br>
ប្រូបាបសរុប<br>
$P(B)=\sum_{i=1}^{n}P(A_i)\times P(B/A_i)$
</td>
<td>
ជាព្រឹត្តិការណ៍មិនទាក់ទងគ្នា ឬមិនអាស្រ័យគ្នា<br>
- $P(A/B)=p(A)$<br>
– $P(B/A)=P(B)$<br><br>
- សិស្សសង្កេត និងទាញរូបមន្ត
</td>
</tr>
</table>

| | | |
|---|---|---|
| - ដាក់ឧទាហរណ៍រួចអោយសិស្សតាងព្រឹត្តិការណ៍និងសង្ខេបបំរាប់<br><br>- តើចំនុច ក សួររកអ្វី?<br><br>– ណែនាំសិស្សអោយគណនាដោយប្រើរូបមន្តប្រូបាបសរុបដោយចាត់ទុក $A;B;C$ ដូចជា $A_1;A_2;A_3$ តើយើងទាញបានដូចម្តេច? | **ទ្រឹស្តីបទបៃយេស**<br>$P(A_k/B)=\dfrac{P(B/A_k)\times P(A_k)}{\sum_{i=1}^{n}P(A_i)\times P(B/A_i)}$<br>ឧទាហរណ៍: គេមានម៉ាស៊ីន $A;B$ និង $C$ ផលិតវត្ថុដូចគ្នា។ ម៉ាស៊ីន $A$ ផលិតបាន ៥០% $B$ បាន៣០% និង $C$ បាន២០%។ គេដឹងថាវត្ថុដែលផលិតដោយម៉ាស៊ីន $A$ មានខូច៣% ម៉ាស៊ីន $B$ ខូច៣% និងម៉ាស៊ីន $C$ ខូច៤%។<br>ក. រកប្រូបាបដែលមានវត្ថុខូច<br>ខ. ក្នុងចំណោមវត្ថុខូច១០០០ តើរបស់ម៉ាស៊ីន $A;B;C$ ប៉ុន្មាន? | – តាងព្រឹត្តិការណ៍<br>$A$ ម៉ាស៊ីន $A$ ផលិតវត្ថុ<br>$B$ ម៉ាស៊ីន $B$ ផលិតវត្ថុ<br>$C$ ម៉ាស៊ីន $C$ ផលិតវត្ថុ<br>$D$ វត្ថុខូច<br>បំរាប់មាន<br>$P(A)=0.5$<br>$P(B)=0.3$<br>$P(C)=0.2)$<br>$P(D/A)=0.03$<br>$P(D/B)=0.04$<br>$P(D/C)=0.04$<br>ក. រក $P(D)$<br>$P(D)$<br>$=P(D\cap A)+P(D\cap B)$<br>$+P(D\cap C)$<br>$=P(A)\times P(D/A)$<br>$+P(B)\times P(D/B)$<br>$+P(C)\times P(D/C)$<br>$=0.5\times 0.03+0.3$<br>$\times 0.04+0.2\times 0.04$<br>$=0.035$<br>ខ.-ប្រូបាបម៉ាស៊ីន $A$ ផលិតវត្ថុខូចគឺ<br>$P(A/D)$<br>$=\dfrac{P(D/A)\times P(A)}{P(D)}$<br>$=0.428$<br><br>$\Rightarrow$ វត្ថុខូចផលិតដោយម៉ាស៊ីន $A$ គឺ<br>$1000\times 0.428=428$<br><br>– ដូចគ្នាដែរចំពោះ $B$ |

| | | |
|---|---|---|
| | | $P(B/D)$<br>$=\frac{P(D/B)\times P(B)}{P(D)}$<br>$=\frac{0.04\times 0.3}{0.035}$<br>$=0.343$<br>$\Rightarrow$វត្ថុផលិតខូចដោយម៉ាស៊ីន $B$ គឺ<br>$1000\times 0.343=343$<br>- $P(C/D)$<br>$=\frac{P(D/C)\times P(C)}{P(D)}$<br>$=\frac{0.04\times 0.2}{0.035}$<br>$=0.229$<br>$\Rightarrow$វត្ថុខូចរបស់ម៉ាស៊ីន $C$ គឺ<br>$1000\times 0.229=229$ |
| - សួររូមន្តប្រូបាបសរុប និងទ្រឹស្តីបទបៃយេស | - ជំហានទី៥ ពង្រឹងពុទ្ធិ | − $P(B)$<br>$=\sum_{i=1}^{n}P(A_i)\times P(B/A_i)$<br>− $P(A_k/B)$<br>$=\frac{P(B/A_k)\times P(A_k)}{\sum_{i=1}^{n}P(A_i)\times P(B/A_i)}$ |
| – អោយសិស្សត្រលប់ទៅផ្ទះធ្វើប្រតិបត្តិទំព័រ ១២៩ | ជំហានទី៥ បណ្តាំធ្វើប្រតិបត្តិទំព័រ ១២៩ | – សិស្សកត់ប្រតិបត្តិ |